# កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី ១៣

## កិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់អនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់ សម្រាប់ ASEM

កែសម្រួលដោយ Anita Prakash

ERIA

ASEM13 - PHNOM PENH - CAMBODIA

# កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប ( ASEM ) លើកទី ១៣

## កិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់អនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់ សម្រាប់ ASEM

កែសម្រួលដោយ Anita Prakash

ERIA

ASEM13 - PHNOM PENH - CAMBODIA

© វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ២០២១។
រក្សាសិទ្ធិគ្រប់បែបយ៉ាង។

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ ពុំមានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះអាចត្រូវបានផលិតឡើងវិញ ត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធដែលអាចទាញយកមកវិញបាន ឬ ត្រូវបានបញ្ជូននៅក្នុងទម្រង់ណាមួយ តាមវិធីណាមួយ ទោះបីជាតាមប្រព័ន្ធអេឡិចត្រូនិក ឬ មេកានិចក្តី ដោយគ្មានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ និង ដោយគ្មានការអនុញ្ញាតពី ERIA នោះទេ។

គំហើញ បំណកស្រាយ សេចក្តីសន្និដ្ឋាន និង ទស្សនៈដែលត្រូវបានបង្ហាញនៅក្នុងជំពូកផ្សេងៗគ្នា គឺជាកម្មសិទ្ធិរបស់អ្នកនិពន្ធទាំងស្រុង។ ទំនួលខុសត្រូវលើភាពត្រឹមត្រូវ និង សុចរិតភាពនៃទិន្នន័យ និង ព័ត៌មាន គឺជាទំនួលខុសត្រូវរបស់អ្នកនិពន្ធជំពូកផ្សេងៗគ្នា។ គំហើញ បំណកស្រាយ សេចក្តីសន្និដ្ឋាន ទស្សនៈ និង គំនិតដែលត្រូវបានបង្ហាញដោយអ្នកនិពន្ធជំពូកផ្សេងៗគ្នា គឺជាកម្មសិទ្ធិរបស់អ្នកនិពន្ធរូបនោះទាំងស្រុង និង មិនចាំបាច់ត្រូវឆ្លុះបញ្ចាំងអំពីទស្សនៈ និងគោលនយោបាយរបស់ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) រាជរដ្ឋាភិបាលកម្ពុជា គណៈអភិបាលរបស់ ERIA រដ្ឋាភិបាលនៃប្រទេសដែលជាសមាជិករបស់ ERIA នោះទេ។ កំហុសឆ្គងណាមួយនៅក្នុងខ្លឹមសារ ឬ ការដកស្រង់នៅក្នុងជំពូកផ្សេងៗគ្នា គឺជាទំនួលខុសត្រូវរបស់អ្នកនិពន្ធទាំងស្រុង។

ផែនទី និង រូបភាពនៅលើគម្របទំព័រតំណាងឲ្យទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប។ ផែនទី និង រូបភាពទាំងនោះមិនបានតំណាងឲ្យប្រទេសដែលជាដៃគូរបស់ ASEM នោះទេ។ ផែនទីនោះមិនត្រូវបានកំណត់មាត្រដ្ឋាននោះទេ។ គំនូសបង្ហាញ និង ព្រំដែននានាត្រូវបានចង្អុលបង្ហាញសម្រាប់តែគោលបំណងនៃការសិក្សាតែប៉ុណ្ណោះ និង ពុំមានបំណងតំណាងឲ្យព្រំដែនជាតិ/អន្តរជាតិរបស់ប្រទេស ឬ ក្រុមប្រទេសណាមួយនោះទេ។

ខ្លឹមសារនៅក្នុងការបោះពុម្ពផ្សាយនេះអាចត្រូវបានដកស្រង់ ឬ បោះពុម្ពឡើងវិញដោយមានការទទួលស្គាល់ និង ការដកស្រង់យ៉ាងត្រឹមត្រូវ។

ក្នុងករណីមានភាពខុសគ្នា ឬ អសង្គតភាព រវាងសំណៅជាភាសាអង់គ្លេស និង ការបកប្រែជាភាសាខ្មែរ ត្រូវយកសំណៅដើមជាភាសាអង់គ្លេសជាគោល។ ដូច្នេះ អត្ថន័យ និងស្មារតីនៃសំណៅជាភាសាអង់គ្លេស ត្រូវយកមកប្រើប្រាស់ដើម្បីបកស្រាយអត្ថបទ និង រូបភាពឱ្យបានត្រឹមត្រូវ។

គម្របសៀវភៅ និង សៀវភៅត្រូវបានរចនាដោយ Ranti Amelia និង Fadriani Trianingsih

បណ្ណាល័យជាតិឥណ្ឌូនេស៊ី ទិន្នន័យត្រៀមសម្រាប់ការបោះពុម្ពផ្សាយ
ISBN៖ ៩៧៨-៦០២-៥៤៦០-២៦-៥

# សារលិខិត

## ឯ.ឧ. ប្រាក់ សុខុន

ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
រាជរដ្ឋាភិបាលកម្ពុជា



កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) ត្រូវបានរៀបចំឡើងជាពិសេស ដើម្បីពង្រឹងទំនាក់ទំនងអន្តរតំបន់។ អាស៊ី និង អឺរ៉ុបត្រូវការទាំងការពឹងពាក់គ្នា និង ការភ្ជាប់ទំនាក់ទំនងទៅវិញទៅមក។ ដៃគូទាំងពីរកំពុងតែស្ថិតនៅក្នុងកាលៈទេសៈមួយដែលឱកាស និង បញ្ហាប្រឈមកើតឡើងទូទៅជាងមុន។

កិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM ១៣) គឺជាព្រឹត្តិការណ៍ ដ៏សំខាន់មួយនៅក្នុងរយៈពេល២៥ឆ្នាំនៃអត្ថិភាពរបស់ខ្លួន ខណៈដែលប្រទេសជាដៃគូបានត្រៀមខ្លួនរួចជាស្រេចក្នុងការនាំយកភាពជោគជ័យផ្នែកសេដ្ឋកិច្ច នយោបាយ និង សង្គមវប្បធម៌កើតចេញពីវេទិកានេះ ទៅក្នុងផែនការគោលនៃកិច្ចសហប្រតិបត្តិការ និង ការភ្ជាប់ទំនាក់ទំនងរវាងអាស៊ី និងអឺរ៉ុប ដែលត្រូវបានតម្រង់ទិសសម្រាប់ពេលអនាគត។ ផលប៉ះពាល់នៃជំងឺរាតត្បាតសកល កូវីដ-១៩ បានកើតឡើងនៅគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។ ទ្វីបអាស៊ី និង អឺរ៉ុបបាន និង កំពុងទប់ទល់ទៅនឹងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និង សង្គមនៃជំងឺរាតត្បាតសកលនេះ ដោយភាពអត់ធ្មត់ និង សេចក្ដីក្លាហាន។ ការចាកចេញពីជំងឺរាតត្បាតសកលនេះ នឹងក្លាយទៅជាដំណើរការដែលចំណាយពេលយូរនិងពិបាកមួយ។ ដូច្នេះ ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ ASEM ១៣ នៅក្នុងប្រទេសកម្ពុជា ពិតជាមានសារសំខាន់ខ្លាំងណាស់។ ក្នុងនាមជាប្រធានកិច្ចប្រជុំ ASEM ១៣ កម្ពុជាបាននាំមកនូវមាគ៌ាកំណើនប្រកបដោយបរិយាប័ន្ន និង វិបុលភាព សម្រាប់តំបន់អាស៊ី-អឺរ៉ុប តាមរយៈកិច្ចសហប្រតិបត្តិការពហុភាគី និង ការអភិវឌ្ឍប្រកបដោយចីរភាព។

ASEM មានការប្ដេជ្ញាចិត្តដ៏រឹងមាំក្នុងការកសាងសហគមន៍ ASEM ដែលមានទំនាក់ទំនងយ៉ាងស្អិតរមួត មានលក្ខណៈប្រកួតប្រជែង មានភាពធន់ និងមានចីរភាព សម្រាប់ប្រជាជនអាស៊ី និង អឺរ៉ុប។ ទោះបីជាយ៉ាងណាក៏ដោយ ពិភពលោកដែល ASEM ត្រូវដោះស្រាយនៅក្នុងទសវត្សរ៍បន្ទាប់ នឹងមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីពិភពលោកដែល ASEM បានអនុវត្តកិច្ចសហប្រតិបត្តិការ និង សកម្មភាពភ្ជាប់ទំនាក់ទំនងនាពេលកន្លងមក។ មានការវិវឌ្ឍជាច្រើនពាក់ព័ន្ធនឹងការភ្ជាប់ទំនាក់ទំនងនានា ការប្រែប្រួលនៃពហុភាគីនិយម និង អភិបាលកិច្ចពិភពលោក

ការផ្លាស់ប្ដូរផ្នែកឌីជីថល និង បដិវត្តន៍ផ្នែកឧស្សាហកម្មជំនាន់ទីបួន។ កំណើននៃ តួនាទីរបស់ស្ត្រី និង យុវជននៅក្នុងវិស័យសេដ្ឋកិច្ច គឺជាបញ្ហាដែលត្រូវតែមានអន្តរទំនាក់ទំនងជាមួយវឌ្ឍនភាពផ្នែកសេដ្ឋកិច្ច និង សង្គម។ ទ្វីបអាស៊ី និង អឺរ៉ុប ក៏នឹងត្រូវគ្រប់គ្រងហានិភ័យនៃការប្រែប្រួលផ្នែកសេដ្ឋកិច្ចបច្ចេកវិទ្យា សុខាភិបាលសាធារណៈ និង សង្គមផងដែរ។ ផ្នត់គំនិត និងអភិក្រមដែលតម្រង់ទិសសម្រាប់ពេលអនាគត និង សមត្ថភាពនៅក្នុងការដោះស្រាយការប្រែប្រួល និងការរំខាននានា នឹងធ្វើឲ្យ ASEM ត្រៀមខ្លួនបានកាន់តែល្អប្រសើរឡើងសម្រាប់ពេលអនាគត និងធានាបាននូវចីរភាពនៃសមិទ្ធផលដែល ASEM សម្រេចបាននាទសវត្សរ៍កន្លងមក។

ខ្ញុំសូមអបអរសាទរដល់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) ដែលបានបង្កើតការសិក្សាគ្រប់ជ្រុងជ្រោយនេះឡើង សម្រាប់កិច្ចប្រជុំកំពូល ASEM លើកទី ១៣ នៅប្រទេសកម្ពុជា។ ការសិក្សានេះបាននាំមកនូវការត្រៀមខ្លួនជាស្រេចក្នុងតំបន់របស់ ASEM ដើម្បីឆ្ពោះទៅចាប់យកឱកាស និងដោះស្រាយបញ្ហាប្រឈមរួមគ្នានៅក្នុងវិស័យអាទិភាព របស់ ASEM ព្រមទាំងបានស្នើឡើងនូវវិធីសាស្ត្រនានាក្នុងការប្រើប្រាស់យន្តការនៃកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់របស់ ASEM ដើម្បីសម្រេចបាននូវតំបន់ ASEM ដែលមានបរិយាប័ន្នមានចីរភាព និងត្រៀមខ្លួនជាស្រេចសម្រាប់ អនាគត។ ខ្ញុំសង្ឃឹមថា ប្រទេសដៃគូរបស់ ASEM នឹងប្រើប្រាស់ការសិក្សានេះឱ្យបានទូលំទូលាយ ដើម្បីតភ្ជាប់ឡើងវិញនៃវិស័យសេដ្ឋកិច្ច និង សង្គមនៅក្នុងពិភពលោកក្រោយពេលមានជំងឺរាតត្បាតសកល និង នៅក្នុងការរួបរួមគ្នារវាងទ្វីបអាស៊ី និង អឺរ៉ុប សំដៅឆ្ពោះទៅកាន់អនាគតដែលមានការតភ្ជាប់ មានចីរភាព និង មានបរិយាប័ន្ន។

**ឯ.ឧ. ប្រាក់ សុខុន**

ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
រាជរដ្ឋាភិបាលកម្ពុជា

# បុព្វកថា



វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) មានមោទនភាពដែលបានចូលរួមសហការ នៅក្នុង កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) និង កិច្ចប្រជុំរដ្ឋមន្ត្រី ASEM នានា។

ERIA បាន និង កំពុងផ្តល់ការគាំទ្រដល់ ASEM តាមរយៈការស្រាវជ្រាវ និង ការងារនៃគោលនយោបាយរបស់ខ្លួនស្តីពីការតភ្ជាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ភាពរីកចម្រើនដែលប្រកបដោយបរិយាប័ន្ន ចាប់តាំងពីឆ្នាំ២០១៦ មកម្ល៉េះ នៅពេលដែល ERIA បានផ្តល់ការគាំទ្រដល់រដ្ឋាភិបាលនៃប្រទេសម៉ុងហ្គោលី តាមរយៈសំណេរ "ចក្ខុវិស័យនៃការតភ្ជាប់អាស៊ី-អឺរ៉ុប ឆ្នាំ២០២៥" ដែលត្រូវបានបង្ហាញទៅកាន់ថ្នាក់ដឹកនាំរបស់ ASEM នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី១១ នៅក្នុងឆ្នាំ២០១៦។ ចាប់តាំងពីពេលនោះមក ERIA បានផ្តល់ការគាំទ្រដល់កិច្ចការនានារបស់ក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្តីពីការតភ្ជាប់ (APGC) នៅក្នុងការអភិវឌ្ឍវិស័យអាទិភាពនានានៃកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់។

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងនៅក្នុងការចែករំលែកការសិក្សាស្តីពី "កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី ១៣៖ កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីអនាគតដែលមានភាពធន់មានចីរភាពនិងផ្អែកលើច្បាប់សម្រាប់ASEM"។ការសិក្សានេះបានរួមបញ្ចូលគ្នារវាងចក្ខុវិស័យរបស់ប្រទេសកម្ពុជាចំពោះ ASEM និង សកម្មភាពជាអាទិភាព ដែលចាំបាច់ត្រូវអនុវត្តនៅក្នុងវិស័យអាទិភាពរបស់ ASEM ដើម្បីគាំទ្រដល់បណ្តាប្រទេសដៃគូ ASEM ក្នុងការរួមគ្នាដោះស្រាយបញ្ហាប្រឈមសកល និងតំបន់នានា។

ខ្ញុំមានទំនុកចិត្តថា ការសិក្សានេះនឹងបង្ហាញទិសដៅឆ្ពោះទៅកាន់អនាគតនៃទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុប និង ធ្វើឲ្យប្រជាជននៅក្នុងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុបមានទំនាក់ទំនងកាន់តែជិតស្និទ្ធថែមទៀត។ ERIA នឹងបន្តប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងជំនាញ តាមលទ្ធភាពដែលអាចធ្វើបានទាំងអស់ដែលប្រហែលជាចាំបាច់នៅក្នុងការធ្វើឲ្យ ASEM ក្លាយជាវេទិកាមួយប្រកបដោយការឆ្លើយតប និងភាពច្នៃប្រឌិតសម្រាប់ការតភ្ជាប់រវាងអាស៊ី និងអឺរ៉ុប។

ខ្ញុំជឿជាក់ថា សៀវភៅនេះនឹងរួមចំណែកដល់ភាពជោគជ័យរបស់កិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM ១៣) នៅក្នុងប្រទេសកម្ពុជា។



**សាស្ត្រាចារ្យ Hidetoshi Nishimura**

ប្រធានវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា

# មាតិកា

**សេចក្តីផ្តើម** ........ IX

Anita Prakash

**I ការតភ្ជាប់ផ្នែកនយោបាយ និងរូបវន្ត** ........ 1

1. អាស៊ីនិងអឺរ៉ុប នៅក្នុងពិភពលោកដែលកំពុងប្រែប្រួល ........ 3
ធានាបាននូវអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់
ANITA PRAKASH

2. ផែនការការតភ្ជាប់សម្រាប់អាស៊ី និង អឺរ៉ុប ........ 27
ទំនិញសាធារណៈ និង កំណើនជាសមូហភាព
ANITA PRAKASH
FRANS-PAUL VAN DER PUTTEN

**II កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ........ 61

3. កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុបស្តីពីការសម្រួលពាណិជ្ជកម្ម ........ 63
RASHESH SHRESTHA

4. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប និងប្រទេសវៀតណាម ........ 80
ដំណើរការ ផលប៉ះពាល់ និង មេរៀនសំខាន់ៗ
THANH TRI VO

5. តួនាទីរបស់កិច្ចប្រជុំអាស៊ី - អឺរ៉ុប នៅក្នុងការលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិក ...... 105
LURONG CHEN

6. គំរូនៃកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារនៃសេដ្ឋកិច្ចឌីជីថល របស់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប . 121
ឌីជីថលនីយកម្ម និង បច្ចេកវិទ្យាថ្មីៗ
IRMA MOSQUERA VALDERRAMA

**III ការភ្ជាប់ទំនាក់ទំនង ស្ថាប័ន និង ប្រជាជន** ........ 161

7. កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប ក្នុងការកសាងសង្គមឌីជីថលប្រកបដោយបរិយាប័ន្ន .. 163
EMMANUEL C. LALLANA

8. កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុប លើបម្លាស់ទីដើម្បីស្វែងរកការងារ ការអប់រំ និង ការបណ្តុះបណ្តាល ..... 202
តើអ្វីទៅជាលទ្ធផលកើតចេញពីការផ្លាស់ប្តូរផ្អែកឌីជីថល សម្រាប់ ASEM ?
FLAVIA JURJE TRIFA

9. ការបម្លាស់ទីរបស់ប្រជាជននៅក្នុងអាស៊ាន
កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុបស្តីពីការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន ..... 224
ការតភ្ជាប់ផ្អែកឌីជីថល និង ការអប់រំ
YEO LAY HWEE

**IV ការអភិវឌ្ឍប្រកបដោយចីរភាព ..... 241**

10. កិច្ចសហប្រតិបត្តិការ ASEM លើវិស័យថាមពលស្អាត ..... 243
HAN PHOUMIN

11. ការពង្រឹងការទូតសភាដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ..... 264
CHHEANG VANNARITH

12 កិច្ចប្រជុំអាស៊ី-អឺរ៉ុប និង ចីរភាពសង្គមនៅក្នុងយុគសម័យនៃការតភ្ជាប់ប្រកបដោយភាពប្រកួតប្រជែង ..... 282
JÜRGEN RÜLAND

13. កិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ..... 295
ការគ្រប់គ្រងទឹកនៅក្នុងតំបន់ទន្លេមេគង្គ និង តំបន់ទន្លេ ដានូប
THEARITH LENG

**V សេចក្តីបញ្ចប់ ..... 309**

14. ការបោះជំហានឆ្ពោះទៅមុខ ..... 311
កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់ សម្រាប់អាស៊ី និង អឺរ៉ុប
ANITA PRAKASH
GARY R. HAWKE

# សេចក្តីផ្តើម

កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) គឺជាគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការដ៏ពិសេសមួយដែលនាំមកនូវវិសាលភាពសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន រវាងប្រទេសនានា តាមរយៈសកម្មភាពនៅថ្នាក់តំបន់ និង ថ្នាក់អនុតំបន់។ ចាប់តាំងពីពេលដែលកិច្ចប្រជុំនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦ ASEM បាននិងកំពុងដើរតួនាទីជាវេទិកាដ៏សំខាន់មួយសម្រាប់ កិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការក្នុងការតភ្ជាប់ទំនាក់ទំនងរវាងអាស៊ី និងអឺរ៉ុប។ ASEM គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីឆ្ពោះទៅរកការដោះស្រាយតម្រូវការនៃការតភ្ជាប់កាន់តែទូលំទូលាយ ក្នុងចំណោមបណ្តាភូមិសាស្ត្រ សេដ្ឋកិច្ច និង ប្រជាជននៃទ្វីបអាស៊ី និងអឺរ៉ុប។ ASEM មានភាពទូលំទូលាយគ្រប់គ្រាន់សម្រាប់គ្របដណ្តប់លើអាទិភាពនៃការអភិវឌ្ឍនៅថ្នាក់សកល និង ថ្នាក់អន្តរទ្វីប។ ប៉ុន្តែ វាផ្តោតលើការភ្ជាប់ទំនាក់ទំនងរវាងប្រទេសដៃគូសម្រាប់ភាពជាដៃគូដើម្បីកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពការអភិវឌ្ឍជំនាញ ការអប់រំ ការអភិវឌ្ឍប្រកបដោយចីរភាព និង ការប្រែប្រួលអាកាសធាតុ។ខណៈពេលដែលស្បៃអន្ធការនៃជំងឺរាតត្បាតសកលបង្កដោយវីរុសកូរ៉ូណា (កូវីដ-១៩) កំពុងជះឥទ្ធិពលយ៉ាងខ្លាំងក្លា ទាំងនៅទ្វីបអឺរ៉ុប និង ទ្វីបអាស៊ី ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣របស់កម្ពុជា ពិតជាមានសារសំខាន់កាន់តែខ្លាំង ព្រោះវាប្រមើលឃើញនូវមាគ៌ាកំណើនប្រកបដោយបរិយាប័ន្ន និង វិបុលភាពមួយ សម្រាប់តំបន់អាស៊ី-អឺរ៉ុប តាមរយៈកិច្ចសហប្រតិបត្តិការពហុភាគី និង ការអភិវឌ្ឍប្រកបដោយចីរភាព។ កិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM ១៣) មានបេសកកម្មធ្វើការកំណត់មាគ៌ានាពេលអនាគតសម្រាប់ ASEM ដោយផ្អែកលើគោលការណ៍នៃភាពរីកចម្រើនទៅវិញទៅមក ការអភិវឌ្ឍប្រកបដោយចីរភាព និង ពហុភាគីនិយមដែលផ្អែកលើច្បាប់។

ASEM បានលើកកម្ពស់សមាហរណកម្មរបស់ទ្វីបអាស៊ីជាមួយទ្វីបអឺរ៉ុប តាមរយៈការតភ្ជាប់ផ្នែករូបវ័ន្ត ផ្នែកស្ថាប័ន និង សង្គម ដែលនៅក្នុងនោះ ពហុភាគីនិយម និង ការគាំទ្រចំពោះអភិបាលកិច្ចពិភពលោក បានដើរតួនាទីយ៉ាងសំខាន់។ ផ្នែកខុសៗគ្នានៃសៀវភៅនេះផ្តល់មាគ៌ាសម្រាប់ចក្ខុវិស័យរបស់ASEMអំពីទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុបដែលមានបរិយាប័ន្ននិងវិបុលភាព។ ផែនការថ្នាក់តំបន់ និង អនុតំបន់សម្រាប់ការតភ្ជាប់ផ្នែករូបវ័ន្ត ការធ្វើជំនួញ និង ការវិនិយោគទុន ការតភ្ជាប់ផ្នែកស្ថាប័ន និង និយ័តកម្ម សមត្ថភាព និង ជំនាញ ដែលខ្លាំងក្លាជាងមុន អភិក្រមរួមមួយដើម្បីឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និង ការចូលរួមនៅក្នុងសេដ្ឋកិច្ចឌីជីថល គឺជាសសរស្តម្ភសំខាន់ៗនៅលើមាគ៌ានេះ។ មូលដ្ឋានគ្រឹះផ្នែកទ្រឹស្តីសម្រាប់គ្រប់

ជំពូកទាំងអស់ ផ្អែកយ៉ាងខ្លាំងលើបទពិសោធន៍នៅតាមប្រទេសជាក់ស្តែង និង/ឬ នៅក្នុងតំបន់ក្នុងវិស័យផ្សេងៗគ្នា។ ចាប់តាំងពីឆ្នាំ២០១៦ មក វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានព្យាយាមបញ្ចូលអភិក្រមរួម និង អភិក្រមនៃការប្រមូលផ្តុំកម្លាំងនៅក្នុងកិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប តាមរយៈការសិក្សាជាបន្តបន្ទាប់របស់ខ្លួនស្តីពីការតភ្ជាប់របស់ ASEM។ ការសិក្សានេះបានចាប់យកបទពិសោធន៍ដ៏សម្បូរបែបនៅក្នុងចំណោមប្រទេសជាដៃគូ ដែលមានផលិតភាព និង អាច អនុវត្តឡើងវិញបាន និង បង្ហាញបទពិសោធន៍ទាំងនោះទៅកាន់ប្រធាន ASEM ១៣ ដើម្បីធ្វើការពង្រឹង និង ពង្រីកទិសដៅរបស់ប្រធានចំពោះ ASEM។ សៀវភៅនេះបំពេញគោលបំណងនេះ និង បង្កើតមាគ៌ាសម្រាប់ធ្វើឲ្យ ASEM ក្លាយជាវេទិកាពហុភាគីមួយដែលមានភាពសកម្ម មានប្រសិទ្ធផល និងឥទ្ធិពល សម្រាប់កិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់រវាងអាស៊ី និង អឺរ៉ុប។

ផ្នែកទី ១ ពណ៌នាអំពីទស្សនាទាន លក្ខណៈពិសេស និង ផែនការដែលពាក់ព័ន្ធនឹងការភ្ជាប់ទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុប។ ក្រៅពីគ្របដណ្តប់លើសារសំខាន់របស់ ASEM នៅក្នុងនាមជាដៃគូនៃកិច្ចសហប្រតិបត្តិការពហុភាគីហើយនោះ ជំពូកទាំងពីរបង្ហាញពីទិដ្ឋភាពផ្នែករូបវ័ន្ត ផ្នែកស្ថាប័ន និង ការអភិវឌ្ឍធនធានមនុស្ស នៃការភ្ជាប់ទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុប។ ស្របពេលដែលជំពូកទី ១ គ្របដណ្តប់លើលក្ខណៈពហុទិដ្ឋភាពនៃកិច្ចប្រជុំ ASEM និង វិសាលភាពដែលបានបន្តជាថ្មីសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងដំណាក់កាលកំណើនក្រោយជំងឺកូវីដ-១៩ ជំពូកទី ២ គូសបញ្ជាក់អំពីគោលនយោបាយនៃការតភ្ជាប់ និង ផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលតំណាងឲ្យការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប នៅក្នុងដំណើរការនៃការអភិវឌ្ឍ។ ជំពូកទាំងពីរគឺជាក្របខណ្ឌប្រតិបត្តិមួយសម្រាប់អនុវត្តការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប។

ផ្នែកទី ២ ពណ៌នាអំពីទំនាក់ទំនងដែលសំខាន់បំផុត និង ទំនាក់ទំនងជាក់ស្តែងរវាងអាស៊ី-អឺរ៉ុប រួមមាន ពាណិជ្ជកម្ម ការវិនិយោគទុន និង សេដ្ឋកិច្ច។ ការសម្រួលពាណិជ្ជកម្ម និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គឺជាសសរស្តម្ភដែលទ្វីបអាស៊ី និង អឺរ៉ុបបានមើលឃើញដោយផ្ទាល់នូវភាពរីកចម្រើនយ៉ាងខ្លាំងនៅក្នុងការធ្វើពាណិជ្ជកម្មទំនិញ និង ការវិនិយោគផ្ទាល់ពីបរទេស (FDI)។ ដោយសារតែសសរស្តម្ភនៃភាពរីកចម្រើនទាំងពីរតម្រូវឲ្យមានកំណែទម្រង់នីតិវិធីនៅក្នុងព្រំដែន និង នៅក្រៅព្រំដែនរបស់ប្រទេស និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និង មជ្ឈដ្ឋាននៃការធ្វើនិយ័តកម្មនោះ ជំពូកដំបូងទាំងពីរនៅក្នុងផ្នែកនេះ គូសបញ្ជាក់អំពីបទពិសោធន៍ប្រទេសដើម្បីបង្ហាញពីរបៀបដែលការសម្រួលពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចជួយកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្មឱ្យនៅកម្រិតអប្បបរមា និងជំរុញឱ្យមានលំហូរពាណិជ្ជកម្ម

កាន់តែច្រើនឡើងថែមទៀត ហើយក៏អាចជាប្រភពមួយនៃឧត្តមភាពប្រកួតប្រជែងនៅក្នុងមជ្ឈដ្ឋានដែលកំពុងប្រែប្រួល ផងដែរ។

ជាពិសេស ផ្នែកទី ២ បង្ហាញអំពីការត្រៀមខ្លួនជាស្រេចរបស់តំបន់អាស៊ី-អឺរ៉ុបសម្រាប់សេដ្ឋកិច្ចឌីជីថល ដោយផ្អែកលើទស្សនវិស័យផ្នែកស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និង គោលនយោបាយនៃការធ្វើនិយ័តកម្ម។ សេដ្ឋកិច្ចឌីជីថលមានភាពអចិន្ត្រៃយ៍។ ប្រទេសជាដៃគូ ASEM មានឱកាសនៅក្នុង ASEM ដែលអាចក្លាយជាវេទិកានៃកិច្ចសហប្រតិបត្តិការសម្រាប់ការចូលរួមកាន់តែទូលំទូលាយនៅក្នុងខ្សែចង្វាក់តម្លៃសកលនៃសេដ្ឋកិច្ចឌីជីថល និង ជំរុញឲ្យមានសង្គមឌីជីថលដែលប្រកបដោយបរិយាប័ន្ន។

ផ្នែកទី ៣ ផ្តោតលើបញ្ហាការអភិវឌ្ឍមនុស្ស ដូចជា យេនឌ័រ យុវជន និង ការប្រមូលផ្តុំកម្លាំងពលកម្ម។ កម្ពុជាក្នុងនាមជាប្រធាននៃកិច្ចប្រជុំកំពូលនេះ បានផ្តោតជាពិសេសលើការអភិវឌ្ឍប្រកបដោយបរិយាប័ន្ននៅក្នុងតំបន់ ASEM។ ផ្នែកនេះ បង្ហាញពីការចូលរួមកាន់តែច្រើនរបស់ស្ត្រី និងយុវជននៅក្នុងសេដ្ឋកិច្ច ASEM និងការបញ្ជ្រាបបញ្ហានានាពាក់ព័ន្ធនឹងការប្រមូលផ្តុំកម្លាំងពលកម្ម ផងដែរ។

ផ្នែកទី ៤ គ្របដណ្តប់លើបទពិសោធន៍នៃការអភិវឌ្ឍប្រកបដោយចីរភាពនៅទ្វីបអាស៊ី និង អឺរ៉ុប ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើផ្នែកថាមពល ការគ្រប់គ្រងទឹក និង ចីរភាពនៃផែនការតភ្ជាប់។

ផ្នែកទី ៥ ទាញសេចក្តីសន្និដ្ឋានអំពីការសិក្សានេះ និង គូសបញ្ជាក់អំពីតួនាទីរបស់ ASEM នៅក្នុងការគាំទ្រសណ្តាប់ធ្នាប់ពហុភាគី និង ដំណើរឆ្ពោះទៅសម្រេចបាននូវតំបន់អាស៊ី-អឺរ៉ុបប្រកបដោយចីរភាព បរិយាប័ន្ន និងវិបុលភាព។ វាបញ្ជាក់អំពីតួនាទី និងទស្សនវិស័យរបស់កម្ពុជាក្នុងនាមជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូល ASEM13 ក៏ដូចជាតម្រូវការដាក់បញ្ចូលចំណុចទាំងនោះទៅក្នុងកិច្ចប្រជុំកំពូល ASEM14 នៅអឺរ៉ុប ផងដែរ។

ការសិក្សានេះបានរួមបញ្ចូលអ្នកប្រាជ្ញ និង អ្នកប្រកបវិជ្ជាជីវៈទាំងឡាយមកពីទ្វីបអាស៊ី និង អឺរ៉ុប ដែលបានរួមបញ្ចូលចំណេះដឹងដែលទទួលបានពីការសិក្សា និង ការអនុវត្តជាក់ស្តែងរបស់ពួកគេនៅក្នុងជំពូកផ្សេងៗគ្នារបស់ពួកគេ ហើយ ERIA មានមោទនភាពនៅក្នុងការប្រមូលផ្តុំសំណេររបស់ពួកគេដោយមានការគាំទ្រពីការសិក្សានេះ។ ការសិក្សានេះសូមថ្លែងអំណរគុណជាពិសេស ចំពោះឥទ្ធិពលនៃកិច្ចការស្រាវជ្រាវដំបូងគេបង្អស់របស់សាស្ត្រាចារ្យ FUKUNARI KIMURA ប្រធានផ្នែកសេដ្ឋកិច្ចនៃ ERIA អំពីវិស័យនានានៃការតភ្ជាប់ និង សមាហរណកម្ម

សេដ្ឋកិច្ចនៅអាស៊ាន និង អាស៊ីបូព៌ា។ ការសិក្សានេះឆ្លុះបញ្ចាំងអំពីទំនុកចិត្តលើសមត្ថភាពក្នុងការស្រាវជ្រាវរបស់ ERIA ដែលបានត្រួសត្រាយការស្រាវជ្រាវជាច្រើនស្តីពីសហគមន៍អាស៊ាន តំបន់អាស៊ីបូព៌ា និង ការតភ្ជាប់ ដែលជាគំរូនៃការអភិវឌ្ឍនៅអាស៊ី និង រវាងអាស៊ី-អឺរ៉ុប និង អាស៊ី-អាហ្វ្រិក។

ERIA សូមថ្លែងអំណរគុណចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីនៃកិច្ចប្រជុំកំពូលASEM13 នេះ។ ERIA សូមថ្លែងអំណរគុណដល់ឯកឧត្តមប្រាក់សុខុនឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានចូលរួមជាសារលិខិតសម្រាប់កិច្ចប្រជុំកំពូល ASEM13 តាមរយៈសៀវភៅនេះ។ ERIA សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ឱកាស ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ជូនឲ្យធ្វើការរៀបចំ និង ធ្វើបទបង្ហាញអំពីការសិក្សាគ្រប់ជ្រុងជ្រោយនេះ ទៅកាន់ថ្នាក់ដឹកនាំ និង ប្រមុខរដ្ឋាភិបាលនៃប្រទេសដៃគូ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី ១៣។ ERIA សូមថ្លែងអំណរគុណចំពោះការរួមចំណែក និង ការគាំទ្រដ៏ខ្លាំងក្លារបស់ ឯកឧត្តមបណ្ឌិត សុខ ស៊ីផាន់ណា ទីប្រឹក្សាជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា និងជាឧត្តមមន្ត្រីកម្ពុជាទទួលបន្ទុកកិច្ចប្រជុំ ASEM ក្នុងការតម្រង់ទិសសៀវភៅនេះ ចាប់តាំងពីការចាប់ផ្តើម ការអភិវឌ្ឍ និង ការបញ្ចប់សៀវភៅនេះ។

ការសិក្សានេះបន្តជាមួយនឹងតួនាទីដ៏ពិសេសរបស់ ERIA នៅក្នុងការផ្តល់ការគាំទ្រផ្នែកការសិក្សាស្រាវជ្រាវ និង សមត្ថភាពដល់ដំណើរការរបស់ ASEM និង ប្រធាន ASEM។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅនេះនឹងផ្តល់គំនិតនិងទិសដៅនៃគោលនយោបាយសំខាន់ៗដល់កិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM ១៣) និងកិច្ចប្រជុំពាក់ព័ន្ធនានានៅកម្ពុជា។

ERIA សូមឆ្លៀតឱកាសនេះ ជូនពរដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យទទួលបានជោគជ័យនៅក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM ១៣) នេះ។

**Anita Prakash**
ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ (IEC) ការិយាល័យប្រធាន ERIA

# I

# ការតភ្ជាប់ផ្នែកនយោបាយ និងរូបវ័ន្ត

**អាស៊ី និង អឺរ៉ុប នៅក្នុងពិភពលោកដែលមានការប្រែប្រួល៖** ធានាបាននូវអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់

ANITA PRAKASH
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

**ផែនការតភ្ជាប់សម្រាប់អាស៊ី និង អឺរ៉ុប៖** កំណើនទំនិញសាធារណៈ និង កំណើនជារួម

ANITA PRAKASH
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

FRANS-PAUL VAN DER PUTTEN*
*វិទ្យាស្ថាន Clingendael ប្រទេសហូឡង់*

1

# អាស៊ីនិងអឺរ៉ុប នៅក្នុងពិភពលោកដែលកំពុងប្រែប្រួល

## ធានាបាននូវអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់

ANITA PRAKASH

គិតត្រឹមឆ្នាំ២០២១ កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) បានដំណើរការអស់រយៈពេល ២៥ ឆ្នាំមកហើយ ដែលក្នុងអំឡុងនេះ ទំនាក់ទំនងអាស៊ី-អឺរ៉ុប បានជួបប្រទះនូវការផ្លាស់ប្តូរជាសកលយ៉ាងឆាប់រហ័ស។ គោលការណ៍ស្នូលរបស់ ASEM ពោលគឺ ការសន្ទនា ភាពមិនផ្លូវការ ភាពអាចបត់បែនបាន សមភាព និង ការគោរពគ្នាទៅវិញទៅមក ស្មារតីនៃការព្រមព្រៀងជាឯកច្ឆន្ទ និង ការផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក បានជួយឲ្យអាស៊ី-អឺរ៉ុបមានភាពរីកចម្រើនជាបន្តបន្ទាប់ នៅក្នុងសម័យកាលដែលមានទាំងវិបុលភាព និង ហេតុការណ៍អាក្រក់ៗកើតឡើងស្របពេលគ្នា។ ASEM តំណាងឲ្យផ្នែកដ៏ធំមួយនៃសហគមន៍សកល។ ចាប់តាំងពីពេលចាប់កំណើតរបស់ខ្លួននៅក្នុងឆ្នាំ១៩៩៦ ASEM បានដើរតួនាទីដ៏សំខាន់នៅក្នុងនាមជាវេទិកាមួយសម្រាប់ការសន្ទនា និង កិច្ចសហប្រតិបត្តិការ ក្នុងការតភ្ជាប់គ្នារវាងអាស៊ី និង អឺរ៉ុប។ ASEM ត្រូវបានរៀបចំឱ្យមានដំណើរការជាពិសេសដើម្បីជំរុញទំនាក់ទំនងអន្តរតំបន់។ នៅក្នុងរយៈពេល ២៤ ឆ្នាំកន្លងមក ដំណើរការរបស់ ASEM បញ្ជាក់ឱ្យឃើញពីភាពស្វាហាប់ និង ការជាប់ពាក់ព័ន្ធរបស់ខ្លួន តាមរយៈកំណើនសមាជិកភាពជាបន្តបន្ទាប់ និង បានពង្រឹងកិច្ចសហប្រតិបត្តិការរវាងតំបន់ទាំងពីរដើម្បីអត្ថប្រយោជន៍របស់ប្រជាជននៅអាស៊ី និងអឺរ៉ុប។ បច្ចុប្បន្នកិច្ចប្រជុំនេះមានប្រទេសជាដៃគូចំនួន ៥១ ប្រទេស (ប្រទេសនៅអឺរ៉ុបចំនួន ៣០ និង ប្រទេសនៅទ្វីបអាស៊ីចំនួន ២១) និង ដៃគូស្ថាប័នចំនួនពីរ៖ សហភាពអឺរ៉ុប (EU) និង លេខាធិការដ្ឋាននៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ ដោយរួមបញ្ចូលដៃគូទាំងអស់ កិច្ចប្រជុំ ASEM តំណាងឲ្យប្រមាណ ៦២% នៃប្រជាជននៅលើសកលលោក ៥៥% នៃពាណិជ្ជកម្មសកល ៦៥% នៃសេដ្ឋកិច្ចសកលលោក និង ៧៥%នៃវិស័យទេសចរណ៍នៅលើសកលលោក។ នៅក្នុងនាមជាវេទិកាពហុភាគីដ៏សំខាន់មួយ នៅក្នុងការភ្ជាប់ទំនាក់ទំនងរវាងអាស៊ី និង អឺរ៉ុប ASEM តំណាងឲ្យកម្លាំងជាសកលដ៏សំខាន់មួយ។ វាបង្ហាញពីចំណុចខ្លាំងរួមរបស់ទ្វីបអាស៊ី និង អឺរ៉ុប ក្នុងការបង្កើតឲ្យមានឥទ្ធិពលមួយដែល

មានអំណោយផលលើដំណើរការអភិវឌ្ឍនៅថ្នាក់តំបន់ និង ថ្នាក់សកល និងជាសម្លេងដ៏សំខាន់មួយនៅក្នុងអភិបាលកិច្ចសកល។

ទ្វីបអាស៊ី និង អឺរ៉ុបបានបង្ហាញអំពីគំរូនៃការអភិវឌ្ឍដែលមានលក្ខណៈពិសេសទៅតាមតំបន់នីមួយៗ ប៉ុន្តែ មានទស្សនៈដូចគ្នានៅក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ ទ្វីបអឺរ៉ុបគឺជាអ្នកនាំផ្លូវនៃការតភ្ជាប់ផ្ទៃក្នុងតំបន់របស់ខ្លួននៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ តាមរយៈការបង្កើតទីផ្សារតែមួយ EU បានអនុញ្ញាតឲ្យមានលំហូរនៃប្រជាជន ទំនិញ សេវាកម្ម និង មូលធនដោយសេរី។ វិធានដ៏ទូលំទូលាយរបស់ EU ដូចជា វិធានគ្រប់គ្រងជំនួយ និង វិធានលទ្ធកម្មរបស់រដ្ឋជាសមាជិក EU ជាដើម ធានាបាននូវការប្រកួតប្រជែងដែលមានភាពសុក្រឹត្យ និង មានតម្លាភាពនៅខណៈពេលដែល គោលនយោបាយរបស់ EU ធានាបាននូវកិច្ចការពារបរិស្ថាន សុវត្ថិភាពសន្តិសុខ ព្រមទាំង សិទ្ធិផ្នែកសង្គម និង សិទ្ធិរបស់បុគ្គល (គណៈកម្មការអឺរ៉ុប ឆ្នាំ២០១៨)។ គោលនយោបាយតភ្ជាប់របស់ EU មានបំណងលើកកម្ពស់ប្រសិទ្ធភាពនៅក្នុងទីផ្សារតែមួយរបស់ EU និង ពង្រឹងការតភ្ជាប់នៅកម្រិតសកល ដោយសង្កត់ធ្ងន់លើអត្ថប្រយោជន៍ និង សិទ្ធិរបស់ប្រជាជន។ ម៉្យាងវិញទៀត ទ្វីបអាស៊ីបានឆ្លងកាត់ការអភិវឌ្ឍជាច្រើនកម្រិតខុសៗគ្នានៅថ្នាក់អនុតំបន់។ អាស៊ីបូព៌ា និង អាស៊ីអាគ្នេយ៍មានភាពឈានមុខគេលើផ្នែកសមាហរណកម្មសេដ្ឋកិច្ច ដែលជាដំបូងត្រូវផ្អែកលើការវិនិយោគ និង ទីតាំងប្រតិបត្តិការ។ ការតភ្ជាប់ផ្នែកសេដ្ឋកិច្ចទាំងនេះបានបង្កើតមជ្ឈមណ្ឌលផលិតមួយ ដែលបង្កើតបានជាពាក្យ "រោងចក្ររបស់ពិភពលោក"។ ការតភ្ជាប់ផ្នែកស្ថាប័ន រវាងអាជីវកម្ម រដ្ឋាភិបាល និង ទីផ្សារ បានជួយដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់នេះ។

រួមជាមួយការតភ្ជាប់ដែលមានភាពល្អប្រសើរឡើង និង ការរីកសាយភាយនៃការវិនិយោគ គំរូនៃភាពរីកចម្រើននេះ នៅពេលនេះ ក៏បានកើតឡើងនៅអាស៊ីខាងត្បូង និង ខាងលិចផងដែរ ដែលនាំមកនូវកំណើនប្រាក់ចំណូល និង សូចនាករនៃការអភិវឌ្ឍកាន់តែល្អប្រសើរនៅក្នុងអនុតំបន់ទាំងនេះ។

ទ្វីបអាស៊ី និងអឺរ៉ុបបានបង្កើតវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមគួរឲ្យកត់សម្គាល់នៅក្នុងរយៈពេល២៥ឆ្នាំចុងក្រោយនេះ។ រដ្ឋសមាជិកជាច្រើនបានធ្វើកំណែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ទីផ្សាររបស់ខ្លួនក្នុងអំឡុងពេលនេះ។ រដ្ឋជាសមាជិកថ្មីៗមួយចំនួនបានពង្រីកឥទ្ធិពលសេដ្ឋកិច្ច និងនយោបាយរបស់EU។ ទ្វីបអាស៊ី គឺជាជម្រករបស់ប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសមានការអភិវឌ្ឍតិចតួចបំផុតជាច្រើន ដែលបានមើលឃើញនូវកំណើនប្រាក់ចំណូលយ៉ាងច្រើនរបស់ពួកគេ និង កំណើនផលិតភាពនៅក្នុងអំឡុងពេលដូចគ្នានេះ។ ទាំងទ្វីបអាស៊ី និងអឺរ៉ុប បាន និង កំពុងធ្វើជាអ្នកតម្រង់

ទិសទាំងនៅក្នុងការភ្ជាប់តំបន់របស់ខ្លួន និងការតភ្ជាប់អន្តរតំបន់ ផងដែរ ដែលធ្វើឱ្យមានលំហូរនៃប្រជាជន ទំនិញ សេវា និងមូលធនកាន់តែសេរីជាងមុន។

ជាពិសេស EU បានលើកកម្ពស់អភិក្រមនៃការតភ្ជាប់មួយដែលមានចីរភាព មានភាពគ្រប់ជ្រុងជ្រោយ និង ផ្អែកលើច្បាប់ និង មានបំណងលើកកម្ពស់ប្រសិទ្ធផលនៅក្នុងទីផ្សារតែមួយរបស់ EU និង ពង្រឹងការតភ្ជាប់នៅកម្រិតសកល ដោយសង្កត់ធ្ងន់លើអត្ថប្រយោជន៍ និង សិទ្ធិរបស់ប្រជាជន។ ម៉្យាងវិញទៀត ទ្វីបអាស៊ីបានលើកកម្ពស់ការតភ្ជាប់អន្តរតំបន់តាមរយៈផែនការហេដ្ឋារចនាសម្ព័ន្ធដែលគួរឲ្យកត់សម្គាល់ ដូចជា ផែនការមេស្តីពីការតភ្ជាប់អាស៊ាន គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និង ផ្លូវ បណ្តាញផ្លូវល្បឿនលឿនអាស៊ី បណ្តាញផ្លូវហាយវេអាស៊ី ផ្លូវហាយវេត្រីភាគីឥណ្ឌា-មីយ៉ាន់ម៉ា-ថៃ និង របៀងសេដ្ឋកិច្ចភាគខាងកើត-ខាងលិច។ ទ្វីបអាស៊ីបានប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីធ្វើការតភ្ជាប់ផ្នែកសេដ្ឋកិច្ច និង ស្ថាប័ន តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីខាងត្បូង និង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយនៅក្នុងតំបន់ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ។

សមាជិក ASEM នៅទ្វីបអឺរ៉ុប រួមមាន គ្រប់ប្រទេសជាសមាជិក EU ទាំងអស់ ប្រទេសន័រវ៉េ និង ប្រទេសស្វីស។ សមាជិក EU មានកម្រិតខុសៗគ្នានៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពនៃសូចនាករសង្គម និង ស្ថាប័ននៅក្នុងប្រទេស ប៉ុន្តែត្រូវបានចងភ្ជាប់ដោយវិធាន និង គុណតម្លៃរួមនានា ទីផ្សារតែមួយ និង ស្ថាប័នរួម។ ទ្វីបអាស៊ីត្រូវបានតំណាងដោយសមាជិកដែលមានសេដ្ឋកិច្ច អភិបាលកិច្ច និង យន្តការស្ថាប័នខុសៗគ្នា។ សមាជិកជាច្រើននៃទ្វីបអាស៊ីបានបង្កើតក្រុម និង សមាគមនៅក្នុងតំបន់ ដែលមានបែបបទ និង គណនេយ្យភាពនៅកម្រិតខុសៗគ្នា។

អាស៊ានគឺជាសហគមន៍ដែលមានភាពលេចធ្លោខ្លាំងជាងគេបំផុតនៅអាស៊ី ទោះបីជាក្រុមដទៃទៀតនៅក្នុងតំបន់ ដូចជា សមាគមអាស៊ីខាងត្បូងដើម្បីកិច្ចសហប្រតិបត្តិការតំបន់ (SAARC) និង គំនិតផ្តួចផ្តើមនៃឈូងសមុទ្របេងហ្គាល់ សម្រាប់កិច្ចសហប្រតិបត្តិការ បច្ចេកទេស និង សេដ្ឋកិច្ចពហុវិស័យ (BIMSTEC) មានបំណងធ្វើការតភ្ជាប់នៅថ្នាក់អនុតំបន់ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្ម និង វិនិយោគ និង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង បច្ចេកទេសនៅក្នុងចំណោមប្រទេសសមាជិកក្តី។

ប្រទេសម៉ុងហ្គោលី ក្នុងនាមជាប្រធាន ASEM ១១ នៅឆ្នាំ២០១៦ បានលើកកម្ពស់ចក្ខុវិស័យនៃការតភ្ជាប់រវាងអាស៊ី-អឺរ៉ុបនៅក្នុងទសវត្សរ៍ក្រោយ ដើម្បីធ្វើឲ្យមានលក្ខណៈផ្លូវការ និង ពង្រីកសកម្មភាពនានានៃកិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់ផ្នែកស្ថាប័នរវាងអាស៊ី និង អឺរ៉ុប។ ការតភ្ជាប់

នេះបានឈានដល់ការអភិវឌ្ឍន៍ និងអនុម័តគោលការណ៍ ASEM ស្ដីពីការតភ្ជាប់ នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១២ នៅទីក្រុងប្រ៊ុសសែល នៅឆ្នាំ២០១៨។ នៅក្នុងកិច្ចប្រជុំកំពូលនោះ EU បានបង្ហាញអំពីវិស័យនានាដើម្បីឆ្ពោះទៅកាន់ការតភ្ជាប់រវាង EU-អាស៊ី (គណៈកម្មការអឺរ៉ុប ឆ្នាំ២០១៨) ដោយផ្អែកលើបទពិសោធន៍របស់ EU នៅក្នុងការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការ។ យុទ្ធសាស្ត្ររបស់ EU ធ្វើឲ្យ ASEM អាចលើកកម្ពស់អភិក្រមមួយចំពោះការតភ្ជាប់រវាងអឺរ៉ុប និង អាស៊ី ដែលមានចីរភាព មានភាពគ្រប់ជ្រុងជ្រោយ និង ផ្អែកលើច្បាប់។ ស្រដៀងគ្នានេះដែរ បទពិសោធន៍ក្នុងការអភិវឌ្ឍរបស់អាស៊ីតាមរយៈការតភ្ជាប់ផ្នែករូបវ័ន្ត សេដ្ឋកិច្ច និង ស្ថាប័ន និង កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និង បច្ចេកទេស គឺជាគំរូដ៏ល្អមួយសម្រាប់ ASEM នៅក្នុងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងចំណោមអនុតំបន់នានា និង ដៃគូរបស់ ASEM។ តាមរយៈការរួមបញ្ចូលគ្នា មាគ៌ាទាំងពីរនេះនឹងនាំទៅរកភាពជាដៃគូរវាងអាស៊ី-អឺរ៉ុប សម្រាប់តំបន់ ASEM មួយដែលមានបរិយាប័ន្ន និង ត្រៀមខ្លួនរួចជាស្រេចសម្រាប់ថ្ងៃអនាគត ដោយទទួលបានការគាំទ្រពីគោលនយោបាយស្ដីពីការតភ្ជាប់ ពាណិជ្ជកម្ម និង ការវិនិយោគ ការអភិវឌ្ឍប្រកបដោយចីរភាព ឌីជីថលនីយកម្ម ធនធានមនុស្ស និង ជំនាញ និង ការការពារពហុភាគីនិយម។

លក្ខណៈពហុសមាសភាគនៃការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប មានន័យថា វាមិនអាចត្រូវបានគ្របដណ្ដប់ដោយសូចនាករតែមួយបាននោះទេ (Becker et al. ឆ្នាំ២០១៨)។ ASEM រួមបញ្ចូលគ្នានូវសមិទ្ធផល និង សក្ដានុពលរបស់តំបន់ទាំងពីរ និង ផ្ដល់ក្របខណ្ឌមួយសម្រាប់កិច្ចសហប្រតិបត្តិការ និង តភ្ជាប់នៅក្នុងវិស័យសេដ្ឋកិច្ច និង សង្គមសំខាន់ៗ។ ក្របខណ្ឌមួយនៃសូចនាករ និង ទិន្នន័យដែលពាក់ព័ន្ធ អាចផ្ដល់ជូននូវរូបភាពដ៏ធំមួយនៃកិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្ន និង អភិក្រមដើម្បីភាពរីកចម្រើននាពេលអនាគត។ ក្របខណ្ឌនេះផ្អែកលើការយល់ដឹងជារួមមួយថា វឌ្ឍនភាពសេដ្ឋកិច្ចត្រូវបានបកស្រាយថាជាវឌ្ឍនភាពសង្គម ដែលវឌ្ឍនភាពសង្គមនេះត្រូវបានបញ្ជាក់អះអាងបានយ៉ាងល្អបំផុត តាមរយៈកំណើនប្រាក់ចំណូលដែលគួរឲ្យកត់សម្គាល់ ការកាត់បន្ថយគម្លាតនៃភាពក្រីក្រ និង លទ្ធផលដទៃទៀតនៅក្នុងសង្គម ដូចជា សុខភាព និង អក្ខរកម្ម ជាដើម។ ចំណុចដែលសំខាន់គឺ តំបន់ទាំងពីរអាចធ្វើការជាមួយគ្នាដោយមានផែនការរួមមួយដើម្បីសេដ្ឋកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ និង ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

កិច្ចសហប្រតិបត្តិការរវាងប្រទេសនានានៃ ASEM នៅក្នុងវិស័យខុសៗគ្នា ដូចជា ការអប់រំ ការស្រាវជ្រាវ នវានុវត្តន៍ ទេសន្តរប្រវេសន៍ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំណាងឲ្យការភ្ជាប់ទំនាក់ទំនងជាអន្តរជាតិរបស់ប្រទេសជាងពាក់កណ្ដាលនៃ ASEM (រូបភាពទី ១)។ ការជួញដូរទំនិញនៅ

ក្នុងប្រទេសនានានៃ ASEM ប្រហែល ៧០% ត្រូវបានធ្វើឡើងជាមួយប្រទេសដទៃទៀតនៃ ASEM វិនិយោគិននៅ ASEM ជាង ៦០% ជ្រើសរើសធ្វើការវិនិយោគនៅក្នុងប្រទេស ASEM មួយផ្សេងទៀត ជាង ៦០% នៃចលនារបស់សិស្សជាអន្តរជាតិនៅក្នុងវិស័យអប់រំជាន់ខ្ពស់ បានផ្លាស់ទីទៅកាន់ប្រទេស ASEM មួយផ្សេងទៀត និង ៨០% នៃការប្រើប្រាស់ប័ណ្ណប៉ាតង់រួមគ្នាលក្ខណៈអន្តរជាតិនៅ ASEM គឺជាលទ្ធផលនៃកិច្ចសហការរវាងបណ្តាប្រទេសនៅ ASEM។

**រូបភាពទី១៖ ចំណងនៅក្នុង ASEM មានភាពរឹងមាំជាងចំណងជាមួយប្រទេសដទៃទៀតក្នុងពិភពលោក**




ASEM = កិច្ចប្រជុំអាស៊ី-អឺរ៉ុប
ប្រភព៖ Becker et al. (២០១៨)

តម្លៃទាំងនេះចង្អុលបង្ហាញអំពីលទ្ធផលជាវិជ្ជមានយ៉ាងពិតប្រាកដនៃការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប។ តម្លៃទាំងនេះក៏ផ្តល់គំនិតអំពីទំហំនៃសក្តានុពលដែលមិនទាន់ទាញប្រយោជន៍នៅឡើយ នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងតំបន់ទាំងពីរ។ សូចនាករសំខាន់ៗផ្សេងទៀតដែលត្រូវបានពិភាក្សានៅខាងក្រោមនឹងធ្វើឲ្យអ្នកបង្កើតគោលនយោបាយ និង ភាគីពាក់ព័ន្ធដទៃទៀតអាចធ្វើការប៉ាន់ប្រមាណអំពីសមិទ្ធផល និង សក្តានុពលរបស់ ASEM និង អនុញ្ញាតឲ្យក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការមានការវិវឌ្ឍន៍ និង មានភាពល្អប្រសើរឡើង ដោយផ្អែកលើតម្រូវការរបស់ ASEM។

## ពាណិជ្ជកម្ម ទីផ្សារ និង សេដ្ឋកិច្ច

ពាណិជ្ជកម្ម និង ការវិនិយោគគឺជាឆ្អឹងខ្នងនៃវិបុលភាព និង ភាពរីកចម្រើននាពេលអនាគតរបស់តំបន់ ASEM។ ទ្វីបអាស៊ី និង អឺរ៉ុបត្រូវតែមានផែនការ និង គោលនយោបាយដើម្បីប្រើប្រាស់សក្តានុពលនៃទីផ្សារមួយដែលមានប្រជាជនជិត ៥ ប៊ីលាននាក់ ជាពិសេស នៅក្នុងកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និង បច្ចេកវិទ្យា។ ពាណិជ្ជកម្មអន្តរតំបន់បានធ្វើជាសាក្សីនៃ

ភាពរីកចម្រើនជាបន្តបន្ទាប់នៅក្នុងទសវត្សរ៍កន្លងទៅ (រូបភាពទី ២)។ ទោះបីជាយ៉ាងណាក៏ដោយ អាស៊ី និង អឺរ៉ុបត្រូវតែដោះស្រាយផលប៉ះពាល់ជាអវិជ្ជមាននៃភាពតានតឹងនៃពាណិជ្ជកម្មជាសកល ដែលមានសភាពកាន់តែខ្លាំងក្លាឡើងដោយសារភាពតក់ស្លុតដែលបង្កឡើងដោយជំងឺរាតត្បាតសកលខ្សែចង្វាក់ផ្គត់ផ្គង់ ការរំខានដល់ផលិតកម្ម និង ទិដ្ឋភាពនៃការថយចុះផ្នែកសេដ្ឋកិច្ចជាសកល។

**រូបភាពទី២៖ GDP និង ទំហំពាណិជ្ជកម្មរបស់ប្រទេសដៃគូ ASEM ធៀបនឹងផ្នែកដទៃទៀតនៃពិភពលោក ឆ្នាំ២០១៨**
(ប៊ីលានដុល្លារ)




ASEM = កិច្ចប្រជុំអាស៊ី-អឺរ៉ុប GDP = ផលិតផលក្នុងស្រុកសរុប
ប្រភព៖ ទិន្នន័យរបស់ធនាគារពិភពលោក (២០២០b ២០២០c ២០២០d)

សកម្មភាពនៃកិច្ចសហប្រតិបត្តិការដើម្បីលើកកម្ពស់ការវិនិយោគ និង ការលុបចោលរបាំងមិនមែនជាពន្ធគយ គឺជាវិធានការសំខាន់ៗបំផុតចំនួនពីរនៅចំពោះមុខ ASEM។ ការរាតត្បាតយ៉ាងខ្លាំងក្លានៃជំងឺដែលកើតពីវីរុសកូរ៉ូណា (កូវីដ-១៩) ចាប់តាំងពីចុងឆ្នាំ២០១៩ មក បានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរលើវិស័យសេដ្ឋកិច្ចនៅទ្វីបអាស៊ី និង អឺរ៉ុប។ ដោយមានការគ្រប់គ្រងព្រំដែនយ៉ាងតឹងរ៉ឹង ការរំខានដល់ផលិតកម្ម និង ភាពតក់ស្លុតចំពោះខ្សែចង្វាក់តម្លៃសកល (GVCs) ការធ្វើពាណិជ្ជកម្មរវាងទ្វីបអាស៊ី-អឺរ៉ុបនឹងមានការថយចុះនៅក្នុងរយៈពេលខ្លី។ សហគ្រាសធុន

តូចបំផុត សហគ្រាសធុនតូច និង មធ្យម (MSMEs) ពាណិជ្ជកម្មផ្នែកសេវាកម្ម និង វិស័យទេសចរណ៍នឹងរងផលប៉ះពាល់ខ្លាំងបំផុត។ ការដាក់បញ្ចូលសាច់ប្រាក់ទំនេរក្នុងបរិមាណដ៏ច្រើនទៅក្នុងសេដ្ឋកិច្ចជឿនលឿននឹងបណ្តាលឱ្យទំនោរអវិជ្ជមាននៃលំហូរមូលធនហិរញ្ញវត្ថុចូលទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (OECD ឆ្នាំ២០២០)។ វិស័យសេវាកម្មទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺរាតត្បាតសកលដែលកំពុងតែកើតឡើងនេះ។ ពាណិជ្ជកម្មទំនិញ ដែលមានការថយចុះដោយភាពតានតឹងផ្នែកពាណិជ្ជកម្ម នៅក្នុងឆ្នាំ២០១៩ ត្រូវការជាតុចូលផ្នែកសេវាកម្មយ៉ាងខ្លាំងក្លា។ ASEM ត្រូវតែមានកិច្ចសហប្រតិបត្តិការតាមវិធីថ្មីស្រឡាងមួយ ដែលទំនុកចិត្ត និងការផ្តល់អត្ថប្រយោជន៍ទៅវិញទៅមកនឹងធ្វើឲ្យពាណិជ្ជកម្មទំនិញ និង សេវាកម្មត្រឡប់ទៅរកកម្រិតដែលមានស្ថេរភាពឡើងវិញ។

នៅទ្វីបអាស៊ី និង អឺរ៉ុប ពាណិជ្ជកម្មនៅក្នុងតំបន់ គឺជាកត្តាដ៏សំខាន់មួយដែលនាំឲ្យមានកំណើនសេដ្ឋកិច្ច បង្ហាញថាតើ GVCs នៅក្នុងតំបន់ទាំងពីរ ភាគច្រើនមានលក្ខណៈប្រចាំតំបន់ខ្លាំងដល់កម្រិតណា។ ទំនិញដែលត្រូវបានផលិតរួចហើយ តំណាងឲ្យភាគហ៊ុនធំជាងគេបំផុតរបស់ពាណិជ្ជកម្មរវាងអាស៊ី និង អឺរ៉ុប។ នាពេលបច្ចុប្បន្ន ប្រទេសចិនគឺជាប្រភពនៃការនាំចូលធំជាងបំផុតរបស់ EU និង ជាទីផ្សារនាំចេញធំជាងគេបំផុតលំដាប់ទីពីររបស់ EU។ EU គឺជាដៃគូពាណិជ្ជកម្មធំជាងគេបង្អស់លំដាប់ទីពីររបស់អាស៊ាន បន្ទាប់ពីចិន ដោយមានពាណិជ្ជកម្មប្រហែល ១៣% របស់អាស៊ាន។ មានសូចនាករដ៏រឹងមាំ ដែលបង្ហាញឱ្យឃើញថា ភាពតក់ស្លុតចំពោះតម្រូវការដែលមានរយៈពេលវែង អាចធ្វើឲ្យសង្វាក់ផ្គត់ផ្គង់រវាងអាស៊ី និង អឺរ៉ុប ចុះទន់ខ្សោយ ឬ ថែមទាំងអាចមានភាពដុនដាបផងដែរ។ កំណើនផលិតផលក្នុងស្រុកសរុប (GDP) នៅក្នុងឆ្នាំ២០២១ ត្រូវបានហ៊ុំព័ទ្ធដោយភាពមិនច្បាស់លាស់ ដោយសារតែវិវឌ្ឍន៍នៃជំងឺរាតត្បាតសកល។ ការលំបាកក្នុងរយៈពេលខ្លីនឹងក្លាយជារឿងធម្មតា និង មិនអាចជៀសវាងបាននៅគ្រប់ផែនការទាំងអស់។ ការលំបាកទាំងនេះមិនគួររារាំង ASEM ពីកិច្ចសហប្រតិបត្តិការលើយុទ្ធសាស្ត្ររយៈពេលវែង ដែលមានភាពមោះមុត គ្រប់ជ្រុងជ្រោយ និង មានផែនការសម្រាប់ថ្ងៃអនាគតនោះទេ។

## សេដ្ឋកិច្ចឌីជីថល

នៅក្នុងទសវត្សរ៍នេះ បម្រែបម្រួលផ្នែកឌីជីថលនឹងបង្កើនផលប៉ះពាល់បន្ថែមទៀត និង កាន់តែខ្លាំងក្លាឡើង លើវិស័យសេដ្ឋកិច្ចនៅទ្វីបអាស៊ី និង អឺរ៉ុប។ សេដ្ឋកិច្ចឌីជីថលនឹងមានផលប៉ះពាល់លើលំនាំគំរូ និង ទីតាំងភូមិសាស្ត្ររបស់ឧស្សាហកម្ម ការងារ ពាណិជ្ជកម្ម និង កំណើនសេដ្ឋកិច្ច (Prakash ឆ្នាំ២០១៩)។ តំបន់ ASEM ត្រូវតែទទួលបានអត្ថប្រយោជន៍ពីវឌ្ឍនភាពនេះ

ប៉ុន្តែក៏ត្រូវតែធានាថាឌីជីថលនីយកម្មលើកកម្ពស់បរិយាប័ន្នផងដែរ ជាពិសេស សម្រាប់យុវជន និង ស្ត្រី។ ទ្វីបអាស៊ី និង អឺរ៉ុបមានសមត្ថភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការតភ្ជាប់នៅកម្រិតខុសៗគ្នា។ ការអភិវឌ្ឍផ្នែកសេវាកម្ម បទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យ និង ផ្នែកពន្ធដារតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការខ្លាំងក្លាជាងនេះ និង ត្រូវបានពន្យល់កាន់តែលម្អិតបន្ថែមទៀតនៅក្នុងជំពូកបន្តបន្ទាប់ទៀត។

ការកែប្រែរចនាសម្ព័ន្ធ និង ការបង្កើតការងារនៅទ្វីបអាស៊ី និង អឺរ៉ុបត្រូវតែត្រៀមជាស្រេចសម្រាប់ និង ឆ្លើយតបទៅនឹងសេដ្ឋកិច្ចឌីជីថលថ្មី ពីព្រោះសេដ្ឋកិច្ចឌីជីថលថ្មីនេះនឹងមានផលប៉ះពាល់លើលំនាំគំរូ និង ទីតាំងភូមិសាស្ត្ររបស់ឧស្សាហកម្ម ការងារ ពាណិជ្ជកម្ម និង កំណើនសេដ្ឋកិច្ច។ សេដ្ឋកិច្ចឌីជីថលថ្មីនេះបានកើតឡើងកាន់តែឆាប់រហ័សជាងនេះទៀតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ជាពិសេសផ្នែកដែលមិនបានធ្វើសមាហរណកម្មយ៉ាងខ្លាំងក្លានៅក្នុងបណ្តាញផលិតកម្មប្រចាំតំបន់។

ការចូលរួមនៅក្នុង GVCs មានសារសំខាន់ចំពោះភាពរីកចម្រើន និង ការបង្កើតការងារ។ តំបន់ទាំងនេះ ត្រូវការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថល កាន់តែខ្លាំងក្លាជាងនេះទៀត ពីព្រោះតម្រូវការជាសកលចំពោះឧស្សាហកម្មនានាត្រូវបានកំណត់ទិសដៅដោយបច្ចេកវិទ្យាថ្មីៗ ជំនាញថ្មីៗ និង បណ្តុំស្ថានប្រព័ន្ធនៃអាជីវកម្មដែលមានលក្ខណៈថ្មីទាំងស្រុង (Prakash ឆ្នាំ២០១៩)។ ទ្វីបអាស៊ី និង អឺរ៉ុបមានឱកាសដ៏មហិមានៅក្នុងការរីកចម្រើនជាមួយគ្នា តាមរយៈកិច្ចសហប្រតិបត្តិការ និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអប់រំ និង ការបណ្តុះជំនាញ និង ការវិនិយោគលើការតភ្ជាប់ផ្នែករូបវ័ន្ត និង ផ្នែកស្ថាប័ន។ គម្រោងសាកល្បងសម្រាប់ការបោះជំហានទៅមុខផ្នែកបច្ចេកវិទ្យានៅក្នុងប្រទេសមានការអភិវឌ្ឍតិចតួចបំផុត ការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍ និង កិច្ចសហប្រតិបត្តិការនៃការធ្វើនិយ័តកម្មលើសេរីភាវូបនីយកម្ម និង ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និង ការវិនិយោគ ជាពិសេសផ្នែកសេវាកម្ម និង ពាណិជ្ជកម្មអេឡិចត្រូនិក គួរតែកំណត់នូវភាពត្រៀមខ្លួនជាស្រេចសម្រាប់ពេលអនាគតរបស់ ASEM។ លើសពីនេះទៀត ASEM ត្រូវតែស្តារឡើងវិញនូវវិធានការគោលនយោបាយ ដើម្បីជួយសម្រួលដល់ផ្នែកពាណិជ្ជកម្ម និង ការផ្លាស់ទីរបស់កម្មករជំនាញដើម្បីសេដ្ឋកិច្ចឌីជីថល។ គោលនយោបាយការពារអ្នកប្រើប្រាស់ និង ឯកជនភាព គោលនយោបាយប្រកួតប្រជែង ពន្ធដារ និង សន្តិសុខព័ត៌មាន ក៏ត្រូវការការយកចិត្តទុកដាក់កាន់តែខ្លាំង និង ការថ្លឹងថ្លែងជាសកល។

សមាជិករបស់ ASEM មានយុទ្ធសាស្ត្រជាតិរបស់ពួកគេរៀងៗខ្លួន និង សម្រេចបានភាពជោគជ័យនៅកម្រិតខុសៗគ្នា នៅក្នុងការបង្កើតសេដ្ឋកិច្ចឌីជីថលរបស់ពួកគេ (Prakash ឆ្នាំ២០១៦)។

ដៃគូរបស់ ASEM ក៏ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ផងដែរ។ "សេដ្ឋកិច្ចឌីជីថលដែលអាចប្រើប្រាស់ មានបរិយាប័ន្ន និង មានតម្លៃសមរម្យ" គឺជាលទ្ធផលដ៏សំខាន់មួយនៃផែនការមេ ICT ឆ្នាំ២០២០ របស់អាស៊ាន (អាស៊ាន ២០១៥:១២)។ យុទ្ធសាស្ត្រទីផ្សារឌីជីថលតែមួយរបស់អឺរ៉ុបមានបំណងបើកឱកាសផ្នែកឌីជីថលដល់ប្រជាជន និង អាជីវកម្ម និង ពង្រីកមុខតំណែងរបស់ខ្លួននៅក្នុងនាមជាតំបន់ឈានមុខគេនៅលើពិភពលោកផ្នែកសេដ្ឋកិច្ចឌីជីថល។ EU មានបំណងធ្វើឲ្យគោលនយោបាយរបស់ខ្លួនរួមបញ្ចូលគុណតម្លៃនៃសង្គម និង លើកកម្ពស់បរិយាប័ន្ន។ ក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្តីពីការតភ្ជាប់ បានអនុម័តផែនការតភ្ជាប់មួយនៅក្នុងឆ្នាំ២០១៨ ដែលរាយនាមវិស័យសំខាន់ៗនៃការតភ្ជាប់។ ពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងព្រំដែន រួមបញ្ចូលទាំងការជាប់ពាក់ព័ន្ធរបស់ MSMES ផងដែរនោះ ត្រូវបានរាយនាមថាជាវិស័យដ៏សំខាន់មួយសម្រាប់ដៃគូ ASEM នៅក្នុងលើកទឹកចិត្តឲ្យមានការចូលរួមរបស់ MSME នៅក្នុងឱកាសធ្វើអាជីវកម្ម និង សមាហរណកម្មពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងព្រំដែន ចូលទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់សកល។ សន្ទស្សន៍នៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដោយសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍ (UNCTAD) បង្ហាញអំពីគម្លាតរវាងអាស៊ី និង អឺរ៉ុបនៅក្នុងវិស័យមួយចំនួន ដែលពាក់ព័ន្ធនឹងការចូលរួមនៅក្នុងសេដ្ឋកិច្ចឌីជីថលប្រកបដោយភាពជោគជ័យ។ សន្ទស្សន៍នៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក ជាមធ្យម មានសូចនាករចំនួនបួន៖ (i) ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត (ii) ចំនួនបុគ្គលដែលមានគណនី (iii) អ៊ីនធឺណិតសឺវឺដែលមានសុវត្ថិភាព និង (iv) ពិន្ទុនៃការជឿជាក់លើការអភិវឌ្ឍសេវាប្រៃសណីយ៍ (រូបភាពទី៣)។ បញ្ហាប្រឈមផ្នែកគោលនយោបាយដែលទ្វីបអាស៊ី និង អឺរ៉ុបត្រូវប្រឈមមុខគឺ ការធានាថា សេដ្ឋកិច្ចឌីជីថលមិនបានលើកកម្ពស់ការអភិវឌ្ឍដែលមិនស្មើភាពគ្នានោះទេ និងថា វាជំរុញឲ្យមានការវិនិយោគនៅក្នុងក្រុមហ៊ុន តំបន់ និង ប្រទេសដែលមិនសូវអភិវឌ្ឍន៍កាន់តែច្រើនឡើង។

ទ្វីបអាស៊ី និង អឺរ៉ុបបានទទួលអត្ថប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថលដែលកំពុងតែរីកលូតលាស់ រួមបញ្ចូលទាំង ឧបសគ្គចំពោះការចូលតិចជាងមុន បន្ទុកចំណាយប្រតិបត្តិការទាបជាងមុន និង ផលិតភាពល្អប្រសើរជាងមុនផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេក៏ប្រឈមមុខនឹងបញ្ហាប្រឈមនានាទាក់ទងនឹងពន្ធដារអន្តរជាតិ និង ការប្រមូលផ្តុំធនធាននៅក្នុងប្រទេសផងដែរ។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១២ ថ្នាក់ដឹកនាំបានទទួលស្គាល់អំពីភាពចាំបាច់ក្នុងការត្រួតពិនិត្យឡើងវិញលើទិដ្ឋភាពសំខាន់ៗចំនួនពីរនៃក្របខណ្ឌពន្ធដារដែលមានស្រាប់ ការបែលកប្រាក់ចំណេញ និង វិធានទំនាក់ទំនងក្នុងការហូតពន្ធ សំដៅធ្វើឲ្យការហូតពន្ធមានភាពស្របគ្នា

នឹងការបង្កើតតម្លៃ (ASEM ឆ្នាំ២០១៨)។ ដំណោះស្រាយរបស់ ASEM នឹងរួមចំណែកដល់កិច្ចពិភាក្សាជាសកលនៅក្នុងអង្គការសហប្រជាជាតិ (UN) ក្រុមប្រទេស G20 និង អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) និង ផ្តល់ដំណោះស្រាយដែលផ្អែកលើការព្រមព្រៀងជាឯកច្ឆន្ទ ដើម្បីដោះស្រាយផលប៉ះពាល់នានានៃការធ្វើឌីជីថលនីយកម្មនៃវិស័យសេដ្ឋកិច្ច លើប្រព័ន្ធពន្ធដារអន្តរជាតិ។

**រូបភាពទី៣៖ សន្ទស្សន៍ពាណិជ្ជកម្មអេឡិចត្រូនិក ឆ្នាំ២០១៩**




ប្រភព៖ UNCTAD (២០១៩)

## កិច្ចសហប្រតិបត្តិការលើមូលធនមនុស្ស

មូលធនមនុស្សគឺជាចំណុចសំខាន់នៃកំណើនរបស់ស្ថានប្រព័ន្ធ ជាពិសេស នៅក្នុងយុគសម័យឌីជីថល។ ពិភពការងារកំពុងតែមានការប្រែប្រួលដោយសារភាពជឿនលឿនផ្នែកបច្ចេកវិទ្យានវានុវត្តន៍ ស្វ័យប្រវត្តិកម្ម បច្ចេកវិទ្យាផលិតមនុស្សយន្ត វេទិកាឌីជីថល និង ការតភ្ជាប់ដែលកាន់តែខ្លាំងក្លាជាងមុន។ ឥទ្ធិពលនៃសេដ្ឋកិច្ចឌីជីថលមានភាពជឿនលឿនខ្លាំងជាងគេបំផុតនៅក្នុងកម្មវិធីសាជីវកម្ម និង ប្រព័ន្ធឧស្សាហកម្ម ដូច្នេះ វាជះឥទ្ធិពលលើការជួល ការបណ្តុះបណ្តាលជំនាញ និង គោលនយោបាយសម្របសម្រួលការងារ (Prakash ២០១៩)។

ទ្វីបអាស៊ីមានប្រជាជនវ័យក្មេង និង មានកំណើនកម្លាំងពលកម្ម ដែលជាទ្រព្យសកម្មមានតម្លៃខ្ពស់នៅក្នុងពិភពលោកដែលមានវ័យចំណាស់នេះ។ ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីមានកម្លាំងពលកម្មប្រចាំតំបន់ច្រើនជាងគេបំផុតនៅលើពិភពលោក ដោយមានអ្នកធ្វើការជិត ២ ប៊ីលាននាក់។ កម្លាំងពលកម្មនៅអាស៊ី ត្រូវបានគេប្រមើលមើលថាមានកំណើនប្រចាំឆ្នាំត្រឹម ០,៥% ពី ១,៩ ប៊ីលាននាក់ នៅក្នុងឆ្នាំ២០១៥ រហូតដល់ ២,១ ប៊ីលាននាក់នៅក្នុងឆ្នាំ២០៣០ និង ២,២ ប៊ីលាននាក់នៅក្នុងឆ្នាំ២០៥០ (ADB ២០១៨)។ ប្រទេសឥណ្ឌាត្រូវបានគេប្រមើលមើលថាមានកម្លាំងពលកម្មចំនួន ៣០% នៃកម្លាំងពលកម្មប្រចាំតំបន់ គិតត្រឹមឆ្នាំ២០៣០ ហើយប្រទេសដែលមានប្រជាជនវ័យក្មេងជាង នឹងមានកំណើនកម្លាំងពលកម្មខ្លាំងជាង និង ចាំបាច់ត្រូវមានគោលនយោបាយដើម្បីធានាថាមានចំនួនការងារផ្នែកផលិតកម្មគ្រប់គ្រាន់។

ដូច្នេះសកម្មភាពរបស់ASEMដែលលើកកម្ពស់ការសិក្សានៅក្នុងសាលារៀន សាកលវិទ្យាល័យ និង ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមានសារសំខាន់នៅក្នុងការផ្តល់ជូនប្រជាជននូវជំនាញនានាដែលចាំបាច់ដើម្បីមានផលិតភាពកាន់តែខ្លាំងឡើង។ កម្មវិធីកិច្ចសហប្រតិបត្តិការរបស់ ASEM ដើម្បីលើកកម្ពស់មុខវិទ្យាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ភាពជាសហគ្រិន និង គណិតវិទ្យានៅក្នុងការអប់រំក្នុងប្រព័ន្ធ គឺជាការចាំបាច់ ពីព្រោះកម្មវិធីទាំងនេះនឹងជួយអភិវឌ្ឍភាពងាយបត់បែន ផលិតភាព និងសមត្ថភាពផ្នែកនវានុវត្តន៍របស់តំបន់។ កម្មវិធីទាំងនេះរួមបញ្ចូលការកសាងសមត្ថភាពសម្រាប់ភាពជាសហគ្រិន និង ការធ្វើការឲ្យខ្លួនឯង តាមរយៈការបណ្តុះបណ្តាលអំពីអាជីវកម្ម ការបង្កើនកម្រិតជំនាញ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការបណ្តុះបណ្តាលក្នុងពេលធ្វើការ។ វិនិយោគិន ផ្តល់តម្លៃដល់ជំនាញ និង សមត្ថភាពក្នុងការផលិតរបស់ក្រុមហ៊ុន។ ការផ្តល់ជំនាញគឺជាការពិចារណាដ៏សំខាន់មួយនៅក្នុងការសម្រេចចិត្តធ្វើការវិនិយោគ ដោយសារតែកម្លាំងពលកម្មដែលបានទទួលការបណ្តុះបណ្តាល (ឬអាចបណ្តុះបណ្តាលបាន) ជួយបង្កើនផលិតភាព និង ប្រតិបត្តិការដ៏រលូន។

ការបោះជំហានការវិនិយោគលើជំនាញ និង ការអប់រំរបស់ប្រជាជន គឺជាចំណុចសំខាន់ដើម្បីភាពរីកចម្រើននាថ្ងៃអនាគត ដែលមានទាំងបរិយាប័ន្ន និង ភាពធន់។ គំនិតផ្តួចផ្តើមរបស់ ASEM នៅក្នុងការអភិវឌ្ឍធនធានមនុស្ស និង ជំរុញឲ្យមាននវានុវត្តន៍ និង កិច្ចប្រឹងប្រែងក្នុងការស្រាវជ្រាវរួមគ្នា នៅតែជាគំរូចាស់មួយ និង កំពុងតែបញ្ជាក់ថា វាមិនគ្រប់គ្រាន់សម្រាប់ការបំពេញតាមបញ្ហាប្រឈម និង កាលានុវត្តភាពនាពេលខាងមុខនោះទេ។ កម្មវិធីអប់រំ ASEM–DUO ដែលមានស្រាប់ ការបណ្តុះបណ្តាលអ្នកការទូត និង សកម្មភាពរបស់មូលនិធិអាស៊ី-អឺរ៉ុប (ASEF) ដទៃទៀត ឆ្លុះបញ្ចាំងអំពីស្ថានភាពនេះ។ ឧទាហរណ៍៖ ASEM–DUO គឺ

ជាកម្មវិធីមេដែលមានកម្មវិធីនៅក្នុងប្រទេសផ្សេងៗគ្នាចំនួន ៦ ដែលមកពីសាធារណរដ្ឋកូរ៉េ ប្រទេសសិង្ហបុរី ប្រទេសថៃ ប្រទេសស៊ុយអែត ប្រទេសប៊ែលហ្ស៊ិក និង ប្រទេសឥណ្ឌា ជាប្រទេសសមាជិកដែលបានរួមចំណែក។ ព័ត៌មានលម្អិតអំពីកម្មវិធីទាំងនេះត្រូវបានបញ្ញត្តិដោយសមាជិកដែលរួមចំណែក។ នៅឆ្នាំ២០១៧ សាស្ត្រាចារ្យចំនួនប្រាំមួយនាក់ និង សិស្សចំនួន ២០៥ នាក់បានចូលរួមកម្មវិធីផ្លាស់ប្តូរការសិក្សាអប់រំរបស់ប្រទេសទាំងប្រាំមួយ (លេខាធិការដ្ឋានអាហារូបករណ៍ ASEM–DUO ឆ្នាំ២០១៧)។ ស្រដៀងគ្នានេះដែរ សន្និសីទបណ្តាញថ្នាក់រៀន ASEF ដែលស្ថិតនៅក្រោមការអប់រំអំពីកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាព គ្របដណ្តប់លើការបង្រៀនដែលមានបទពិសោធន៍ ការរៀនសូត្រ និង ការកសាងសមត្ថភាព។ កម្មវិធីទាំងនេះមានអ្នកចូលរួមដែលមានចំនួនកំណត់ នៅក្នុងរយៈពេលខ្លី ចំនួន ១ ឬ ២ សប្តាហ៍ (ASEF ឆ្នាំ២០១៩)។ កម្មវិធីអប់រំដទៃទៀតដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ ASEF បានបង្ហាញយ៉ាងច្បាស់ថា អាស៊ី និង អឺរ៉ុបត្រូវការកម្មវិធីអភិវឌ្ឍធនធានមនុស្សដែលមានភាពស្វាហាប់ និង មានពហុសមាសភាគ ដែលជះឥទ្ធិពលនៅកម្រិតមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាការងារ នវានុវត្តន៍ ប្រាក់ចំណូល និង ផលិតភាពដែលមានការកើនឡើង។

ទោះបីជាយ៉ាងណាក៏ដោយ វេទិកា ASEM សម្រាប់ការអប់រំ និង ការអភិវឌ្ឍជំនាញ ដែលមានស្រាប់ អាចត្រូវបានធ្វើសេចក្តីព្រាងឡើងវិញ និង ផ្តល់ថាមពលជូន ដើម្បីដោះស្រាយតម្រូវការជាក់ស្តែងផ្អែកជំនាញ និង ការអប់រំ រួមបញ្ចូលទាំងការស្រាវជ្រាវរួមគ្នានៅក្នុងចំណោមយុវជននៃតំបន់ ASEM ផងដែរ។ ឥទ្ធិពលនៃសេដ្ឋកិច្ចឌីជីថលមានភាពជឿនលឿនខ្លាំងជាងគេបំផុតនៅក្នុងកម្មវិធីសាជីវកម្ម និង ប្រព័ន្ធឧស្សាហកម្ម ដូច្នេះ វាមានឥទ្ធិពលលើការវិនិយោគ ការជួលការបណ្តុះបណ្តាលជំនាញ និង ការអប់រំ។ ASEM ត្រូវតែផ្តល់អាទិភាពខ្ពស់ដល់កម្មវិធីបណ្តុះបណ្តាល និង កម្មវិធីជំនាញ និង សកម្មភាពអប់រំ និង ស្រាវជ្រាវរួមគ្នា នៅក្នុងចំណោមសាកលវិទ្យាល័យ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលនានានៅអាស៊ី និង អឺរ៉ុប។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី ៨ ពោលគឺលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង បរិយាប័ន្ន មានមុខរបរពេញលេញ និង មានផលិតភាព និង មានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប" សហគមន៍អន្តរជាតិត្រូវតែកាត់បន្ថយឱ្យបានខ្លាំងក្លានូវសមាមាត្ររបស់យុវជនដែលមិនបំពេញការងារ មិនទទួលការអប់រំ ឬ ការបណ្តុះបណ្តាល (NEET) និង អភិវឌ្ឍ និង ធ្វើប្រតិបត្តិការយុទ្ធសាស្ត្រសកលដើម្បីការងាររបស់យុវជន។ អង្គការអន្តរជាតិខាងការងារ (ឆ្នាំ ២០២០) បានបង្ហាញថា គោលដៅអនុវត្តទាំងនេះនឹងមានការខកខាន (តារាងទី១)។ ទ្វីបអាស៊ី និង អឺរ៉ុបត្រូវតែខិតខំប្រឹងប្រែងទ្វេដង

ដើម្បីកំណើនបរិយាប័ន្ន ដែលបង្កើតការងារសមរម្យសម្រាប់អ្នកធ្វើការជំនាន់ក្រោយ។ ទីផ្សារការងារយុវជននៅទូទាំងពិភពលោកនឹងទទួលរងផលជះជាពិសេស តាមរយៈភាពយឺតយ៉ាវនៃសកម្មភាពសេដ្ឋកិច្ចដែលបណ្តាលពីជំងឺរាតត្បាតសកលកូវីដ-១៩។ កម្មវិធីអប់រំ និង កម្មវិធីបណ្តុះបណ្តាលជំនាញរបស់ ASEM ត្រូវតែដោះស្រាយបញ្ហាអនាគតរបស់យុវជននៅក្នុងតំបន់ទាំងពីរ។ កម្មវិធីកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍធនធានមនុស្សរបស់ ASEM ត្រូវតែធានាបាននូវសមភាពរវាងស្ត្រី និង បុរស ព្រមទាំងសិទ្ធិ និង ឱកាសស្មើភាពគ្នារបស់មនុស្សគ្រប់រូបផងដែរ។

ចំណុចនេះមានភាពចាំបាច់ចំពោះសង្គម និង ជាទ្រព្យសកម្មផ្នែកសេដ្ឋកិច្ចសម្រាប់មនុស្សគ្រប់រូបផងដែរ។

**តារាងទី I ៖ អត្រានៃការចូលរួមរបស់កម្លាំងពលកម្មយុវវ័យ (%) និង គម្លាតយេនឌ័រ (ការចង្អុលបង្ហាញជាភាគរយ)៖ ទ្វីបអាស៊ី និង អឺរ៉ុប ឆ្នាំ១៩៩៩ និង ឆ្នាំ២០១៩**

| តំបន់ | អនុតំបន់ | LFPR ឆ្នាំ១៩៩៩ | | | LFPR ឆ្នាំ២០១៩ | | | គម្លាតយេនឌ័រ (បុរស/ស្ត្រី) ការចង្អុលបង្ហាញជាភាគរយ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | ១៩៩៩ | ២០១៩ |
| អាស៊ី និង ប៉ាស៊ីហ្វិក | អាស៊ីបូព៌ា | ៦៧,០ | ៦៧,៣ | ៦៦,៦ | ៤៥,២ | ៤៦,៥ | ៤៣,៨ | ០,៧ | ២,៧ |
| | អាស៊ីអាគ្នេយ៍ និង ប៉ាស៊ីហ្វិក | ៥៧,៦ | ៦៤,៧ | ៥០,៤ | ៤៧,៤ | ៥៤,៥ | ៣៩,៩ | ១៤,៣ | ១៤,៦ |
| | អាស៊ីខាងត្បូង | ៤៤,៩ | ៦៥,០ | ២៣,១ | ៣១,៦ | ៤៧,៤ | ១៤,២ | ៤១,៩ | ៣៣,២ |
| អឺរ៉ុប | អឺរ៉ុបខាងជើង ខាងត្បូង និង ខាងលិច | ៤៧,៩ | ៥១,៦ | ៤៤,១ | ៤៣,៨ | ៤៦,១ | ៤១,៤ | ៧,៥ | ៤,៧ |
| | អឺរ៉ុបខាងកើត | ៤១,៩ | ៤៥,៩ | ៣៧,៧ | ៣២,២ | ៣៥,៩ | ២៨,៣ | ៨,២ | ៧,៥ |
| ពិភពលោក | | ៥៣,១ | ៦២,២ | ៤៣,៧ | ៤១,២ | ៤៩,១ | ៣២,៨ | ១៨,៥ | ១៦,២ |

LFPR = អត្រាការចូលរួមរបស់កម្លាំងពលកម្ម

ប្រភព៖ អង្គការអន្តរជាតិខាងការងារ (ឆ្នាំ២០១៩)

## ការអភិវឌ្ឍប្រកបដោយចីរភាព និង កំណើនប្រកបដោយបរិយាប័ន្ន

ទ្វីបអាស៊ីនិងអឺរ៉ុបត្រូវលើកកម្ពស់បរិយាប័ន្ននិងចីរភាពនៅពេលដោះស្រាយផលប៉ះពាល់នៃការវិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា និង ការប្រែប្រួលអាកាសធាតុ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអាចមើលឃើញកាន់តែច្បាស់ និង រីករាលដាលកាន់តែខ្លាំង ដែលស្នើឲ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ចំណាត់ការពហុភាគីកាន់តែរឹងមាំជាងនេះ។ ខណៈពេលដែលទ្វីបអឺរ៉ុបកំពុងតែឈានមុខគេផ្នែកវិធីកែប្រែសេដ្ឋកិច្ច និង សង្គមរបស់ខ្លួនផ្ទាល់ ដើម្បីសម្រេចបាននូវការមិនបញ្ចេញឧស្ម័នទៅក្នុងបរិយាកាសនោះ ប្រទេសនានានៅអាស៊ីកំពុងតែបង្កើតវឌ្ឍនភាពតាមវិធីមួយ ដែលពិចារណាអំពីស្ថានភាពរបស់ប្រទេស និង ថ្លៃដើមផ្នែកសង្គម និង សេដ្ឋកិច្ច។ ទ្វីបអាស៊ី និង អឺរ៉ុបអាចប្រឈមនឹងការប្រែប្រួលអាកាសធាតុ ស្របពេលដំណាលគ្នាទៅនឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

ASEM ស្ថិតនៅទីតាំងដែលស័ក្តិសមសម្រាប់ការកំណត់វិធានការនានាដើម្បីធ្វើឲ្យបរិស្ថាននៅក្នុងទីក្រុង និង នៅតាមទីជនបទមានភាពល្អប្រសើរឡើង ពង្រឹងគុណភាពខ្យល់ និង ទឹក និង លើកកម្ពស់ការធ្វើកសិកម្មប្រកបដោយចីរភាព ដែលមានភាពចាំបាច់ដើម្បីធានាចំពោះសុវត្ថិភាពចំណីអាហារ និង ជំរុញផលិតផលដែលមានគុណភាពល្អ។ ប្រទេសនានានៃ ASEM ត្រូវតែឈានមុខគេនៅក្នុងការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការបាត់បង់ជីវចម្រុះ និង ការថែរក្សាប្រព័ន្ធបរិស្ថាន រួមបញ្ចូលទាំងមហាសមុទ្រផងដែរ។ ASEM បានទទួលស្គាល់អំណាចជាសកលចំពោះការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលរបស់ខ្លួន នៅក្នុងឆ្នាំ២០១៦ និង ២០១៨ ជាកន្លែងដែលថ្នាក់ដឹកនាំរបស់ ASEM បានណែនាំឲ្យមានការចូលរួមកាន់តែខ្លាំងក្លាថែមទៀតជាមួយអង្គការ Global Compact នៃអង្គការសហប្រជាជាតិនៅលើរបៀបវារៈ ឆ្នាំ២០៣០។ វឌ្ឍនភាពរបស់ដៃគូ ASEM ដើម្បីឆ្ពោះទៅសម្រេចបាន SDGs (រូបភាពទី ៤ និង ទី ៥) គូសបញ្ជាក់អំពីគុណសម្បត្តិនៃយន្តការកិច្ចសន្ទានរបស់ ASEM ដើម្បីគាំទ្រដល់ការបន្តការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅទ្វីបអាស៊ី និង អឺរ៉ុប រួមបញ្ចូលទាំង តាមរយៈរបៀបវារៈនៃការតភ្ជាប់របស់ខ្លួនផងដែរ។

**រូបភាពទី៤៖ ទិដ្ឋភាពទូទៅនៃវឌ្ឍនភាពរបស់ EU ២៧ ឆ្ពោះទៅកាន់ SDGs កាលពីជាង ៥ ឆ្នាំមុន ឆ្នាំ២០២០**




EU = សហភាពអឺរ៉ុប SDG = គោលដៅអភិវឌ្ឍន៍សហសវត្សរ៍
សម្គាល់៖ ទិន្នន័យសំដៅជាចម្បងលើឆ្នាំ២០១៣-២០១៨ ឬ ២០១៤-២០១៩
ប្រភព៖ Eurostat ២០២០
(ត្រូវបានកែសម្រួលបន្តិចបន្តួចដោយអ្នកនិពន្ធក្នុងគោលបំណងកែប្រែទ្រង់ទ្រាយនៃឯកសារ)។

**រូបភាពទី៥៖ វឌ្ឍនភាពរបស់ SDG នៅក្នុងឆ្នាំ២០១៩ – តំបន់អាស៊ីប៉ាស៊ីហ្វិក**




SDG = គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
ប្រភព៖ UNESCAP ( ២០២០ )

ASEM បានបង្ហាញការប្តេជ្ញាចិត្តជាពិសេសចំពោះសមភាពយេនឌ័រ និង ការផ្តល់ភាពអង់អាចដល់ស្ត្រី និង កុមារី ដែលមានសារសំខាន់ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងរបស់ ASEM ត្រូវតែមានការកែសម្រួលដើម្បីបញ្ច្រៀបសមភាពយេនឌ័រនៅក្នុងសសរស្តម្ភទាំងបីរបស់ ASEM - នយោបាយ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វប្បធម៌សង្គម។ ភាពអង់អាចរបស់ស្ត្រីធ្វើឲ្យមានភាពរីកចម្រើន និង ផលិតភាព និង នាំទៅរកសង្គមដែលមានបរិយាប័ន្ន។ នៅពេលដែល ASEM គាំទ្រភាពជាអ្នកដឹកនាំរបស់ស្ត្រី ទ្វីបអាស៊ី និង អឺរ៉ុបអាចធានាបាននូវការចូលរួមយ៉ាងពេញលេញរបស់ស្ត្រីនៅក្នុងដំណើរការនយោបាយ និង សេដ្ឋកិច្ច និង ទទួលស្គាល់ជាផ្លូវការអំពីការរួមចំណែករបស់ពួកគេនៅក្នុងសង្គម។

## ពហុភាគីនិយម និង បទបញ្ញាអន្តរជាតិដែលផ្អែកលើច្បាប់

ASEM តែងតែបង្ហាញអំពីការត្រៀមខ្លួនជាស្រេចនៅក្នុងការធ្វើការរួមគ្នា ដើម្បីសន្តិភាព និង សន្តិសុខ ការអភិវឌ្ឍ និង កំណើនប្រកបដោយចីរភាព និង បរិយាប័ន្ន និង ការលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស ដោយផ្អែកលើធម្មនុញ្ញរបស់ UN និង អនុលោមតាមច្បាប់អន្តរជាតិ។ នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅប្រទេសម៉ុងហ្គោល កាលពីខែកក្កដា ឆ្នាំ២០១៦ ថ្នាក់ដឹកនាំ ASEM បានកត់សម្គាល់ និង ជូនដំណឹងជាមុន ប្រឆាំងនឹងវិបត្តិពិភពលោក ដែលជាគោលនយោបាយប្រកួតប្រជែង ដែលមានបំណងលើកកម្ពស់ការបើកចំហរ និង កំណើនសេដ្ឋកិច្ចពិភពលោក។ ថ្នាក់ដឹកនាំទាំងឡាយបានទទួលស្គាល់ថា ហានិភ័យនៃការសម្លឹងមើលទៅផ្នែកដទៃទៀតនៃពិភពលោកនៅតែបន្តកើតឡើងនៅក្នុងបរិបទនៃភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ច និង និយោបាយភូមិសាស្ត្រ ភាពឆាប់ប្រែប្រួលផ្នែកហិរញ្ញវត្ថុនៅតែបន្ត សមត្ថភាពផលិតច្រើនជាងតម្រូវការជាសកល នៅក្នុងវិស័យឧស្សាហកម្ម បញ្ហាប្រឈមនានាដែលប្រឈមមុខដោយអ្នកនាំចេញទំនិញ និង អតិផរណាកម្រិតទាបនៅតែបន្តកើតឡើង។

បញ្ហាប្រឈមកំពុងដែលទីភ្នាក់ងារពហុភាគីជួបប្រទះ កំពុងតែធ្វើឲ្យយន្តការឆ្លើយតបរបស់ប្រទេសដៃគូមានភាពយឺតយ៉ាវ។ ថ្នាក់ដឹកនាំ ASEM បានបញ្ជាក់ឡើងវិញថា ពួកគេត្រៀមខ្លួនជាស្រេចនៅក្នុងការប្រើប្រាស់គ្រប់ឧបករណ៍គោលនយោបាយទាំងអស់ រូបិយវត្ថុ សារពើពន្ធ និង រចនាសម្ព័ន្ធ រៀងខ្លួន និង រួមគ្នា តាមភាពចាំបាច់ ដើម្បីជំរុញទំនុកចិត្ត និងសម្រេចបាននូវកំណើនសេដ្ឋកិច្ចដែលមានភាពរឹងមាំ មានចីរភាព និង មានតុល្យភាព។ ដើម្បីសម្រេចគោលបំណងនេះ កិច្ចសហប្រតិបត្តិការនៅក្នុងចំណោមស្ថាប័នពហុភាគីរវាងអាស៊ី និង អឺរ៉ុប មានសារសំខាន់។

ភាពមិនច្បាស់លាស់ដែលត្រូវបានបង្កើតឡើងដោយ Brexit នៅអឺរ៉ុប និង ការដកសហរដ្ឋអាមេរិកចេញពីកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និង វឌ្ឍនភាពសម្រាប់ភាពជាដៃគូឆ្លងតំបន់ប៉ាស៊ីហ្វិកកំពុងតែត្រូវគេធ្វើការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃបញ្ហាទាំងនេះទៅលើការវិនិយោគ និង ពាណិជ្ជកម្មក្នុងតំបន់។ បញ្ហាទាំងនេះមានសភាពកាន់តែស្មុគស្មាញថែមទៀត ដោយសាររបាំងពន្ធគយដែលត្រូវបានដាក់ចេញដោយប្រទេសជាច្រើននៅជុំវិញពិភពលោក។ កំណើននៃការគាំទ្រលើការរឹតត្បិតផ្នែកពាណិជ្ជកម្មមានសភាពកាន់តែធ្ងន់ធ្ងរឡើងដោយសារកំណើននៃការគ្រប់គ្រងនៅតាមព្រំដែនចំពោះការផ្លាស់ទីរបស់ប្រជាជន។ នៅក្នុងស៊ីណារីយ៉ូដែលសកលភាវូបនីយកម្ម និង អត្ថប្រយោជន៍របស់សកលភាវូបនីយកម្មកំពុងតែមានភាពមិនច្បាស់លាស់នោះ អភិបាលកិច្ចជាសកល និង ប្រព័ន្ធពហុភាគីក៏កំពុងតែមានបញ្ហាផងដែរ។ នាពេលបច្ចុប្បន្ន ប្រព័ន្ធពហុភាគីនៃអភិបាលកិច្ច និង កិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ច

កំពុងតែមានភាពតានតឹង ដែលបណ្តាលមកពីសេដ្ឋកិច្ចខ្នាតធំភាគច្រើន។ គោលជំហរផ្ទាល់ខ្លួនចំពោះអាជីវកម្ម ពន្ធគយ ទំនាស់ និង កិច្ចសហប្រតិបត្តិការ កំពុងតែលុបពីលើប្រព័ន្ធអភិបាលកិច្ចពហុភាគី។ វិធីសាស្រ្តសម្របសម្រួលផ្នែកពាណិជ្ជកម្ម ដែលត្រូវបានចាត់ទុកថាជាមាគ៌ាសម្រាប់វិបុលភាពជាយូរមកហើយនោះ មានហានិភ័យចំពោះភាពយឺតយ៉ាវ ឬ ត្រូវបានគេមើលរំលង។ ចំណុចនេះអាចមានភាពអន្តរាយចំពោះប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ដូចគ្នានឹងនៅទ្វីបអាស៊ី និង អឺរ៉ុបដែរ។ ប្រទេសតូចជាង និង ងាយរងគ្រោះផ្នែកសេដ្ឋកិច្ចខ្លាំងជាង មានហានិភ័យនៃការមិនអើពើកាន់តែខ្លាំង។

អង្គភាពពហុភាគី ដូចជា អង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាដើម និង វេទិកាអន្តររដ្ឋាភិបាល និង វេទិកាមិនសូវផ្លូវការ ដូចជា G20 ជាដើម កំពុងតែដឹកនាំប្រទេសសមាជិក និងតំបន់របស់ពួកគេ ចូលរួមនៅក្នុងសមាហរណកម្មផ្នែកពាណិជ្ជកម្ម ការវិនិយោគ និងផ្នែកសេដ្ឋកិច្ច។ នៅខែធ្នូ ឆ្នាំ២០១៩ សេចក្តីថ្លែងការណ៍អំពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃ ASEM បានបញ្ជាក់អំពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមចម្បងៗ ដូចៗគ្នាជាសកល ដោយផ្អែកលើការប្តេជ្ញាចិត្តដ៏រឹងមាំចំពោះពហុភាគីនិយម។

នៅពេលដែលបទបញ្ញាជាអន្តរជាតិ ដែលផ្អែកលើនីតិរដ្ឋ និង ច្បាប់អន្តរជាតិកំពុងតែមានការលំបាកនោះ ដៃគូរបស់ ASEM បានធ្វើការអះអាងឡើងវិញអំពីការតាំងចិត្តរបស់ពួកគេចំពោះការប្រកាន់ខ្ជាប់ និង ពង្រឹងអភិក្រមនៃកិច្ចសហប្រតិបត្តិការ ពហុភាគី និង ពហុប្រទេស។ រដ្ឋមន្ត្រីទាំងឡាយបានផ្តល់អាទិភាពលើកិច្ចសហប្រតិបត្តិការដែលមានប្រពលភាពរបស់ ASEM ចំពោះវិធានការអាកាសធាតុដ៏ខ្លាំងក្លា និង បានស្នើសុំឲ្យមានសកម្មភាពបន្ថែមទៀតដើម្បីអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។ ASEM បានអះអាងឡើងវិញថាតម្រូវការក្នុងការប្រកាន់ខ្ជាប់ ពង្រឹង និង ធ្វើកំណែទម្រង់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើច្បាប់ ជាមួយ WTO គឺជាចំណុចសំខាន់ (ASEM ឆ្នាំ២០១៩)។ ASEM គួរតែឆ្លុះបញ្ចាំងអំពីយុទ្ធសាស្រ្តដែលមានបរិយាប័ន្ននេះនៅក្នុងការងាររបស់ខ្លួន ជាពិសេសនៅក្នុងយន្តការនៃការតភ្ជាប់។ ការតភ្ជាប់រវាងអាស៊ី អឺរ៉ុប អាចផ្តល់ការគាំទ្រដល់កម្មវិធីអភិបាលកិច្ច និងកិច្ចសហប្រតិបត្តិការជាសកល និង ពហុភាគីនិយមដោយផ្ទាល់ ដើម្បីជួយដល់ប្រទេសនានាឲ្យមានបរិយាប័ន្នកាន់តែខ្លាំងឡើង នៅក្នុងការអនុវត្តជាក់ស្តែង។ សកម្មភាពរបស់ ASEM អាចរួមចំណែកដោយផ្ទាល់ដល់ការងាររបស់ WTO និង G20 និង យន្តការគាំទ្រដើម្បីការតភ្ជាប់ផ្នែកសេដ្ឋកិច្ចដែលកាន់តែស៊ីជម្រៅជាងនេះទៀត និង GVCs រវាងអាស៊ី និង អឺរ៉ុប។

## បញ្ហាប្រឈមនៃការតភ្ជាប់ និង សន្តិសុខរបស់ ASEM

ASEM តែងតែបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួននៅក្នុងការថែរក្សាសន្តិភាព និង ស្ថេរភាព និង ធានាបាននូវសន្តិសុខ និង សុវត្ថិភាពផ្លូវសមុទ្រ។ មានកាលានុវត្តភាព និង បញ្ហាប្រឈមជាច្រើនដែលអាស៊ី និង អឺរ៉ុបប្រឈមមុខ នៅក្នុងពិភពលោកដែលមានការប្រែប្រួលកាន់តែខ្លាំងឡើងនេះ។ កិច្ចសហប្រតិបត្តិការដំបូងគេបង្អស់របស់ ASEM គឺសេរីភាពក្នុងការចង្អុលបង្ហាញទិសដៅ និង សកម្មភាពសេដ្ឋកិច្ចដែលគ្មានការរារាំង ដែលមានការចាប់ អារម្មណ៍ពីសំណាក់ប្រទេសដៃគូទាំងអស់។ ការប្តេជ្ញាចិត្តរបស់ ASEM ចំពោះការដោះស្រាយវិវាទដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និង គោរពដំណើរការការទូត គឺជាមូលដ្ឋានគ្រឹះដើម្បីលើកកម្ពស់វិធីសាស្រ្តបង្កើនទំនុកចិត្តនៅក្នុងតំបន់។

ASEM បានរួមបញ្ចូលការគ្រប់គ្រងជំងឺឆ្លងជាចំណុចគោលដ៏សំខាន់មួយសម្រាប់ដៃគូរបស់ ASEM នៅក្នុងការផ្លាស់ប្តូរមេរៀនដែលទទួលបាន និង ឧត្តមានុវត្តស្តីពីវិធីប្រយុទ្ធប្រឆាំងនឹងហានិភ័យនៃជំងឺរាតត្បាតសកលដែលកំពុងតែមានការកើនឡើង និង វិធីធានាបាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិដែលល្អប្រសើរជាងមុន។

ជំងឺរាតត្បាតសកលនាពេលបច្ចុប្បន្នបានធ្វើឲ្យតំបន់នេះមានត្រូវការជាចាំបាច់នូវកិច្ចសហប្រតិបត្តិការរបស់ ASEM ផ្នែកសេវាកម្មនានាដែលទាក់ទងនឹងសុខភាព ការវិនិយោគលើផលិតកម្ម និង ពាណិជ្ជកម្មផ្នែកឱសថ និង បរិក្ខារពេទ្យ។ ចំណុចនេះក៏រួមបញ្ចូលកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវអំពីការប្រយុទ្ធប្រឆាំងនឹងជំងឺផងដែរ។ ជាពិសេស ជំងឺរាតត្បាតសកល កូវីដ-១៩ គួរតែជំរុញឲ្យ ASEM ផ្តួចផ្តើមគំនិតរៀបចំផែនការសកម្មភាពដែលមានពេលវេលាកំណត់ សម្រាប់ការអភិវឌ្ឍ និង ការចែកចាយថ្នាំបង្ការតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និង ពហុភាគីរវាងអាស៊ី និង អឺរ៉ុប។

ជំងឺរាតត្បាតសកល កូវីដ-១៩ ក៏បានគូសបញ្ជាក់អំពីសារសំខាន់នៃសន្តិសុខស្បៀងផងដែរ។ ដៃគូរបស់ ASEM ត្រូវតែបង្កើតយន្តការនានាដើម្បីធានាបាននូវសន្តិសុខស្បៀងសម្រាប់មនុស្សជំនាន់ក្រោយៗទៀត រួមបញ្ចូលទាំងការស្រាវជ្រាវ និង ការអភិវឌ្ឍផលិតភាពកសិកម្ម ទម្លាប់អនុវត្តផ្នែកកសិកម្ម ការអភិរក្សកសិជីវចម្រុះ និង ការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

កិច្ចសហប្រតិបត្តិការរបស់ ASEM ចំពោះផ្នែកបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) និង ការតភ្ជាប់តាមបែបឌីជីថលដើម្បីមជ្ឈដ្ឋាន ICT ជាសកលដែលប្រកបដោយសន្តិភាព ភាពបើក

ចំហរ ស្ថេរភាព និង សន្តិសុខ ត្រូវបានចាត់ទុកថាមានសារសំខាន់ចំពោះការការពារសិទ្ធិមនុស្ស និង សេរីភាពអនឡាញ និង គោរពក្របខណ្ឌច្បាប់ជាតិ និង អន្តរជាតិដែលពាក់ព័ន្ធ។ តម្រូវការស្ថេរភាព និង សន្តិសុខនៅក្នុងលំហអ៊ីនធឺណិតដោយផ្អែកលើច្បាប់អន្តរជាតិ បទដ្ឋានសកល និង វិធានា និង គោលការណ៍នានាដែលពាក់ព័ន្ធ ចំពោះអាកប្បកិរិយារបស់រដ្ឋដែលមានទំនួលខុសត្រូវ គឺមានភាពចាំបាច់សម្រាប់ ASEM ដែលត្រៀមខ្លួនជាស្រេចសម្រាប់ថ្ងៃអនាគត។

នៅពេលដែលឌីជីថលនីយកម្មកំពុងតែផ្លាស់ប្តូរគ្រប់ទិដ្ឋភាពទាំងអស់នៃសេដ្ឋកិច្ច និង សង្គមរបស់យើងនោះទិន្នន័យក៏ក្លាយជាប្រភពដែលមានសារសំខាន់កាន់តែខ្លាំងចំពោះកំណើនសេដ្ឋកិច្ច និង សុខមាលភាពសង្គម ហើយការប្រើប្រាស់ទិន្នន័យយ៉ាងមានប្រសិទ្ធភាពគួរតែរួមចំណែកដល់ការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប និង ភាពរីកចម្រើនទៅវិញទៅមក។ ឧទាហរណ៍៖ ASEM គឺជាកន្លែងដែលមានឧទាហរណ៍ល្អប្រសើរនៃការការពារទិន្នន័យ និង សន្តិសុខអ៊ីនធឺណិត នៅ EU ចក្រភពអង់គ្លេស ប្រទេសឥណ្ឌា ប្រទេសអូស្ត្រាលី និង ប្រទេសជប៉ុន។ ការតភ្ជាប់ ASEM អាច និង ត្រូវតែជាវេទិកាប្រចាំតំបន់ដែលមានសារប្រយោជន៍ ដើម្បីលើកកម្ពស់សន្តិសុខទិន្នន័យ និង លំហូរទិន្នន័យដោយសេរី និង គួរឲ្យទុកចិត្ត ដោយគោរពក្របខណ្ឌច្បាប់ជាតិ និង អន្តរជាតិដែលពាក់ព័ន្ធចំពោះឯកជនភាព និង ការការពារទិន្នន័យ។

ការតភ្ជាប់នេះនឹងកាត់បន្ថយជាអប្បបរមានូវហានិភ័យដែលបណ្តាលមកពីការប្រើប្រាស់ ITC។

## ចក្ខុវិស័យផ្អែកយុទ្ធសាស្ត្រចំពោះសហគមន៍ ASEM៖ ការតភ្ជាប់គ្រប់ជ្រុងជ្រោយ មានចីរភាព និង ផ្អែកលើច្បាប់

នៅខណៈពេលដែលកិច្ចប្រជុំកំពូល ASEM ត្រូវរៀបចំឡើងនៅក្នុងឆ្នាំ២០២១ នោះ ជំងឺរាតត្បាតសកល កូវីដ-១៩ នឹងរាតត្បាតប្រជាជនជាច្រើននាក់ និង មានផលប៉ះពាល់អវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចនៅក្នុងផ្នែកភាគច្រើននៃពិភពលោក។ ដូច្នេះ ទ្វីបអាស៊ី និងអឺរ៉ុបត្រូវតែរៀបចំផែនការសម្រាប់ថ្ងៃអនាគតដែលមានបញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា សន្តិសុខ និង ចីរភាព និង ភាពតក់ស្លុតដែលបង្កឡើងដោយជំងឺរាតត្បាតសកល កូវីដ-១៩ ដែលត្រូវបានដោះស្រាយតាមរយៈសកម្មភាពសមូហភាព។ ដើម្បីបន្តអនុវត្តតាមមូលដ្ឋាននៃកំណើនប្រកបដោយចីរភាព និង បរិយាប័ន្ននៅក្នុងរយៈពេលវែង និង ពង្រឹងការទំនាក់ទំនងនៅក្នុងចំណោមដៃគូនោះ ASEM តម្រូវឲ្យមានការឆ្ពោះទៅកាន់គោលដៅរួមមួយនៅក្នុងវិស័យសេដ្ឋកិច្ច ដើម្បីដោះស្រាយបញ្ហាប្រឈមដូចគ្នា តាមរយៈការតភ្ជាប់ដែលមានភាពគ្រប់ជ្រុងជ្រោយ និង ផ្អែកលើច្បាប់។ តម្រូវឲ្យមាន វិធាន និង បទប្បញ្ញត្តិនានាដើម្បីធ្វើឲ្យប្រជាជន ទំនិញ សេវាកម្ម និង មូលធន

ផ្លាស់ទីបានយ៉ាងមានប្រសិទ្ធភាព ស្មើភាព និង រលូន។ ទម្លាប់អនុវត្ត វិធាន អនុសញ្ញា និង បទដ្ឋានបច្ចេកទេសដែលបានព្រមព្រៀងជាអន្តរជាតិ ដែលបានទទួលការគាំទ្រពីអង្គការ និង ស្ថាប័នអន្តរជាតិ អនុញ្ញាតឲ្យមានអន្តរប្រតិបត្តិការរវាងបណ្តាញនានា និង ការធ្វើពាណិជ្ជកម្មឆ្លងព្រំដែន។ ការមិនរើសអើង និង ទីផ្សាប្រកួតប្រជែងនៅកម្រិតមួយសម្រាប់សហគ្រាស និង មជ្ឈដ្ឋាននៃការវិនិយោគដែលមានភាពបើកចំហរ និង មានតម្លាភាព គឺជាផ្នែកមួយនៃស្ថានប្រព័ន្ធ ដែលផ្អែកលើច្បាប់។ ទ្វីបអឺរ៉ុប និង អាស៊ីត្រូវតែបង្កើតភាពជាដៃគូដើម្បីការតភ្ជាប់ដែលផ្អែកលើ វិធាន និង បទដ្ឋានដែលមានការព្រមព្រៀងរួមគ្នា ដើម្បីធ្វើឲ្យមានអភិបាលកិច្ចដែលកាន់តែល្អ ប្រសើរឡើងសម្រាប់លំហូរនៃទំនិញ ប្រជាជន មូលធន និង សេវាកម្ម។ ចំណុចនេះអាចនឹងរួមបញ្ចូលការប្រមូលផ្តុំធនធានបានល្អប្រសើរជាងមុន និង ភាពជាដៃគូអន្តរជាតិដែលមានអានុភាព និង មានភាពរឹងមាំជាងមុនផងដែរ (គណៈកម្មការអឺរ៉ុប ឆ្នាំ២០១៨)។

ASEM អាចជំរុញឲ្យមានគុណតម្លៃរួម ដែលផ្តល់ការគាំទ្រដល់គំរូនានានៃប្រជាធិបតេយ្យ និង សង្គម ដែលជាមូលដ្ឋានគ្រឹះនៃសេរីភាព សន្តិភាព និង វិបុលសុខរបស់ប្រជាជនអឺរ៉ុប និង អាស៊ី។ នីតិរដ្ឋគឺជាការធានាដ៏សំខាន់មួយសម្រាប់កិច្ចការពារ និង ការថែទាំគុណតម្លៃទាំងនេះ។ ទស្សនវិស័យរបស់អឺរ៉ុប និង អាស៊ីចំពោះសមាហរណកម្ម មានលក្ខណៈខុសគ្នា ប៉ុន្តែតំបន់ទាំងពីរប្តេជ្ញាចិត្តលើកកម្ពស់ និង ការពារសិទ្ធមនុស្ស ប្រជាធិបតេយ្យ និង នីតិរដ្ឋ។ EU ជាពិសេស បានប្តេជ្ញាចិត្តការពារសិទ្ធិមនុស្សតាមរយៈភាពជាដៃគូដ៏សកម្មជាមួយប្រទេសជាដៃគូ និង អង្គការអន្តរជាតិ និង អង្គការនៅក្នុងតំបន់។ ASEM មានឱកាសក្លាយជាវេទិកាមួយសម្រាប់ការលើកកម្ពស់សិទ្ធិមនុស្ស ជាពិសេស សិទ្ធិរបស់ស្ត្រី កុមារ ជនជាតិដើមភាគតិច និង ជនភៀសខ្លួន ដែលជាចំណុចសំខាន់នៃទំនាក់ទំនងរវាង EU ជាមួយប្រទេស និង តំបន់ដទៃទៀត (EU ឆ្នាំ២០២០)។ ASEM ក៏អាចដើរតួជាវេទិកាមួយ ដើម្បីសម្រេចបាននូវគោលដៅអនុវត្តនៃគោលដៅទី ១៦ (សន្តិភាព យុត្តិធម៌ និង ស្ថាប័នរឹងមាំ) និង គោលដៅទី ១៧ (ភាពជាដៃគូដើម្បីការអភិវឌ្ឍ) នៃ SDGs នៅតំបន់អាស៊ី និង អឺរ៉ុបផងដែរ។

## ASEM នៅឆ្នាំ២០២១ និង ឆ្នាំបន្តបន្ទាប់ទៀត

កិច្ចសហប្រតិបត្តិការ និង ភាពជាដៃគូដើម្បីពហុភាគីនិយមដ៏រឹងមាំ និង មានប្រសិទ្ធភាព និង បទបញ្ញាអន្តរជាតិដែលផ្អែកលើច្បាប់ គឺជាស្មារតីនៃមគ្គុទ្ទេសក៍ណែនាំរបស់ ASEM។ សសរស្តម្ភទាំងបីនៃការភ្ជាប់របស់ ASEM ៖ រូបវ័ន្ត សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វប្បធម៌សង្គម បានជួយដល់ ASEM នៅក្នុងការសម្រេចបាននូវវត្ថុបំណងផ្នែកសន្តិភាព និង សន្តិសុខ ការអភិវឌ្ឍ និង កំណើនប្រកបដោយបរិយាប័ន្ន និង ចីរភាព និង ការលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស

ដោយអនុលោមតាមច្បាប់អន្តរជាតិ។ នៅពេលដែលប្រទេសទាំងឡាយងើបចេញពីជំងឺរាតត្បាតសកល កូវីដ-១៩ វិញនោះ សេដ្ឋកិច្ច និង ប្រជាជនរបស់ពួកគេនឹងត្រូវការអភិក្រមដែលមានបរិយាប័ន្ន និងមានការបែងចែក ដើម្បីភាពរីកចម្រើននាពេលអនាគត សុខភាព និង សុវត្ថិភាពការងារ និង ការថែទាំមនុស្សចាស់ និង កិច្ចខិតខំប្រឹងប្រែងបន្តទៀតដើម្បីពង្រឹង និង ធ្វើកំណែទម្រង់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើច្បាប់។ ភាពជាដៃគូដ៏សំខាន់មួយសម្រាប់ការស្រាវជ្រាវ និង ការអភិវឌ្ឍវិស័យសុខាភិបាលសាធារណៈ ផលិតកម្ម និង ការចែកចាយថ្នាំបង្ការ និង បរិក្ខារពេទ្យ និង ការបង្កើតខ្សែសង្វាក់ផ្គត់ផ្គង់ដែលមានភាពធន់ រវាងអាស៊ី និង អឺរ៉ុប នឹងក្លាយជាសកម្មភាពចម្បងៗរបស់ ASEM នៅក្នុងឆ្នាំក្រោយៗទៀត។ ការងើបចេញពីជំងឺរាតត្បាតសកលទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុបនិងសកម្មភាពរបស់ASEMត្រូវតែពង្រឹងភាពធន់របស់ខ្លួន និងបង្កលក្ខណៈឱ្យមានការចូលរួមពីស្ត្រី និងយុវជនដែលមិនទាន់បានពាក់ព័ន្ធ នៅក្នុងកិច្ចសហប្រតិបត្តិការ និងសកម្មភាពជាដៃគូនានារបស់ ASEM។

មុនពេលមានជំងឺរាតត្បាតសកល កូវីដ-១៩ ពាណិជ្ជកម្មអន្តរជាតិ និង ការផ្លាស់ទីឆ្លងព្រំដែនរបស់ប្រជាជនគឺជាប្រព័ន្ធនៃការតភ្ជាប់ជាសកល។ នៅពេលនេះ គ្រប់តំបន់ទាំងអស់នៅលើពិភពលោកកំពុងតែប្រឈមមុខនឹងការរំខាន និង ការបែកបាក់ខ្សែសង្វាក់ផ្គត់ផ្គង់ ព្រមទាំងការរឹតត្បិតលើការផ្លាស់ទីឆ្លងព្រំដែនរបស់ប្រជាជនផងដែរ។ សកម្មភាពសេដ្ឋកិច្ចបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ នៅក្នុងចក្ខុវិស័យសេដ្ឋកិច្ចពិភពលោកលើកចុងក្រោយបង្អស់ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានលើកឡើងថា "នៅឆ្នាំនេះ សេដ្ឋកិច្ចពិភពលោកនឹងមានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរបំផុត ដោយសារវិបត្តិឱនភាពសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ដែលធ្ងន់ធ្ងរជាងវិបត្តិសេដ្ឋកិច្ច ដែលត្រូវគេមើលឃើញក្នុងអំឡុងពេលកើតវិបត្តិហិរញ្ញវត្ថុសកល កាលពីមួយទសវត្សរ៍មុន" (IMF ឆ្នាំ២០២០: v)។ ស្ថានភាពជំងឺរាតត្បាតសកលនាពេលអនាគតគឺមិនច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសារសំខាន់ក្នុងការរំឭកដល់ប្រទេសដៃគូរបស់ ASEM អំពីវិបុលភាពដែលការតភ្ជាប់បាននាំមកកាន់ពិភពលោក។ សម្រាប់ការឆ្ពោះទៅឆ្នាំ២០២១ និងទៅអនាគត ការយកចិត្តទុកដាក់លើភាពធន់ និងចីរភាពនៃការតភ្ជាប់របស់ ASEM គឺជារឿងដ៏សំខាន់មួយ។ អនាគតរបស់ ASEM ស្ថិតនៅលើភាពជាដៃគូដែលផ្អែកលើច្បាប់ មានភាពធន់ និង ប្រកបដោយបរិយាប័ន្ន រវាងអាស៊ី និង អឺរ៉ុប។

**សេចក្តីថ្លែងអំណរគុណ៖** *អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ការគាំទ្ររបស់លោក Rudhian Chlissma Putra ជំនួយការផ្នែកស្រាវជ្រាវនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និង អាស៊ីបូព៌ា ក្នុងការបង្កើតរូបភាព និង តារាងសម្រាប់ជំពូកនេះ។*

# ឯកសារយោង

ADB (2018), *Asian Development Outlook 2018: How Technology Affects Jobs.* Manila: Asian Development Bank.

ASEAN (2015), *The ASEAN ICT Masterplan 2020: Propelling ASEAN Towards a Digitally Enabled Economy that Is Secure, Sustainable, and Transformative; and Enabling an Innovative, Inclusive and Integrated ASEAN Community.* Jakarta: ASEAN Secretariat.

ASEF (2019), *Annual Report 2019.* Singapore: Asia–Europe Foundation.

ASEM (2018), 'Global Partners for Global Challenges', Chair's Statement, 12th Asia–Europe Meeting, Brussels, 18–19 October.

ASEM (2019), 'Chair's Statement, 16 December 2019', 14th ASEM Foreign Ministers' Meeting, Madrid, 15–16 December.

Becker, W., M. Dominguez-Torreiro, A.R. Neves, C.J. Tacao Moura, and M. Saisana (2018), *Exploring ASEM Sustainable Connectivity: What Brings Asia and Europe Together?* Ispra: European Commission, Joint Research Centre.

EU (2020), *Human rights and democracy. EU official website.* https://europa.eu/european- union/topics/human-rights_en#:~:text=Human%20rights%20are%20at%20the%20heart%20 of%20EU,defending%20civil%2C%20political%2C%20economic%2C%20social%20and%20 cultural%20rights (accessed 11 September 2020).

European Commission (2018), 'Connecting Europe and Asia – Building Blocks for an EU Strategy', Joint Communication to the European Parliament, the Council, the European Economic and Social Committee, the Committee of the Regions and the European Investment Bank. Brussels: European Commission.

European Council (2019), *A New Strategic Agenda, 2019–2024. Brussels:* European Council.

Eurostat (2020), *Sustainable Development in the European Union: Monitoring Report on Progress Towards the SDGs in an EU Context,* 2019 Edition. Luxembourg: European Union.

IMF (2020), *World Economic Outlook, April 2020: The Great Lockdown.* Washington, DC: International Monetary Fund.

International Labour Organization (2019), *Global Employment Trends for Youth 2020: Technology and the Future of Jobs.* Geneva: International Labour Organisation.

OECD (2020), 'Tackling Coronavirus (COVID-19): Contributing to a Global Effort – COVID-19 in Emerging Asia: Regional Socio-Economic Implications and Policy Priorities'. Paris: Organisation for Economic Co-operation and Development.

Prakash, A., ed. (2016), *Asia–Europe Connectivity Vision 2025: Challenges and Opportunities.* Jakarta: Economic Research Institute for ASEAN and East Asia and Government of Mongolia.

Prakash, A. (2019), 'Industrialization and Growth in Digital Age: Disruptions and Opportunities for Employment Led Growth in Asia and Africa', T 20, Task Force 7: The Future of Work and Education for the Digital Age, G20, Japan.

Secretariat for ASEM Duo Fellowship (2017), 'Progress Report: ASEM-DUO Fellowship Programme'. Seoul: Secretariat for ASEM Duo Fellowship.

Statista (2020), eCommerce. https://www.statista.com/outlook/243/100/ecommerce /(accessed 24 August 2020).

UNCTAD (2019), *'UNCTAD B2C E-Commerce Index 2019', UNCTAD Technical Notes on ICT for Development,* No. 14. Geneva: United Nations Conference on Trade and Development.

UNESCAP (2020), *Asia and the Pacific: SDG Progress Report.* Bangkok: United Nations Economic and Social Commission for Asia and the Pacific.

World Bank (2020a), *From Containment to Recovery,* Economic Update for East Asia and the Pacific, October 2020. Washington, DC: World Bank. https://www.worldbank.org/en/ region/eap/publication/east-asia-pacific-economic-update (accessed 30 April 2020).

World Bank (2020b), World Bank Open Data, GDP growth (annual %). https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?view=chart (accessed 8 September 2020).

World Bank (2020c), World Bank Open Data, Merchandise Imports. https://data.worldbank. org/indicator/TX.VAL.MRCH.CD.WT?view=chart (accessed 8 September 2020).

World Bank (2020d), World Bank Open Data, Merchandise Exports. https://data.worldbank. org/indicator/TX.VAL.MRCH.CD.WT?view=chart (accessed 8 September 2020).

2

# ផែនការការតភ្ជាប់សម្រាប់អាស៊ី និង អឺរ៉ុប

## ទំនិញសាធារណៈ និង កំណើនជាសមូហភាព

ANITA PRAKASH

FRANS-PAUL VAN DER PUTTEN*

ការតភ្ជាប់នៅថ្នាក់តំបន់កំពុងតែមានការកើនឡើងនៅជុំវិញពិភពលោក។ អាស៊ី អាហ្វ្រិក និង អឺរ៉ុប ព្រមទាំងទ្វីបដទៃទៀត កំពុងតែមានអន្តរទំនាក់ទំនងកាន់តែខ្លាំងឡើង តាមរយៈគំនិតផ្តួចផ្តើមតំបន់រួម។ ពាក់ព័ន្ធនឹងចំណុចនេះ ទ្វីបអាស៊ីគឺជាអ្នកត្រួសត្រាយផ្លូវ ហើយផែនការតភ្ជាប់ភាគច្រើនមានទ្វីបអាស៊ីជាចំណុចស្នូល។

ទ្វីបអាស៊ីក៏ជាចំណុចកណ្តាលនៃគំនិតផ្តួចផ្តើមតភ្ជាប់តំបន់រួមនេះផងដែរ។ ផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និង ផ្លូវ (BRI) ច្រករបៀងនៃកំណើនរវាងអាស៊ី-អាហ្វ្រិក និង កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ផែនការតភ្ជាប់ទាំងអស់ មានបំណងធ្វើឲ្យថាមវន្តនៃវិស័យសេដ្ឋកិច្ចរបស់អាស៊ីមានលក្ខណៈស៊ីជម្រៅ និង ពង្រីកថាមវន្តនោះទៅកាន់ដៃគូឆ្លងតំបន់។ គំនិតផ្តួចផ្តើមធ្វើសមាហរណកម្មនៅតាមតំបន់ធំៗ ដូចជា កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និង វឌ្ឍនភាពសម្រាប់ភាពជាដៃគូឆ្លងតំបន់ប៉ាស៊ីហ្វិក និង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយប្រចាំតំបន់ ជាដើម ក៏មានសារសំខាន់ចំពោះតំបន់នេះដែរ។

ភាពចាំបាច់នៃការតភ្ជាប់ដ៏រឹងមាំរវាងអាស៊ី និង អឺរ៉ុបត្រូវបានទទួលស្គាល់ដោយ ASEM ចាប់តាំងពីកិច្ចប្រជុំកំពូល ASEM លើកទី ១០ នៅឆ្នាំ២០១៤ នៅប្រទេសអ៊ីតាលី មកម្ល៉េះ។ ASEM គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយដើម្បីឆ្ពោះទៅដោះស្រាយតម្រូវការនៃការតភ្ជាប់កាន់តែខ្លាំងក្លាឡើងនៅក្នុងចំណោម ភូមិសាស្ត្រ សេដ្ឋកិច្ច និង ប្រជាជនទាំងឡាយនៅ អាស៊ី និង អឺរ៉ុប។

* ផ្នែកដែលនិយាយអំពីគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវថ្នល់ ត្រូវបានសរសេរដោយ Frans-Paul van der Puten នៃវិទ្យាស្ថាន Clingendael ដោយមានការស្រាវជ្រាវអំពីសាវតា ដែលត្រូវបានធ្វើឡើងដោយ Xiaoxue Martin នៃវិទ្យាស្ថាន Clingendael។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១០ នៅឆ្នាំ២០១៤ នៅក្នុងប្រទេសអ៊ីតាលី "ថ្នាក់ដឹកនាំបានគូសបញ្ជាក់អំពីសារសំខាន់នៃការតភ្ជាប់រវាងតំបន់ពីរ ដើម្បីវិបុលភាពផ្នែកសេដ្ឋកិច្ច និង ការអភិវឌ្ឍប្រកបដោយចីរភាព" (ASEM ឆ្នាំ២០១៤៖ កថាខណ្ឌ ទី៧)។ កិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅឆ្នាំ២០១៦ នៅ Ulaanbaatar បានព្រមព្រៀងគ្នាធ្វើឲ្យ ASEM មានការឆ្លើយតបទៅនឹងតម្រូវការ និង ភាពចាំបាច់នៃការតភ្ជាប់ដែលកំពុងតែលេចឡើង ហើយដើម្បីសម្រេចគោលបំណងនេះ បានបង្កើតក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្តីពីការតភ្ជាប់ (APGC)។

## ផែនការតភ្ជាប់ ASEM៖ ប្រភពដើម វឌ្ឍនភាព និង រដ្ឋបច្ចុប្បន្នរបស់ខ្លួន

ក្របខណ្ឌកិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុប (AECF) ឆ្នាំ២០០០ កំណត់ចក្ខុវិស័យសម្រាប់ការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប នៅក្នុងបរិបទ ASEM។ ក្របខណ្ឌនេះបានសម្គាល់ឃើញវិស័យអាទិភាពចំនួនបីសម្រាប់កិច្ចសហប្រតិបត្តិការរបស់ ASEM៖ នយោបាយ សេដ្ឋកិច្ច និង វប្បធម៌សង្គម។ ក្របខណ្ឌនេះបានបញ្ជាក់អំពីយន្តការលម្អិតសម្រាប់ការសម្របសម្រួល ការផ្តោត និង ការគ្រប់គ្រងសកម្មភាពរបស់ ASEM។ កិច្ចប្រជុំរដ្ឋមន្ត្រី និង កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ ASEM នាពេលបច្ចុប្បន្នដែលសម្របសម្រួលលទ្ធផលនៃការតភ្ជាប់របស់ ASEM ភាគច្រើន ត្រូវបានរៀបចំឡើងនៅក្នុង AECF ឆ្នាំ២០២០។

ដោយត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទីបីនៅសាធារណរដ្ឋកូរ៉េ (ចាប់តាំងពីពេលនោះមក ប្រទេសកូរ៉េ) AECF បានទទួលស្គាល់ថា ASEM ត្រូវបានផ្តួចផ្តើមឡើងដោយមានបំណងពង្រឹងទំនាក់ទំនងរវាងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប។ ដៃគូរបស់ ASEM បានយល់ព្រមធ្វើការរួមគ្នាដើម្បីលើកកម្ពស់លក្ខខណ្ឌនានាដែលអនុគ្រោះដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមប្រកបដោយចីរភាព។ ថ្នាក់ដឹកនាំរបស់ ASEM បានចាត់ទុកទ្វីបអាស៊ី និង អឺរ៉ុបជាកន្លែងអភិវឌ្ឍដោយសន្តិភាព និង ការចែករំលែក ដោយមានចំណាប់អារម្មណ៍ និង សេចក្តីរំពឹងទុកដូចគ្នា - ការប្រកាន់ខ្ជាប់នូវគោលបំណង និង គោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ គោរពប្រជាធិបតេយ្យ នីតិរដ្ឋ សមធម៌ យុត្តិធម៌ និង សិទ្ធិមនុស្ស កង្វល់អំពីបរិស្ថាន និង បញ្ហាសកលដទៃទៀត កាត់បន្ថយភាពក្រីក្រ ការពារកេរ្តិ៍ដំណែលវប្បធម៌ និង លើកកម្ពស់ការខិតខំប្រឹងប្រែងផ្នែកប្រាជ្ញាស្មារតី ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ចំណេះដឹង និង ធនធាននៃការអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ពាណិជ្ជកម្ម ការវិនិយោគ និង សហគ្រាស។

ដើម្បីសម្រេចគោលបំណងនេះ ASEM បានរៀបចំផែនការលម្អិតមួយសម្រាប់ទ្វីបអាស៊ី និង អឺរ៉ុបដើម្បីបង្កើតភាពជាដៃគូគ្រប់ជ្រុងជ្រោយ និង តម្រង់ទិសទៅថ្ងៃអនាគត។ ទម្រង់សង្ខេបអំពីកិច្ច

សន្ទនា និង កិច្ចប្រឹងប្រែងរួមគ្នា ដែលទាក់ទងនឹងបញ្ហានយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និង ការអប់រំត្រូវបានបង្កើតឡើង។ ចំណុចសំខាន់ ដៃគូរបស់ ASEM បានទទួលស្គាល់អំពីភាពចាំបាច់ក្នុងការធ្វើការជាមួយគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗដែលបណ្តាលមកពីនៅក្នុងចំណោមមូលហេតុដទៃទៀត សកលភាវូបនីយកម្ម បច្ចេកវិទ្យាព័ត៌មាន ពាណិជ្ជកម្ម អេឡិចត្រូនិក និង សេដ្ឋកិច្ចថ្មី នៅពេលត្រូវបានគេស្គាល់កាន់តែទូលំទូលាយជាងមុនថាជា សេដ្ឋកិច្ចឌីជីថល។

នៅក្នុងវិស័យនយោបាយ កិច្ចខិតខំប្រឹងប្រែងរបស់ ASEM បានផ្តោតលើបញ្ហាផលប្រយោជន៍រួម ប៉ុន្តែត្រូវបាននាំផ្លូវដោយដំណើរការនៃការបង្កើតការព្រមព្រៀងជាឯកច្ឆន្ទ។ នៅក្នុងនាមជាវេទិកាមិនផ្លូវការ វត្ថុបំណងនៃការតភ្ជាប់ផ្នែកនយោបាយរបស់ ASEM នឹងត្រូវគេទទួលស្គាល់តាមរយៈការយល់ដឹង និង ការយោគយល់ទៅវិញទៅមករបស់ដៃគូទាំងឡាយ។ គ្រប់បញ្ហាទាំងអស់ត្រូវបានលើកយកមកពិភាក្សា ប៉ុន្តែមានការប្រើប្រាស់ សុភវិនិច្ឆ័យ និង វិចារណញ្ញាណនៅក្នុងការជ្រើសរើសប្រធានបទ ដើម្បីយកមកពិភាក្សា និង សហការគ្នា។ កិច្ចសន្ទនាផ្នែកនយោបាយដែលត្រូវបានរៀបចំឡើងដោយដៃគូរបស់ ASEM នឹងត្រូវកំណត់តាមគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក សមភាព ការលើកកម្ពស់សិទ្ធិមូលដ្ឋាន និង ស្របតាមវិធាននៃច្បាប់អន្តរជាតិ និង កាតព្វកិច្ចនានា ពុំមានការធ្វើអន្តរាគមន៍លើការងារផ្ទៃក្នុងរបស់ដៃគូនីមួយៗនោះទេ ទោះបីជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី។

អាទិភាពសំខាន់ៗ រួមមាន (i) កិច្ចសន្ទនាផ្នែកនយោបាយនៅកម្រិតខ្ពស់នៅក្នុងកិច្ចប្រជុំឧត្តមមន្ត្រី (SOM) ស្តីពីបញ្ហាផលប្រយោជន៍រួម ដែលកើតឡើងនៅក្នុងបរិបទនៃស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធ និង (ii) ការពង្រឹងកិច្ចសន្ទនាផ្នែកនយោបាយមិនផ្លូវការស្តីពីបញ្ហាផលប្រយោជន៍រួមនៅថ្នាក់តំបន់ និង អន្តរជាតិ នៅក្នុងសិក្ខាសាលា និង កិច្ចប្រជុំផ្លាស់ប្តូរយោបល់របស់ ASEM ដែលត្រូវបានស្នើឡើងដោយដៃគូនីមួយៗ និង ត្រូវបានអនុម័តដោយ SOM នៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ នយោបាយ និង សេដ្ឋកិច្ច។ បញ្ហាសកលដែលជាកង្វល់រួម ចំពោះ ASEM មានដូចជា៖

- ពង្រឹងកិច្ចខិតខំប្រឹងប្រែងនៅក្នុងបរិបទសកល និង បរិបទតំបន់ ចំពោះ ការគ្រប់គ្រងអាវុធ ការរំសាយសព្វាវុធ និង ការមិនរីកសាយនៃអាវុធធុនធ្ងន់
- លើកកម្ពស់សុខមាលភាពរបស់ស្ត្រី និង កុមារ
- ពង្រឹងកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការរបស់ ASEM ចំពោះបញ្ហាសកលដទៃទៀត ដូចជាការអភិវឌ្ឍធនធានមនុស្ស ការកែលម្អការថែទាំសុខភាពនៅតាមសហគមន៍ និង សន្តិសុខស្បៀង និង ការផ្គត់ផ្គង់

- ដោះស្រាយបញ្ហាបរិស្ថានជាសកល ដោយខិតខំប្រឹងប្រែងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និង គាំទ្រការងាររបស់មជ្ឈមណ្ឌលបច្ចេកវិទ្យាបរិស្ថាននៃអាស៊ី-អឺរ៉ុប
- គ្រប់គ្រងលំហូរនៃទេសន្តរប្រវេសន៍នៅក្នុងពិភពលោកដែលមានសកលភាវូបនីយកម្ម
- ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន រួមមាន ការសម្អាតប្រាក់ ការរត់ពន្ធ និង ការកេងប្រវ័ញ្ចលើជនទេសន្តរប្រវេសន៍ ការជួញដូរមនុស្ស (ជាពិសេសស្ត្រី និង កុមារ) ភេរវកម្មអន្តរជាតិ និង ចោរសមុទ្រ និង ការប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន និង
- ប្រយុទ្ធប្រឆាំងនឹងការរើសអើងជាតិសាសន៍ និង ការស្អប់ជនបរទេស។

នៅក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កិច្ចខិតខំប្រឹងប្រែងរបស់ ASEM បានផ្តោតលើការពង្រឹងកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការរវាងតំបន់ពីរ ដោយមានបំណងជួយសម្រួលដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមចំណែកជាមួយគ្នាដល់កិច្ចសន្ទនាអំពីសេដ្ឋកិច្ចជាសកល និង ដោះស្រាយផលប៉ះពាល់នៃសកលភាវូបនីយកម្ម។

នៅក្នុងបរិបទនេះ អាទិភាពចម្បងៗ រួមមាន កិច្ចសន្ទនានៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច និង កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីពាណិជ្ជកម្ម និង ការវិនិយោគ (SOMTI) ដែលពាក់ព័ន្ធជាពិសេសនឹងការពង្រឹងការបើកចំហរ និង ប្រព័ន្ធពាណិជ្ជកម្មពហុភាគីផ្អែកលើច្បាប់ ដូចមានចែងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ ការពង្រឹងលំហូរនៃពាណិជ្ជកម្ម និង ការវិនិយោគពីរផ្លូវ រវាងអាស៊ី និង អឺរ៉ុប គឺជាផែនការសកម្មភាពដ៏សំខាន់ ដែលត្រូវបានកត់សម្គាល់តាមរយៈការអនុវត្ត និង ការពង្រឹងផែនការសកម្មភាពនៃការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និង ការលើកកម្ពស់ការវិនិយោគ។ តួនាទីរបស់វេទិកាពាណិជ្ជកម្មអាស៊ី-អឺរ៉ុប និង សារសំខាន់របស់វេទិកានេះនៅក្នុងការសម្របសម្រួលកិច្ចសន្ទនាពីរផ្លូវ រវាងរដ្ឋាភិបាលទាំងឡាយ និង វិស័យពាណិជ្ជកម្ម/វិស័យឯកជន ត្រូវបានគូសបញ្ជាក់ដោយ ASEM ជាពិសេសចំពោះការដោះស្រាយបញ្ហានានាដែលសហគ្រាសខ្នាតតូច និង មធ្យមត្រូវប្រឈមមុខ។ ការពង្រឹងកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យឧស្សាហកម្មអាទិភាព ដោយផ្តោតលើវិស័យបច្ចេកវិទ្យាកម្រិតខ្ពស់ដែលផ្តល់ផលប្រយោជន៍រួម - ឧ. កសិបច្ចេកវិទ្យា ការកែច្នៃចំណីអាហារ ជីវបច្ចេកវិទ្យា បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ (រួមបញ្ចូលទាំង ពាណិជ្ជកម្មអេឡិចត្រូនិក) ការដឹកជញ្ជូន ថាមពល និង វិស្វកម្មបរិស្ថានផងដែរ ត្រូវបានគូសបញ្ជាក់ដោយសង្ខេបសម្រាប់ ASEM។

ការតភ្ជាប់ផ្នែកសេដ្ឋកិច្ចក៏បានព្យាយាមធ្វើឲ្យកិច្ចសន្ទនាយ៉ាងជិតស្និទ្ធនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និង កិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុផងដែរ ដែលទាក់ទងជាពិសេសទៅនឹងការពង្រឹង

កិច្ចសន្ទនាស្តីពីបញ្ហាហិរញ្ញវត្ថុសកល រួមបញ្ចូលទាំងស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិផងដែរ ការពង្រឹងកិច្ចសហប្រតិបត្តិការស្តីពីជំនួយបច្ចេកទេស នៅក្នុងចំណោមប្រធានបទផ្សេងទៀត ការពង្រឹងការពិគ្រោះយោបល់អំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកគយ កិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ និង កិច្ចសន្ទនាយ៉ាងទូលំទូលាយអំពីបញ្ហាសំខាន់ៗដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាពរបស់តំបន់ទាំងពីរ និង សេដ្ឋកិច្ចពិភពលោក រួមបញ្ចូលទាំង បញ្ហាសង្គមសេដ្ឋកិច្ចសំខាន់ៗផងដែរ។

នៅក្នុងវិស័យសង្គម វប្បធម៌ និង អប់រំ ASEM បានយល់ព្រមផ្តោតលើការលើកកម្ពស់ការទំនាក់ទំនងដែលមានល្អប្រសើរជាងមុន និង ការយល់ដឹងទៅវិញទៅមកដែលមានភាពរឹងមាំជាងមុន រវាងប្រជាជននៃតំបន់ទាំងពីរ ក្នុងបំណងជួយដល់ប្រជាជននៅអឺរ៉ុប និង អាស៊ី ឲ្យមានការយល់ដឹងច្រើនជាងមុន អំពីបញ្ហាដូចៗគ្នាដែលមានផលជះដល់អនាគតរបស់ពួកគេ និង យល់ពីគ្នាទៅវិញទៅមកបានល្អប្រសើរជាងមុន តាមរយៈការសន្ទនា។ នៅក្នុងបរិបទនេះ ដៃគូ ASEM បានពង្រីកការគាំទ្រដ៏រឹងមាំដល់មូលនិធិអាស៊ី-អឺរ៉ុប ដែលជាយានដ៏សំខាន់មួយសម្រាប់លើកកម្ពស់ និង ជំរុញឲ្យមានការផ្លាស់ប្តូរវប្បធម៌ ប្រាជ្ញា និង ការផ្លាស់ប្តូររវាងមនុស្ស និង មនុស្ស។ អាទិភាពសំខាន់ៗរួមមាន ការពង្រឹងទំនាក់ទំនង និង ការផ្លាស់ប្តូរគ្នាទៅវិញទៅមកនៅក្នុងវិស័យអប់រំ កិច្ចសហការអន្តរមហាវិទ្យាល័យ និង ការបង្កើតការផ្លាស់ប្តូរសិស្សរវាងតំបន់ទាំងពីរ, កិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការនៅក្នុងការការពារ និង លើកកម្ពស់កេរ្តិ៍ដំណែលវប្បធម៌, លើកកម្ពស់ការបង្កើតបណ្តាញ និង ការចែករំលែកបទពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គម សិល្បៈ មនុស្សសាស្ត្រ និង កីឡា, ជំរុញឲ្យមានកិច្ចសន្ទនាដ៏ទូលំទូលាយ និង ការបង្កើតបណ្តាញនៅគ្រប់វិស័យទាំងអស់នៅក្នុងសង្គម រួមបញ្ចូលទាំង សភាតំណាងរាស្ត្រ ផងដែរ, និង ពង្រឹងការផ្សព្វផ្សាយព័ត៌មានអំពី ASEM នៅទីសាធារណៈ និង អំពីសារសំខាន់នៃទំនាក់ទំនងរវាងអាស៊ី-អឺរ៉ុបដែលមានភាពជិតស្និទ្ធជាងមុន។ ជាចុងក្រោយ វិស័យជាអាទិភាពនៃកិច្ចសហប្រតិបត្តិការទាំងនេះត្រូវបានវិវឌ្ឍន៍នៅក្រោមសសរស្តម្ភចំនួនបីនៃការតភ្ជាប់ ASEM (នយោបាយ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វប្បធម៌សង្គម) ដើម្បីបង្កើតមូលដ្ឋានគ្រឹះនៃកម្មវិធីការងាររយៈពេល ២ឆ្នាំ ដែលត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីការបរទេសនៅក្នុងកិច្ចប្រជុំកំពូលនីមួយៗ និង បានត្រួតពិនិត្យឡើងវិញ និង បានធ្វើបច្ចុប្បន្នភាពនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៅចន្លោះពេលនៃកិច្ចប្រជុំកំពូលនានា។ ប្រមុខរដ្ឋ និង រដ្ឋាភិបាល ទទួលបានបច្ចុប្បន្នភាពស្តីពីវឌ្ឍនភាពនៃសកម្មភាពតភ្ជាប់នៅក្នុងកិច្ចប្រជុំកំពូល ASEM។

## ២៤ឆ្នាំ នៃការតភ្ជាប់អាស៊ី-អឺរ៉ុប

ភាពចាំបាច់នៃការពង្រឹងការតភ្ជាប់រវាងអាស៊ី និង អឺរ៉ុបដែលមានភាពរឹងមាំជាងមុន ត្រូវបានទទួលស្គាល់ដោយ ASEM ចាប់តាំងពីកិច្ចប្រជុំកំពូល ASEM លើកទី ១០ នៅឆ្នាំ២០១៤ នៅប្រទេសអ៊ីតាលី មកម្ល៉េះ។ កិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅឆ្នាំ២០១៦ នៅ Ulaanbaatar បានព្រមព្រៀងគ្នាធ្វើឲ្យ ASEM មានការឆ្លើយតបទៅនឹងតម្រូវការនៃការតភ្ជាប់ដែលកំពុងតែលេចឡើង នៅក្នុងក្របខណ្ឌនៃវិបុលភាពសេដ្ឋកិច្ច ការភ្ជាប់ទំនាក់ទំនងរវាងស្ថាប័ន និង ការផ្លាស់ប្តូរវប្បធម៌សង្គម និង កិច្ចសហប្រតិបត្តិការ ហើយដើម្បីសម្រេចគោលបំណងនេះ APGC ក៏ត្រូវបានបង្កើតឡើង។

APGC ត្រូវបានចាត់តាំងឲ្យផ្តល់ព័ត៌មានលម្អិតយ៉ាងច្បាស់លាស់ស្តីពីការតភ្ជាប់ ASEM ដែលរួមបញ្ចូលទាំង និយមន័យនៃការតភ្ជាប់ដែលត្រូវបានព្រមព្រៀងគ្នា បញ្ជីសកម្មភាពដែលបំពេញតាមនិយមន័យនេះ ការអនុវត្តសកម្មភាពតភ្ជាប់ជាក់លាក់ ការផ្តល់ធាតុសំខាន់ៗសម្រាប់ផែនការសកម្មភាពនៃការតភ្ជាប់ ASEM និង ផ្តល់ការវាយតម្លៃជាក់លាក់អំពីអំណះអំណាងគុណតម្លៃរបស់ ASEM ពាក់ព័ន្ធនឹងការតភ្ជាប់។ APGC មានអាណត្តិ ២ ឆ្នាំ នៅក្នុងការផ្តល់វេទិកាសម្រាប់ការសម្របសម្រួលការចូលរួម និង សកម្មភាពស្តីពីការតភ្ជាប់ និង ស្វែងរកតម្លៃបន្ថែមរបស់ ASEM នៅក្នុងផ្នែកនេះ។

APGC បានព្រមព្រៀងគ្នាចំពោះនិយមន័យនៃការតភ្ជាប់នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស ASEM លើកទី ១៣ នៅប្រទេសមីយ៉ាន់ម៉ា កាលពីខែវិច្ឆិកា ឆ្នាំ២០១៧។ អាស្រ័យហេតុនេះ ដូចមានចែងនៅក្នុងលក្ខខណ្ឌយោងរបស់ APGC ដៃគូ ASEM បានស្វែងរកវិស័យអាទិភាពដែលមានសក្តានុពល និង បានអភិវឌ្ឍក្របខណ្ឌរួមមួយសម្រាប់ "ចំណុចជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យតភ្ជាប់" (TACC) ដែលអាចធ្វើជាឧបករណ៍ណែនាំសម្រាប់អង្គភាពនានារបស់ ASEM ដែលមានសមត្ថកិច្ចធ្វើការតភ្ជាប់រវាងអាស៊ី-អឺរ៉ុប និង ធ្វើសកម្មភាពដើម្បីទទួលបានលទ្ធផលជាក់ស្តែងទៅតាមជំនាញរបស់ពួកគេ។

APGC មានសហប្រធានមកពីមន្ទីរការបរទេសសហភាពអឺរ៉ុប (EEAS) និង ប្រធានសហភាពអឺរ៉ុប (EU) សម្រាប់ក្រុមអឺរ៉ុប និង ប្រទេសចិន និង ជប៉ុន សម្រាប់ក្រុមអាស៊ី។

## ការត្រួតពិនិត្យឡើងវិញលើការតភ្ជាប់ ASEM នៅឆ្នាំ២០១៨

EEAS បានផ្តល់អាណត្តិដល់ការត្រួតពិនិត្យឡើងវិញលើសកម្មភាពតភ្ជាប់ និង កិច្ចសហប្រតិបត្តិ

ការនៅក្នុងASEMកាលពីឆ្នាំ២០១៨ដើម្បីគាំទ្រដល់កិច្ចការរបស់APGCនិងកំណត់ផែនទីបង្ហាញផ្លូវសម្រាប់សកម្មភាពរបស់ ASEM នៅក្នុងទសវត្សរ៍ទីបីរបស់ខ្លួន។ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និង អាស៊ីបូព៌ា (ERIA) និង វិទ្យាស្ថាន Clingendael បានធ្វើការត្រួតពិនិត្យឡើងវិញជូន EEAS។ ការត្រួតពិនិត្យឡើងវិញបានបង្ហាញអំពីចន្លោះប្រហោងនានានៅក្នុងស្ថានភាពនៃផែនការបច្ចុប្បន្ន និង ឱកាសជាច្រើនដែលត្រូវបានណែនាំ ដែលអាចធ្វើឲ្យការតភ្ជាប់អាស៊ី-អឺរ៉ុបត្រៀមខ្លួនជាស្រេចសម្រាប់ថ្ងៃអនាគត និង មានការឆ្លើយតប។ ដោយសារតែលក្ខណៈជាស្ថាប័នដ៏ពិសេសរបស់ ASEM និង ពិពិធភាពនៅក្នុងចំណុចនានានៃកិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍទិសដៅ និង ក្របខណ្ឌសម្រាប់ដំណើរការគោលនយោបាយនៃសកម្មភាពតភ្ជាប់អាស៊ី-អឺរ៉ុបរបស់ ASEM ក៏ជាលទ្ធផលដ៏សំខាន់មួយនៃការត្រួតពិនិត្យឡើងវិញនេះដែរ។ គេបានកត់សម្គាល់ថា ចំណុចខ្លាំងនៃផែនការតភ្ជាប់របស់ ASEM គឺជាសកម្មភាពជាច្រើនរបស់ ASEMដែលពាក់ព័ន្ធនឹងសសរស្តម្ភមួយ ឬច្រើននៃសសរស្តម្ភនៃការតភ្ជាប់ទាំងបី។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានភ័ស្តុតាងដែលបញ្ជាក់អះអាងយ៉ាងពេញលេញអំពីការជាប់ពាក់ព័ន្ធ និង ការរួមចំណែកនៃសកម្មភាពទាំងនេះចំពោះការធ្វើឲ្យការតភ្ជាប់ផ្នែករូបវ័ន្ត ស្ថាប័ន ឬ មនុស្សទៅកាន់មនុស្ស នៅក្នុងប្រទេសនានាមានភាពជឿនលឿនជាងមុននោះទេ។ ការបែងចែកមិនស្មើគ្នានៃព្រឹត្តិការណ៍នានាទៅតាមពេលវេលា និង ប្រធានបទ ខ្វះសកម្មភាពតាមដាន និង ការអនុវត្តលទ្ធផលមិនច្បាស់លាស់ ត្រូវបានមើលឃើញកើតមានឡើងជាទូទៅនៅក្នុងសកម្មភាពនានាដែលស្ថិតនៅក្រោមសសរស្តម្ភទាំងបីរបស់ ASEM។ សកម្មភាពជាច្រើនដែលស្ថិតនៅក្រោមសសរស្តម្ភទាំងបីត្រូវបានបកស្រាយថាជាភ័ស្តុតាងនៃការរួមចំណែកយ៉ាងខ្លាំងក្លារបស់ពួកគេចំពោះការតភ្ជាប់រវាងអាស៊ី និង អឺរ៉ុប។

ការត្រួតពិនិត្យឡើងវិញបានរកឃើញថា រចនាសម្ព័ន្ធផ្លូវការរបស់ ASEM - ដូចជា កិច្ចប្រជុំរដ្ឋមន្ត្រី និង កិច្ចប្រជុំកំពូលជាដើម ផ្តោតលើលទ្ធផល។ រចនាសម្ព័ន្ធទាំងនេះបង្កើតបានជាចំណុចខ្លាំងរបស់ ASEM និង ផ្តល់មគ្គុទ្ទេសក៍ណែនាំ និង ទិសដៅយ៉ាងច្បាស់លាស់ដល់សកម្មភាពនានារបស់ ASEM ជាពិសេសសម្រាប់ការតភ្ជាប់អាស៊ី-អឺរ៉ុប ការដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលទទួលបានអត្ថប្រយោជន៍ជាពិសេសពីកិច្ចប្រជុំរដ្ឋមន្ត្រី និង SOMs។ ការត្រួតពិនិត្យឡើងវិញបានផ្តល់អនុសាសន៍ដល់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និង ដំណើរការ SOMs ចំពោះសកម្មភាពភាគច្រើនរបស់ ASEM ដើម្បីជួយធ្វើឲ្យផែនការតភ្ជាប់សម្រាប់អាស៊ី និង អឺរ៉ុប ក្លាយជាមានវិស័យអាទិភាពមានចីរភាព និង មានគុណភាពល្អជាងមុន។

សមត្ថភាពរបស់ ASEM ក្នុងការទាញយកសកម្មភាពជាក់ស្តែងចេញពីសកម្មភាពដែលទាក់ទងនឹងការតភ្ជាប់របស់ខ្លួន គឺមានកម្រិតខ្លាំងណាស់ នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។

ដោយហេតុថា ASEM លាតសន្ធឹងផ្អែកភូមិសាស្ត្រពីមហាសមុទ្រអាត្លង់ទិចទៅកាន់មហាសមុទ្រប៉ាស៊ីហ្វិក រដ្ឋាភិបាលនៅទូទាំងទ្វីបអាស៊ី និង អឺរ៉ុបបានទទួលស្គាល់អំពីសារសំខាន់នៃការតភ្ជាប់កាន់តែខ្លាំងឡើង។ APGC ត្រូវបានគាំទ្រដោយកម្លាំងជំរុញផ្នែកនយោបាយដែលទទួលបានតាមរយៈកិច្ចប្រជុំរដ្ឋមន្ត្រី និង SOMs ផ្នែកដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ផែនទីបង្ហាញផ្លូវដល់ការតភ្ជាប់ ASEM នៅក្នុងទសវត្សរ៍ បច្ចុប្បន្ន។ អាស្រ័យហេតុនេះ ប្រធានបទនៃការតភ្ជាប់ត្រូវបានពង្រីកដើម្បីរួមបញ្ចូល វិស័យនានា ដូចជា ពាណិជ្ជកម្ម និង ការវិនិយោគ ថាមពល សេដ្ឋកិច្ចឌីជីថល ការគ្រប់គ្រងហិរញ្ញវត្ថុ និង កិច្ចសហប្រតិបត្តិការតាមរយៈដំណើរការដែលមានលក្ខណៈផ្លូវការជាងនេះ ដែលរួមបញ្ចូលរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធដទៃទៀត។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានផ្តល់កម្លាំងជំរុញថ្មីមួយដល់ការភ្ជាប់ទំនាក់ទំនងទៅវិញទៅមក និង ការតភ្ជាប់សកម្មភាពនានានៅក្នុងសសរស្តម្ភទាំងបីរបស់ ASEM។ កិច្ចសហប្រតិបត្តិការពីធនាគារអភិវឌ្ឍពហុភាគី (MDBs) និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFIs) គួរតែត្រូវបានសំយោគសម្រាប់ការប្រើប្រាស់ជាក់ស្តែងនៅក្នុងបរិបទនៃការតភ្ជាប់អាស៊ី-អឺរ៉ុប ពីព្រោះការផ្តល់ហិរញ្ញប្បទានដល់ផែនការតភ្ជាប់ និង បំណុលកាន់តែច្រើន អាចបំផ្លាញដល់ការធ្វើផែនការតភ្ជាប់រយៈពេលវែង។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១២ ដែលបានប្រារព្ធធ្វើឡើងកាលពីខែតុលា ឆ្នាំ២០១៨ វិស័យអាទិភាពនៃការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការរបស់ ASEM ត្រូវបានអនុម័តដោយផ្អែកលើការចូលរួមដោយស្ម័គ្រចិត្ត។ វិស័យអាទិភាពចំនួនប្រាំមួយ រួមមាន (i) គោលនយោបាយនៃការតភ្ជាប់, (ii) ការតភ្ជាប់ប្រកបដោយចីរភាព (ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ ចីរភាពនៃហិរញ្ញប្បទាន ខ្សែសង្វាក់នៃការផ្គត់ផ្គង់ប្រកបដោយចីរភាព ការដឹកជញ្ជូនតាមផ្លូវសមុទ្រដោយសេរី ដោយបើកចំហរ និង ដោយសុវត្ថិភាព និង បច្ចេកវិទ្យាថាមពលស្អាត), (iii) ការតភ្ជាប់ផ្នែកពាណិជ្ជកម្ម និង ការវិនិយោគ (ពាណិជ្ជកម្ម និង ការវិនិយោគដោយសេរី ដោយបើកចំហរ និង យ៉ាងរស់រវើក, ការជួយសម្រួលដល់ការបញ្ចេញទំនិញពីគយ និង ការលើកកម្ពស់ការតភ្ជាប់ការដឹកជញ្ជូន), (iv) ការតភ្ជាប់នាពេលអនាគត និង សេដ្ឋកិច្ចឌីជីថល (សេដ្ឋកិច្ចឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន), (v) ការតភ្ជាប់រវាងមនុស្ស និង មនុស្ស (អន្តរជាតូបនីយកម្ម និង ការផ្លាស់ទីនៅក្នុងវិស័យអប់រំ ការជួយសម្រួលដល់ការធ្វើដំណើរជាអន្តរជាតិរបស់ភ្ញៀវទេសចរណ៍ និង វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ការផ្លាស់ទីរបស់អ្នកប្រកបវិជ្ជាជីវៈផ្នែកវប្បធម៌ និង អ្នកសិល្បៈ ការផ្តល់ភាពអង់អាចដល់ស្ត្រី និង ការឆ្លើយតបដូចៗគ្នាទៅនឹងប្រជាជនវ័យចំណាស់នៅទូទាំងសកលលោក) និង (vi) បញ្ហាប្រឈមផ្នែកសន្តិសុខដែលមានទំនាក់ទំនងនឹងការតភ្ជាប់ (ពង្រឹងសន្តិសុខប្រឆាំងនឹងភាពជ្រុលនិយម ការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង និង សន្តិសុខស្បៀង)។

APGC បានកំណត់និយមន័យ និង បានផ្តល់ព័ត៌មានលម្អិតអំពីវិស័យអាទិភាពនៃការតភ្ជាប់ដល់ ASEM។ AECF ឆ្នាំ២០០០ បានបញ្ជាក់អំពីគោលការណ៍ដែលកាន់តែទូលំទូលាយនៃកិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់ ASEM។ បញ្ហាប្រឈមរបស់ ASEM នៅពេលនេះ គឺ ធ្វើឲ្យការតភ្ជាប់ ASEM មានទំនាក់ទំនង និង មានសារប្រយោជន៍ចំពោះរដ្ឋាភិបាល និង ប្រជាជន និង ធានាថាសកម្មភាពរបស់ ASEM រួមចំណែកដល់ដំណើរការគោលនយោបាយនៅក្នុងប្រទេសដៃគូ។

## តើការតភ្ជាប់ ASEM កំពុងតែបាត់បង់កម្លាំងជំរុញ មែនដែរឬទេ ?

ដំណើរការនៃការតភ្ជាប់ ASEM បានឆ្លងកាត់ការវាយតម្លៃនៅក្នុងទ្រង់ទ្រាយធំ និង បានបង្កើតរចនាសម្ព័ន្ធឡើងវិញ ចាប់ពីឆ្នាំ២០១៦ រហូតដល់ ឆ្នាំ២០១៨។ ដោយមានការសម្រេចចិត្តជាលើកចុងក្រោយលើ TACC និង អនុសាសន៍ឲ្យដំណើរការ APGC នៅពេលបំពេញអាណត្តិរបស់ខ្លួននោះ គេបានរំពឹងទុកថា ការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការរបស់ ASEM នឹងអាចរកឃើញទិសដៅដែលត្រូវបានបញ្ជាក់ពីសំណាក់ប្រទេសដៃគូ ដែលពាក់ព័ន្ធទាំងគុណភាព និង បរិមាណនៃសកម្មភាពនានា។ គេក៏រំពឹងទុកថា នឹងមានលទ្ធផលជាក់ស្តែង និង ការតាមដានលទ្ធផលផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីកិច្ចប្រជុំកំពូល ASEM លើកទី ១២ មក មានភស្តុតាងតិចតួចខ្លាំងណាស់ដែលបញ្ជាក់អំពីសកម្មភាពនានា ដែលត្រូវបានរៀបចំឡើងជុំវិញវិស័យផ្តោតយកចិត្តទុកដាក់នៃ TACC។ ព្រឹត្តិការណ៍សំខាន់ៗដែលត្រូវបានកត់ត្រាទុកនៅលើគេហទំព័រព័ត៌មានរបស់ ASEM ជាប់ពាក់ព័ន្ធនឹងបញ្ហានានាផ្នែកនវានុវត្តន៍ និង ការអភិវឌ្ឍ ឌីជីថលនីយកម្ម និង ការអប់រំ កិច្ចសហប្រតិបត្តិការច្រកចេញចូលតែមួយស្តីពីគយ ការតភ្ជាប់ផ្នែកឌីជីថលប្រកបដោយចីរភាព ប្រជាជនវ័យចំណាស់នៅទូទាំងសកលលោក។ល។

ព្រឹត្តិការណ៍ទាំងអស់នេះត្រូវបានរៀបចំឡើងតាមរបៀបសិក្ខាសាលា ដោយមានការកែប្រែបន្តិចបន្តួចចំពោះវិធីថ្លែងសន្ទរកថា ដែលត្រូវបានគូសបញ្ជាក់នៅក្នុងការត្រួតពិនិត្យឡើងវិញលើសកម្មភាពរបស់ ASEM នៅក្នុងឆ្នាំ២០១៨។ ព្រឹត្តិការណ៍ភាគច្រើននៅតែគ្មានឯកសារស្តីពីលទ្ធផលនោះទេ។ កម្មវិធី របៀបវារៈ និង ឯកសារចុះបញ្ជី គឺជាព័ត៌មានដែលត្រូវបានបង្ហាញជាទូទៅ។ វេទិកាស្តីពីនវានុវត្តន៍ និង ការអភិវឌ្ឍន៍នៃអាស៊ី-អឺរ៉ុប ត្រូវបានប្រារព្ធធ្វើឡើងដោយប្រទេសចិន នៅក្នុងឆ្នាំ២០១៩ មានលទ្ធផលប្រហាក់ប្រហែលគ្នា។ ទោះបីជាមានឯកសារស្តីពីលទ្ធផលក៏ដោយ ក៏ឯកសារទាំងនោះមិនត្រូវបានចែករំលែកជាមួយភាគីពាក់ព័ន្ធរបស់ ASEM តាមរយៈគេហទំព័រព័ត៌មាននោះទេ។ ពាក់ព័ន្ធនឹងប្រសិទ្ធភាព ដំណើរការ និង លទ្ធផលនៃសកម្មភាពតភ្ជាប់របស់ ASEM នៅតែមានបញ្ហាចាស់ៗដដែល។

សេចក្ដីសម្រេចសំខាន់ៗមួយចំនួនរបស់ ASEM ដែលត្រូវបានរំពឹងទុកថា នឹងធ្វើឲ្យចំណុចស្នូលនៃការតភ្ជាប់អាស៊ី-អឺរ៉ុបមានភាពរឹងមាំឡើងវិញនោះ ត្រូវបានផ្អាកជាបណ្ដោះអាសន្ន។ ដោយសារតែពាណិជ្ជកម្ម និង ការវិនិយោគ គឺជាចំណុចស្នូលនៃការតភ្ជាប់អាស៊ី-អឺរ៉ុបនោះ SOMTI មានភាពរស់រវើកឡើងវិញនៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅប្រទេសម៉ុងហ្គោលកាលពីឆ្នាំ២០១៦ បន្ទាប់ពីមានគម្លាតរយៈពេល ១២ ឆ្នាំ និង ត្រូវបានប្រារព្ធធ្វើឡើងនៅប្រទេសកូរ៉េ នៅឆ្នាំ២០១៧។ ទោះបីជាយ៉ាងណាក៏ដោយ មកទល់បច្ចុប្បន្ន ASEM មិនអាចកោះប្រជុំ SOMTI ណាមួយផ្សេងទៀតបាននោះទេ។ ដូច្នេះ ពុំមានសកម្មភាពពិនិត្យតាមដានទៅលើការអនុវត្តសេចក្ដីសម្រេចនានា និង ផែនទីបង្ហាញផ្លូវ ដែលត្រូវបានកំណត់សម្រាប់ការតភ្ជាប់ផ្នែកសេដ្ឋកិច្ចនៅតំបន់អាស៊ី-អឺរ៉ុប ដែលរួមបញ្ចូលទាំងកិច្ចការសំខាន់ៗសម្រាប់ការភ្ជាប់ផ្នែកឌីជីថលផងដែរនោះទេ។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចរបស់ ASEM មានវាសនាប្រហាក់ប្រហែលគ្នា។

ប្រាកដណាស់ ការតភ្ជាប់របស់ ASEM មិនទាន់មានជំនាញគ្រប់គ្រាន់នៅក្នុងការដោះស្រាយទិដ្ឋភាពពិបាកៗនៃការតភ្ជាប់អន្តរតំបន់នៅឡើយទេ ហើយអភិក្រមចំពោះបញ្ហាសកលក៏ស្ថិតនៅក្នុងតំបន់សកម្មភាពស្ម័គ្រចិត្តដែរ ដូចជា កិច្ចពិភាក្សា និង សិក្ខាសាលា ជាដើម ដោយមានធាតុចូលបន្តិចបន្តួចនៅក្នុងការធ្វើឲ្យផែនការតភ្ជាប់របស់ ASEM មានលក្ខណៈផ្លូវការ និង មានភាពរឹងមាំ។

ស្មារតីរបស់ AECF ២០០០ និង វត្ថុបំណងនៃការតភ្ជាប់របស់ ASEM ក៏ត្រូវបានត្រួតពិនិត្យនៅក្នុងផែនការតភ្ជាប់ខុសៗគ្នា នៅតំបន់អាស៊ី និង អឺរ៉ុបផងដែរ នៅផ្នែកបន្ទាប់។ អភិក្រមដើម្បីឆ្ពោះទៅកាន់ការសិក្សាអំពីផែនការតភ្ជាប់ គឺការបង្កើតទំនិញសមូហភាព និង ទំនិញសាធារណៈសម្រាប់តំបន់អាស៊ី និង អឺរ៉ុប ដោយអនុលោមតាម អាទិភាពនៃការអភិវឌ្ឍរបស់តំបន់ទាំងពីរ។

## យុទ្ធសាស្ត្រនៃការតភ្ជាប់ EU–អាស៊ី

រហូតមកដល់ឆ្នាំ ២០១៨ ការតភ្ជាប់របស់ ASEM គឺជាទស្សនាទាននៃការតភ្ជាប់រវាងតំបន់អាស៊ី និង អឺរ៉ុប ដែលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយថែមទៀត។ EU គឺជាប្រធានរួមរបស់ ASEM នៅប៉ែកអឺរ៉ុប និង មានទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង សេដ្ឋកិច្ចយ៉ាងស៊ីជម្រៅជាមួយតំបន់អាស៊ី។ ក្នុងនាមជាដៃគូដ៏សំខាន់របស់អាស៊ី គណៈកម្មការអឺរ៉ុបបានដាក់ចេញនូវវិស័យនានាដើម្បីឆ្ពោះទៅកាន់យុទ្ធសាស្ត្ររបស់ EU ដែលធ្វើការតភ្ជាប់តំបន់អឺរ៉ុប និង តំបន់អាស៊ី ដោយមានសំណើផ្នែកនយោបាយជាក់លាក់ និង គំនិតផ្តួចផ្តើមនានា ដែលត្រូវបានលើកឡើងកាលពីខែកញ្ញា ឆ្នាំ២០១៨ ក្នុងពេលដំណាលគ្នានឹងកិច្ចប្រជុំកំពូល ASEM លើកទី ១២ នៅទីក្រុងប្រ៊ុសសែល (គណៈកម្មការអឺរ៉ុប ២០១៨a)។

ការណែនាំអំពីយុទ្ធសាស្ត្ររបស់ EU ដើម្បីតភ្ជាប់តំបន់អឺរ៉ុប និង តំបន់អាស៊ី គឺជាការទទួលស្គាល់អំពីសារសំខាន់ជាសកលនៃការភ្ជាប់ទំនាក់ទំនងជាមួយតំបន់អាស៊ី ជាតំបន់ដែលមានការនាំចេញពី EU ចំនួន ៣៥% (៦១៨ ប៊ីលានអឺរ៉ូ) និង ការនាំចូលរបស់ EU ចំនួន ៤៥% (៧៧៤ ប៊ីលានអឺរ៉ូ)។ សម្រាប់ទាំងតំបន់អឺរ៉ុប និង តំបន់អាស៊ី កំណើននៃការពឹងផ្អែកទៅវិញទៅមកជាសកល គឺជាឱកាសមួយសម្រាប់កិច្ចសហប្រតិបត្តិការដែលមានការកើនឡើង កិច្ចសហប្រតិបត្តិការផ្នែកនយោបាយដោយសន្តិភាព ទំនាក់ទំនងផ្នែកសេដ្ឋកិច្ចដែលមានភាពសុក្រឹត្យ និង កាន់តែរឹងមាំឡើង កិច្ចសន្ទនាអំពីសង្គមគ្រប់ជ្រុងជ្រោយ និង កិច្ចសហការស្ដីពីសន្តិសុខអន្តរជាតិ និងសន្តិសុខប្រចាំតំបន់។ ចំពោះ EU ការតភ្ជាប់ជាមួយតំបន់អាស៊ី ត្រូវបានគេមើលឃើញថាជាភាពជាដៃគូមួយដែលមានសារសំខាន់ជាសកល ដែលតំបន់អឺរ៉ុប និង តំបន់អាស៊ី រួមបញ្ចូលគ្នាអាចក្លាយជាម៉ាស៊ីននៃអភិក្រមមួយដែលមានកិច្ចសហប្រតិបត្តិការកាន់តែច្រើនឡើង ចំពោះនយោបាយពិភពលោក ស្ថេរភាពសកល និង វិបុលភាពនៃសេដ្ឋកិច្ចប្រចាំតំបន់។

យុទ្ធសាស្ត្រតភ្ជាប់ រវាង EU-អាស៊ី ត្រូវបានបង្កើតឡើងដោយផ្អែកលើជំនឿដែលថា EU-អាស៊ីគួរតែធានាចំពោះការតភ្ជាប់ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ពីព្រោះការតភ្ជាប់នេះរួមចំណែកដល់កំណើនសេដ្ឋកិច្ច និង ការងារ, ភាពប្រកួតប្រជែង និង ពាណិជ្ជកម្មជាសកល និងបម្លាស់ទីរបស់ប្រជាជន ទំនិញ និង សេវាកម្មនៅទូទាំង និង រវាងតំបន់អឺរ៉ុប និង តំបន់អាស៊ី។ វាបានបង្ហាញដោយសង្ខេបអំពីសំណើគោលនយោបាយជាក់លាក់ និង គំនិតផ្ដួចផ្ដើមនានាដើម្បីពង្រឹងការតភ្ជាប់រវាងតំបន់អឺរ៉ុប និង តំបន់អាស៊ី រួមបញ្ចូលទាំង តាមរយៈបណ្ដាញនៃការដឹកជញ្ជូនថាមពល និង ឌីជីថល ដែលអាចដំណើរការទៅវិញទៅមកបាន។ EU លើកកម្ពស់អភិក្រមមួយចំពោះការតភ្ជាប់ជាមួយតំបន់អាស៊ី ដែលមានចីរភាព គ្រប់ជ្រុងជ្រោយ និង ផ្អែកលើច្បាប់៖

- ការតភ្ជាប់ប្រកបដោយចីរភាព ប្រមើលមើលជាមុនថា ការតភ្ជាប់ត្រូវតែមានចីរភាពផ្នែកសេដ្ឋកិច្ច សារពើពន្ធ បរិស្ថាន និង សង្គម នៅក្នុងរយៈពេលវែង។
- ការតភ្ជាប់គ្រប់ជ្រុងជ្រោយ និយាយអំពីបណ្ដាញ និង លំហូររបស់មនុស្ស ទំនិញ សេវាកម្ម និង មូលធន ដែលឆ្លងកាត់ពួកគេ។ វាបញ្ជាក់អំពីមុខងារដ៏សំខាន់របស់មនុស្ស និង ផលប្រយោជន៍ និង សិទ្ធិរបស់ប្រជាជន ដែលគួរតែជាចំណុចស្នូលនៃការតភ្ជាប់។
- ការតភ្ជាប់ដែលផ្អែកលើច្បាប់អន្តរជាតិ គឺចាំបាច់ដើម្បីធ្វើឲ្យប្រជាជន ទំនិញ សេវាកម្ម និង មូលធនផ្លាស់ទីបានយ៉ាងមានប្រសិទ្ធភាព យ៉ាងស្មើភាព និង យ៉ាងរលូន។ ទម្លាប់អនុវត្ត វិធានអនុសញ្ញា និង បទដ្ឋានបច្ចេកទេសដែលត្រូវបានព្រមព្រៀងគ្នាជាសកល ដែលត្រូវបានគាំទ្រដោយអង្គការ និង ស្ថាប័នអន្តរជាតិ អនុញ្ញាតឲ្យមានការដំណើរការទៅវិញទៅមកនៃបណ្ដាញនានា និង ពាណិជ្ជកម្មឆ្លងព្រំដែន។

លើសពីនេះទៀត ច្រករបៀងនៃការដឹកជញ្ជូនជាអាទិភាព តំណភ្ជាប់ផ្អែកឌីជីថល និង កិច្ចសហប្រតិបត្តិការផ្អែកថាមពល ដែលត្រូវប្រើប្រាស់ដោយប្រជាជន និង សេដ្ឋកិច្ចរៀងៗខ្លួន ការបង្កើតភាពជាដៃគូសម្រាប់ការតភ្ជាប់ដោយផ្អែកលើវិធាន និង បទដ្ឋានដែលត្រូវបានព្រមព្រៀងរួមគ្នា និង ការរួមចំណែកដល់ការដោះស្រាយគម្លាតនៃការវិនិយោគដ៏ធំ តាមរយៈការប្រមូលផ្តុំធនធានហិរញ្ញវត្ថុដែលមានភាពល្អប្រសើរជាងមុន និង ភាពជាដៃគូអន្តរជាតិដែលរឹងមាំជាងមុន គឺជាចំណុចសំខាន់។

EU នឹងចូលរួមជាមួយដៃគូនៅតំបន់អាស៊ីរបស់ខ្លួនតាមរយៈផ្នែកទាំងបី៖

(i) តាមរយៈការរួមចំណែកដល់ការភ្ជាប់ទំនាក់ទំនង និង បណ្តាញយ៉ាងប្រសិទ្ធភាពរវាងតំបន់អឺរ៉ុប និង តំបន់អាស៊ី តាមរយៈច្រករបៀងនៃការដឹកជញ្ជូនជាអាទិភាព តំណភ្ជាប់ផ្អែកឌីជីថល និង កិច្ចសហប្រតិបត្តិការផ្អែកថាមពល ដែលត្រូវប្រើប្រាស់ដោយប្រជាជន និង សេដ្ឋកិច្ចរបស់ពួកគេរៀងៗខ្លួន

(ii) តាមរយៈការបង្កើតភាពជាដៃគូសម្រាប់ការតភ្ជាប់ដោយផ្អែកលើវិធាន និង បទដ្ឋានដែលត្រូវបានព្រមព្រៀងរួមគ្នា ធ្វើឲ្យមានអភិបាលកាន់តែល្អប្រសើរឡើងចំពោះលំហូរនៃទំនិញ ប្រជាជន មូលធន និង សេវាកម្ម និង

(iii) តាមរយៈការរួមចំណែកដល់ការដោះស្រាយគម្លាតនៃការវិនិយោគដ៏ធំ តាមរយៈការប្រមូលផ្តុំធនធានហិរញ្ញវត្ថុដែលមានភាពល្អប្រសើរជាងមុន ការលើកកម្ពស់ធនធានហិរញ្ញវត្ថុរបស់ EU ដែលរឹងមាំជាងមុន និង ភាពជាដៃគូអន្តរជាតិដែលរឹងមាំជាងមុន។

ចំពោះការបង្កើតការតភ្ជាប់ប្រកបដោយប្រសិទ្ធភាពរវាងតំបន់អឺរ៉ុប និង តំបន់អាស៊ីយុទ្ធសាស្ត្រតភ្ជាប់រវាង EU-អាស៊ី ប្រមើលមើលជាមុនអំពីការតភ្ជាប់ផ្អែករូបវន្ត (ការដឹកជញ្ជូនតាមផ្លូវអាកាស ផ្លូវគោក និង តាមសមុទ្រ)។ EU នឹងធ្វើការដើម្បីឆ្ពោះទៅកាន់ការតភ្ជាប់ក្របខណ្ឌនៃបណ្តាញដឹកជញ្ជូនឆ្លងអឺរ៉ុប (TEN-T) ដែលត្រូវបានអភិវឌ្ឍឡើងបានយ៉ាងល្អ ជាមួយបណ្តាញនានានៅតំបន់អាស៊ី។ EU បានពង្រីក TEN–T ទៅកាន់ Balkans ភាគខាងលិច និង បានយល់ព្រមលើការលាតសន្ធឹងរបស់ TEN–T ជាមួយប្រទេសដៃគូនៅភាគខាងកើតចំនួនប្រាំមួយប្រទេស អាមេនី អាស៊ែបៃហ្សង់ បេឡារុស្ស ហ្សកហ្ស៊ី ម៉ុលដាវី និង អ៊ុយក្រែន) (គណៈកម្មការអឺរ៉ុប ២០១៨b)។

ទាំងការតភ្ជាប់ផ្លូវរថភ្លើងរវាងភាគខាងជើង-ភាគខាងត្បូង និង រវាងភាគខាងកើត-ភាគខាងលិច អាចដើរតួនាទីដ៏សំខាន់នាពេលអនាគត។ ជាពិសេស ការតភ្ជាប់ផ្លូវរថភ្លើងរវាង EU-អាស៊ី បាន និង កំពុងតែមានកំណើនយ៉ាងខ្លាំងក្លា។ EU កំពុងតែគាំទ្រដល់គំនិតផ្តួចផ្តើមនៃច្បាប់ស្តីពីផ្លូវ

រថភ្លើងរួម នៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុបនៃអង្គការសហប្រជាជាតិ ដែលកំពុងតែព្យាយាមធ្វើការបង្រួបបង្រួមរបបច្បាប់សម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវរថភ្លើងឆ្លងកាត់ទ្វីបអឺរ៉ាស៊ាន។ EU នឹងធ្វើការជាមួយអង្គការដឹកជញ្ជូនតាមផ្លូវរថភ្លើងដែលពាក់ព័ន្ធដើម្បីពង្រីកការអនុវត្តយថាប្រភេទផ្នែកបច្ចេកទេស និង ក្របខណ្ឌគ្រប់គ្រងសុវត្ថិភាពរបស់ EU។

នៅខណៈពេលដែលយុទ្ធសាស្ត្រ EU-អាស៊ី គ្របដណ្តប់លើការតភ្ជាប់តាមផ្លូវអាកាស និង តាមសមុទ្រ តាមវិធីសាស្ត្រមួយចំនួននោះ ការដឹកជញ្ជូនតាមផ្លូវគោកទទួលបានចំណាប់អារម្មណ៍ច្រើនជាង ពីព្រោះគេចាត់ទុកថា ការដឹកជញ្ជូនតាមផ្លូវគោកមានភាពសមហេតុផលច្រើនជាង នៅក្នុងរយៈចម្ងាយកម្រិតមធ្យម (ដូចជា ទៅកាន់អាស៊ីកណ្តាល ជាដើម) និង ជាបណ្តាញដឹកជញ្ជូនបន្ទាប់បន្សំសម្រាប់រួមបញ្ចូលជាមួយមធ្យោបាយដឹកជញ្ជូនដទៃទៀត។ ការលើកកម្ពស់សុវត្ថិភាពផ្លូវថ្នល់តាមរយៈការចែករំលែកឧត្តម្មានុវត្ត ជំរុញការផ្លាស់ប្តូរព័ត៌មានរបស់អតិថិជន និង អភិវឌ្ឍកិច្ចសហប្រតិបត្តិការស្តីពីផ្លូវឆ្លងកាត់ (ទាំងទ្វេភាគី និង តាមរយៈអង្គការគយពិភពលោក) គឺជាវិធីសាស្ត្រនៃគោលនយោបាយដែលមានសារសំខាន់ចំពោះការដឹកជញ្ជូនតាមផ្លូវគោក។

ការតភ្ជាប់ផ្នែកឌីជីថល និង ផ្នែកថាមពល ក៏ត្រូវបានគេប្រមើលមើលថាមានសារសំខាន់ចំពោះផែនការនេះដែរ។ តំណភ្ជាប់បណ្តាញដែលមានសមត្ថភាពខ្ពស់មានសារសំខាន់ខ្លាំងណាស់ចំពោះការគាំទ្រដល់សេដ្ឋកិច្ចឌីជីថល។ តំណភ្ជាប់បណ្តាញស្នូលជាមួយតំបន់អាស៊ី និង ប្រទេសលោកទីបីដទៃទៀត នឹងរួមចំណែកដល់បណ្តាញដែលមានលក្ខណៈពេញលេញមួយ ដោយផ្តល់អត្រាបញ្ជូនទិន្នន័យជាអតិបរមា និង លក្ខណៈវិនិច្ឆ័យផ្នែកគុណភាពដទៃទៀតដែលចាំបាច់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់នេះ។ ដោយមានទំនាក់ទំនងជាមួយប្រទេសនានានៅតំបន់អាស៊ី យុទ្ធសាស្ត្រ EU លើកកម្ពស់មជ្ឈដ្ឋានព័ត៌មាន និង គមនាគមន៍ប្រកបដោយសន្តិភាព សន្តិសុខ និង បើកចំហរ ស្របពេលជាមួយគ្នានេះ ដោះស្រាយការគំរាមកំហែងផ្នែកសន្តិសុខ អ៊ីនធឺណិត និង ការពារសិទ្ធិមនុស្ស និង សេរីភាពអនឡាញ រួមបញ្ចូលទាំង ការការពារទិន្នន័យផ្ទាល់ខ្លួនផងដែរ។ ការតភ្ជាប់ EU-អាស៊ី បានផ្តល់អភិក្រមនៃនិយ័តកម្មដែលមានទំនាក់ទំនងនឹងគ្នានៅក្នុងការតភ្ជាប់ផ្នែកឌីជីថល ពីព្រោះវាមានសារសំខាន់ចំពោះការគាំទ្រដល់ការវិនិយោគឯកជន និង សាធារណៈលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ យុទ្ធសាស្ត្រនេះក៏គូសបញ្ជាក់អំពីគោលនយោបាយ និង គ្រឿងលើកទឹកចិត្តដើម្បីតភ្ជាប់ការបែងចែកផ្នែកឌីជីថល ជាពិសេសនៅតាមតំបន់ដាច់ស្រយាល ឬ នៅក្នុងប្រទេសដែលគ្មានព្រំដែនជាប់សមុទ្រ។ យុទ្ធសាស្ត្រឌីជីថលដើម្បីការអភិវឌ្ឍ (Digital4Development) នៅតំបន់អាស៊ីនឹងចាប់ផ្តើមអនុវត្តដើម្បីលើកកម្ពស់បច្ចេកវិទ្យានិងសេវាកម្មឌីជីថល ដើម្បីជំរុញដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម។

EU បានស្នើឡើងនូវការលើកកម្ពស់វេទិកានៃការតភ្ជាប់ផ្នែកថាមពលប្រចាំតំបន់ ដែលផ្ដោតលើគោលការណ៍ទីផ្សារ ការជំរុញឲ្យមានទំនើបកម្មនៃប្រព័ន្ធថាមពល និងការអនុម័តលើដំណោះស្រាយថាមពលស្អាត (ដែលបែងចែកទៅច្រើនស្ថានីយ៍) លើកកម្ពស់ប្រសិទ្ធភាពនៃថាមពល និងគាំទ្រដល់ការតភ្ជាប់ផ្នែកថាមពលទាំងរវាង និង ជាមួយដៃគូនានានៅក្នុងតំបន់អាស៊ី។

លក្ខណៈពិសេសសំខាន់ៗមួយចំនួនផ្សេងទៀតរបស់យុទ្ធសាស្ត្រ EU ចំពោះការតភ្ជាប់ជាមួយតំបន់អាស៊ី រួមមាន សកម្មភាពដែលពង្រឹងកម្មវិធីកិច្ចសហប្រតិបត្តិការទ្វេភាគី ថ្នាក់តំបន់ និងអន្តរជាតិដែលមានស្រាប់ និង សកម្មភាពនានានៅក្នុងតំបន់អាស៊ី។

**កិច្ចសហប្រតិបត្តិការទ្វេភាគី៖** EU គឺជាដៃគូនៃកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍ និង ការវិនិយោគនៅក្នុងតំបន់អាស៊ី។ EU និង ដៃគូរបស់ខ្លួននៅក្នុងតំបន់អាស៊ី អាចធ្វើការជាមួយគ្នាបានកាន់តែល្អប្រសើរឡើង ដើម្បីពង្រឹងមជ្ឈដ្ឋាននៃការធ្វើនិយ័តកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការប្រមូលផ្ដុំធនធានក្នុងស្រុក។

ជំនួយបច្ចេកទេសដើម្បីអភិវឌ្ឍ និងអនុវត្តគម្រោងតភ្ជាប់ប្រកបដោយចីរភាព គោលនយោបាយ និង របបនិយ័តកម្ម មានសារសំខាន់ចំពោះភាពជាដៃគូនេះ។ កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសនីមួយៗនឹងត្រូវសម្របទៅតាមស្ថានភាពជាក់លាក់នៃប្រទេសទាំងនោះ។ មានការរៀបចំផែនការពង្រីកកិច្ចសន្ទនាអំពីការដឹកជញ្ជូនដែលមានស្រាប់ ជាមួយប្រទេសចិន ប្រទេសជប៉ុន និងប្រទេសសិង្ហបុរី។ EU ក៏មានផែនការពង្រីកកិច្ចសន្ទនាស្ដីពីការតភ្ជាប់ប្រកបដោយចីរភាពជាមួយដៃគូដទៃទៀត ដែលរួមមាន ប្រទេសអាហ្គានីស្ថាន ប្រទេសឥណ្ឌា ប្រទេសឥណ្ឌូនេស៊ី ប្រទេសអៀរ៉ង់ប្រទេសប៉ាគីស្ថានប្រទេសរុស្ស៊ីប្រទេសកូរ៉េប្រទេសទួរគីនិងប្រទេសនានានៃអាស៊ីកណ្ដាល ព្រមទាំង ប្រទេសអូស្ត្រាលី និង សហរដ្ឋអាមេរិកផងដែរ ពីព្រោះវានឹងផ្ដល់ការបង្រួបបង្រួមកម្លាំងដល់យុទ្ធសាស្ត្រនៃការតភ្ជាប់ EU-អាស៊ី។

កិច្ចសហប្រតិបត្តិការថ្នាក់តំបន់៖ តំបន់អាស៊ីមានអង្គការ និង យន្តការអន្តរជាតិជាច្រើន ដែលមានអំណាចពាក់ព័ន្ធនឹងការតភ្ជាប់។ យុទ្ធសាស្ត្ររបស់ EU ផ្ដល់ការគាំទ្រដល់ MPAC ២០២៥ និងសំដៅឆ្ពោះទៅកាន់បទដ្ឋាននៃ MPAC នោះ រួមទាំង តាមរយៈកិច្ចសន្ទនាស្ដីពីការដឹកជញ្ជូនជាបន្តបន្ទាប់ផងដែរ។

នៅអាស៊ីកណ្ដាល ការលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់ស្ដីពីការតភ្ជាប់ប្រកបដោយចីរភាព អាចជាយុទ្ធសាស្ត្រដ៏សំខាន់មួយ។ គំនិតផ្ដួចផ្ដើមនៃឈូងសមុទ្របេងហ្គាល់សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស និង សេដ្ឋកិច្ចពហុវិស័យ, កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច

ប្រចាំតំបន់អាស៊ីកណ្តាល, សមាគមអាស៊ីខាងត្បូងដើម្បីកិច្ចសហប្រតិបត្តិការប្រចាំតំបន់, កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅអនុតំបន់អាស៊ីអាគ្នេយ៍ និង អង្គការកិច្ចសហប្រតិបត្តិការសៀងហៃ គឺជាគំនិតផ្តួចផ្តើមប្រចាំតំបន់មួយចំនួនផ្សេងទៀត ដែលត្រូវបានសម្គាល់ឃើញដោយ EU សម្រាប់កិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ី។

**កិច្ចសហប្រតិបត្តិការអន្តរជាតិ៖** គណៈកម្មការអឺរ៉ុបបានពង្រីកកិច្ចសហប្រតិបត្តិការដើម្បីធ្វើការជាមួយអង្គការអន្តរជាតិ និង ឧស្សាហកម្មដែលពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យឡើងវិញលើភាពចាំបាច់នៃបទដ្ឋាននានាដែលទាក់ទងនឹងការតភ្ជាប់ផ្នែកប្រែប្រួលអាកាសធាតុ ភាពរិចរិលនៃបរិស្ថាន ការចូលទៅកាន់ទីផ្សារ ការធ្វើពាណិជ្ជកម្មដោយសេរី និង ស្មើភាព និង ភាពអាចដំណើរការទៅវិញទៅមកបាននៃបណ្តាញនានា។ ការទទួលបានការប្តេជ្ញាចិត្តពីសំណាក់ប្រទេសលោកទីបីសំខាន់ៗ ចំពោះបទដ្ឋានទាំងនោះ និង ការអនុម័តយ៉ាងទូលំទូលាយរបស់ពួកគេ គឺជាគោលដៅអនុវត្តដ៏សំខាន់មួយ។

## ការផ្តល់ហិរញ្ញប្បទានដល់ការតភ្ជាប់ EU-អាស៊ី

យុទ្ធសាស្ត្រនៃការតភ្ជាប់ EU-អាស៊ី ពុំមានបំណងបង្កើតផែនការវិនិយោគនោះទេ ទោះបីជាលិខិតូបករណ៍ផ្នែកហិរញ្ញវត្ថុដែលមានស្រាប់ និង លិខិតូបករណ៍នាពេលអនាគត របស់ EU ទំនងជាអាចគាំទ្រដល់ការវិនិយោគជាលក្ខណៈឯកជនលើគម្រោងនានាដែលទាក់ទងនឹងការតភ្ជាប់ក៏ដោយ។ EU បានផ្តល់ការគាំទ្រដល់ការតភ្ជាប់រួចរាល់ហើយ តាមរយៈកន្លែងវិនិយោគក្បែរខាង កន្លែងវិនិយោគសម្រាប់តំបន់អាស៊ីកណ្តាល និង កន្លែងវិនិយោគនៅតំបន់អាស៊ី ដោយភាគច្រើនតាមរយៈការផ្តល់ហិរញ្ញប្បទាន និង ជំនួយបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និង ការតភ្ជាប់។ កន្លែងវិនិយោគនៅតំបន់អាស៊ី និង កន្លែងវិនិយោគនៅតំបន់អាស៊ីកណ្តាល តែមួយមុខ បានបង្កើតទឹកប្រាក់វិនិយោគជាង ៤,២ ប៊ីលានអឺរ៉ូ ចាប់ពីឆ្នាំ២០១០ រហូតដល់ ពាក់កណ្តាលឆ្នាំ២០១៨ តាមរយៈការរួមបញ្ចូលគ្នានៃប្រាក់ជំនួយ និង ប្រាក់កម្ចី។ ផែនការវិនិយោគសម្រាប់តំបន់អឺរ៉ុបក៏បង្ហាញអំពីឱកាសដ៏រឹងមាំសម្រាប់ការវិនិយោគរួមគ្នានៅក្នុងតំបន់អឺរ៉ុបផងដែរ។

ចំពោះក្របខណ្ឌហិរញ្ញវត្ថុរយៈពេលច្រើនឆ្នាំបន្ទាប់ទៀត (២០២១-២០២៧) សំណើរបស់គណៈកម្មការអឺរ៉ុបបានរួមបញ្ចូលក្របខណ្ឌវិនិយោគសម្រាប់សកម្មភាពខាងក្រៅ ដែលបង្កើតឡើងដោយផ្អែកលើមូលនិធិអឺរ៉ុបសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនាពេលបច្ចុប្បន្ន។ នៅ EU បានណែនាំឲ្យមានការសហការកាន់តែជិតស្និទ្ធនៅក្នុងការអនុវត្តសកម្មភាពនានា ជាមួយស្ថាប័នហិរញ្ញវត្ថុសាធារណៈ និង ឯកជនរបស់ប្រទេសដែលជាសមាជិករបស់ EU រួមទាំង មូលនិធិ

អធិបតេយ្យភាព ផងដែរ។ EU បានគូសបញ្ជាក់អំពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដើម្បីប្រមូលផ្តុំប្រភពមូលនិធិនានា ដែលរួមបញ្ចូលទាំង កំណើននៃការវិនិយោគជាលក្ខណៈឯកជន និង ការប្រើប្រាស់លិខិតូបករណ៍ដែលមានស្រាប់បានយ៉ាងល្អបំផុតផងដែរ ដូចជា មូលនិធិអឺរ៉ុបសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ជាដើម។

ផែនការសកម្មភាពសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់កំណើនប្រកបដោយចីរភាពបានលើកកម្ពស់ផ្នែកហិរញ្ញវត្ថុប្រកបដោយចីរភាព និង ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយចីរភាព ហើយផែនការនេះក៏ជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រតភ្ជាប់ផងដែរ។

ផែនការសកម្មភាពនេះបានណែនាំឲ្យ EU និង តំបន់អឺរ៉ុបផ្តល់កម្ចីដល់ស្ថាប័ននានា ដើម្បីពង្រឹងកិច្ចសន្ទនាជាមួយស្ថាប័នហិរញ្ញវត្ថុសាធារណៈ និង ឯកជននៃប្រទេសលោកទីបី និង លើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការស្តីពីហិរញ្ញវត្ថុប្រកបដោយចីរភាព និង ការផ្លាស់ប្តូរឧត្តមានុវត្តរវាងធនាគារនានានៅតំបន់អឺរ៉ុប រួមបញ្ចូលទាំង ធនាគាររដ្ឋ និង ធនាគារនៃប្រទេសដទៃទៀតដែលមិនមែនជាសមាជិក EU ផងដែរ។ EU នឹងគាំទ្រដល់ដំណើរការនានានៅក្នុងក្រុមប្រទេស G7 ក្រុមប្រទេស G20 និង អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ដើម្បីធ្វើឲ្យទម្លាប់អនុវត្តនៃការផ្តល់កម្ចីរបស់ស្ថាប័នហិរញ្ញវត្ថុសាធារណៈមានលក្ខណៈស្របគ្នានឹងគោលការណ៍នានានៃការតភ្ជាប់ប្រកបដោយចីរភាព។

យុទ្ធសាស្ត្រនៃការតភ្ជាប់ EU–អាស៊ី ដែលពឹងផ្អែកលើភាពជាដៃគូអន្តរជាតិលើវិស័យហិរញ្ញវត្ថុ ដូចជា IFIs និង MDBs ជាដើម គឺជាសមាសធាតុដ៏សំខាន់មួយនៃស្ថាបត្យកម្មសកលសម្រាប់ការតភ្ជាប់ផ្នែកហិរញ្ញវត្ថុ។

ធនាគារវិនិយោគរបស់អឺរ៉ុប និង ធនាគារអឺរ៉ុបដើម្បីការស្ថាបនាឡើងវិញ និង ការអភិវឌ្ឍ ត្រូវបានគេសម្គាល់ឃើញថាជាដៃគូវិនិយោគ។ មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក គឺជាដៃគូដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកចីរភាពបំណុល និង ការតភ្ជាប់។ ចំណុចសំខាន់គឺ EU បានព្យាយាមធ្វើឲ្យកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី មានលក្ខណៈស៊ីជម្រៅ ស្របពេលជាមួយគ្នានោះធានាថា ចំណុចអាទិភាពរបស់ EU បានទទួលការគោរពយ៉ាងពេញលេញនៅក្នុងទំនាក់ទំនងទាំងនេះ។ MDBs នឹងជួយដល់ការអនុវត្ត “ផែនទីបង្ហាញផ្លូវទៅកាន់ហេដ្ឋារចនាសម្ព័ន្ធក្នុងជាទ្រព្យសកម្មមួយក្រុម” របស់ G20 និង “គោលការណ៍របស់ G20 ចំពោះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ”។

យុទ្ធសាស្ត្ររបស់ EU ស្ដីពីការតភ្ជាប់តំបន់អឺរ៉ុប និង តំបន់អាស៊ី មិនបានរួមបញ្ចូលផែនការលម្អិត ឬ គម្រោងណាមួយនៅពេលនេះនោះទេ។ យុទ្ធសាស្ត្រនេះពន្យល់យ៉ាងច្បាស់អំពីទិសដៅនៃផែនការតភ្ជាប់របស់ EU ជាមួយតំបន់អាស៊ី និង រំឭកដល់សមភាគីអាស៊ីថា រាល់សកម្មភាពនាពេលអនាគតទាំងអស់នឹងត្រូវអនុវត្តក្រោមគោលការណ៍នៃការតភ្ជាប់ប្រកបដោយចីរភាព គ្រប់ជ្រុងជ្រោយ និង ផ្អែកលើច្បាប់អន្តរជាតិ។ ឯកសារនៃយុទ្ធសាស្ត្រនេះបញ្ជាក់អំពីដៃគូ ទាំងទ្វេភាគី និង ប្រចាំតំបន់ និង កម្មវិធីផ្ដួចផ្ដើមនានាដែលការតភ្ជាប់ជាមួយអាស៊ីនឹងត្រូវបានជំរុញ ស្របតាមកម្មវិធីនោះទេ។ យុទ្ធសាស្ត្រនេះបានទទួលរងការជះឥទ្ធិពលពីភាពចាំបាច់របស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់អាស៊ីកាន់តែខ្លាំងឡើង ពោលគឺពង្រឹងភាពជាដៃគូរវាង EU និង ប្រទេសលោកទីបី តំបន់ និង អង្គការអន្តរជាតិនៅអាស៊ី ដែលរហូតមកពេលនេះ មិនត្រូវបានលើកឡើងនៅក្នុងផែនការរបស់ EU សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិនោះទេ។ យុទ្ធសាស្ត្រនេះក៏អនុញ្ញាតឱ្យ EU និង ប្រទេសដែលជាសមាជិករបស់ខ្លួនសម្រេចបាននូវការប្រាស្រ័យទាក់ទងបានល្អប្រសើរជាងមុន ការបង្កើតម៉ាកសញ្ញា និង ការធ្វើទីផ្សារតាមវិធីរបស់ពួកគេ ដើម្បីសម្រេចបាននូវគម្រោង និង កម្មវិធីនៃការតភ្ជាប់ជាមួយដៃគូអាស៊ី។

## គំនិតផ្ដួចផ្ដើមនៅអាស៊ីសម្រាប់ការតភ្ជាប់អាស៊ី-អឺរ៉ុប

ទ្វីបអាស៊ីគឺជាជម្រកនៃផែនការ និង គម្រោងតភ្ជាប់ជាច្រើន។ បន្ទាប់ពីបានដាក់ចេញនូវ MPAC រួចមក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ទទួលបានទំនុកចិត្តនៅក្នុងការកំណត់ផែនការតភ្ជាប់ រួមជាមួយកំណើនសេដ្ឋកិច្ច និង ការកសាងសហគមន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ផែនការតភ្ជាប់នៅតាមតំបន់សំខាន់ៗផ្សេងទៀតនៅអាស៊ី រួមមាន ច្រករបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ, បណ្ដាញផ្លូវហាយវេអាស៊ី, ផ្លូវហាយវេត្រីភាគីរវាងប្រទេសឥណ្ឌា-ប្រទេសមីយ៉ាន់ម៉ា-ប្រទេសថៃ, តំបន់ត្រីកោណអភិវឌ្ឍន៍រវាងប្រទេសឥណ្ឌូនេស៊ី-ប្រទេសម៉ាឡេស៊ី-ប្រទេសថៃ, កម្មវិធីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅតំបន់អាស៊ីកណ្ដាល និង កម្មវិធីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅអនុតំបន់អាស៊ីខាងត្បូង។

EU សម្រេចបាននូវសហគមន៍អឺរ៉ុបមួយដែលមានការតភ្ជាប់យ៉ាងរលូន និង បានធ្វើសមាហរណកម្មគ្រប់ជ្រុងជ្រោយ។ កិច្ចសហប្រតិបត្តិការណ៍លើវិស័យពាណិជ្ជកម្ម និង សេដ្ឋកិច្ចជាច្រើន ការតភ្ជាប់ផ្អែកស្ថាប័ន និង ផែនការនានា មានអត្ថិភាព រវាងប្រទេសនានានៃ EU និង ទ្វីបអាស៊ី។ ទោះបីជាយ៉ាងណាក៏ដោយ ផែនការតភ្ជាប់អន្តរទ្វីបដែលតភ្ជាប់ទ្វីបអឺរ៉ុប និង ទ្វីបអាស៊ីមានចំនួនតិចតួច។ ចំណុចដែលសំខាន់ មានតែគម្រោងនៅខាងទ្វីបអាស៊ីប៉ុណ្ណោះដែលមានភាពច្បាស់លាស់ និង កំពុងស្ថិតនៅក្រោមការអនុវត្ត។ យុទ្ធសាស្ត្ររបស់អឺរ៉ុបចំពោះការតភ្ជាប់ EU–អាស៊ី ត្រូវបានរៀបរាប់លម្អិតនៅក្នុងអភិក្រមនៃយុទ្ធសាស្ត្រនោះ ប៉ុន្តែគម្រោងជាក់លាក់មិនទាន់បានអនុវត្តនៅឡើយទេ។

## ១. គំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ

ប្រធានាធិបតេយ្យ Xi Jinping បានចាប់ផ្តើមប្រើប្រាស់ BRI ជាគំនិតផ្តួចផ្តើមនៃគោលនយោបាយបរទេសដ៏ពិសេសមួយនៅក្នុងអំឡុងពេលទស្សនកិច្ចជាផ្លូវការរបស់លោកទៅកាន់ប្រទេសកាហ្សាស្ថាន កាលពីឆ្នាំ២០១៣។ BRI ត្រូវបានគេរំពឹងទុកថានឹងក្លាយជាផែនការអភិវឌ្ឍន៍ដ៏ធំមួយដើម្បីបង្កើតការតភ្ជាប់ជាសកល ដោយមានប្រទេសចិនជាចំណុចកណ្តាល។ យោងតាម "ចក្ខុវិស័យដើម្បីកិច្ចសហប្រតិបត្តិការតាមផ្លូវសមុទ្រ ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ" ដែលត្រូវបានដាក់ចេញដោយរដ្ឋាភិបាលនៃប្រទេសចិនកាលពីឆ្នាំ ២០១៥ នោះ (Xinhua, 2017)៖

> គម្រោងតភ្ជាប់នៃគំនិតផ្តួចផ្តើមនេះនឹងជួយបន្ស៊ី និង សម្របសម្រួលយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសនានាឲ្យស្របគ្នានឹងគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ, អាចប្រើប្រាស់សក្តានុពលនៃទីផ្សារនៅក្នុងតំបន់នេះ, លើកកម្ពស់ការវិនិយោគ និង ការប្រើប្រាស់, បង្កើតតម្រូវការ និង ឱកាសការងារ, ពង្រឹងការផ្លាស់ប្តូររវាងមនុស្ស និង មនុស្ស និង ការផ្លាស់ប្តូរវប្បធម៌ និង ការរៀនសូត្រពីគ្នាទៅវិញទៅមកនៅក្នុងចំណោមប្រជាជននៃប្រទេសដែលពាក់ព័ន្ធ និង ធ្វើឲ្យពួកគេមានការយល់ដឹង មានទំនុកចិត្ត និង គោរពគ្នាទៅវិញមក និង រស់នៅប្រកបដោយភាពសុខដុមរមនាមានសេចក្តីសុខ និង វិបុលសុខ។

### រូបភាពទី១៖ រូបភាពដែលបង្ហាញអំពីគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ

| | |
|---|---|
| ២០១៣ | ឆ្នាំដែល BRI ត្រូវបានប្រកាសជាលើកដំបូង |
| ២០១៧ | ឆ្នាំដែល BRI ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសចិនជាផ្លូវការ |
| ១៣៨ | ចំនួនប្រទេសដែលជាភាគីផ្លូវការនៃ BRI |
| ៤៥១ | ចំនួនគម្រោងដែលជាផ្នែកនៃ BRI (គិតត្រឹមខែធ្នូ ឆ្នាំ២០១៩) |
| ១ ទ្រីលាន | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិកដែលប្រទេសចិនបានសន្យាថានឹងផ្តល់មូលនិធិដល់ BRI |
| ៨០ប៊ីលាន | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិកដែលប្រទេសចិនបានវិនិយោគដោយផ្ទាល់នៅក្នុង BRI |

BRI = គំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ US = ដុល្លារអាមេរិក
ប្រភព៖ អ្នកនិពន្ធ

គោលបំណងពង្រឹងការតភ្ជាប់ អាស៊ី-អឺរ៉ុប គឺជាចំណុចសំខាន់នៃគំនិតផ្តួចផ្តើមនេះ។

គម្រោង និង សកម្មភាព ដែលស្ថិតនៅក្រោម BRI ភាគច្រើនផ្តោតលើហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូននៅក្នុង និង រវាងទ្វីបអាស៊ី និង អឺរ៉ុប។ ប៉ុន្តែ គេគួរតែកត់សម្គាល់ផងដែរថា វិសាលភាពផ្នែកភូមិសាស្ត្ររបស់ BRI គឺក្បែរសកល ពីព្រោះវាក៏គ្របដណ្តប់លើទ្វីបអាហ្រ្វិក ទ្វីបអូសេអានី និង ទ្វីបអាមេរិកឡាទីនផងដែរ។ លើសពីនេះទៀត ក្រៅពីការតភ្ជាប់ផ្នែកដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធផ្នែកថាមពល និង គមនាគមន៍ ក៏ជាវិស័យសំខាន់ៗនៃ BRI ផងដែរ។ BRI មានអត្ថន័យសំខាន់ៗចំពោះសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលកិច្ចពហុភាគី និង ទំនាក់ទំនងរវាងប្រជាជន និង ប្រជាជននៅទូទាំងទ្វីបអាស៊ី-អឺរ៉ុប និង ទ្វីបដទៃទៀតផងដែរ។ ប្រទេសជាច្រើន ទោះបីជាមិនមែនទាំងអស់ក៏ដោយ នៅក្នុងទ្វីបអាស៊ី និង អឺរ៉ុប បានចុះអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីជាមួយប្រទេសចិន ដើម្បីកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធលើសកម្មភាពនានាដែលទាក់ទងនឹង BRI (មណ្ឌលគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវបៃតង ឆ្នាំ២០២០)។

នៅខណៈពេលដែល BRI គឺជាផែនការកម្រិតខ្ពស់ ពីព្រោះវាគឺជាគោលនយោបាយបរទេសដ៏ពិសេសរបស់ប្រធានាធិបតី Xi នោះ វាមិនមែនជាយុទ្ធសាស្ត្រដែលផ្អែកលើការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំតែម្នាក់នោះទេ។ ផ្ទុយមកវិញ វាបង្ហាញអំពីល្បាយ (ដែលពេលខ្លះមានភាពស្មុគស្មាញ) នៃអន្តរកម្មពីថ្នាក់លើមកថ្នាក់ក្រោម និង ពីថ្នាក់ក្រោមទៅថ្នាក់លើ រវាងតួអង្គជាច្រើននាក់នៅក្នុងប្រទេសចិន។ យុទ្ធសាស្ត្រមានប្រភពដើមមកពីគំនិត និង ទម្លាប់អនុវត្តនៅថ្នាក់ក្រោមជាតិ ដែល BRI លើកកម្ពស់ឲ្យក្លាយជាថ្នាក់ជាតិ (Summers ឆ្នាំ២០១៦)។ កងកម្លាំងដ៏ចម្បងមួយ ពោលគឺក្រុមការងារតូចដែលឈានមុខគេលើការជំរុញការស្ថាបនាខ្សែក្រវាត់ និង ផ្លូវ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ ដើម្បីពង្រឹងការសម្របសម្រួល BRI នៅក្នុងចំណោមតួអង្គទាំងឡាយនៃប្រទេសចិន ដែលជាប់ពាក់ព័ន្ធនឹង BRI។ ប៉ុន្តែ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទាំងនេះក្តី BRI នៅពេលនេះ នៅតែបន្តរងគ្រោះដោយសារបញ្ហាការសម្របសម្រួលនានា ដែលបណ្តាលមកពីវិសាលភាពរបស់ខ្លួនផ្ទាល់ និង ពហុភាពរបស់តួអង្គដែលពាក់ព័ន្ធ។

ការផ្តល់មូលនិធិដល់ BRI ត្រូវបានបំបែកជាច្រើនផ្នែក (Summers ឆ្នាំ២០២០) ហើយការប៉ាន់ស្មានអំពីថវិកាមានការប្រែប្រួលយ៉ាងខ្លាំង។ មូលនិធិទទួលបានពីច្រើនប្រភព ដែលក្នុងនោះ ធនាគាររដ្ឋ ធនាគារនៃគោលនយោបាយ មូលនិធិទ្រព្យសម្បត្តិអធិបតេយ្យភាព និង IFIs គឺជាអ្នកផ្តល់វិភាគទានសំខាន់បំផុត។ ធនាគាររដ្ឋ និង មូលនិធិអភិវឌ្ឍនៃប្រទេសចិន មានចំណែកធំជាងគេបង្អស់នៃការផ្តល់មូលនិធិ (Dossani, Bouey និង Zhu ឆ្នាំ២០២០)។ ធនាគារអភិវឌ្ឍនៃប្រទេសចិន ធនាគារអាហារ័ណ-នីហារ័ណនៃប្រទេសចិន មូលនិធិផ្លូវសូត្រ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធ

អាស៊ី និង ធនាគារអភិវឌ្ឍន៍ថ្មី គឺជាអ្នកផ្តល់ហិរញ្ញប្បទានសំខាន់ៗ (គណៈកម្មការត្រួតពិនិត្យឡើងវិញលើវិស័យសេដ្ឋកិច្ចនិងមូលបត្ររបស់អាមេរិក-ចិនឆ្នាំ២០១៨)។ពេលវេលាកន្លងផុតទៅតួនាទីផ្នែកហិរញ្ញវត្ថុរបស់ប្រទេសចិនមានការកែប្រែមួយចំនួន ពីព្រោះធនាគារបរទេសបានចូលរួមកាន់តែច្រើន។ លើសពីនេះទៀត បទប្បញ្ញត្តិរបស់ប្រទេសចិនចំពោះការផ្តល់ហិរញ្ញប្បទានដល់គម្រោងមានភាពតឹងរ៉ឹងជាងមុន។

## ធាតុសំខាន់ៗរបស់ BRI

ហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូនដើរតួនាទីដ៏សំខាន់នៅក្នុងអភិក្រមនៃការតភ្ជាប់របស់ BRI។

សកម្មភាពនានាដែលស្ថិតនៅក្រោម BRI ដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូនអាចត្រូវបានបំបែកជាផ្នែកតូចៗ រួមមាន ការផ្តល់ហិរញ្ញប្បទាន និង ការសាងសង់ ការដឹកជញ្ជូនតាមផ្លូវរថភ្លើង ការដឹកជញ្ជូនតាមសមុទ្រ និង ការដឹកជញ្ជូនតាមផ្លូវអាកាស។ បន្ថែមពីលើហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូនទៀតនោះ វិស័យឌីជីថលក៏ជាលក្ខណៈពិសេសនៃការតភ្ជាប់ដ៏សំខាន់មួយរបស់ BRI ផងដែរ។

### ក. ការផ្តល់ហិរញ្ញប្បទាន និង ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន

តួអង្គនៃប្រទេសចិន តាមធម្មតា មានតួនាទីដ៏សំខាន់មួយនៅក្នុងគម្រោងនានាដែលមានបំណងធ្វើការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន និង ថាមពលនៅក្នុងក្របខណ្ឌរបស់ BRI។ នៅក្នុងចំណោមភាគីចុះកិច្ចសន្យាសំខាន់ៗទាំង ១០ នៅទូទាំងសកលលោក កាលពីឆ្នាំ២០១៩ មានប្រាំពីរ គឺជាក្រុមហ៊ុនចិន (ENR ឆ្នាំ២០១៩)[1] ៖

នៅក្នុងឆ្នាំ២០១៨ ភាគីចិនដែលចុះកិច្ចសន្យា ទទួលបានប្រាក់ចំណូលពីការសាងសង់ជាអន្តរជាតិ ចំនួន ២៤,៤% (Kurimoto ឆ្នាំ២០១៩)។ ទ្វីបអាស៊ី អាហ្វ្រិក និង មជ្ឈិមបូព៌ា គឺជាតំបន់សំខាន់ៗដែលមានជាប់ពាក់ព័ន្ធនឹងភាគីចិនដែលចុះកិច្ចសន្យា (Morris ឆ្នាំ២០២០)។ ទ្វីបអឺរ៉ុប និង អាមេរិកឡាទីន ត្រូវបានគេមើលឃើញថា មិនសូវមានសកម្មភាពនៅក្នុងគម្រោងនេះទេ។ វិស័យអាទិភាពសម្រាប់ភាគីចិនដែលចុះកិច្ចសន្យា នៅទ្វីបអាស៊ី-អឺរ៉ុប ដែលនៅខាង

[1] ក្រុមហ៊ុនត្រូវបានចាត់ចំណាត់ថ្នាក់តាមប្រាក់ចំណូលនៃការសាងសង់ដែលទទួលបាននៅខាងក្រៅប្រទេសដើមកំណើតរបស់ក្រុមហ៊ុននីមួយៗនៅក្នុងឆ្នាំ២០១៨ ជាលានដុល្លារអាមេរិក៖ (i) State Construction Engineering Corporation Ltd.; (ii) China Railway Group Ltd.; (iii) China Railway Construction Corporation Ltd.; (iv) China Communications Construction Group Ltd.; (v) Power Construction Corporation of China; (vi) China Metallurgical Group Corporation និង (vii) Shanghai Construction Group Co. Ltd.។

ក្រៅប្រទេសចិន រួមមាន អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង (ជាពិសេសប្រទេសប៉ាគី-ស្ថាន) មជ្ឈិមបូព៌ា និង អឺរ៉ុប (Balkans ខាងលិច)។

ធនាគារអាហារ័ណ-នីហារ័ណនៃប្រទេសចិន និង ធនាគារអភិវឌ្ឍនៃប្រទេសចិន គឺជាអ្នកផ្តល់ហិរញ្ញប្បទានសំខាន់ៗនៃគម្រោងសាងសង់របស់ BRI ដែលផ្តល់មូលនិធិប្រហែល ៣៣៤ ប៊ីលានដុល្លារអាមេរិក នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅដំណាក់កាលខុសៗគ្នានៃការអភិវឌ្ឍ (ផ្នែកស្រាវជ្រាវ និង ទីផ្សារ ឆ្នាំ២០១៩)។ បន្ថែមពីលើធនាគារទាំងពីរនេះទៀត ធនាគារពាណិជ្ជកម្មចិន និង ធនាគារពាណិជ្ជកម្មអន្តរជាតិ ជាញឹកញាប់ បានចូលរួមនៅក្នុងការផ្តល់ហិរញ្ញប្បទានផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

វឌ្ឍនភាព៖ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ BRI ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ ឆ្នាំ២០១៩ កិច្ចសន្យាសាងសង់នៃប្រទេសចិនដែលតម្លៃជាង ៥០០ ប៊ីលានដុល្លារ ត្រូវបានចុះហត្ថលេខា (ឧ. កំពង់ផែ ផ្លូវរថភ្លើង ផ្លូវល្បឿនលឿន អាកាសយានដ្ឋាន ស្ពាន រោងចក្រអគ្គិសនី និង ទំនប់ទឹក) (AEI ២០២០)។ ការផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំបានឡើងដល់ចំណុចខ្ពស់បំផុតនៅក្នុងឆ្នាំ២០១៤ ដែលមានចំនួនប្រហែល ៩៥ ប៊ីលានដុល្លារ បន្ទាប់មកបានធ្លាក់ចុះរហូតដល់ ៧៦ ប៊ីលានដុល្លារ នៅក្នុងឆ្នាំ២០១៨។ គម្រោងជាច្រើនចំណាយពេលដើម្បីបញ្ចប់ យូរជាងការរំពឹងទុក។ និន្នាការនេះមានភ័ស្តុតាងបញ្ជាក់កាន់តែច្រើនបន្ទាប់ពីមានជំងឺរាតត្បាតសកល វីរុសកូរ៉ូណា (កូវីដ-១៩)។

## ខ. ការគ្រប់គ្រង និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន៖ ផ្លូវរថភ្លើង សមុទ្រ និង ផ្លូវអាកាស

ផ្លូវរថភ្លើងសម្រាប់ដឹកជញ្ជូនទំនិញ BRI បានដាក់ឲ្យដំណើរការរវាងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ពោលគឺច្រករបៀងចម្បងធ្វើការតភ្ជាប់ទីក្រុងជាច្រើននៃប្រទេសចិន និង អឺរ៉ុប តាមរយៈ ប្រទេសកាហ្សាស្ថាន ម៉ុងហ្គោល រុស្ស៊ី និង បេឡារុស្ស។ ច្រករបៀបផ្សេងទៀតតភ្ជាប់ប្រទេសចិន និង អឺរ៉ុប តាមរយៈតំបន់អាស៊ីកណ្តាល និង មជ្ឈិមបូព៌ា។

ផ្លូវរថភ្លើងសម្រាប់ដឹកជញ្ជូនទំនិញ BRI រវាងអឺរ៉ុប និង ប្រទេសចិនបានទទួលឧបត្ថម្ភធនជាច្រើនពីរដ្ឋាភិបាលកណ្តាល រដ្ឋាភិបាលប្រចាំខេត្ត និង ស្រុកនៃប្រទេសចិន ដែលជួយឲ្យរថភ្លើងធ្វើប្រតិបត្តិការបាន និង បង្កើតផ្លូវថ្មីៗ។ ក្រុមហ៊ុនផ្តល់សេវារថភ្លើងទាំងជារបស់ប្រទេសចិន និង មិនមែនជារបស់ប្រទេសចិន មានសិទ្ធិទទួលបានឧបត្ថម្ភកធន។

ក្រៅពីរដ្ឋាភិបាលកណ្តាល និង រដ្ឋាភិបាលប្រចាំខេត្តទៀតហើយនោះ ក្រុមហ៊ុន China State Railway Group Co. Ltd. និង ក្រុមហ៊ុនផ្តល់សេវាផ្លូវរថភ្លើងជាអន្តរជាតិ គ្រប់គ្រងផ្លូវរថភ្លើង។ នៅឆ្នាំ២០២២ ឧបត្ថម្ភកធននឹងត្រូវលុបចោល ដោយសារចរាចរណ៍នៃការដឹកជញ្ជូនទំនិញគួរតែអាចធ្វើប្រតិបត្តិការដោយគ្មានឧបត្ថម្ភកធនបាន (Leng ២០១៩)។

**វឌ្ឍនភាព** នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២០ រថភ្លើងដែលដឹកជញ្ជូនទំនិញរវាងប្រទេសចិន-អឺរ៉ុប បានធ្វើដំណើរចំនួន ១.៩៤១ លើក ដោយកត់សម្គាល់ថាមានកំណើន ១៥% ពីមួយឆ្នាំទៅមួយឆ្នាំ ចាប់តាំងពីពេលដែលសេវាផ្លូវរថភ្លើងចិន-អឺរ៉ុបត្រូវបានចាប់ផ្តើមនៅក្នុងឆ្នាំ២០១១។ មានទំនិញកាន់តែច្រើនត្រូវបានដឹកជញ្ជូនពីប្រទេសចិន ទៅកាន់ទ្វីបអឺរ៉ុប ហើយក៏មានទំនិញកាន់តែច្រើនត្រូវបានដឹកជញ្ជូនពីទ្វីបអឺរ៉ុបទៅកាន់ប្រទេសចិនវិញដែរ។

ការអភិវឌ្ឍកំពង់ផែ និង ការគ្រប់គ្រងចំណតនៅតាមបណ្តោយផ្លូវសូត្រសមុទ្រ គឺជាទិដ្ឋភាពដែលសំខាន់ជាងគេបំផុតនៃគម្រោងផ្លូវសមុទ្រនានានៅក្នុង BRI។ ប្រតិបត្តិករចំណតសំខាន់ៗនៅក្នុង BRI មានមូលដ្ឋាននៅក្នុងប្រទេសចិន (រួមទាំង ហុងកុង ផងដែរ) (Duchâtel និង Duplaix ២០១៨: ១៤) ទោះបីជាអាជ្ញាធរនៃប្រទេសសិង្ហបុរី (ប្រតិបត្តិករចំណតដ៏ធំជាងគេបំផុតនៅទូទាំងពិភពលោក), Dubai Ports World, AP Moller Terminals, CMA CGM, Evergreen, និង Eurogate មានភាពសកម្មក៏ដោយ។ ផ្លូវសូត្រសមុទ្រ កំពុងតែត្រូវបានអនុវត្តទៅទូទាំងទ្វីបអាស៊ីមជ្ឈិមបូព៌ា និង តំបន់អាហ្វ្រិកខាងជើង អឺរ៉ុប និង អាហ្វ្រិកខាងកើត។

ដោយសារតែកង្វះខាតការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដើម្បីបំពេញតាមតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍនៅទូទាំងតំបន់មហាសមុទ្រឥណ្ឌា ប្រទេសភាគច្រើនបានស្វាគមន៍ឱកាសធ្វើការដេញថ្លៃដើម្បីទទួលបានការផ្តល់មូលនិធិពីប្រទេសចិន (Green ឆ្នាំ២០១៨)។ ប្រតិបត្តិករចំណតធំៗ ដែលកាន់កាប់ដោយរដ្ឋនៃប្រទេសចិន ទទួលបានកម្ចីដែលមានការប្រាក់ទាប ពីធនាគាររដ្ឋចិន និង ការផ្តល់ហិរញ្ញប្បទានដល់ BRI ពីសំណាក់ធនាគារអភិវឌ្ឍន៍នៃប្រទេសចិន (Johnson ឆ្នាំ២០១៨)។ ប្រតិបត្តិករកំពង់ផែចិន បានធ្វើអន្តរជាតូបនីយកម្មយ៉ាងឆាប់រហ័សចាប់ពីឆ្នាំ២០១០ មក ដើម្បីក្លាយជាដៃគូប្រកួតប្រជែងដ៏រឹងមាំនៃប្រតិបត្តិករចំណតធំៗនៅលើសកលលោក។

ចាប់តាំងពី ឆ្នាំ២០១៥ មក អាកាសចរណ៍បានក្លាយជាផ្នែកមួយនៃ BRI ជាផ្លូវការ ទោះបីជាគ្មានលក្ខណៈពិសេសក៏ដោយ (មជ្ឈមណ្ឌលសម្រាប់អាកាសចរណ៍ CAPA ឆ្នាំ២០១៨)។ ក្រុមហ៊ុនចិនមានភាពសកម្ម ប៉ុន្តែមិនបានដើរយ៉ាងសំខាន់នៅក្នុងការតភ្ជាប់សេវាតាមផ្លូវអាកាស

នៅទូទាំងអាស៊ី-អឺរ៉ុបនោះទេ។ ក្រុមហ៊ុនអាកាសចរណ៍បានពង្រីកការគ្របដណ្តប់របស់ពួកគេយ៉ាងសន្សឹមៗតែប៉ុណ្ណោះ។ នៅក្នុងប្រទេសជាច្រើននៃ BRI ក្រុមហ៊ុនអាកាសចរណ៍ China Southern Airlines គឺជាក្រុមហ៊ុនអាកាសចរណ៍ចិនតែមួយគត់ដែលកំពុងប្រតិបត្តិការ។

ចាប់ពីឆ្នាំ២០១៣ រហូតដល់ ឆ្នាំ២០១៩ ក្រុមហ៊ុនចិនបានវិនិយោគទឹកប្រាក់ចំនួន ២១,៥៧ ប៊ីលានដុល្លារអាមេរិក លើវិស័យអាកាសចរណ៍សកល។ នៅពេលដំណាលគ្នានោះ កិច្ចសន្យាសាងសង់របស់ប្រទេសចិន នៅក្នុងវិស័យអាកាសចរណ៍សកល ដែលមានទឹកប្រាក់ចំនួន ៩,៦៨ ប៊ីលានដុល្លារ ត្រូវបានចុះហត្ថលេខាជាមួយប្រទេសដៃគូ (AEI ២០២០)។ ប្រទេសចិនបានក្លាយជាប្រទេសដើមកំណើត និង ទិសដៅដ៏សំខាន់មួយនៃចរាចរណ៍ផ្លូវអាកាស។ អ្នកធ្វើដំណើរតាមផ្លូវអាកាសពីប្រទេសចិន បានកើនឡើងពី ៣៥២,៧៩ លាននាក់ កាលពីឆ្នាំ២០១៣ រហូតដល់ ៦១១,៤៣ លាននាក់នៅក្នុងឆ្នាំ២០១៨ (ធនាគារពិភពលោក ២០២០b)។ ជំងឺរាតត្បាតសកល កូវីដ-១៩ បានរំខានដល់និន្នាការកាលពីមុន ស្របពេលជាមួយគ្នានោះ ទំនិញតាមផ្លូវអាកាសរវាងប្រទេសចិន-អឺរ៉ុប មានការកើនឡើងដោយសារការដឹកជញ្ជូនបរិក្ខារពេទ្យ និង ឱសថ (Knowler ឆ្នាំ២០២០)។

## គ. ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

សមាសធាតុឌីជីថលរបស់ BRI ឬ ផ្លូវសូត្រឌីជីថល (DSR) ត្រូវបានប្រកាសជាលើកដំបូងនៅក្នុងឆ្នាំ២០១៥។ DSR មានបំណងពង្រឹងការតភ្ជាប់ផ្នែកឌីជីថលនៅលើសកលលោក ដោយមានប្រទេសចិនស្ថិតនៅចំណុចកណ្តាល តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ពង្រីកការស្នើផ្តល់ការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក នៅក្នុងចំណោមផ្នែកដទៃទៀត។

ចិនដើរតួនាទីជាតួអង្គដ៏សំខាន់នៅទីនេះ-ក្នុងនាមជាអ្នកផលិតផលិតផលលក់តាមរយៈពាណិជ្ជកម្មអេឡិចត្រូនិក ក្នុងនាមជាវេទិកាពាណិជ្ជកម្មអេឡិចត្រូនិក និង ក្នុងនាមជាអ្នកផ្តល់ភ័ស្តុភារ និង ការដឹកជញ្ជូនដល់ប្រទេសនានានៃ BRI។ តួអង្គសំខាន់ៗ រួមមាន ក្រុមហ៊ុនឯកជនខ្នាតយក្សផ្នែកបច្ចេកវិទ្យានៃប្រទេសចិន ដូចជា Alibaba, Tencent, JD.com, Baidu, Huawei និង ZTE ដែលជាផ្នែកនៃ DSR ដែលលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិក និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅលើសកលលោក។ នៅខណៈពេលដែលភាគច្រើនជាក្រុមហ៊ុនឯកជននោះ ពួកគេជាញឹកញាប់ ទទួលបានការគាំទ្រផ្នែកនយោបាយពីរដ្ឋាភិបាលចំពោះប្រតិបត្តិការជាអន្តរជាតិរបស់ពួកគេ។ ធនាគារចិនផ្តល់មូលនិធិសម្រាប់សកម្មភាពទាំងនេះ (ក្រុមប្រឹក្សាប្រចាំរដ្ឋ ឆ្នាំ២០១៦; The Economist ឆ្នាំ២០២០; Triolo et al. ឆ្នាំ២០២០)។

## ឃ. ផ្លូវឆ្ពោះទៅកាន់ភាពជោគជ័យសម្រាប់ BRI

នៅខណៈពេលដែលប្រទេសចិនបន្តអភិវឌ្ឍ BRI និង ធ្វើការកែសម្រួលគំនិតផ្តួចផ្តើមនេះ នៅពេលដែលវាបន្តដំណើរទៅខាងមុខទៀតនោះ (Rolland ឆ្នាំ២០១៩) មានបញ្ហាប្រឈមពីរបានលេចឡើង ដោយសារតែវាមានទំនាក់ទំនងយ៉ាងខ្លាំងនឹងការតភ្ជាប់អាស៊ី-អឺរ៉ុប។ ទីមួយ កិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និង តួអង្គអន្តរជាតិដទៃទៀតដែលបានចូលរួមនៅក្នុងការផ្តល់ហិរញ្ញប្បទាន និង សាងសង់ហេដ្ឋារចនាសម្ព័ន្ធ នៅតែមានកម្រិត។ គម្រោងជាច្រើនបានរួមបញ្ចូលតួនាទីដ៏សំខាន់មួយសម្រាប់តួអង្គចិន ឬ តួអង្គអន្តរជាតិដទៃទៀត។ គម្រោងដែលអ្នកផ្តល់ហិរញ្ញប្បទាន និង អ្នកចុះកិច្ចសន្យានៃប្រទេសចិនតំណាងឲ្យយ៉ាងខ្លាំងក្លានោះ ជាញឹកញាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងទំនាក់ទំនងទ្វេភាគីរវាងរដ្ឋាភិបាល និង រដ្ឋាភិបាល។ ដើម្បីសម្រេចបានការធ្វើឲ្យរឹងមាំទៅវិញទៅមក នៅកម្រិតខ្ពស់ រវាង BRI និង គំនិតផ្តួចផ្តើមនៃការតភ្ជាប់ដែលមិនមែនជារបស់ប្រទេសចិន ដែលអាចនាំមកនូវគុណសម្បត្តិដល់ការបង្រួបបង្រួមកម្លាំង និង ប្រសិទ្ធភាពនោះ តម្រូវឲ្យមានការបង្រួបបង្រួមបទដ្ឋានដើម្បីតម្លាភាព ការប្រកួតប្រជែងដោយយុត្តិធម៌ និង ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម។ ចំណុចនេះក៏អនុវត្តចំពោះហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន ថាមពល និង ឌីជីថលផងដែរ។

ទីពីរ កំណើនដែលគួរឲ្យកត់សម្គាល់នៃសម្ពាធផ្អែកភូមិសាស្ត្រនយោបាយនៅក្នុងចំណោមប្រទេសមហាអំណាច នាំឲ្យមានដំណើរការនយោបាយនីយកម្មនៃទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ។ ចំណុចនេះធ្វើឲ្យមានភាពស្មុគស្មាញកាន់តែច្រើនឡើងចំពោះរដ្ឋាភិបាល និង ក្រុមហ៊ុន ចិន និង មិនមែនចិន នៅក្នុងការសហការជាមួយគ្នាទៅវិញទៅមកនៅក្នុងគំនិតផ្តួចផ្តើមនៃការតភ្ជាប់ក្នុងទ្រង់ទ្រាយធំ។ ការបែងចែករវាងនយោបាយ និង សេដ្ឋកិច្ច នៅកម្រិតជាក់លាក់មួយ គឺមានភាពចាំបាច់ដើម្បីធ្វើឲ្យទីភ្នាក់ងាររដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុន និង ភាគីពាក់ព័ន្ធនៅក្នុងមូលដ្ឋានអាចផ្តោតលើការពង្រឹងជាអតិបរមានូវកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍ និង ការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

ការតភ្ជាប់ អាស៊ី-អឺរ៉ុប ដែលមានភាពល្អប្រសើរឡើង រួមចំណែកដល់គោលដៅនៃកំណើនដែលមានបរិយាប័ន្ន និង ចីរភាពរបស់ ASEM។ BRI របស់ប្រទេសចិន មិនត្រឹមតែជាគំនិតផ្តួចផ្តើមនៃការតភ្ជាប់តែប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាគំនិតផ្តួចផ្តើមដែលមានវិសាលភាពធំជាងគេបំផុត។ ASEM អាចធ្វើការរួមចំណែកដ៏សំខាន់មួយចំពោះការតភ្ជាប់អាស៊ី-អឺរ៉ុប តាមរយៈការសម្របសម្រួលការចូលរួមរវាង BRI និង គំនិតផ្តួចផ្តើមដទៃទៀត។ វាអាចធ្វើបែបនេះបានតាមរយៈការអភិវឌ្ឍបទដ្ឋាននៃការតភ្ជាប់រួមមួយសម្រាប់ទ្វីបអាស៊ី និង អឺរ៉ុប និង តាមរយៈការផ្តល់វេទិកាមិនពាក់ព័ន្ធនឹងនយោបាយ ដល់កិច្ចសហប្រតិបត្តិការពហុភាគីស្តីពីការតភ្ជាប់អាស៊ី-អឺរ៉ុប។

## ២.ភាពជាដៃគូរវាង EU–ជប៉ុន ស្ដីពីការតភ្ជាប់ប្រកបដោយចីរភាព និង ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ

ផែនការរបស់ប្រទេសជប៉ុនចំពោះហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ និង ការអភិវឌ្ឍប្រកបដោយចីរភាពគឺជាមូលដ្ឋានគ្រឹះនៃភាពជាដៃគូលើការតភ្ជាប់នៅក្នុងតំបន់។ ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ គឺជាចំណុចសំខាន់នៃគំនិតផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធ និង ការតភ្ជាប់ទាំងអស់របស់ប្រទេសជប៉ុន។ កាលពីឆ្នាំ២០១៩ ប្រទេសជប៉ុន និង EU បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ពួកគេ ចំពោះការបង្កើតភាពជាដៃគូនៃការតភ្ជាប់មួយដែលផ្អែកលើចីរភាពដែលជាគុណតម្លៃរួម ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ និង ជំនឿរបស់ពួកគេចំពោះអត្ថប្រយោជន៍នៃទីផ្សារប្រកួតប្រជែងនៅកម្រិតមួយ។

នៅក្នុងភាពជាដៃគូរវាង EU–ជប៉ុន ចំពោះការតភ្ជាប់ប្រកបដោយចីរភាព និង ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ EU និង ប្រទេសជប៉ុនមានបំណងធ្វើការជាមួយគ្នា នៅគ្រប់កម្រិតទាំងអស់នៃការតភ្ជាប់ ទាំងទ្វេភាគី និង ពហុភាគី ដែលរួមបញ្ចូលទាំងការផ្លាស់ប្តូរផ្នែកឌីជីថល ការដឹកជញ្ជូន ថាមពល និង ការផ្លាស់គ្នារវាងប្រជាជន និង ប្រជាជនផងដែរ (ក្រសួងការបរទេសប្រទេសជប៉ុន ឆ្នាំ២០១៩)។ ផែនការតភ្ជាប់នឹងធ្វើការពិចារណាយ៉ាងពេញលេញអំពីភាពចាំបាច់ និង តម្រូវការរបស់ដៃគូ និង យកចិត្តទុកដាក់ខ្លាំងបំផុតចំពោះសមត្ថភាពផ្នែកសារពើពន្ធ និង ចីរភាពនៃបំណុលរបស់ពួកគេ។ EU និង ប្រទេសជប៉ុន នឹងសម្របសម្រួលកិច្ចសហប្រតិបត្តិការលើការតភ្ជាប់ និង ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ ផ្សេងៗគ្នា របស់ពួកគេជាមួយប្រទេសលោកទីបីដែលជាដៃគូ ដូចដែលអាចកត់សម្គាល់ឃើញនៅតាមតំបន់ Balkans ខាងលិច អឺរ៉ុបខាងកើត អាស៊ីកណ្តាល និង ឥណ្ឌូប៉ាស៊ីហ្វិក ព្រមទាំង អាហ្វ្រិកផងដែរ។

ក្នុងគោលបំណងនៃការប្តេជ្ញាចិត្តលើកកម្ពស់ការតភ្ជាប់ដែលផ្អែកលើច្បាប់ជាសកល ភាគីទាំងសងខាងមានបំណងសហការជាមួយអង្គភាពអន្តរជាតិ និង ប្រចាំតំបន់ រួមបញ្ចូលទាំងវេទិកាអន្តរជាតិផងដែរ ដូចជា G7, G20, OECD, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារអឺរ៉ុបដើម្បីការស្ដាបនាឡើងវិញ និង ការអភិវឌ្ឍ, និង ADB។ ជាមួយគ្នានឹងកិច្ចព្រមព្រៀងភាពជាដៃគូលើវិស័យសេដ្ឋកិច្ចរវាងប្រទេសជប៉ុន-EUនេះដែរការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្មដើម្បីពាណិជ្ជកម្ម និង ការវិនិយោគដោយសេរី ដោយបើកចំហរ ដោយផ្អែកលើច្បាប់ និង ដោយស្មើភាព គឺជាសមាសធាតុនៃស្ថាប័នដ៏សំខាន់មួយសម្រាប់ភាពជាដៃគូនៃការតភ្ជាប់នេះ។ ភាគីទាំងពីរបានគូសបញ្ជាក់អំពីការរួមចំណែកជាវិជ្ជមាននៃការតភ្ជាប់ប្រកបដោយចីរភាពដល់ការអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និង រំឭកឡើងវិញ

អំពីការត្រៀមខ្លួនជាស្រេចនៅក្នុងការគាំទ្រដល់ប្រទេសដៃគូ នៅក្នុងការបង្កើតមជ្ឈដ្ឋានដែលអនុគ្រោះដល់ការវិនិយោគ។

ទាំង EU និង ប្រទេសជប៉ុនបានគូសបញ្ជាក់ថា ការតភ្ជាប់ផ្នែកឌីជីថលគឺជាកត្តាដែលមានថាមពលនៅក្នុងការធ្វើឲ្យមានកំណើនប្រកបដោយបរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាព រួមបញ្ចូលទាំង តាមរយៈហេដ្ឋារចនាសម្ព័ន្ធផ្នែកឌីជីថល និង ទិន្នន័យ ព្រមទាំង ក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌនៃការធ្វើនិយ័តកម្មផងដែរ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ប្រទេសជប៉ុន និង EU សង្កត់ធ្ងន់ថា ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលពឹងផ្អែកលើលំហាបច្ចេកវិទ្យាដែលមានភាពបើកចំហរ ដោយសេរី មានស្ថេរភាព អាចចូលប្រើប្រាស់បាន អាចធ្វើប្រតិបត្តិការទៅវិញទៅមកបាន អាចជឿជាក់បាន និង មានសុវត្ថិភាព និង ពឹងផ្អែកលើ "លំហូរនៃទិន្នន័យដោយសេរី និង ប្រកបដោយទំនុកចិត្ត" (ដូចដែលបានប្រកាសដោយថ្នាក់ដឹកនាំរបស់ G20 នៅអូសាកា)។ ប្រទេសជប៉ុន និង EU មានបំណងធ្វើការជាមួយគ្នាដើម្បីបកស្រាយបន្ថែមទៀត លើកកម្ពស់ និង ធ្វើប្រតិបត្តិការទស្សនាទាន "លំហូរនៃទិន្នន័យដោយសេរី និង ប្រកបដោយទំនុកចិត្ត" និង មានបំណងពង្រឹងទំនុកចិត្តដែលពាក់ព័ន្ធនឹងសន្តិសុខ និង ឯកជនភាពរបស់ទិន្នន័យផងដែរ ស្របពេលជាមួយគ្នានោះ គោរពតាមក្របខណ្ឌនៃការធ្វើនិយ័តកម្មរបស់ពួកគេរៀងៗខ្លួន ទៅវិញទៅមក។

ប្រទេសជប៉ុន និង EU មានផែនការប្រើប្រាស់កិច្ចសន្ទនាស្តីពីការដឹកជញ្ជូនរវាងប្រទេសជប៉ុន-EU ដែលមានស្រាប់ ជាក្របខណ្ឌមួយសម្រាប់ការចូលរួម និង កិច្ចសហប្រតិបត្តិការលើគ្រប់មធ្យោបាយនៃការដឹកជញ្ជូន និង បញ្ហាដូចៗគ្នាទាំងអស់។ ការពង្រឹងការតភ្ជាប់នៃការដឹកជញ្ជូនប្រកបដោយចីរភាព តាមរយៈកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅ និង ការបង្រួបបង្រួមកម្លាំងនៃក្របខណ្ឌធ្វើនិយ័តកម្ម ការតភ្ជាប់ទៅវិញទៅមកនៃច្រករបៀងសម្រាប់ការដឹកជញ្ជូន និង ការពង្រឹងសុវត្ថិភាព និង សន្តិសុខនៃការដឹកជញ្ជូន នឹងក្លាយជាចំណុចសំខាន់នៃភាពជាដៃគូនៃការតភ្ជាប់នេះ។ ផែនការ និង គម្រោងកិច្ចសហប្រតិបត្តិការនៅក្នុងក្របខណ្ឌភាពជាដៃគូនៃការតភ្ជាប់ នឹងត្រូវបានសម្គាល់ឃើញតាមរយៈក្របខណ្ឌនៃកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការដែលមានស្រាប់ ជាពិសេស នៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រ និង កិច្ចព្រមព្រៀងភាពជាដៃគូលើវិស័យសេដ្ឋកិច្ច រវាងប្រទេសជប៉ុន-EU។ គណៈកម្មាធិការចម្រុះ ដែលត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសជប៉ុន-EU នឹងត្រួតពិនិត្យវឌ្ឍនភាពឡើងវិញជាទៀងទាត់។

លើសពីនេះទៀត កិច្ចសន្ទនាផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និង សេដ្ឋកិច្ចកម្រិតខ្ពស់ រវាងប្រទេសជប៉ុន-EU អាចបំពេញមុខងារជាវេទិកាសម្រាប់កិច្ចពិភាក្សាផ្នែកយុទ្ធសាស្ត្រ នៅក្រោមភាពដៃគូនៃការតភ្ជាប់។

## ៣.គំនិតផ្តួចផ្តើមមហាតំបន់ទន្លេទូមិន

គំនិតផ្តួចផ្តើមមហាតំបន់ទន្លេទូមិន(GTI)(ដើមឡើយហៅថាកម្មវិធីអភិវឌ្ឍតំបន់ទន្លេទូមិន)គឺជាយន្តការនៃកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលមួយនៅក្នុងចំណោមប្រទេសចំនួនបួនៈប្រទេសចិន ប្រទេសម៉ុងហ្គោល ប្រទេសកូរ៉េ និង ប្រទេសរុស្ស៊ី ដោយទទួលបានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (Dulambazar ឆ្នាំ២០១៥)។

កាលពីឆ្នាំ១៩៩៥ រដ្ឋាភិបាលសមាជិកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតយន្តការ GTI ដែលមានបំណងពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និង បច្ចេកទេស និង សម្រេចបាននូវភាពរីកចម្រើនកាន់តែខ្លាំង និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅអាស៊ីឦសាន្ត ជាពិសេសមហាតំបន់ទន្លេទូមិន (GTR)។ GTI ផ្តោតលើតំបន់អាទិភាពនៃការដឹកជញ្ជូន ពាណិជ្ជកម្ម និង ការវិនិយោគ ទេសចរណ៍ កសិកម្ម និង ថាមពល ដោយមានបរិស្ថានជាវិស័យនៃចំណុចប្រសព្វ។

GTI បានក្លាយជាវេទិកាដ៏មានប្រសិទ្ធភាពមួយសម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅក្នុងតំបន់ រវាងប្រទេសជិតខាងនៅទ្វីបអាស៊ី និង អឺរ៉ុប ពោលគឺការពង្រីកកិច្ចសន្ទនាអំពីគោលនយោបាយ ការធ្វើឲ្យមជ្ឈដ្ឋានអាជីវកម្មមានភាពល្អប្រសើរឡើង និង រួមចំណែកដល់សន្តិភាព និង ស្ថេរភាព (Dulambazar ឆ្នាំ២០១៦)។ លើសពីនេះទៀត GTI ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអន្តរជាតិសំខាន់ៗ ដើម្បីរួមគ្នាលើកកម្ពស់តំបន់ និង ធ្វើជាម្ចាស់ផ្ទះនៃសមាគមធនាគារ EXIM នៃអាស៊ីឦសាន្ត ដែលជាយន្តការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍនៅក្នុងតំបន់ និង គណៈកម្មាធិការកិច្ចសហប្រតិបត្តិការនៅក្នុងមូលដ្ឋាន ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការនានានៅក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីឦសាន្ត។

រដ្ឋាភិបាលដែលជាសមាជិករបស់ GTI ផ្តល់អាទិភាពដល់ជម្រើសនៃការអភិវឌ្ឍសម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅក្នុង GTR ដែលមានបំណងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលត្រឹមត្រូវ និង បណ្តាញភ័ស្តុភារ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅក្នុងប្រទេស GTI។ GTI បានរួមបញ្ចូលគ្នារវាង BRI ដែលផ្តួចផ្តើមគំនិតដោយប្រទេសចិន គំនិតផ្តួចផ្តើមអឺរ៉ាស៊ីដែលស្នើឡើងដោយប្រទេស រុស្ស៊ី និង ផ្លូវ Grassland ដោយប្រទេសម៉ុងហ្គោល បានយ៉ាងមានប្រសិទ្ធភាព នៅក្នុងការបង្កើតច្រករបៀងនៃការដឹកជញ្ជូនរវាងប្រទេសចិន-រុស្ស៊ី-ម៉ុងហ្គោល នៅក្នុង GTR។ នៅក្នុងឆ្នាំ២០០១ អនុគណៈកម្មាធិការផ្នែកដឹកជញ្ជូននៃគណៈកម្មាធិការរៀបចំសន្និសីទផ្នែកសេដ្ឋកិច្ចនៃអាស៊ីឦសាន្ត បានសម្គាល់ឃើញច្រករបៀងនៃការដឹកជញ្ជូននៅអាស៊ីឦសាន្ត ចំនួនប្រាំបួន ដែលប្រទេសទាំងអស់នៅក្នុងតំបន់អាចប្រើប្រាស់វាជាច្រករបៀងអន្តរជាតិសំខាន់ៗបាន។ ក្នុងចំណោមច្រករបៀងទាំងប្រាំបួននេះ មានច្រករបៀងចំនួន

ប្រាំមួយត្រូវបានសម្គាល់ឃើញថាជា ច្រករបៀងសម្រាប់ការដឹកជញ្ជូនឆ្លង GTR ដែលរួមមាន ច្រករបៀងផ្លូវគោកទូមិន, ច្រករបៀងផ្លូវដែកទូមិន, ច្រករបៀងសម្រាប់ការដឹកជញ្ជូន Suifenhe, ស្ពានតភ្ជាប់តំបន់ Siberian, ច្រករបៀងសម្រាប់ការដឹកជញ្ជូន Dalian, ច្រករបៀងខាងលិច និង ច្រករបៀងខាងកើតនៃឧបទ្វីបកូរ៉េ និង ច្រករបៀងសម្រាប់ការដឹកជញ្ជូនតាមស្ពានតភ្ជាប់តំបន់នានានៃប្រទេសចិន ដែលតភ្ជាប់ទ្វីបអាស៊ី និង ទ្វីបអឺរ៉ុបតាមរយៈប្រទេសកាហ្សាស្ថាន។ នៅឆ្នាំ២០១៣ បណ្ដាញដឹកជញ្ជូនចំនួនពីរបន្ថែមទៀត រវាង Ulaanbaatar និង Bichigt ត្រូវបានបន្ថែមនៅក្នុងតំបន់ដឹកជញ្ជូនទូមិន។

ផែនការសកម្មភាពយុទ្ធសាស្ត្រ GTI ឆ្នាំ២០១៧–២០២០ បានរំពឹងទុកថានឹងលើកកម្ពស់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដឹកជញ្ជូននៅកម្រិតមូលដ្ឋាន និង មណ្ឌលដឹកជញ្ជូនសំខាន់ៗ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និង ការអភិវឌ្ឍ និង បម្លាស់ទីនៃទំនិញ និង ប្រជាជន។ ក្រុមប្រឹក្សា/គណៈកម្មាធិការអន្តររដ្ឋាភិបាលនៅក្នុងវិស័យចំនួនប្រាំមួយ (ក្រុមប្រឹក្សាលើវិស័យដឹកជញ្ជូន ក្រុមប្រឹក្សាលើវិស័យទេសចរណ៍ គណៈកម្មាធិការសម្របសម្រួលការធ្វើពាណិជ្ជកម្ម ក្រុមប្រឹក្សាលើវិស័យថាមពល ក្រុមប្រឹក្សាលើវិស័យបរិស្ថាន និង គណៈកម្មាធិការកសិកម្ម) ត្រូវបានបង្កើតឡើងដើម្បីធ្វើស្ថាប័ននីយកម្មប្រតិបត្តិការរបស់ GTI នៅក្នុងវិស័យទាំងនេះ និង សម្របសម្រួលសកម្មភាព និង គម្រោងតាមវិស័យជាក់លាក់។ មូលនិធិរួម GTI ដែលបរិច្ចាគដោយប្រទេសសមាជិក គឺជាមូលនិធិដែលស្ថិតក្នុងភារៈគ្រប់គ្រងរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដើម្បីផ្ដល់ហិរញ្ញប្បទានដល់ប្រតិបត្តិការរបស់លេខាធិការដ្ឋាន GTI។ សមាគមធនាគារ EXIM នៃ GTI ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១២ គឺជាអង្គភាពដ៏សំខាន់នៅក្នុងយន្តការផ្ដល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍនៅក្នុងតំបន់ ដើម្បីគាំទ្រដល់គម្រោងនាពេលអនាគត (វេបសាយត៍របស់កម្មវិធី GTI ឆ្នាំ២០២០)។

## ការតភ្ជាប់គំនិតផ្ដួចផ្ដើមខុសៗគ្នា៖ ការបង្កើតទំនិញសមូហភាពសម្រាប់ទ្វីបអឺរ៉ុប និង ទ្វីបអាស៊ី

បញ្ហាប្រឈមគឺ វិធីធានាថានឹងមានការសម្របសម្រួលកាន់តែល្អប្រសើរឡើងនៅក្នុងចំណោមគំនិតផ្ដួចផ្ដើមនានានៃការតភ្ជាប់នៅក្នុងតំបន់។ ប្រសិនបើមានការគ្រប់គ្រងបានយ៉ាងល្អ ចំណុចនេះអាចនាំឲ្យមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និង ចីរភាព កំណើនសុខមាលភាពសង្គមសម្រាប់ប្រជាជន និង ទំនុកចិត្តយ៉ាងស៊ីជម្រៅនៅក្នុងចំណោមដៃគូទាំងឡាយ។ ដូច្នេះ ផែនទីបង្ហាញផ្លូវសម្រាប់ការប្រមូលផ្ដុំកម្លាំងធ្វើការអភិវឌ្ឍនៅក្នុងចំណោមផែនការ និង វិធីសាស្ត្រតភ្ជាប់នានា ត្រូវតែជាចំណុចសំខាន់នៃរបៀបវារៈផ្នែកគោលនយោបាយ។

“ការតភ្ជាប់” តែងតែមានអត្ថិភាព ក្នុងនាមជាគំនិតមួយ ប៉ុន្តែការយកគំនិតនេះមកអនុវត្ត ជាក់ស្តែងដើម្បីកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ និង ជះឥទ្ធិពលលើទំនាក់ទំនងអន្តរជាតិ គឺជាបាតុភូតមួយ ដែលកើតឡើងនាពេលថ្មីៗនេះ (Hawke និង Prakash ឆ្នាំ២០១៦)។ នៅក្នុងមជ្ឈដ្ឋានសកលផែនការតភ្ជាប់កំពុងតែប្រកួតប្រជែងដើម្បីដណ្តើមយកទីផ្សា ការជះឥទ្ធិពល និង លទ្ធផល (តាមធម្មតា ដើម្បីផ្សព្វផ្សាយអំពីប្រទេស)។ ការកែប្រែទិសដៅអភិបាលកិច្ចសកល ទំនាក់ទំនងអន្តរជាតិ ការរំពឹងទុកអំពីប្រជាសាស្ត្រជនវ័យក្មេង ការតភ្ជាប់ផ្នែកបច្ចេកវិទ្យា និង អនាគតនៃការងារ កំពុងតែនាំឲ្យមានការពិភាក្សាអំពីការតភ្ជាប់នាពេលបច្ចុប្បន្ន។ ដោយសារមូលហេតុនេះ ផែនការតភ្ជាប់ឥណ្ឌូ-ប៉ាស៊ីហ្វិក អាស៊ាន-ឥណ្ឌា MPAC BRI និង EU-អាស៊ី កំពុងតែព្យាយាមសង្កត់ធ្ងន់កាន់តែខ្លាំងលើអភិបាលកិច្ច បទដ្ឋាន តម្លាភាព និង គណនេយ្យភាព។ ការផ្តល់ហិរញ្ញប្បទានដល់ហេដ្ឋារចនាសម្ព័ន្ធនៅទ្វីបអាស៊ី និង អឺរ៉ុប មានការប៉ាន់ស្មានខុសៗគ្នា។ ក៏ចាំបាច់ត្រូវរួមបញ្ចូលបន្ទុកចំណាយលើការសម្រប និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅក្នុងផែនការតភ្ជាប់ផងដែរ។

ការស្វែងរកចំណុចប្រសព្វនៅក្នុងចំណោមផែនការតភ្ជាប់ដែលមានលក្ខណៈប្រកួតប្រជែង គឺផ្អែកលើសញ្ញាណដែលថា រាល់ផែនការតភ្ជាប់ទាំងអស់មានវត្ថុបំណងដូចគ្នា។ ភាពបត់បែនរបស់ MPAC, BRI និង ផែនការតភ្ជាប់ដទៃទៀត នឹងបង្ហាញថា នេះមិនមែនជាករណីដែលតែងតែកើតឡើងនោះទេ។ មានភាពខុសៗគ្នាដែលនាំមកជាមួយផែនការនីមួយៗ ដោយសារប្រភពដើមភាពជាដៃគូ ធនធាន និង អាទិភាពផ្នែកនយោបាយ និង សេដ្ឋកិច្ចរបស់អ្នកផ្សព្វផ្សាយ។ ជាចម្បង ការផ្តល់ហិរញ្ញប្បទាននៃផែនការតភ្ជាប់ តម្លាភាពនៅក្នុងការរៀបចំគម្រោង និង គណនេយ្យភាពនៅក្នុងការអនុវត្តគម្រោង គឺជាកង្វល់សកលដ៏សំខាន់ ដែលកើតចេញពីការអនុវត្តផែនការតភ្ជាប់។ ឧទាហរណ៍របស់ BRI មានសារសំខាន់ ពីព្រោះវាបានទាក់ទាញចំណាប់អារម្មណ៍ជាសកលចំពោះបញ្ហានៃការធ្វើផែនការ និង ការរចនាគម្រោង ការផ្តល់ហិរញ្ញប្បទាន និង ចីរភាពនៃបំណុល (Prakash ឆ្នាំ២០១៩)។ ទិដ្ឋភាពជាក់ស្តែងនៃការតភ្ជាប់ឆ្លងតំបន់ ដូចជា យថាប្រភេទផ្នែកបច្ចេកទេស ក្របខណ្ឌគ្រប់គ្រងសុវត្ថិភាព សុខមាលភាពសង្គម និង សេដ្ឋកិច្ចរបស់អ្នកធ្វើការនៅក្នុងវិស័យទាំងនេះ គោលនយោបាយនៃការប្រកួតប្រជែង និង កិច្ចសហប្រតិបត្តិការផ្នែកគយ ស្នើឲ្យមានរបបរួម ឬ ដូចគ្នា សម្រាប់ការដឹកជញ្ជូនទំនិញ និង ប្រជាជននៅទូទាំងទ្វីប។

ដោយសារតែភាពចាំបាច់នៃទំនិញសមូហភាព និង ទំនិញសាធារណៈត្រូវតែមានការទទួលស្គាល់នៅក្នុងចំណោមលក្ខណៈខុសៗគ្នានៃការប្រកួតប្រជែងនោះ ការព្រមព្រៀងជាឯកច្ឆន្ទនៅក្នុងចំណោមរដ្ឋាភិបាល អាជីវកម្ម និង ប្រជាជន កំពុងតែលេចឡើង ដើម្បីបង្កើតយន្តការធ្វើអភិបាល

កិច្ច ដែលយកចិត្តទុកដាក់លើផែនការតភ្ជាប់ខុសៗគ្នាតិចជាង គោលដៅ និង បទដ្ឋាននៃការអភិវឌ្ឍដែលបានព្រមព្រៀងគ្នាជាសកល។ មានគោលដៅណែនាំជាច្រើនបានលេចចេញពី G20, OECD និង ADB ស្តីពីហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ និង ការផ្តល់ហិរញ្ញប្បទានដល់គម្រោងនៃការតភ្ជាប់។ គោលដៅទាំងនេះនឹងជួយបង្កើតវត្ថុបំណងដូចៗគ្នា និង បង្កើតការប្រមូលផ្តុំកម្លាំងនៅក្នុងចំណោមផែនការតភ្ជាប់ខុសៗគ្នា។ ការកំណត់បទដ្ឋានសកលសម្រាប់គម្រោង និង សកម្មភាពនានានៃការតភ្ជាប់មានការលំបាក ប៉ុន្តែ មិនមែនមិនអាចធ្វើបាននោះទេ។ កម្មវិធីអភិវឌ្ឍន៍សកល និង កម្លាំងជំរុញសម្រាប់ពហុភាគីនិយម អាចផ្តល់វិធីភ្ជាប់ទំនាក់ទំនងទៅវិញទៅមកកាន់តែខ្លាំងក្លា រវាងផែនការតភ្ជាប់នានា តាមរយៈរដ្ឋាភិបាល និង ស្ថាប័ននៅក្នុងតំបន់ និង ស្ថាប័នពហុភាគី។ ដំណើរការនៃកិច្ចសហប្រតិបត្តិការពហុភាគីដើម្បីជួយសម្រួលដល់ការវិនិយោគអាចកាត់បន្ថយពហុភាព និង បង្កើតការប្រមូលផ្តុំកម្លាំង និង គោលបំណងដូចគ្នា នៅក្នុងចំណោមផែនការហេដ្ឋារចនាសម្ព័ន្ធខុសៗគ្នា។ ក្របខណ្ឌកិច្ចសហប្រតិបត្តិការពហុភាគីនឹងលើកកម្ពស់ និង កសាងតម្លាភាពនៅក្នុងចំណោមគំនិតផ្តួចផ្តើមដែលមានភាពប្រកួតប្រជែង ហើយវិនិយោគនឹងអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ (Prakash ឆ្នាំ២០២០)។

ផែនការទាំងនោះត្រូវតែមានលក្ខណៈស្របគ្នានឹងអាទិភាពផ្នែកហិរញ្ញវត្ថុ អភិបាលកិច្ច និង ការអភិវឌ្ឍនៃទ្វីបអាស៊ី និង អឺរ៉ុប ហើយអត្ថប្រយោជន៍នៃផែនការទាំងនោះត្រូវទៅដល់ប្រជាជន។ ជាចុងក្រោយ ផែនការតភ្ជាប់ត្រូវតែក្លាយទំនិញសមូហភាពសាធារណៈ ដែលមានបំណងអភិវឌ្ឍប្រជាជន និង តំបន់។ របៀបវារៈស្តីពីកិច្ចសហប្រតិបត្តិការរបស់ ASEM សម្រាប់ទសវត្សរ៍បន្ទាប់គួរតែចែងអំពីទិសដៅសម្រាប់ការផ្លាស់ប្តូរផែនការតភ្ជាប់អាស៊ី-អឺរ៉ុប ឲ្យទៅជាផែនការសមូហភាព ឬ ផែនការរួមសម្រាប់មនុស្សគ្រប់រូប។

# ឯកសារយោង

AEI (2020), 'China Global Investment Tracker'. Washington, DC: American Enterprise Institute. https://www.aei.org/china-global-investment-tracker/ (accessed 30 June 2020).

ASEM (2000), The Asia–Europe Cooperation Framework (AECF) 2000. Seoul: Asia Europe Meeting.

ASEM (2014), 'Chair's Statement of the 10th Asia Europe Meeting', Milan, 16–17 October.

CAPA Centre for Aviation (2018), 'China's Belt and Road Initiative and Aviation'. Sydney: CAPA Centre for Aviation. https://centreforaviation.com/analysis/airline-leader/chinas-belt-and-road-initiative-and-aviation-427350 (accessed 30 June 2020).

Dossani, R., J. Bouey, and K. Zhu (2020), 'Demystifying the Belt and Road Initiative:

A Clarification of its Key Features, Objectives and Impacts'. Santa Monica: RAND Corporation.

Duchâtel, M. and A.S. Duplaix (2018), 'Blue China: Navigating the Maritime Silk Road to Europe', Policy Brief. Berlin: European Council on Foreign Relations. https://www.ecfr.eu/publications/summary/blue_china_navigatingthe_maritime_silk_road_to_europe (accessed 30 June 2020).

Dulambazar, T. (2015), 'Mongolia's Cooperation in the GTI Transport Corridor',

in Blue Book: 20 Years in Greater Tumen Regional Cooperation. Beijing: China Association of International Trade (CAIT).

Dulambazar, T. (2016), 'Physical Connectivity between Asia and Europe: A Mongolian Perspective', in A. Prakash (ed.) ASEM Connectivity Vision 2025: Challenges and Opportunities, An ERIA–Government of Mongolia Document. Jakarta: Economic Research Institute for ASEAN and East Asia, pp. 35–44.

ENR (2019), 'ENR 2019 Top 250 Global Contractors 1–100', ENR Engineering News-Record, August. https://www.enr.com/toplists/2019-Top-250-Global-Contractors-1 (accessed 30 June 2020).

European Commission (2018a), 'Connecting Europe and Asia: Building Blocks for an EU Strategy', Communication to the European Parliament, the Council, the European Economic and Social Committee, the Committee of the Regions and the European Investment Bank. Brussels: European Commission.

European Commission (2018b), 'A Credible Enlargement Perspective for and Enhanced EU Engagement with the Western Balkans', Communication to the European Parliament, the Council, the European Economic and Social Committee, and the Committee of the Regions. Brussels: European Commission.

Green Belt and Road Initiative Center (2020), Countries of the Belt and Road Initiative (BRI). https://green-bri.org/countries-of-the-belt-and-road-initiative-bri (accessed 30 June 2020).

Green, M.J. (2018), 'China's Maritime Silk Road: Strategic and Economic Implications for the Indo-Pacific Region', in N. Szechenyi (ed.), China's Maritime Silk Road: Strategic and Economic Implications for the Indo-Pacific Region. Washington, DC: Center for Strategic and International Studies, pp. 1–3.

Hawke, G. and A. Prakash (2016), 'Conceptualising Asia–Europe Connectivity: Imperatives, Current Status, and Potential for ASEM', in A. Prakash (ed.), ASEM Connectivity Vision 2025: Challenges and Opportunities, An ERIA–Government of Mongolia Document. Jakarta: Economic Research Institute for ASEAN and East Asia, pp. 3–10.

Johnson, K. (2018), 'Why is China Buying Up Europe's Ports?', Foreign Policy, 2 February. https: //foreignpolicy.com/2018/02/02/why-is-china-buying-up-europes-ports/ (accessed 30 June 2020).

Knowler, G. (2020), 'China-Europe Air Cargo Rates Hit New Highs on Medical Demand', 6 April, JOC. https://www.joc.com/air-cargo/china-europe-air-cargo-rates-hit-new- highs-medical-demand_20200406.html (accessed 30 June 2020).

Kurimoto, S. (2019), 'Belt and Road Propels Chinese Contractors to Top of Global Ranks', Nikkei Asian Review, 19 September. https://asia.nikkei.com/Spotlight/Belt-and-Road/Belt-and-Road-propels-Chinese-contractors-to-top-of-global-ranks (accessed 30 June 2020).

Leng, S. (2019), 'China's Belt and Road Cargo to Europe under Scrutiny as Operator Admits to Moving Empty Containers', South China Morning Post, 20 August. https://www.scmp.com/economy/china-economy/article/3023574/chinas-belt-and-road-cargo-europe- under-scrutiny-operator (accessed 30 June 2020).

Ministry of Foreign Affairs, Japan (2019), 'The Partnership on Sustainable Connectivity and Quality Infrastructure between Japan and the European Union'. Tokyo: Government of Japan, Ministry of Foreign Affairs.

Morris, J. (2020), 'For Chinese Contractors, Belt and Road Initiative Rewards Come with Heightened Risks in a Changing World', South China Morning Post, 28 April. https://www.scmp.com/business/article/3081760/chinese-contractors-belt-and-road -initiative-rewards-come-heightened-risks (accessed 30 June 2020).

Okano-Heijmans, M., A. Prakash, W. Zweers, and B. Dekker (2018), ASEM Connectivity Inventory. Jakarta and The Hague: Economic Research Institute for ASEAN and East Asia (ERIA) and the Netherlands Institute of International Relations (Clingendael Institute).

Prakash, A. (2019), 'Connecting the Connectivities: It's Time for Regional Initiatives to Work Together', in Rethinking Global Governance. Brussels: Friends of Europe, pp. 18–21.

Prakash, A. (2020), T 20 Task Force 3: Infrastructure Investment and Financing.

Policy Brief 5: 'Multilateral Cooperation for Investment Facilitation Can Mobilise Funds for Infrastructure and Converge the Needs of Investors, Governments and People'. Riyadh.

Research and Markets (2019), 'China's Involvement in Global Infrastructure'. https://www.researchandmarkets.com/reports/4855800/chinas-involvement-in-global-infrastructure?utm_source=dynamic&utm_medium=BW&utm_code=r8lwm3&utm_ campaign=1319069+-+China%27s+Involvement+in+Global+Infrastructure+-+2019+Research+Report+with+a+Focus+on+the+Belt+%26+Road+Initiative+(BRI)&utm_ exec=joca220bwd (accessed 30 June 2020).

Rolland, N. (2019), 'Beijing's Response to the Belt and Road Initiative's 'Pushback': A Story of Assessment and Adaptation', Asian Affairs, 50(2), pp. 216–235.

State Council (2016), 'State Council Releases Five-Year Plan on Informatization', Press release, The State Council of the People's Republic of China, 27 December. http://english.www.gov.cn/policies/latest_releases/2016/12/27/content_281475526646686.htm (accessed 30 June 2020).

Summers, T. (2016), 'China's 'New Silk Roads': Sub-National Regions and Networks of Global Political Economy', Third World Quarterly, 37(9), pp. 1628–1643.

Summers, T. (2020), 'Structural Power and the Financing of the Belt and Road Initiative', Eurasian Geography and Economics, 61(2), pp. 146–151.

The Economist (2020), 'The Digital Side of the Belt and Road Initiative is Growing', 6 February. https://www.economist.com/special-report/2020/02/06/the-digital-side-of-the-belt-and-road-initiative-is-growing (accessed 30 June 2020).

Triolo, P., C. Brown, and K. Allison. (2020), 'The Digital Silk Road: Expanding China's Digital Footprint', Eurasia Group, 29 April. https://www.eurasiagroup.net/live-post/digital-silk- road-expanding-china-digital-footprint (accessed 30 June 2020).

Urata, S., A. Prakash, G. Hawke, and M. Pangestu (2019), ASEAN Vision 2040: Towards an Integrated and Connected East Asia and Indo-Pacific 2040. Jakarta: Economic Research Institute for ASEAN and East Asia.

US–China Economic and Security Review Commission (2018), 2018 Report to Congress of the US–China Economic and Security Review Commission. Washington, DC: US–China Economic and Security Review Commission. https://www.uscc.gov/sites/default/files/2019-09/2018%20Annual%20Report%20to%20Congress.pdf (accessed 30 June 2020).

World Bank (2020a), Air Transport, Freight (million ton-km) – China. https://data.worldbank.org/indicator/IS.AIR.GOOD.MT.K1?contextual=aggregate&locations=CN&sta rt=2013 (accessed 30 June 2020).

World Bank (2020b), Air Transport, Passengers Carried – China. https://data.worldbank. org/indicator/IS.AIR.PSGR?locations=CN (accessed 30 June 2020).

Xinhua (2017), 'Full Text: Vision for Maritime Cooperation under the Belt and Road Initiative', 20 June. http://english.www.gov.cn/archive/publications/2017/06/20/content_281475691873460.htm (accessed 30 June 2020).

Xinhua (2020), 'China Focus: China–Europe Freight Trains Pick up Steam amid Pandemic', 20 April. http://www.xinhuanet.com/english/2020-04/20/c_138993307.htm (accessed 30 June 2020).

# II

# កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុបស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម**

RASHESH SHRESTHA
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប-ប្រទេសវៀតណាម**

ដំណើរការ ផលប៉ះពាល់ និង មេរៀនចម្បងៗ

THANH TRI VO
*វិទ្យាស្ថានគ្រប់គ្រងសេដ្ឋកិច្ចកណ្តាលប្រទេសវៀតណាម*

**តួនាទីរបស់កិច្ចប្រជុំអាស៊ី-អឺរ៉ុបនៅក្នុងការលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិក**

LURONG CHEN
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

**គំរូកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារសេដ្ឋកិច្ចឌីជីថលរបស់ ASEM៖**

ឌីជីថលនីយកម្ម និង បច្ចេកវិទ្យាថ្មីៗ

IRMA MOSQUERA VALDERRAMA
*មហាវិទ្យាល័យច្បាប់ សាកលវិទ្យាល័យ LEIDEN ប្រទេសហូឡង់*

3

# កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុបស្តីពីការសម្រួលពាណិជ្ជកម្ម

RASHESH SHRESTHA

## សេចក្តីផ្តើម

ពាណិជ្ជកម្មគឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការភ្ជាប់ទំនាក់ទំនងរវាងប្រទេសនានានៅទ្វីបអាស៊ី និង អឺរ៉ុប។ ការជួញដូរទំនិញសរុបរវាងតំបន់ទាំងពីរបានឈានដល់ ១,៥ ទ្រីលានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨ គឺពាក់កណ្តាលនៃការជួញដូរទំនិញនៅលើពិភពលោក។[2] ទោះបីជាប្រទេសអាល្លឺម៉ង់ និង ប្រទេសចិន កាន់កាប់មួយផ្នែកធំនៃពាណិជ្ជកម្មអន្តរតំបន់ក្តី ប្រទេសជាច្រើនបានភ្ជាប់ទំនាក់ទំនងនឹងលំហូរពាណិជ្ជកម្មនេះតាមរយៈបណ្តាញផលិតកម្មអន្តរជាតិដែលជាចំណុចដ៏សំខាន់នៃមណ្ឌលពាណិជ្ជកម្មទាំងពីរ។

កាលពីជាង ២៥ ឆ្នាំមុន មានការប្រែប្រួលដ៏សំខាន់មួយនៅក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ។ ទោះបីជាពន្ធគយបានធ្លាក់ចុះដល់កម្រិតទាបជាប្រវត្តិសាស្ត្រក៏ដោយ ក៏បន្ទុកចំណាយពាណិជ្ជកម្មដែលអាចជៀសវាងបាន មានការកើនឡើងនៅក្នុងអំឡុងពេលដំណើរការការដឹកជញ្ជូនទំនិញពីប្រភពដើមទៅកាន់គោលដៅ។ បន្ទុកចំណាយទាំងនេះជាប់ពាក់ព័ន្ធនឹងការអនុលោមតាមវិធានបទប្បញ្ញត្តិនិងនីតិវិធីនានាដែលទាក់ទងនឹងការធ្វើពាណិជ្ជកម្មដែលបណ្តាលឲ្យមានភាពយឺតយ៉ាវហើយការចំណាយពេលវេលា និង ការចំណាយប្រាក់មានការកើនឡើង។ នៅខណៈពេលដែលវិធាន និង បទប្បញ្ញត្តិជាច្រើនបម្រើដល់ផលប្រយោជន៍ផ្នែកច្បាប់នោះ វិធាន និង បទប្បញ្ញត្តិទាំងនោះក៏អាចត្រូវបានបង្កើតឡើង និង អនុវត្តតាមវិធីដែលកាត់បន្ថយជាអប្បបរមានូវចំណាយលើអនុលោមភាពរបស់ពាណិជ្ជករ បានដែរ។ គេបានប៉ាន់ស្មានថា អត្ថប្រយោជន៍ដែលទទួលបានពីបន្ទុកចំណាយពាណិជ្ជកម្មមិនមែនជាពន្ធគយ គឺលើសពីការកាត់បន្ថយពន្ធគយ។ ការ

2 https://www.weforum.org/agenda/2019/05/ways-asia-and-europe-together-connected/

ជួយសម្រួលពាណិជ្ជកម្មតម្រូវឲ្យមានកំណែទម្រង់នៅក្នុងប្រទេស ចំពោះនីតិវិធីនៅក្នុងព្រំដែន ព្រមទាំង នីតិវិធីនៅខាងក្រៅព្រំដែនផងដែរ ( Persson ឆ្នាំ២០០៨ ) ការទទួលបានភាពរីកចម្រើន នៃហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ រដ្ឋបាលគយ ហេដ្ឋារចនាសម្ព័ន្ធនៃសេវាកម្មនានា និង មជ្ឈដ្ឋាននៃការធ្វើនិយ័តកម្មនៅក្នុងប្រទេស។ តាមរយៈការបង្កើនប្រសិទ្ធភាពនៃសមាសធាតុផ្សេងៗគ្នា ដែលបង្កើតបានជាដំណើរការពាណិជ្ជកម្មអន្តរជាតិនោះ ការជួយសម្រួលពាណិជ្ជកម្មអាចជួយកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្មជាអប្បបរមា និង លើកទឹកចិត្តឲ្យមានលំហូរពាណិជ្ជកម្មកាន់តែខ្លាំងក្លា ហើយវាក៏អាចជាប្រភពមួយនៃគុណសម្បត្តិប្រកួតប្រជែង នៅក្នុងមជ្ឈដ្ឋានដែលមានការប្រែប្រួលផងដែរ។

ទោះបីជាជំហាននានាដើម្បីឆ្ពោះទៅកាន់ការជួយសម្រួលពាណិជ្ជកម្មត្រូវតែបានអនុវត្តដោយប្រទេសនីមួយៗដោយផ្ទាល់ក្តី ក៏មានតំបន់នៃកិច្ចសហប្រតិបត្តិការជាច្រើន រវាងប្រទេសនានានៅក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុប ( ASEM ) ដែរ។ អត្ថប្រយោជន៍នៃការធ្វើសកម្មភាពរៀងៗខ្លួននឹងកាន់តែខ្លាំងក្លា ប្រសិនបើស្របពេលជាមួយគ្នានោះ ដៃគូពាណិជ្ជកម្មនានាបានស្រុះស្រួលគ្នាខិតខំប្រឹងប្រែងពង្រឹងមជ្ឈដ្ឋាននៃការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសរបស់ពួកគេផងដែរនោះ។ ដូចគ្នានេះដែរ កម្លាំងជំរុញសម្រាប់ការធ្វើកំណែទម្រង់កាន់តែឆាប់រហ័ស អាចទទួលបានពីកិច្ចព្រមព្រៀងប្រចាំតំបន់ និង កិច្ចព្រមព្រៀងសកល។ ដោយបានគិតដល់អត្ថប្រយោជន៍នៃការធ្វើពាណិជ្ជកម្មដែលមានភាពរលូនជាងនេះ អង្គការពាណិជ្ជកម្មពិភពលោក ( WTO ) បានបញ្ចប់ការចរចាស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម និង បានបន្ថែមកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម ( TFA ) ទៅក្នុងឯកសារស្ថាបនារបស់ខ្លួន ជាផ្លូវការ ក្នុងឆ្នាំ២០១៣ ដើម្បីធ្វើឲ្យប្រទេសសមាជិកមានកាតព្វកិច្ចអនុវត្តការជួយសម្រួលពាណិជ្ជកម្ម។

ការអនុវត្តកិច្ចព្រមព្រៀងនេះយ៉ាងមានប្រសិទ្ធភាព និង ឆាប់រហ័ស ដោយគ្រប់ប្រទេសទាំងអស់ នៅតែជាបញ្ហាប្រឈមដ៏ធំមួយ។ ទោះបីជាយ៉ាងណាក៏ដោយ វិធីសាស្ត្រជាក់លាក់ និង អាចធ្វើសកម្មភាពបាន ដែលត្រូវបានសម្គាល់ឃើញនៅក្នុង WTO-TFA មានលក្ខណៈអនុគ្រោះចំពោះការសម្របសម្រួល ( ទាំងនៅក្នុងប្រទេស និង ជាអន្តរជាតិ ) និង វិធីសាស្ត្រនៃវឌ្ឍនភាព។

សូចនាករមួយចំនួនដែលទាក់ទងនឹងស្ថានភាពនៃកិច្ចសម្រួលពាណិជ្ជកម្មក្នុងប្រទេសខុសៗគ្នាបង្ហាញថា ប្រទេសនៃ ASEM នៅក្នុងទ្វីបអឺរ៉ុបមានអត្រានៃការអនុវត្តវិធីសាស្ត្រជួយសម្រួលពាណិជ្ជកម្មខ្ពស់ ប្រសិនបើប្រៀបធៀបនឹងសមភាគីរបស់ពួកគេ នៅអាស៊ី។ ផលិតផលក្នុងស្រុកសរុប ( GDP ) ក្នុងប្រជាជនម្នាក់ គឺជាកត្តាព្យាករណ៍ដ៏ខ្លាំងក្លាអំពីអត្រានៃការអនុវត្តវិធីសាស្ត្រជួយសម្រួលពាណិជ្ជកម្ម។ ប្រទេសដែលមានប្រាក់ចំណូលទាបមួយចំនួន នៅក្នុងសមាគមប្រជាជាតិអាស៊ី

អាគ្នេយ៍ (អាស៊ាន) បានពន្លឿនការធ្វើកំណែទម្រង់នានា ដែលត្រូវបានលើកទឹកចិត្តដោយកិច្ចព្រមព្រៀងប្រចាំតំបន់អាស៊ាន។ផែនការលម្អិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) រួមបញ្ចូលការជួយសម្រួលពាណិជ្ជកម្មនៅក្នុងតំបន់យ៉ាងរលូន ហើយអ្នកបង្កើតគោលនយោបាយបានកំណត់ផែនការដ៏ច្រើនលើសលុបសម្រាប់ការកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្ម។ អត្ថប្រយោជន៍មួយនៃគំនិតផ្តួចផ្តើមរបស់អាស៊ានដែលមានស្រាប់នេះ គឺថា រដ្ឋសមាជិកអាស៊ាន (AMS) បានចាប់ផ្តើមមុនប្រទេសដែលអាចប្រៀបធៀបគ្នាបានផ្សេងៗទៀត នៅក្នុងស្ថានភាពនៃគំនិតផ្តួចផ្តើមជួយសម្រួលពាណិជ្ជកម្មរបស់ពួកគេ។ UNESCAP និង ADB (២០១៩: ៩) នៅក្នុងរបាយការណ៍របស់ពួកគេស្តីពីស្ថានភាពនៃកិច្ចសម្រួលពាណិជ្ជកម្មនៅក្នុងតំបន់ បានកត់សម្គាល់ថា "ដំណើរការសមាហរណកម្មនៅក្នុងតំបន់អាស៊ានត្រូវបានគេមើលឃើញថាមានតួនាទីយ៉ាងសំខាន់ និង ជាវិជ្ជមាននៅក្នុងការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម"។

ថ្នាក់ដឹកនាំ ASEM "បានបញ្ជាក់ឡើងវិញអំពីការគាំទ្រយ៉ាងខ្លាំងក្លាចំពោះការថែរក្សា និងពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើច្បាប់ ដែលមានចែងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក" និង "បានគូសបញ្ជាក់អំពីសារសំខាន់នៃការអនុវត្ត និង ការពង្រឹងកាតព្វកិច្ចដែលស្ថិតនៅក្រោម WTO ពីសំណាក់សមាជិករបស់ខ្លួន រួមបញ្ចូលទាំង ការធ្វើការជាបន្តបន្ទាប់ដើម្បីអនុវត្តកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្មរបស់ខ្លួនផងដែរ"។[3] ដំណើរការរបស់ ASEM អាចជួយពន្លឿនការអនុវត្តកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម តាមរយៈការសម្របសម្រួលយុទ្ធសាស្ត្រ ការចែករំលែកចំណេះដឹង ការផ្តល់ជំនួយបច្ចេកទេសដល់គ្នាទៅវិញទៅមក និង ការផ្តល់អាទិភាពដល់កិច្ចសម្រួលពាណិជ្ជកម្មនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី។

## ការជួយសម្រួលពាណិជ្ជកម្មនៅទ្វីបអាស៊ី និង អឺរ៉ុប

WTO-TFA មានវិធីសាស្ត្រ/បញ្ញត្តិចំនួន ១២ ធំៗ សម្រាប់ "ការពន្លឿនចលនា ការបញ្ចេញទំនិញ និង ការត្រួតពិនិត្យទំនិញ ដែលរួមបញ្ចូលទាំង ទំនិញដែលស្ថិតក្នុងការដឹកជញ្ជូន បូករួមនឹងកិច្ចសហប្រតិបត្តិការរបស់គយផងដែរ"។ វិធីសាស្ត្រនានារួមមាន៖

(១) ការបោះពុម្ពផ្សាយ និង ការអាចទទួលបានព័ត៌មាន (២) ឱកាសក្នុងការបញ្ចេញមតិព័ត៌មានមុនពេលចូលជាធរមាន និង ការពិគ្រោះយោបល់ (៣) សេចក្តីសម្រេចបុរេប្រទាន (៤)

[3] សេចក្តីថ្លែងការណ៍របស់ប្រធាន ASEM https://cdn.aseminfoboard.org/documents/ASEM12-Chairs-Statement.pdf (ចូលប្រើប្រាស់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)។

នីតិវិធីសម្រាប់ការដាក់បណ្ដឹងតវ៉ា ឬ ការត្រួតពិនិត្យឡើងវិញ (៥) វិធីសាស្ត្រផ្សេងទៀតដើម្បីពង្រឹងភាពមិនលម្អៀង មិនរើសអើង និង តម្លាភាព (៦) វិធានស្ដីពីថ្លៃសេវា និង ថ្លៃបន្ទុកដែលត្រូវដាក់លើ ឬ ពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និង ការពិន័យ (៧) ការបញ្ចេញ និង ការត្រួតពិនិត្យទំនិញ (៨) កិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារតាមបណ្ដោយព្រំដែន (៩) ការផ្លាស់ទីទំនិញដែលមានបំណងនាំចូល ក្រោមការត្រួតពិនិត្យរបស់គយ (១០) បែបបទដែលពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និង ការឆ្លងកាត់ (១១) សេរីភាពក្នុងការឆ្លងកាត់ និង (១២) កិច្ចសហប្រតិបត្តិការរបស់គយ។ វិធីសាស្ត្រទាំងនេះពាក់ព័ន្ធនឹងគោលនយោបាយជាក់លាក់ដែលចាំបាច់ត្រូវតែអនុវត្តដោយប្រទេសនីមួយៗ អាស្រ័យហេតុនេះ វានឹងនាំឲ្យមានការវាស់វែង និង ការពិនិត្យតាមដានវឌ្ឍនភាព។

**រូបភាពទី១៖ សមាមាត្រនៃវិធីសាស្ត្រកិច្ចសម្រួលពាណិជ្ជកម្មដែលត្រូវបានអនុវត្តយ៉ាងពេញលេញ នៅក្នុងឆ្នាំ២០១៩ នៅក្នុងប្រទេសនានានៃ ASEM ដែលត្រូវបានជ្រើសរើស**






ASEM = កិច្ចប្រជុំអាស៊ី-អឺរ៉ុប
សម្គាល់៖ រួមបញ្ចូលតែប្រទេសដែលមានទិន្នន័យនៅក្នុងការស្ទង់មតិ UNTF តែប៉ុណ្ណោះ។
ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ពីការស្ទង់មតិ UNTF។

បន្ទាប់ពីមានកិច្ចព្រមព្រៀងនេះ ស្ថានភាពនៃការជួយសម្រួលពាណិជ្ជកម្មកំពុងតែត្រូវបានគេវាយតម្លៃតាមរយៈការស្ទង់មតិអំពីការសម្រួលពាណិជ្ជកម្មនៃអង្គការសហប្រជាជាតិ (UNTF) ដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០១៥ ២០១៧ និង ២០១៩។ ការស្ទង់មតិ UNTF មាន ៥២ សំណួរដែលផ្ទុកផ្គងធាតុនានានៃវិធីសាស្ត្រ WTO-TFA យ៉ាងទូលំទូលាយ។ វិធីសាស្ត្រនីមួយៗត្រូវបានគេវាយតម្លៃថា បានអនុវត្តយ៉ាងពេញលេញ បានអនុវត្តមួយផ្នែក ស្ថិតនៅក្នុងដំណាក់កាលសាកល្បង មិនបានអនុវត្ត ឬ មិនពាក់ព័ន្ធ។ ការវាយតម្លៃត្រូវបានធ្វើឡើងដោយអ្នកជំនាញ និង ត្រូវបានផ្ទៀងផ្ទាត់ដោយប្រទេសនានា។ នៅខណៈពេលដែលគុណភាពនៃវិធីសាស្ត្រកិច្ចសម្រួលពាណិជ្ជកម្មមិនអាចវាយតម្លៃបានទេនោះ ការស្ទង់មតិ UNTF ទោះបីជាយ៉ាងណាក៏ដោយ បានផ្តល់រូបភាពមួយនៃទីតាំងរបស់ប្រទេសនីមួយៗ ពាក់ព័ន្ធនឹងការជួយសម្រួលពាណិជ្ជកម្ម អាស្រ័យហេតុនេះ វានឹងផ្តល់ទិន្នន័យសម្រាប់ការប្រៀបធៀបយ៉ាងទូលំទូលាយ។

យោងតាមលទ្ធផលនៃការស្ទង់មតិ UNTF សេដ្ឋកិច្ចនៃទ្វីបអឺរ៉ុបឈានមុខសេដ្ឋកិច្ចនៃទ្វីបអាស៊ីយ៉ាងខ្លាំង នៅក្នុងការអនុវត្តវិធីសាស្ត្រកិច្ចសម្រួលពាណិជ្ជកម្ម។ ប្រទេសចំនួនប្រាំបី ក្នុងចំណោម

២១ ប្រទេស នៅទ្វីបអាស៊ី បានអនុវត្តវិធីសាស្ត្រនេះ បានជាង ៦០% នៅខណៈពេលដែល ១៧ ក្នុងចំណោម ២៤ ប្រទេសនៅអឺរ៉ុបក៏បានអនុវត្តនៅកម្រិតនេះដែរ។ ប្រទេសនៅទ្វីបអាស៊ីដែលមានការអភិវឌ្ឍខ្លាំងជាង (ប្រទេសអូស្ត្រាលី សាធារណរដ្ឋកូរ៉េ [ក្រោយមកហៅថា ប្រទេសកូរ៉េ] ប្រទេសម៉ាឡេស៊ី ប្រទេសណូវែលហ្សេឡង់ សហព័ន្ធរុស្ស៊ី និង ប្រទេសសិង្ហបុរី) មានភាពឈានមុនគេនៅក្នុងការអនុវត្តនេះ នៅខណៈពេលដែលប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ (ប្រទេសបង់ក្លាដេស ឡាវ ប្រទេសម៉ុងហ្គោល ប្រទេសមីយ៉ាន់ម៉ា ប្រទេសប៉ាគីស្ថាន និង ប្រទេសវៀតណាម) មានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីតាមឲ្យទាន់ប្រទេសទាំងនោះ។ បម្រែនៃអត្រាអនុវត្តនៅក្នុងទ្វីបអាស៊ីមានទំហំធំជាងនៅក្នុងទ្វីបអឺរ៉ុប។

រូបភាពទី ២ បង្ហាញទីតាំងរបស់ប្រទេសនានាជាពីរទម្រង់៖ អត្រានៃការអនុវត្តការជួយសម្រួលពាណិជ្ជកម្មយ៉ាងពេញលេញ (ខ្សែបន្ទាត់ឈរ) និង GDP ក្នុងប្រជាជនម្នាក់ នៅក្នុងឆ្នាំ២០១៥ (បានបង្ហាញនៅក្នុងឡូការីត)។

ទីតាំងរបស់ប្រទេស ASEM នៅអាស៊ី នៅអឺរ៉ុប និង ប្រទេសដទៃទៀតដែលមិនមែនជា ASEM ត្រូវបានគូសបញ្ជាក់ដាច់ដោយឡែកពីគ្នា។ ទំនាក់ទំនងវិជ្ជមានដ៏រឹងមាំមួយរវាងអត្រានៃការអនុវត្ត និង គោលជំហរផ្នែកសេដ្ឋកិច្ច គឺគួរឲ្យកត់សម្គាល់ ពោលគឺប្រទេសអភិវឌ្ឍន៍ខ្លាំងជាង ត្រូវបានគេយល់ថាមានអត្រានៃការអនុវត្តខ្ពស់ជាង។ កត្តាអន្តរាគមន៍មួយនៅក្នុងករណីនេះគឺ សារសំខាន់នៃពាណិជ្ជកម្មចំពោះសេដ្ឋកិច្ចរបស់ប្រទេស ដែលតាមធម្មតា មានលក្ខណៈវិជ្ជមាន លើកលែងចំពោះប្រទេសដែលពឹងផ្អែកលើធនធានធម្មជាតិ។ នៅក្នុងករណីនេះ ប្រទេស ASEM នៃទ្វីអឺរ៉ុបភាគច្រើនមានទីតាំងនៅផ្នែកខាងលើខាងស្តាំនៃគំនូសតាង ដែលមាន GDP ក្នុងប្រជាជនម្នាក់ខ្ពស់ និង មានអត្រានៃការអនុវត្តខ្ពស់។

ទីតាំងរបស់ប្រទេស ASEM នៅអាស៊ីក៏គួរឲ្យកត់សម្គាល់ដែរ។ ទីមួយ ពួកគេមានទីតាំងល្អនៅពីលើខ្សែបន្ទាត់ "តម្លៃកំណត់ជាមុន" ដែលកត់សម្គាល់ទំនាក់ទំនងជាមធ្យមរវាងអត្រាអនុវត្តការជួយសម្រួលពាណិជ្ជកម្ម និង GDP ក្នុងប្រជាជនម្នាក់ នៅគ្រប់ប្រទេសទាំងអស់ដែលមានទិន្នន័យ។ ចំណុចនេះប្រាប់យើងថា ប្រទេស ASEM នៅអាស៊ី អនុវត្តបានល្អជាងអ្វីដែលបានរំពឹងទុកពាក់ព័ន្ធនឹងការជួយសម្រួលពាណិជ្ជកម្មបើប្រៀបធៀបនឹងកម្រិតGDPក្នុងប្រជាជនម្នាក់។ ចង្កោមប្រទេសASEMនៅអាស៊ីនៅផ្នែកខាងក្រោម-ខាងឆ្វេងនៃរូបភាពទី២គឺជាប្រទេសអភិវឌ្ឍន៍ដែលនៅក្បែរកម្រិតអនុវត្តដែលបានរំពឹងទុក។ កិច្ចសហប្រតិបត្តិការរវាងអាស៊ី និង អឺរ៉ុប អាចផ្តោតលើការពន្លឿនកំណែទម្រង់នៅក្នុងបណ្តុំប្រទេសទាំងនេះ។

**រូបភាពទី២៖ ទំនាក់ទំនងរវាងអត្រាអនុវត្តពេញលេញ នៅក្នុងឆ្នាំ២០១៩ និង GDP ក្នុងប្រជាជនម្នាក់នៅក្នុងឆ្នាំ២០១៥**




ASEM = កិច្ចប្រជុំអាស៊ី-អឺរ៉ុប, GDP = ផលិតផលក្នុងស្រុកសរុប, TF = ការសម្រួលពាណិជ្ជកម្ម
ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ដោយប្រើប្រាស់ទិន្នន័យដែលទទួលបានពីការស្ទង់មតិ UNTF និង សូចនាករនៃការអភិវឌ្ឍពិភពលោករបស់ធនាគារពិភពលោក។

តាមរយៈការសម្លឹងមើលគម្លាតនៃការអនុវត្ត តាមវិធីសាស្ត្រជាក់លាក់ យើងមើលឃើញថា អឺរ៉ុបឈានមុខអាស៊ីនៅក្នុងការជួយសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់ (វិធីសាស្ត្រ UNTF ចំនួន ៣៦ ទៅ ៣៨ សូមមើល សេចក្តីបន្ថែម សម្រាប់សេចក្តីពណ៌នាអំពីវិធីសាស្ត្រនានា) ដែលអាចយល់បានថា បណ្តាលមកពីទីផ្សារតែមួយនៅក្នុងសហភាពអឺរ៉ុប និង វត្តមាននៃប្រទេសដីកោះជាច្រើននៅអាស៊ី។ ទោះបីជាយ៉ាងណាក៏ដោយ យើងក៏សង្កេតឃើញវិធីសាស្ត្រជាច្រើនដែលអាចអនុវត្តបានចំពោះប្រទេសភាគច្រើនដែលនៅតែមានគម្លាតធំៗនៅលើវិធីសាស្ត្រទី៣២ "ទីភ្នាក់ងាររដ្ឋាភិបាលធ្វើប្រតិភូកម្មការគ្រប់គ្រងទៅកាន់អាជ្ញាធរគយ" ជាងបីភាគបួននៃដៃគូ ASEM នៅអឺរ៉ុបបានអនុវត្តវិធីសាស្ត្រនេះ នៅខណៈពេលដែលដៃគូ ASEM នៅអាស៊ីតែមួយភាគបួនប៉ុណ្ណោះដែលបានអនុវត្តវិធីសាស្ត្រនេះ។ ដូចគ្នានេះដែរ នៅខណៈពេលដែលដៃគូ ASEM នៅអឺរ៉ុបនៅចំណោមប្រទេសគំរូ មានសំវិធានធនរបស់ប្រតិបត្តិករសេដ្ឋកិច្ចដែលបានទទួលការអនុញ្ញាត

ប្រទេសនៅអាស៊ីជាងពាក់កណ្តាលបានអនុវត្តវិធីសាស្ត្រនេះ។ ចន្លោះប្រហោងសំខាន់ៗផ្សេងៗទៀតបានលេចឡើងនៅក្នុងការអនុវត្តការគ្រប់គ្រងហានិភ័យ និង ការប្រើប្រាស់ឯកសារអេឡិចត្រូនិក (ដូចជា ការដាក់ជូនសេចក្តីប្រកាសពន្ធគយ ជាដើម)។

វិធីសាស្ត្រមួយចំនួនដែលពាក់ព័ន្ធនឹងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងព្រំដែន មានការអនុវត្តនៅ កម្រិតទាប ទាំងនៅអាស៊ី និង អឺរ៉ុប ដូច្នេះវាផ្តល់ឱកាសខ្ពស់បំផុតសម្រាប់កិច្ចសហប្រតិបត្តិការ។ មានតែប្រទេសប៊ែលហ្ស៊ិក ប្រទេសណូវែលហ្សេឡង់ និង ចក្រភពអង់គ្លេសប៉ុណ្ណោះ ដែលអនុវត្តការផ្លាស់ប្តូរលិខិតបញ្ជាក់ប្រភពដើមតាមប្រព័ន្ធអេឡិចត្រូនិកបានយ៉ាងពេញលេញ នៅខណៈពេលដែលមានតែចក្រភពអង់គ្លេសតែមួយប៉ុណ្ណោះដែលអនុវត្តការផ្លាស់ប្តូរលិខិតបញ្ជាក់អនាម័យ និង ភូតគាមអនាម័យ តាមប្រព័ន្ធអេឡិចត្រូនិកបានយ៉ាងពេញលេញ។ សម្រាប់លិខិតបញ្ជាក់ប្រភពដើម ប្រទេសនៅអាស៊ីចំនួនប្រាំបួនប្រទេស អនុវត្តបានមួយផ្នែក និង ប្រាំមួយប្រទេសទៀតស្ថិតនៅក្នុងដំណាក់កាលនៃការធ្វើផែនការ។

## បន្ទុកចំណាយពាណិជ្ជកម្មនៅអាស៊ី និង អឺរ៉ុប

ភាពខុសគ្នានៅក្នុងការអនុវត្តការជួយសម្រួលពាណិជ្ជកម្ម ត្រូវបានបញ្ជាក់អះអាងនៅក្នុងសូចនាករនៃបន្ទុកចំណាយពាណិជ្ជកម្ម។ ដោយសារតែវត្ថុបំណងនៃកិច្ចសម្រួលពាណិជ្ជកម្ម គឺដើម្បីកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្មនោះ យើងអាចត្រួតពិនិត្យរង្វាស់បន្ទុកចំណាយពាណិជ្ជកម្មដែលអាចស្វែងរកបាន ដើម្បីធ្វើការប៉ាន់ស្មានអំពីកម្រិតនៃការជួយសម្រួលពាណិជ្ជកម្ម។ ជាលទ្ធផលបន្ទុកចំណាយពាណិជ្ជកម្មធ្វើការព្យាករណ៍អំពីកម្រិតនៃលំហូរពាណិជ្ជកម្ម ហេតុដូចនេះវាក៏ព្យាករណ៍អំពីសមាហរណកម្មសេដ្ឋកិច្ចរវាងប្រទេសនានាផងដែរ៖ ប្រទេសដែលមានបន្ទុកចំណាយពាណិជ្ជកម្មទាបជាង ធ្វើពាណិជ្ជកម្មច្រើនជាង ប្រទេសដែលមានបន្ទុកចំណាយពាណិជ្ជកម្មខ្ពស់ជាង ទោះបីជាគ្មានទំនាក់ទំនងហេតុ និង ផលក៏ដោយ (Persson ឆ្នាំ២០០៨)។ មានសូចនាករនៃបន្ទុកចំណាយពាណិជ្ជកម្មជាច្រើនដែលអាចស្វែងរកបាន ដែលរួមមាន រង្វាស់បន្ទុកចំណាយពាណិជ្ជកម្មទ្វេភាគីរបស់ UNESCAP, សំណុំឯកសារ និង ពេលវេលានៃអនុលោមភាពក្នុងការនាំចូល/នាំចេញ ដែលត្រូវបានវាយតម្លៃដោយសូចនាករនានានៃការធ្វើពាណិជ្ជកម្មឆ្លងព្រំដែនរបស់ធនាគារពិភពលោក និងចំណាត់ថ្នាក់ដែលផ្តល់ជូនដោយរបាយការណ៍ស្តីពីភាពប្រកួតប្រជែងជាសកលរបស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF)។

សហភាពអឺរ៉ុប (EU) ជាទូទៅត្រូវបានចាត់ទុកថាជាក្រុមប្រទេសដែលបានធ្វើសមាហរណកម្មច្រើនជាងគេបំផុតនៅលើពិភពលោក។ ទិន្នន័យបន្ទុកចំណាយពាណិជ្ជកម្មចុងក្រោយគេបង្ហាញដែល

ទទួលបានពី UNESCAP ដោយមូលដ្ឋានទិន្នន័យបន្ទុកចំណាយពាណិជ្ជកម្មរបស់ធនាគារពិភពលោក បង្ហាញថា បន្ទុកចំណាយសរុបលើការធ្វើពាណិជ្ជកម្មទំនិញនានានៅក្នុងចំណោមសេដ្ឋកិច្ច EUធំជាងគេបង្អស់ចំនួនបីមានតម្លៃស្មើនឹង៤២%នៃពន្ធគយជាមធ្យមចំនួនលើតម្លៃនៃទំនិញដែលបានធ្វើពាណិជ្ជកម្ម។ ផ្ទុយមកវិញ សមាជិកអាស៊ានដែលមានប្រាក់ចំណូលកម្រិតកណ្តាល ត្រូវបានប៉ាន់ស្មានថាមានបន្ទុកចំណាយពាណិជ្ជកម្មស្មើនឹង៧៦% នៃពន្ធគយជាមធ្យម។

សូចនាករនៃភាពប្រកួតប្រជែងជាសកលរបស់ WEF តាមធម្មតា ប្រមូលផ្តុំទិន្នន័យអំពីទិដ្ឋភាពនៃការអនុវត្តរបស់ប្រទេសនានាដែលទទួលរងផលជះពីការសម្រួលពាណិជ្ជកម្ម។ សូចនាកររបស់ WEF គឺផ្តោតលើការស្ទង់មតិអំពីទស្សនៈរបស់ក្រុមហ៊ុនឯកជន។ រូបភាពទី ៣ បង្ហាញអំពីពិន្ទុជាមធ្យមនៃបន្ទុករបស់នីតិវិធីគយ ដែលពិន្ទុខ្ពស់ជាងចង្អុលបង្ហាញអំពីការអនុវត្តបានល្អជាង។ ប្រទេស ASEM ទាំងនៅអាស៊ី និង អឺរ៉ុប បានពង្រឹងការអនុវត្តរបស់ពួកគេ ចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១៧ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងភាពល្អប្រសើរឡើងនៃពិន្ទុនៅខ្សែកណ្តាល (ចង្អុលបង្ហាញដោយខ្សែពណ៌ ស)។ ទោះបីជាយ៉ាងណាក៏ដោយ ពិន្ទុនៅខ្សែកណ្តាលរបស់អាស៊ីទាបជាងពិន្ទុនៅខ្សែកណ្តាលរបស់អឺរ៉ុប ដែលចង្អុលបង្ហាញថា នីតិវិធីតាមព្រំដែននៅក្នុងប្រទេសដៃគូ ASEM ជាច្រើន នៅអាស៊ី ត្រូវបានចាត់ទុកមានបន្ទុកខ្ពស់ជាង។

## កិច្ចព្រមព្រៀងពាណិជ្ជកម្ម និង កិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់

កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និង ក្នុងតំបន់ អាចមានសារសំខាន់នៅក្នុងការកាត់បន្ថយរបាំងពាណិជ្ជកម្ម តាមរយៈការដោះស្រាយបញ្ហាដែលលើសពីការកាត់បន្ថយពន្ធគយ ដើម្បីរួមបញ្ចូលកិច្ចព្រមព្រៀងស្តីពីការជួយសម្រួល។ ជាពិសេស កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងដៃគូនៅដំណាក់កាលនៃការអនុវត្តខុសៗគ្នា អាចផ្តល់ការជំរុញជាពិសេសដល់ការធ្វើកំណែទម្រង់នៅក្នុងប្រទេសដែលខ្សោយជាង។ភាពល្អប្រសើរឡើងនៅក្នុងមជ្ឈដ្ឋានពាណិជ្ជកម្មដែលកើតចេញពីកិច្ចព្រមព្រៀងនៅក្នុងតំបន់ទាំងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេស ASEM ទាំងអស់។

Beverelli et al. (ឆ្នាំ២០១៤) បានកត់សម្គាល់ថា គំនិតផ្តួចផ្តើមនានានៃការជួយសម្រួលពាណិជ្ជកម្ម ដូចជា តម្លាភាព និង បែបបទនានា គួរតែគ្មានការរើសអើងនោះទេ ដូច្នេះវានឹងផ្តល់អត្ថប្រយោជន៍ដល់ដៃគូពាណិជ្ជកម្មទាំងអស់ស្មើៗគ្នា។

**រូបភាពទី៣៖ ពិន្ទុនៃបន្ទុកនីតិវិធីគយរបស់ WEF ( ១–៧ )**




WEF = វេទិកាសេដ្ឋកិច្ចពិភពលោក
សម្គាល់៖ ខ្សែបន្ទាត់ ស តំណាងឲ្យចំណុចកណ្ដាលនៃការបែងចែងផ្សេងៗគ្នា។ បានរួមបញ្ចូលប្រទេស ASEM មកពីអាស៊ី តែ ១៨ ប្រទេស និង មកពីអឺរ៉ុប តែ ២៤ ប្រទេសប៉ុណ្ណោះ ដែលមានទិន្នន័យ។
ប្រភព៖ ការគណនារបស់អ្នកនិពន្ធ យោងតាមរបាយការណ៍ស្ដីពីភាពប្រកួតប្រជែងជាសកលនៃវេទិកាសេដ្ឋកិច្ចពិភពលោក។

គំនិតផ្ដួចផ្ដើមមួយចំនួនផ្សេងទៀត ដូចជា ការធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិ និង ការជួយសម្រួលដល់ការឆ្លងកាត់ អាចត្រូវបានផ្ដល់ជូនតែនៅក្នុងបរិបទនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម នៅក្នុងតំបន់តែប៉ុណ្ណោះ ដូច្នេះវារើសអើងចំពោះប្រទេសដែលមិនមែនជាសមាជិក ( Maur ឆ្នាំ ២០១១ )។ ការជួយសម្រួលដល់ការឆ្លងកាត់នៅតែមានអត្ថប្រយោជន៍ទូលំទូលាយជាង ពីព្រោះបណ្ដាញផលិតកម្មអន្តរជាតិ ដែលតាមធម្មតា ត្រូវបានបង្កើតឡើងនៅទ្វីបអាស៊ី និង អឺរ៉ុបទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងអន្តរតំបន់ទាំងនេះ និង លាតសន្ធឹងយ៉ាងទូលំទូលាយ នៅពេលដែលអាស៊ី និង អឺរ៉ុបត្រូវបានតភ្ជាប់នឹងប្រទេសដែលនៅចំណុចកណ្ដាល ដូចជា ប្រទេសចិន និង ប្រទេសអាល្លឺម៉ង់ ជាដើម។

កិច្ចព្រមព្រៀងទ្វេភាគីរបស់ EU តាមធម្មតា បានរួមបញ្ចូលកិច្ចព្រមព្រៀងស្ដីពីបណ្ដុំបញ្ហានៃការជួយសម្រួលពាណិជ្ជកម្មដែលទូលំទូលាយជាងនេះ។ នាពេលថ្មីៗនេះ សហភាពអឺរ៉ុប និង ប្រទេសវៀតណាមបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងការពារការវិនិយោគ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលរួមបញ្ចូលការព្រមព្រៀងកាត់បន្ថយឧបសគ្គផ្នែក

បទប្បញ្ញត្តិ និង ការិយាល័យធិបតេយ្យត្រួតគ្នា ឧទាហរណ៍៖ តាមរយៈការបង្កើនការប្រើប្រាស់បទដ្ឋានអន្តរជាតិនៅក្នុងបទប្បញ្ញត្តិរបស់ខ្លួន។[4]

នៅខណៈពេលដែលមានកិច្ចព្រមព្រៀងជាច្រើននៅក្នុងប្រទេសនានានៅអឺរ៉ុប និង អាស៊ីនោះ ការភ្ជាប់ទំនាក់ទំនងរវាងអាស៊ី និង អឺរ៉ុប ដែលត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ច មានចំនួនតិចតួចខ្លាំងណាស់។ កិច្ចព្រមព្រៀងដែលតភ្ជាប់អាស៊ី និង អឺរ៉ុប រួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី EU-កូរ៉េ, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី EU-វៀតណាម, សមាគមពាណិជ្ជកម្មសេរីអឺរ៉ុប (EFTA) (ដែលរួមបញ្ចូលប្រទេសន័រវេ៉ និង ប្រទេសស្វីសផងដែរ) និង ប្រទេសកូរ៉េ, EFTA-សិង្ហបុរី, និង កិច្ចព្រមព្រៀងទ្វេភាគីរវាងប្រទេសស្វីស និង ប្រទេសចិន, ប្រទេសស្វីស និងប្រទេសជប៉ុន, និង ប្រទេសស្វីស និង ប្រទេសសិង្ហបុរី។[5] កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីមួយរវាង EUនិង ប្រទេសជប៉ុន និង EU និង ប្រទេសសិង្ហបុរី បានចូលជាធរមាននៅក្នុងឆ្នាំ២០១៩។ កិច្ចព្រមព្រៀងជាមួយជប៉ុន រួមបញ្ចូលបញ្ញត្តិមួយដែលចែងអំពីកិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្មពាក់ព័ន្ធនឹងការអនុម័តលើបទដ្ឋានអន្តរជាតិ និង ការបង្កើតគណៈកម្មាធិការកិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្មរួមគ្នាមួយ ជាវិធីមួយដើម្បីកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្មដែលមិនមែនជាពន្ធគយ។[6] គិតត្រឹមពេលសរសេរសៀវភៅនេះ EU ក៏បានចាប់ផ្តើមការចរចា ដើម្បីកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រទេសអូស្ត្រាលី និង ប្រទេសនូវែលហ្សេឡង់ ដាច់ដោយឡែកពីគ្នាផងដែរ។ ក្នុងនាមជាប្រទេសអភិវឌ្ឍន៍ កិច្ចសម្រួលពាណិជ្ជកម្មទាំងនេះ មានភាពជឿនលឿនគួរសមរួចហើយ។

## កិច្ចសម្រួលពាណិជ្ជកម្មនៅអាស៊ាន

សមាជិកទាំង ១០ របស់អាស៊ាន ក៏បានប្តេជ្ញាចិត្តពន្លឿនកំណែទម្រង់នានានៃកិច្ចសម្រួលពាណិជ្ជកម្មផងដែរ។ ផែនការលម្អិត AEC ឆ្នាំ២០១៥ រួមបញ្ចូលការធ្វើពាណិជ្ជកម្មដោយរលូននៅក្នុងតំបន់ ដោយមានការសម្រួលពាណិជ្ជកម្មអន្តរជាតិយ៉ាងសកម្មពីសំណាក់ប្រទេសសមាជិកទាំង ១០ របស់ខ្លួន។ ដើម្បីសម្រេចគោលបំណងនេះ អាស៊ានបានបញ្ជាក់អំពីវិធីសាស្ត្រដែលអាចអនុវត្តបានដោយប្រទេសនានាជាឯកតោភាគី និង តាមរយៈការសម្របសម្រួលជាមួយគ្នាទៅវិញទៅមក។ វិធីសាស្ត្រសម្រួលពាណិជ្ជកម្មទាំងនេះ ដែលភាគច្រើនបានលេចឡើងនៅក្នុងទាំងផែនការលម្អិតរបស់ AEC និង WTO-TFA មានទំនាក់ទំនងយ៉ាងទូលំទូលាយនឹងតម្លាភាព (ឧ. ការបោះពុម្ពផ្សាយព័ត៌មានស្តីពីគេហទំព័រប្រើប្រាស់ផ្តាច់មុខមួយ ហៅថា ការរក្សាទុកព័ត៌មានអំពី

[4] https://trade.ec.europa.eu/doclib/docs/2018/october/tradoc_157444.pdf
[5] https://publications.jrc.ec.europa.eu/repository/bitstream/JRC112998/asem-report_online.pdf
[6] https://trade.ec.europa.eu/doclib/docs/2017/july/tradoc_155720.pdf

ពាណិជ្ជកម្មជាតិ) កិច្ចសម្រួលនីតិវិធីគយ (ឧ. ការបញ្ជាក់ដោយខ្លួនឯង កម្មវិធីប្រតិបត្តិករផ្អែកសេដ្ឋកិច្ចដែលមានការអនុញ្ញាត) ពាណិជ្ជកម្មដែលគ្មានឯកសារ (ឧ. ច្រកចេញចូលតែមួយថ្នាក់ជាតិ) និង ការជួយសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់។ ការអនុវត្តវិធីសាស្ត្រសម្រួលពាណិជ្ជកម្មទាំងនេះ ត្រូវបានរំពឹងទុកថានឹងបង្កើនពាណិជ្ជកម្មអន្តរតំបន់។

កាលពីឆ្នាំ២០១៧ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានកំណត់គោលដៅកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្មនៅក្នុងអាស៊ាន ត្រឹម ១០%។ ដោយមានពន្ធគយក្បែរសូន្យរួចទៅហើយនោះ ការកាត់បន្ថយទាំងនេះ ភាគច្រើនចាំបាច់ត្រូវតែទទួលបានពីការកាត់បន្ថយបន្ទុកចំណាយប្រតិបត្តិការពាណិជ្ជកម្ម ពោលគឺបន្ទុកចំណាយលើការផ្លាស់ទីទំនិញឆ្លងកាត់ព្រំដែននានា ដែលពាក់ព័ន្ធនឹងការអនុលោមតាមនាំងនិយ័តកម្ម។ មានភ័ស្តុតាងបង្ហាញថា បន្ទុកចំណាយទាំងនោះនៅតែខ្ពស់គួរសមនៅក្នុងតំបន់ និង ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីសម្រេចគោលដៅនេះ។ ចំពោះ AMS ជាច្រើន ការសម្រួលពាណិជ្ជកម្មគឺជាចំណុចផ្តោតដ៏សំខាន់បំផុតនៃគោលនយោបាយដែលជាញឹកញាប់ មានទំនាក់ទំនងនឹងការពង្រឹងការចាត់ចំណាត់ថ្នាក់ ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម។ ចំពោះ AMS មួយចំនួនតូច ការពង្រឹងកិច្ចសម្រួលពាណិជ្ជកម្មជាទ្រង់ទ្រាយធំ នឹងមានសារសំខាន់ចំពោះការធ្វើពាណិជ្ជកម្ម ការវិនិយោគ និង លទ្ធផលផ្នែកសេដ្ឋកិច្ចនាពេលអនាគត។

ERIA ដោយបានសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់រួមគ្នាអំពីការសម្រួលពាណិជ្ជកម្មនៅអាស៊ាន បាន និង កំពុងតែធ្វើការសិក្សាមួយនៅទូទាំងអាស៊ាន ដើម្បីស្វែងយល់អំពីមជ្ឈដ្ឋាននៃការសម្រួលពាណិជ្ជកម្មនៅក្នុងតំបន់។ ការសិក្សាអំពីបន្ទាត់គោលមួយត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០១៨ ដោយមានការសិក្សាតាមដាននៅពេលក្រោយមួយត្រូវបានរៀបចំផែនការអនុវត្តនៅក្នុងឆ្នាំ២០២០។ វត្ថុបំណងនៃការសិក្សានេះ គឺដើម្បីផ្តល់អនុសាសន៍សម្រាប់ការកាត់បន្ថយបន្ទុកចំណាយលើប្រតិបត្តិការពាណិជ្ជកម្មអន្តរអាស៊ាន តាមរយៈការវាយតម្លៃអំពីគំនិតផ្តួចផ្តើមនៃការសម្រួលពាណិជ្ជកម្មខុសៗគ្នា ដែលត្រូវបានអនុម័តដោយ AMS នីមួយៗ។ ដូច្នេះ លទ្ធផលនៃការសិក្សាជួយបំភ្លឺផ្លូវដល់តំបន់នានា ដែលកិច្ចសហប្រតិបត្តិការបន្ថែមលើការសម្រួលពាណិជ្ជកម្មអាចជួយកាត់បន្ថយបន្ទុកចំណាយលើប្រតិបត្តិការអាជីវកម្មនៅក្នុងអនុតំបន់។

បទពិសោធន៍របស់អាស៊ានផ្តល់ការយល់ដឹងយ៉ាងស៊ីជម្រៅមួយចំនួនអំពីចំណុចនានានៃកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការសម្រួលពាណិជ្ជកម្ម។ចំណុចទីមួយគឺការចែករំលែកចំណេះដឹងដែលAMSអាចរៀនសូត្រទៅវិញទៅមកអំពីគំនិតផ្តួចផ្តើមរបស់រដ្ឋទាំងនោះ។AMSដែលស្ថិតនៅដំណាក់កាលខុសៗគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ច និង កិច្ចសម្រួលពាណិជ្ជកម្ម កំពុងតែធ្វើការរួមគ្នាដើម្បីសម្រេចបាននូវការធ្វើពាណិជ្ជកម្មដ៏រលូននៅក្នុងតំបន់។ តំបន់គឺជាអតិសុខុមលោកមួយរបស់ពិភពលោក ដោយមានអ្នកអនុវត្តបានល្អបំផុតនៅលើពិភពលោក នៅក្នុងការសម្រួលពាណិជ្ជកម្ម

ដែលជាប្រទេសសិង្ហបុរី និង រួមជាមួយប្រទេសដែលកំពុងតែងើបឡើង ដូចជា ប្រទេសកម្ពុជា ឡាវ និង ប្រទេសមីយ៉ាន់ម៉ាជាដើម។ AMS ដែលពឹងផ្អែកលើពាណិជ្ជកម្ម បាន និង កំពុងតែធ្វើការដើម្បីឆ្ពោះទៅកាន់ការសម្រួលពាណិជ្ជកម្មដ៏រលូនក្នុងរយៈពេលវែង។ ច្រកចេញចូលតែមួយនៅថ្នាក់ជាតិរបស់ប្រទេសសិង្ហបុរីបានចាប់ផ្តើមនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និង បានដំឡើងកម្រិតជាបន្តបន្ទាប់។ប្រព័ន្ធគយ៤.០របស់ប្រទេសថៃនិងuCustomsរបស់ប្រទេសម៉ាឡេស៊ីផ្តល់លក្ខណៈពិសេសនៃកិច្ចសម្រួលពាណិជ្ជកម្មថ្មីៗ និង ប្រកបដោយនវានុវត្តន៍ជាច្រើន។ ប្រទេសទាំងនេះបានដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រជួយសម្រួលនានា ដូចជា សេចក្តីសម្រេចបុរេប្រទានការដំណើរការមុនពេលមកដល់ និង ប្រតិបត្តិករសេដ្ឋកិច្ចដែលមានការអនុញ្ញាត។ ករណីនៃឧត្តម្មានុវត្តមួយចំនួននៅក្នុង AMS មានតម្លៃសម្រាប់ AMS ដទៃទៀតយកទៅអនុវត្តតាម។ ដំណើរការរបស់អាស៊ានអាចជួយប្រទេសនានាឲ្យរៀនសូត្រអំពីគ្នាទៅវិញទៅមក។

ឧទាហរណ៍ទីពីរនៃកិច្ចសហប្រតិបត្តិការអាចត្រូវបានរកឃើញនៅក្នុងការអភិវឌ្ឍវិធីសាស្ត្រជាក់លាក់របស់អាស៊ានចំពោះបន្ទុកចំណាយលើប្រតិបត្តិការពាណិជ្ជកម្មដែលជាជំហានដ៏សំខាន់មួយដើម្បីឆ្ពោះទៅកាន់ការវាស់វែងអំពីភាពជោគជ័យនៃគោលដៅរួមនៅក្នុងការកាត់បន្ថយបន្ទុកចំណាយលើប្រតិបត្តិការពាណិជ្ជកម្ម។ សំណើរបស់ ERIA ឲ្យប្រើប្រាស់ពេលវេលាបញ្ចេញទំនិញនៅតាមព្រំដែនជាវិធីដ៏សមស្របមួយនៅក្នុងការគណនាបន្ទុកចំណាយលើប្រតិបត្តិការពាណិជ្ជកម្មនោះត្រូវបានទទួលយកដោយ AMS។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ AMS បានធ្វើការសិក្សាស្តីពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញ (TRS) ក្នុងអំឡុងឆ្នាំ២០១៨–២០១៩ ដើម្បីវាយតម្លៃអំពីភាពរាំងស្ទះនៅក្នុងការនីតិវិធីនាំចូល និង ការចេញនៅតាមព្រំដែនរបស់ពួកគេ។ នៅខណៈពេលដែលប្រទេសនីមួយៗបានអនុវត្ត TRS ស្របតាមវិធីសាស្ត្រដែលត្រូវបានណែនាំដោយអង្គការគយពិភពលោករួចហើយនោះ ប្រទេសទាំងនោះបានព្រមព្រៀងគ្នាចំពោះវិសាលភាពអប្បបរមារបស់ TRS ធ្វើដូច្នេះ ព័ត៌មានដែលមានសង្គតភាពអាចត្រូវបានបង្កើតឡើង។ យោងតាមការយល់ដឹងរបស់អ្នកនិពន្ធ នេះគឺជាលើកទីមួយដែលប្រទេសនានាបានសហការគ្នានៅក្នុងដំណើរការសម្គាល់ការរាំងស្ទះនៅក្នុងនីតិវិធីរបស់ពួកគេរៀងៗខ្លួន និង អាចជាជំហានទីមួយដើម្បីឆ្ពោះទៅកាន់កិច្ចសហការបន្ថែមទៀតនៅក្នុងកិច្ចសម្រួលពាណិជ្ជកម្មផងដែរ។

ទីបី កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានដើម្បីឆ្ពោះទៅកាន់ការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងកាត់ព្រំដែន នៅក្នុងទម្រង់ច្រកចេញចូលតែមួយរបស់អាស៊ាន (ASW) គឺគួរឲ្យកត់សម្គាល់។ ចំណុចមួយអាចត្រូវបានរំឭកឡើងវិញថា ផ្អែកតាមទិន្នន័យរបស់ UNTF នេះគឺជាតំបន់មួយដែលការធ្វើពាណិជ្ជកម្មមានភាពខ្វះខាត ទៅនៅអឺរ៉ុប និង នៅអាស៊ី។ នៅអាស៊ាន ច្រកចេញចូលតែមួយថ្នាក់ជាតិ និង ASW គឺជាគំនិតផ្តួចផ្តើមនៃការពាណិជ្ជកម្មដ៏សំខាន់បំផុត ចាប់

តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០ មក។ នៅខណៈពេលដែល ប្រទេសសមាជិកនីមួយៗ នឹងអភិវឌ្ឍប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិក នៅក្នុងទម្រង់ NSW នោះ ASW នឹងជួយសម្រួលពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងកាត់ព្រំដែន តាមរយៈការធ្វើឲ្យមានការផ្លាស់ប្តូរឯកសារពាណិជ្ជកម្ម។

ទំហំនៃការអនុវត្តដើម្បីឆ្ពោះទៅកាន់ការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកមានការប្រែប្រួលយ៉ាងខ្លាំង។ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ នៅអាស៊ាន ការផ្តោតកាន់តែខ្លាំង និង ការវិនិយោគលើការពង្រឹង NSWs គួរតែជាចំណុចអាទិភាពនៃគោលនយោបាយដែលសំខាន់ជាងគេបំផុត។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ICT និង ការកសាងសមត្ថភាពរបស់មន្ត្រីទាំងឡាយនៅក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក មានភាពចាំបាច់ចំពោះការបញ្ចេញសក្តាពលយ៉ាងពេញរបស់ NSWs។ ប៉ុន្តែ ប្រទេសថៃ ប្រទេសវៀតណាម ប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី និង ប្រទេសសិង្ហបុរីដែល NSWs មានភាពជឿនលឿនរួចហើយនោះ បាន និង កំពុងតែចូលរួមនៅក្នុងគម្រោងសាកល្បង ASW ចំពោះការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក ដែលចាំបាច់ចំពោះគម្រោងអនុគ្រោះពន្ធគយរួមរបស់អាស៊ាន (ទម្រង់ D កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញរបស់អាស៊ាន) ដើម្បីជួយសម្រួលការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន។

## វិស័យនៃកិច្ចសហប្រតិបត្តិការ

កម្រិតដែលកិច្ចសម្រួលពាណិជ្ជកម្មអាចធ្វើវិសោធនកម្មបាន ដើម្បីកិច្ចសហប្រតិបត្តិការជាអន្តរជាតិ គឺជាចម្ងល់ដ៏សំខាន់មួយ។ ក្រោយមក កិច្ចសម្រួលពាណិជ្ជកម្មគឺនិយាយអំពីការវាយតម្លៃអំពីការរាំងស្ទះនៅក្នុងនីតិវិធីដែលទាក់ទងនឹងពាណិជ្ជកម្មដែលមានស្រាប់ និង ការកាត់បន្ថយ ឬ ធ្វើកំណែទម្រង់នីតិវិធីដែលពិបាកខ្លាំងពេក ដោយមិនបន្ធូរបន្ថយវត្ថុបំណងនៃការធ្វើនិយ័តកម្មស្របច្បាប់នោះទេ។ នីតិវិធីនៅតាមព្រំដែនមួយចំនួនមានលក្ខណៈបច្ចេកទេសគួរសម (ឧ. ការគ្រប់គ្រងហានិភ័យ) ដូច្នេះ តម្រូវឲ្យមានការបណ្តុះបណ្តាល និង ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរដ្ឋបាលឲ្យបានល្អ។ ជាចុងក្រោយ ការយល់ព្រមចំពោះ និង ការប្រកាន់ខ្ជាប់នូវទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ នឹងអាចបង្កើនប្រសិទ្ធភាពរបស់នីតិវិធីនៅតាមព្រំដែនជាអតិបរមា។

នៅអាស៊ាន ជាកន្លែងដែល AMS បានព្យាយាមពង្រឹងចំណុចខ្លាំងរបស់គ្នាទៅវិញទៅមក តាមរយៈការអនុវត្តតាមគោលដៅសមាហរណកម្មសេដ្ឋកិច្ចដ៏ធំមួយ ដើម្បីបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននោះ ក៏មានវិសាលភាពសម្រាប់ការចែករំលែកចំណេះដឹង ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង និង កិច្ចព្រមព្រៀងពិសេសៗស្តីពីកិច្ចសម្រួលពាណិជ្ជកម្មនៅក្នុងការធ្វើជំនួញនៅក្នុងចំណោមប្រទេសនៃ ASEM។ ចំពោះប្រទេសដែលទន់ខ្សោយជាង កិច្ចសម្រួលពាណិជ្ជកម្មដែលមានគុណភាពខ្ពស់នឹងតម្រូវឲ្យមានទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែករូបវ័ន្ត និង ការកសាងសមត្ថភាព

ដែលអាចទទួលបានការគាំទ្រពីប្រទេសសម្រួលពាណិជ្ជកម្មដែលមានបទពិសោធន៍ច្រើនជាង។ ការរៀបចំ/ការគាំទ្រចំពោះកិច្ចប្រជុំពិភាក្សា សិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាលស្តីពីធាតុនានានៃកិច្ចសម្រួលពាណិជ្ជកម្មដែលមានលក្ខណៈស្មុគស្មាញ ដូចជា ការគ្រប់គ្រងហានិភ័យដែលបានធ្វើសមាហរណកម្មរួចហើយ ជាដើមនោះ អាចជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងពន្លឿនការអនុវត្តរបស់ពួកគេ។

ដោយសារតែបច្ចេកវិទ្យាឌីជីថល កិច្ចសម្រួលពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន អាចមានសារសំខាន់នៅក្នុងពង្រឹងការតភ្ជាប់នៅក្នុងចំណោមប្រទេសនៃ ASEM។ សូម្បីតែនៅក្នុងប្រទេសដែលមានភាពជឿនលឿនជាងក៏ដោយ ក៏ការសម្រួលពាណិជ្ជកម្មឆ្លងដែននៅតែជាព្រំដែនបន្ទាប់នៃកិច្ចសម្រួលពាណិជ្ជកម្មដែរ។

ដើម្បីធ្វើឲ្យពាណិជ្ជកម្មអេឡិចត្រូនិកមានភាពរលូន ចាំបាច់ត្រូវមានសុខដុមនីយកម្មផ្នែកបច្ចេកទេស និង ផ្នែកច្បាប់ ដើម្បីធានាចំពោះលទ្ធភាពក្នុងការដំណើរការទៅវិញទៅមក ការកសាងសមត្ថភាព កិច្ចសហការ និង ការសម្របសម្រួលអន្តររដ្ឋាភិបាល។ ក្នុងករណីនេះ មានវឌ្ឍនភាពមួយចំនួន។ប្រទេសជាច្រើននៅអាស៊ីបានអនុម័តកិច្ចព្រមព្រៀងនៃក្របខណ្ឌមួយស្តីពីការសម្រួលពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងព្រំដែន ដែលរួមបញ្ចូលការផ្លាស់ប្តូរទិន្នន័យ និង ឯកសារដែលទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក នៅក្នុងប្រព័ន្ធពាណិជ្ជកម្មថ្នាក់ជាតិ។ ដំណើរការរបស់ ASEM អាចជំរុញឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធនៅក្នុងច្រកចេញចូលតែមួយ។

# ឯកសារយោង

Beverelli, C., S. Neumueller, and R. Teh (2014), A New Look at the Extensive Trade Margin Effects of Trade Facilitation, World Trade Organization Staff Working Paper ERSD-2014-16. https://www.wto.org/english/res_e/reser_e/ersd201416_e.pdf (accessed 24 April 2020).

Maur, J.C. (2011), 'Trade Facilitation', in J.-P. Chauffour and J.C. Maur (eds.), Preferential Trade Agreement Policies for Development, 15, pp. 327–346. Washington, DC: World Bank.

Persson, M. (2008), Trade Facilitation and the EU–ACP Economic Partnership Agreements,

Journal of Economic Integration, pp. 518–546.

UNESCAP and ADB (2019), Asia–Pacific Trade Facilitation Report 2019: Bridging Trade Finance Gaps through Technology. Manila: Asian Development Bank.

## សេចក្តីបន្ថែម៖ បញ្ជីវិធីសាស្ត្រសម្រួលពាណិជ្ជកម្មដែលត្រូវបានប៉ាន់ប្រមាណដោយការស្ទង់មតិ UNTF

1. គណៈកម្មាធិការសម្រួលពាណិជ្ជកម្មថ្នាក់ជាតិ ឬ អង្គភាពប្រហាក់ប្រហែលគ្នា
2. ការបោះពុម្ពផ្សាយបទប្បញ្ញត្តិស្តីពីការនាំចូល-នាំចេញដែលមានស្រាប់នៅលើអ៊ីនធឺណិត
3. ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធអំពីសេចក្តីព្រាងបទបញ្ញត្តិថ្មីៗ (មុនពេលសម្រេចបញ្ចប់)
4. ការបោះពុម្ពផ្សាយ/សេចក្តីជូនដំណឹងជាមុនអំពីបទប្បញ្ញត្តិថ្មីៗដែលទាក់ទងនឹងពាណិជ្ជកម្ម មុនពេលអនុវត្ត
5. សេចក្តីសម្រេចជាមុន ស្តីពីការបែងចែកប្រភេទពន្ធគយ និង ប្រភពដើមនៃទំនិញនាំចូល
6. ការគ្រប់គ្រងហានិភ័យ
7. ការដំណើរការមុនពេលមកដល់
8. សវនកម្មក្រោយពេលត្រួតពិនិត្យ
9. យន្តការបណ្តឹងតវ៉ាដោយឯករាជ្យ
10. ការបំបែកការបញ្ចេញទំនិញពីគោលដៅចុងក្រោយនៃពន្ធគយ ពន្ធដារ ថ្លៃសេវា និង ថ្លៃបន្ទុកនានា
11. ការបង្កើត និង ការបោះពុម្ពផ្សាយពេលវេលាបញ្ចេញទំនិញជាមធ្យម
12. វិធីសាស្ត្រសម្រួលពាណិជ្ជកម្មសម្រាប់ប្រតិបត្តិករដែលមានការអនុញ្ញាត
13. ការដឹកជញ្ជូនតាមកប៉ាល់ឆាប់រហ័ស
14. ការទទួលយកសំណៅចម្លងនៃឯកសារគាំទ្រដែលត្រូវបានតម្រូវសម្រាប់ទម្រង់បែបបទនៃការនាំចូល ការនាំចេញ ឬ ការដឹកជញ្ជូនឆ្លងកាត់
15. ប្រព័ន្ធគយស្វ័យប្រវត្តិ
16. ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ដែលមានសម្រាប់ទីភ្នាក់ងារគយ និង ទីភ្នាក់ងារគ្រប់គ្រងពាណិជ្ជកម្មដទៃទៀត
17. ប្រព័ន្ធច្រកចេញតែមួយតាមប្រព័ន្ធអេឡិចត្រូនិក
18. ការដាក់សេចក្តីប្រកាសពន្ធគយតាមប្រព័ន្ធអេឡិចត្រូនិក
19. ពាក្យស្នើសុំ និង ការចេញលិខិតអនុញ្ញាតនាំចូល និង នាំចេញតាមប្រព័ន្ធអេឡិចត្រូនិក

20. ការដាក់បញ្ជីដឹកជញ្ជូនទំនិញតាមផ្លូវសមុទ្រតាមប្រព័ន្ធអេឡិចត្រូនិក
21. ការដាក់បញ្ជីដឹកជញ្ជូនទំនិញតាមផ្លូវអាកាសតាមប្រព័ន្ធអេឡិចត្រូនិក
22. ពាក្យស្នើសុំ និង ការចេញលិខិតបញ្ជាក់ប្រភពដើមដែលមានលក្ខណៈអនុគ្រោះតាមប្រព័ន្ធអេឡិចត្រូនិក
23. ការទូទាត់ពន្ធគយ និង ថ្លៃសេវាតាមប្រព័ន្ធអេឡិចត្រូនិក
24. ពាក្យស្នើសុំបង្វិលប្រាក់ពន្ធគយវិញតាមប្រព័ន្ធអេឡិចត្រូនិក
25. ច្បាប់ និង បទប្បញ្ញត្តិសម្រាប់ចម្លងការតាមប្រព័ន្ធអេឡិចត្រូនិក
26. អាជ្ញាធរបញ្ជាក់ដែលមានការទទួលស្គាល់
27. ការផ្លាស់ប្តូរសេចក្តីប្រកាសពន្ធគយតាមប្រព័ន្ធអេឡិចត្រូនិក
28. ការផ្លាស់ប្តូរលិខិតបញ្ជាក់ប្រភពដើមតាមប្រព័ន្ធអេឡិចត្រូនិក
29. ការផ្លាស់ប្តូរលិខិតបញ្ជាក់អនាម័យ និង ភូតគាមអនាម័យតាមប្រព័ន្ធអេឡិចត្រូនិក
30. ការប្រមូលប្រាក់ពីសំណុំឯកសារលិខិតឥណទានតាមប្រព័ន្ធអេឡិចត្រូនិក
31. ក្របខណ្ឌច្បាប់ជាតិ និង/ឬ ការព្រមព្រៀងរបស់ស្ថាប័នចំពោះកិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារនៅតាមព្រំដែន
32. ទីភ្នាក់ងាររដ្ឋាភិបាល ដែលធ្វើប្រតិភូកម្មការគ្រប់គ្រងទៅកាន់អាជ្ញាធរគយ
33. ការសម្របថ្ងៃធ្វើការ និង ម៉ោងធ្វើការតាមប្រទេសជិតខាងនៅពេលឆ្លងព្រំដែន
34. ការសម្របទម្រង់បែបបទ និង នីតិវិធីតាមប្រទេសជិតខាងនៅពេលឆ្លងព្រំដែន
35. កិច្ចព្រមព្រៀងសម្រួលការដឹកជញ្ជូនឆ្លងកាត់
36. អាជ្ញាធរគយដាក់កំហិតលើការត្រួតពិនិត្យផ្នែករូបវន្តលើទំនិញឆ្លងកាត់ និង ប្រើប្រាស់ការប៉ាន់ប្រមានអំពីហានិភ័យ
37. គាំទ្រការដំណើរការមុនពេលមកដល់ ដើម្បីសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់
38. កិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងាររបស់ប្រទេសនានាដែលជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់។

4

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប និងប្រទេសវៀតណាម

## ដំណើរការ ផលប៉ះពាល់ និង មេរៀនសំខាន់ៗ

THANH TRI VO

### ១. សេចក្តីផ្តើម

កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និង ប្រចាំតំបន់ ពង្រឹងការតភ្ជាប់ផ្នែកសេដ្ឋកិច្ច និង ធ្វើឲ្យសមាហរណកម្មរបស់ស្ថាប័នមានលក្ខណៈស៊ីជម្រៅនៅក្នុង និង រវាងតំបន់នានា។ កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសនានានៅអឺរ៉ុប និង អាស៊ី មានអត្ថប្រយោជន៍ជាពិសេស ពីព្រោះកិច្ចព្រមព្រៀងទាំងនោះពង្រឹងបណ្តាញផលិតកម្មអន្តរជាតិនៅក្នុង និង រវាងទ្វីបអាស៊ី និង អឺរ៉ុប។ កំណើនសមាហរណកម្មរបស់សហភាពអឺរ៉ុប (EU) រួមជាមួយខ្សែសង្វាក់តម្លៃរបស់អាស៊ីធ្វើឲ្យមានកំណើនពាណិជ្ជកម្ម ការវិនិយោគ និង កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី EU-វៀតណាមនេះ គឺជាឧទាហរណ៍ដ៏គួរឲ្យកត់សម្គាល់មួយ។ ប្រទេសវៀតណាមបានចាប់ផ្តើមប្រតិបត្តិការកំណែទម្រង់សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ចាប់តាំងពីមានគំនិតផ្តួចផ្តើម Doi Moi (ការកែលម្អ) នៅឆ្នាំ១៩៨៦។ ទោះបីជាមានភាពខុសគ្នាចំពោះប្រភេទកំណែទម្រង់ និង ការប្រែប្រួលជំហាននៃការអនុវត្តទៅតាមពេលវេលាក៏ដោយ ក៏កំណែទម្រង់នោះស្ថិតនៅលើសសរស្តម្ភដែរដូចជា (i) កំណែទម្រង់ដែលតម្រង់ទិសចំពោះទីផ្សារ (ii) ការធ្វើឲ្យមានស្ថេរភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច និង (iii) សមាហរណកម្មប្រកបដោយប្រតិសកម្ម។[7] ចំណុចដែលគួរឲ្យកត់សម្គាល់គឺ ដំណើរការនៃការធ្វើសមាហរណកម្មមានអន្តរកម្មយ៉ាងជិតស្និទ្ធនឹងកំណែទម្រង់នៅក្នុងប្រទេស ជាពិសេស ពាក់ព័ន្ធនឹងស្ថាប័ននានា ដើម្បីសេដ្ឋកិច្ចទីផ្សារ។

យោងតាមការសិក្សាខុសៗគ្នា (ឧ. Dinh et al. ២០០៩, CIEM ២០១៣) រយៈពេលខិតខំប្រឹងប្រែងដែលមានអត្ថន័យកាន់តែខ្លាំងចំពោះការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការវិនិយោគ

[7] សម្រាប់ព័ត៌មានបន្ថែម សូមមើល Dinh et al. (២០០៩)។

(ពោលគឺឆ្នាំ១៩៨៩–១៩៩៦ឆ្នាំ២០០០–២០០៧និងឆ្នាំ២០១៤–២០១៩)ក៏ជារយៈពេលដែលមានកំណែទម្រង់ស្ថាប័នសេដ្ឋកិច្ចក្នុងប្រទេសគ្រប់ជ្រុងជ្រោយផងដែរ។

ការធានាចំពោះការទទួលបានអត្ថប្រយោជន៍ប្រកបដោយចីរភាពពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចបន្ថែមទៀត នៅតែជាអាទិភាពដ៏សំខាន់មួយសម្រាប់ប្រទេសវៀតណាម។[8] យោងតាមទស្សនវិស័យរបស់ប្រទេស កម្រិតនៃការធ្វើសមាហរណកម្មជាអន្តរជាតិនៅតែមានកម្រិតទាបនៅក្នុងវិស័យជាច្រើន ជាពិសេសពាក់ព័ន្ធនឹងសុខដុមនីយកម្មនៃបទដ្ឋាន ការទទួលស្គាល់ទៅវិញទៅមក និង កំណែទម្រង់សេដ្ឋកិច្ចទីផ្សារ។ល។ ដូច្នេះ ការធ្វើឲ្យសមាហរណកម្មនៅក្នុងវិស័យទាំងនោះមានភាពស៊ីជម្រៅ មានសារសំខាន់ដើម្បីជំរុញឲ្យសមត្ថភាពនៅក្នុងប្រទេសមានភាពល្អប្រសើរឡើង។ យោងតាមទស្សនវិស័យនោះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ដែលមានបទដ្ឋានខ្ពស់ ជាពិសេស ជាមួយដៃគូដែលមានភាពជឿនលឿនជាង គឺមានសារសំខាន់ខ្លាំងណាស់ចំពោះប្រទេសវៀតណាម។

បរិបទសម្រាប់សេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការវិនិយោគ បានបញ្ជាក់អំពីកំណើននៃភាពមិនច្បាស់លាស់នៅក្នុងអំឡុងឆ្នាំ២០១៦-២០២០ ហើយភាពមិនច្បាស់លាស់នេះនៅតែបន្តកើតឡើង។ ទោះបីជាវាមិនល្អឥតខ្ចោះក៏ដោយ ក៏ FTAs ជំនាន់ថ្មី យ៉ាងហោចណាស់បានកំណត់វិស័យ និង ភាពស៊ីជម្រៅដែលពាក់ព័ន្ធ សម្រាប់សេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការវិនិយោគ ទោះបីជានៅកម្រិតក្រៅព្រំដែនក៏ដោយ នៅកន្លែងដែលអាចមានការព្រមព្រៀងគ្នា។ បន្ទាប់ពីមានការអនុវត្តកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និង មានវឌ្ឍនភាពសម្រាប់ភាពជាដៃគូឆ្លងប៉ាស៊ីហ្វិក (CPTPP) ហើយនោះ FTA រវាង សហភាពអឺរ៉ុប-វៀតណាម (EVFTA) ត្រូវបានគេរំពឹងទុកថានឹងបន្តពង្រឹងអភិក្រមរបស់ប្រទេសវៀតណាមចំពោះសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការវិនិយោគ ព្រមទាំងកំណែទម្រង់សេដ្ឋកិច្ចក្នុងប្រទេសឲ្យកាន់តែរឹងមាំថែមទៀត។ នៅខណៈពេលដែលសេរីភាវូបនីយកម្មពាណិជ្ជកម្មពហុភាគីនៅតែពិបាកឈោងចាប់នោះ កម្លាំងជំរុញចំពោះការប៉ុនប៉ងធ្វើសេរីភាវូបនីយកម្មដែលមានភាពទន់ខ្សោយនៅក្នុងទីផ្សារ និង តំបន់ខុសៗគ្នា បានបង្កប់អត្ថន័យថាវឌ្ឍនភាពណាមួយចំពោះការបន្តសេរីភាវូបនីយកម្មពាណិជ្ជកម្មពហុភាគី និង នៅក្នុងតំបន់ ដូចជាតាមរយៈ EVFTA ជាដើម អាចបញ្ជាក់ថា នៅចុងបញ្ចប់ វាពិតជាមានអត្ថន័យខ្លាំងណាស់។ ស្របពេលជាមួយគ្នានេះ កិច្ចខិតខំប្រឹងប្រែងដែលត្រូវបានសម្របសម្រួលនៅកម្រិតអន្តរជាតិ/តំបន់ នឹងមិនគ្រប់គ្រាន់នោះទេ ប្រសិនបើគ្មានយុទ្ធសាស្ត្រដែលត្រូវបានកែសម្រួលយ៉ាងសមស្រប

[8] ចំណុចនេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងសេចក្តីសម្រេច 06-NQ/TW ដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីសនៃប្រទេសវៀតណាម កាលពីខែវិច្ឆិកា ឆ្នាំ២០១៦។

ដើម្បីធ្វើសេរីភាវូបនីយកម្ម និង លើកកម្ពស់ពាណិជ្ជកម្ម និង ការវិនិយោគនៅក្នុងសេដ្ឋកិច្ចនីមួយៗ និង អាចលើសពីនេះទៀត ចំពោះសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសវៀតណាម ជាដើម។

ជំពូកនេះមានបំណងត្រួតពិនិត្យឡើងវិញលើដំណើរការ និង ផលប៉ះពាល់នៃ EVFTA ចំពោះសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម។ នៅខណៈពេលត្រួតពិនិត្យឡើងវិញបែបនោះ វាពឹងផ្អែកលើការស្ទង់មតិលើអក្សរសាស្ត្រស្តីពី EVFTA និង ផលប៉ះពាល់របស់វា និង ដោយផ្អែកលើមូលដ្ឋាននៃការស្ទង់មតិនោះ សង្ខេបអំពីមេរៀនសំខាន់ៗដែលទទួលបានពី EVFTA។

ចំណុចផ្សេងៗទៀតនៃជំពូកនេះមានរចនាសម្ព័ន្ធដូចតទៅ។ ផ្នែកទី ២ ពណ៌នាដោយសង្ខេបអំពីដំណើរការ EVFTA។ បន្ទាប់មក ផ្នែកទី ៣ ធ្វើការស្ទង់មតិលើឯកសារស្តីពីផលប៉ះពាល់នៃ EVFTA ចំពោះសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម។ ផ្នែកទី ៤ ពិភាក្សាអំពីមេរៀនសំខាន់ៗដែលទទួលបានមកពី EVFTA។ ផ្នែកទី ៥ ស្នើផ្តល់កំណត់សម្គាល់នៃការសន្និដ្ឋានមួយចំនួន។

## ២. ព្រឹត្តិការណ៍សំខាន់ៗរបស់ EVFTA

កាលពីខែតុលា ឆ្នាំ២០១០ ប្រទេសវៀតណាម និង សហភាពអឺរ៉ុប (EU) បានព្រមព្រៀងគ្នាចាប់ផ្តើមចរចាអំពីជំនួញពាណិជ្ជកម្ម។ នៅខែមិថុនា ឆ្នាំ២០១២ ការចរចាជុំដំបូងបានចាប់ផ្តើម។ រហូតមកដល់ ខែសីហា ឆ្នាំ២០១៥ ប្រទេសវៀតណាម និង EU បានបញ្ចប់ការចរចាជាផ្លូវការចំនួន ១៤ លើក និង ការចរចានៅដំណាក់កាលកណ្តាលមួយចំនួន។

ប្រទេសវៀតណាម និង EU បានប្រកាសអំពីការបញ្ចប់ការចរចានៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ហើយការចរចានានាត្រូវបានទាញសេចក្តីសន្និដ្ឋានជាផ្លូវការនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥។

ផ្អែកតាមមូលដ្ឋាននៃការចរចានេះ ប្រទេសវៀតណាម និង EU បានត្រៀមខ្លួនសម្រាប់ការចុះហត្ថលេខា និង ការផ្តល់សច្ចាប័នដល់ EVFTA។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ អត្ថបទផ្លូវការពេញលេញអំពី EVFTA ត្រូវបានបោះពុម្ពផ្សាយ។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ EVFTA ត្រូវបានបំបែកជាកិច្ចព្រមព្រៀងចំនួនពីរ គឺ EVFTA និង កិច្ចព្រមព្រៀងការពារការវិនិយោគ រវាង EU-វៀតណាម (EVIPA)។[9] នៅក្នុងខែដូចគ្នានោះ ការត្រួតពិនិត្យឡើងវិញតាមផ្លូវច្បាប់លើ

[9] ដូចដែលបានកត់សម្គាល់ដោយសភាអឺរ៉ុប (n.d.) “ FTA និង IPA ត្រូវបានចរចាជាលើកដំបូង ជាអត្ថបទតែមួយ ប៉ុន្តែ នៅក្នុងឆ្នាំ២០១៨ EU និង ប្រទេសវៀតណាមបានសម្រេចចិត្តបំបែកកិច្ចព្រមព្រៀងទាំងពីរនេះ បន្ទាប់ពីមានអភិក្រមត្រូវបានជ្រើសរើសសម្រាប់កិច្ចព្រមព្រៀងធ្វើពាណិជ្ជកម្ម និង ការវិនិយោគជាមួយប្រទេសសិង្ហបុរី។ FTA គ្របដណ្តប់លើសមត្ថភាពផ្តាច់មុខរបស់ EU អាស្រ័យហេតុនេះ មានតែ EU មួយ ប៉ុណ្ណោះដែលអាចផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះបាន ដោយមិនជាប់ពាក់ព័ន្ធនឹងរដ្ឋសមាជិកនោះទេ។ IPA គ្របដណ្តប់លើការវិនិយោគដោយប្រយោល (“ជាមូលបត្រ”) និង យន្តការដោះស្រាយទំនាស់នៅក្នុងរដ្ឋរបស់សហគ្រិន៖ ទាំងនេះគឺជាសមត្ថភាពរួម ដែល EU ចែករំលែកសមត្ថភាពក្នុងការសម្រេចចិត្តជាមួយរដ្ឋសមាជិក ដែលមានន័យថា កិច្ចព្រមព្រៀងត្រូវតែបានផ្តល់សច្ចាប័នដោយរដ្ឋសមាជិក។”

EVFTA ត្រូវបានបញ្ចប់ជាផ្លូវការ និងមានការព្រមព្រៀងគ្នាលើ EVIPA។ នៅខែសីហា ឆ្នាំ២០១៨ ការត្រួតពិនិត្យឡើងវិញតាមផ្លូវច្បាប់លើ EVIPA ត្រូវបានបញ្ចប់ជាផ្លូវការ។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ គណៈកម្មការអឺរ៉ុបបានអនុម័តជាផ្លូវការលើ EVFTA និង EVIPA។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តលើ EVFTA និង EVIPA និង បានទទួលយកដើម្បីឲ្យ EU ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រទេសវៀតណាម។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ EVFTA និង EVIPA ត្រូវបានចុះហត្ថលេខាជាផ្លូវការ។

កាលពីខែកុម្ភៈ ឆ្នាំ២០២០ សភាអឺរ៉ុបបានផ្តល់សច្ចាប័នដល់ EVFTA និង EVIPA។ EVIPA ត្រូវបានអនុម័តដោយមានសម្លេងឆ្នោតគាំទ្រចំពោះកិច្ចព្រមព្រៀងចំនួន ៤០៧ សម្លេង សម្លេងឆ្នោតប្រឆាំងនឹងកិច្ចព្រមព្រៀងចំនួន ១៨៨ សម្លេង និង អនុបវាទចំនួន ៥៣ សម្លេង ហើយ EVFTA មានសម្លេងឆ្នោត ៤០១ ១៩២ និង ៤០ ដោយឡែកពីគ្នា។ ដើម្បីទទួលបានសច្ចាប័នពីខាង EU EVIPA ត្រូវតែបានអនុម័តដោយគ្រប់សភាទាំងអស់នៃរដ្ឋសមាជិក EU។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តលើសេចក្តីសម្រេចចុះ EVFTA។ នៅខែឧសភា ឆ្នាំ២០២០ EVIPA និង EVFTA ត្រូវបានដាក់ជូនរដ្ឋសភានៃប្រទេសវៀតណាមដើម្បីធ្វើការពិចារណា និង ផ្តល់សច្ចាប័ន។ កិច្ចព្រមព្រៀងទាំងពីរនេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភានៃប្រទេសវៀតណាម នៅខែមិថុនា ឆ្នាំ២០២០។ អាស្រ័យហេតុនេះ EVFTA នឹងចូលជាធរមាននៅដើមខែសីហា ឆ្នាំ២០២០ នៅខណៈពេលដែល EVIPA នឹងចូលជាធរមានក្រោយពេលផ្តល់សច្ចាប័នដោយសភានៃរដ្ឋសមាជិក EU ទាំងអស់។

ជាការកត់សម្គាល់ចុងក្រោយ ការចរចារសម្រាប់ EVFTA បានចាប់ផ្តើមនៅ ប្រហែលពីរឆ្នាំបន្ទាប់ពីប្រទេសវៀតណាមបានចូលរួមនៅក្នុងការចរចាភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP)។ អាស្រ័យហេតុនេះ អ្នកបង្កើតគោលនយោបាយ និង សាធារណជនមានភាពបើកចំហរ និង មានទម្លាប់កាន់តែខ្លាំងឡើង នៅក្នុងការជជែកវែកញែកអំពីការចងកាតព្វកិច្ច ការរឹតត្បិតជាងមុន ការប្តេជ្ញាចិត្តស្របតាម FTAs ជំនាន់ថ្មី (រួមបញ្ចូលទាំង TPP ផងដែរ)។ នៅក្នុងករណីនេះ បទដ្ឋានខ្ពស់របស់ EVFTA នៅក្នុងវិស័យជាច្រើន ដូចជា ពាក់ព័ន្ធនឹងសហគ្រាសដែលកាន់កាប់ដោយរដ្ឋ ការអភិវឌ្ឍប្រកបដោយចីរភាព និង សិទ្ធិការងារ។ល។ ត្រូវបានគេមើលឃើញថាមិនមែនមានបញ្ហានោះទេ។

ផ្ទុយមកវិញ អត្ថប្រយោជន៍ដែលអាចទទួលបានពី EVFTA ត្រូវបានបន្ថែមទៅលើបទដ្ឋានរបស់ TPP ដែលរួមបញ្ចូលគ្នាទាំងអស់ បានរួមចំណែកដល់ការបញ្ជាក់អំពីការកំណត់របស់ប្រទេសវៀតណាម ដើម្បីរួមបញ្ចូលបទដ្ឋានខ្ពស់ៗនៅក្នុង FTAs។ ផ្នែកបន្ទាប់ទៀតនឹងធ្វើការស្ទង់មតិពីឯកសារនានាស្តីពីផលប៉ះពាល់របស់ EVFTA ចំពោះសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម។

# ៣. ផលប៉ះពាល់របស់ EVFTA ចំពោះសេដ្ឋកិច្ចរបស់ប្រទេសវៀតណាមៈ ការស្ទង់មតិពីឯកសារនានា

## ៣.១ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប

ការសិក្សាផ្អែកបរិមាណខុសៗគ្នា (ឧ. Baker et al. [២០១៤], Baker et al. [២០១៧], និង Ha [២០២០]) បង្ហាញថា ប្រទេសវៀតណាមប្រហែលជាអាចទទួលបានផលចំណេញជាច្រើនពី EVFTA។ យោងតាម Baker et al. (២០១៧) ប្រសិនបើប្រៀបធៀបនឹងខ្សែបន្ទាត់គោលនៃអាជីវកម្មធម្មតា ផលចំណេញដែលបានរំពឹងទុកមានចំនួន ៣,២ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២០ ៦,៧ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២៥ និង ៧,២ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០៣០។ ទាក់ទងនឹងប្រាក់ចំណូលជាតិ EVFTA អាចជួយពង្រីកសេដ្ឋកិច្ចវៀតណាម ត្រឹម ២,៥% ៤,៦% និង ៤,៣% នៅឆ្នាំ២០២០ ២០២៥ និង ២០៣០។ នៅក្នុងអំឡុងឆ្នាំ២០១៧–២០៣០ EVFTA អាចជួយបង្កើនអត្រាកំណើន GDP ប្រចាំឆ្នាំជាមធ្យមរបស់ប្រទេសវៀតណាម ពី ៤,២% ទៅ ៤,៦%។

ដោយប្រើប្រាស់បច្ចុប្បន្នភាពផ្អែកបរិបទរហូតមកដល់ខែកញ្ញាឆ្នាំ២០១៩[10] ក្រសួងផែនការ និងវិនិយោគនៃប្រទេសវៀតណាម (២០១៩ បានដកស្រង់ពី Ha [២០២០]) ប៉ាន់ស្មានថា ផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំរបស់ប្រទេសវៀតណាម (GDP) អាចកើនឡើងត្រឹម ១,២៤%–២,០២% នៅក្នុងអំឡុងឆ្នាំ ២០២២–២០២៤ ត្រឹម ៣,៥៣%–៤,៣៧% នៅក្នុងអំឡុងឆ្នាំ២០២៥–២០៣០ និងត្រឹម ៤,៦៥%–៥,២៧% មុនឆ្នាំ២០៣០ អាស្រ័យលើស៊ីណារីយ៉ូ។ ការសិក្សាផ្អែកបរិមាណក៏មានបំណងពន្យល់អំពីផលប៉ះពាល់នានាចំពោះ GDP របស់ប្រទេសវៀតណាមផងដែរ។

Baker et al. (២០១៧) អះអាងថា ប្រទេសវៀតណាមមានផលធៀបពាណិជ្ជកម្មខ្ពស់ ចំពោះ GDP ព្រមទាំងមានទំហំពាណិជ្ជកម្មដ៏ធំមួយជាមួយ EU ផងដែរ ខណៈពេលដែល EU អនុវត្តកិច្ចការពារកម្រិតខ្ពស់លើការនាំចេញសំខាន់ៗរបស់ប្រទេសវៀតណាម។ លើសពីនេះទៀត EVFTA អាចរួមចំណែកយ៉ាងសំខាន់ដល់ការលុបចោលកិច្ចការពារដ៏សំខាន់របស់ប្រទេសវៀតណាមចំពោះឧស្សាហកម្មជាច្រើន។ ជាពិសេស ប្រភពចំនួនបីសំខាន់ៗនៃផលចំណេញរបស់ប្រទេសវៀតណាមរួមមានៈ (i) ការចូលក្នុងទីផ្សារបានល្អប្រសើរជាងមុន (ii) ការប្រើប្រាស់ធនធាននៅក្នុងប្រទេសបានល្អប្រសើរជាងមុន និង (iii) ការប្រើប្រាស់ទាយជ្ជទាននៃមូលធន និង ពលកម្ម

[10] រួមបញ្ចូលសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក–ប្រទេសចិន និង Brexit។ល។

លើការមានការងារធ្វើមិនគ្រប់គ្រាន់ កាលពីមុន (រូបភាពទី១)។ Ha (២០២០) បន្ថែមថា ការដករបាំងមិនមែនពន្ធគយចេញសន្សឹមៗ និង កំណើនយ៉ាងឆាប់រហ័សនៃលំហូរវិនិយោគផ្ទាល់ពីបរទេសចូលទៅក្នុងប្រទេសវៀតណាម អាចមានផលប៉ះពាល់យ៉ាងខ្លាំងក្លាចំពោះ GDP នៅក្នុងរយៈពេលមធ្យមទៅរយៈពេលវែង នៅខណៈពេលដែលផលប៉ះពាល់នៅរយៈពេលវែងក៏អាចមើលឃើញការរួមចំណែកចំពោះភាពល្អប្រសើរឡើងនៃផលិតភាពផងដែរ។

**រូបភាពទី១៖ ចំណងនៅក្នុង ASEM មានភាពរឹងមាំជាងចំណងជាមួយប្រទេសដទៃទៀតក្នុងពិភពលោក**




ប្រភព៖ Baker et al. (២០១៧).

ការប្រមើលមើលអំពីផលប៉ះពាល់នានានៅខាងលើ ប្រហែលជាមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ ចំពោះប្រទេសវៀតណាម។ តាមរយៈការចូលរួមនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) សហគ្រាសនៃប្រទេសវៀតណាមមានការចំណាយទាបក្នុងការចូល និងការពង្រីកខ្លួនទៅកាន់ទីផ្សារអន្តរជាតិ ស្របពេលដែលទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នាបន្ថែមទៀតនៅក្នុងពាណិជ្ជកម្ម និង ការដោះស្រាយជម្លោះ។ បន្ទុកចំណាយទាបជាងមុនបែបនោះ ទទួលបានពីកំណែទម្រង់វិស័យសេដ្ឋកិច្ចនៅក្នុងប្រទេស ដែលស្របនឹងការចរចានានា ដើម្បីចូលជាសមាជិករបស់ WTO ចាប់តាំងពី ២០០០ មក។ លទ្ធផលនេះត្រូវបានមើលឃើញជាមុន នៅក្នុង Roland-Holst et al. (២០០២) ហើយក្រោយមក ត្រូវបានបញ្ជាក់នៅក្នុង Vo និង Nguyen (២០០៩)។ ទីបី ប្រទេសវៀតណាម

បានបន្តទាក់ទាញការវិនិយោគពីបរទេស ដោយសារការរក្សាបាននូវស្ថេរភាពផ្នែកនយោបាយ និង សេដ្ឋកិច្ចសង្គម (CIEM ២០១០ ២០១៣)។

ការសិក្សាដែលប្រើប្រាស់ការវិភាគមុន និង ក្រោយពេលមានផលប៉ះពាល់លើសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម មានការដាក់កម្រិតជាច្រើន។ ការវិភាគទាំងនេះត្រូវធ្វើការសន្មតថា កិច្ចព្រមព្រៀងណាមួយនឹងត្រូវបានអនុវត្តតាមការរៀបចំ។ ស្របពេលជាមួយគ្នានោះ វិធីសាស្ត្រមិនមែនពន្ធគយអាចរារាំងដល់ការធ្វើសេរីភាវូបនីយកម្ម ប្រកបដោយអត្ថន័យបន្ថែមទៀត តាមតម្រូវការនៅក្នុងការអនុវត្ត FTAs ដែលមានស្រាប់ និង នៅថ្ងៃអនាគត (Nguyen et al. ២០១៥)។ អត្រាពន្ធគយខ្ពស់បំផុតមួយចំនួនអាចត្រូវបានហាមឃាត់ ដែលអាចបណ្តាលឲ្យការអះអាងលើសពីការពិត អំពីប្រាក់ចំណេញដែលបានរំពឹងទុកថានឹងទទួលបានពីកំណែទម្រង់ពន្ធគយ។ ជាចុងក្រោយការសិក្សាក្រោយមកទៀត ទោះបីជាមានភាពប្រាកដប្រជាលក្ខណៈបច្ចេកទេសក៏ដោយ ក៏មិនអាចញែកផលប៉ះពាល់នៃពាណិជ្ជកម្ម និង សេរីភាវូបនីយកម្ម ចេញពីផលប៉ះពាល់ដែលបណ្តាលមកពីគោលនយោបាយដទៃទៀតនៅក្នុងប្រទេសវៀតណាម ទាំងស្រុងបាននោះទេ។

Nguyen et al. (២០១៥) ក៏សម្គាល់ឃើញការដាក់កម្រិតជាច្រើនផងដែរ ពាក់ព័ន្ធនឹងប្រភេទគំរូនៃតុល្យភាពទូទៅដែលអាចគណនាបាន ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាខុសៗគ្នា (ដូចជា Nguyen et al. [២០១៥] ធនាគារពិភពលោក [២០១៨] និង Baker et al. [២០១៧])។ ទីមួយ ការប្រែប្រួលមួយចំនួននៃអាកប្បកិរិយាផ្នែកផលិត និង ប្រើប្រាស់ ត្រូវបានគេសន្មតថាកើតឡើងជាស្វ័យប្រវត្តិ ដើម្បីឆ្លើយតបទៅនឹងបំរែបម្រួល ពន្ធគយ (ដូច្នេះ និង បំរែបម្រួលតម្លៃប្រៀបធៀប) នៅខណៈពេលដែលកត្តាអនុវត្តជាក់ស្តែងមួយចំនួនត្រូវបានគេមិនអើពើ ដែលផ្ទុយមកវិញ វាអាចមានផលជះដល់ការប្រើប្រាស់ FTA។ ទីពីរ គំរូទាំងនេះកម្រអាចរួមបញ្ចូលផលប៉ះពាល់នៃការពង្រឹងស្ថាប័ន និង លំហូរមូលធនបរទេសណាស់។ ទីបី ស៊ីណារីយ៉ូមានសារប្រយោជន៍គួរសមចំពោះទំហំដែលពួកគេជួយផ្តោតលើផលប៉ះពាល់របស់ FTAs ខុសៗគ្នា ប៉ុន្តែការកំណត់គោលនយោបាយមិនមែនជាពាណិជ្ជកម្មជាក់ស្តែង ប្រហែលជាពុំមានសង្គតភាពនឹងស៊ីណារីយ៉ូទាំងនោះ ទាំងស្រុងនោះទេ។

## ៣.២ ផលប៉ះពាល់លើពាណិជ្ជកម្ម

ការសិក្សាផ្នែកបរិមាណពន្យល់អំពីភាពរីកចម្រើននៃ GDP របស់ប្រទេសវៀតណាម តាមរយៈការពង្រីកពាណិជ្ជកម្ម ដែលកើតឡើងតាមរយៈ EVFTA។ យោងតាមការប៉ាន់ស្មានដោយ Baker et al. (២០១៧) គិតត្រឹមឆ្នាំ២០៣០ ការនាំចេញរបស់ប្រទេសវៀតណាមទៅកាន់

EU ស្របតាម EVFTA អាចកើនឡើងត្រឹម ៤៤% ប្រសិនបើប្រៀបធៀបនឹងខ្សែបន្ទាត់គោល នៅខណៈពេលដែលការនាំចេញពី EU ទៅកាន់ប្រទេសវៀតណាមអាចមានការកើនឡើងត្រឹម ៣៧% (រូបភាពទី ២)។ ចំណុចដែលគួរឲ្យកត់សម្គាល់គឺ ការកាត់បន្ថយពន្ធគយភាគច្រើននឹងត្រូវអនុវត្តនៅមុនឆ្នាំ២០៣០។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើប្រៀបធៀបនឹងខ្សែបន្ទាត់គោល EVFTA ក៏បង្ហាញអំពីឥទ្ធិពលដោយប្រយោលចំពោះការនាំចេញផងដែរ។ យោងតាម Baker et al. (២០១៧) ចំណុចនេះត្រូវបានពន្យល់ដោយប្រទេសវៀតណាម និង ធនធានរបស់ខ្លួននៅក្នុងទ្រង់ទ្រាយតូចដែលដាក់កំហិតលើការផ្គត់ផ្គង់។ អាស្រ័យហេតុនេះ កំណើននៃការនាំចេញជាទូទៅរបស់ប្រទេសវៀតណាមអាចមានភាពប្រសើរឡើង តិចជាងកំណើននៃការនាំចេញទៅកាន់ EU។

យោងតាមការប៉ាន់ស្មានរបស់ Baker et al. (២០១៧) ការនាំចេញជាទូទៅដែលស្ថិតនៅក្រោម EVFTA នៅក្នុងឆ្នាំ២០២០ ២០២៥ និង ២០៣០ នឹងមានការកើនឡើងត្រឹម ៣,១% ៥,៧% និង ៥,៦% ដោយឡែកពីគ្នា ប្រសិនបើប្រៀបធៀបនឹងខ្សែបន្ទាត់គោល (រូបភាពទី៣)។ ស្របពេលជាមួយគ្នានោះ ក្រសួងផែនការ និង វិនិយោគ (២០១៩ បានដកស្រង់ពី Ha [២០២០]) ប៉ាន់ស្មានថា កំណើនប្រចាំឆ្នាំជាមធ្យមលើការនាំចេញទូទៅ ដែលកើនឡើងដោយសារ EVFTA នឹងមានចន្លោះពី ៣,១៤៨% ទៅ ៥,១៣% សម្រាប់ឆ្នាំ ២០២២–២០២៤ និង មានចន្លោះពី ១០,៥១៨% ទៅ ១៩,៧៤% សម្រាប់ឆ្នាំ២០២៥–២០៣០។

**រូបភាពទី២៖ ការនាំចេញទ្វេភាគីនៅក្នុងឆ្នាំ២០២០ ២០២៥ និង ២០៣០ (លានដុល្លារអាមេរិក)**




ប្រភព៖ Baker et al. (២០១៧).

**រូបភាពទី៣៖ ការនាំចេញ និង ការនាំចូលជាទូទៅរបស់ប្រទេសវៀតណាម នៅក្នុងឆ្នាំ ២០២០ ២០២៥ និង ២០៣០ (លានដុល្លារអាមេរិក)**




ប្រភព៖ Bakeretal. (២០១៧)

រចនាសម្ព័ន្ធនៃការនាំចូលរបស់ប្រទេសវៀតណាមក៏អាចធ្វើជាសក្ខីភាពបញ្ជាក់អំពីការផ្លាស់ប្តូរដោយសារផលប៉ះពាល់របស់ EVFTA ផងដែរ។ Bakeretal. (២០១៧) ប៉ាន់ស្មានថាការនាំចូលជាទូទៅរបស់ប្រទេសវៀតណាម ក្រោម EVFTA នឹងកើនឡើងត្រឹម ៣,២% នៅក្នុងឆ្នាំ២០២០ ៦,១% នៅក្នុងឆ្នាំ២០២៥ និង ៥,៩៤% នៅក្នុងឆ្នាំ២០៣០ ដោយប្រៀបធៀបនឹងខ្សែបន្ទាត់គោល។ ការប៉ាន់ស្មាននាពេលថ្មីៗនេះ ដោយក្រសួងផែនការ និង វិនិយោគ (២០១៩ បានដកស្រង់ពី Ha [២០២០]) បង្ហាញថា កំណើននៃការនាំចូលទូទៅ អាចស្ថិតនៅចន្លោះពី ២,៧២% ទៅ ៥,០២% សម្រាប់ឆ្នាំ ២០២២–២០២៤ និង មានចន្លោះពី ១០,០៨% ទៅ ១៤,៧% សម្រាប់ឆ្នាំ២០២៥–២០៣០។ នៅគ្រប់ឆ្នាំទាំងអស់ ការពង្រីកការនាំចូល ក្រោម EVFTA ភាគច្រើនត្រូវបានរួមចំណែកដោយកំណើនការវិនិយោគផ្ទាល់ពីបរទេស ដែលអាចមានចំនួនរហូតដល់ ៧៦,៨% នៃ ការពង្រីកការនាំចូលទាំងនោះ។

គេគួរតែកត់សម្គាល់ផងដែរថា កំណើនការនាំចូលជាក់ស្តែងរបស់ប្រទេសវៀតណាម ពឹងផ្អែកលើកត្តាមួយចំនួន រួមបញ្ចូលទាំង សមត្ថភាពនៅក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្មនៅក្នុងប្រទេសផងដែរ។ ជាក់ស្តែង នៅក្នុងចំណោមមូលហេតុសំខាន់ៗដែលបណ្តាលឲ្យមានកំណើនការនាំចូលយឺតជាងមុន ចាប់តាំងពីឆ្នាំ២០១១ មក គឺការកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈ ដើម្បីជួយធ្វើឲ្យមជ្ឈដ្ឋានម៉ាក្រូសេដ្ឋកិច្ចមានស្ថេរភាព ដែល

ជារួម បានកាត់បន្ថយតម្រូវការការនាំចូល (Nguyen et al. ២០១៧)។ លើសពីនេះទៀត វៀតណាមបានពង្រឹងសមត្ថភាពរបស់ខ្លួននៅក្នុងការប្រើប្រាស់វិធីសាស្ត្រមិនគិតពន្ធគយបន្ថែមទៀត ដែលកាត់បន្ថយការនាំចូលបានយ៉ាងមានប្រសិទ្ធភាព (Nguyen et al. ២០១៩)។

## ៣.៣ ផលប៉ះពាល់តាមវិស័យ

ទោះបីជាយ៉ាងណាក៏ដោយ ផលប៉ះពាល់របស់ EVFTA មានការប្រែប្រួលទៅតាមវិស័យ។ Baker et al. (២០១៧) ប៉ាន់ស្មានថា ចំពោះវិស័យភាគច្រើន ការប្រែប្រួលនៃលទ្ធផលដោយប្រៀបធៀបនឹងខ្សែបន្ទាត់គោល នៅក្នុងប្រទេសវៀតណាម គឺស្ថិតនៅចន្លោះពី 0,៥% ទៅ ២% នៅក្នុងឆ្នាំជាក់លាក់ណាមួយ។ កំណើនលទ្ធផលមានសារសំខាន់បំផុតចំពោះឧស្សាហកម្មវាយនភ័ណ្ឌ សម្លៀកបំពាក់ និង ស្បែកជើង (ស្បែក) នៅពេលដែលពន្ធគយរបស់ EU ចំពោះសម្ភារទាំងនេះ ដែលមានចំនួន ១២%–១៧% ត្រូវបានលុបចោល។ ផលប៉ះពាល់ដ៏ធំបំផុតនឹងកើតឡើងនៅក្នុងឆ្នាំ២០២៥ ដែលគិតត្រឹមពេលនោះ ពន្ធគយភាគច្រើននឹងត្រូវបានលុបចោល។ មានការថយចុះចំពោះ "ដំណាំដទៃទៀត" ព្រៃឈើ ធនធាន ឧបករណ៍អេឡិចត្រូនិក ផលិតផលឈើ គ្រឿងម៉ាស៊ីន និង បរិក្ខារ និង ផលិតផលលោហធាតុ។ ការថយចុះនៃធាតុចេញតាមវិស័យជាក់លាក់ ភាគច្រើនមានចំនួនតិចជាង ៣%។ Baker et al. (2017) បានណែនាំផលប៉ះពាល់ផ្នែកពាណិជ្ជកម្មទូទៅ នៅក្នុងវិស័យមួយចំនួន អាចចំនួនច្រើនជាងវិស័យដទៃទៀត។ ការប្រែប្រួលខ្លាំងបំផុតអាចជាវិស័យសម្លៀកបំពាក់ (៤,៣ ប៊ីលានដុល្លារអាមេរិក) និង ស្បែកជើង (២,១ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ១៥% និង ៣៣% ចាប់ពីឆ្នាំ២០២៥ ដែលជាចំណុចគោលនៃវិស័យទាំងនេះ។ វិស័យដទៃទៀតដែលមានការប្រែប្រួលខ្លាំងនៅក្នុងការធ្វើពាណិជ្ជកម្ម រួមមានវិស័យវាយនភ័ណ្ឌ (៣៤៩ លានដុល្លារអាមេរិក) និង "ផលិតចំណីអាហារដទៃទៀត" (១៦៩ លានដុល្លារអាមេរិក)។ ស្របពេលជាមួយគ្នានោះ ពាណិជ្ជកម្មផ្នែកសេវាកម្មអាចមានការកើនឡើងយ៉ាងខ្លាំង ចំពោះសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និង សេវាកម្មផ្នែកអាជីវកម្មដែលមិនអាចចាត់ជាក្រុមនៅកន្លែងផ្សេងទៀតបាន (ពោលគឺ មិនរួមបញ្ចូលវិស័យហិរញ្ញវត្ថុ និង ធានារ៉ាប់រង)។

ទោះបីជាយ៉ាងណាក៏ដោយ ការនាំចេញរបស់ប្រទេសវៀតណាមទៅកាន់ EU ត្រូវបានរំពឹងទុកថានឹងមានការកើនឡើងយ៉ាងខ្លាំងចំពោះវិស័យមួយចំនួន (Baker et al. ២០១៧)។ ដោយមានសង្គតភាពនឹងរចនាបថនៃការធ្វើពាណិជ្ជកម្មទូទៅនៅគ្រប់វិស័យទាំងអស់ វិស័យដែលមានកំណើនការនាំចេញទៅកាន់EUខ្លាំងជាងគេបំផុតអាចជាវិស័យវាយនភ័ណ្ឌសម្លៀកបំពាក់និងស្បែកជើង។ លើសពីនេះទៀត ស្រូវ និង ផលិតផលត្រី អាចរួមចំណែកដល់ការនាំចេញទៅកាន់ EU

បានយ៉ាងខ្លាំងក្លាផងដែរ ទាំងនៅក្នុងចំនួនប្រៀបធៀប និង ចំនួនដាច់ខាត។ លំនាំកំណើននៃការនាំចេញនឹងមិនឋិតថេរគ្រប់ពេលនោះទេ ផ្ទុយមកវិញ កំណើនភាគច្រើន ត្រូវបានគេរំពឹងទុកថានឹងបង្គនៅក្នុងអំឡុងពេលប្រាំពីរឆ្នាំដំបូង នៅពេលដែលដំណាក់កាល EU ស្ថិតនៅក្នុងការធ្វើកំណែទម្រង់របស់ខ្លួន។

ពាក់ព័ន្ធនឹងការនាំចូលទូទៅ កំណើនដែលឆាប់រហ័សបំផុតអាចជាវិស័យវាយនភ័ណ្ឌដែលផ្តល់ធាតុចូលសម្រាប់ផលិតកម្មនាំចេញ (Baker et al., 2017)។ ស្រដៀងគ្នាដែរ កំណើនយ៉ាងខ្លាំងនៃការនាំចូលស្បែកសត្វ នឹងគាំទ្រដល់ការផលិតស្បែកជើង។ ការនាំចូលផលិតផលមួយចំនួនពី EU អាចមានការកើនឡើងយ៉ាងខ្លាំង ដោយសារតែពន្ធគយដ៏ខ្ពស់ដែលមានអត្ថិភាពនៅក្នុងប្រទេសវៀតណាម ត្រូវបានលុបចោល។ ពាក់ព័ន្ធនឹងភាគរយ កំណើនជាងគេខ្លាំងបំផុតនៅក្នុងការនាំចូល ត្រូវបានរំពឹងទុកថានឹងកើតឡើងចំពោះសាច់ជ្រូក និង សាច់មាន់ សាច់គោ ដំណាំដទៃទៀត ព្រៃឈើ ផលិតផលផលិតពីទឹកដោះគោ ចំណីអាហារកែច្នៃផ្សេងៗ និង ស្បែកសត្វ។ វិស័យសេវាកម្មដែលមានកំណើនការនាំចូលយ៉ាងខ្លាំង គឺវិស័យហិរញ្ញវត្ថុ និង ធានារ៉ាប់រង និង ការដឹកជញ្ជូនតាមផ្លូវអាកាស និង តាមសមុទ្រ។

## ៣.៤ ប្រាក់ចំណូល និង វិស័យសង្គម

Baker et al. (២០១៧) គឺជាការសិក្សាតែមួយគត់ ដែលចងក្រងឯកសារអំពីលទ្ធផលសន្មតថាតើ EVFTA មានផលជះលើប្រាក់ចំណូលរបស់អ្នកធ្វើការដើម្បីប្រាក់ឈ្នួល នៅតាមវិស័យ និង យេនឌ័រនានា យ៉ាងដូចម្តេចខ្លះ (តារាងទី១)។

អ្នកនិពន្ធចាត់ទុកប្រាក់ចំណូលដែលទទួលបានពីសកម្មភាពជាច្រើន (ប្រសិនបើមាន) ហាក់បីដូចជាប្រាក់ចំណូលទាំងនេះទទួលបានពីសកម្មភាពសេដ្ឋកិច្ចសំខាន់ៗដែរ ដែលចង្អុលបង្ហាញអំពីវិស័យ/មុខរបររបស់អ្នកធ្វើការផងដែរ។[11] ចំពោះវិស័យទាំងនោះ ដូចជា ឧបករណ៍អេឡិចត្រូនិក ផលិតផលឈើ គ្រឿងម៉ាស៊ីន និង បរិក្ខារ ដែលមិនអាចបែងចែកក្រុមនៅកន្លែងផ្សេងទៀតបាន (n.e.c.) និង លោហធាតុ ប្រាក់ចំណូលសម្រាប់ពលកម្ម ត្រូវបានរំពឹងទុកថានឹងមានការថយចុះធៀបនឹងខ្សែបន្ទាត់គោល សម្រាប់ទាំងបុរស និង ស្ត្រី។ ផលប៉ះពាល់អវិជ្ជមាន មានចំនួនតិចតួចបំផុតនៅក្នុងឆ្នាំ២០២០ ប្រហែលមកពីការចាប់ផ្តើមមានការប្តេជ្ញាចិត្តបន្តិចម្តងៗទៅតាមពេលវេលា។ ការថយចុះនៃប្រាក់ចំណូលរបស់ស្ត្រីអាចមានចំនួនច្រើនជាងប្រាក់ចំណូលរបស់បុរសនៅក្នុងវិស័យអេឡិចត្រូនិក និង គ្រឿងម៉ាស៊ីន និង បរិក្ខារនានា។

[11] អ្នកធ្វើការមួយចំនួនអាចមានសកម្មភាពសេដ្ឋកិច្ចលើសពីមួយ ហើយសកម្មភាពដែលទទួលបានប្រាក់ចំណូលច្រើនជាងគេត្រូវបានចាត់ទុកតាមផ្នែកស្ថិតិថាជាសកម្មភាពចម្បង។

## តារាងទី១៖ ការប្រែប្រួលនៃប្រាក់ចំណូលរបស់អ្នកធ្វើការដើម្បីប្រាក់ឈ្នួលតាមយេនឌ័រ និង តាមវិស័យ

(% EVFTA ធៀបនឹងចំណុចគោល)

| វិស័យ | ២០២០ | | ២០២៥ | | ២០៣០ | |
|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| ស្រូវ | ១,៤០ | ០,៤៨ | ២,៦៥ | ១,១៧ | ២,៤៤ | ១,០០ |
| បន្លែ ផ្លែឈើ សណ្ដែក | ២,៦៤ | ១,៦៩ | ៤,៦៨ | ៣,៨៥ | ៤,៦០ | ៣,៦៨ |
| ស្ករស | -០,៤២ | ៤,០៨ | ០,៩០ | ៥,៤៦ | ០,៦៧ | ៥,២២ |
| ដំណាំផ្សេងទៀត | ០,៩០ | ៤,០១ | ២,១០ | ៥,១៣ | ២,១២ | ៥,០៥ |
| ព្រៃឈើ | ១,៦២ | ១,៤៦ | ៣,១៤ | ៣,០៦ | ៣,១៧ | ៣,០៥ |
| នេសាទ | ៣,៦៣ | ១,៤៩ | ៦,៨១ | ៤,៦២ | ៦,៥៩ | ៤,២៤ |
| ធនធាន | ១,៧១ | ១,៥៦ | ៣,៣០ | ២,៩៦ | ៣,១២ | ២,៧៧ |
| ធនធានរ៉ែ | ២,៤៦ | ២,៦០ | ៤,៥៦ | ៤,៩២ | ៤,២០ | ៤,៥៨ |
| សាច់គោ និង សាច់កូនគោ | ៦,៦៤ | n.a. | ៧,០២ | n.a. | ៥,៨៨ | គ្មាន |
| សាច់ជ្រូក និង សាច់មាន់-ទា | ៣,១២ | ២,០៦ | ៥,៨៥ | ៣,៧៧ | ៥,៥៣ | ៣,៥១ |
| ផលិតផលចំណីអាហារ n.e.c. | ០,៧៦ | ០,៧៦ | ១,៨៦ | ១,៨៦ | ២,១០ | ២,១១ |
| ភេសជ្ជៈ និង ថ្នាំជក់ | ១,៨៦ | ១,៩០ | ៣,២០ | ៣,២៧ | ២,៨៦ | ២,៩៤ |
| វាយនភ័ណ្ឌ | ៣,៧១ | ៣,៧០ | ៧,៣១ | ៧,៣៤ | ៧,៣៣ | ៧,៣៦ |
| សម្លៀកបំពាក់ | ៥,០៥ | ៥,០៨ | ១៤,៤៨ | ១៤,៥៤ | ១៤,៨៨ | ១៤,៩៤ |
| ស្បែកសត្វ | ២២,៩២ | ២២,៩០ | ៣២,៦៣ | ៣២,៥៨ | ៣១,៥៦ | ៣១,៥៣ |
| ឧបករណ៍អេឡិចត្រូនិក | -០,៧១ | -០,៧៩ | -១,៣០ | -១,៤៣ | -១,១០ | -១,២២ |
| គេលសិលា ផលិតផលថ្មូងថ្ម | n.a. | ២,២៤ | n.a. | ៤,៥២ | n.a. | ៤,១២ |
| យានយន្ត និង បរិក្ខារដឹកជញ្ជូន | ១,២៤ | ១,២៨ | ២,៣១ | ២,៤៣ | ២,១៨ | ២,៣២ |
| ផលិតផលឈើ | -០,៨៦ | -០,៨៤ | -១,៦១ | -១,៦១ | -១,៤៣ | -១,៤២ |
| ផលិតផលផលិតពីក្រដាស ការបោះពុម្ពផ្សាយ | ១,៦៣ | ១,៥៧ | ២,៧៨ | ២,៦៦ | ២,៧៦ | ២,៦៤ |
| សារធាតុគីមី ជ័រ និង ប្លាស្ទិក | ១,៩១ | ១,៩០ | ២,៧៨ | ២,៧៧ | ២,៨៤ | ២,៨៣ |
| គ្រឿងម៉ាស៊ីន និង បរិក្ខារ n.e.c. | -០,៨៦ | -០,៩០ | -១,៥៨ | -១,៦៣ | -១,៣៧ | -១,៤៣ |
| ផលិតផលរ៉ែ n.e.c. | ១,៧២ | ១,៧០ | ៣,២២ | ៣,១៨ | ៣,១២ | ៣,០៨ |
| លោហធាតុ | -១,២៤ | -១,២២ | -២,២៨ | -២,២១ | -២,០០ | -១,៩៣ |
| ការផលិត | ០,៧៣ | ០,៧៦ | ០,៩៩ | ១,០២ | ១,១៦ | ១,១៨ |
| សេវាសាធារណៈ | ១,៧៥ | ១,៧៥ | ៣,២៤ | ៣,២២ | ៣,០៨ | ៣,០៧ |
| ការដឹកជញ្ជូនតាមសមុទ្រ | ២,០៦ | n.a. | ៦,៦១ | n.a. | ៣,៩៧ | n.a. |
| ការដឹកជញ្ជូនតាមផ្លូវអាកាស | ១,៦៥ | ០,៨៩ | ១១,៨៧ | ១០,៣២ | ៨,៤៩ | ៧,១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ការដឹកជញ្ជូនផ្សេងទៀត | ០,៧៩ | ០,៧១ | ៥,០៣ | ៤,៨៥ | ៣,៩១ | ៣,៧៥ |
| គមនាគមន៍ | ២,៣០ | ១,៩៦ | ៦,៩៦ | ៦,២៣ | ៦,៦៦ | ៥,៩៥ |
| ពាណិជ្ជកម្មលក់ដុំ និង លក់រាយ | ៣,១៧ | ៣,១៤ | ៥,៧១ | ៥,៦៧ | ៥,៣២ | ៥,២៨ |
| ហិរញ្ញវត្ថុ និង ធានារ៉ាប់រង | ១,៧៤ | ១,៦៤ | ៦,២៥ | ៦,០៧ | ៦,០៦ | ៥,៨៨ |
| ការលំហែ និង សេវាកម្មដទៃទៀត | ២,៣៥ | ២,៣០ | ៤,១៦ | ៤,០៦ | ៣,៧៩ | ៣,៧០ |
| សេវាកម្មពាណិជ្ជកម្ម n.e.c. | ៣,១១ | ៣,១០ | ៥,៩០ | ៥,៨៨ | ៥,៦៤ | ៥,៦២ |

ដោយមានសង្គតភាពនឹងកិច្ចពិភាក្សាអំពីផលប៉ះពាល់តាមវិស័យនៅខាងលើកំណើនប្រាក់ចំណូលច្រើនជាងគេ ដោយសារ EVFTA ត្រូវបានរំពឹងទុកសម្រាប់អ្នកធ្វើការទាំងបុរស និង ស្ត្រីនៅក្នុងវិស័យស្បែកសត្វ, វាយនភ័ណ្ឌ និង សម្លៀកបំពាក់, សេវាកម្មអាជីវកម្មដទៃទៀត និង វិស័យដឹកជញ្ជូនតាមផ្លូវអាកាស ដែលទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីការអនុវត្ត EVFTA។ វិស័យដែលស្ត្រីទទួលបានផលចំណេញជាប្រាក់ចំណូលច្រើនជាងបុរសនោះ រួមមាន ផលិតផលចំណីអាហារ n.e.c., ការផលិត, វាយនភ័ណ្ឌ, សម្លៀកបំពាក់, ភេសជ្ជៈ និង ថ្នាំជក់, យានយន្ត និង បរិក្ខារដឹកជញ្ជូន, ធនធានរ៉ែ, ដំណាំដទៃទៀត និង ស្ករស (រូបភាពទី ៤)។

**រូបភាពទី៤៖ វិស័យដែលមានអំណោយផលដល់ស្ត្រីដែលធ្វើការដើម្បីប្រាក់ឈ្នួលច្រើនជាង**

(ដោយប្រៀបធៀបនឹងបុរសដែលធ្វើការដើម្បីប្រាក់ឈ្នួល នៅក្នុងឆ្នាំ២០៣០ ការប្រែប្រួលនៃ EVFTA ជាភាគរយ ទល់នឹង ខ្សែបន្ទាត់គោល)




សម្គាល់៖ វិស័យដែលត្រូវបានរៀបរាប់ពីលើមកក្រោម រួមមាន៖ ផលិតផលចំណីអាហារដែលមិនបានបែងចែកក្រុមនៅកន្លែងផ្សេងទៀត ការផលិត វាយនភ័ណ្ឌ សម្លៀកបំពាក់ ភេសជ្ជៈ និង ថ្នាំជក់ យានយន្ត និង បរិក្ខារដឹកជញ្ជូន ធនធានរ៉ែ ដំណាំដទៃទៀត និង ស្ករស។

ប្រភព៖ Baker et al. (២០១៧).

Baker et al. (២០១៧) បង្ហាញថា អ្នកស្វែងរកប្រាក់ចំណូលនៅគ្រប់មុខរបរទាំងអស់ អាចទទួលបានអត្ថប្រយោជន៍ពីការអនុវត្ត EVFTA (តារាងទី ២)។ កម្មករនៅក្នុងវិស័យកសិកម្ម និងកម្មករគ្មានជំនាញ មានកំណើនប្រាក់ចំណូលខ្ពស់បំផុត ចំនួន ៥,៥% សម្រាប់កម្មករដែលជាបុរស និង ៤,៧%សម្រាប់កម្មករដែលជាស្ត្រីនៅក្នុងឆ្នាំ២០៣០(ស្របតាមEVFTAទល់នឹងខ្សែបន្ទាត់គោល)។ បុរសដែលជាមន្ត្រី និង អ្នកគ្រប់គ្រង កម្មករនៅក្នុងវិស័យកសិកម្ម និង កម្មករគ្មានជំនាញ ត្រូវបានរំពឹងទុកថានឹងទទួលបានអត្ថប្រយោជន៍ពី EVFTA ច្រើនជាងអ្នកធ្វើការដែលជាស្ត្រី។ ស្របពេលជាមួយគ្នានោះ ប្រាក់ចំណូលរបស់ស្ត្រីដែលបំពេញការងារជាអ្នកបច្ចេកទេស ស្មៀន និង អ្នកបម្រើសេវាកម្មនានា អាចកើនឡើងខ្ពស់ជាងសមភាគីរបស់ពួកគេ ដែលជាបុរស។

**តារាងទី២៖ ផលប៉ះពាល់នៃ EVFTA ចំពោះប្រាក់ចំណូលរបស់អ្នកធ្វើការដើម្បីប្រាក់ឈ្នួល តាមយេនឌ័ និង មុខរបស់ (%)**

| មុខរបរ | ២០២០ | | ២០២៥ | | ២០៣០ | |
|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| មន្ត្រី និង អ្នកគ្រប់គ្រង | ២,៣ | ១,៤ | ៥,១ | ៤,១ | ៤,៨ | ៣,៦ |
| អ្នកបច្ចេកទេស | ២,៤ | ៣,៦ | ៤,៨ | ៦,៥ | ៤,៦ | ៦,៤ |
| ស្មៀន | ១,៩ | ៣,៣ | ៤,៥ | ៦,៣ | ៤,៤ | ៦,២ |
| បុគ្គលិកបម្រើសេវាកម្ម | ២,៥ | ២,៦ | ៤,៨ | ៥,៣ | ៤,៧ | ៥,២ |
| អ្នកធ្វើការក្នុងវិស័យកសិកម្ម និង កម្មករគ្មានជំនាញ | ២,៩ | ២,៥ | ៦,០ | ៤,៩ | ៥,៥ | ៤,៧ |

ប្រភព៖ Baker et al. (២០១៧).

Baker et al. (២០១៧) ក៏បានចងក្រងឯកសារអំពីផលប៉ះពាល់ជាសក្តានុពលរបស់ EVFTA ចំពោះប្រាក់ចំណូលរបស់ជនដែលធ្វើការឲ្យខ្លួនឯង តាមវិស័យ និង តាមយេនឌ័រ ផងដែរ។ ដោយប្រៀបធៀបនឹងអ្នកធ្វើការដើម្បីប្រាក់ឈ្នួល ជនដែលធ្វើការឲ្យខ្លួនឯង ត្រូវបានរំពឹងទុកថា មានកំណើនប្រាក់ចំណូលទាបជាង នៅក្នុងសកម្មភាពកសិកម្ម និង ការរុករករ៉ែដទៃទៀត និង មានកំណើនប្រាក់ខ្ពស់នៅក្នុងវិស័យផ្សេងៗទៀត។ វិស័យដែលស្ត្រីធ្វើការឲ្យខ្លួនឯងមានកំណើនប្រាក់ចំណូលខ្ពស់ជាងបុរស រួមមាន ផលិតផលរ៉ែ n.e.c., ផលិតផលចំណីអាហារ n.e.c., ការផលិត, ផលិតផលធ្វើពីក្រដាស និង ការបោះពុម្ពផ្សាយ និង ហិរញ្ញវត្ថុ និង ការធានារ៉ាប់រង (រូបភាពទី ៥)។

**រូបភាពទី៥៖ វិស័យដែលមានអំណោយផលដល់ស្ត្រីដែលធ្វើការឲ្យខ្លួនឯងច្រើនជាង**

(ដោយប្រៀបធៀបនឹងបុរសដែលធ្វើការឲ្យខ្លួនឯង នៅក្នុងឆ្នាំ២០៣០
% នៃការប្រែប្រួលនៃ EVFTA ទល់នឹង ខ្សែបន្ទាត់គោល)




សម្គាល់៖ វិស័យដែលត្រូវបានរៀបរាប់ពីលើមកក្រោម រួមមាន៖ ផលិតផលរ៉ែដែលមិនបានបែងចែកក្រុមនៅកន្លែងផ្សេងទៀត ផលិតផលចំណីអាហារដែលមិនបានបែងចែកក្រុមនៅកន្លែងផ្សេងទៀត ការផលិត ផលិតផលធ្វើពីក្រដាស ការបោះពុម្ពផ្សាយ ហិរញ្ញវត្ថុ និង ធានារ៉ាប់រង។
ប្រភព៖ Baker et al. (២០១៧).

## ៤. មេរៀនសំខាន់ដែលទទួលបានពីដំណើរការ EVFTA

ការចូលរួមរបស់ប្រទេសវៀតណាមនៅក្នុងដំណើរការ EVFTA បង្ហាញអំពីមេរៀនសំខាន់ៗមួយចំនួន។

*ទីមួយ កិច្ចព្រមព្រៀងពាណិជ្ជកម្មខ្នាតធំណាមួយ ចាំបាច់ត្រូវតែមានលក្ខណៈសមស្របនឹងយុទ្ធសាស្ត្រធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងប្រទេសដែលទូលំទូលាយជាងនោះ។*

EVFTAមិនមែនជាការធ្វើសមាហរណកម្មតែមួយគត់របស់ប្រទេសវៀតណាមនោះទេ។ជាក់ស្តែង ចាប់តាំងពីមាន Doi Moi (ការកែលម្អ) នៅឆ្នាំ១៩៨៦ មក ប្រទេសវៀតណាមបានបើកចំហរសេដ្ឋកិច្ចរបស់ខ្លួនទៅកាន់ពាណិជ្ជកម្ម និង ការវិនិយោគបរទេសសន្សឹមៗ។ ដំណើរការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសវៀតណាមចាប់តាំងពីពេលនោះមកមានព្រឹត្តិការណ៍សំខាន់ៗចំនួនបួន។

ជាដំបូង ប្រទេសវៀតណាមបានចូលរួមនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅក្នុងឆ្នាំ១៩៩៥ និង តំបន់ពាណិជ្ជកម្មសេរីអាស៊ាន នៅក្នុងឆ្នាំ១៩៩៦។ គិតត្រឹមខែឧសភា ឆ្នាំ២០២០ ប្រទេសវៀតណាមបានក្លាយជាហត្ថលេខីនៃ FTAs ជាច្រើន ដែលស្ថិតនៅក្រោមក្របខណ្ឌអាស៊ានបូក។ នៅចុងឆ្នាំ២០១៥ ប្រទេសវៀតណាមបានចូលរួមនៅក្នុងសហគមន៍

អាស៊ាន។ គិតត្រឹមខែឧសភា ឆ្នាំ២០២០ ប្រទេសនេះកំពុងតែធ្វើការជាមួយអាស៊ាន និង ដៃគូរបស់ខ្លួនដើម្បីធ្វើសេចក្តីសម្រេចលើភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយនៅក្នុងតំបន់ រវាង (RCEP) អាស៊ាន ប្រទេសចិន សាធារណរដ្ឋកូរ៉េ (ក្រោយមកហៅថា ប្រទេសកូរ៉េ) ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី ប្រទេសនូវែលហ្សេឡង់ និង ប្រទេសឥណ្ឌា។

ទីពីរ ប្រទេសវៀតណាមបានចរចា និង ចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសវៀតណាម សហរដ្ឋអាមេរិក (US) នៅក្នុងឆ្នាំ២០០០ ដែលធ្វើឲ្យប្រទេសវៀតណាមត្រូវត្រៀមខ្លួនសម្រាប់ការធ្វើសមាហរណកម្មដោយផ្អែកលើ FTA នៅក្នុងតំបន់ និង ដំណើរការរបស់ WTO និង បានផ្តល់ជូនប្រទេសវៀតណាមនូវលទ្ធភាពក្នុងការចូលទៅកាន់សហរដ្ឋអាមេរិក ដែលជាទីផ្សារនាំចេញធំបំផុតរបស់ខ្លួន បានកាន់តែល្អប្រសើរឡើង ដែលបង្កប់អត្ថន័យអំពីភាពប្រកួតប្រជែងដែលមានភាពល្អប្រសើរឡើង ធៀបនឹងប្រទេសនាំចេញសំខាន់ៗដទៃទៀត។

ទីបី ប្រទេសវៀតណាមបានក្លាយជាសមាជិករបស់ WTO នៅខែមករា ឆ្នាំ២០០៧។ សម្ពាធដ៏ធំបំផុតនៅក្រោម WTO គឺទាក់ទងនឹងកំណែទម្រង់ស្ថាប័ន និង វិស័យសេវាកម្ម (CIEM ឆ្នាំ២០១៣)។ ដើម្បីបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះ WTO ប្រទេសវៀតណាមត្រូវធ្វើវិសោធនកម្ម ឬ ប្រកាសឲ្យប្រើប្រាស់ច្បាប់ បញ្ញត្តិ និង ក្រឹត្យជាច្រើន ទាក់ទងនឹងបទប្បញ្ញត្តិរបស់ស្ថាប័ននៅក្នុងប្រទេស។

ទីបួន ចាប់តាំងពីឆ្នាំ២០០៨ មក ប្រទេសវៀតណាមបានផ្តោតលើ FTAs ទ្វេភាគី និង ពហុភាគី។ សូម្បីតែការចូលជាសមាជិករបស់ WTO ក៏មិនមែនជាចំណុចបញ្ចប់នៃដំណើរការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសនេះដែរ។ ប្រទេសវៀតណាមបានធ្វើការចរចា និង/ឬ ចុះហត្ថលេខានៅលើនៅក្នុងចំណោមកិច្ចព្រមព្រៀងដទៃទៀត កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចជាមួយប្រទេសជប៉ុន និង FTAs ជាមួយ EU ប្រទេសឈីលី ប្រទេសកូរ៉េ និង សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី។ នៅខណៈពេលដែល TPP ដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ២០១៦ មិនអាចដំណើរការបាន ដោយសារការដកខ្លួនចេញរបស់ US នោះ ប្រទេសវៀតណាមបានចុះហត្ថលេខាលើ CPTPP នៅក្នុងខែមីនា ឆ្នាំ២០១៨ និង បានផ្តល់សច្ចាប័ននៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។

ដំណើរការ និង ការប៉ុនប៉ងធ្វើសមាហរណកម្មដូចខាងលើ បានធ្វើឲ្យប្រទេសវៀតណាមធ្វើការសម្របខ្លួនសន្សឹមៗទៅនឹងប្រព័ន្ធពាណិជ្ជកម្ម និង ការវិនិយោគដែលផ្អែកលើច្បាប់ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ។ ដោយសារតែមូលហេតុទាំងនេះ ការចូលរួមនៅក្នុង EVFTA បង្ហាញអំពីការប៉ុនប៉ងដោយឯកឯង ដែលស្របគ្នានឹងដំណើរការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម។

ប្រសិនបើគ្មានដំណើរការរយៈពេលវែង និង មានសង្គតភាពបែបនោះទេ វាអាចពិបាកនឹងស្រមើស្រមៃអំពីការចូលរួមរបស់ប្រទេសវៀតណាមនៅក្នុងFTAក៏ដូចជាEVFTAដែលមានគុណភាពខ្ពស់បែបនេះ។

ដូចបានកត់សម្គាល់ខាងលើ អត្ថប្រយោជន៍បន្ថែមដែលបានទទួលពីការសម្របសម្រួល TPP និង ការចរចា EVFTA ដែលកើតឡើងក្នុងពេលដំណាលគ្នា មានសារសំខាន់នៅក្នុងការជួយបញ្ចុះបញ្ចូលភាគីពាក់ព័ន្ធនៅក្នុងប្រទេស។

ស្របពេលជាមួយគ្នានោះ ការចូលរួមនៅក្នុង FTA ជាមួយ EU មានសង្គតភាពនឹងសំណើខុសៗគ្នានៅក្នុងឯកសារ (ឧ. Truong et al. [២០១១] និង CIEM [២០១៣]) ដែលថាការជ្រើសរើសដៃគូត្រូវតែផ្អែកលើលក្ខណវិនិច្ឆ័យនានា ដូចជា អត្ថប្រយោជន៍ជាយុទ្ធសាស្ត្រនយោបាយទូទៅ និង អត្ថប្រយោជន៍សេដ្ឋកិច្ចជាតិ។

*ទីពីរ សមាហរណកម្មសេដ្ឋកិច្ចដែលផ្អែកលើ FTA ចាំបាច់ត្រូវតែរួមចំណែកដល់ការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រនៅក្នុងវិស័យសេដ្ឋកិច្ច។*

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ទំនាក់ទំនងរវាងប្រទេសវៀតណាម និង EU មានសភាពកាន់តែរឹងមាំឡើង និង កាន់តែមានសារសំខាន់។ ប្រទេសវៀតណាម និង EU បានបង្កើតទំនាក់ទំនងការទូតជាផ្លូវការនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩០។ មានតែនៅក្នុងឆ្នាំ១៩៩៥ ប៉ុណ្ណោះ ដែលភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការលើក្របខណ្ឌមួយ ហើយនៅឆ្នាំដដែលនោះ ប្រទេសវៀតណាមបានចូលរួមជាមួយអាស៊ាន និងមានរយៈពេលមួយឆ្នាំ បន្ទាប់ពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចដោយ US ទៅលើប្រទេសវៀតណាម ត្រូវបានលុបចោល។ នៅឆ្នាំ១៩៩៦ ការតំណាងផ្នែកការទូតរបស់គណៈកម្មការអឺរ៉ុបត្រូវបានបង្កើតឡើងនៅទីក្រុងហាណូយ។ នៅឆ្នាំ២០០៤ កិច្ចប្រជុំកំពូលលើកដំបូងរវាងប្រទេសវៀតណាម និង EU ត្រូវបានធ្វើឡើងនៅទីក្រុងហាណូយ។ នៅឆ្នាំ២០០៥ ប្រទេសវៀតណាមបានអនុម័តផែនការមេ និង ផែនការសកម្មភាពសម្រាប់អភិវឌ្ឍទំនាក់ទំនងជាមួយ EU ដើម្បីឆ្ពោះទៅកាន់ឆ្នាំ២០១០ និង ការតម្រង់ទិសឆ្ពោះទៅកាន់ឆ្នាំ២០១៥។ នៅឆ្នាំ២០០៧ ប្រទេសវៀតណាម និង EU បានប្រកាសថា ពួកគេនឹងចាប់ផ្តើមធ្វើការចរចាអំពីភាពជាដៃគូគ្រប់ជ្រុងជ្រោយ និង កិច្ចព្រមព្រៀងសហប្រតិបត្តិការ (PCA)។ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ PCA ត្រូវបានចាប់ផ្តើមដោយនាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាម និង ប្រធានគណៈកម្មការអឺរ៉ុប។ PCA ត្រូវបានចុះហត្ថលេខាជាផ្លូវការនៅឆ្នាំ២០១២។

អាស្រ័យហេតុនេះ EVFTA រួមចំណែកដល់ការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសវៀតណាម និង EU។ EU គឺជាទីផ្សារធំបំផុតទីពីរសម្រាប់ប្រទេសវៀតណាម អស់រយៈពេល

ជាច្រើនឆ្នាំមកហើយ ដែលរ៉ាប់រងប្រហែល ២០% នៃការនាំចេញរបស់ប្រទេសវៀតណាម។ ការសិក្សាខុសៗគ្នា (ឱ. Truong et al. [២០១១]; Nguyen et al. [២០១៤]; Nguyen et al. [២០១៧] និង Dinh et al. [២០២០]) បង្ហាញថាប្រទេសវៀតណាម និង EU សម្រេចបាននូវការបំពេញឲ្យគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងពាណិជ្ជកម្ម នៅកម្រិតខ្ពស់ និង មានការកើនឡើង។

EU ក៏មានចំណាត់ថ្នាក់ខ្ពស់ជាង ពាក់ព័ន្ធនឹងបច្ចេកវិទ្យាផងដែរ ដែលអាចផ្គូរផ្គង់តម្រូវការរបស់ប្រទេសវៀតណាមនៅក្នុងការធ្វើនវានុវត្តន៍ និង ការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាពីភាគីបរទេសដែលពាក់ព័ន្ធ។

*ទីបី តម្រូវការ FTA ថ្មីៗ ចាំបាច់ត្រូវតែប្រកាន់ខ្ជាប់នូវនិយាមអន្តរជាតិថ្មីៗ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព។*

ចាប់តាំងពីពេលបញ្ចប់វិបត្តិហិរញ្ញវត្ថុសកលមក សេដ្ឋកិច្ចសកលបានឆ្លងកាត់ដំណើរការនៃការងើបឡើងវិញយឺតៗ។ រចនាបថនៃកំណើន មិនសូវអាចទស្សទាយន៍ទុកមុនបាននោះទេ និង កាន់តែមិនស្មើភាពគ្នានៅក្នុងក្រុមសេដ្ឋកិច្ចខុសៗគ្នា។ គេអាចមើលឃើញកាន់តែច្បាស់ថា ការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដើម្បីសម្រេចបាននូវកំណើន ស្ទើរតែគ្មានប្រសិទ្ធភាពនោះទេ នៅក្នុងផ្នែកខុសៗគ្នានៅលើពិភពលោក រួមបញ្ចូលទាំងនៅ EU និង ប្រទេសវៀតណាមផងដែរ។ ចន្លោះទំនេរផ្នែកសារពើពន្ធប្រែជាកាន់តែចង្អៀត បន្ទាប់ពីបានអនុវត្តកត្តាជំរុញការប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចអស់រយៈពេលយ៉ាងយូរ។ នៅក្នុងបរិបទនេះ បានលេចឡើងនូវតម្រូវការនៃកិច្ចខិតខំប្រឹងប្រែងនៅក្នុងការកំណត់ប្រភពនៃកំណើនដែលមានភាពទូលំទូលាយជាងនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនោះគួរតែកំណត់គោលដៅអនុវត្ត មិនត្រឹមតែចំពោះកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាពតែប៉ុណ្ណោះទេ ប៉ុន្តែ ក៏គួរតែកំណត់គោលដៅអនុវត្តចំពោះការចូលរួមកាន់តែទូលំទូលាយពីសំណាក់ក្រុមប្រជាជនខុសៗគ្នា ដូចជា ស្ត្រី ប្រជាជនវ័យក្មេង មនុស្សវ័យចំណាស់ និង ជនជាតិភាគតិចផងដែរ។ ចំណុចដែលសំខាន់ជាងនេះទៀតនោះ កិច្ចខិតខំប្រឹងប្រែងទាំងនោះគួរតែរួមបញ្ចូលកិច្ចសហការអន្តរជាតិដើម្បីជួយសម្រួលដល់ការចែករំលែកបទពិសោធន៍ និង លើកកម្ពស់សកម្មភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

EVFTA ជួយលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលនៅក្នុងនោះ EVFTA បានចែងអំពីជំពូក និង ការប្តេជ្ញាចិត្តខុសៗគ្នាដែលទាក់ទងនឹងពាណិជ្ជកម្មនិង ចីរភាព ថាមពលកកើតឡើងវិញ និង សិទ្ធិការងារ។ល។ បញ្ហាមួយចំនួន ក្នុងចំណោមបញ្ហាទាំងនេះ នៅតែជាបញ្ហាថ្មី និង មិនទាន់មានការយល់ដឹងយ៉ាងពេញលេញពីសំណាក់ប្រទេសវៀតណាមនៅឡើយទេ។

ឧទាហរណ៍៖ បញ្ញត្តិមួយចំនួនដែលស្ថិតនៅក្រោមជំពូកស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍប្រកបដោយចីរភាព ប្រហែលជាមិនត្រូវបានបកស្រាយដូចៗគ្នាដោយប្រទេសវៀតណាម និង EU នោះទេ។ ទោះបីជា EVFTA ត្រូវបានចុះហត្ថលេខា ក្រោយ CPTPP ក៏ដោយ ក៏គំនិតនៃការបង្កើតរបាយការណ៍ស្តីពីការប៉ាន់ប្រមាណអំពីផលប៉ះពាល់ប្រកបដោយចីរភាព របស់ FTA ត្រូវបានណែនាំឲ្យអនុវត្ត នៅក្រោមដំណើរការ EVFTA ដូចដែលបានឆ្លុះបញ្ចាំងដោយរបាយការណ៍របស់ Baker et al. (២០១៤) និង Baker et al. (២០១៧)។ នោះគឺ ការប៉ាន់ប្រមាណអំពីផលប៉ះពាល់របស់ EVFTA មិនត្រូវបានរឹតត្បិតចំពោះទិដ្ឋភាពសេដ្ឋកិច្ច និង ពាណិជ្ជកម្មបន្តទៀតទេ ប៉ុន្តែវារួមបញ្ចូលវិស័យផ្សេងៗទៀតដែលត្រូវបានជ្រើសរើស ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព ដូចជា ការបែងចែកប្រាក់ចំណូល និង បរិស្ថាន។ល។ នៅខណៈពេលដែលលក្ខខណ្ឌតម្រូវថ្មីៗ (និងតម្រូវការដែលបានដឹង) ទាំងនេះ អាចបង្កឲ្យមានការកែប្រែបន្ទុកចំណាយ និង ធ្វើឲ្យភាពប្រកួតប្រជែងក្នុងការនាំចេញរបស់ប្រទេសវៀតណាមចុះទន់ខ្សោយ យ៉ាងហោចណាស់ក៏នៅក្នុងរយៈពេលខ្លីទៅមធ្យមដែរ ពួកគេអាចគាំទ្រប្រទេសឲ្យបន្តការប្តេជ្ញាចិត្តចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០។ ទោះបីជាយ៉ាងណាក៏ដោយ EVFTA មិនមែនគ្រាន់តែរួមបញ្ចូលការប្តេជ្ញាចិត្តរបស់ប្រទេសវៀតណាមនោះទេ។ កិច្ចព្រមព្រៀងនេះក៏រួមបញ្ចូលបញ្ញត្តិស្តីពីកិច្ចសហប្រតិបត្តិការ និង ការកសាងសមត្ថភាពផងដែរ ដែលប្រទេសវៀតណាមអាចសម្រេចចិត្តប្រើប្រាស់បញ្ញត្តិទាំងនេះនៅក្នុងការអនុវត្តការអភិវឌ្ឍប្រកបដោយចីរភាពរបស់ខ្លួន។

*ទីបួន ចាំបាច់ត្រូវតែមានការថែរក្សាគោលការណ៍សំខាន់ៗ របស់ EVFTA ដែលមានគុណភាពខ្ពស់។*

ការលើកកម្ពស់ FTA ដែលមានគុណភាពខ្ពស់ ដូចជា EVFTA ជាដើម គឺមិនងាយស្រួលនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមបទពិសោធន៍ កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសវៀតណាម (និង EU) នៅក្នុងដំណើរការចរចា និង ផ្តល់សច្ចាប័ន មិនអាចបកស្រាយបានយ៉ាងពេញលេញនោះទេ។ ពេលវេលាចាប់ពីមានសេចក្តីសម្រេចលើការចរចា (ខែធ្នូ ឆ្នាំ២០១៥) រហូតដល់ការផ្តល់សច្ចាប័នដោយ EU (ខែកុម្ភៈ–មីនា ឆ្នាំ២០២០) និង ការបំបែកកិច្ចព្រមព្រៀងទៅជា EVFTA និង EVIPA មិនអាចពណ៌នាយ៉ាងពេញលេញអំពីបញ្ហាប្រឈមនានាដែលជួបប្រទះដោយភាគីទាំងពីរនៅក្នុងការផ្សព្វផ្សាយអំពីការធ្វើជំនួញរួមបញ្ចូលទាំង គុណភាពដ៏ខ្ពស់របស់ខ្លួនបាននោះទេ។ ស្របពេលជាមួយគ្នានោះ កត្តាទាំងនោះចែងអំពីភាពងាយបត់បែនដែលចាំបាច់សម្រាប់ដំណើរការរបស់ EVFTA។ នៅក្នុងករណីនេះ CPTPP ដែលមានគុណភាពខ្ពស់អាចផ្តល់ចំណុចគោលមួយ និង ចែករំលែកបន្ទុកក្នុងការទទួលបានការព្រមព្រៀងជាឯកច្ឆ័ន្ទនៅក្នុងប្រទេសវៀតណាម សម្រាប់ដំណើរការ EVFTA។ ទោះបីជាយ៉ាងណាក៏ដោយ មនុស្សម្នាក់មិនអាចមាក់ងាយការប្រឹងប្រែង និងការ

ប្តេជ្ញាចិត្តរបស់ភាគីទាំងពីរនៅក្នុងការលើកម្ពស់កិច្ចព្រមព្រៀងដែមានគុណភាពខ្ពស់បាននោះទេ។

*ទីប្រាំ FTAs ដែលមានគុណភាពខ្ពស់ត្រូវតែមានសង្គតភាពនឹងកំណែទម្រង់នៅក្នុងប្រទេស។*

ដូចដែលបានកត់សម្គាល់នៅខាងលើ ដំណើរការធ្វើសមាហរណកម្មមានអន្តរកម្មយ៉ាងជិតស្និទ្ធនឹងកំណែទម្រង់នៅក្នុងប្រទេស ជាពិសេស ពាក់ព័ន្ធនឹងស្ថាប័ន ដើម្បីសេដ្ឋកិច្ចទីផ្សារ។ យោងតាមការសិក្សាខុសៗគ្នា រយៈពេលនៃកិច្ចខិតខំប្រឹងប្រែងដែលមានអត្ថន័យជាងនេះ នៅក្នុងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការវិនិយោគ (ពោលគឺ ឆ្នាំ១៩៨៩–១៩៩៦ ឆ្នាំ២០០០–២០០៧ និង ឆ្នាំ២០១៤–២០១៩) ក៏ជារយៈពេលដែលមានកំណែទម្រង់គ្រប់ជ្រុងជ្រោយនៃស្ថាប័នសេដ្ឋកិច្ចនៅក្នុងប្រទេសផងដែរ។ ជាផ្នែកមួយនៃការប៉ុនប៉ងធ្វើសមាហរណកម្មរបស់ប្រទេសវៀតណាម EVFTA ក៏រួមបញ្ចូលសង្គតភាពនៃកំណែទម្រង់នៅក្នុងប្រទេសវៀតណាមផងដែរ។

ខ្លឹមសារស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដូចបានបកស្រាយនៅផ្នែកមុនៗ អាចគាំទ្រដល់ប្រទេសវៀតណាមនៅក្នុងការអនុវត្តតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅឆ្នាំ២០៣០។ លើសពីនេះទៀត EVFTA គ្របដណ្តប់លើវិន័យរបស់សហគ្រាសដែលកាន់កាប់ដោយរដ្ឋ (SOEs) ហើយចំណុចនេះបំពេញបន្ថែមលើកំណែទម្រង់ និង ការកែប្រែរចនាសម្ព័ន្ធឡើងវិញរបស់សហគ្រាសដែលកាន់កាប់ដោយរដ្ឋនៅក្នុងប្រទេសវៀតណាម។ ចំណុចមួយទៀត ពាក់ព័ន្ធនឹងគោលនយោបាយប្រកួតប្រជែង ដែលប្រទេសវៀតណាមបាន និង កំពុងតែពង្រឹងស្ថាប័ន និង ទម្លាប់អនុវត្តរបស់ខ្លួន។

កាលពីទសវត្សរ៍មុន ប្រទេសវៀតណាមបានពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចក្នុងប្រទេស និង ការបង្កើតគោលនយោបាយបានយ៉ាងខ្លាំងក្លា។ គេនៅតែបន្តប្រកាន់ខ្ជាប់នូវកម្លាំងជំរុញសម្រាប់កំណែទម្រង់នានានៅក្នុងប្រទេស យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ២០១៤ មកម្ល៉េះ ដោយមានសេចក្តីផ្តើមនៃសេចក្តីសម្រេចលេខ ១៩ (ក្នុងអំឡុងឆ្នាំ២០១៤–២០១៨) និង សេចក្តីសម្រេចទី ០២ (ក្នុងអំឡុងឆ្នាំ២០១៩–២០២០) ស្តីពីកំណែទម្រង់មជ្ឈដ្ឋានធ្វើអាជីវកម្ម និង ការប្រកួតប្រជែងថ្នាក់ជាតិ។

ជាពិសេស ការកាត់បន្ថយលក្ខខណ្ឌសម្រាប់ការចូលទីផ្សារ និង បន្ទុកផ្នែកនិយ័តកម្មដែលមិនចាំបាច់លើការធ្វើអាជីវកម្ម ក៏បានរួមចំណែកដល់ការធ្វើឲ្យវិធីសាស្ត្រមិនគិតពន្ធគយមានប្រសិទ្ធភាពផងដែរ (Artuso និង Nguyen ២០១៩)។ សំណួរដែលកើតឡើងដោយឯកឯងនៅក្នុងបរិបទនេះ គឺថាតើប្រទេសវៀតណាមអាចលើកកម្ពស់កំណែទម្រង់ដោយខ្លួនឯងបានដែរឬទេ និងថាតើទ្រឹស្តីដែលថា FTAs ជាសម្ពាធខាងក្រៅចំពោះកំណែទម្រង់នៅក្នុងប្រទេសនៅតែអនុវត្តចំពោះប្រទេសវៀតណាម ដែរឬទេ។ ចម្លើយប្រហែលជាមានទាំង អាច និង មិនអាច។ គឺថាប្រទេសវៀតណាម យោងតាមសមត្ថភាពរបស់ខ្លួន អាចប្រើប្រាស់ឧត្តម្ភានុវត្តសម្រាប់ការធ្វើ

កំណែទម្រង់សេដ្ឋកិច្ច និង ដំណើរការបង្កើតគោលនយោបាយនៅក្នុងប្រទេស ប៉ុន្តែវាក៏ត្រូវការ EVFTA ដែលមានគុណភាពខ្ពស់ដើម្បីធ្វើឲ្យកំណែទម្រង់មានលក្ខណៈសមស្របនឹងឧត្តម្មានុវត្តជាអន្តរជាតិផងដែរ។

ជាចុងក្រោយ ការស្វែងរកមតិគាំទ្រសម្រាប់ EVFTA បានអមមកជាមួយនូវយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដ៏សមស្របមួយ ដែលជួយធ្វើឲ្យការព្រមព្រៀងជាឯកច្ឆ័ន្ទនៅក្នុងសង្គមមានភាពរឹងមាំ។

ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ រួមទាំងសហគមន៍អាជីវកម្ម និង វិនិយោគិនបរទេសផងដែរនោះ គឺជាសមាសធាតុដ៏សំខាន់មួយនៃកំណែទម្រង់សេដ្ឋកិច្ចសំខាន់ៗ។ ទោះបីជាមានអភិក្រមដែលអនុវត្តពីថ្នាក់លើមកថ្នាក់ក្រោម ចំពោះការរៀបចំកំណែទម្រង់នានាកាលពីទសវត្សរ៍មុនៗក៏ដោយ ក៏នាពេលថ្មីៗនេះ ប្រទេសវៀតណាមបានប្រឹងប្រែងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធកាន់តែច្រើន ដែលជាផ្នែកមួយនៃដំណើរការអនុវត្តការប្តេជ្ញាចិត្តចំពោះសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់ និង កំណែទម្រង់នៅក្នុងប្រទេសរបស់ខ្លួន។ វិសាលភាពនៃការពិគ្រោះយោបល់ត្រូវបានពង្រីកបន្តិចម្តងៗ។ សិក្ខាសាលា និង កិច្ចសន្ទនាខុសៗគ្នាត្រូវបានរៀបចំឡើង ដើម្បីពិគ្រោះយោបល់ជាមួយសហគមន៍អាជីវកម្ម អំពីផែនទីបង្ហាញផ្លូវនៃការធ្វើសមាហរណកម្មខុសៗគ្នា និង បញ្ហាដែលពាក់ព័ន្ធដទៃទៀត។ ទម្លាប់អនុវត្តនៃការពិគ្រោះយោបល់នេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១០ បន្ទាប់ពីនាយករដ្ឋមន្ត្រីបានពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលមានអំណាចតាមផ្លូវច្បាប់ នៅពេលរៀបចំកំណែទម្រង់សេដ្ឋកិច្ចសំខាន់ៗ។

ពាក់ព័ន្ធនឹង EVFTA ទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះបញ្ហាសំខាន់ៗ ដូចជា ការកាត់បន្ថយពន្ធគយ វិធានរបស់ប្រទេសប្រភពដើម ការអភិវឌ្ឍប្រកបដោយចីរភាព និង កម្មសិទ្ធិបញ្ញា។ល។ ត្រូវបានប្រមូលផ្តុំ។ កិច្ចប្រជុំពិគ្រោះយោបល់ខុសៗគ្នា ស្តីពី EVFTA បានរួមចំណែកដល់ការបង្កើនការយល់ដឹងអំពីសហគមន៍សេដ្ឋកិច្ចអាស៊ាន មុនពេលមានការប្រែប្រួលជាសក្តានុពលណាមួយ។ ចំណុចទាំងនេះមានសង្គតភាពនឹងសេចក្តីណែនាំរបស់ Politburo និង រដ្ឋាភិបាល ស្តីពីការបង្កើនការយល់ដឹងអំពីដំណើរការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ ប្រទេសវៀតណាមមិនបានបដិសេធមិនចូលរួមនៅក្នុងការសន្ទនាដោយស្មោះត្រង់ និង ដោយបើកចំហរអំពីបញ្ហារសើបនោះទេ ដូចជា យន្តការដោះស្រាយវិវាទរវាងវិនិយោគិន-រដ្ឋ និង កម្មសិទ្ធិបញ្ញា។ល។ នៅក្នុងករណីនេះ ផលវិបាកចំពោះប្រាក់ចំណូលរបស់គ្រួសារ និង ប្រាក់ចំណូលតាមយេនឌ័រ ដែលបានចងក្រងជាឯកសារអាចមានសារប្រយោជន៍។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនោះ EVFTA (ព្រមទាំង CPTPP ផងដែរ) មិនបានទទួលមតិយោបល់អវិជ្ជមាននៅក្នុងប្រទេសវៀតណាម នៅក្នុងកម្រិតដែលអាចផ្លាស់ប្តូរទិសដៅនៃការដំណើរការនោះទេ។

## ៥. ចំណាប់អារម្មណ៍បញ្ចប់

ជំពូកនេះមានបំណងត្រួតពិនិត្យឡើងវិញលើដំណើរការ និង ផលប៉ះពាល់របស់ EVFTA ចំពោះសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ព្រមទាំង មេរៀនសំខាន់ៗដែលទទួលបានពីដំណើរការ EVFTA ផងដែរ។ បន្ទាប់ពីបានធ្វើការចរចាអស់រយៈពេលជាច្រើនឆ្នាំ និង កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ដំណើរការផ្តល់សច្ចាប័នដល់ EVFTA ត្រូវបានបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅដើមខែសីហា ឆ្នាំ២០២០ នៅខណៈពេលដែល EVIPA នឹងចូលជាធរមានបន្ទាប់ពីមានការផ្តល់សច្ចាប័នដោយសភានៃរដ្ឋសមាជិករបស់ EU ទាំងអស់។

ការចរចាអំពី EVFTA ត្រូវបានធ្វើឡើងដោយស្របនឹងការចរចាអំពី TPP ដែលបានជួយគ្រប់គ្រងការព្រមព្រៀងជាឯកច្ឆន្ទនៅក្នុងប្រទេស និង ថែរក្សាកិច្ចព្រមព្រៀងដែលមានគុណភាពខ្ពស់។

EVFTA ត្រូវបានគេរំពឹងទុកថា នឹងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ពាក់ព័ន្ធនឹង GDP និង ពាណិជ្ជកម្ម ទោះបីជាលទ្ធផលដោយប្រយោលមួយចំនួននឹងកើតឡើងជាសក្តានុពលក៏ដោយ។ លទ្ធផលនៃការបែងចែករបស់ EVFTA អាចជាកង្វល់មួយចំពោះវិស័យមួយចំនួន និង/ឬ ចំពោះស្ត្រី។

ដំណើរការ EVFTA បង្ហាញមេរៀនសំខាន់ៗមួយចំនួន។ ទីមួយ កិច្ចព្រមព្រៀងពាណិជ្ជកម្មគួរតែមានលក្ខណៈសមស្របនឹងយុទ្ធសាស្ត្រថ្នាក់ជាក់សម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ ទីពីរ កិច្ចព្រមព្រៀងនេះចាំបាច់ត្រូវតែរួមចំណែកដល់ការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រនៅក្នុងវិស័យសេដ្ឋកិច្ច។ ទីបី EVFTA ចាំបាច់ត្រូវតែរួមបញ្ចូលនិយាមអន្តរជាតិថ្មីៗស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព។ ទីបួន កិច្ចព្រមព្រៀងចាំបាច់ត្រូវតែថែរក្សាឲ្យមានគុណភាពខ្ពស់ ទោះបីជាអាចអនុញ្ញាតឲ្យមានភាពបត់បែនមួយចំនួនក៏ដោយ។ ទីប្រាំ កិច្ចព្រមព្រៀងត្រូវតែមានសង្គតភាពនឹងកំណែទម្រង់នៅក្នុងប្រទេស។ ជាចុងក្រោយ ការគ្រប់គ្រងការព្រមព្រៀងជាឯកច្ឆ័ន្ទ រួមបញ្ចូលទាំង តាមរយៈយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដ៏សមស្របមួយផងដែរ មានតួនាទីយ៉ាងសំខាន់។

កិច្ចពិភាក្សាខាងលើមានអត្ថន័យមួយចំនួនចំពោះអាស៊ាន។ ទីមួយ រដ្ឋសមាជិកអាស៊ាន (AMS) នីមួយៗ ចាំបាច់ត្រូវតែខិតខំប្រឹងប្រែងអនុវត្ត បញ្ចប់ ឬ ចាប់ផ្តើមធ្វើការចរចា ដើម្បីចុះ FTA ជាមួយ EU ដោយទទួលស្គាល់អំពីសារសំខាន់នៃការព្រមព្រៀងទាំងនោះ ពាក់ព័ន្ធនឹងការពង្រឹងលទ្ធភាពចូលក្នុងទីផ្សារ រួមជាមួយការបំពេញបន្ថែមលើកំណែទម្រង់នៅក្នុងប្រទេស។ល។ ដំណើរការនេះអាចចំណាយពេលតិច ឬ ច្រើន អាស្រ័យលើ AMS នីមួយៗ ស្របតាម "វិធីអាស៊ាន" ប៉ុន្តែគួរតែត្រូវបានលើកកម្ពស់ ដើម្បីការភ្ជាប់ទំនាក់ទំនងផ្នែកសេដ្ឋកិច្ចនៅក្នុងតំបន់ដែលមានភាព

រឹងមាំជាងមុន និង បើកចំហរតំបន់និយម ដែលអាស៊ានផ្តល់ការគាំទ្រជាផ្លូវមួយ។

ទីពីរ AMSs ចាំបាច់ត្រូវតែបន្តលើកកម្ពស់កំណែទម្រង់នៅក្នុងប្រទេស ដើម្បីត្រៀមខ្លួនសម្រាប់ និង រួមបញ្ចូល FTAs ដែលមានគុណភាពខ្ពស់ជាមួយ EU។ ការពង្រឹង FTAs ជាមួយ EU ក្នុងនាមជាយានមួយសម្រាប់កំណែទម្រង់នៅក្នុងប្រទេស នៅតែជាប់ពាក់ព័ន្ធ ប៉ុន្តែយាននេះមិនគួរមានតែមួយនោះទេ។ ដើម្បីបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងនេះ AMS ត្រូវការទាំងការប៉ាន់ប្រមាណអំពីផលប៉ះពាល់យ៉ាងហ្មត់ចត់ ព្រមទាំងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផងដែរ។

ទីបី AMS គួរតែត្រួតពិនិត្យឡើងវិញលើភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការ និង ការកសាងសមត្ថភាពសម្រាប់ការរៀបចំ និង ការអនុវត្ត FTAs ជាមួយ EU យ៉ាងមានប្រសិទ្ធភាព។ ភាពចាំបាច់នោះអាចត្រូវបានរួមបញ្ចូលទៅក្នុង FTAs ជាមួយ EU ដោយផ្ទាល់។ លើសពីនេះទៀត AMS អាចជំរុញឲ្យមានកម្មវិធី និង កិច្ចខិតខំប្រឹងប្រែងដែលពាក់ព័ន្ធ ដើម្បីកិច្ចសហប្រតិបត្តិការ និង ការកសាងសមត្ថភាពនៅក្នុងចំណោមពួកគេ។

ជាចុងក្រោយ វានឹងជំរុញឲ្យមានកិច្ចសហប្រតិបត្តិការនៅក្នុងដំណើរការរបស់អាស៊ាន ព្រមទាំងស្មារតីរបស់សហគមន៍អាស៊ានផងដែរ។

# ឯកសារយោង

Artuso, F. and A.D. Nguyen (2019), 'Good Practices in Dealing with NTMs in the CLMV: How Can They Be Leveraged?', Manuscript for Economic Research Institute for ASEAN and East Asia.

Baker, P., D. Vanzetti, T.L.H. Pham, T.X.T. Nguyen, and M.T. Nguyen (2014), 'Impact Assessment: EU-Vietnam FTA', Report for Multilateral Trade and Investment Project (MUTRAP).

Baker, P., D. Vanzetti, T.L.H. Pham, C.T. Tran, T.X.T. Nguyen, and A.D. Nguyen (2017), 'Impact Assessment: EU-Vietnam FTA', Report for Multilateral Trade and Investment Project (MUTRAP).

Central Institute for Economic Management (CIEM) (2010), Comprehensive Evaluations of Vietnam's Socio-Economic Performance 3 Years After Accession to the WTO. Hanoi: Financial Publishing House.

CIEM (2013), Comprehensive Evaluations of Vietnam's Socio-Economic

Performance 5 Years After Accession to the WTO. Hanoi: Financial Publishing House.

Dinh, H.M., Q.L. Trinh, and A.D. Nguyen (2009), 'Trade, Growth, Employment, and Wages in Vietnam', Research Project: Globalization, Adjustment and the Challenge of Inclusive Growth: Furthering Inclusive Growth and Industrial Upgrading in Indonesia, the Philippines and Vietnam.

Dinh, T.H., A.D. Nguyen, B.M. Tran, T.H. Pham, T.N.T. Do, P.N. Le, and T.H. Dang (2020), Implementing CPTPP as a Part of Economic Integration Roadmap in Vietnam: Requirement for Structural Reforms and Firms' Preparedness. Hanoi: Dan Tri Publishing House.

European Parliament (n.d.), Legislative Train Schedule: A Balanced and Progressive Trade Policy to Harness Globalisation. EU-Vietnam Free Trade Agreement (EVFTA). https://www.europarl.europa.eu/legislative-train/theme-a-balanced-and-progressive-trade-policy-to-harness- globalisation/file-eu-vietnam-fta (accessed 16 May 2020).

Ha, T.T.T. (2020), 'Assessing Impacts of EU-Vietnam Free Trade Agreement on Viet Nam's Economy in 2020–2030', Ministerial-level Project, Ministry of Planning and Investment of Viet Nam. In Vietnamese.

Nguyen, A.D., T.H. Dinh, T.N.T. Do, and T.T. Vo (2019), 'Non-tariff Measures in Viet Nam', in H.T.T. Doan and S. Rosenow (eds.), Non-tariff measures in ASEAN – An Update. Jakarta: ERIA, pp. 207–233.

Nguyen, A.D., D.C. Nguyen, T.T. Vo, B.M. Tran, T.H. Pham, and H.L. Le (2017), Việt Nam tham gia các hiệp định thương mại tự do mới: Một số yêu cầu cải cách thể chế thương mại và đầu tư [Impacts of New-Generation FTAs and Institutional Reforms in Vietnam], funded by the Australian Department for Foreign Affairs and Trade project, Restructuring for a Competitive Vietnam. In Vietnamese.

Nguyen, A.D., D. Vanzetti, R. Trewin, T.H. Dinh, T.H. Vu, and X.S. Le (2014), Assessing the Impacts of the Regional Comprehensive Economic Partnership on Vietnam's Economy Multilateral Trade and Investment Project. Activity code: ICB-8.

Roland-Holst, D., F. Tarp, V.A. Dinh, T.T. Vo, L.H. Pham, and H.M. Dinh (2002), Vietnam's Accession to the World Trade Organization: Economic Projections to 2020. https://mpra.ub.uni-muenchen.de/29417/ (accessed 17 August 2018).

Truong, D.T., T.T. Vo, T.G. Bui, V.C. Phan, T.D. Le, A.D. Nguyen, and S.A. Pham (2011), Tác động của cam kết mở cửa thị trường trong WTO và các hiệp định thương mại tự do đến hoạt động sản xuất, thương mại của Việt Nam và các cơ chế hoàn thiện cơ

chế điều hành xuất nhập khẩu của Bộ Công Thương giai đoạn 2011–2015 [Impacts of Commitments on Opening the Market under WTO and other Free Trade Agreements on Vietnam's Production and Trade Activities and Mechanism to Improve Import and Export Management Scheme of the Ministry of Industry and Trade in 2011–2015], report for Multilateral Trade Assistance Project (MUTRAP). In Vietnamese.

Vo, T.T. and A.D. Nguyen (2009), 'Vietnam after Two Years of WTO Accession: What Lessons Can Be Learnt', ASEAN Economic Bulletin, 26(1), pp. 115–135.

World Bank (2018), Economic and Income Distribution Impacts of the Comprehensive and Progressive Agreement for Trans-Pacific Partnership: The Case of Viet Nam. Hanoi: World Bank. English and Vietnamese.

5

# តួនាទីរបស់កិច្ចប្រជុំអាស៊ី - អឺរ៉ុប នៅក្នុងការលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិក

LURONG CHEN

## បុព្វកថា

អាស៊ី និង អឺរ៉ុបមានសក្តានុពលខ្ពស់នៅក្នុងការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក ហើយកិច្ចប្រជុំអាស៊ី-អឺរ៉ុប (AEM) មានតួនាទីដ៏សំខាន់នៅក្នុងការប្រើប្រាស់សក្តានុពលនេះ។ ការលើកកម្ពស់ឌីជីថលនីយកម្ម និង ពាណិជ្ជកម្មអេឡិចត្រូនិក មានអាទិភាពខ្ពស់បំផុតនៅក្នុងការបញ្ជាការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងអាស៊ី និង អឺរ៉ុប។ លក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយដើម្បីសម្រេចបានភាពជោគជ័យផ្នែកសេដ្ឋកិច្ចនៅក្នុងយុគសម័យឌីជីថល គឺការតភ្ជាប់ផ្នែកទិន្នន័យ។ ជាពិសេស កិច្ចប្រជុំអាស៊ី-អឺរ៉ុបត្រូវតែផ្តល់ការសហការនៅក្នុងការជួយសម្រួលដល់លំហូរទិន្នន័យដោយសេរី និង ដោយទំនុកចិត្ត។

## កិច្ចប្រជុំអាស៊ី-អឺរ៉ុប លើពាណិជ្ជកម្មអេឡិចត្រូនិកជាសកល

ពាណិជ្ជកម្មអេឡិចត្រូនិកគឺជាវិស័យមួយប្រកបដោយថាមវន្តខ្លាំងបំផុតនៅក្នុងសេដ្ឋកិច្ចសកល។ ការលក់ដូរតាមរយៈពាណិជ្ជកម្មអេឡិចត្រូនិកជាសកលមានការកើនឡើងជាបន្តបន្ទាប់ហើយគេបានមើលឃើញកំណើនប្រកបដោយចីរភាព។ ការលក់រាយតាមរយៈការធ្វើពាណិជ្ជកម្មអេឡិចត្រូនិកនៅទូទាំងពិភពលោកមានអត្រាកំណើនពីរខ្ទង់ ចាប់ពី ១,៥ ទ្រីលានដុល្លារនៅក្នុងឆ្នាំ២០១៥ ទៅ ៣,៥ ទ្រីលានដុល្លារនៅក្នុងឆ្នាំ២០១៩ និង ត្រូវបានព្យាករណ៍ទុកជាមុនថានឹងកើនឡើងបន្ថែមទៀតរហូតដល់ ៦,៥ ទ្រីលានដុល្លារត្រឹមឆ្នាំ២០២៣ ដែលតំណាងឲ្យជិតមួយភាគបួននៃការលក់រាយសរុបជាសកល។

កត្តាខុសៗគ្នាជាច្រើនបានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន រួមមាន ការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ អ៊ីនធឺណិតល្បឿនលឿន ភាពចាស់ទុំនៃប្រព័ន្ធទូទាត់ប្រាក់តាមអនឡាញ ភាពប្រែប្រួលនៃឥរិយាបទរបស់អ្នកប្រើប្រាស់ និង សេរីភាវូបនីយកម្មផ្នែកសេវាកម្ម។ តាមរយៈការណែនាំអំពីឧបករណ៍ឌីជីថលថ្មីៗ ដូចជា ប្រាជ្ញាសិប្បនិម្មិត, ការផ្ទុកទិន្នន័យតាមប្រព័ន្ធខ្លៅ (cloud computing), ទិន្នន័យខ្នាតធំ, និង ការរៀនសូត្ររបស់ម៉ាស៊ីនអំពីទីផ្សារ, ឌីជីថលនីយកម្ម កំពុងតែរំខានដល់ការការធ្វើអាជីវកម្មតាមបែបប្រពៃណីតាមវិធីខុសៗគ្នាជាច្រើន (Chen និង Kimura ឆ្នាំ២០២០)។ ឧទាហរណ៍៖ នៅក្នុងទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិក ពីអាជីវកម្មទៅកាន់អ្នកប្រើប្រាស់ គណនីដែលប្រើប្រាស់តាមប្រព័ន្ធទូរស័ព្ទឆ្លាតវៃ ធ្វើឲ្យមានការចូលមើលវែបសាយត៍លក់រាយជាងពាក់កណ្ដាលនៅទូទាំងពិភពលោក និង ធ្វើឲ្យមានប្រាក់ចំណូលនៃការលក់រាយតាមប្រព័ន្ធអេឡិចត្រូនិកខ្ពស់បំផុត។ បំរែបម្រួលមួយនៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក ដែលហៅថា ការធ្វើពាណិជ្ជកម្មចល័ត ឬ អឹម-ខមមើស បានទទួលការគាំទ្រតាមរយៈការអភិវឌ្ឍ និង សមាហរណកម្មរបស់ទូរស័ព្ទឆ្លាតវៃ ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និង បច្ចេកវិទ្យាអ៊ីនធឺណិត ដែលជួយសម្រួលដល់ការធ្វើទីផ្សារ និង ការទិញទំនិញអនឡាញបានយ៉ាងមានប្រសិទ្ធភាព។

គិតត្រឹមចុងឆ្នាំ២០១៨ មានអ្នកប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិក ជាង ២,៤ ប៊ីលាននាក់ នៅតាមបណ្ដាប្រទេសនានានៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ដែលមានប្រាក់ចំណូលសរុបជាង ១,២ ទ្រីលានដុល្លារ។ ប្រទេសចិនគឺជាទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកធំជាងគេបំផុត ពាក់ព័ន្ធនឹងចំនួនអ្នកប្រើប្រាស់ និង ប្រាក់ចំណូលប្រចាំឆ្នាំពីពាណិជ្ជកម្មអេឡិចត្រូនិក។

ប្រទេសជប៉ុន ចក្រភពអង់គ្លេស ប្រទេសអាល្លឺម៉ង់ និង សាធារណរដ្ឋកូរ៉េ ក៏ស្ថិតនៅលំដាប់ខ្ពស់បំផុតនៅក្នុងបញ្ជីនេះដែរ ពាក់ព័ន្ធនឹងប្រាក់ចំណូលប្រចាំឆ្នាំ ពីពាណិជ្ជកម្មអេឡិចត្រូនិក។ គេបានព្យាករណ៍ទុកជាមុនថា ចំនួនអ្នកប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិកសរុបនៅទូទាំងពិភពលោកនឹងឈានដល់ ៣,៤ ប៊ីលាននាក់ ហើយប្រាក់ចំណូលសរុបពីពាណិជ្ជកម្មអេឡិចត្រូនិកនឹងឈានដល់ ២,២ ទ្រីលានដុល្លារ ត្រឹមឆ្នាំ២០២៤ (រូបភាពទី ១)។

## រូបភាពទី១៖ ប្រាក់ចំណូល និង ចំនួនអ្នកប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិក នៅក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុប




[a] ទិន្នន័យព្យាករណ៍ទុកមុន

ប្រភព៖ អ្នកនិពន្ធ។ ទិន្នន័យនៅត្រូវបានទាញចេញពី Statista Digital Market Outlook 2019. www.statista.com (ចូលប្រើប្រាស់នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)

ទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកនៃ ASEM ទាំងអស់ ជាពិសេសទីផ្សារនៃប្រទេសចំនួនបីដែលមានប្រជាជនច្រើនជាងគេបំផុតនៅអាស៊ី ដូចជាប្រទេសចិន ប្រទេសឥណ្ឌា និង ប្រទេសឥណ្ឌូនេស៊ី ត្រូវបានរំពឹងទុកថានឹងមានកំណើនយ៉ាងឆាប់រហ័ស។ ពាក់ព័ន្ធនឹងប្រាក់ចំណូលជាមធ្យមពីពាណិជ្ជកម្មអេឡិចត្រូនិកក្នុងអ្នកប្រើប្រាស់ម្នាក់ (ARPU) មានគម្លាតរវាងបណ្តាប្រទេសនៅអាស៊ី និង នៅអឺរ៉ុប។ ក្នុងចំណោមប្រទេសទាំងប្រាំពីរដែលមាន ARPU លើស ១.០០០ ដុល្លារ នៅឆ្នាំ២០១៨ មានប្រាំប្រទេសនៅអឺរ៉ុប។ ជាទូទៅ ការជ្រៀតចូលទីផ្សារ និង ការចំណាយជាមធ្យមលើពាណិជ្ជកម្មអេឡិចត្រូនិកក្នុងប្រជាជនម្នាក់ នៅក្នុងចំណោមអ្នកប្រើប្រាស់នៅអាស៊ី មានចំនួនទាបជាងអ្នកប្រើប្រាស់នៅអឺរ៉ុប។ ទោះបីជាយ៉ាងណាក៏ដោយ ទីផ្សារនៅអាស៊ីកំពុងតែដេញតាមយ៉ាងឆាប់រហ័ស។ គេបានប៉ាន់ស្មានថា នៅក្នុងរយៈពេល ៥-១០ ឆ្នាំបន្ទាប់ទៀត ទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកដែលមានកំណើនលឿនជាងគេបំផុតចំនួនប្រាំ នៅលើពិភពលោក នឹងសុទ្ធតែជា ទីផ្សារនៅអាស៊ី។[12]

[12] តាមរយៈការវាស់វែងដោយអត្រាកំណើនប្រចាំឆ្នាំនៅក្នុងរយៈពេលជាក់លាក់មួយនៃការជ្រៀតចូលទីផ្សាររបស់ពាណិជ្ជកម្មអេឡិចត្រូនិក ទីផ្សារដែលមានកំណើនឆាប់រហ័សជាងគេបំផុតចំនួនប្រាំ រួមមាន ប្រទេសបង់ក្លាដេស ប៉ាគីស្ថាន ឡាវ ម៉ុងហ្គោលី និង កម្ពុជា។

ប្រទេសចំនួនប្រាំដែលមានប្រាក់ចំណូលជាមធ្យមក្នុងអ្នកប្រើប្រាស់ម្នាក់ ខ្ពស់ជាងគេ ដែលត្រូវបានវាស់វែងដោយអត្រាកំណើនប្រចាំឆ្នាំនៅក្នុងរយៈពេលជាក់លាក់មួយ រួមមាន ប្រទេសឥណ្ឌូនេស៊ី ប្រទេសប៉ាគីស្ថាន ប្រទេសបង់ក្លាដេស ប្រទេសមីយ៉ាន់ម៉ា និង ប្រទេសឥណ្ឌា។

## រូបភាពទី២៖ ការជ្រៀតចូលទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិក និង ប្រាក់ចំណូលជាមធ្យមក្នុងអ្នកប្រើប្រាស់ម្នាក់នៅក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុប




ARPU = ប្រាក់ចំណូលជាមធ្យមពីពាណិជ្ជកម្មអេឡិចត្រូនិកក្នុងអ្នកប្រើប្រាស់ម្នាក់, ប្រទេសកូរ៉េ = សាធារណរដ្ឋកូរ៉េ, ឡាវ = សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, UK = ចក្រភពអង់គ្លេស។

[a] ប្រទេសចំនួនប្រាំដែលមានកំណើនការជ្រៀតចូលទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកខ្ពស់ជាងគេបំផុត

[b] ប្រទេសចំនួនប្រាំដែលមានកំណើនប្រាក់ចំណូលជាមធ្យមក្នុងអ្នកប្រើប្រាស់ម្នាក់ ខ្ពស់ជាងគេបំផុត

ប្រភព៖ អ្នកនិពន្ធ។ ទិន្នន័យនៅត្រូវបានទាញចេញពី Statista Digital Market Outlook 2019. www.statista.com (ចូលប្រើប្រាស់នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)

គិតត្រឹមឆ្នាំ២០២៤ ទាំងការជ្រៀតចូលទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិក និង ARPU នៅអាស៊ី នឹងមានកំណើនយ៉ាងខ្លាំងក្លា។ ទោះបីជាការបែងចែកប្រព័ន្ធឌីជីថលមិនទំនងជានឹងរលាយបាត់ក៏ដោយ ក៏គម្លាតរវាងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន និង ប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍នៅអាស៊ី កំពុងតែរួមតូច ជាពិសេសពាក់ព័ន្ធនឹងការជ្រៀតចូលទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិក (រូបភាពទី ២)។

ជារួម ការធ្វើអាជីវកម្មអនឡាញ មានទំនាក់ទំនងអន្តរការីរវាងអ្នកលក់ និង អ្នកទិញតិចជាងមុន។ ដោយសារតែការប្រើប្រាស់អ៊ីនធឺណិត និង សេវាកម្មពាណិជ្ជកម្មអេឡិចត្រូនិក បានកាន់តែងាយស្រួល (ឧ. ការស្វែងរក ការដឹកជញ្ជូន ការធ្វើអត្តសញ្ញាណកម្មឌីជីថល ការទូទាត់ប្រាក់ និង ការការពារអ្នកប្រើប្រាស់) ពាណិជ្ជកម្មអេឡិចត្រូនិកបានកាត់បន្ថយរនាំងនៃការចូលទៅកាន់ទីផ្សារបានយ៉ាងមានប្រសិទ្ធភាព និង អនុញ្ញាតឲ្យបុគ្គល និង សហគ្រាសធុនតូចបំផុត សហគ្រាសធុនតូច និង មធ្យម (MSMEs) ចូលទៅកាន់ទីផ្សារបានកាន់តែច្រើនឡើង។ នៅកម្រិតអន្តរជាតិ វាជួយសម្រួលដល់ពាណិជ្ជកម្ម និង ការវិនិយោគ តាមរយៈការកាត់បន្ថយបន្ទុកចំណាយធ្វើប្រតិបត្តិការ និង ដឹកជញ្ជូនឆ្លងព្រំដែន ហើយចំណុចដែលសំខាន់ជាងនេះទៀត វាលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអន្តរជាតិ និង បង្កើនតម្លាភាព ដែលជួយកំណត់ទីផ្សារថ្មីៗ និង ពង្រីកខ្សែសង្វាក់តម្លៃសកល (GVCs) (Chen ឆ្នាំ២០១៧; ឆ្នាំ២០១៩)។ ចំពោះការផ្តត់ផ្តង់ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) មិនត្រឹមតែពង្រឹងសកលភាវូបនីយកម្ម (ដែលត្រូវបានពណ៌នាជាចម្បង ដោយពាណិជ្ជកម្មអន្តរជាតិ និង GVCs) ដែលមានស្រាប់តែប៉ុណ្ណោះទេ ប៉ុន្តែវាក៏នាំទៅរករចនាបថថ្មីមួយនៃការបែងចែកការងារជាអន្តរជាតិផងដែរ ដែលជួយសម្រួលដល់បុគ្គល និង MSMEs ចំពោះការចូលរួមនៅក្នុង GVCs ("ការបំបែកអាជីវកម្មលើកទីបី") (Baldwin ឆ្នាំ២០១៦; Kimura ឆ្នាំ២០១៨; Kimura និង Chen ឆ្នាំ២០១៨)។ នៅកម្រិតមីក្រូ ពាណិជ្ជកម្មអេឡិចត្រូនិកអាចផ្តល់ភាពអង់អាចដល់ MSMEs នៅក្នុងការសម្រេចបាននូវកំណើនដែលមានបរិយាប័ន្ន តាមរយៈការបង្កើតឱកាសសម្រាប់ពួកគេនៅក្នុងការចូលទៅកាន់ទីផ្សារបានកាន់តែទូលំទូលាយ ដែលគ្មានចំណាយប្រតិបត្តិការនោះទេ។ ចំពោះទាំងអាស៊ី និង អឺរ៉ុប ការតភ្ជាប់ MSMEs ទៅនឹង GVCs តាមរយៈពាណិជ្ជកម្មអេឡិចត្រូនិក ទំនងជាទទួលបានការពង្រីកទីផ្សារយ៉ាងខ្លាំងក្លា ហើយកាន់តែសំខាន់ជាងនេះទៀត បង្កើតលទ្ធផលទ្វេគុណដ៏ធំមួយចំពោះផ្នែកសេដ្ឋកិច្ចផ្សេងៗទៀត។

ឌីជីថលនីយកម្មកំពុងតែមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅជំពោះសេដ្ឋកិច្ចសកលហើយការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិកគឺជាទំហំនៃការអភិវឌ្ឍដ៏សំខាន់មួយ។ ដើម្បីប្រើប្រាស់សក្តានុពលផ្នែកពាណិជ្ជកម្មអេឡិចត្រូនិករបស់ ASEM គេមិនអាចសម្លឹងមើលវិស័យនេះដោយប្រើទស្សនវិស័យតែ

មួយនោះទេ។ ផ្ទុយមកវិញ ថ្នាក់ដឹកនាំដែលមកពីទ្វីបអាស៊ី និង អឺរ៉ុបចាំបាច់ត្រូវតែបំពេញ ការងារដើម្បីឆ្ពោះទៅគាំទ្រដល់បណ្តាញខ្សែសង្វាក់តម្លៃទាំងមូល ដែលគ្របដណ្តប់លើទ្វីបទាំងពីរ។

នេះមានន័យថា ផ្តល់ភាពអង់អាចដល់តួអង្គជាច្រើននៅក្នុងស្ថានប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិចជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មឆ្លងព្រំដែន និង ពង្រឹងទំនុកចិត្តដល់អ្នកប្រើប្រាស់នៅក្នុង "ការគ្រប់គ្រងរលកឌីជីថល"។ ដោយមានបំណងសម្របសម្រួលការចូលរួម និង សកម្មភាពតភ្ជាប់រវាង អាស៊ី-អឺរ៉ុប ASEM បានបង្កើតក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្តីពីការតភ្ជាប់ (APGC) ដែលរួមបញ្ចូល វិស័យអាទិភាពចំនួនប្រាំមួយ ហើយ "ការតភ្ជាប់ និង សេដ្ឋកិច្ចឌីជីថលនាពេលអនាគត" គឺជាវិស័យផ្តោតមួយក្នុងចំណោមវិស័យអាទិភាពទាំងប្រាំមួយនោះ ("វិស័យផ្តោតទី ៤")។

## កង្វល់ និង អាទិភាពផ្នែកគោលនយោបាយ

ការលើកកម្ពស់ឌីជីថលនីយកម្ម និង ពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានមើលឃើញថាជាយានមួយនៃការតភ្ជាប់បន្ថែមទៀត និង កិច្ចសហប្រតិបត្តិការរវាងអាស៊ី និង អឺរ៉ុប។ ចំពោះរដ្ឋជាដៃគូរបស់ ASEM គោលដៅគឺដើម្បីបង្កើតឱកាសក្នុងការទទួលស្គាល់សក្តានុពលចំពោះកំណើនយ៉ាងឆាប់រហ័ស តាមរយៈការពង្រឹងជាសមូហភាពនូវការតភ្ជាប់ផ្នែកឌីជីថល ការពន្លឿនការផ្ទេរតាមប្រព័ន្ធឌីជីថល និង ជួយសម្រួលដល់ការអាជីវកម្មអនឡាញ ពីព្រោះចំណុចនេះមានទំនាក់ទំនងនឹងសុខមាលភាពរបស់ប្រជាជនជាង ៥៥%នៃចំនួនប្រជាជនសរុបនៅលើពិភពលោក។ កិច្ចការដែលទាក់ទងនឹងចំណុចនេះភាគច្រើនស្ថិតនៅក្រោមសសរស្តម្ភសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ ASEM ប៉ុន្តែត្រូវតែមានការគាំទ្រពីវឌ្ឍនភាពដំណាលគ្នា ដែលស្ថិតនៅក្រោមសសរស្តម្ភនយោបាយ និង វប្បធម៌សង្គម។

បន្ថែមពីលើសកម្មភាពទីផ្សារដែលកំណត់ជំហាននៃវឌ្ឍនភាពផ្នែកបច្ចេកវិទ្យា និង ដំណើរការនៃការសម្រេចចិត្តលើការទិញ-លក់នៅលើទីផ្សារ យុទ្ធសាស្ត្រអភិវឌ្ឍន៍ និង គោលនយោបាយសេដ្ឋកិច្ចជាតិរបស់ប្រទេស ក៏ដើរតួយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្មអេឡិច ត្រូនិកផងដែរ។ ជាពិសេសនៅក្នុងវិស័យដែលយន្តការទីផ្សារបាត់បង់ប្រសិទ្ធភាព ឬ ប្រសិទ្ធផលរបស់វា អន្តរាគមន៍ផ្នែកគោលនយោបាយអាចជួយលុបបំបាត់ ឬ កាត់បន្ថយ បច្ច័យនៃការបរាជ័យផ្នែកទីផ្សារ តាមរយៈការផ្តល់ជូននូវទំនិញជាសាធារណៈ។ ដើម្បីលើកកម្ពស់ការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក ការបង្កើតក្របខណ្ឌនិយ័តកម្មក៏មានសារសំខាន់ដូចគ្នានឹងហេដ្ឋារចនាសម្ព័ន្ធរបស់បណ្តាញដែរ។

ទីមួយ កិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយជួយដល់ទីផ្សារនៅក្នុងការសន្សំសំចៃពេលវេលា "ប្រតិកម្ម" ដើម្បីឆ្លើយតបទៅនឹងរលកនៃបច្ចេកវិទ្យាថ្មីៗ និង ចាប់យកឱកាសនៃការអភិវឌ្ឍជំហាន

គឺង្គក់ដែលអាចកើតឡើងបាន។ ការគាំទ្ររបស់រដ្ឋាភិបាលអាចជួយពាណិជ្ជកម្មអេឡិចត្រូនិកឲ្យរកឃើញមជ្ឈដ្ឋានទីផ្សារដែលអំណោយផលការអភិវឌ្ឍខ្លាំងជាងមុន (ពោលគឺ ទីផ្សារបើកចំហររួមជាមួយប្រព័ន្ធច្បាប់ដែលបំពេញមុខងារបានយ៉ាងល្អ) និង ជាលទ្ធផលមានកំណើនយ៉ាងឆាប់រហ័ស។ ទីពីរ ការចូលរួមរបស់វិស័យសាធារណៈនៅក្នុងផ្នែកភ័ស្តុភារ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធនឹងជួយបំពេញចន្លោះនៃការអភិវឌ្ឍ និង ពង្រឹងការតភ្ជាប់ទាំងមូល។ ទីបី គោលនយោបាយដែលអំណោយផលដល់ការអភិវឌ្ឍវិស័យសេវាកម្ម នឹងមានឥទ្ធិពលជាវិជ្ជមានលើពាណិជ្ជកម្មអេឡិចត្រូនិក។ ឧទាហរណ៍៖ ប្រសិទ្ធភាពផ្នែកសេវាកម្មនឹងកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្ម បង្កើនទំនុកចិត្ត និង អាស្រ័យហេតុនេះ លើកកម្ពស់សកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិក។ ទីបួនទីផ្សារអនឡាញត្រូវការវិធាន និង បទប្បញ្ញត្តិនានាដើម្បីធានាចំពោះភាពបើកចំហរ ការប្រកួតប្រជែងដោយស្មើភាព សន្តិសុខ និង ប្រសិទ្ធភាពរបស់ទីផ្សារនេះ។ ជាចុងក្រោយ ការគាំទ្រផ្នែកគោលនយោបាយដើម្បីពង្រឹងមូលធនមនុស្ស និង ជំនាញការងារ នឹងរួមចំណែកដល់ភាពជោគជ័យរបស់ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងរយៈពេលវែង (Chen ២០១៧; ២០១៩)។

ជារួម ប្រទេសជាដៃគូរបស់ ASEM ដែលព្យាយាមសហការនៅក្នុងការលើកកម្ពស់ការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក គួរតែពង្រឹងការតភ្ជាប់ផ្នែកឌីជីថលរវាង និង នៅក្នុងចំណោមប្រទេសនានានៅទ្វីបអាស៊ី និង អឺរ៉ុប។ ពួកគេគួរតែធ្វើបែបនេះ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នដែលផ្តល់ការសហការ ដែល (i) លើកកម្ពស់ហេដ្ឋានរចនាសម្ព័ន្ធដែលទាក់ទងនឹងឌីជីថល ទាំងនៅក្នុងពិភពរូបវ័ន្ត និង លំហបច្ចេកវិទ្យា (ii) ធ្វើសុខដុមនីយកម្មវិធាន និង បទប្បញ្ញត្តិនានា ដើម្បីធានាចំពោះការប្រកួតប្រជែងដោយស្មើភាពនៅលើទីផ្សារអនឡាញ (iii) ពង្រឹងសេវាកម្មនានាដែលទាញចេញពីការតភ្ជាប់ដើម្បីបង្កើតតម្លៃបន្ថែម បន្ថែមទៀត និង (iv) ពង្រឹងភាពជាដៃគូរវាងរដ្ឋាភិបាល និង រដ្ឋាភិបាល រវាងវិស័យឯកជន និង វិស័យឯកជន និង រវាងវិស័យសាធារណៈ និង វិស័យឯកជន (Chen ២០២០a)។

ដើម្បីពង្រឹងការតភ្ជាប់ទិន្នន័យ វាមានភាពចាំបាច់នៅក្នុងការបង្កើតហាតវែរ (ពោលគឺ ហេដ្ឋារចនាសម្ព័ន្ធ ICT និង ផ្នែកភ័ស្តុភារ) និង សូហ្វវែរ រួមបញ្ចូលទាំង សេវាកម្ម និង បទប្បញ្ញត្តិផងដែរ ដើម្បីអនុញ្ញាតឲ្យមាន និង ផ្តល់ការគាំទ្រដល់ពាណិជ្ជកម្មអេឡិចត្រូនិក តាមរយៈការជួយសម្រួលដល់លំហូរនៃទិន្នន័យ មូលធន ទំនិញ និង សេវាកម្ម និង/ឬ ប្រជាជន ដែលហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងទិន្នន័យគឺជាលក្ខខណ្ឌតម្រូវមូលដ្ឋាន។ ឧបសគ្គចំពោះការតភ្ជាប់ទិន្នន័យរវាងអាស៊ី-អឺរ៉ុប គឺបណ្តាលមកពីអត្ថិភាពគម្លាតនៃការអភិវឌ្ឍ ទាំងឆ្លងកាត់ប្រទេសខុសៗគ្នា និង នៅក្នុងប្រទេសតែមួយ រវាងទីក្រុង និង តំបន់ជនបទដាច់ស្រយាល។ នៅក្នុងប្រទេសជាច្រើន ការអភិវឌ្ឍហេដ្ឋារចនា

សម្ព័ន្ធដែលទាក់ទងនឹងទិន្នន័យមានការលំបាកយ៉ាងខ្លាំង ដោយសារកង្វះខាតដើមទុន មូលធនមនុស្ស និង ចំណេះធ្វើផ្នែកបច្ចេកវិទ្យា។ ឧទាហរណ៍៖ ការបង្កើតបណ្តាញហ្វៃប៊ែរគឺជាផ្នែកដ៏សំខាន់មួយនៃហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ចំពោះសេដ្ឋកិច្ចឌីជីថល។ ទោះបីជាការប្រើប្រាស់ផ្កាយរណបមានការកើនឡើងក៏ដោយ ក៏ខ្សែកាបហ្វៃប៊ែរអុបទិកនៅលើដី និង/ឬ នៅក្រោមសមុទ្រនៅតែជាប្រព័ន្ធផ្សព្វផ្សាយចម្បងសម្រាប់ការ “បញ្ជូន” ទិន្នន័យ។ ការបង្កើតបណ្តាញហ្វៃប៊ែរតម្រូវឲ្យមានការវិនិយោគមូលធនថេរ និង បច្ចេកវិទ្យានៅកម្រិតខ្ពស់ ហើយការថែរក្សា និង ការដំឡើងកម្រិតបណ្តាញតម្រូវឲ្យមានធាតុចូលសំខាន់ៗសម្រាប់ការអនុវត្តនៅពេលក្រោយ ពីព្រោះបច្ចេកវិទ្យាហ្វៃប៊ែរកំពុងតែមានវឌ្ឍនភាពយ៉ាងឆាប់រហ័ស ប្រសិនបើប្រៀបធៀបនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធតាមបែបប្រពៃណី។ លើសពីនេះទៀត ការធ្វើប្រតិបត្តិការ និង ការត្រួតពិនិត្យបណ្តាញត្រូវការមូលធនមនុស្សដែលមានជំនាញបច្ចេកទេស និង ជំនាញគ្រប់គ្រងកម្រិតខ្ពស់ ព្រមទាំង មានសមត្ថភាពក្នុងការរៀនសូត្រអំពីបច្ចេកវិទ្យា និង គំរូអាជីវកម្មថ្មីៗ បានយ៉ាងឆាប់រហ័សផងដែរ។

បញ្ហាប្រឈមដែលកាន់តែខ្លាំងក្លាជាងនេះទៀត គឺវិធីទទួលបានការព្រមព្រៀងជាឯកច្ឆន្ទជាសកល ដើម្បីទទួលស្គាល់លំហូរទិន្នន័យដោយសេរី និង ដោយមានទំនុកចិត្ត។ បញ្ហាទិន្នន័យមានសារសំខាន់ខ្លាំងណាស់ចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃបរិវត្តកម្មឌីជីថល និង អាចមានផលជះទៅលើចីរភាពនៃការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិកដោយផ្ទាល់។ ការធានាបាននូវលំហូរទិន្នន័យដោយសេរី និង ដោយមានទំនុកចិត្ត នឹងលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងទិដ្ឋភាពជាច្រើន។ ទីមួយ លំហូរទិន្នន័យដោយសេរី បង្កើតភាពទាន់ពេលវេលា តម្លាភាព និង អាស្រ័យហេតុនេះ បង្កើនភាពត្រឹមត្រូវរបស់ទិន្នន័យ។ ទីពីរ លំហូរទិន្នន័យឆ្លងកាត់ព្រំដែនដោយសេរី អនុញ្ញាតឲ្យអ្នកប្រើប្រាស់ទាំងនៅក្នុងប្រទេស និង នៅបរទេស ទទួលបានទិន្នន័យដោយគ្មានការរើសអើង បង្កើនភាពសុក្រឹត និង ការប្រកួតប្រជែងនៅលើទីផ្សារ។ ទីបី ចំណុចនេះនឹងជួយបញ្ចេញសក្តានុពលរបស់ទីផ្សារដើម្បីបង្កើតតម្លៃបន្ថែមរបស់ទិន្នន័យតាមរយៈការកំណត់ព្រំដែនច្បាប់យ៉ាងច្បាស់លាស់ពាក់ព័ន្ធនឹងការប្រើប្រាស់ និង រក្សាទុកទិន្នន័យ។

និយាយដោយសាមញ្ញ លំហូរទិន្នន័យដោយសេរី និង ដោយមានទំនុកចិត្តមានន័យពីរ។ នៅម្ខាង “ដោយសេរី” មានន័យថា អនុញ្ញាតឲ្យមានលំហូរនៃទិន្នន័យដោយសេរី តាមតម្រូវការ ពាក់ព័ន្ធនឹងល្បឿន ទម្រង់ ទិសដៅ។ល។ នៅក្នុងន័យប្រៀបធៀប រនាំងផ្នែកបច្ចេកវិទ្យាចំពោះលំហូរទិន្នន័យត្រូវបានកាត់បន្ថយបានយ៉ាងមានប្រសិទ្ធភាព ជាពិសេសតាមរយៈការប្រើប្រាស់យ៉ាងទូលំទូលាយនូវទូរស័ព្ទឆ្លាតវៃ បណ្តាញ 4G និង បណ្តាញ 5G ដែលនឹងមកដល់នាពេលខាងមុខ ដោយបានទទួលការគាំទ្រពីភាពជឿនលឿនផ្នែក បច្ចេកវិទ្យានៅក្នុងការប្រមូល ដំណើរការ រក្សាទុក និង

ចែកចាយទិន្នន័យ។ ទិន្នន័យ និង ព័ត៌មានបច្ចុប្បន្ន ភាគច្រើនមានលក្ខណៈឌីជីថលជាប់មកជាមួយរួចហើយ ពោលគឺទិន្នន័យ និង ព័ត៌មានទាំងនោះត្រូវបានបង្កើតឡើងដោយគ្មានព្រំដែននោះទេ ហើយ វដ្តនៃជីវិតរបស់ពួកគេ មានអត្ថិភាពនៅក្នុងលំហបច្ចេកវិទ្យា។

ម៉្យាងវិញទៀត "ទំនុកចិត្ត" គូសបញ្ជាក់អំពីការកើនឡើងនៃកង្វល់អំពីភាពត្រឹមត្រូវ និង សុវត្ថិភាព និង ការការពារឯកជនភាពរបស់ទិន្នន័យ។ បច្ចេកវិទ្យា ICT គឺជាកាំបិតមុខពីរ៖ នៅខណៈពេលដែលវាជួយសម្រួលដល់លំហូរទិន្នន័យ វាក៏បង្កើនភាពងាយរងគ្រោះដែលទិន្នន័យអាចនឹងត្រូវលេចធ្លាយ លួច ឬ ប្រើប្រាស់មិនបានត្រឹមត្រូវផងដែរ។ របៀបរក្សាតុល្យភាពរវាងលំហូរទិន្នន័យដោយសេរី និង ការការពារឯកជនភាពត្រូវតែស្ថិតនៅក្នុងការជជែកវែកញែក។

យោងតាមទស្សនវិស័យអំពីការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក រដ្ឋាភិបាលត្រូវតែមានការប្រុងប្រយ័ត្នជាពិសេសចំពោះវិធីសាស្រ្តនានា ដូចជា ការធ្វើមូលដ្ឋានូបនីយកម្មលើលក្ខខណ្ឌតម្រូវការ ការរឹតត្បិត ការចម្រោះ និង ការរាំងស្ទះដល់លំហូរទិន្នន័យ និង ភាព អព្យាក្រឹត្យចំពោះការផ្គត់ផ្គង់អ៊ីនធឺណិត ដែលតាមធម្មតា បញ្ជាក់អត្ថន័យអំពីរនាំងចំពោះលំហូរទិន្នន័យដោយសេរី នៅក្នុងនាមនៃការដោះស្រាយឯកជនភាព ឬ សន្តិសុខដែលពាក់ព័ន្ធ។

នៅកម្រិតអន្តរជាតិ គោលនយោបាយគាំពារនិយមនៅក្នុងទិន្នន័យ ទំនងជាបង្កភាពអន្តរាយដល់ពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន ប្រហាក់ប្រហែលគ្នានឹងវិធីដែលគោលនយោបាយគាំពារនិយមនៅក្នុងពាណិជ្ជកម្មបង្កភាពអន្តរាយដល់ពាណិជ្ជកម្មអន្តរជាតិដែរ។ ដូច្នេះ ចាំបាច់ត្រូវតែបង្កើតការព្រមព្រៀងជាឯកច្ឆន្ទមួយដែលចែងអំពីលំហូរទិន្នន័យដោយសេរីឆ្លងកាត់ព្រំដែននានានៅក្នុងASEM ស្របពេលជាមួយគ្នានោះ ដោះស្រាយកង្វល់ផ្នែកឯកជនភាព និង សន្តិសុខដែលសមហេតុផល។ សកម្មភាពនេះនឹងត្រូវបានស្វាគមន៍ដោយថ្នាក់ដឹកនាំទីផ្សារនៅទ្វីបអាស៊ី និង អឺរ៉ុប ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជនផងដែរ ដែលកំពុងតែធ្វើការជាមួយគ្នាដើម្បីពន្លឿនដំណើរការនេះ ដោយប្រើប្រាស់ ASEM ជាវេទិកាមួយ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទង និង ការស្វែងយល់នៅក្នុងចំណោមប្រទេសជាដៃគូ។

## លំហូរទិន្នន័យដោយសេរីនិងមានទំនុកចិត្តនិងគោលនយោបាយគាំទ្រ

វិធាន និង បទប្បញ្ញត្តិមានភាពចាំបាច់ ដើម្បីធានាថា អ៊ីនធឺណិតគឺជាបណ្តាញបើកចំហរដែលទិន្នន័យអាចហូរចូលបានដោយសេរី និង មានសុវត្ថិភាព។ ទោះបីជាយ៉ាងណាក៏ដោយ ការបង្កើតវិធានគឺជាកិច្ចការមួយដែលត្រូវធ្វើដោយប្រុងប្រយ័ត្ន។ ការធ្វើនិយ័តកម្មហួសហេតុ (ពោលគឺ ការផ្តោត

លើផ្នែកសន្តិសុខខ្លាំងពេក) អាចបង្អាក់លំហូរទិន្នន័យ និង រារាំងកំណើនរបស់សេដ្ឋកិច្ចឌីជីថល នៅខណៈពេលដែលការធ្វើនិយ័តកម្មមិនគ្រប់គ្រាន់ (មិនយកចិត្តទុកដាក់ចំពោះសន្តិសុខ និង ឯកជនភាព) អាចបំផ្លាញថាមវន្តរបស់ទីផ្សារ ក្នុងរយៈពេលវែង ឬ ថែមទាំងអាចនាំឱ្យឈានទៅរកតំបន់អនឡាញពណ៌ប្រផេះ ថែមទៀតផង (Chen ឆ្នាំ២០១៧)។

លំហូរទិន្នន័យដោយសេរី និង មានទំនុកចិត្តមិនមែនជាបញ្ហាដែលកើតឡើងតែម្នាក់ឯងនោះទេ ប៉ុន្តែវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងកង្វល់ផ្នែកគោលនយោបាយដទៃទៀតដែលទាក់ទងនឹងសេដ្ឋកិច្ចឌីជីថល ដូចជា ឯកជនភាព ការការពារអតិថិជន ការប្រកួតប្រជែង ពន្ធដារ និង សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ វាក៏ជាចំណុចសំខាន់នៃរបបគោលនយោបាយដែលទូលំទូលាយជាងមុនសម្រាប់សេដ្ឋកិច្ចឌីជីថលផងដែរ និង ស្នើសុំឲ្យមានអភិក្រមជាប្រព័ន្ធដើម្បីកំណត់វិធានស្តីពីលំហូរនៃទិន្នន័យ និង អាជីវកម្មដែលទាក់ទងនឹងទិន្នន័យ។ ទោះបីជាយ៉ាងណាក៏ដោយ របៀបដែលប្រទេសនានាអនុវត្តចំពោះទិន្នន័យ និង ធ្វើអភិបាលកិច្ចទិន្នន័យមានលក្ខណៈខុសប្លែកពីគ្នា។ ពាក់ព័ន្ធនឹងកិច្ចសហការរវាងអាស៊ី-អឺរ៉ុបនៅក្នុងការបង្កើតវិធានថ្មីស្តីពីអភិបាលកិច្ចទិន្នន័យ ជំនួសឲ្យការព្យាយាមបង្កើតគំរូដូចៗគ្នាក្នុងពេលតែមួយនោះ វាកាន់តែជាក់ស្តែងថែមទៀត នៅក្នុងការប៉ុនប៉ងទទួលបានការព្រមព្រៀងជាឯកច្ឆន្ទលើក្របខណ្ឌ pan-Asia–Europe ឬ អភិបាលកិច្ចទិន្នន័យជាមុនសិន ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយរដ្ឋដៃគូរបស់ ASEM និង អាចត្រូវបានប្រើប្រាស់ជាឯកសារយោងរួម ដោយរបបគោលនយោបាយឌីជីថលនីមួយៗ។ ចំណុចសំខាន់ ក្របខណ្ឌនៃគោលនយោបាយនេះនឹងត្រូវបង្កើតឡើងដោយផ្អែកលើភាពសមហេតុផលផ្នែកសេដ្ឋកិច្ច ដើម្បីឲ្យទីផ្សារទទួលយក និង អនុវត្តវិធាននៃការប្រកួតប្រជែងថ្មីៗនៅក្នុងការធ្វើអាជីវកម្ម។

ដោយសារតែលក្ខណៈដ៏ទូលំទូលាយនៃទិន្នន័យស្តីពីសេដ្ឋកិច្ច និង សង្គម អ្នកបង្កើតគោលនយោបាយចាំបាច់ត្រូវតែធ្វើការពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីគោលនយោបាយបម្រុងល្អៗ ដែលនឹងអាចសម្រេចបាននូវលំហូរទិន្នន័យដោយសេរី។ Kimura et al. (២០១៩) បានស្នើឡើងនូវក្របខណ្ឌមួយសម្រាប់លំហូរទិន្នន័យដោយសេរីសម្រាប់សេដ្ឋកិច្ចឌីជីថល ដែលអាចជាឯកសារយោងដ៏មានប្រយោជន៍សម្រាប់រដ្ឋដៃគូ ASEM នៅក្នុងការស្វែងរកការព្រមព្រៀងជាឯកច្ឆន្ទ ដើម្បីគាំទ្រដល់លទ្ធភាពក្នុងការធ្វើប្រតិបត្តិការទៅវិញទៅមក នៅក្នុងរបបនៃគោលនយោបាយខុសៗគ្នា និង ជួយសម្រួលដល់លំហូរទិន្នន័យ និង ការចែករំលែកទិន្នន័យ។

មានគោលនយោបាយបម្រុងទុកយ៉ាងតិចប្រាំប្រភេទ ដែលផ្អែកលើគំរូមីក្រូសេដ្ឋកិច្ច។ ប្រភេទទីមួយរួមមាន គោលនយោបាយដែលលើកកម្ពស់ការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច និង ការសម្រួលពាណិជ្ជកម្ម ដែលផ្តល់អត្ថប្រយោជន៍ដល់លំហូរទិន្នន័យដោយសេរីផងដែរ ពីព្រោះខ្សែសង្វាក់តម្លៃ

របស់ពាណិជ្ជកម្មអេឡិចត្រូនិករួមបញ្ចូលលំហូរទំនិញ ព្រមទាំង លំហូរទិន្នន័យផងដែរ។ ដូច្នេះ គោលនយោបាយដែលមានផលជះដល់លំហូរទំនិញដោយសេរីអាចមានផលជះដល់លំហូរទិន្នន័យ ហើយគោលនយោបាយដែលមានផលជះដល់លំហូរទិន្នន័យក៏អាចមានផលជះដល់លំហូរទំនិញដែរ។ ឧទាហរណ៍៖ គេបានផ្តល់អនុសាសន៍ឲ្យថៃរក្សាទម្លាប់អនុវត្តនៃការបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក ដោយមិនគិតអាករ និង អនុវត្តគោលការណ៍មិនរើសអើស ដូចជា ជាតិដែលមានភាពអនុគ្រោះខ្លាំងជាងគេបំផុត និង ការប្រព្រឹត្តិនៅថ្នាក់ជាតិពីសំណាក់អង្គការពាណិជ្ជកម្មពិភពលោក ចំពោះការធ្វើពាណិជ្ជកម្មផលិតផលដែលមានខ្លឹមសារឌីជីថល ជាអន្តរជាតិ។ សកម្មភាពនានា ដូចជា ការទទួលយកហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក និង ការបញ្ជាក់យថាភាពតាមប្រព័ន្ធអេឡិចត្រូនិកជួយសម្រួលដល់ពាណិជ្ជកម្ម និង បង្កើតឥទ្ធិពលនៃមតិត្រឡប់លើការលើកកម្ពស់លំហូរទិន្នន័យដោយសេរី និង មានទំនុកចិត្ត។

ប្រភេទទីពីររួមមាន គោលនយោបាយដើម្បីកែតម្រូវ និង កាត់បន្ថយភាពបរាជ័យរបស់ទីផ្សារ ដែលបណ្តាលមកពីលក្ខណៈពិសេសរបស់សេដ្ឋកិច្ចដែលបញ្ជាដោយទិន្នន័យ ដូចជា សភាពខាងក្រៅរបស់បណ្តាញសេដ្ឋកិច្ចមាត្រដ្ឋានភាពអស៊ីមេទ្រីនៃព័ត៌មានឬការរួមបញ្ចូលគ្នានៃលក្ខខណ្ឌទាំងនេះ។ គោលនយោបាយដែលស្ថិតនៅក្រោមប្រភេទនេះ តាមធម្មតា មានទំនាក់ទំនងនឹងការប្រកួតប្រជែង ការការពារអ្នកប្រើប្រាស់ និង ការការពារកម្មសិទ្ធិបញ្ញា។ នៅក្នុងការអនុវត្តជាក់ស្តែង វានឹងមានប្រសិទ្ធភាពជាងនេះនៅក្នុងការកំណត់កញ្ចប់គោលនយោបាយដែលលុបចោលការបកស្រាយខុសដែលមានទំនាក់ទំនង និង មានប្រសិទ្ធភាពជាសកល ច្រើនជាងការបណ្តោយឲ្យរដ្ឋាភិបាលនីមួយៗមានប្រតិកម្មទៅនឹងហេតុការណ៍ជាក់លាក់នានា ដោយឧបាស្រ័យផ្នែកគោលនយោបាយ។

ទីបី វានឹងមានភាពចាំបាច់នៅក្នុងការធ្វើឲ្យគោលនយោបាយនានា មានភាពស៊ីគ្នានឹង គុណតម្លៃសង្គម និង ប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច ជាពិសេស ចំពោះបញ្ហា ដូចជា ការការពារឯកជនភាពជាដើម ដែលប្រទេស និង តំបន់នានា (ពោលគឺ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និង ប្រទេសចិន) បានកំណត់របបនិយ័តកម្មបីប្រភេទខុសៗគ្នា។ យោងតាមទស្សន វិស័យជាសកលហានិភ័យនៃភាពខុសគ្នាទាំងនេះ ដែលបង្កើតពិភពឌីជីថលដែលមានការបែងចែកគ្នាតាមផ្នែក លើកលែងតែមានកិច្ចខិតខំប្រឹងប្រែងតាមស្ថាប័នយ៉ាងខ្លាំងក្លា និង មានការសម្របសម្រួលនោះ ត្រូវបានធ្វើឡើងដើម្បីបង្កើតនិយាមអន្តរជាតិ និង ធ្វើសុខុដុមនីយកម្មអភិក្រមនីមួយៗ។ ស្រដៀងគ្នានេះដែរ គាលនយាហាយសុ្តីពីសន្តិសុខតាមបុ្រព័ន្ធអុីនធឺណិតគួរតមែានបំណងទទួលហានការសហាការជាអន្តរជាតិ ដើម្បីត្រៀម និង អនុវត្តវិធីសាស្ត្រប្រយុទ្ធប្រឆាំងនឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតឆ្លងព្រំដែន។

ប្រភេទទីបួនរួមបញ្ចូលគោលនយោបាយដែលមានបំណងផ្តល់ជូននូវលំហូរទិន្នន័យ និង អាជីវកម្មដែលទាក់ទងនឹងទិន្នន័យនៅក្នុងរបបគោលនយោបាយជាតិ។ កង្វល់ជាចម្បងរបស់គោលនយោបាយទាំងនោះគឺ វិធីរួមបញ្ចូលបច្ចេកវិទ្យាឌីជីថលថ្មីៗ គំរូអាជីវកម្មថ្មីៗ និង សេវាកម្មថ្មីៗចូលទៅក្នុងប្រព័ន្ធនិយ័តកម្ម។ ចំណុចនេះតម្រូវឲ្យមានវិធានការដើម្បីដោះស្រាយជាមួយបញ្ហាចម្រូងចម្រាសនានា ដូចជា ពន្ធដារ ជាដើម ដើម្បីធានាបាននូវធុរកិច្ចអនឡាញ និង អហ្វឡាញយ៉ាងសុក្រឹត ព្រមទាំងការប្រព្រឹត្តិដោយស្មើភាពគ្នារវាងតួអង្គនៃទីផ្សារក្នុងប្រទេស និង ទីផ្សារអន្តរជាតិផងដែរ។

ប្រភេទទីប្រាំ រួមបញ្ចូល វិធានការការពារ ចំពោះវិធានការលំហូរទិន្នន័យ ដែលស្រដៀងគ្នានឹងវិធានការការពារឧស្សាហកម្មដែលទើបនឹងបង្កើតថ្មីដែរ។ ប្រទេសនានាមានបំណងទទួលបានអត្ថប្រយោជន៍ពីគុណសម្បត្តិនៃការប្រកួតប្រជែង និង អត្ថប្រយោជន៍ផ្នែកសង្គមដែលបង្កើតឡើងដោយអាជីវកម្មដែលទាក់ទងនឹងទិន្នន័យថ្មីៗ ហើយប្រទេសមួយចំនួនប្រហែលជាមានបំណងថែរក្សាអាជីវកម្មរបស់ពួកគេដោយផ្ទាល់ ដោយប្រើគោលនយោបាយយុទ្ធសាស្ត្រជាតិ។ នៅក្នុងករណីនេះ ប្រព័ន្ធនិយ័តកម្មសកលត្រូវតែរួមបញ្ចូលភាពបត់បែនមួយចំនួន ដរាបណាគោលនយោបាយយុទ្ធសាស្ត្រដែលពាក់ព័ន្ធនោះមានភាពសមហេតុផលតាមផ្នែកសេដ្ឋកិច្ច។ នៅក្នុងសេដ្ឋកិច្ចឌីជីថល គោលនយោបាយ និង ទឡ្ហីករណ៍អំពីការការពារឧស្សាហកម្មដែលទើបនឹងបង្កើតថ្មី គួរតែអាចទាញយកមកវិញបានតាមរយៈប្រព័ន្ធដែលជួយសម្រួលដល់លំហូរទិន្នន័យ។

## អត្ថន័យផ្នែកគោលនយោបាយ

នៅក្នុងន័យទូលំទូលាយ សេដ្ឋកិច្ចឌីជីថលមិនមែនរួមបញ្ចូលតែពាណិជ្ជកម្មអេឡិចត្រូនិកតែប៉ុណ្ណោះទេ ប៉ុន្តែក៏រួមបញ្ចូលអាជីវកម្មដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ការប្រាស្រ័យទាក់ទង និង សេវាកម្មដែលពាក់ព័ន្ធនៅក្នុងផ្នែកនានានៃការផលិត ការលក់រាយ ការអប់រំ ការថែទាំសុខភាព ការដឹកជញ្ជូន ហិរញ្ញវត្ថុ ទេសចរណ៍ ប្រព័ន្ធផ្សព្វផ្សាយ និង ការកម្សាន្តផងដែរ។ សាច់រឿងជោគជ័យផ្នែកសេដ្ឋកិច្ចនៅអាស៊ី និង អឺរ៉ុបហាក់បីដូចជាមានកត្តាដូចគ្នាមួយចំនួន រួមបញ្ចូលទាំង ការធ្វើសមាហរណកម្មនៅក្នុងសេដ្ឋកិច្ចសកល តាមរយៈការចូលរួមនៅក្នុង GVCs ផងដែរ។ ដូច្នេះ ការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក និង ការចូលរួមរបស់សេដ្ឋកិច្ចមួយនៅក្នុង GVC អាចផ្តល់ភាពរឹងមាំទៅវិញទៅមក។

បន្ថែមពីលើកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យសមាហរណកម្មទីផ្សារ និង កិច្ចសហប្រតិបត្តិការអន្តរតំបន់មានស៊ីជម្រៅទៀតនោះ នៅតែមានចន្លោះសម្រាប់ការអភិវឌ្ឍគោលការណ៍ណែនាំអំពីគោលនយោបាយ និង យន្តការដើម្បីធ្វើឲ្យការធ្វើសុខដុមរូបនីយកម្មនៃបទប្បញ្ញត្តិរវាងអាស៊ី-អឺរ៉ុប និង ការធ្វើសេរីភាវូបនីយកម្មសេវាកម្មឆ្លងដែនឲ្យមានភាពល្អប្រសើរឡើងនៅទូទាំង ASEM។

កិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយទាំងនេះនឹងជួយសម្រួលដល់អាជីវកម្មអនឡាញបាន យ៉ាងមានប្រសិទ្ធភាព ជាពិសេសសកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន នៅក្នុងចំណោមរដ្ឋដៃគូរបស់ ASEM។

នៅក្នុងការដំណើរការរយៈពេលវែង ការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិកស្នើសុំឲ្យមានក្របខណ្ឌនិយ័តកម្មដែលមានភាពទូលំទូលាយជាងនេះ ដែលរួមបញ្ចូលបញ្ហាដែលពាក់ព័ន្ធជាច្រើន ចាប់ពីការការពារអតិថិជនរហូតដល់ការប្រកួតប្រជែង។ ទោះបីជាបញ្ហាភាគច្រើនមិនមែនជាបញ្ហាថ្មី និងធ្លាប់បានធ្វើនិយ័តកម្មពីមុនមកហើយក៏ដោយ ឌីជីថល នីយកម្ម បានណែនាំខ្លឹមសារ និង បញ្ហាប្រឈមថ្មីៗ។ ឧទាហរណ៍៖ ឯកាធិភាពនៃទិន្នន័យអាចបកស្រាយទៅជាអំណាចឯកាធិភាពបានយ៉ាងងាយស្រួល ហើយពន្ធដារនៃសេដ្ឋកិច្ចឌីជីថលក៏ត្រូវតែពិចារណាអំពីវិធីដោះស្រាយការធ្វើពាណិជ្ជកម្មឌីជីថល ការផ្លាស់ទីនៃទិន្នន័យ និង ការចែករំលែកព័ត៌មានផងដែរ។ អាស្រ័យហេតុនេះ ដំណោះស្រាយចំពោះបញ្ហាទាំងនេះត្រូវតែរួមបញ្ចូលការពិចារណាអំពីធាតុដែលមានបណ្តាលឲ្យមានបច្ចេកវិទ្យាថ្មីៗ ដោយមានការយល់ដឹងយ៉ាងជ្រៅជ្រះ ព្រមទាំងដំណោះស្រាយចំពោះលទ្ធផលនៃគោលនយោបាយជាសក្តានុពល ដូចដែលត្រូវបានបង្ហាញតាមរយៈអក្សរសិល្ប៍ផ្នែកសេដ្ឋកិច្ច ច្បាប់ និង សង្គមវិទ្យា។

ឧទាហរណ៍៖ ការការពារអតិថិជនបានយ៉ាងមានប្រសិទ្ធិភាព នៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិចនឹងជួយការពារផលប្រយោជន៍ និង សុខមាលភាពរបស់អ្នកប្រើប្រាស់ តាមរយៈការធានាបាននូវឧបាស្រ័យដែលអាចស្វែងរកបាន នៅក្នុងករណីមានវិវាទណាមួយ និង ពង្រឹងការផ្តល់រង្វាន់ដែលត្រូវផ្តល់ជូនអតិថិជន។ ឌីជីថលនីយកម្មធ្វើឲ្យមានការផ្តល់ព័ត៌មានដែលត្រឹមត្រូវអំពីផលិតផល និង សេវាកម្មនានាដែលត្រូវបានធ្វើពាណិជ្ជកម្ម និង បង្កើនតម្លាភាពនៃការការពារដែលត្រូវបានជូនដោយយុត្តាធិការរបស់អ្នកលក់។ ការការពារអតិថិជនសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែន ក៏នឹងតម្រូវឲ្យមានការបង្កើតប្រព័ន្ធដោះស្រាយវិវាទអនឡាញជាអន្តរជាតិ ព្រមទាំងអង្គភាពប៉ាន់ប្រមាណអំពីអនុលោមភាពថ្នាក់ជាតិផងដែរ ដើម្បីធ្វើការផ្ទៀងផ្ទាត់អំពីបទដ្ឋានដែលត្រូវបានតម្រូវ និង បទប្បញ្ញត្តិផ្នែកបច្ចេកទេសនៃផលិតផល និង សេវាកម្មដែលបានធ្វើពាណិជ្ជកម្ម។

នៅអាស៊ី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) កំពុងតែធ្វើផែនការបង្កើតក្របខណ្ឌដោះស្រាយវិវាទអនឡាញ នៅមុនឆ្នាំ២០២១ ដែលជាផ្នែកមួយនៃការអនុវត្តផែនការលម្អិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥។ រដ្ឋសមាជិកអាស៊ាន ក៏កំពុងតែអនុម័ត "ការប្រព្រឹត្តិថ្នាក់ជាតិ" នៅក្នុងការប៉ាន់ប្រមាណអំពីអនុលោមភាព ដើម្បីជួយសម្រួលសង្គតភាព និង ការទទួលស្គាល់ទៅវិញទៅមកលើការធ្វើតេស្ត និង ការបញ្ជាក់ដោយអង្គភាពប៉ាន់ប្រមាណអំពីអនុលោមភាពដែលមានគុណវុឌ្ឍិ នៅក្នុងប្រទេសខុសៗគ្នាផងដែរ។

រដ្ឋសមាជិកអាស៊ានបានអនុម័តក្របខណ្ឌអភិបាលកិច្ចទិន្នន័យឌីជីថលរបស់អាស៊ាន នៅឆ្នាំ ២០១៨ ហើយយន្តការលំហូរទិន្នន័យឆ្លងព្រំដែនអាស៊ាន កំពុងតែត្រូវបានរៀបចំឡើងនាពេលបច្ចុប្បន្ន។

នៅអឺរ៉ុប សិទ្ធិមូលដ្ឋាននៃឯកជនភាព និង ការការពារទិន្នន័យ ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់របស់ EU។[13] នៅឆ្នាំ២០១២ គណៈកម្មការអឺរ៉ុបបានអនុវត្តកញ្ចប់កំណែទម្រង់ការការពារទិន្នន័យ ដើម្បីពង្រឹងសិទ្ធិឯកជនភាពរបស់ពលរដ្ឋនៅក្នុងយុគសម័យឌីជីថល។ បទប្បញ្ញត្តិស្ដីពីការការពារទិន្នន័យទូទៅ (GDPR) បានចាប់ផ្ដើមដំណើរការនៅក្នុងឆ្នាំ២០១៨ ដែលជាផ្នែកមួយនៃរបបការពារទិន្នន័យថ្មីរបស់ EU ដែលផ្ដោតលើការការពារ ការដំណើរការទិន្នន័យផ្ទាល់ខ្លួន និង ការផ្លាស់ទីនៃទិន្នន័យទាំងនោះដោយសេរី។ GDPR ត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ ចំពោះការដំណើរការទិន្នន័យផ្ទាល់ខ្លួន ទោះបីជានៅខាងក្នុង ឬ នៅខាងក្រៅ EU ក៏ដោយ និង មានផលជះលើសកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិកស្ទើរតែទាំងអស់ ដែលជាប់ពាក់ព័ន្ធនឹងអាជីវកម្ម ស្ថាប័ន ឬ អង្គភាពណាមួយផ្សេងទៀតរបស់ EU។

លក្ខខណ្ឌតម្រូវនៃលំហូរទិន្នន័យឆ្លងព្រំដែនអាស៊ាន ពាក់ព័ន្ធនឹងការការពារទិន្នន័យ នឹងមិនដូចគ្នានឹងលក្ខខណ្ឌតម្រូវរបស់ EU GDPR នោះទេ ពីព្រោះមានភាពខុសគ្នាជាច្រើនរវាងតំបន់ទាំងនេះនៅក្នុងវិស័យមួយចំនួន។ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិក រវាងអាស៊ាន-EU ភាគីទាំងពីរត្រូវតែសម្រេចបាននូវលទ្ធភាពក្នុងការដំណើរការទៅវិញទៅមកនៃរបបទិន្នន័យទាំងពីរ។ ក្រៅពីអាស៊ាន និង EU រដ្ឋដៃគូរបស់ ASEM ដទៃទៀត ក៏មានច្បាប់ការពារទិន្នន័យក្នុងមូលដ្ឋានដែលបានចូលជាធរមានរួចហើយ ឬ ស្ថិតនៅក្នុងដំណើរការនៃការអនុវត្ត និងមានក្រុមហ៊ុនពហុជាតិជាច្រើនបានអនុវត្តកាតព្វកិច្ចផ្នែកឯកជនភាពជាសកល និង កាតព្វកិច្ចផ្នែកសន្តិសុខផងដែរ។ អាស្រ័យហេតុនេះ ការសម្រេចបាននូវលទ្ធភាពក្នុងការដំណើរការទៅវិញទៅមក អាចជាបញ្ហាប្រឈមមួយនៅក្នុងការបង្កើតគោលនយោបាយសម្រាប់ ASEM។

សម្រាប់ថ្នាក់ដឹកនាំរបស់ ASEM ការស្វែងរកដំណោះស្រាយដើម្បីសម្រេចបានលទ្ធភាពក្នុងការដំណើរការទៅវិញទៅមករវាង pan-ASEM មានប្រសិទ្ធភាពជាង អាស្រ័យហេតុនេះ ពួកគេមានបំណងជ្រើសរើសជម្រើសផ្សេងទៀត ដោយទុកឲ្យប្រទេសរហូតដល់ជាង ៥០ ប្រទេសផ្សេងទៀតដោះស្រាយបញ្ហានេះជាទ្វេភាគី។ នៅក្នុងករណីនេះ តួនាទីរបស់ ASEM ក្នុងនាមជាវេទិកាមួយសម្រាប់កិច្ចសន្ទនាអាស៊ី-អឺរ៉ុប នឹងមានសារសំខាន់យ៉ាងខ្លាំងដើម្បីបញ្ចៀសបញ្ហា “ចាក់ស្រេះ” ដែលអាចបណ្ដាលមកពីអភិក្រមទ្វេភាគី។

---

[13] ធម្មនុញ្ញនៃសិទ្ធិមូលដ្ឋានរបស់ EU រួមបញ្ចូលសិទ្ធិទទួលបានឯកជនភាព (មាត្រា ៧) និង សិទ្ធិទទួលបានការការពារទិន្នន័យ (មាត្រា ៨)។

ស្រដៀងគ្នានេះដែរ វាមានតម្លៃនៅក្នុងការកត់សម្គាល់អំពីសារសំខាន់នៃការទទួលយករបស់ទីផ្សារ។ ប្រព័ន្ធនិយ័តកម្មណាមួយដែលត្រូវបានស្នើឡើង ត្រូវតែបានទទួលយកដោយទីផ្សារ និង ត្រូវបានអនុម័តយ៉ាងទូលំទូលាយដោយវិស័យឯកជននៅក្នុងអាជីវកម្មប្រចាំថ្ងៃ បើមិនដូច្នោះទេវាអាចនឹងបរាជ័យនៅក្នុងការសម្រេចគោលដៅដើមរបស់ខ្លួន នៅក្នុងការលើកកម្ពស់សេដ្ឋកិច្ចឌីជីថល និង ពាណិជ្ជកម្មអេឡិចត្រូនិក។ ការការពារមតិយោបល់របស់វិស័យឯកជននៅក្នុងវដ្តនៃការរៀបចំគោលនយោបាយ និង ការបង្កើតវិធាន នឹងមានសារប្រយោជន៍ ហើយវាមានភាពចាំបាច់នៅក្នុងការធ្វើឲ្យមានតុល្យភាពរវាងគំនិតរបស់ក្រុមហ៊ុនយក្សផ្នែកឌីជីថល និង គំនិតរបស់ MSMEs។ (Chen ២០២១)

ជាចុងក្រោយ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថា ភាពងាយបត់បែននៃការអនុវត្តនឹងជួយសម្រួលដល់ការសន្និដ្ឋានអំពីកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ។ ASEM រួមបញ្ចូល ប្រទេសមួយចំនួនដែលមានសេដ្ឋកិច្ចជឿនលឿនបំផុតនៅលើពិភពលោក ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដែលមានកំណើនសេដ្ឋកិច្ចឆាប់រហ័សបំផុត និង ប្រទេសអភិវឌ្ឍន៍តិចតួចបំផុតមួយចំនួន។ ការកំណត់វិធានជាអន្តរជាតិស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកត្រូវតែពិចារណាអំពីចំណុចនេះដើម្បីពង្រឹងបរិយាប័ន្ន។ គេមិនចាំបាច់កាត់បន្ថយលក្ខខណ្ឌតម្រូវសម្រាប់ប្រទេសដែលមានការអភិវឌ្ឍទាបជាងនោះទេ ប៉ុន្តែពួកគេអាចអនុញ្ញាតឲ្យមានរយៈពេលវែងជាងនៅក្នុងការអនុវត្តកិច្ចព្រមព្រៀង និង អនុម័តវិធានថ្មីៗ។

## សេចក្តីបញ្ចប់

សេដ្ឋកិច្ចឌីជីថលផ្តល់ជូនប្រទេសនានានូវឱកាសថ្មីៗសម្រាប់ភាពរីកចម្រើន និង ពុំមានករណីលើកលែងចំពោះប្រទេសនានានៃ ASEM នោះទេ។ របបគោលនយោបាយដែលពាក់ព័ន្ធត្រូវតែគាំទ្រដល់ទីផ្សារ ក្នុងការទទួលស្គាល់អំពីសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ មានតម្រូវការនៃស្ថានប្រព័ន្ធដែលអំណោយផលដល់ផ្នែក ឌីជីថល ដែលរួមបញ្ចូលគោលនយោបាយគាំទ្រនានា ជាពិសេសគោលនយោបាយដែលពង្រឹងការតភ្ជាប់ទាំងនៅក្នុងពិភពរូបវ័ន្ត និង លំហបច្ចេកវិទ្យា ដើម្បីត្រួសត្រាយផ្លូវសម្រាប់បរិវត្តកម្មឌីជីថល និង ការលើកកម្ពស់អាជីវកម្មអនឡាញ។

ការតភ្ជាប់ផ្នែកទិន្នន័យ គឺជាលក្ខខណ្ឌតម្រូវមូលដ្ឋានដើម្បីសម្រេចបាននូវភាពជោគជ័យផ្នែកសេដ្ឋកិច្ចនៅក្នុងយុគសម័យឌីជីថល។ ASEM ត្រូវតែធ្វើការជាមួយគ្នាដើម្បីជួយសម្រួលដល់លំហូរទិន្នន័យដោយសេរី និង មានទំនុកចិត្ត ដែលទទួលបានការគាំទ្រពីគោលនយោបាយគាំទ្រ ដែល (i) លើកកម្ពស់ការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច និង ការសម្រួលពាណិជ្ជកម្ម (ii) កែតម្រូវ និង កាត់បន្ថយភាពបរាជ័យរបស់ទីផ្សារ (iii) ធ្វើឲ្យគុណតម្លៃសង្គម មានភាពស៊ីសង្វាក់គ្នាទៅនឹង

ប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច (iv) ផ្តល់ជូននូវលំហូរទិន្នន័យ និង អាជីវកម្មដែលទាក់ទងនឹងទិន្នន័យនៅក្នុងរបបគោលនយោបាយជាតិនិង(v)គាំទ្រដល់ពាណិជ្ជកម្មនិងការវិនិយោគលក្ខណៈយុទ្ធសាស្ត្រ។

ក្រៅពីកិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយពាក់ព័ន្ធនឹងការតភ្ជាប់ទិន្នន័យហើយនោះ រដ្ឋាភិបាលគួរតែពិចារណាអំពីវិធីបង្កើតមជ្ឈដ្ឋានទីផ្សារដែលមានអំណោយផលដល់ការអភិវឌ្ឍ ដើម្បីគាំទ្រពាណិជ្ជកម្មអេឡិចត្រូនិក ពន្លឿនដំណើរការនៃការអនុម័តលើវិស័យឌីជីថល វិនិយោគ លើផ្នែកភ័ស្តុភារ និង ហេដ្ឋារចនាសម្ព័ន្ធ លើកកម្ពស់ការអភិវឌ្ឍវិស័យសេវាកម្ម និង ផ្តល់ទំនិញសាធារណៈដើម្បីពង្រឹងមូលធនមនុស្ស និង ជំនាញការងារ។

# ឯកសារយោង

Baldwin, R. (2016), The Great Convergence: Information Technology and the New Globalization. Cambridge, MA: The Belknap Press of Harvard University Press.

Chen, L. (2017), 'Developing Asia in the Era of Cross-Border E-commerce', Economic Research Institute for ASEAN and Southest Asia (ERIA) Discussion Papers, DP-2017-11, ERIA: Jakarta.

Chen, L. (2019), 'ASEAN in the Digital Era: Enabling Cross-Border E-commerce', in L. Chen and F. Kimura (eds.) Developing the Digital Economy in ASEAN. Abingdon; New York, NY: Routledge, pp. 259–275.

Chen, L. (2020a), 'Improving Digital Connectivity for E-Commerce: A Policy Framework and Empirical Note for ASEAN', ERIA Discussion Papers, DP-2020-1, ERIA: Jakarta.

Chen, L. (2021), 'ASEM's Role in Promoting Asia– Europe E-Commerce', ERIA Policy Brief, ERIA: Jakarta. Forthcoming.

Kimura, F. (2018), "Unbundlings' and Development Strategies in ASEAN: Old Issues and New Challenges', Journal of Southeast Asian Economies, 35(1), pp. 13–21.

Kimura, F. and L. Chen (2018), 'Value Chain Connectivity in Indonesia: The Evolution of Unbundlings', Bulletin of Indonesian Economic Studies, 54(2), pp. 165–192.

Kimura, F. et al. (2019), 'The Digital Economy for Economic Development: Free Flow of Data and Supporting Policies', Policy Brief for T20 Summit 2019.

6

# គំរូនៃកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារនៃសេដ្ឋកិច្ចឌីជីថល របស់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប

## ឌីជីថលនីយកម្ម និង បច្ចេកវិទ្យាថ្មីៗ

IRMA MOSQUERA VALDERRAMA

### សេចក្តីផ្តើម

គោលបំណងទូទៅរបស់ជំពូកនេះគឺ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលទ្វីបអាស៊ី និង អឺរ៉ុបត្រូវប្រឈមមុខនៅក្នុងការតភ្ជាប់ផ្នែកឌីជីថល នៅក្នុងវិស័យពន្ធដារ និង ជួយសម្រួលដល់ការផ្លាស់ប្តូរទម្លាប់អនុវត្តល្អៗនៅក្នុងក្របខណ្ឌនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ស្តីពីការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការ។

ជំពូកនេះអនុវត្តតាមសេចក្តីថ្លែងការណ៍របស់ប្រធាននៅក្នុងកិច្ចប្រជុំ ASEM ឆ្នាំ២០១៨ និង កថាខណ្ឌទី ១៥ ជាចម្បង ដើម្បីដោះស្រាយតម្រូវការការតភ្ជាប់ផ្នែកឌីជីថល តាមរយៈទំនុកចិត្ត និង ភាពជឿជាក់លើមជ្ឈដ្ឋានបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT)។ ជំពូកនេះក៏អនុវត្តតាមកថាខណ្ឌទី ២៦ ដែលចែងអំពីកំណើននៃអត្ថប្រយោជន៍ដែលទទួលបានពីសេដ្ឋកិច្ចឌីជីថល និង តម្រូវការក្នុងការស្វែងរកដំណោះស្រាយ ដើម្បីដោះស្រាយផលប៉ះពាល់នៃឌីជីថលនីយកម្មលើប្រព័ន្ធពន្ធដារអន្តរជាតិផងដែរ។វត្ថុបំណងទាំងនេះក៏ស្របគ្នានឹងរបៀបវារៈឆ្នាំ២០៣០ ស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ផងដែរ ជាពិសេស គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ១៧.១ ស្តីពីការប្រមូលផ្តុំធនធាននៅក្នុងប្រទេស និង SDG ១៧.១៦ ស្តីពីភាពជាដៃគូសកលដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ឌីជីថលនីយកម្ម និង បច្ចេកវិទ្យាថ្មីៗផ្តល់ឱកាសថ្មីៗសម្រាប់ផ្នែករដ្ឋបាលពន្ធដារ "នៅក្នុងការគ្រប់គ្រងអនុលោមភាព ដោះស្រាយបដិលោមភាព និង ការពារមូលដ្ឋានពន្ធរបស់ពួកគេបានកាន់តែល្អប្រសើរឡើង" (OECD ២០១៩a:២២)។ តាមរយៈឌីជីថលនីកម្ម រដ្ឋបាលពន្ធដារអាចទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ថ្មីៗ (ឧ. ប្រាជ្ញាសិប្បនិម្មិត និង វិធីសាស្ត្រវិភាគទិន្នន័យ) ដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួន និង ទិន្នន័យអាជីវកម្ម។ បច្ចេកវិទ្យា

ទាំងនេះអាចបង្កើនតម្លាភាព និង ពង្រឹងការប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ និង ការក្លែងបន្លំពន្ធ។ កំណើននៃតម្លាភាពនេះអាចអនុញ្ញាតឲ្យបណ្តាប្រទេសនានាបង្កើនការប្រមូលផ្តុំធនធានក្នុងប្រទេស (SDG ១៧.១)។

របាយការណ៍របស់វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីពន្ធដារ និង ការអភិវឌ្ឍ (Araki និង Nakabayashi ២០១៨:១២៨) បានសង្កត់ធ្ងន់លើតម្រូវការនៃការផ្លាស់ប្តូរទស្សនៈ និង បទពិសោធន៍ពីមន្ត្រីរដ្ឋបាលពន្ធដារដទៃទៀត ដែលមានបញ្ហាប្រឈម និង បញ្ហាប្រហាក់ប្រហែលគ្នា។ អាស្រ័យហេតុនេះ ការផ្លាស់ប្តូរឧត្តមានុវត្តរវាងប្រទេសនានានៅក្នុងតំបន់ និង នៅក្នុងចំណោមតំបន់នានា (អឺរ៉ុប និង អាស៊ី) អាចរួមចំណែកដល់ការកសាងភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (SDG ១៧.១៦)។

ជំពូកនេះត្រូវបានរៀបចំរចនាសម្ព័ន្ធដូចខាងក្រោម។ ផ្នែកទីមួយនឹងលើកឡើងអំពី ឌីជីថលនីយកម្ម និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដោយផ្នែករដ្ឋបាលពន្ធដារ រួមបញ្ចូលទាំងការប្រមូលព័ត៌មានពន្ធដារ ប្រភពបែបប្រពៃណី និង ប្រភពឌីជីថលផងដែរ។ ផ្នែកទីពីរនឹងលើកឡើងអំពីលិខិតុបករណ៍ដែលត្រូវបានប្រើប្រាស់ដោយផ្នែករដ្ឋបាលពន្ធដារ ដើម្បីការពារការជំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិនិងការការពារសិទ្ធិរបស់អ្នកជាប់ពន្ធ។ផ្នែកទីបីនឹងទាញសេចក្តីសន្និដ្ឋានអំពីចំណាប់អារម្មណ៍ និង អនុសាសន៍ចុងក្រោយសម្រាប់បណ្តាញ ASEM Network។

## ឌីជីថលនីយកម្ម និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដោយផ្នែករដ្ឋបាលពន្ធដារ

### ឌីជីថលនីយកម្ម និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ

ដោយសារតែមានវិធីថ្មីៗនៅក្នុងការប្រមូលព័ត៌មានពន្ធដារ (ពោលគឺ ប្រភពឌីជីថល) នៅពេលនេះ អាជ្ញាធរពន្ធដារអាចទទួលបានទិន្នន័យកាន់តែច្រើន រួមបញ្ចូលទាំង "ប្រតិបត្តិការ និង ទិន្នន័យប្រាក់ចំណូល, ទិន្នន័យអាកប្បកិរិយាដែលបង្កើតឡើងតាមរយៈអន្តរកម្មរវាងអ្នកជាប់ពន្ធ និង រដ្ឋបាលពន្ធដារ, ទិន្នន័យប្រតិបត្តិការស្តីពីភាពជាកម្មសិទ្ធិ អត្តសញ្ញាណ និង ទីតាំង, និង ទិន្នន័យនៃប្រភពបើកចំហរ ដូចជា ប្រព័ន្ធផ្សព្វផ្សាយសង្គម និង ការផ្សាយពាណិជ្ជកម្ម ជាដើម។ ទិន្នន័យអាចត្រូវបានប្រើប្រាស់ជាប្រភពនីមួយៗ ឬ ប្រភពជាច្រើនរួមបញ្ចូលគ្នា ដើម្បីអនុញ្ញាតឲ្យមានការរាយការណ៍មួយផ្នែក ឬ ទាំងស្រុងអំពីប្រាក់ចំណូលជាប់ពន្ធ និង បើកចំហរការរាយការណ៍មិនគ្រប់ជ្រុងជ្រោយ ការគេចពន្ធ ឬ ការក្លែងបន្លំពន្ធ។ វាក៏អាចត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់

កាន់តែច្បាស់អំពីអាកប្បកិរិយារបស់អ្នកជាប់ពន្ធ ដើម្បីវាស់វែងផលប៉ះពាល់នៃសកម្មភាពនានានិង ដើម្បីសម្គាល់អន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្លាំងជាងគេបំផុត ទាំងអន្តរាគមន៍បែបប្រតិសកម្ម និង បែបប្រតិកម្មផងដែរ" (OECD ២០១៩b:៧)។

ដំណើរការឌីជីថលនីយកម្មនេះ "កំពុងតែកែប្រែវិធីដែលរដ្ឋាភិបាលអាចប្រមូល ដំណើរការ និង ធ្វើសកម្មភាពលើព័ត៌មានបាន" (Gupta et al. ២០១៧:១) អាស្រ័យហេតុនេះ រដ្ឋាភិបាល គួរតែបង្កើត និង អនុវត្តគោលនយោបាយថ្មីៗដើម្បីដោះស្រាយលើឌីជីថលនីយកម្ម និង ផ្នែកពន្ធដារ។ ដើម្បីវិភាគទិន្នន័យដែលប្រមូលបាន ផ្នែករដ្ឋបាលពន្ធដារកំពុងតែប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ថ្មីៗ (ឧ. ប្រាជ្ញាសិប្បនិម្មិត និង វិធីសាស្ត្រវិភាគទិន្នន័យ) ដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួន និង ទិន្នន័យអាជីវកម្ម។ បច្ចេកវិទ្យាទាំងនេះអាចបង្កើនតម្លាភាព និង ពង្រឹងការប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ និង ការក្លែងបន្លំពន្ធ។[14]

ដូចដែលបានគូសបញ្ជាក់ដោយវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (Araki និង Nakabayashi ២០១៨:១៣) រដ្ឋបាលពន្ធដារដែលមានប្រសិទ្ធភាពនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក តម្រូវឲ្យមាន "ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានយ៉ាងទូលំទូលាយដើម្បីប្រមូល និង ដំណើរការព័ត៌មានរបស់អ្នកជាប់ពន្ធ ធ្វើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ផ្អែកតាមការវិភាគអំពីហានិភ័យ ការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិរវាងទីភ្នាក់ងាររដ្ឋាភិបាល និង ការផ្តល់ព័ត៌មានបានទាន់ពេលវេលាដើម្បីគាំទ្រដល់ការសម្រេចចិត្តលើការគ្រប់គ្រង និង ការបង្កើតគោលនយោបាយពន្ធដារ"។ អាស្រ័យហេតុនេះ អង្គការក្នុងតំបន់ និងអង្គការអន្តរជាតិ និង ប្រទេសនានាដែលស្ថិតនៅក្នុងបណ្តាញ ASEM គួរតែដឹងអំពីបញ្ហាប្រឈមដែលរដ្ឋបាលពន្ធដារត្រូវប្រឈមមុខ ដើម្បីជួយសម្រួលដល់ការប្រមូលព័ត៌មានពន្ធដារតាមរយៈប្រភពបែបប្រពៃណី និង ប្រភពឌីជីថល ព្រមទាំង ភាពចាំបាច់របស់

[14] ឧទាហរណ៍៖ Microsoft និង PwC (២០១៨) លើកឧទាហរណ៍ដូចខាងក្រោម ពាក់ព័ន្ធនឹងវិធីដែលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ថ្មីៗ រួមទាំង ការវិភាគកម្រិតខ្ពស់ផងដែរ អាចត្រូវបានប្រើប្រាស់ដើម្បី៖

- "កំណត់វិធានដើម្បីសម្គាល់ និង កំណត់ប្រភេទចម្លងការក្លែងបន្លំ
- ស្វែងរកមូលដ្ឋានទិន្នន័យរបស់អ្នកក្លែងបន្លំដែលបានដឹង ឬ ជាប់សង្ស័យ ដោយប្រើអាល់កូរីតសម្រាប់ ផ្គូរផ្គងទិន្នន័យ
- ប្រើប្រាស់ការវិភាគស្ថិតិដើម្បីរកឃើញករណីដែលរចនាបថផ្នែកអាកប្បកិរិយាមានលក្ខណៈខុសគ្នាពីវិធាន
- សម្គាល់អាកប្បកិរិយានៃការក្លែងបន្លំដែលមានភាពស្មុគស្មាញ និង លាក់បាំងបានយ៉ាងល្អ ដូចជា បណ្តាញប្រសាទ ដើមឈើនៃការសម្រេច, ការសន្និដ្ឋានផ្អែកលើពហុប្រភព។ល។
- គិតអំពីលក្ខណៈនៃទំនាក់ទំនងរវាងអង្គភាពនីមួយៗ
- សម្គាល់ឃើញរចនាបថ និង អសង្គតភាពដែលត្រូវបានលាក់បាំងនៅក្នុងទិន្នន័យដែលគ្មានរចនាសម្ព័ន្ធ ដូចជា ទម្រង់ទាមទារប្រាក់ ឬ វិក្កយបត្រអេឡិចត្រូនិក ជាដើម"។ (Microsoft និង PwC, 2018: 25)

រដ្ឋបាលពន្ធដារនៅក្នុងការពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យ និង កែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ពួកគេផងដែរ។ ធាតុទាំងពីរនេះនឹងត្រូវលើកឡើងដូចមាននៅខាងក្រោម។

## ការប្រមូលព័ត៌មានពន្ធដារ៖ ប្រភពបែបប្រពៃណី និង ប្រភពឌីជីថល

រដ្ឋបាលពន្ធដារមានបំណងបង្កើនតម្លាភាព និង ដោះស្រាយការក្លែងបន្លំពន្ធ និង ការគេចពន្ធតាមរយៈការប្រើប្រាស់ប្រភពបែបប្រពៃណី និង ប្រភពឌីជីថល ដើម្បីទទួលបានព័ត៌មានរបស់អ្នកជាប់ពន្ធ។ ឧទាហរណ៍មួយចំនួនរួមមាន ការប្រើប្រាស់កិច្ចព្រមព្រៀងទ្វេភាគី និង ពហុភាគីដើម្បីផ្លាស់ប្តូរព័ត៌មានពន្ធដារ ការជួយសម្រួលដល់ការផ្លាស់ប្តូរទិន្នន័យអំពីប្រតិបត្តិការតាមរយៈវេទិកាអនឡាញ ទិន្នន័យដែលទទួលបានពីការទូទាត់ប្រាក់ឌីជីល និង វិក្កយបត្រអេឡិចត្រូនិក និង ទិន្នន័យពន្ធដារដែលទទួលបានប្រព័ន្ធផ្សព្វផ្សាយ អ៊ីនធឺណិត និង តតិយជន នៅក្នុងចំណោមប្រភពដទៃទៀត។

### ប្រភពបែបប្រពៃណីដើម្បីប្រមូលព័ត៌មានពន្ធដារ

នៅកម្រិតអន្តរជាតិ បទដ្ឋាននៃការផ្លាស់ប្តូរព័ត៌មាន និង ចាប់តាំងពីឆ្នាំ២០១៣ មក បទដ្ឋាននៃការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិបានជួយសម្រួលដល់ការប្រមូលព័ត៌មាន តាមរយៈរដ្ឋបាលពន្ធដារ។ ការផ្លាស់ប្តូរព័ត៌មានបានលាតសន្ធឹងទៅទូទាំងពិភពលោក ដែលជាចម្បង បណ្តាលមកពីការចូលរួមរបស់ប្រទេសនានានៅក្នុងវេទិកាតម្លាភាពសកល[15] និង ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី (ឧ. សន្ធិសញ្ញាស្តីពីពន្ធដារ និង កិច្ចព្រមព្រៀងផ្លាស់ប្តូរព័ត៌មានពន្ធដារ) និង លិខិតូបករណ៍ពហុភាគី (ឧ. អនុសញ្ញាពហុភាគីស្តីពីជំនួយផ្នែករដ្ឋបាលទៅវិញទៅមកចំពោះបញ្ហាពន្ធដារ និង កិច្ចព្រមព្រៀងស្តីពីអាជ្ញាធរមានសមត្ថកិច្ចពហុភាគីចំពោះបទដ្ឋានសកលស្តីពីការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិ)។

ការអភិវឌ្ឍជាអន្តរជាតិចំនួនពីរ ដែលបង្កើនចំនួនព័ត៌មានដែលត្រូវបានផ្លាស់ប្តូរ រួមមាន៖ (i) សេចក្តីណែនាំដោយសហរដ្ឋអាមេរិក (US) អំពីច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនី

[15] នៅពេលសរសេរ (ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ វេទិកាតម្លាភាពសកល មានសមាជិកចំនួន ១៦១ និង អ្នកសង្កេតការណ៍ចំនួន ១៩ (អង្គការប្រចាំតំបន់ និង អង្គការអន្តរជាតិ)។ នៅក្នុងចំណោមប្រទេសសមាជិក ASEM ទាំង ២១ នៅទ្វីបអាស៊ី មានតែបួនប្រទេសប៉ុណ្ណោះដែលមិនបានចូលរួមនៅក្នុងវេទិកានេះ (ពោលគឺ ប្រទេសបង់ក្លាដេស ប្រទេសប្រ៊ុយណេដារូសាឡឹម ប្រទេសឡាវ និង ប្រទេសមីយ៉ាន់ម៉ា)។ គ្រប់ប្រទេសនៅអឺរ៉ុបទាំងអស់កំពុងតែចូលរួមនៅក្នុងវេទិកាតម្លាភាពសកលនេះ។

បរទេស (FATCA) ដើម្បីផ្លាស់ប្តូរព័ត៌មានស្តីពីគណនីហិរញ្ញវត្ថុរបស់អ្នកជាប់ពន្ធនៃ US[16] និង (ii) សេចក្តីណែនាំអំពីគម្រោងលុបបំបាត់មូលដ្ឋានពន្ធ និងការផ្ទេរអត្ថប្រយោជន៍ BEPS[17] រួមបញ្ចូលទាំងសកម្មភាពចំនួនបីដែលជួយសម្រួលដល់ការប្រមូល និង ការផ្លាស់ប្តូរព័ត៌មាននៅក្នុងចំណោមប្រទេសនានាផងដែរ៖ សកម្មភាពទី ៥ លើកឡើងអំពី ទម្លាប់អនុវត្តពន្ធដារដែលបង្កក្តីអន្តរាយ និង ការផ្លាស់ប្តូរសេចក្តីសម្រេចនានា, សកម្មភាពទី ១២ លើកឡើងអំពីការបើកចំហរជាចាំបាច់ ចំពោះគ្រោងការណ៍រៀបចំផែនការពន្ធដារដាច់ខាត, និង សកម្មភាពទី ១៣ លើកឡើងអំពីឯកសារកំណត់តម្លៃផ្ទេរ និង ការរាយការណ៍តាមប្រទេស។[18] ការផ្លាស់ប្តូររបាយការណ៍រវាងប្រទេស នៅពេលនេះ អាចធ្វើឡើងបាននៅក្នុងប្រទេសនានាដែលបានធ្វើឲ្យទំនាក់ទំនងនៃការផ្លាស់ប្តូរមានភាពសកម្ម តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីអាជ្ញាធរមានសមត្ថកិច្ចពហុភាគី (MCAA)។[19]

---

16 FATCA ត្រូវបានអនុវត្តចំពោះរបាយការណ៍របស់ស្ថាប័នហិរញ្ញវត្ថុ (ពោលគឺ ធនាគារ) នៅទូទាំងពិភពលោក ដែលត្រូវដាក់ជូនផ្នែកសេវាប្រាក់ចំណូលផ្ទៃក្នុងសម្រាប់គណនីបរទេស ដែលកាន់កាប់ដោយអ្នកជាប់ពន្ធនៃ US។ FATCA មានបំណងដោះស្រាយការគេចពន្ធនៅក្រៅប្រទេស និង បដិលោមភាពដោយអ្នកជាប់ពន្ធនៃ US ចំពោះគណនីបរទេស។ សូមមើល https://www.irs.gov/businesses/corporations/foreign-account-tax-compliance-act-fatca (ចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

17 គម្រោង BEPS ត្រូវបានផ្តួចផ្តើមគំនិតដោយ OECD ដែលមានអំណាចផ្នែកនយោបាយរបស់ G20 ដោយមានបំណងដោះស្រាយការលុបបំបាត់មូលដ្ឋានពន្ធ និងការផ្ទេរអត្ថប្រយោជន៍ដោយពហុជាតិ។ គម្រោង BEPS មានសកម្មភាពចំនួន ១៥ ហើយសកម្មភាពចំនួន ៤ ក្នុងចំណោមនោះ (សកម្មភាពទី៥ ទី៦ ទី១៣ និង ទី១៤) គឺជាបទដ្ឋានអប្បបរមា។ ប្រទេសដែលមិនមែនជា OECD ប្រទេសដែលមិនមែនជា G20 អាចចូលរួមជាសមាជិកនៃក្របខណ្ឌបរិយាប័ន្ន BEPS និង ប្តេជ្ញាចិត្តអនុវត្តបទដ្ឋានអប្បបរមា BEPS។ នៅពេលសរសេរនេះ ក្របខណ្ឌបរិយាប័ន្ន BEPS មានយុត្តាធិការពន្ធដារចំនួន ១៣៧ កន្លែង។ ក្នុងចំណោមប្រទេសដៃគូទាំង ២១ ប្រទេសនៅអាស៊ី នៅក្នុង ASEM មានតែប្រាំប្រទេសប៉ុណ្ណោះដែលមិនបានចូលរួមនៅក្នុងក្របខណ្ឌបរិយាប័ន្ន (ពោលគឺ ប្រទេសបង់ក្លាដេស ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសមីយ៉ាន់ម៉ា និង ប្រទេសហ្វីលីពីន)។ គ្រប់ប្រទេសទាំងអស់នៅអឺរ៉ុបកំពុងតែចូលរួមនៅក្នុងក្របខណ្ឌបរិយាប័ន្ន BEPS។

18 ការអនុម័តលើវិធាន និង បទដ្ឋានពន្ធដារអន្តរជាតិ ដែលលើកឡើងអំពីការផ្លាស់ប្តូរព័ត៌មានទាំងនេះ និង គម្រោង BEPS ក៏ត្រូវបានលើកឡើងក្នុងនាមជាការអភិវឌ្ឍដែលអំណោយផលដល់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី និង ប៉ាស៊ីហ្វិកផងដែរ ដោយ Highfield (២០១៧) នៅក្នុងសេចក្តីសង្ខេបគ្រួសៗអំពីអភិបាលកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

19 នៅពេលសរសេរនេះ ក្នុងចំណោមប្រទេសដៃគូទាំង ២១ ប្រទេសនៅអាស៊ី នៅក្នុង ASEM មានតែប្រាំពីរប្រទេសប៉ុណ្ណោះដែលមិនបានចុះហត្ថលេខាលើ MCAA (ពោលគឺ ប្រទេសបង់ក្លាដេស ប្រទេសព្រុយណេដារូសាឡឹម ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសម៉ុងហ្គោល ប្រទេសមីយ៉ាន់ម៉ា ប្រទេសហ្វីលីពីន ប្រទេសថៃ និង ប្រទេសវៀតណាម) និង ប្រទេសនៅទ្វីបអឺរ៉ុប (ពោលគឺ Bulgaria)។ https://www.oecd.org/tax/beps/country-by- country-exchange-relationships.htm (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

នៅកម្រិតអឺរ៉ុប លិខិតុបករណ៍សំខាន់បំផុតសម្រាប់ការជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានស្តីពីពន្ធដារ គឺសេចក្តីណែនាំអំពីកិច្ចសហប្រតិបត្តិការផ្នែករដ្ឋបាល (២០១១/១៦/EU)។ សេចក្តីណែនាំនេះត្រូវបានធ្វើវិសោធនកម្មចំនួនប្រាំលើកមកហើយ ដើម្បីធ្វើឲ្យ (i) ការផ្លាស់ប្តូរព័ត៌មានគណនេយ្យហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ (២០១៤/១០៧/EU) (ii) ការផ្លាស់ប្តូរសេចក្តីសម្រេចអំពីពន្ធដារដោយស្វ័យប្រវត្តិ និង កិច្ចព្រមព្រៀងកំណត់តម្លៃជាមុន (២០១៥/២៣៧៦/EU); (iii) ការផ្លាស់ប្តូររបាយការណ៍រវាងប្រទេសដោយស្វ័យប្រវត្តិ (២០១៦/៨៨១/EU); (iv) ការធានាថាអាជ្ញាធរពន្ធដារទទួលបានព័ត៌មានអំពីភាពជាកម្មសិទ្ធិដែលមានអត្ថប្រយោជន៍ ដែលត្រូវបានប្រមូលដោយយោងតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់(២០១៦/២២៥៨/EU);និង(v)ការផ្លាស់ប្តូរកិច្ចព្រមព្រៀងឆ្លងព្រំដែនដែលអាចរាយការណ៍បានដោយស្វ័យប្រវត្តិ ដោយអន្តរការីពន្ធដារ (២០១៨/៨២២/EU) ដែលអាចរាយការណ៍បាន។

លើសពីនេះទៀតរដ្ឋបាលពន្ធដារកំពុងតែទទួលបានទិន្នន័យឧទាហរណ៍បន្ទាប់ពីមានការផ្លាស់ប្តូរទិន្នន័យនៅក្នុងសវនកម្មរួមគ្នារវាងមន្ត្រីដែលមកពីរដ្ឋបាលពន្ធដារ (នៃប្រទេស) ចំនួនពីរ[20] ឬនៅក្នុងកិច្ចប្រជុំរួមក្រៅផ្លូវការ ដើម្បីវិភាគអំពីទិន្នន័យរបស់អ្នកជាប់ពន្ធ ដែលកើតឡើងនៅតាមទីតាំងរបស់រដ្ឋបាលពន្ធដារណាមួយ។[21]

ទម្រង់ថ្មីនៃកិច្ចសហប្រតិបត្តិការ (ឧ. អនុលោមភាពនៃកិច្ចសហប្រតិបត្តិការ [OECD, ២០១៣ ២០១៦a] និងកម្មវិធីបញ្ជាក់អំពីអនុលោមភាពអន្តរជាតិ ICAP[22]) រវាងរដ្ឋបាលពន្ធដារនានាកំពុងតែស្ថិតនៅក្នុងការពិភាក្សា បន្ទាប់ពីមានឌីជីថលនីយកម្មផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំងក្លា និង ការលេចឡើងនូវគំរូអាជីវកម្មថ្មីៗ។[23]

---

[20] សូមមើល OECD (2017) Burgers and Criclivaia (2016), and iin-Šain, Ehrke-Rabel, and Englisch (2018).

[21] ឧទាហរណ៍ នៅក្នុងករណីរបស់ប្រទេសហូឡង់ នេះគឺជាកន្លែងដែលរដ្ឋបាលពន្ធដារនៃប្រទេសជាច្រើនប្រមូលផ្តុំគ្នានៅក្នុងបន្ទប់មួយដើម្បីវិភាគអំពីទិន្នន័យដែលត្រូវបានប្រមូល ឬ ត្រូវបានទទួលពី Panama Papers, Paradise Papers ឬ LuxLeaks នៅក្នុងចំណោមប្រភពដទៃទៀត។

[22] សូមមើល កម្មវិធីបញ្ជាក់អំពីអនុលោមភាពអន្តរជាតិ (ICAP) របស់ OECD។ https://www.oecd.org/tax/forum-on- tax-administration/international-compliance-assurance-programme.htm (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[23] ទម្រង់ថ្មីៗនៃកិច្ចសហប្រតិបត្តិការទាំងនេះ ត្រូវបានលើកឡើងនៅទិវាភាពច្បាស់លាស់នៃពន្ធដារ (Tax Certainty Day) របស់ OECD ដែលត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។ កម្មវិធីនេះមាននៅ https://www.oecd.org/tax/forum-on-tax-administration/events/Tax-certainty-Day-2019-Agenda.pdf (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០២០)។

## ប្រភពឌីជីថលសម្រាប់ប្រមូលព័ត៌មានពន្ធដារ

បន្ថែមពីលើវិធីសាស្រ្តបុរាណនៅក្នុងការប្រមូលព័ត៌មានទៀតនោះ រដ្ឋបាលពន្ធដារកំពុងតែប្រើប្រាស់ប្រភពឌីជីថលដើម្បីទទួលបានព័ត៌មារបស់អ្នកជាប់ពន្ធ។ ឧទាហរណ៍មួយដែលត្រូវបានលើកឡើងដោយ OECD (2019b:5) គឺជាការប្រើប្រាស់វេទិកាអនឡាញពហុផ្នែក។[24] ប្រភពឌីជីថលដទៃទៀតដែលត្រូវបានលើកឡើងដោយ Microsoft and PwC (2018) រួមមាន៖ ‘(i) ការទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថល ការចេញវិក្កយបត្រតាមប្រព័ន្ធ អេឡិចត្រូនិក និង ឧបករណ៍ដែលត្រូវបានតភ្ជាប់ (ឧ. ដំណោះស្រាយនៃម៉ាស៊ីនគិតប្រាក់ និង ទីកន្លែងលក់អនឡាញ)’; (ii) ‘ទិន្នន័យពន្ធដារពីប្រព័ន្ធផ្សព្វផ្សាយ អ៊ីនធឺណិត និង ប្រភពរបស់តតិយជន (ឧ. ធនាគារសភាពាណិជ្ជកម្ម និង គណៈកម្មការមូលបត្រ) (iii) បណ្តាញឌីជីថល និង គំរូអាជីវកម្មថ្មីៗ (ឧ. វេទិកាចល័ត កម្មវិធីផ្ញើសារ IoT ប្រព័ន្ធផ្សព្វផ្សាយសង្គម និង bitcoins)’។ (Microsoft and PwC 2018:4–5)

នៅកម្រិតក្នុងប្រទេស អ្នកបង្កើតច្បាប់ ឬ រដ្ឋបាលពន្ធដារអាចណែនាំអំពីវិធាននានាដើម្បីផ្តល់ការទទួលបានព័ត៌មានឌីជីថល និង ធានាថា ព័ត៌មានដែលទទួលបានពីប្រភពឌីជីថល ត្រូវបានចែករំលែកជាមួយរដ្ឋបាលពន្ធដារ។[25] នៅកម្រិតអន្តរជាតិ ព័ត៌មានអាចត្រូវបានផ្លាស់ប្តូរនៅក្នុងចំណោមរដ្ឋបាលពន្ធដារនានា នៅក្នុងលក្ខខណ្ឌដែលមានលិខិតូបករណ៍ដើម្បីផ្លាស់ប្តូរព័ត៌មាន (ឧ.សន្ធិសញ្ញាកិច្ចព្រមព្រៀងផ្លាស់ប្តូរព័ត៌មានស្តីពីពន្ធដារឬMCAA)។ដើម្បីផ្លាស់ប្តូរព័ត៌មាននេះ វេទិកាស្តីពីរដ្ឋបាលពន្ធដារ របស់ OECD បានកំណត់ប្រព័ន្ធផ្ទេរព័ត៌មានទូទៅមួយ[26] ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរដោយស្វ័យប្រវត្តិរវាងរដ្ឋបាលពន្ធដារនានា ដើម្បីទទួលបានព័ត៌មានគណនីហិរញ្ញវត្ថុ (បទដ្ឋានរាយការណ៍រួម CRS) ការផ្លាស់ប្តូររបាយការណ៍រវាងប្រទេស និង ការផ្លាស់ប្តូរដទៃទៀត។

---

[24] វេទិកាទាំងនេះ “ជាញឹកញាប់ ជួយសម្រួលដល់ចម្លងការរវាងអ្នកលក់ទំនិញ និង សេវាកម្មនីមួយ ទៅឲ្យអ្នកប្រើប្រាស់ម្នាក់ៗ ដែលកើតឡើងនៅខាងក្រៅរចនាសម្ព័ន្ធអាជីវកម្មតាមបែបប្រពៃណី ឧ. នៅក្នុងករណីទីផ្សារ)” (OECD, 2019b)។

[25] ឧទាហរណ៍មួយគឺគំនិតផ្តួចផ្តើមរបស់ចក្រភពអង់គ្លេស នៅក្នុងការបង្កើតពន្ធដារឌីជីថលសម្រាប់ VAT និង ពន្ធលើប្រាក់ចំណូលដែលត្រូវបានណែនាំនៅក្នុង ច្បាប់ស្តីពីហិរញ្ញវត្ថុ (លេខ ២) ឆ្នាំ២០១៧។ https://www.gov.uk/government/publications/making-tax-digital/overview-of-making-tax-digital (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[26] ប្រព័ន្ធនេះត្រូវបានព្រមព្រៀងគ្នាដោយប្រធានសមាជិករដ្ឋបាលពន្ធដារចំនួន ៤៤ នៃវេទិកាស្តីពីរដ្ឋបាលពន្ធដាររបស់ OECD នៅទីក្រុងប៉េកាំងថ្ងៃទី១៣ខែឧសភាឆ្នាំ២០១៦។ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការ៖ “ចំណុចមូលដ្ឋានរបស់ CTS គឺសន្តិសុខទិន្នន័យ ដែលមានបទដ្ឋានឧស្សាហកម្មឈានមុខនៅក្នុងការសរសេរកូដ ដែលត្រូវបានប្រើប្រាស់នៅក្នុងការបញ្ជូនព័ត៌មាននីមួយ” (OECD, 2016b)។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើព័ត៌មានស្ថិតនៅខាងក្រៅដែនកំណត់យុត្តាធិការនោះ (ឧ. ព័ត៌មានត្រូវបានកាន់កាប់ដោយតតិយជននៅក្នុងវេទិកាអនឡាញ) ឬ ពុំមានវិធានដើម្បីជួយសម្រួលដល់ការទទួលបានព័ត៌មានទាំងនោះ (ឧ. Facebook, Instagram និង Twitter[27]) ការចូលប្រើប្រាស់ប្រភពឌីជីថលនៃព័ត៌មានទាំងនេះ ដោយរដ្ឋបាលពន្ធដារ នឹងប្រែជាមានការលំបាក។[28]

ដើម្បីដោះស្រាយបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនេះ OECD (២០១៩) នៅក្នុងឯកសារមួយដែលលើកឡើងអំពីពន្ធដារ និង ឌីជីថលនីយកម្ម បានបញ្ជាក់អំពីតម្រូវការនៃគំនិតផ្តួចផ្តើមជាឯកតោភាគី និង ពហុភាគី ដើម្បីទទួលបានទិន្នន័យពន្ធដារស្តីពីចម្លងការដែលត្រូវបានជួយសម្រួលតាមរយៈវេទិកាអនឡាញ។ នៅថ្នាក់ជាតិ OECD ស្នើឲ្យមានការណែនាំអំពី "វិធានការតាមផ្លូវច្បាប់ ដែលតម្រូវឲ្យមានវេទិកា ឬ តតិយជនដទៃទៀត នៅក្នុងការរាយការណ៍អំពីការទូទាត់ប្រាក់ និង ទិន្នន័យធ្វើអត្តសញ្ញាណកម្មអ្នកប្រើប្រាស់ និង/ឬ ដែលអនុញ្ញាតឲ្យមានការស្នើសុំព័ត៌មាន អំពីព័ត៌មានជាក្រុម អាចផ្តល់ជូនរដ្ឋបាលពន្ធដារ នូវព័ត៌មានដែលចាំបាច់ដើម្បីធ្វើឲ្យអនុលោមភាពមានភាពល្អប្រសើរឡើង ឬ ពង្រឹងការជ្រើសរើសករណីសម្រាប់ធ្វើសវនកម្ម" (OECD 2019b:6)។

នៅក្នុងករណីដែលទិន្នន័យស្ថិតនៅក្នុងយុត្តាធិការណាមួយ ដែលនៅក្រៅយុត្តាធិការនៃវេទិការបស់អ្នកលក់នោះ OECD ស្នើឲ្យមានការស្វែងរកលទ្ធភាពដែលកិច្ចព្រមព្រៀង ពហុភាគីអាចជួយសម្រួលដល់ការទទួលបាន និង ការផ្លាស់ប្តូរព័ត៌មានទាំងនោះ ស្របតាមបទដ្ឋានរាយការណ៍រួម

---

27 កាលពីអតីតកាល ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដោយ IRS ត្រូវបានលើកឡើងដោយអ្នកប្រាជ្ញនានា។ សូមមើល Houser and Sanders (2017)។ នៅខែធ្នូ ឆ្នាំ២០១៨ ការិយាល័យលទ្ធកម្មជាតិនៃ IRS បានធ្វើសំណើមួយទៅកាន់ Facebook, Instagram និង Twitter ដើម្បីចូលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេ ដើម្បីសម្គាល់អំពីអ្នកបោកប្រាស់ពន្ធដារ។ https://qz.com/1507962/the-irs-wants-to-use-facebook-and-instagram-to-catch-tax-evaders/ (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

28 នៅអាស៊ី លើកលែងចំពោះប្រទេសសិង្ហបុរី ដោយសារតែរដ្ឋបាលពន្ធដារ (អាជ្ញាធរប្រាក់ចំណូលនៅក្នុងប្រទេស) ប្រើប្រាស់បណ្តាញសង្គមដើម្បីសម្គាល់ឃើញហានិភ័យ និង ជ្រើសរើសករណីសម្រាប់ធ្វើសវនកម្ម។ សូមមើល OECD (២០១៧:៧៥–៧៦)។ នៅអឺរ៉ុប មានប្រទេសចំនួនពីរដែលត្រូវបានលើកលែង គឺ ប្រទេសបារាំង និង ប្រទេសហូឡង់ ដែលបានណែនាំអំពីវិធានដែលផ្តល់អំណាចដល់អាជ្ញាធរពន្ធដារនៅក្នុងការប្រមូលទិន្នន័យរបស់អ្នកជាប់ពន្ធ តាមរយៈឧបករណ៍ប្រាជ្ញាសិប្បនិម្មិត ដែលធ្វើប្រតិបត្តិការដោយស្វ័យប្រវត្តិ៖ នៅប្រទេសបារាំង មាត្រា (ម.) ២៥៤ ២០២០ Budget Bill និង នៅប្រទេសហូឡង់ ម. ៧:៤ និង ៨:៤២ នៃច្បាប់ស្តីពីរដ្ឋបាលទូទៅ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចទាំងនេះមានជម្លោះនៅតុលាការ៖ សូមមើល នៅប្រទេសបារាំង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ សេចក្តីសម្រេចលេខ ២០១៩-៧៩៦ DC, និង នៅប្រទេសហូឡង់ សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ២០១៨ (BNB ២០១៨/១៦៤) និង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ (BNB ២០១៨/១៨២)។ សូមមើល Offermans (២០២០) និង Calderon និង Ribeiro (២០២០)។

សម្រាប់ការផ្លាស់ប្តូរព័ត៌មានអំពីគណនីហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ។ កិច្ចព្រមព្រៀងបែបនេះ "អាចត្រូវការគ្រប់វេទិកាទាំងអស់ដែល អនុវត្តសកម្មភាពជាក់លាក់ ដើម្បីផ្តល់ព័ត៌មាននៅក្នុងទម្រង់ស្តង់ដារ អំពីអ្នកប្រើប្រាស់វេទិកា ប្រតិបត្តិការ និង ប្រាក់ចំណូល ទៅកាន់អាជ្ញាធរពន្ធដារនៅក្នុងយុត្តាធិការនៃទីលំនៅសម្រាប់ការផ្លាស់ប្តូររបស់ពួកគេ តាមរយៈផ្លូវច្បាប់ដែលសមស្របទៅកាន់យុត្តាធិការនៃ ទីលំនៅសម្រាប់ការគណនាពន្ធរបស់អ្នកប្រើប្រាស់" (OECD, 2019b:6)។

## បញ្ហាប្រឈមសម្រាប់រដ្ឋបាលពន្ធដារ

### កម្រិតអន្តរជាតិ

របាយការណ៍រដ្ឋបាលពន្ធដារ OECD ប្រចាំឆ្នាំ២០១៩ បានថែងថា "រដ្ឋបាលពន្ធដារដូចជា អ្នកបង្កើតគោលនយោបាយពន្ធដារ ជាដើម ប្រឈមមុខនឹងការប្រែប្រួលយ៉ាងខ្លាំងក្លាតាមរយៈឌីជីថលនីយកម្មសេដ្ឋកិច្ច និង ការលេចឡើងនៃគំរូអាជីវកម្ម និង វិធីធ្វើការថ្មីៗ។ ស្របតាមពេលជាមួយគ្នានោះ លទ្ធភាពនៃការទទួលបានបច្ចេកវិទ្យាថ្មីៗ ប្រភពទិន្នន័យថ្មីៗ ឧបករណ៍វិភាគ និង កំណើននៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ការផ្លាស់ប្តូរព័ត៌មាន ក៏កំពុងតែផ្តល់ឱកាសថ្មីៗដល់រដ្ឋបាលពន្ធដារនៅក្នុងការគ្រប់គ្រងអនុលោមភាព ដោះស្រាយបដិលោមភាព និង ការពារមូលដ្ឋានពន្ធដាររបស់ពួកគេឲ្យកាន់តែល្អប្រសើរឡើង" (OECD, 2019a:22)។

កិច្ចប្រជុំកំពូល ឆ្នាំ២០១៨ របស់បណ្តាញរដ្ឋបាលពន្ធដារនៅក្នុងតំបន់ (មជ្ឈមណ្ឌលរដ្ឋបាលពន្ធដារអន្តរទ្វីបអាមេរិក ['CIAT'] និង អង្គការរដ្ឋបាលពន្ធដារអន្តរទ្វីបអឺរ៉ុប ['IOTA']) ក៏បានលើកឡើងអំពីបញ្ហាប្រឈមមួយចំនួនដែលប្រឈមមុខដោយរដ្ឋបាលពន្ធដារផងដែរ ជាពិសេស តម្រូវការក្នុងការពង្រឹងតម្លាភាពពន្ធដារនៅក្នុងយុគសម័យឌីជីថល តម្រូវការនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដើម្បីពង្រឹងអនុលោមភាពពន្ធដារ និង ការប្រមូលពន្ធ និង តម្រូវការនៅក្នុងការផ្លាស់ប្តូរឧត្តមានុវត្ត។

ឧទាហរណ៍នៃឧត្តមានុវត្ត រួមមាន (i) ការប្រើប្រាស់ឧបករណ៍ឌីជីថលដើម្បីធ្វើឲ្យការផ្លាស់ប្តូរទិន្នន័យមានភាពសាមញ្ញ និង ការប្រើប្រាស់វិធីសាស្ត្រវិភាគថ្មីៗ ដូចជា ការវិភាគស្ថិតិដើម្បីសម្គាល់ហានិភ័យពន្ធដារ (ឧទាហរណ៍ នៅក្នុងការរបាយការណ៍រវាងប្រទេស នៅប្រទេសអាល្លឺម៉ង់) (ii) ការអភិវឌ្ឍការកែប្រែជាច្រើនចំពោះការផ្ទេរទិន្នន័យ (ឧ. ប្រទេសស្វីសបានយោងដល់ការប្រើប្រាស់ ការអាប់ឡូត XML នៅលើ Portal Suisse Tax នៃរដ្ឋបាលពន្ធដារសហព័ន្ធ [FTA]) អនឡាញ និង តាមរយៈសេវាកម្មគេហទំព័រ (ការប្រាស្រ័យ

ទាក់ទង M2M); និង (iii) ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីពង្រឹងការគ្រប់គ្រងពន្ធដារ (ឧ. ការអភិវឌ្ឍឧបករណ៍ប្រើប្រាស់ទិន្នន័យធំនៅក្នុងប្រទេសអេស្ប៉ាញ)។[29] កាលពីថ្មីៗនេះ នៅខែតុលា ឆ្នាំ២០១៩ បទពិសោធន៍របស់ប្រទេសនានានៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលថ្មីៗ និង ទិន្នន័យធំ (ប្រទេសឈីលី និង ប្រទេសម៉ិចស៊ិកូ) និង ប្រាជ្ញាសិប្បនិម្មិត (ប្រទេសកាណាដា) បានធ្វើបទបង្ហាញនៅក្នុងសន្និសីទបច្ចេកទេស CIAT។[30]

ការផ្លាស់ប្តូរឧត្តមានុវត្តនៅក្នុងកិច្ចប្រជុំកំពូងឆ្នាំ២០១៨ ត្រូវបានសម្របសម្រួលដោយ CIAT និង IOTA រវាងប្រទេសនានានៅតំបន់អាមេរិកខាងជើង អាមេរិកកណ្តាល អាមេរិកខាងត្បូង អាស៊ី និង អឺរ៉ុប។ នៅក្នុងចំណោមប្រទេសដៃគូនៅទ្វីបអាស៊ី នៅក្នុង ASEM ទាំង ២១ ប្រទេស មានតែប្រទេសឥណ្ឌា និង ប្រទេសរុស្ស៊ីប៉ុណ្ណោះ ដែលបានធ្វើបទបង្ហាញអំពីឧត្តមានុវត្តមួយចំនួន (ពោលគឺ ប្រទេសឥណ្ឌាបានធ្វើបទបង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធប្រមូលព័ត៌មានហិរញ្ញវត្ថុផ្ទៃក្នុង និង ប្រទេសរុស្ស៊ីបានធ្វើបទបង្ហាញអំពីកំណែទម្រង់ម៉ាស៊ីនគិតប្រាក់ដោយប្រើប្រាស់ការវិភាគទិន្នន័យ) (CIAT និង IOTA ២០១៨)។ នៅឆ្នាំ ២០១៩ សន្និសីទបច្ចេកទេស CIAT នៅក្នុងចំណោមប្រទេសដៃគូនៅទ្វីបអាស៊ី នៅក្នុង ASEM ទាំង ២១ ប្រទេស មានតែប្រទេសឥណ្ឌាប៉ុណ្ណោះដែលបានធ្វើបទបង្ហាញ ដោយលើកឡើងជាចម្បងអំពីការប្រើប្រាស់ការវិភាគទិន្នន័យ និង ប្រាជ្ញានៅក្នុងការធ្វើអាជីវកម្ម ដើម្បីកំណត់គោលដៅនៃកង្វះខាតការរាយការណ៍នៅក្នុងសេដ្ឋកិច្ចមិនផ្លូវការ។[31]

អាស្រ័យហេតុនេះ គេបានផ្តល់អនុសាសន៍ឲ្យប្រទេសនានានៅអាស៊ីចូលរួមយ៉ាងសកម្មផងដែរនៅក្នុងកិច្ចប្រជុំប្រភេទនេះ ឬ រៀបចំកិច្ចប្រជុំរបស់ពួកគេផ្ទាល់ នៅអាស៊ី។ ឧទាហរណ៍៖ នៅក្នុងសន្និសីទនៃវេទិកាស្តីពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលពន្ធដារលើគំនិតផ្តួចផ្តើម ខ្សែក្រវាត់ និង ផ្លូវ (BRITACOF) ដែលបានគ្រោងនឹងរៀបចំនៅខែឧសភា ឆ្នាំ២០២០ (បានពន្យារពេលរហូតដល់ខែឧសភា ឆ្នាំ២០២១[32]) នៅប្រទេសកាហ្សាស្ថាន នៅក្នុងក្របខណ្ឌយន្តការនៃកិច្ចសហប្រតិបត្តិ

[29] បញ្ហាប្រឈមមួយចំនួនត្រូវបានលើកឡើងដោយ កិច្ចប្រជុំកំពូលស្តីពីពន្ធដារ CIAT–IOTA (CIAT និង IOTA ២០១៨)។ នៅអាស៊ី

[30] ផ្នែក ៣.២ បទបង្ហាញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ មាននៅ https://www.ciat.org/ciat-2019-technical-conference/?lang=en (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[31] បទបង្ហាញនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ មាននៅ https://www.ciat.org/ciat-2019-technical-conference/?lang=en.

[32] សន្និសិទ្ធនេះត្រូវបានពន្យារពេលដោយសារកូវីដ-១៩។ http://www.chinatax.gov.cn/eng/n4260854/ c5149476/content.html (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

ការរវាងរដ្ឋបាលពន្ធដារលើគំនិតផ្តួចផ្តើម ខ្សែក្រវាត់ និង ផ្លូវ (BRITACOM[33]) ប្រធានបទមួយដែលនឹងត្រូវលើកឡើងគឺឌីជីថល នីយកម្មរដ្ឋបាលពន្ធដារ។

ក្នុងគោលបំណងនេះ សភាពាណិជ្ជកម្មអន្តរជាតិ (ICC ឆ្នាំ២០២០) បានធ្វើសេចក្តីព្រាងរបាយការណ៍មួយដើម្បីផ្តល់ទស្សនវិស័យអំពីអាជីវកម្ម ស្តីពីឌីជីថលនីយកម្មរដ្ឋបាលពន្ធដារ។ របាយការណ៍នេះបានណែនាំអំពីគោលការណ៍មួយចំនួនសម្រាប់ឌីជីថលនីយកម្ម ដើម្បីធានាថាប្រព័ន្ធឌីជីថលត្រូវបានរៀបចំឡើង និង ធ្វើប្រតិបត្តិការតាមវិធីដែលពិចារណាអំពីតម្រូវការនៃសមតុល្យរវាងផលប្រយោជន៍តាមផ្លូវច្បាប់របស់រដ្ឋាភិបាល និង អាជីវកម្ម (ICC ២០២០:២–៣)។ លើសពីនេះទៀត របាយការណ៍នេះលើកឡើងអំពីលក្ខខណ្ឌតម្រូវជាមុនសម្រាប់បរិវត្តកម្មឌីជីថលបានយ៉ាងជោគជ័យ យោងតាមទស្សនវិស័យផ្នែកអាជីវកម្ម (ពោលគឺ សន្តិសុខទិន្នន័យលក្ខខណ្ឌតម្រូវរបស់ប្រព័ន្ធ ភាពអាចស្វែងរកបាននៃទិន្នន័យ ការប្រើប្រាស់ទិន្នន័យយ៉ាងសមហេតុផល តម្លាភាព អត្តសញ្ញាណរបស់អ្នកជាប់ពន្ធ និង សង្គតភាព) (ICC ២០២០: ៥–៧)។

ក្របខណ្ឌមួយទៀតដែលអាចត្រូវបានប្រើប្រាស់ដែរនោះ គឺក្របខណ្ឌនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកសិក្សាស្តីពីរដ្ឋបាលពន្ធដារនៅអាស៊ី និង ការស្រាវជ្រាវ (SGATAR)។[34] ឧទាហរណ៍៖ កិច្ចប្រជុំប្រចាំឆ្នាំលើកទី ៤៩ របស់ SGATAR (ឆ្នាំ២០១៩) បានលើកឡើងអំពីបញ្ហាប្រឈមនៃឌីជីថលនីយកម្មសម្រាប់រដ្ឋបាលពន្ធដារនៅក្នុងប្រទេសនានានៃតំបន់អាស៊ី។[35] អនុសាសន៍មួយក្នុងចំណោមអនុសាសន៍នានានៃកិច្ចប្រជុំនេះ ស្នើសុំឲ្យរដ្ឋបាលពន្ធដារពង្រឹងទំនើបកម្មរបស់ពួកគេ "រួមបញ្ចូលទាំងការគ្រប់គ្រងវប្បធម៌ និង ការប្រែប្រួល ការគ្រប់គ្រង និង ទទួលខុសត្រូវលើទិន្នន័យធំ ផ្តោតលើការគ្រប់គ្រងអត្តសញ្ញាណ ការធ្វើការជាមួយដៃគូដើម្បីផ្តល់ផ្នែកទន់ដល់

[33] ប្រទេសចិនបានសម្ភោធ BRITACOM ដើម្បីដោះស្រាយជាមួយបញ្ហាប្រឈមមួយចំនួន ក្នុងចំណោមបញ្ហាប្រឈមទាំងនេះ និង បានលើកឡើងអំពីការអនុគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ ផងដែរ។ BRITACOM មានសមាជិកចំនួន ៣៤ ប្រទេស និង មាន ១១ ប្រទេស ជាអ្នកសង្កេតការណ៍ ដែលមកពីតំបន់ខុសៗគ្នា (ឧ. អាស៊ី អាហ្វ្រិក អឺរ៉ុប) បូក អង្គការ (នៃការសិក្សា) មិនស្វែងរកប្រាក់ចំណេញចំនួនមួយ។ http://www.chinatax.gov.cn/eng/n4260869/c5112279/content.html (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។ ចំពោះតួនាទីរបស់ BRITACOM សូមមើល Sampson, Wang និង Mosquera Valderrama (ក្នុងពេលឆាប់ៗខាងមុខ)។

[34] SGATAR គឺជាអង្គការរដ្ឋបាលពន្ធដារមួយនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧០។ សមាជិកបច្ចុប្បន្ន រួមមាន ប្រទេសអូស្ត្រាលី ប្រទេសចិន ហុងកុង ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ ម៉ាកាវ ប្រទេសម៉ាឡេស៊ី ប្រទេសម៉ុងហ្គោល ប្រទេសនូវែលហ្សេឡង់ ប្រទេស Papua New Guinea ប្រទេសហ្វីលីពីន ប្រទេសសិង្ហបុរី តៃវ៉ាន់ ប្រទេសថៃ និង ប្រទេសវៀតណាម (http://sgatar.org/category/focus/)។

[35] បន្ថែមពីលើប្រទេសសមាជិកទៀតនោះ អង្គការអន្តរជាតិ (ឧ. OECD ធនាគារពិភពលោក និង IMF) និង បណ្តាញរដ្ឋបាលពន្ធដារប្រចាំតំបន់ (ឧ. CIAT) ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំនេះដែរ។

អ្នកជាប់ពន្ធ ការរៀបចំបញ្ជូនកម្លាំងពលកម្ម ដែលស្របនឹងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា” (SGATAR ២០១៩)។

## កម្រិតអឺរ៉ុប

នៅកម្រិតអឺរ៉ុប នៅខែកញ្ញា ឆ្នាំ២០១៨ ប្រទេសនានានៃសហភាពអឺរ៉ុប (EU) បានបង្កើត កិច្ចប្រជុំកំពូលសហភាពអឺរ៉ុបស្តីពីរដ្ឋបាលពន្ធដារ (TADEUS)។ TADEUS គឺជាកិច្ចប្រជុំប្រចាំឆ្នាំ ដោយប្រធានផ្នែករដ្ឋបាលពន្ធដារនៃប្រទេសនានានៃ EU និង គណៈកម្មការ EU អគ្គនាយកដ្ឋានសហភាពពន្ធដារ និង គយ (DGTAXUD) ដើម្បីលើកឡើងអំពីបញ្ហាប្រឈមទូទៅនៃឌីជីថលនីយកម្ម និង សកលភាវូបនីយកម្ម។ គោលបំណងគឺ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ជាច្រើន រួមទាំងការលើកឡើងអំពីសេដ្ឋកិច្ចឌីជីថល និង ឌីជីថលនីយកម្មនៃអាជ្ញាធរពន្ធដារ និង ការគ្រប់គ្រងប្រព័ន្ធ IT និង ធនធាននានា (សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំពេញអង្គ TADEUS ថ្ងៃទី១៧–១៨ ខែកញ្ញា ឆ្នាំ២០១៩)។ នៅក្នុងគោលបំណងនេះ មានគម្រោងជាច្រើនត្រូវបានផ្តួចផ្តើមគំនិតឡើង។ ឧទាហរណ៍៖ ពាក់ព័ន្ធនឹងបច្ចេកវិទ្យាថ្មីៗ គម្រោងមួយគឺ គម្រោងឌីជីថល និង ទិន្នន័យ ដែលដឹកនាំដោយប្រទេសហ្វាំងឡង់ ស្តីពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍សម្រាប់ការចែករំលែកនិងទីផ្សារការងាររយៈពេលខ្លី (gigeconomy) (សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំពេញអង្គ TADEUS ថ្ងៃទី១៧–១៨ ខែកញ្ញា ឆ្នាំ២០១៩:២,៣)។

នៅក្នុងកិច្ចប្រជុំ ថ្ងៃទី១៧–១៨ ខែកញ្ញា ឆ្នាំ២០១៩ ប្រធានផ្នែករដ្ឋបាលពន្ធដារបានទទួលស្គាល់អំពីការកែប្រែតាមផ្លូវច្បាប់ និង កម្រិតនៃកិច្ចសហប្រតិបត្តិការផ្នែករដ្ឋបាល ដែលនឹងតម្រូវឲ្យការអភិវឌ្ឍផ្នែក IT ថ្មីៗ និង ការវិនិយោគលើប្រព័ន្ធអេឡិចត្រូនិកឆ្លងអឺរ៉ុប។

អាស្រ័យហេតុនេះ លទ្ធផលមួយនៃកិច្ចប្រជុំនេះគឺ តម្រូវការក្នុងការធ្វើឲ្យការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទូទៅ ឬ អាចធ្វើប្រតិបត្តិការទៅវិញទៅមកបាន របស់ EU មានភាពស្របគ្នា និង បង្កើត “ដំណើរការសម្របសម្រួលដោយផ្អែកលើការព្រមព្រៀងជាឯកច្ឆ័ន្ទ នៅក្នុងទម្រង់ជាផែនការរយៈពេលច្រើនឆ្នាំ ក្រោមការសម្របសម្រួលរបស់ TADEUS”។ (សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំពេញអង្គ TADEUS ថ្ងៃទី១៧–១៨ ខែកញ្ញា ឆ្នាំ២០១៩:៣)។

ជាចុងក្រោយ ប្រទេសនានាកំពុងតែស្វែងរកវិធីផ្សេងទៀតដើម្បីសហការ។ ឧទាហរណ៍មួយគឺ ប្រទេសបែលហ្ស៊ិក ប្រទេសហូឡង់ និង ប្រទេសលុចហ្សំប៊ួរ (BENELUX) បានធ្វើការសម្រេចចិត្តកាលពីឆ្នាំ២០០១ លើការណែនាំអំពីប្រព័ន្ធថ្មីមួយ គឺការវិភាគអំពីបណ្តាញចម្លងការ ដើម្បី

ដោះស្រាយការក្លែងបន្លំអាករលើតម្លៃបន្ថែមដោយស្វ័យប្រវត្តិ នៅក្នុងតំបន់ Benelux។[36] ការវិភាគអំពីបណ្តាញចម្លងការនេះ ត្រូវបានអនុម័តដោយគណៈកម្មការ EU នាពេលថ្មីៗនេះ ថាជាប្រព័ន្ធថ្មីដើម្បីដោះស្រាយការក្លែងបន្លំ អតប. នៅ EU។ (សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩)

នាពេលថ្មីៗនេះ និង ដើម្បីដោះស្រាយការគេចពន្ធ និង ការក្លែងបន្លំពន្ធ ប្រទេសនានានៃ BENELUX បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីមួយ (អនុស្សរណៈនៃការយោគយល់គ្នា) នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩[37] ដែលសម្របសម្រួលការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិរវាងប្រទេសនានា មិនត្រឹមតែរួមបញ្ចូលប្រភពបែបប្រពៃណីនោះទេ ប៉ុន្តែវាក៏រួមបញ្ចូលប្រភពឌីជីថល និង គម្រោងឌីជីថលផងដែរ ដូចជា FIC.net[38] ជាដើម (MOU Benelux ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩:៣)។

នៅក្នុងដំណើរការឌីជីថលនីយកម្មនេះ រដ្ឋបាលពន្ធដារចាំបាច់ត្រូវតែមានយុទ្ធសាស្រ្តគ្រប់គ្រងទិន្នន័យ និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រឹមត្រូវ។ ធាតុទាំងពីរនេះនឹងត្រូវពន្យល់នៅខាងក្រោម។

## យុទ្ធសាស្រ្តគ្រប់គ្រងទិន្នន័យ និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

### យុទ្ធសាស្រ្តគ្រប់គ្រងទិន្នន័យ

យុទ្ធសាស្រ្តគ្រប់គ្រងទិន្នន័យគួរតែជាយុទ្ធសាស្រ្តរយៈពេលវែង ដែលមិនត្រឹមតែផ្តោតលើការវិភាគបែបពណ៌នា (សម្រាប់ធ្វើការវិនិច្ឆ័យ) តែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្តោតលើការវិភាគបែបទស្សន៍ទាយទុកមុន និង បែបបញ្ញត្តិផងដែរ (Microsoft និង PwC ឆ្នាំ២០១៨)។ ការវិភាគបែបទស្សន៍ទាយទុកមុន (“ផ្តល់ព័ត៌មានអំពីអ្វីដែលទំនងជាលទ្ធផលនាពេលអនាគត ឬ គម្រោងថៃរក្សាធនធាន” នៅខណៈពេលដែលការវិភាគបែបបញ្ញត្តិ “គណនាលទ្ធផលដែលត្រូវបាន

[36] ការវិភាគនេះនឹងប្រើប្រាស់ “សូហ្វវែស្វែងរកទិន្នន័យរួមជាមួយអាល់កូរីតឆ្លាតវៃដែលអាចបើកចំហរចម្លងការដែលជាប់សង្ស័យបានយ៉ាងឆាប់រហ័ស ដែលចង្អុលបង្ហាញអំពីការក្លែងបន្លំ អតប.” (បច្ចុប្បន្នភាពនៃ អតប. ឆ្នាំ២០១៩)។

[37] https://www.benelux.int/files/6015/8098/4521/MoU_fraude_fiscale_10.10.2019-NL.pdf

[38] FCInet គឺជាប្រព័ន្ធកុំព្យូទ័រវិមជ្ឈការដែលមិនធ្វើពាណិជ្ជកម្ម (ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល) ដែលអនុញ្ញាតឲ្យ FCISs (សេវាស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ និង/ឬ ផ្នែកព្រហ្មទណ្ឌ) ដែលមកពីយុត្តាធិការខុសៗគ្នាធ្វើការជាមួយគ្នាបាន ស្របពេលជាមួយគ្នានោះ គោរពស្វ័យភាពរបស់គ្នាទៅវិញទៅមក។ https://www.fcinet.org/index.php/what-is-fcinet/ (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

រំពឹងទុក និង ជួយផ្តល់អនុសាសន៍អំពីសកម្មភាពល្អបំផុតសម្រាប់ការសម្រេចចិត្តនានា ដូចជា ការកែប្រែបទប្បញ្ញត្តិពន្ធដារ ជាដើម។ ទម្រង់នៃការយល់ដឹងយ៉ាងជ្រៅជះនេះ ជាញឹកញាប់ រួមបញ្ចូលការប្រើប្រាស់ប្រាជ្ញាសិប្បនិម្មិត (ឧ. សតិបញ្ញា ការយល់ដឹងអំពីបរិបទ) និង ការវិភាគដោយស្វ័យប្រវត្តិ និង ការវិភាគឲ្យបានល្អបំផុត (ឧ. ការជ្រាបចូលទៅគ្រប់ផ្នែក ស្វ័យប្រវត្តិកម្ម)"។ (Microsoft និង PwC ២០១៨:៩)

ពាក់ព័ន្ធនឹងប្រាជ្ញាសិប្បនិម្មិត ទីភ្នាក់ងារប្រាក់ចំណូលនៃប្រទេសកាណាដាបានចែករំលែកបទពិសោធន៍របស់ខ្លួននៅក្នុងបទបង្ហាញ ឆ្នាំ២០១៩ ដែលត្រូវបានធ្វើឡើងនៅក្នុងក្របខណ្ឌនៃសន្និសីទបច្ចេកទេស CIAT។

ចំពោះទីភ្នាក់ងារប្រាក់ចំណូលនៃប្រទេសកាណាដា ប្រាជ្ញាសិប្បនិម្មិតជាលទ្ធផលធ្វើឱ្យមាន (i) ការយល់ដឹងជ្រៅជ្រះកម្រិតខ្ពស់ពីទិន្នន័យធំ សម្រាប់ការវិភាគអំពីបណ្តាញ ការវិភាគអំពីសមាគម និង ការវិភាគដែលមានការបែងចែកក្រុម (ii) ប្រព័ន្ធនៃការទស្សន៍ទាយទុកមុន រួមមាន អាល់កូរីតដើមឈើ បណ្តាញប្រសាទ និង អាល់កូរីតថយក្រោយ (iii) ការចាប់យកទិន្នន័យខុសពីធម្មតា រួមមាន អាល់កូរីតនៃការចាប់បាននៅក្រៅប្រព័ន្ធ និង (iv) ការយល់ដឹងអំពីភាសាធម្មជាតិសម្រាប់ការយល់ដឹងអំពីតួអក្សរ-សម្លេង និង ការទទួលបានទិន្នន័យដែលគ្មានរចនាសម្ព័ន្ធ។[39]

ទីភ្នាក់ងារប្រាក់ចំណូលនៃប្រទេសកាណាដាបានលើកឡើងអំពីវិធីមួយចំនួនដែលប្រាជ្ញាសិប្បនិម្មិតត្រូវបានប្រើប្រាស់ដោយពួកគេ៖ chatbots ដើម្បីពង្រឹងសេវាកម្ម, បណ្តាញប្រសាទដើម្បីបង្កើតពិន្ទុហានិភ័យសម្រាប់សហគ្រាសធុនតូច និង មធ្យម, ប្រព័ន្ធទស្សន៍ទាយទុកមុនដើម្បីរកឃើញបដិលោមភាពនៅក្រៅប្រទេស, គំរូទស្សន៍ទាយទុកមុន ដើម្បីធ្វើឲ្យដំណោះស្រាយបំណុលមានភាពល្អបំផុត, ការបែងចែកក្រុមដែលគ្មានការគ្រប់គ្រង ដើម្បីវាស់វែងអំពីសក្តានុពលនៃបដិលោភាពពន្ធលើប្រាក់ចំណូលរបស់សាជីវកម្ម និង វិស្វកម្មទិន្នន័យដើម្បីសម្រេចបាននូវទស្សនៈ ៣៦០ ដឺក្រេរបស់អ្នកជាប់ពន្ធ (ការវិភាគអំពីបណ្តាញ)។

ដោយពិចារណាអំពីចំណុចនានានៅខាងលើ គេអាចផ្តល់ទឡ្ហីករណ៍បានថា ការចូលប្រើប្រាស់ប្រភពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ រួមបញ្ចូលទាំង យុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យផងដែរនោះ អាចផ្តល់ឧបករណ៍នានាដល់រដ្ឋបាលពន្ធដារនៅក្នុងការបង្កើនតម្លាភាព និង ប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ និង ការក្លែងបន្លំពន្ធ តាមរយៈការរកឃើញហានិភ័យ ការទស្សន៍ទាយ

---

[39] បទបង្ហាញមាននៅផ្នែក ៣.២ https://www.ciat.org/ciat-2019-technical-conference/?lang=en (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

អំពីអាកប្បកិរិយា និង ការធ្វើសវនកម្មឆ្លាតវៃ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមមួយសម្រាប់ប្រទេសនានា ដើម្បីទទួលបានអត្ថប្រយោជន៍ពីយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យទាំងនេះគឺការណែនាំអំពីការកែប្រែហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលពន្ធដារ ដូចបានពន្យល់នៅខាងក្រោម។

## ហេដ្ឋារចនាសម្ព័ន្ធ

ឌីជីថលនីយកម្មពន្ធដារតម្រូវឲ្យមានការកែប្រែហេដ្ឋារចនាសម្ព័ន្ធ ដែលអាចនឹងពិបាកសម្រេចបានដោយប្រទេសដែលមានធនធាន (ផ្ទាល់ខ្លួន ឬ ថវិកា) មានកម្រិត ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ (Debelva និង Mosquera Valderrama ឆ្នាំ២០១៧)។ ប្រទេសកំពុងអភិវឌ្ឍន៍អាចមានវិស័យមិនគិតពន្ធ មិនផ្លូវការក្នុងទ្រង់ទ្រាយធំ អាស្រ័យហេតុនេះ វាប្រែជាមានការពិបាកនៅក្នុងការទទួលបាន (និង/ឬ ធ្វើបច្ចុប្បន្នភាព) ព័ត៌មានពីបុគ្គល និង/ឬ អាជីវកម្ម។[40]

ចំណាប់អារម្មណ៍វិជ្ជមានមួយ ដូចបានលើកឡើងដោយ Krishna, Fleming និង Assefa (២០១៧) គឺថា នៅក្នុងយុគសម័យបច្ចេកវិទ្យាថ្មីនេះ ប្រទេសកំពុងអភិវឌ្ឍន៍អាចកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ពួកគេពីចំណុចដំបូងបំផុត និង មិនត្រូវបានដាក់កំហិតដោយប្រព័ន្ធដែលជា“កេរ្តិ៍ដំណែលរបស់មនុស្សជំនាន់មុន” នៅប្រទេសអភិវឌ្ឍន៍។

ហេតុដូចនេះ ពួកគេអាច “ជ្រើសរើសកសាងហេដ្ឋារចនាសម្ព័ន្ធទំនើប ដោយប្រើប្រាស់ប្រព័ន្ធ blockchain និង ដំណើរការការគិតរបស់មនុស្ស (cognitive computing) ជាមូលដ្ឋាន ជាជាង

[40] ដូចបានលើកឡើងដោយ Kanbur (២០១៧)៖ “ចំណុចចាប់ផ្តើមដែលច្បាស់លាស់ និង ប្រាកដប្រជាបំផុត គឺជាសក្តានុពលនៃបដិវត្តន៍ឌីជីថល ដើម្បីកាត់បន្ថយបន្ទុកចំណាយព័ត៌មាននៅក្នុងការកំណត់គោលដៅអនុវត្ត។ ប្រព័ន្ធទិន្នន័យជីវសាស្រ្ត និង ការធ្វើអត្តសញ្ញាណកម្មបុគ្គល ជាញឹកញាប់ ត្រូវបានយល់ឃើញថាជាដំណោះស្រាយចំពោះបញ្ហាព័ត៌មាននៅក្នុងការកំណត់គោលដៅអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលការកំណត់គោលដៅអនុវត្តត្រូវការ មិនមែនត្រឹមតែការកំណត់អត្តសញ្ញាណរបស់បុគ្គលនោះទេ ប៉ុន្តែក៏ជាព័ត៌មានលម្អិតដែលឲ្យអនុញ្ញាតឲ្យមានការគណនាប្រាក់ចំណូល ឬ ការប្រើប្រាស់ផងដែរ ហេតុដូចនេះ រួមទាំងការធ្វើអត្តសញ្ញាណកម្មជនក្រីក្រផងដែរ។ លើសពីនេះទៀត ការគណនានេះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ប្រសិនបើកម្មវិធីនៅតែបន្តត្រូវបានគេកំណត់គោលដៅអនុវត្តយ៉ាងលម្អិត។ នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចខ្នាតតូច អភិវឌ្ឍន៍ និង មានលក្ខណៈផ្លូវការខ្លាំង ដូចជា ប្រទេសហ្វាំងឡង់ ជាដើម ព័ត៌មានអំពីប្រាក់ចំណូលទាំងនោះត្រូវបានធ្វើឌីជីថលនីយកម្ម និង ត្រូវបានភ្ជាប់ទៅកាន់មូលដ្ឋានទិន្នន័យថ្នាក់ជាតិដទៃទៀតរួចហើយ ហើយការប្រើប្រាស់ព័ត៌មានទាំងនោះមិនមែនជាបញ្ហានោះទេ។ ប៉ុន្តែនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានវិស័យមិនគិតពន្ធក្រៅផ្លូវការក្នុងទ្រង់ទ្រាយធំ វាមានភាពមិនច្បាស់លាស់នោះទេ ថាតើឌីជីថលនីយកម្មអាចជួយបានយ៉ាងពិតប្រាកដដល់កម្រិតណា យ៉ាងហោចណាស់ មិនមែននៅក្នុងរយៈពេលជាច្រើនឆ្នាំបន្ទាប់ទៀតនោះទេ។ ហើយភាពមិនផ្លូវការហាក់បីដូចជាមិនបានចុះអន់ថយយ៉ាងខ្លាំងក្លា ឬ ទាំងស្រុងនោះទេ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន”។

ការប្រើប្រាស់បរិក្ខារដែលអាចមានអាយុច្រើនទសវត្សរ៍មកហើយ” (Krishna, Fleming និង Assefa ២០១៧:១៨២)។

លើសពីនេះទៀត រដ្ឋបាលពន្ធដារមួយចំនួន ទោះបីជាមានធនធានក៏ដោយ អាចមានការប្រុងប្រយ័ត្នចំពោះឌីជីថលនីយកម្មដែលមានភាពជឿនលឿន “ដោយសារតម្លៃនៃកំហុសឆ្គងជាសក្តានុពល។តម្លៃនៃកំហុសឆ្គងខ្ពស់បំផុតរួមមានហានិភ័យចំពោះប្រាក់ចំណូលការខូចកេរ្តិ៍ឈ្មោះ និង ការកាត់បន្ថយសីលធម៌ពន្ធដារជាសក្តានុពល។ ឌីជីថលនីយកម្ម រដ្ឋបាលពន្ធដារ មានភាពស្មុគស្មាញផ្នែកបច្ចេកទេស ដោយសារតែទំហំនៃសកម្មភាពដែលប្រព័ន្ធនឹងត្រូវផ្តល់ជូន និង សារសំខាន់ផ្នែកសន្តិសុខ និង អវត្តមាននៃកំហុសឆ្គង។ បទដ្ឋានគុណភាពដែលត្រូវបានតម្រូវនឹងសម្រេចបានតែតាមរយៈបច្ចេកទេសខាងក្រៅ និង ការធ្វើតេស្តមុខងារតែប៉ុណ្ណោះ។ ប្រព័ន្ធណាមួយដែលត្រូវបានសាកល្បងមិនគ្រប់គ្រាន់នឹងធ្លាក់ចុះយ៉ាងឆាប់រហ័សជាមួយនឹងការខាតបង់ខាងហិរញ្ញវត្ថុនិងកេរ្តិ៍ឈ្មោះ” (Chen, Grimshaw និង Myles ២០១៧:១១៤)។

សរុបមក ទិន្នន័យត្រូវបានប្រមូលចេញពីប្រភពបែបប្រពៃណី និង ប្រភពឌីជីថល ហើយទិន្នន័យនេះអាចត្រូវបានប្រើប្រាស់ដោយរដ្ឋបាលពន្ធដារដើម្បីបង្កើនតម្លាភាព និង ដោះស្រាយការគេចពន្ធ និង ការក្លែងបន្លំពន្ធ។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសនានាគួរតែណែនាំលិខិតូបករណ៍ថ្មីៗ (វិធានក្នុងប្រទេស និង កិច្ចព្រមព្រៀងអន្តរជាតិ) ដើម្បីផ្តល់ការចូលទៅប្រើប្រាស់ប្រព័ន្ធឌីជីថល និង ការផ្លាស់ប្តូរទិន្នន័យឌីជីថល។

ការចូលទៅប្រើប្រាស់ទិន្នន័យពន្ធដារ និង ការប្រើប្រាស់ទិន្នន័យខ្នាតធំ[41] អាចជួយរកឃើញហានិភ័យបានល្អបំផុត និង អនុវត្តសវនកម្មឆ្លាតវៃ ដោយប្រើប្រាស់ការវិភាគទិន្នន័យ។ ដើម្បីសម្រេចបានវត្ថុបំណងទាំងនេះ រដ្ឋបាលពន្ធដារគួរតែមានយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការវិភាគទិន្នន័យ និង ប្រើប្រាស់ការវិភាគបែបវិនិច្ឆ័យ បែបទស្សន៍ទាយទុកមុន និង បែបបញ្ញត្តិ។ ផ្នែកបន្ទាប់នឹងលើកឡើងអំពីលិខិតូបករណ៍ដើម្បីការពារសិទ្ធិរបស់អ្នកជាប់ពន្ធនៅក្នុងយុគសម័យឌីជីថលនីយកម្មថ្មីនេះ។

---

[41] ពាក្យទិន្នន័យខ្នាតធំ “តាមធម្មតា សម្គាល់បណ្តុំទិន្នន័យដែលមានទំហំធំខ្លាំងណាស់ ដែលប្រហែលជាត្រូវបានវិភាគតាមប្រព័ន្ធកុំព្យូទ័រដើម្បីទាញយកការបញ្ជាក់យ៉ាងជាក់លាក់អំពីទិន្នន័យ រចនាបថ និន្នាការ និង ទំនាក់ទំនងទៅវិញទៅមក” (Mantelero ២០១៧)។

# លិខិតុបករណ៍ដើម្បីការពារការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ និង ការការពារសិទ្ធិអ្នកជាប់ពន្ធ

## ការប្រមូលទិន្នន័យផ្ទាល់ខ្លួន និង ទិន្នន័យអាជីវកម្ម

ជាទូទៅ ទិន្នន័យដែលប្រមូលបាន រួមបញ្ចូលទាំង ទិន្នន័យផ្ទាល់ខ្លួនផងដែរ (ពោលគឺ ព័ត៌មានដែលទាក់ទងនឹងបុគ្គលដែលត្រូវបានសម្គាល់ឃើញ ឬ អាចសម្គាល់ឃើញ រួមទាំងព័ត៌មានសេនេទិច និង ព័ត៌មានជីវសាស្ត្រ ផងដែរ[42]) និង ទិន្នន័យអាជីវកម្ម (ពោលគឺ ព័ត៌មានដែលទាក់ទងនឹងប្រតិបត្តិការអាជីវកម្ម រួមទាំង អាថ៌កំបាំងពាណិជ្ជកម្ម ផងដែរ[43])។

ទិន្នន័យទាំងនេះអាចត្រូវបានចាត់ទុកថាជាទិន្នន័យរបស់អ្នកជាប់ពន្ធ អាស្រ័យហេតុនេះ ត្រូវបានការពារស្របតាមវិធានស្តីពីការសម្ងាត់ និង ការរក្សាការសម្ងាត់ ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ និង/ឬ ច្បាប់ស្តីពីពន្ធដារនៃប្រទេសណាមួយ។[44]

នៅក្នុងយុគសម័យរដ្ឋបាលពន្ធដារឌីជីថលថ្មីនេះ[45] ប្រទេសនានាគួរតែធានាចំពោះនីតិរដ្ឋ នៅក្នុងការដំណើរការព័ត៌មានផ្ទាល់ខ្លួន និង ព័ត៌មានអាជីវកម្ម។ ដូច្នេះ សំណួរនានាដូចតទៅ គួរតែត្រូវបានលើកឡើងដោយរដ្ឋបាលពន្ធដារ ដែលប្រមូល និង ដំណើរការទិន្នន័យ៖ (i) តើអ្នកណាមានទិន្នន័យរបស់អ្នកជាប់ពន្ធ? (ii) តើទិន្នន័យរបស់អ្នកជាប់ពន្ធត្រូវបានប្រមូល រក្សាទុក និង ត្រួតពិនិត្យបានយ៉ាងត្រឹមត្រូវដែរឬទេ? (iii) តើមានការអនុញ្ញាតឲ្យដំណើរការទិន្នន័យរបស់អ្នកជាប់ពន្ធដែរឬទេ? (iv) តើអ្នកណាជាអ្នកកាន់កាប់ព័ត៌មានរបស់អ្នកជាប់ពន្ធ? (Mosquera Valderrama ឆ្នាំ២០១៩)។

---

[42] ឧទាហរណ៍នៃទិន្នន័យជីវសាស្ត្ររួមមានស្នាមម្រាមដៃ, ការស្កេនប្រស្រីភ្នែក, និង DNA។ ទិន្នន័យទាំងនេះបានទទួលការការពារជាប្រភេទដ៏ពិសេសមួយនៃទិន្នន័យផ្ទាល់ខ្លួន នៅក្នុង មាត្រា ៩ បទប្បញ្ញត្តិស្តីពីការការពារទិន្នន័យទូទៅ (GDPR) មាត្រា ៩ ចែងថា "ការដំណើរការទិន្នន័យផ្ទាល់ខ្លួនបង្ហាញអំពីដើមកំណើតនៃជាតិសាសន៍ ឬ ជាតិពន្ធ គំនិតផ្នែកនយោបាយ ជំនឿផ្នែកសាសនា ឬ ទស្សនវិទ្យា ឬ សមាជិកភាពនៃសហជីពពាណិជ្ជកម្ម ហើយ ចំពោះការដំណើរការទិន្នន័យសេនេទិច ទិន្នន័យជីវសាស្ត្រ ក្នុងគោលបំណងកំណត់រូបវន្តបុគ្គលតែមួយគត់ ទិន្នន័យដែលពាក់ព័ន្ធនឹងសុខភាព ឬ ទិន្នន័យដែលពាក់ព័ន្ធជីវិតផ្លូវភេទ ឬ ទំនោរផ្លូវភេទរបស់រូបវន្តបុគ្គលនោះនឹងត្រូវបានហាមឃាត់"។

[43] ចំពោះការសម្ងាត់ពាណិជ្ជកម្ម សូមមើល D'souza (២០១៩)។

[44] សូមមើល Mosquera Valderrama et al. (២០១៧)។ សូមមើល Debelva និង Mosquera Valderrama (២០១៧)។

[45] ធាតុមួយផ្សេងទៀតនៅក្នុងយុគសម័យរដ្ឋបាលពន្ធដារឌីជីថលនេះគឺ ការបង្កើតបច្ចេកវិទ្យាឌីជីថលនៅក្នុងអន្តរកម្មរវាងរដ្ឋបាលពន្ធដារ និង អ្នកជាប់ពន្ធ ឧ. អាករលើផលរបរដែលបំពេញទុកមុន ការបំពេញទម្រង់បែបបទតាមប្រព័ន្ធអេឡិចត្រូនិក និង សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ល។ សូមមើល Microsoft និង PwC (២០១៨)។

ដូចបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍របស់វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីរដ្ឋបាលពន្ធដារនោះ ដើម្បីពង្រឹងអនុលោមភាពដោយស្ម័គ្រចិត្ត "អង្គភាពប្រាក់ចំណូលត្រូវតែបង្ហាញថាបានធ្វើប្រតិបត្តិការនៅក្នុងលក្ខណៈដែលបណ្តុះគំនិតនៃទំនុកចិត្ត ការគោរព និង ការជឿជាក់លើគ្នាទៅវិញទៅមកនៅកម្រិតខ្ពស់ នៅក្នុងចំណោមអ្នកជាប់ពន្ធរបស់ខ្លួន។ ចំណុចនេះអាចសម្រេចបានលុះត្រាតែមានការទទួលស្គាល់ និង ការទទួលយកពីសំណាក់បណ្តុំសិទ្ធិ និង កាតព្វកិច្ចមូលដ្ឋានរបស់អ្នកជាប់ពន្ធ" (ADB ២០១៨:២៦)។ អាស្រ័យហេតុនេះ ប្រទេសនានាគួរតែពិចារណាអំពីលិខិតូបករណ៍ដើម្បីការពារសិទ្ធិរបស់អ្នកជាប់ពន្ធ ក្នុងការប្រមូលផ្តុំ ការផ្លាស់ប្តូរ និង ការដំណើរការព័ត៌មានដោយរដ្ឋបាលពន្ធដារ។

ដើម្បីពង្រឹងអនុលោមភាពពន្ធដារដោយស្ម័គ្រចិត្ត អ្នកជាប់ពន្ធចាំបាច់ត្រូវតែដឹងថា ពន្ធដារនឹងត្រូវទូទាត់ដោយមនុស្សគ្រប់រូប រួមបញ្ចូលទាំង បុគ្គល និង ពហុជាតិដែលមានពន្ធលើទ្រព្យសម្បត្តិច្រើនផងដែរ និងថា ទិន្នន័យដែលប្រមូលបាននឹងត្រូវបានប្រើប្រាស់យ៉ាងស្របច្បាប់ (សម្រាប់គោលបំណងពន្ធដារ) និង ស្របតាមនីតិរដ្ឋ។ អាស្រ័យហេតុនេះ កំណើននៃតម្លាភាព និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ចាំបាច់ត្រូវតែពិចារណាអំពី (i) ការការពារសុវត្ថិភាពសម្រាប់ការដំណើរការទិន្នន័យដោយស្វ័យប្រវត្តិ រួមបញ្ចូលទាំង ទិន្នន័យខ្នាតធំ ផងដែរ (Van Hout ២០១៩) និង (ii) សិទ្ធិរបស់អ្នកជាប់ពន្ធ រួមបញ្ចូលទាំង សិទ្ធិក្នុងការរក្សាការសម្ងាត់ ភាពសម្ងាត់ និង ឯកជនភាព ផងដែរ។

ការការពារសុវត្ថិភាពមួយចំនួន ចំពោះកិច្ចការពារទិន្នន័យនៅក្នុងការដំណើរការទិន្នន័យដោយស្វ័យប្រវត្តិ ត្រូវបានលើកឡើងរួចរាល់ហើយ។[46]

## សិទ្ធិរបស់អ្នកជាប់ពន្ធនៅអាស៊ី

សិទ្ធិរបស់អ្នកជាប់ពន្ធនៅអាស៊ី (ឧ. សិទ្ធិឯកជនភាព សិទ្ធិរក្សាការសម្ងាត់ និង ភាពសម្ងាត់)

[46] យោងតាម Debelva និង Mosquera Valderrama (២០១៧) ការការពារដូចតទៅ គួរតែបានចាប់ផ្តើមអនុវត្តចំពោះការផ្លាស់ប្តូរព័ត៌មាន រួមបញ្ចូលទាំង ការផ្លាស់ប្តូរព័ត៌មានដោយស្វ័យប្រវត្តិផងដែរ៖ (១) ទិន្នន័យប្រហាក់ប្រហែលគ្នា អាចទទួលបានពីបដិភាពរបស់រដ្ឋទទួល (២) រដ្ឋទទួល ធានាចំពោះការការពារភាពគ្រប់គ្រាន់នៃការរក្សាការសម្ងាត់ និង ឯកជនភាពរបស់ទិន្នន័យ ដែលត្រូវបានធានាដោយការតាមដានរបស់រដ្ឋផ្គត់ផ្គង់ ដើម្បីធានាចំពោះការគោរពការរក្សាការសម្ងាត់ទាំងនោះ នៅក្នុងរដ្ឋទទួល (៣) ការផ្លាស់ប្តូរមានភាពគ្រប់គ្រាន់ ពាក់ព័ន្ធ និង ច្រើនហួសហេតុពេក ពាក់ព័ន្ធនឹងគោលបំណងក្នុងការដំណើរការទិន្នន័យទាំងនោះ (៤) ការបញ្ជូនទិន្នន័យមិនបង្កើតបន្ទុកខ្លាំងហួសហេតុពេកចំពោះរដ្ឋបាលពន្ធដារដែលខ្វះខាតសមត្ថភាពផ្នែករដ្ឋបាល ឬ ចំណេះដឹងបច្ចេកទេសនៅក្នុងការអភិវឌ្ឍប្រព័ន្ធអេឡិចត្រូនិកដែលមានសុវត្ថិភាព សម្រាប់ការផ្លាស់ប្តូរទិន្នន័យ និង (៥) គោលការណ៍នៃភាពត្រឹមត្រូវ ការចែងថា អ្នកគ្រប់គ្រងទិន្នន័យមានភារកិច្ចធ្វើការត្រួតពិនិត្យជាទៀងទាត់លើគុណភាពទិន្នន័យផ្ទាល់ខ្លួន (Debelva និង Mosquera Valderrama ២០១៧)។

ត្រូវបានលើកឡើងខ្លីៗ និង ច្បាស់ ដោយអង្គការអន្តរជាតិ និង អង្គការប្រចាំតំបន់។ សិទ្ធិទាំងនេះត្រូវអាស្រ័យលើវិធានប្រចាំប្រទេស ដែលអាចសម្រេចចិត្តធ្វើការណែនាំ ឬ មិនណែនាំអំពីច្បាប់ឯកជនភាព ឬ សិទ្ធិជាក់លាក់របស់អ្នកជាប់ពន្ធនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិផ្នែករដ្ឋបាល។

ឧទាហរណ៍មួយចំនួនដែលអាចបង្ហាញអំពីចំណុចនេះបានគឺ របាយការណ៍របស់វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB ២០១៨ និង ADB ២០២០) ដែលបង្ហាញអំពីការសិក្សាតាមបែបប្រៀបធៀប អំពីរដ្ឋបាលពន្ធដារនៅអាស៊ី និង ប៉ាស៊ីហ្វិក។ របាយការណ៍ទាំងនេះមិនបានបញ្ជាក់អំពីបញ្ហាប្រឈមនានាដែលត្រូវបានប្រឈមមុខដោយប្រទេសនានា នៅក្នុងការការពារសិទ្ធិរបស់អ្នកជាប់ពន្ធ និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង ការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ។ ផ្ទុយមកវិញ មានការយោងដល់ឯកសារនានា ត្រូវបានធ្វើឡើងដោយ OECD និង អង្គការអន្តរជាតិដទៃទៀត។ តាមអ្វីដែលយើងដឹង ការសិក្សាតាមបែបប្រៀបធៀបលើសិទ្ធិរបស់អ្នកជាប់ពន្ធនៅអាស៊ី ចំពោះការផ្លាស់ប្តូរព័ត៌មាន និង ឌីជីថលនីយកម្ម មិនបានធ្វើឡើងនៅឡើយទេ។[47]

នៅក្នុងរបាយការណ៍ឆ្នាំ២០១៨ មានការយោងដល់ឯកសាររបស់ OECD ស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ឆ្នាំ២០០៣ (OECD ២០០៣)។ លើសពីនេះទៀត របាយការណ៍ឆ្នាំ២០១៨ ផ្តោតជាពិសេសលើការស្ទង់មតិរបស់អង្គការអន្តរជាតិ (មូលនិធិរូបិយវត្ថុអន្តរជាតិ IMF ២០០៧; OECD ២០១៧) ផ្តល់ការប្រៀបធៀបដ៏ខ្លីមួយអំពីវិធីតាមផ្លូវច្បាប់ ឬ វិធានផ្នែករដ្ឋបាលដែលណែនាំអំពីសិទ្ធិរបស់អ្នកជាប់ពន្ធ (ADB ២០១៨:៣៨-៣៩)។ យោងតាមការប្រៀបធៀបនេះ ក្នុងចំណោមប្រទេសទាំង ២៨ នៅអាស៊ី និង ប៉ាស៊ីហ្វិកដែលត្រូវបានវិភាគកាលពីឆ្នាំ២០១៨ មានតែប្រាំប្រទេសប៉ុណ្ណោះ ដែលគ្មានសិទ្ធិបង្កើតច្បាប់ និង បទប្បញ្ញត្តិ ឬ បង្កើតអង្គភាពប្រាក់ចំណូល (ពោលគឺ ហុងកុង ប្រទេសជប៉ុន ប្រទេស Papua New Guinea ប្រទេសមីយ៉ាន់ម៉ា និង ប្រទេសសិង្ហបុរី) (ADB ២០១៨:៣៩)។

របាយការណ៍ឆ្នាំ២០២០ មិនបានលើកឡើងអំពីបញ្ហាប្រឈម ដែលត្រូវបានលើកឡើងនៅខាងលើនោះទេ ហើយរបាយការណ៍នោះក៏មិនបានផ្តល់បច្ចុប្បន្នភាពនៃទិដ្ឋភាពរបស់ប្រទេសទាំង ២៨ នៅអាស៊ី និង ប៉ាស៊ីហ្វិក ដែលបានលើកឡើងនៅខាងលើដែរ។

---

47 ទោះបីជាយ៉ាងណាក៏ដោយប្រទេសនៅអាស៊ីមួយចំនួន ឧ. ប្រទេសចិន ប្រទេសឥណ្ឌា សាធារណរដ្ឋកូរ៉េ និង តៃវ៉ាន់ ត្រូវបានលើកឡើងនៅក្នុងការសង្កេតការណ៍របស់ IBFD ចំពោះការការពារសិទ្ធិរបស់អ្នកជាប់ពន្ធ។ ការសង្កេតការណ៍នេះពិនិត្យតាមដានការអភិវឌ្ឍនានាដែលពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិមូលដ្ឋានរបស់អ្នកជាប់ពន្ធបានយ៉ាងមានប្រសិទ្ធភាព។ ព័ត៌មានអំពីការសង្កេតការណ៍មាននៅ https://www.ibfd.org/Academic/Observatory-Protection-Taxpayers-Rights (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

របាយការណ៍ឆ្នាំ២០២០ យោងតាមធាតុទូទៅនៅក្នុងធម្មនុញ្ញរបស់អ្នកជាប់ពន្ធ ដែលមាននៅក្នុងប្រទេសនានានៅអាស៊ី និង ប៉ាស៊ីហ្វិក (ដោយផ្អែកលើរបាយការណ៍ដែលអ្នកនិពន្ធបានចងក្រងដោយផ្ទាល់ [Highfield និង Chooi]) (ADB ២០២០:១០៥)។[48] របាយការណ៍ឆ្នាំ២០២០ ក៏យោងដល់គម្រោងសមូហភាពរវាងទីប្រឹក្សាពន្ធដារនៅអាស៊ី អឺរ៉ុប[49] និង សង្គមអ្នកអនុវត្តបរធនបាលកិច្ច និង ភោគទ្រព្យ ដើម្បីអភិវឌ្ឍគំរូធម្មនុញ្ញអ្នកជាប់ពន្ធ (Cadesky, Hayes និង Russell ឆ្នាំ២០១៥)។ ជាចុងក្រោយ របាយការណ៍ឆ្នាំ២០២០ ផ្តោតលើការទទួលបានសេចក្តីសម្រេច និង សិទ្ធិធ្វើការជំទាស់ នៅអាស៊ី និង ប៉ាស៊ីហ្វិក (ADB ២០២០:១០៣)។

## លិខិតុបករណ៍សម្រាប់ការការពារទិន្នន័យ និង ឯកជនភាព

នៅកម្រិតអន្តរជាតិ ទិន្នន័យរបស់អ្នកជាប់ពន្ធអាចត្រូវបានការពារដោយអនុសញ្ញាស្តីពីការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ របស់ក្រុមប្រឹក្សាអឺរ៉ុប ឆ្នាំ១៩៨១ (និង ពិធីសារនៃអនុសញ្ញានេះ ឆ្នាំ២០០១ និង ២០១៨) បើកចំហរសម្រាប់ការផ្តល់សច្ចាប័នដល់ប្រទេសដែលជាសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុប និង ប្រទេសលោកទីបី (ខាងក្រៅក្រុមប្រឹក្សា) ដែលអាចអនុវត្តចំពោះផ្នែកពន្ធដារ។[50] ប្រទេសមួយចំនួនក៏បានចុះហត្ថលេខាលើកកិច្ចព្រមព្រៀងទ្វេភាគីផងដែរ (ឧ. របាំងការពារឯកជនភាពរវាង EU–US[51])។

[48] ធាតុនានានៃធម្មនុញ្ញដែលបានលើកឡើង រួមមាន សេចក្តីថ្លែងការណ៍អំពីចេតនា សេចក្តីថ្លែងការណ៍អំពីកាតព្វកិច្ចទៅវិញទៅមក សិទ្ធិរបស់អ្នកជាប់ពន្ធ កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និង ព័ត៌មានលម្អិតអំពីសិទ្ធិ និង កាតព្វកិច្ចនានា។ ធាតុទាំងនេះមិនបានពិចារណាអំពីសិទ្ធិរបស់អ្នកជាប់ពន្ធនៅក្នុងនីតិវិធីចលនីយកម្មនោះទេ។

[49] នៅអឺរ៉ុប Confédération Fiscale Européenne (CFE); នៅអាស៊ី សមាគមទីប្រឹក្សាពន្ធដារនៅអាស៊ី និង អូសេអានី (AOTCA)។ អត្ថបទអំពីធម្មនុញ្ញមាននៅ http://www.taxpayercharter.com/index.asp

(បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)

[50] ចំពោះប្រវត្តិសាស្ត្ររបស់អនុសញ្ញា សូមមើល Greenleaf (២០១៨a)។

[51] សេចក្តីសម្រេចរបស់របាំងការពារឯកជនភាព រវាង EU–US ត្រូវបានអនុម័តនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ (គណៈកម្មការ EU ឆ្នាំ២០១៦) និង ក្របខណ្ឌនៃរបាំងការពារឯកជនភាព បានចាប់ផ្តើមដំណើរការនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។ ក្របខណ្ឌនេះការពារសិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូបនៅ EU ដែលទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានបញ្ជូនទៅកាន់សហរដ្ឋអាមេរិកក្នុងគោលបំណងពាណិជ្ជកម្ម។ ព័ត៌មាននេះមាននៅលើគេហទំព័ររបស់គណៈកម្មការ EU។ https://ec.europa.eu/info/law/law-topic/data- protection/data-transfers-outside-eu/eu-us-privacy-shield_en (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

នៅកម្រិតតំបន់ គួរតែមានការលើកឡើងអំពីលិខិតូបករណ៍ទាំងពីររបស់ EU៖ សេចក្តីណែនាំឆ្នាំ២០១៦(EU២០១៦a)និងបទប្បញ្ញត្តិស្តីពីការការពារទិន្នន័យ(ចូលជាធរមានតាំងពីខែឧសភា ឆ្នាំ២០១៨) (EU ២០១៦b)។ សេចក្តីណែនាំឆ្នាំ២០១៦ បានជំនួសសេចក្តីណែនាំស្តីពីកិច្ចការពារទិន្នន័យ ឆ្នាំ១៩៩៥។ កិច្ចព្រមព្រៀងប្រចាំតំបន់ដទៃទៀត រួមមាន (i) ក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច អាស៊ី-ប៉ាស៊ីហ្វិក (APEC) ឆ្នាំ២០០៥ ដែលបានណែនាំអំពីគោលការណ៍ឯកជនភាពនៃព័ត៌មាន[52] និង (ii) ច្បាប់បំពេញបន្ថែម ឆ្នាំ២០១០ ស្តីពីកិច្ចការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងសហគមន៍សេដ្ឋកិច្ចរបស់រដ្ឋនានានៅអាហ្វ្រិកខាងលិច (ECOWAS)។[53]

យោងតាមលិខិតូបករណ៍ដែលបានលើកឡើងនៅខាងលើការស្រាវជ្រាវដែលបានអនុវត្តដោយ Greenleaf បង្ហាញថា សេចក្តីណែនាំស្តីពីកិច្ចការពារទិន្នន័យ ឆ្នាំ១៩៩៥ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រទេសនានានៅខាងក្រៅអឺរ៉ុប រួមបញ្ចូលទាំងប្រទេសនានានៅអាស៊ី និង ប៉ាស៊ីហ្វិក ផងដែរ។[54] យោងតាម Greenleaf ក្របខណ្ឌ APEC មិនត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រទេសដែលមិនមែនជា EU នោះទេ ដូចជា សហរដ្ឋអាមេរិក ប្រទេសអូស្ត្រាលី ប្រទេសកាណាដា និង ប្រទេសម៉ិចស៊ិក ជាដើម ទោះបីជាវាត្រូវបានគេធ្វើបទបង្ហាញថាជាក្របខណ្ឌមួយដែលជំនួសឲ្យបទដ្ឋានរបស់ EU ក៏ដោយ (Greenleaf ២០១២:៧៥)។ មូលហេតុមួយចំនួនដែលត្រូវបានលើកឡើងដោយ Greenleaf រួមមាន ឧទាហរណ៍ "ស្ទើរតែគ្មានភ័ស្តុតាងដែលបង្ហាញអំពីការអនុម័តគោលការណ៍នេះនៅក្នុងនីតិបញ្ញត្តិប្រចាំតំបន់ ទាល់តែសោះ, មានកំណើនបន្តិចបន្តួចនៅក្នុងគំនិតផ្តួចផ្តើមស្តីពីការធ្វើនិយ័តកម្មដោយខ្លួនឯង (មានត្រាឯកជនភាពនៅក្នុងប្រទេសម៉ិចស៊ិក ប្រទេសវៀតណាម និង ប្រទេសជប៉ុន ប៉ុន្តែត្រាទាំងនោះមានតម្លៃដែលកំពុងស្ថិតក្នុងការពិភាក្សា)" (Greenleaf ២០១២:៧៥) នៅក្នុងមូលហេតុដទៃទៀត។

---

[52] ក្របខណ្ឌនេះក៏ផ្តល់ "គោលការណ៍ឯកជនភាពនៃព័ត៌មាន ដែល (១) បង្ការក្តីអន្តរាយ (២) ផ្តល់សេចក្តីជូនដំណឹង (៣) ដាក់កម្រិតលើការប្រមូល (៤) ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន (៥) យន្តការដើម្បីអនុវត្តជម្រើស (៦) សុចរិតភាពនៃព័ត៌មានផ្ទាល់ខ្លួន (៧) ការការពារសន្តិសុខ (៨) ការចូលប្រើប្រាស់ និង ការកែតម្រូវ (៩) គណនេយ្យភាព" (Debelva និង Mosquera Valderrama (២០១៧:៣៦៩)។ ខ្លឹមសាររបស់ក្របខណ្ឌឯកជនភាព APEC មាននៅ http:// www.apec.org/Groups/ Committee-on-Trade-and-Investment/~/media/Files/Groups/ECSG/05_ecsg_ privacyframewk.ashx (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[53] សូមមើលគេហទំព័រ ECOWAS ៖ https://ccdcoe.org/organisations/ecowas/ (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។ អត្ថបទនៃកិច្ចព្រមព្រៀង មាននៅ http://www.tit.comm.ecowas.int/wp-content/uploads/2015/11/ SIGNED-Data- Protection-Act.pdf (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[54] ឧទាហរណ៍មួយចំនួន រួមមាន ម៉ាកាវ សាធារណរដ្ឋកូរ៉េ តៃវ៉ាន់ ប្រទេសម៉ាឡេស៊ី ហុងកុង ប្រទេសអូស្ត្រាលី ប្រទេសនូវែលហ្សឺឡង់ ប្រទេសឥណ្ឌា ប្រទេសជប៉ុន និង ប្រទេសវៀតណាម។ សូមមើល Greenleaf (២០១២)។ សូមមើល Greenleaf (២០១៤b:៦២៤) ផងដែរ សម្រាប់ការវិភាគអំពីច្បាប់ស្តីពីឯកជនភាពនៃទិន្នន័យចំនួន ២៦ នៅអាស៊ី។

ដោយសារតែសេចក្តីណែនាំ និង បទប្បញ្ញត្តិឆ្នាំ២០១៦ គឺថ្មី គួរតែមានការស្រាវជ្រាវបន្ថែមថាតើបញ្ញត្តិនានានៃសេចក្តីណែនាំ និង បទប្បញ្ញត្តិទាំងនោះអាចត្រូវបានប្រើប្រាស់ដោយរបៀបណា ដើម្បីពង្រឹងកិច្ចការពារទិន្នន័យ និង ដើម្បីការពារសិទ្ធិឯកជនភាព។ កាលពីមុន Mosquera Valderrama et al. (២០១៧) បានផ្តល់ទឡ្ហីករណ៍នៅក្នុងការសិក្សាតាមបែបប្រៀបធៀបមួយថា "ពាក់ព័ន្ធនឹងសេចក្តីណែនាំអំពីកិច្ចការពារទិន្នន័យថ្មី របស់ EU និយមន័យជាក់លាក់របស់ពាក្យទិន្នន័យផ្ទាល់ខ្លួន ទិន្នន័យសេនេទិច និង ទិន្នន័យបាអូមេទ្រិច (មាត្រា ៣) និង កិច្ចការពារការដំណើរការទិន្នន័យទាំងនេះ ជាប្រភេទពិសេសៗនៃទិន្នន័យផ្ទាល់ខ្លួន (ទិន្នន័យរសើប) (មាត្រា ១០) អាចតំណាងឲ្យភាពរឹងមាំ ចាប់តាំងពីមានសេចក្តីណែនាំឆ្នាំ១៩៩៥ មក"។

ពាក់ព័ន្ធនឹងអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុប ការជះឥទ្ធិពលនៅខាងក្រៅប្រទេសសមាជិក នៅមានកម្រិត ដោយសារតែនៅពេលសរសេរនេះ មានប្រទេសមិនមែនសមាជិកតែប្រាំបីប្រទេសប៉ុណ្ណោះដែលបានផ្តល់សច្ចានុម័តនៅលើអនុសញ្ញានេះ។ ដោយសារនេះគឺជាកិច្ចព្រមព្រៀងចងកាតព្វកិច្ចពហុភាគីតែមួយគត់ដែលអាចមានការដាក់ពាក្យស្នើសុំទូទាំងពិភពលោក[55] តាមការយល់ឃើញរបស់យើង នៅមានកិច្ចការជាច្រើនទៀតដែលក្រុមប្រឹក្សាអឺរ៉ុបគួរតែអនុវត្ត ដើម្បីលើកកម្ពស់ការអនុម័តលើអនុសញ្ញានេះ ដោយប្រទេសមិនមែនសមាជិក។[56] ចំណុចខ្សោយមួយរបស់អនុសញ្ញានេះគឺថាវាអាចអនុវត្តបានតែចំពោះទិន្នន័យផ្ទាល់ខ្លួនតែប៉ុណ្ណោះ។អាស្រ័យហេតុនេះគេបានផ្តល់អនុសាសន៍ឲ្យក្រុមប្រឹក្សាអឺរ៉ុបធ្វើការលាតសន្ធឹងកិច្ចការពាររបស់អនុសញ្ញានេះទៅកាន់ទិន្នន័យពាណិជ្ជកម្ម ដែលរួមបញ្ចូលទាំង ការសម្ងាត់ពាណិជ្ជកម្មផងដែរ។ ធាតុសំខាន់ៗរបស់អនុសញ្ញានេះត្រូវបានបង្ហាញនេះខាងក្រោម។

## អនុសញ្ញាស្តីពីការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ របស់ក្រុមប្រឹក្សាអឺរ៉ុប

នៅឆ្នាំ១៩៨១ ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តអនុសញ្ញា ១០៨ ដើម្បីការពារបុគ្គលទាំងឡាយពាក់ព័ន្ធនឹងការដំណើរការទិន្នន័យដោយស្វ័យប្រវត្តិ។ អនុសញ្ញានេះការពារបុគ្គលទាំងនោះប្រឆាំងនឹងការបំពានដែលអាចកើតឡើងស្របពេលជាមួយគ្នានឹងការប្រមូល និង ការដំណើរការទិន្នន័យផ្ទាល់ខ្លួន និង ស្របពេលជាមួយគ្នានោះ ធ្វើនិយ័តកម្មលំហូរទិន្នន័យផ្ទាល់ខ្លួនឆ្លងព្រំដែន

[55] ការប្រើប្រាស់អនុសញ្ញានៅកម្រិតសកល ត្រូវបានលើកឡើងដោយ Greenleaf (២០១២:៦៨–៩២)។

[56] មូលហេតុមួយដែលប្រទេសនានាមិនចូលរួមនៅក្នុងអនុសញ្ញានេះ ត្រូវបានលើកឡើងដោយ Greenleaf (២០១២) ដែលបានសំដៅដល់កង្វះខាតតម្លាភាពលើការទទួលបានអនុសញ្ញា។

(Mosquera Valderrama ២០១៩)។ អនុសញ្ញានេះត្រូវបានធ្វើវិសោធនកម្មដោយពិធីសារចំនួនពីរ។[57]

ពិធីសារទីមួយត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០១ និង បានលាតសន្ធឹងអនុសញ្ញានេះសម្រាប់ការអនុម័តដោយប្រទេសមិនមែនសមាជិក (ប្រទេសដែលនៅខាងក្រៅក្រុមប្រឹក្សាអឺរ៉ុប)។ អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុប ចំនួន ៤៧ ប្រទេស និង ប្រទេសមិនមែនសមាជិកចំនួន ៨ ប្រទេស ពោលគឺ ប្រទេសអាហ្សង់ទីន, ប្រទេស Cabo Verde, ប្រទេស Mauritius, ប្រទេសម៉ិកស៊ិក, ប្រទេសម៉ូរ៉ូកូ, ប្រទេសសេនេហ្គាល់ និង ប្រទេសអ៊ុយរ៉ាហ្គាយ។

ពិធីសារទីពីរត្រូវបានអនុម័តនៅខែឧសភា ឆ្នាំ២០១៨ និង ត្រូវបានបើកចំហរសម្រាប់ចុះហត្ថលេខាត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។[58] ពិធីសារនេះមានវត្ថុបំណងពីរសំខាន់ៗ៖ ដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ថ្មីៗ និង ពង្រឹងការអនុវត្តយ៉ាងមានប្រសិទ្ធភាពរបស់អនុសញ្ញានេះ។ ពិធីសារនេះត្រូវបានចុះហត្ថលេខាដោយ ៣៨ ប្រទេស ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុបទាំង ៤៧ ប្រទេស និង ដោយ ៣ ក្នុងចំណោម ៨ ប្រទេសដែលមិនមែនជាសមាជិក (ប្រទេសអាហ្សង់ទីន ប្រទេសទុយណេហ្ស៊ី និង ប្រទេសអ៊ុយរ៉ាហ្គាយ) សរុបមានចំនួន ៤១ ប្រទេស។

យោងតាមប្រទេសដៃគូអាស៊ី នៅក្នុង ASEM មានតែប្រទេសរុស្ស៊ីប៉ុណ្ណោះដែលបានចុះហត្ថលេខា និង បានផ្តល់សច្ចាប័នលើអនុសញ្ញា ១០៨ និង បានចុះហត្ថលេខាលើពិធីសារឆ្នាំ២០១៨ (រង់ចាំការផ្តល់សច្ចាប័ន)។ ប្រទេស ASEM មួយចំនួន មានឋានៈជាអ្នកសង្កេតការណ៍ចំពោះអនុសញ្ញា ១០៨ (ប្រទេសនូវែលហ្សេឡង់ ប្រទេសអូស្ត្រាលី ប្រទេសឥណ្ឌូនេស៊ី ប្រទេសហ្វីលីពីន ប្រទេសជប៉ុន និង សាធារណរដ្ឋកូរ៉េ)។

ប្រទេសអឺរ៉ុបបានចុះហត្ថលេខា និង បានផ្តល់សច្ចាប័នដល់អនុសញ្ញា ១០៨។ គិតត្រឹមខែកក្កដា ឆ្នាំ២០២០ ពិធីសារ ២០១៨ ត្រូវបានចុះហត្ថលេខាដោយប្រទេសនៃ EU ស្ទើរតែទាំងអស់

---

[57] ធាតុមួយចំនួនដែលត្រូវបានវិភាគនៅក្នុងផ្នែកនេះ ត្រូវបានលើកឡើងកាលពីមុន ដោយ Mosquera Valderrama, Affuso និង Coco (២០១៩)។

[58] ព័ត៌មានលម្អិតអំពីសន្ធិសញ្ញាលេខ ២២៣ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨។ https://www.coe.int/en/web/conventions/full-list/-/ conventions/treaty/223 (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

(លើកលែងប្រទេសដាណឺម៉ាក) ហើយអនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួនបួន (ប្រទេសប៊ុលហ្គារី ប្រទេសក្រូអាត ប្រទេសប៉ូឡូញ និង ប្រទេសលីទូអានី)។[59]

## អនុសញ្ញា

អនុសញ្ញាអាចអនុវត្តបានចំពោះបណ្តុំទិន្នន័យផ្ទាល់ខ្លួនដែលដំណើរការដោយស្វ័យប្រវត្តិ និង ការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន (មាត្រា ៣)។[60] មាត្រាចំនួនបួននៃអនុសញ្ញានេះ ដែលអាចជាពាក់ព័ន្ធនឹងរដ្ឋបាលពន្ធដារនៅក្នុងយុគសម័យរដ្ឋបាលឌីជីថលនេះ គឺ មាត្រា ៥ ៦ ៧ និង ៨។ មាត្រា ៥ លើកឡើងអំពីគុណភាពរបស់ទិន្នន័យ ដែលអះអាងថា "ទិន្នន័យផ្ទាល់ខ្លួនដែលឆ្លងកាត់ដំណើរការដោយស្វ័យប្រវត្តិនឹងត្រូវទទួលបាន និង ដំណើរការដោយសុក្រឹត និង ត្រឹមត្រូវតាមច្បាប់ នឹងត្រូវរក្សាទុកសម្រាប់គោលបំណងដែលបានបញ្ជាក់ និង ដែលស្របច្បាប់ និង មិនត្រូវប្រើប្រាស់តាមវិធីណាមួយដែលមិនស្របតាមគោលបំណងទាំងនោះទេ មានភាពគ្រប់គ្រាន់ មានទំនាក់ទំនង និង មិនច្រើនពេកពាក់ព័ន្ធនឹងគោលបំណងក្នុងការរក្សាទុកទិន្នន័យទាំងនោះ មានភាពត្រឹមត្រូវ និង ប្រសិនបើចាំបាច់ត្រូវបានធ្វើបច្ចុប្បន្នភាព ត្រូវបានរក្សាទុកនៅក្នុងទម្រង់ដែលអនុញ្ញាតឲ្យមានការធ្វើអត្តសញ្ញាណកម្មកម្មវត្ថុនៃទិន្នន័យទាំងនោះ ក្នុងរយៈពេលមិនលើសពីរយៈពេលដែលចាំបាច់សម្រាប់គោលបំណងក្នុងការរក្សាទុកទិន្នន័យទាំងនោះទេ។[61]

[59] តារាងចុះហត្ថលេខា និង ផ្តល់សច្ចាប័នដល់សន្ធិសញ្ញា ២២៣ គិតត្រឹមថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០។ https://www.coe.int/en/web/ conventions/full-list/-/conventions/treaty/223/signatures (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[60] យោងតាមមាត្រា ២ "ទិន្នន័យផ្ទាល់ខ្លួន" មានន័យថា ព័ត៌មានណាមួយដែលទាក់ទងនឹងបុគ្គលត្រូវបានសម្គាល់ឃើញ ឬ អាចត្រូវបានសម្គាល់ឃើញ ("កម្មវត្ថុរបស់ទិន្នន័យ")។ "បណ្តុំទិន្នន័យស្វ័យប្រវត្តិ" មានន័យថាបណ្តុះទិន្នន័យណាមួយដែលឆ្លងកាត់ការដំណើរការដោយស្វ័យប្រវត្តិ។ "ការដំណើរការដោយស្វ័យប្រវត្តិ" រួមបញ្ចូលប្រតិបត្តិការនានាដូចតទៅ ប្រសិនបើត្រូវបានអនុវត្តទាំងស្រុង ឬ មួយផ្នែកតាមវិធីស្វ័យប្រវត្តិ៖ ការរក្សាទុកទិន្នន័យ ការធ្វើប្រតិបត្តិការសមស្រប និង/ឬ ប្រតិបត្តិការគណនាតួលេខនៅលើទិន្នន័យទាំងនោះ កែប្រែ លុបចោល ទាញយក ឬ ចែកចាយទិន្នន័យទាំងនោះ និង "អ្នកគ្រប់គ្រងបណ្តុំទិន្នន័យ" មានន័យថាជារូបវន្តបុគ្គល ឬ នីតិបុគ្គល អាជ្ញាធរសាធារណៈ ទីភ្នាក់ងារ ឬ អង្គភាពណាមួយផ្សេងទៀត ដែលមានសមត្ថកិច្ចយោងតាមច្បាប់ជាតិ នៅក្នុងការសម្រេចចិត្ត ថាតើអ្វីខ្លះដែលគួរតែជាគោលបំណងរបស់បណ្តុំទិន្នន័យដែលដំណើរការដោយស្វ័យប្រវត្តិ ថាតើទិន្នន័យផ្ទាល់ខ្លួនប្រភេទណាខ្លះដែលគួរតែរក្សាទុក និង ថាតើប្រតិបត្តិការអ្វីខ្លះដែលគួរតែអនុវត្តចំពោះបណ្តុំទិន្នន័យទាំងនោះ (https://rm.coe.int/1680078b37 បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

[61] មាត្រា ៥ នៃអនុសញ្ញា។

លើសពីនេះទៀត មាត្រា ៦ លើកឡើងអំពីកិច្ចការពារប្រភេទទិន្នន័យពិសេសៗ ដែលអះអាងថា "ទិន្នន័យផ្ទាល់ខ្លួនដែលលាតត្រដាងអំពីដើមកំណើតនៃជាតិសាសន៍ គំនិតផ្នែកនយោបាយ ឬ ជំនឿសាសនា ឬ ជំនឿដទៃទៀត ព្រមទាំង ព័ត៌មានផ្ទាល់ខ្លួនដែលពាក់ព័ន្ធនឹងសុខភាព ឬ ជីវិតផ្លូវភេទផងដែរ ប្រហែលជាមិនត្រូវបានដំណើរការដោយស្វ័យប្រវត្តិនោះទេ លើកលែងតែច្បាប់ក្នុងប្រទេសបានចែងអំពីការការពារយ៉ាងសមស្រប។ ការលើកឡើងនេះក៏អនុវត្តចំពោះទិន្នន័យផ្ទាល់ខ្លួនដែលទាក់ទងនឹងការផ្តន្ទាទោសផងដែរ"។[62]

មាត្រា ៧ ណែនាំអំពីលក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាពទិន្នន័យ ដែលអះអាងថា "វិធីសាស្ត្រសុវត្ថិភាពដែលសមស្រប នឹងត្រូវអនុវត្តចំពោះការការពារទិន្នន័យផ្ទាល់ខ្លួនដែលត្រូវបានរក្សាទុកនៅក្នុងបណ្តុំទិន្នន័យស្វ័យប្រវត្តិ ប្រឆាំងនឹងការបំផ្លាញដោយអចេតនា ឬ ដោយគ្មានការអនុញ្ញាត ឬ ការបាត់បង់ដោយអចេតនា ព្រមទាំង ប្រឆាំងនឹងការចូលប្រើប្រាស់ ការកែប្រែ ឬ ការចែកចាយដោយគ្មានការអនុញ្ញាតផងដែរ"។[63]

មាត្រា ៨ ចែងអំពីការការពារសុវត្ថិភាពបន្ថែមទៀតចំពោះរូបវន្តបុគ្គលដែលត្រូវបានសម្គាល់ឃើញ ឬ អាចត្រូវបានសម្គាល់ឃើញ (កម្មវត្ថុរបស់ទិន្នន័យ)។ អាស្រ័យហេតុនេះ "មនុស្សម្នាក់នឹងត្រូវបានអនុញ្ញាតឲ្យ៖

- បង្កើតអត្ថិភាពនៃបណ្តុំទិន្នន័យផ្ទាល់ខ្លួនស្វ័យប្រវត្តិ គោលបំណងចម្បងរបស់ខ្លួន ព្រមទាំង អត្តសញ្ញាណ និង ទីលំនៅជាប់លាប់ ឬ ទីតាំងគោលនៃការធ្វើអាជីកម្ម របស់អ្នកគ្រប់គ្រងបណ្តុំទិន្នន័យនោះ
- ទទួលបានទិន្នន័យនៅចន្លោះពេលដែលសមហេតុផល និង ដោយគ្មានភាពយឺតយ៉ាវខ្លាំងពេក ឬ មានការបញ្ជាក់អំពីចំណាយ ថាតើទិន្នន័យផ្ទាល់ខ្លួនដែលទាក់ទងនឹងគាត់ត្រូវបានរក្សាទុកនៅក្នុងបណ្តុំទិន្នន័យស្វ័យប្រវត្តិដែរឬទេ ព្រមទាំង ជូនដំណឹងអំពីទិន្នន័យទាំងនោះទៅកាន់អ្នកប្រើប្រាស់ក្នុងទម្រង់ដែលអាចយល់បាន
- ទទួលបាន តាមករណីដែលអាចកើតឡើង ការកែតម្រូវ ឬ ការលុបចោលទិន្នន័យទាំងនោះ ប្រសិនបើទិន្នន័យទាំងនោះត្រូវបានដំណើរការផ្ទុយពីបញ្ញត្តិនានានៃច្បាប់ក្នុងប្រទេស ដែលផ្តល់

---

[62] មាត្រា ៦ នៃអនុសញ្ញា។

[63] មាត្រា ៧ នៃអនុសញ្ញា។

ប្រសិទ្ធភាពអនុវត្តដល់គោលការណ៍មូលដ្ឋានដែលមានចែងនៅក្នុងមាត្រា ៥ និង ៦ នៃអនុសញ្ញានេះ

- មានឧបាស្រ័យប្រសិនបើការស្នើសុំបញ្ជាក់ឬតាមករណីដែលអាចកើតឡើងការស្នើសុំព័ត៌មានការកែតម្រូវ ឬ ការលុបចោល ដូចបានយោងដល់នៅក្នុងកថាខណ្ឌ ខ និង គ នៃមាត្រានេះ មិនត្រូវបានអនុលោមតាម។[64]

## *គោលការណ៍ណែនាំ ឆ្នាំ២០១៧ និង ពិធីសារ ឆ្នាំ២០១៨*

អនុសញ្ញានេះត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីឆ្នាំ១៩៨១ មក (ជាង ៣០ ឆ្នាំ)។ អាស្រ័យហេតុនេះ កាលពីឆ្នាំ ២០១២ ក្រុមប្រឹក្សាអឺរ៉ុបបានសម្រេចចិត្តធ្វើទំនើបកម្មអនុសញ្ញានេះ “ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកឯកជនភាពដែលកំពុងតែលេចឡើង ដែលបណ្តាលមកពីកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ថ្មីៗ (IT), សកលភាវូបនីយកម្មនៃការដំណើរការប្រតិបត្តិការនានាឲ្យបានល្អប្រសើរជាងមុន និង លំហូរទិន្នន័យផ្ទាល់ខ្លួនបានកាន់តែល្អថែមទៀត” (ក្រុមប្រឹក្សាអឺរ៉ុប ២០១៨a)។

ដោយសារមូលហេតុនេះ ក្រុមប្រឹក្សាអឺរ៉ុបបានផ្តល់អាណត្តិដល់ការសិក្សាអំពីគោលការណ៍ណែនាំថ្មីមួយ (ក្រុមប្រឹក្សាអឺរ៉ុប ឆ្នាំ២០១៧) ស្តីពីកិច្ចការពារបុគ្គល ពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួននៅក្នុងពិភពទិន្នន័យខ្នាតធំ។ គោលការណ៍ណែនាំទាំងនេះ (ត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១៧) ត្រូវបានយកមកពិភាក្សានៅក្នុងគណៈកម្មាធិការពិគ្រោះយោបល់នៃអនុសញ្ញាសម្រាប់កិច្ចការពារបុគ្គល ពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ។[65] នាពេលថ្មីៗនេះ គោលការណ៍ណែនាំថ្មីៗត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១៩ ស្តីពីប្រាជ្ញាសិប្បនិម្មិត (AI) និង កិច្ចការពារទិន្នន័យ (ក្រុមប្រឹក្សាអឺរ៉ុប ឆ្នាំ២០១៩)។

[64] មាត្រា ៨ នៃអនុសញ្ញា។

[65] គោលការណ៍ណែនាំទាំងនេះមិនត្រូវបានទទួលស្គាល់ដោយសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុបទាំងអស់នោះទេ។ ក្នុងចំណោមសមាជិកដែលមានសម្លេងឆ្នោតចំនួន ៥០ ប្រទេស ដែលបានទទួលការពិគ្រោះយោបល់តាមរយៈនីតិវិធីជាលាយលក្ខណ៍អក្សរ ប្រទេសដាណឺម៉ាក ប្រទេសលិចទេនស្តែន និង ប្រទេសលុចហ្សំបួរ បានធ្វើអនុប្បវាទ ហើយប្រទេសអាល្លឺម៉ង់ និង ប្រទេសអៀរឡង់បានបដិសេធ។

[66] យោងតាមសេចក្តីណែនាំបឋម គោលការណ៍ណែនាំទាំងនេះចែងអំពីបណ្តុំវិធីសាស្ត្រមូលដ្ឋានដែលរដ្ឋាភិបាល, អ្នកអភិវឌ្ឍ AI, អ្នកផលិត និង អ្នកផ្តល់សេវាកម្ម គួរតែអនុវត្តតាម ដើម្បីធានាថា កម្មវិធី AI មិនបានបំផ្លាញកិត្តិយសរបស់មនុស្ស និង សិទ្ធិមនុស្ស និង សេរីភាពមូលដ្ឋានរបស់បុគ្គលម្នាក់នោះទេ ជាពិសេស ពាក់ព័ន្ធនឹងសិទ្ធិការពារទិន្នន័យ។

គោលការណ៍ណែនាំទាំងនេះមិនទាន់ត្រូវបានប្រើប្រាស់នៅក្នុងអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុបនៅឡើយទេ អាស្រ័យហេតុនេះ វាស្ថិតនៅក្រៅវិសាលភាពនៃការវិភាគនេះ។[66]

គោលការណ៍ណែនាំឆ្នាំ២០១៧ ស្តីពីការការពារបុគ្គល សម្រាប់ការដំណើរការទិន្នន័យផ្ទាល់ខ្លួន ត្រូវបានអនុវត្តចំពោះទិន្នន័យខ្នាតធំ និង ការវិភាគអំពីទិន្នន័យខ្នាតធំ។ នៅក្នុងបរិបទនេះ គោលការណ៍ចែងថា “ពាក់ព័ន្ធនឹងការការពារទិន្នន័យ បញ្ហាចម្បងមិនពាក់ព័ន្ធតែនឹងទំហំ ល្បឿន និង ភាពចម្រុះនៃទិន្នន័យដែលត្រូវបានដំណើរការតែប៉ុណ្ណោះ ប៉ុន្តែក៏ពាក់ព័ន្ធនឹងការវិភាគទិន្នន័យដោយប្រើប្រាស់សូហ្វវែរដើម្បីទាញយកចំណេះដឹងថ្មីៗនិងចំណេះដឹងអំពីការទស្សន៍ទាយទុកមុនក្នុងគោលបំណងធ្វើការសម្រេចចិត្ត ដែលទាក់ទងនឹងបុគ្គល និង ក្រុមនានាផងដែរ” (ក្រុមប្រឹក្សាអឺរ៉ុប ២០១៧:២)។ អាស្រ័យហេតុនេះ គោលការណ៍ណែនាំទាំងនេះ ផ្តល់ការណែនាំអំពីអភិក្រមប្រុងប្រយ័ត្នជាមុន នៅក្នុងការធ្វើនិយ័តកម្មកិច្ចការពារទិន្នន័យ និង ការណែនាំអំពីការវាយតម្លៃហានិភ័យដោយពិចារណាអំពីផលប៉ះពាល់ផ្នែកច្បាប់សង្គមនិងសីលធម៌នៃការប្រើប្រាស់ទិន្នន័យខ្នាតធំផងដែរ។

លើសពីនេះទៀត អ្នកគ្រប់គ្រងគួរតែអនុម័តគោលនយោបាយបង្ការ ដើម្បីធានាចំពោះការការពារបុគ្គលដែលពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួន និង ណែនាំវិធានការសមស្របដើម្បីកំណត់ និង កាត់បន្ថយហានិភ័យនៃការដំណើរការទិន្នន័យតាមរយៈការណែនាំអំពីវិធីសាស្ត្រនានា ដូចជា ដំណោះស្រាយ “តាមការរចនា” និង “តាមការកំណត់ដោយស្វ័យប្រវត្តិ”។[67]

ដោយអនុវត្តតាមកម្រិតមួយចំនួននៃគោលការណ៍ណែនាំឆ្នាំ២០១៧[68] ពិធីសារឆ្នាំ២០១៨ ចែងអំពីតម្លាភាព និង កិច្ចការពារកាន់តែខ្លាំងនៅក្នុងការដំណើរការទិន្នន័យ និង ណែនាំអំពីគណនេយ្យភាពកាន់តែខ្លាំង សម្រាប់អ្នកគ្រប់គ្រងទិន្នន័យ និង កាតព្វកិច្ចនៅក្នុងការប្រកាសអំពីការបំពានលើទិន្នន័យទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចពិសេសដ៏សំខាន់មួយគឺ

67 “តាមការរចនា” សំដៅលើ មានការពិចារណាអំពីវិធានការបច្ចេកទេស និង វិធានការរៀបចំដ៏សមស្រប នៅក្នុងដំណើរការទាំងមូលនៃការគ្រប់គ្រងទិន្នន័យ ចាប់តាំងពីដំណាក់កាលរចនាដំបូងគេបង្អស់ រហូតដល់ការអនុវត្តគោលការណ៍ច្បាប់យ៉ាងមានប្រសិទ្ធភាព និង ការបង្កើតការការពារទិន្នន័យនៅក្នុងផលិតផល និង សេវាកម្មនានា។ យោងតាមអភិក្រម “តាមការកំណត់ដោយស្វ័យប្រវត្តិ” ចំពោះការការពារទិន្នន័យ វិធានការ នានាដែលការពារសិទ្ធិទទួលបានការការពារទិន្នន័យ គឺជាការកំណត់ដោយស្វ័យប្រវត្តិ ហើយចំណុចដែលគួរឲ្យកត់សម្គាល់គឺ ពួកគេធានាថាមានតែព័ត៌មានផ្ទាល់ខ្លួនដែលចាំបាច់ចំពោះការដំណើរការប៉ុណ្ណោះ ដែលនឹងត្រូវដំណើរការ” (ក្រុមប្រឹក្សាអឺរ៉ុប ២០១៧:២)។

68 ឧទាហរណ៍៖ ពាក់ព័ន្ធនឹងដំណោះស្រាយ “តាមការរចនា” និង “ដោយស្វ័យប្រវត្តិ” ចំពោះការកាត់បន្ថយហានិភ័យនៅក្នុងការដំណើរការទិន្នន័យផ្ទាល់ខ្លួន សូមមើលកថាខណ្ឌ ២.៥.(២) នៃក្រុមប្រឹក្សាអឺរ៉ុប (២០១៧) និង មាត្រា ១០ នៃពិធីសារឆ្នាំ២០១៨ និង កថាខណ្ឌ ៨៩ នៃសេចក្តីអធិប្បាយ (ក្រុមប្រឹក្សាអឺរ៉ុប ២០១៨b)។

វាមិនដូចគ្នាទៅនឹងគោលការណ៍ណែនាំឆ្នាំ២០១៧ នោះទេ និង ពុំមានសេចក្តីយោងជាក់លាក់ណាមួយត្រូវបានធ្វើឡើងចំពោះទិន្នន័យខ្នាតធំ នៅក្នុងពិធីសារ ឆ្នាំ២០១៨ ឡើយ។[69]

ពិធីសារ ឆ្នាំ២០១៨ ក៏ណែនាំអំពីភាពស្របច្បាប់នៃការដំណើរការទិន្នន័យ (មាត្រា ៥ នៃអនុសញ្ញា) ផងដែរ ដែលអះអាងថា "ការដំណើរការត្រូវមានសមាមាត្រ ពាក់ព័ន្ធនឹងគោលបំណងស្របច្បាប់ និង ឆ្លុះបញ្ចាំងអំពីគ្រប់ដំណាក់កាលទាំងអស់នៃការដំណើរការ ដោយមានតុល្យភាពដ៏សុក្រឹតមួយរវាងផលប្រយោជន៍ដែលពាក់ព័ន្ធទាំងអស់ទោះបីជាផលប្រយោជន៍សាធារណៈ ឬ ឯកជនក្តី និង សិទ្ធិ និង សេរីភាព ដែលត្រូវលើកយកមកពិភាក្សា"។[70]

លើសពីនេះទៀត មាត្រា ៦ ចែងថា កិច្ចការពារដំណើរការទិន្នន័យគួរតែរួមបញ្ចូលទិន្នន័យសេនេទិច ទិន្នន័យផ្ទាល់ខ្លួន (រួមទាំង ទិន្នន័យរសើប ផងដែរ) និង ទិន្នន័យជីវសាស្រ្ត។ អ្នកគ្រប់គ្រងក៏ត្រូវតែជូនដំណឹងអំពីការបំពានលើទិន្នន័យផងដែរ។

ទោះបីជាទិន្នន័យខ្នាតធំមិនត្រូវបានលើកឡើងយ៉ាងជាក់លាក់នៅក្នុងអត្ថបទនៃពិធីសារក៏ដោយ ក៏វាបានណែនាំអំពីសិទ្ធិថ្មីៗសម្រាប់បុគ្គលទាំងឡាយ នៅក្នុងបរិបទនៃការសម្រេចផ្អែកអាល់កូរីត។ សិទ្ធិទាំងនេះមានទំនាក់ទំនងជាពិសេសនឹងការអភិវឌ្ឍការវិភាគទិន្នន័យ និង ប្រាជ្ញាសិប្បនិម្មិត។ អាស្រ័យហេតុនេះ មាត្រា ៩ (១[ក] និង [គ]) នៃពិធីសារ ឆ្នាំ២០១៨ ដោយឡែកពីគ្នា បានអះអាងថា កម្មវត្ថុរបស់ទិន្នន័យមានសិទ្ធិ (i) "មិនអាស្រ័យលើការសម្រេចចិត្តណាមួយដែលមានផលជះយ៉ាងខ្លាំងចំពោះបុគ្គលទាំងនោះ ដោយផ្អែកលើការដំណើរការទិន្នន័យដោយស្វ័យប្រវត្តិតែមួយមុខ ដោយមិនបានពិចារណាអំពី ទស្សនៈរបស់ពួកគេនោះទេ" និង (ii) "ទទួលបានតាមការស្នើសុំ ការដឹងអំពីមូលហេតុដែលជាមូលដ្ឋាននៃការដំណើរការនោះ ប្រសិនបើលទ្ធផលនៃការដំណើរការបែបនោះ ត្រូវអនុវត្តចំពោះពួកគេ"។[71]

លើសពីនេះទៀត ពិធីសារ ឆ្នាំ២០១៨ រួមបញ្ចូលកាតព្វកិច្ចរបស់អ្នកគ្រប់គ្រង និង អ្នកដំណើរការទិន្នន័យ នៅក្នុងការណែនាំអំពីឯកជនភាព តាមការរចនា, គោលការណ៍ និង ឯកជនភាព

[69] ឧទាហរណ៍៖ នៅក្នុងការស្វែងរកពាក្យ "ទិន្នន័យខ្នាតធំ" នៅក្នុងគោលការណ៍ណែនាំ ឆ្នាំ២០១៧ "ទិន្នន័យខ្នាតធំ" ត្រូវបានលើកឡើងចំនួន ៣៣ ដង នៅខណៈពេលដែល នៅក្នុងពិធីសារ ឆ្នាំ២០១៨ រកមិនឃើញនោះទេ។ ប្រាកដណាស់ គោលការណ៍ណែនាំមានបំណងផ្តល់បញ្ញត្តិជាក់លាក់ ដើម្បីធ្វើនិយ័តកម្មទិន្នន័យខ្នាតធំ ដើម្បីលើកឡើងអំពីផលប៉ះពាល់នៃការដំណើរការទិន្នន័យធំ និង អត្ថន័យផ្នែកជាតិពន្ធ និង ផ្នែកសង្គមរបស់ទិន្នន័យទាំងនោះឲ្យបានកាន់តែទូលំទូលាយ ដើម្បីការពារសិទ្ធិមនុស្ស និង សេរីភាពមូលដ្ឋាន។

[70] សូមមើល មាត្រ ៧ នៃពិធីសារ ឆ្នាំ២០១៨។

[71] សូមមើលកថាខណ្ឌទី ៧៥ និង ៧៧ នៃសេចក្តីអធិប្បាយ (ក្រុមប្រឹក្សាអឺរ៉ុប ២០១៨b) ផងដែរ។

តាមការកំណត់ដោយស្វ័យប្រវត្តិ (មាត្រា ១០ ពិធីសារ ឆ្នាំ២០១៨)។

ចំពោះឯកជនភាព តាមការរចនា (មាត្រា ១០ [១]) កាតព្វកិច្ចទាំងនេះ រួមមាន៖ “(i) ការអនុវត្តដោយអ្នកគ្រប់គ្រង/អ្នកដំណើរការវិធានការបច្ចេកទេស និង វិធានការរៀបចំ ដែលពិចារណាអំពីអត្ថន័យនៃសិទ្ធិការពារទិន្នន័យផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃការដំណើរការទិន្នន័យ(ii)មុនពេលចាប់ផ្ដើមដំណើរការការត្រួតពិនិត្យផលប៉ះពាល់ដែលទំនងនឹងកើតឡើងនៃការដំណើរការទិន្នន័យដែលបំណងធ្វើឡើងនោះ ចំពោះសិទ្ធិ និង សេរីភាពមូលដ្ឋានរបស់កម្មវត្ថុនៃទិន្នន័យ និង (iii) ការរចនាការដំណើរការទិន្នន័យតាមវិធីដែលវាទប់ស្កាត់ (ឬកាត់បន្ថយជាអប្បបរមានូវ)ហានិភ័យនៃការជ្រៀតជ្រែកដល់សិទ្ធិនិងសេរីភាពមូលដ្ឋានទាំងនោះ។ការកែប្រែទាំងនេះមានបំណងធ្វើឲ្យអ្នកគ្រប់គ្រង/អ្នកដំណើរការទិន្នន័យ មានការយល់ដឹងអំពីការការពារទិន្នន័យ ហានិភ័យនៃការដំណើរការទិន្នន័យខ្នាតធំ និង ពិចារណាអំពីហានិភ័យទាំងនោះនៅពេលរចនាប្រព័ន្ធដំណើរការទិន្នន័យរបស់ពួកគេ” (Mosquera Valderrama ឆ្នាំ២០១៩)។

ចំពោះឯកជនភាពតាមការកំណត់ដោយស្វ័យប្រវត្តិ ពិធីសារឆ្នាំ២០១៨ ចែងថា អ្នកគ្រប់គ្រង និង អ្នកដំណើរការគួរតែអនុវត្តវិធានការបច្ចេកទេស និង វិធានការរៀបចំ ដែលពិចារណាអំពីអត្ថន័យនៃសិទ្ធិទទួលបានការការពារទិន្នន័យ នៅគ្រប់ដំណាក់កាលទាំងអស់នៃការដំណើរការទិន្នន័យ (មាត្រា ១០[៣])។ សេចក្ដីអធិប្បាយចំពោះពិធីសារនេះ រៀបរាប់លម្អិតអំពីឯកជនភាពនេះបន្ថែមទៀត តាមគោលការណ៍នៃការកំណត់ដោយស្វ័យប្រវត្តិ៖ “នៅពេលកំណត់លក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសសម្រាប់ការកំណត់ដោយស្វ័យប្រវត្តិ អ្នកគ្រប់គ្រង និង អ្នកដំណើរការទិន្នន័យគួរតែជ្រើសរើសសណ្ឋាននៃបទដ្ឋានដែលអំណោយផលចំពោះឯកជនភាព ធ្វើដូច្នេះការប្រើប្រាស់កម្មវិធី និង សូហ្វវែរនឹងមិនបំពានលើសិទ្ធិរបស់កម្មវត្ថុនៃទិន្នន័យនោះទេ (ការការពារទិន្នន័យតាមការកំណត់ដោយស្វ័យប្រវត្តិ) ជាពិសេស ដើម្បីជៀសវាងដំណើរការទិន្នន័យច្រើនជាងការចាំបាច់ និង ដើម្បីសម្រេចគោលបំណងតាមផ្លូវច្បាប់។ ឧទាហរណ៍៖ បណ្ដាញសង្គមគួរតែត្រូវបានរៀបចំឡើងតាមការកំណត់ដោយស្វ័យប្រវត្តិ ធ្វើដូច្នេះ ការផ្សព្វផ្សាយ ឬ រូបភាពនានាអាចចែករំលែកបានលុះត្រាតែមានការរឹតត្បិត និង មានរង្វង់ដែលត្រូវបានជ្រើសរើស និង មិនមែនសម្រាប់ប្រព័ន្ធអ៊ីនធឺណិតទាំងមូលនោះទេ”។[72]

[72] សូមមើលកថាខណ្ឌទី ៨៩ នៃសេចក្ដីអធិប្បាយ (ក្រុមប្រឹក្សាអឺរ៉ុប ២០១៨a) ផងដែរ។

## សេចក្តីណែនាំ និង បទប្បញ្ញត្តិស្តីពីការការពារទិន្នន័យទូទៅរបស់ EU

សេចក្តីណែនាំអំពីការការពារទិន្នន័យរបស់ EU (EU) ២០១៦/៦៨០ និង បទប្បញ្ញត្តិ (EU) ២០១៦/៦៧៩ (ចូលជាធរមាននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨) អនុវត្តចំពោះការដំណើរការទិន្នន័យផ្ទាល់ខ្លួនទាំងមូល ឬ មួយផ្នែកតាមរយៈវិធីសាស្ត្រស្វ័យប្រវត្តិ ព្រមទាំង ការដំណើរការមិនស្វ័យប្រវត្តិផងដែរ។[73] សេចក្តីណែនាំ និង បទប្បញ្ញត្តិ ឆ្នាំ២០១៦ មិនបានសំដៅយ៉ាងជាក់លាក់លើទិន្នន័យខ្នាតធំនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងឯកសារដែលទទួលបានពីគណៈកម្មការអឺរ៉ុប ស្តីពីការការពារទិន្នន័យ និង ទិន្នន័យខ្នាតធំ[74] គណៈកម្មការអឺរ៉ុបបានថែងថា “ការវិភាគអំពីទិន្នន័យធំមិនមែនតែងតែជាប់ពាក់ព័ន្ធនឹងទិន្នន័យបុគ្គលនោះទេ។ ប៉ុន្តែ ប្រសិនបើវាជាប់ពាក់ព័ន្ធ វាគួរតែអនុលោមតាមវិធាន និង គោលការណ៍នៃការការពារទិន្នន័យ៖ ធម្មនុញ្ញរបស់ EU ស្តីពីសិទ្ធិមូលដ្ឋាន ចែងថា មនុស្សគ្រប់រូបមានសិទ្ធិការពារទិន្នន័យផ្ទាល់ខ្លួននៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត៖ នៅផ្ទះ នៅកន្លែងធ្វើការ នៅពេលកំពុងទិញទំនិញ នៅពេលទទួលការព្យាបាលជំងឺ នៅប៉ុស្តិ៍នគរបាល ឬ នៅលើអ៊ីនធឺណិត។ ទិន្នន័យខ្នាតធំ ក៏មិនខុសគ្នាដែរ” គណៈកម្មការអឺរ៉ុប (២០១៨)។

ដូចគ្នានឹងពិធីសារ ឆ្នាំ២០១៨ នៃអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុបដែរ បទប្បញ្ញត្តិនេះណែនាំអំពីកាតព្វកិច្ចរបស់អ្នកប្រមូលទិន្នន័យនៅក្នុងការណែនាំអំពីយន្តការ “តាមការរចនា” ឬ “តាមការកំណត់ដោយស្វ័យប្រវត្តិ”។ បទប្បញ្ញត្តិនេះចែងថា “អ្នកគ្រប់គ្រងគួរតែអនុម័តគោលនយោបាយផ្ទៃក្នុង និង អនុវត្តវិធានការនានាដែលបំពេញតាមគោលការណ៍នៃការការពារទិន្នន័យតាមការរចនា និង ការការពារទិន្នន័យតាមការកំណត់ដោយស្វ័យប្រវត្តិ ជាពិសេស។ វិធានការទាំងនោះអាចរួមបញ្ចូល នៅក្នុងចំណោមអ្វីផ្សេងទៀត ការកាត់បន្ថយជាអប្បបរមានូវការដំណើរការទិន្នន័យផ្ទាល់ខ្លួន ការធ្វើឲ្យទិន្នន័យផ្ទាល់ខ្លួនមិនអាចកំណត់អត្តសញ្ញាណបាន ឲ្យបានឆាប់រហ័សបំផុត

---

73 សូមមើលគេហទំព័រនៃវិធានការពារទិន្នន័យរបស់ EU។ https://ec.europa.eu/info/law/law-topic/data-protection/eu-data-protection-rules_en#documents (បានចូលប្រើប្រាស់នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០)។

74 សូមមើលគណៈកម្មការអឺរ៉ុប (២០១៨)។ និយមន័យអំពីទិន្នន័យខ្នាតធំក៏ត្រូវបានផ្តល់ជូនផងដែរ ដោយចែងថា “ទិន្នន័យខ្នាតធំ” សំដៅលើ ទិន្នន័យដែលមានចំនួនស្ថិតនៅក្នុងប្រភេទខុសៗគ្នា ដែលផលិតចេញពីប្រភពជាច្រើនប្រភេទខុសៗគ្នា ដូចជា មនុស្ស ម៉ាស៊ីន ឬ សែនស័រ ជាដើម។ ទិន្នន័យនេះអាចជា ព័ត៌មានអំពីអាកាសធាតុ, ព័ត៌មានដែលទទួលបានពីរូបភាពផ្កាយរណប, រូបភាព និង វីឌីអូឌីជីថល, កំណត់ត្រាដែលបញ្ជូនពីផ្នែកមួយទៅផ្នែកមួយផ្សេងទៀត ឬ សញ្ញាជីភីអេស ជាដើម។ ទិន្នន័យខ្នាតធំអាចរួមបញ្ចូលទិន្នន័យផ្ទាល់ខ្លួន៖ ដែលជា ព័ត៌មានណាមួយដែលទាក់ទងនឹងបុគ្គល និង អាចជាព័ត៌មានដែលទទួលបានពីឈ្មោះ រូបថត អាសយដ្ឋានអ៊ីមែល ព័ត៌មានលម្អិតអំពីធនាគារ ការចុះផ្សាយនៅលើគេហទំព័របណ្តាញសង្គម ព័ត៌មានអំពីការព្យាបាលជំងឺ ឬ អាសយដ្ឋាន IP កុំព្យូទ័រណាមួយ”។

តាមដែលអាចធ្វើបាន តម្លាភាពដែលពាក់ព័ន្ធនឹងមុខងារ និង ការដំណើរការទិន្នន័យផ្ទាល់ខ្លួន ការអនុញ្ញាតឲ្យកម្មវិធីរបស់ទិន្នន័យពិនិត្យតាមដានការដំណើរការទិន្នន័យ ការអនុញ្ញាតឲ្យអ្នកគ្រប់គ្រងបង្កើត និង ពង្រឹងទ្រង់ទ្រាយផ្នែកសន្តិសុខ។ នៅពេលអភិវឌ្ឍរចនា ជ្រើសរើស និង ប្រើប្រាស់កម្មវិធីសេវាកម្ម និង ផលិតផលនានាដែលផ្អែកលើការដំណើរការទិន្នន័យផ្ទាល់ខ្លួន ឬ ដំណើរការទិន្នន័យផ្ទាល់ខ្លួនដើម្បីបំពេញការងារ អ្នកផលិតផលិតផល សេវាកម្ម និង កម្មវិធីរបស់ពួកគេ គួរតែត្រូវបានលើកទឹកចិត្តឲ្យពិចារណាអំពីសិទ្ធិការពារទិន្នន័យ នៅពេលអភិវឌ្ឍ និង រចនាផលិតផលសេវាកម្ម និង កម្មវិធីទាំងនោះ ដោយមានការពិចារណាយ៉ាងត្រឹមត្រូវអំពីបច្ចេកវិទ្យាទំនើបៗ ដើម្បីធ្វើឲ្យប្រាកដថា អ្នកគ្រប់គ្រង និង អ្នកដំណើរការ អាចបំពេញកាតព្វកិច្ចការពារទិន្នន័យរបស់ពួកគេបាន”។[75]

ពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួន បទប្បញ្ញត្តិនេះក៏ចែងផងដែរថា “ការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយអាជ្ញាធរសាធារណៈទាំងនោះ គួរតែអនុលោមតាមវិធានស្តីពីការការពារទិន្នន័យដែលអាចអនុវត្តបាន ស្របតាមគោលបំណងនៃការដំណើរការ”។ អាជ្ញាធរសាធារណៈទាំងនេះ រួមបញ្ចូលអាជ្ញាធរពន្ធដារ និង ពន្ធគយផងដែរ (កថាខណ្ឌទី ៣១ នៃបទប្បញ្ញត្តិ [EU ២០១៦b])។

ការសម្រេចចិត្តដោយស្វ័យប្រវត្តិក៏បានទទួលការការពារនៅក្នុងបទប្បញ្ញត្តិនេះដែរ។ កថាខណ្ឌទី ៧១ ចែងថា ការសម្រេចចិត្ត (និង ការដំណើរការដោយស្វ័យប្រវត្តិ) ណាមួយ ដែលមានផលជះចំពោះកម្មវត្ថុរបស់ទិន្នន័យ មិនអាចធ្វើឡើងដោយផ្អែកលើដំណើរការដោយស្វ័យប្រវត្តិតែមួយមុខនោះទេ លើកលែងតែការសម្រេចចិត្តនោះ “ត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយច្បាប់របស់សហភាព ឬ រដ្ឋសមាជិក ដែលអ្នកគ្រប់គ្រងទិន្នន័យជាកម្មវត្ថុនៃសហភាព ឬ រដ្ឋសមាជិកនោះ ក្នុងគោលបំណងពិនិត្យតាមដាន និង ទប់ស្កាត់ការក្លែងបន្លំ និង ការគេចពន្ធ ដែលត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិ បទដ្ឋាន និង អនុសាសន៍របស់ស្ថាប័នសហភាព ឬ អង្គភាពត្រួតពិនិត្យថ្នាក់ជាតិ និង ធានាចំពោះ សន្តិសុខ និង ភាពអាចទុកចិត្តបាននៃសេវាកម្មណាមួយដែលត្រូវបានផ្តល់ជូនដោយអ្នកគ្រប់គ្រង ឬ ចាំបាច់សម្រាប់ការបញ្ចូល ឬ ការអនុវត្តកិច្ចសន្យាណាមួយរវាងកម្មវត្ថុរបស់ទិន្នន័យ និង អ្នកគ្រប់គ្រងទិន្នន័យ ឬ នៅពេលដែលកម្មវត្ថុរបស់ទិន្នន័យបានផ្តល់ការយល់ព្រមរបស់គាត់ ឬ នាងយ៉ាងច្បាស់លាស់”។[76] ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេច

[75] សូមមើលកថាខណ្ឌទី ៧៨ នៃបទប្បញ្ញត្តិ (EU ២០១៦b)។ សូមមើលកថាខណ្ឌទី ៦៣ នៃសេចក្តីណែនាំ (EU ២០១៦a) ផងដែរ។

[76] សូមមើលកថាខណ្ឌទី ៦១ នៃបទប្បញ្ញត្តិ (EU ២០១៦b)។

ចិត្តនេះគួរតែអាស្រ័យលើ "ការការពារសុវត្ថិភាពយ៉ាងសមស្រប ដែលគួរតែរួមបញ្ចូលព័ត៌មានជាក់លាក់អំពីកម្មវត្ថុរបស់ទិន្នន័យ និង សិទ្ធិទទួលបានការធ្វើអន្តរាគមន៍របស់មនុស្ស ដើម្បីបង្ហាញអំពីការយល់ឃើញរបស់គាត់ ឬ នាង ដើម្បីទទួលបានសេចក្តីអធិប្បាយអំពីការសម្រេចចិត្តបន្ទាប់ពីមានការប៉ាន់ប្រមាណបែបនោះ និង ដើម្បីដេញដោលការសម្រេចចិត្តនោះ"។[77]

## ចំណាប់អារម្មណ៍ចុងក្រោយ និង អនុសាសន៍

ជំពូកនេះបានលើកឡើងអំពីបញ្ហាប្រឈមនានាដែលប្រឈមមុខដោយអាស៊ី និង អឺរ៉ុប ពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដោយរដ្ឋបាលពន្ធដារ និង ការការពារសិទ្ធិរបស់អ្នកជាប់ពន្ធ។ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរឧត្តមានុវត្តនៅក្នុងក្របខណ្ឌនៃការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការរបស់ ASEM ជំពូកនេះបានលើកឡើងអំពីការអភិវឌ្ឍនៅអឺរ៉ុប និង អាស៊ី និង ប៉ាស៊ីហ្វិក រួមបញ្ចូលទាំងការងារដែលអនុវត្តដោយអង្គការអន្តរជាតិផងដែរ (ធនាគារអភិវឌ្ឍអាស៊ី និង OECD) និង បណ្តាញរដ្ឋបាលពន្ធដារក្នុងតំបន់ (CIAT, IOTA, BRITACOM និង SGATAR)។

អនុសាសន៍ទីមួយ គឺដើម្បីឲ្យប្រទេសនៅក្នុងបណ្តាញ ASEM មានការយល់ដឹងអំពីបញ្ហាប្រឈមដែលរដ្ឋបាលពន្ធដារប្រឈមមុខនៅក្នុងការប្រមូលព័ត៌មានពន្ធដារ (ប្រភពបែបប្រពៃណីនិង ប្រភពឌីជីថល) និង វិនិយោគលើយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យរបស់ពួកគេ។ យុទ្ធសាស្ត្រទាំងនេះគួរតែជា (i) យុទ្ធសាស្ត្រដែលមានរយៈពេលវែង និង (ii) ពិចារណាប្រើប្រាស់ការវិភាគតាមបែបវិនិច្ឆ័យ តាមបែបទស្សន៍ទាយទុកមុន និង តាមបែបបញ្ញត្តិ។ លើសពីនេះទៀត ប្រទេសនានាគួរតែវិនិយោគលើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ពួកគេផងដែរ ដែលរួមបញ្ចូលការណែនាំអំពីប្រព័ន្ធបញ្ជូនព័ត៌មានទូទៅ និង សូហ្វវែរសម្រាប់វិភាគទិន្នន័យខ្នាតធំ។

ក្នុងគោលបំណងនេះ វាមានសារសំខាន់នៅក្នុងការរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់រដ្ឋបាលពន្ធដារ ដើម្បីធ្វើបទបង្ហាញអំពីបញ្ហាប្រឈមនៃឌីជីថលនីយកម្មផ្នែកពន្ធដាររបស់ពួកគេ និង ដើម្បីផ្លាស់ប្តូរទន្លាប់អនុវត្តល្អបំផុត។ កិច្ចប្រជុំទាំងនេះអាចមានលក្ខណៈប្រហាក់ប្រហែលគ្នានឹង TADEUS ដែរ (កិច្ចប្រជុំកំពូលប្រចាំឆ្នាំរបស់ប្រធានផ្នែករដ្ឋបាលពន្ធដារនៃ EU) ប៉ុន្តែមានប្រទេសដែលចូលរួមនៅក្នុងបណ្តាញ ASEM។ លើសពីនេះទៀត ដោយសារមាន ២៧ ប្រទេសចូលរួមជាប្រទេសដៃគូនៅទ្វីបអាស៊ី នៅក្នុង ASEM ប្រទេសមួយចំនួនអាចចុះអនុស្សរណៈនៃការយោគ

[77] សូមមើលកថាខណ្ឌទី ៧១ នៃបទប្បញ្ញត្តិ (EU ២០១៦)។

យល់គ្នា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយការគេចពន្ធ និង ការក្លែងបន្លំពន្ធ ដោយផ្អែកលើតម្រូវការរបស់ប្រទេសនានា (ដូចបានអនុវត្តនៅក្នុងគំនិតផ្តួចផ្តើម BENELUX)។

អនុសាសន៍ទីពីរលើកឡើងអំពីលិខិតូបករណ៍ដើម្បីការពារសិទ្ធិរបស់អ្នកជាប់ពន្ធ។ ប្រទេសនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកបានណែនាំអំពីវិធានដើម្បីការពារទិន្នន័យផ្ទាល់ខ្លួននិងសិទ្ធិឯកជនភាពជាពិសេស ដោយអនុវត្តតាមសេចក្តីណែនាំអំពីការការពារទិន្នន័យរបស់ EU ឆ្នាំ១៩៩៥។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីណែនាំនេះត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីរួមបញ្ចូល នៅក្នុងចំណោមសកម្មភាពដទៃទៀត ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន ទិន្នន័យសេនេទិច និង ទិន្នន័យជីវសាស្ត្រ។ អាស្រ័យហេតុនេះ យើងផ្តល់ អនុសាសន៍ឲ្យប្រទេសនានា ធ្វើការកែប្រែច្បាប់ស្តីពីការការពារទិន្នន័យ ដោយអនុវត្តតាមសេចក្តីណែនាំអំពីការការពារទិន្នន័យរបស់ EU និង បទប្បញ្ញត្តិឆ្នាំ២០១៦។ ដូចបានអនុវត្តនៅក្នុងអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុប (ពិធីសារ ឆ្នាំ២០១៨) យើងផ្តល់អនុសាសន៍ថាប្រទេសនានាគួរតែរួមបញ្ចូលឯកសារយោង នៅក្នុងការវិភាគអំពីទិន្នន័យខ្នាតធំ ឬ ទិន្នន័យ រួមទាំងសិទ្ធិមនុស្ស (កម្មវត្ថុរបស់ទិន្នន័យ) នៅក្នុងបរិបទនៃការសម្រេចចិត្តតាមអាល់កូរីតផងដែរ។

ជាចុងក្រោយ ពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួនដោយស្វ័យប្រវត្តិ យើងផ្តល់ទឡ្ហីករណ៍ថា អនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុប និង ពិធីសារឆ្នាំ២០១៨ របស់អនុសញ្ញានេះ គឺជាលិខិតូបករណ៍មួយដែលប្រទេសនានាចាំបាច់ត្រូវផ្តល់សច្ចាប័ន។ អាស្រ័យហេតុនេះ ការស្រាវជ្រាវបន្ថែមគួរតែត្រូវបានធ្វើឡើងអំពីការប្រើប្រាស់អនុសញ្ញានោះសម្រាប់ការប្រមូល និង ការផ្លាស់ប្តូរព័ត៌មានរបស់អ្នកជាប់ពន្ធ។

កិច្ចសហប្រតិបត្តិការរបស់ ASEM លើការតភ្ជាប់ផ្នែកឌីជីថល ត្រូវបានដាក់ចេញបានយ៉ាងល្អ ដើម្បីអនុវត្តតាមអនុសាសន៍ទាំងនេះ។ នៅពេលដែលអាស៊ី និង អឺរ៉ុប កំពុងតែផ្លាស់ទីឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល – ទោះបីជាមានជំហានខុសគ្នាក៏ដោយ – កម្មវិធីបង្រួបបង្រួម និង កិច្ចសហប្រតិបត្តិការ ដើម្បីសមត្ថភាព និង ឌីជីថលនីយកម្មដ៏ឆាប់រហ័សមួយ គួរតែគូសបញ្ជាក់អំពីសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM១៣) ប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០២១។

**សម្គាល់៖** អ្នកនិពន្ធសូមថ្លែងអំណរគុណដល់គម្រោងស្រាវជ្រាវ GLOBTAXGOV ដែលជាគម្រោងទទួលបានមូលនិធិគាំទ្រពីក្រុមប្រឹក្សាស្រាវជ្រាវអឺរ៉ុប (កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង លេខ ៧៥៨៦៧១)។

# ឯកសារយោង

Araki, S. and S. Nakabayashi (eds.) (2018), Tax and Development: Challenges in Asia and the Pacific. Tokyo: Asian Development Bank Institute. https://www.adb.org/publications/tax- and-development-challenges-in-asia-pacific (accessed 7 July 2020).

Asian Development Bank (ADB) (2018), A Comparative Analysis of Tax Administration in Asia and the Pacific: 2018 Edition. Manila: ADB. https://www.adb.org/sites/default/files/ publication/441166/tax-administration-asia-pacific-2018.pdf (accessed 7 July 2020).

ADB (2020), A Comparative Analysis of Tax Administration in Asia and the Pacific:

2020 Edition. Manila: ADB. https://www.adb.org/publications/comparative-analysis-tax- administration-asia-pacific-2020 (accessed 7 July 2020).

Benelux (2019), Benelux-landen versterken hun samenwerking in de strijd tegen fiscale fraude. 10 October. https://www.benelux.int/nl/nieuws/benelux-landen-versterken-hun-samenwerking-de-strijd-tegen-fiscale-fraude (accessed 7 July 2020).

Burgers, I.J.J. and D. Criclivaia (2016), 'Joint Tax Audits: Which Countries May Benefit Most?' World Tax Journal, 8(3), Amsterdam, International Bureau of Fiscal Documentation IBFD, pp. 306–355.

Cadesky, M., I. Hayes, and D. Russell (2015), Towards Greater Fairness in Taxation: A Model Taxpayer Charter. AOTCA, CFE, and STEP. https://www.nob.net/sites/default/files/ content/article/uploads/brochure_taxpayer_0.pdf (accessed 7 July 2020).

Calderon, J.M. and J.S. Ribeiro (2020), 'Fighting Tax Fraud through Artificial Intelligence Tools: Will the Fundamental Rights of Taxpayers Survive the Digital Transformation of Tax Administrations?', European Taxation, 60(7), International Bureau of Fiscal Documentation IBFD. Online Publications.

Chen, J., S. Grimshaw, and G.D. Myles (2017), 'Chapter 5: Testing and Implementing Digital Tax Administration in Digital Revolutions in Public Finance', in S. Gupta, M. Keen, A. Shah, and G. Verdier (eds.) (2017), The United States. Washington, DC: International Monetary Fund. https://doi.org/10.5089/9781484315224.071 (accessed 7 July 2020).

CIAT and IOTA (2018), Tax Administrations and the Challenges of the Digital World: Summary Report. CIAT and IOTA. https://www.iota-tax.org/sites/default/files/ documents/publications/Reports/lisbontax_summit_-_summary_report_final.pdf (accessed 7 July 2020).

iin-Šain, N., T. Ehrke-Rabel, and J. Englisch (2018), 'International – Joint Audits: Applicable Law and Taxpayer Rights', World Tax Journal, 10(4), Amsterdam, International Bureau of Fiscal Documentation IBFD, pp. 585–631.

Council of Europe (2017), Guidelines on the Protection of Individuals with Regard to the Processing of Personal Data in a World of Big Data. https://rm.coe.int/16806ebe7a (accessed 7 July 2020).

Council of Europe (2018a), Explanatory Report to the Protocol Amending the Convention for the Protection of Individuals with Regard to Automatic Processing of Personal Data. https://rm.coe. int/CoERMPublicCommonSearchServices/DisplayDCTMContent?documentId=09000016 808ac91a (accessed 7 July 2020).

Council of Europe (2018b), Convention 108+: Convention for the Protection of Individuals with Regard to the Processing of Personal Data. https://rm.coe.int/convention-108-convention- for-the-protection-of-individuals-with-regar/16808b36f1 (accessed 7 July 2020).

Council of Europe (2019), Guidelines on Artificial Intelligence and Data Protection. https://rm.coe.int/guidelines-on-artificial-intelligence-and-data-protection/168091f9d8 (accessed 7 July 2020).

D'souza, C. (2019), Big Data and Trade Secrets (A General Analysis). http://dx.doi.org/10.2139/ssrn.3316328 (accessed 7 July 2020).

Debelva, F. and I.J.M. Mosquera Valderrama (2017), 'Privacy and Confidentiality in Exchange of Information Procedures: Some Uncertainties, Many Issues, but Few Solutions', Intertax, 45(5), pp. 362–381.

European Commission (2016), EU–US Privacy Shield. https://ec.europa.eu/info/law/law-topic/data-protection/data-transfers-outside-eu/eu-us-privacy-shield_en (accessed 7 July 2020).

European Commission (2018), The EU Data Protection Reform and Big Data. https://op.europa.eu/en/publication-detail/-/publication/51fc3ba6-e601-11e7-9749- 01aa75ed71a1 (accessed 7 July 2020).

European Union (EU) (2016a), Directive (EU) 2016/680 of the European Parliament and of the Council of 27 Apr. 2016 on the Protection of Natural Persons with Regard to the Processing of Personal Data by Competent

Authorities for the Purposes of the Prevention, Investigation, Detection or Prosecution of Criminal Offences or the Execution of Criminal Penalties, and on the Free Movement of Such Data. https://eur-lex.europa.eu/legal-content/EN/TXT/PDF/?uri=CELEX:32016L0680&from=EN (accessed 7 July 2020).

EU (2016b), Regulation (EU) 2016/679 of the European Parliament and of the Council of 27 Apr. 2016 on the Protection of Natural Persons with Regard to the Processing of Personal Data and on the Free Movement of Such Data, and Repealing Directive 95/46/EC (General Data Protection Regulation). https://eur-lex.europa.eu/eli/reg/2016/679/oj (accessed 7 July 2020).

Greenleaf, G. (2012), 'The Influence of European Data Privacy Standards Outside Europe: Implications for Globalization of Convention 108', International Data Privacy Law, 2(2), p. 75.

Greenleaf, G. (2014a), 'A World Data Privacy Treaty? 'Globalisation' and 'Modernisation' of Council of Europe Convention 108', in N. Witzleb, D. Lindsay, M. Paterson, and S. Rodrick (eds.), Emerging Challenges in Privacy Law: Comparative Perspectives. Cambridge: Cambridge University Press, pp. 92–138.

Greenleaf, G. (2014b), Asian Data Privacy Laws: Trade and Human Rights Perspectives. Oxford University Press, p. 624.

Gupta, S., M. Keen, A. Shah, and G. Verdier (2017), Digital Revolutions in Public Finance. Washington, DC. International Monetary Fund. https://www.elibrary.imf.org/view/IMF071/24304-9781484315224/24304-9781484315224/Other_formats/Source_PDF/24304-9781484316719.pdf (accessed 7 July 2020).

Highfield, R. (2017), 'Adopting the New International Tax Rules and Standards',

The Governance Brief. Manila: Asian Development Bank, p. 29.

Houser, K.A. and D. Sanders (2017), 'The Use of Big Data Analytics by the IRS: Efficient Solutions or the End of Privacy as We Know It?' Vanderbilt Journal of Entertainment & Technology Law, 19(4). p. 817. https://www.law.columbia.edu/sites/default/files/microsites/public-integrity/article_the_use_of_big_data_analytics_by_the_irs_efficient_ solutions_or_the_end_of_privacy_as_we_1.pdf (accessed 7 July 2020).

International Chamber of Commerce (ICC) (2020), ICC BRITACOM Report: Digitalisation of Tax Administration: A Business Perspective. https://iccwbo.org/content/uploads/sites/3/2020/03/icc-report-britacom-tax-digitalisation-2020.pdf (accessed 7 July 2020).

International Monetary Fund (IMF). 2007. Manual on Fiscal Transparency. Washington, DC.

Kanbur, R. (2017), 'The Digital Revolution and Targeting Public Expenditure for Poverty Reduction', in S. Gupta, M. Keen, A. Shah, and G. Verdier (eds.), Digital Revolutions in Public Finance. International Monetary Fund. https://doi.org/10.5089/9781484315224.071 (accessed 7 July 2020).

Krishna, A., M. Fleming, and S. Assefa (2017), 'Instilling Digital Trust: Blockchain and Cognitive Computer for Government', in S. Gupta, M. Keen, A. Shah, and G. Verdier (eds.), Digital Revolutions in Public Finance. Washington, DC: International Monetary Fund. https://doi.org/10.5089/9781484315224.071 (accessed 7 July 2020).

Mantelero, A. (2017), 'Regulating Big Data. The Guidelines of the Council of Europe in the Context of the European Data Protection Framework', Computer Law & Security Review, 33(5), pp. 584–602.

Microsoft and PwC (2018), The Data Intelligent Tax Administration: Meeting the Challenges of Big Data and Analytics. PwC. https://www.pwc.nl/nl/assets/documents/the-data- intelligent-tax-administration-whitepaper.pdf (accessed 7 July 2020).

Mosquera Valderrama, I.J. (2019), 'Processing Personal and Business Data and the Rule of Law in the Era of Digital Trade', Central European Political Science Review, 76(20), pp. 111–128.

Mosquera Valderrama, I.J., O. Affuso, and A. Coco (2019), 'A Multidisciplinary Regulatory Approach to Big Data and the Rule of Law', GlobTax Gov, 1 January. https://globtaxgov. weblog.leidenuniv.nl/2019/01/01/a-multidisciplinary-regulatory-approach-to-big-data- and-the-rule-of-law/ (accessed 7 July 2020).

Mosquera Valderrama, I.J.M., A. Mazz, L.F. Schoueri, N. Quiñones, J. Roeleveld, P. Pistone, and F. Zimmer (2017), 'The Rule of Law and the Effective Protection of Taxpayers' Rights in Developing Countries', WU International Taxation Research Paper Series No. 10. https://ssrn.com/abstract=3034360 (accessed 7 July 2020).

Organisation for Economic Co-operation and Development (OECD) (2003), Taxpayers Rights and Obligations. Centre for Tax Policy and Administration. Paris. ww.oecd.org/tax/administration/Taxpayers'_Rights_and_Obligations-Practice_Note.pdf (accessed 7 July 2020).

OECD (2013), Co-operative Compliance: A Framework: From Enhanced Relationship to Co-operative Compliance. Paris: OECD Publishing. https://doi.org/10.1787/97892642 00852-en (accessed 7 July 2020).

OECD (2016a), Co-operative Tax Compliance: Building Better Tax Control Frameworks. Paris: OECD Publishing. https://doi.org/10.1787/9789264253384-en (accessed 7 July 2020).

OECD (2016b), Communiqué of the 10th Meeting of the OECD Forum on Tax Administration (FTA), Forum on Tax Administration, Beijing, 13 May. http://www.oecd.org/tax/ administration/fta-communique-2016.pdf (accessed 7 July 2020).

OECD (2017a), The Changing Tax Compliance Environment and the Role of Audit. Paris: OECD Publishing. https://doi.org/10.1787/9789264282186-en (accessed 7 July 2020).

OECD (2017b), Tax Administration 2017: Comparative Information on OECD and Other Advanced and Emerging Economies, OECD Publishing, Paris. https://doi.org/10.1787/ tax_admin-2017-en (accessed 7 July 2020).

OECD (2019a), Tax Administration: Comparative Information on OECD and Other Advanced and Emerging Economies. Paris: OECD Publishing. http://www.oecd.org/ctp/ administration/tax-administration-23077727.htm (accessed 7 July 2020).

OECD (2019b), Tax and Digitalisation. Paris: OECD Publishing. https://www.oecd.org/going-digital/tax-and-digitalisation.pdf (accessed 7 July 2020).

Offermans, R. (2020), Report on the Symposium, Tax Digitization, Help or Obstacle to Legal Protection?, European Taxation, 60(6), International Bureau of Fiscal Documentation IBFD. Online Publications.

Sampson, M., J. Wang, and I.J. Mosquera Valderrama ( forthcoming), 'Trade, Tax, and Development Finance: Understanding China's Choice of BRI Agreements and Institutions', in F. Schneider (ed.), Global Perspectives on the Belt and Road Initiative. Amsterdam: Amsterdam University Press.

Study Group on Asian Tax Administration and Research (SGATAR) (2019), Three Critical Issues on SGATAR Annual Meeting, 25 October. SGATAR. https://sgatar49.org/three- critical-issues-on-sgatar-annual-meeting/ (accessed 7 July 2020).

van Hout, D. (2019), 'Legal Protection in the Era of Big Data', GLOBTAXGOV, 22 February. https://globtaxgov.weblog.leidenuniv.nl/2019/02/22/legal-protection-in-the-era-of-big- data/ (accessed 7 July 2020).

Vat Update (2019), Belgian Super-Weapon against VAT Fraud to Be Rolled Out in EU: Transactional Network Analysis, 9 May. https://www.vatupdate.com/2019/05/09/belgian-super-weapon-transactional-network-analysis-datamining-software-against-vat-fraud-to- be-rolled-out-in-eu/ (accessed 7 July 2020).

III

# ការតភ្ជាប់ទំនាក់ទំនង ស្ថាប័ន និង ប្រជាជន

**កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប ក្នុងការកសាងសង្គមឌីជីថល ប្រកបដោយបរិយាប័ន្ន**

EMMANUEL C. LALLANA

*Ideacorp ប្រទេសហ្វីលីពីន*

**កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប លើបម្លាស់ទីដើម្បីស្វែងរកការងារ ការអប់រំ និង ការបណ្តុះបណ្តាល៖** តើការផ្លាស់ប្តូរផ្នែកឌីជីថល មានអត្ថន័យដូចម្តេចខ្លះចំពោះ ASEM ?

FLAVIA JURJE TRIFA

*សាកលវិទ្យាល័យ Laussane ប្រទេសស្វីស*

**កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប លើការផ្តល់ភាពអង់អាចដល់ស្ត្រី និងយុវជន៖** ការតភ្ជាប់ផ្នែកឌីជីថល និងការអប់រំ

YEO LAY HWEE

*មជ្ឈមណ្ឌលសហភាពអឺរ៉ុប ប្រទេសសិង្ហបុរី*

# 7

# កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប ក្នុងការកសាងសង្គមឌីជីថលប្រកបដោយបរិយាប័ន្ន

EMMANUEL C. LALLANA

យានដើម្បីឆ្ពោះទៅកាន់សង្គមឌីជីថល – ជាកន្លែងដែលជីវិតរស់នៅប្រចាំថ្ងៃ រួមទាំងការងារ និង នយោបាយផងដែរ ត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) – ត្រូវបានពន្លឿនដោយជំងឺរាតត្បាតសកលបង្កដោយមេរោគកូរ៉ូណា នៅទូទាំងសកលលោក។

ជំងឺរាតត្បាតសកល បាននាំឲ្យមានការចាប់ផ្ដើមប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងទូលំទូលាយ នៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។ ទូរគមនាគមន៍បានក្លាយជាឧបករណ៍ដ៏ពិសេសមួយនៃការងារ។ អាជីវកម្មខ្នាតតូច និង សាកលវិទ្យាល័យ ដែលធ្លាប់គិតថា ឌីជីថលនីយកម្មគឺជាភាពប្រណិតនោះ នៅពេលនេះមើលឃើញថា វាចាំបាច់សម្រាប់ការរស់រាន។ ប្រព័ន្ធផ្សព្វផ្សាយសង្គមបានក្លាយជាខ្សែជីវិត។ វាស្ទើរតែគ្មានការជំទាស់ទាល់តែសោះថា "ជំងឺរាតត្បាតសកលបានបង្កើត "ការបំបែករចនាសម្ព័ន្ធពីអតីតកាល" ដែលធ្វើឱ្យរចនាបទនៃអាកប្បកិរិយាដែលមានស្រាប់ជាច្រើនប្រែជាហួសសម័យ ប៉ុន្តែវាក៏ចង្អុលបង្ហាញផ្លូវឆ្ពោះទៅមុខសម្រាប់សង្គមផងដែរ" (Rumelt ឆ្នាំ២០០៨)។

នៅពេលកសាងសង្គមឌីជីថល មានចំណុចមួយទៀតដែលយើងត្រូវតែពិចារណា ដែលជំងឺរាតត្បាតសកលបានគូសបញ្ជាក់នោះគឺ វិសមាភាពដ៏ខ្លាំងក្លាដែលកើតឡើងនៅក្នុងសង្គមរបស់យើងនៅទូទាំងសកលលោក។

វិធានការដែលត្រូវបានស្នើឡើងដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគនេះ មានការពិបាកក្នុងអនុវត្តដោយមនុស្សជាច្រើន។ ការលាងដៃជាមួយសាប៊ូជាញឹកញាប់ គឺជាបញ្ហាប្រឈមមួយសម្រាប់អ្នកដែលគ្មានទឹកសម្រាប់ប្រើប្រាស់នៅក្នុងផ្ទះរបស់ពួកគេ។ ការរក្សាគម្លាតផ្លូវកាយ គឺស្ទើរតែមិនអាចធ្វើទៅបាន ចំពោះអ្នកដែលរស់នៅសំណង់អាណាធិបតេយ្យ, សំណង់មិនរៀបរយ និង សហគមន៍ជនក្រីក្រនៅក្នុងទីក្រុងនៃប្រទេសលោកខាងត្បូង។ ប្រសិនបើយើងមានបំណងសម្រេច

បាននូវវឌ្ឍនភាព និង មិនបង្កើតកំហុសឆ្គងដដែល ដូចកាលពីអតីតកាលនោះ បរិយាប័ន្នគួរតែជាលក្ខណៈពិសេសមួយនៃសង្គមឌីជីថលដែលយើងកំពុងតែបង្កើតឡើង។

## ភាពចាំបាច់នៃបរិយាប័ន្នឌីជីថល

"បរិយាប័ន្នឌីជីថល" មានន័យថា បុគ្គលទាំងឡាយ ដែលស្ថិតនៅក្នុងក្រុមជនទន់ខ្សោយ មានលទ្ធភាពចូលប្រើប្រាស់ និង មានជំនាញប្រើប្រាស់ ICT ហេតុដូចនេះ ពួកគេអាចចូលរួម និង ទទួលបានអត្ថប្រយោជន៍ពីសង្គមឌីជីថលដែលកំពុងតែលេចឡើងនេះ (Digital Inclusion, n.d.)។

វិធីមួយក្នុងការសម្លឹងមើលបរិយាប័ន្ន គឺតាមរយៈគោលដៅចំនួនប្រាំមួយដែលត្រូវបានទទួលយកជាទូទៅ៖

1. *មិនទុកនរណាម្នាក់ចោល៖* ធានាចំពោះការប្រើប្រាស់អ៊ីនធឺណិតដែលមានគុណភាព និង ការចាប់ផ្ដើមអនុវត្តចំពោះមនុស្សគ្រប់រូប

2. *ផ្ដល់ភាពអង់អាចដល់អ្នកប្រើប្រាស់ តាមរយៈអត្តសញ្ញាណឌីជីថលល្អៗ៖* ធានាថា មនុស្សគ្រប់រូបអាចចូលរួមនៅក្នុងសង្គមឌីជីថល តាមរយៈអត្តសញ្ញាណ និង យន្តការចូលប្រើប្រាស់ដែលអនុញ្ញាតដល់អ្នកប្រើប្រាស់

3. *ធ្វើឲ្យអាជីវកម្មដំណើរការដើម្បីប្រជាជន៖* ជួយដល់ក្រុមហ៊ុននានានៅក្នុងការបង្ហាញទិសដៅនៃការបំបែកខ្លួន និង ការវិវឌ្ឍន៍ផ្អែកឌីជីថល ដើម្បីទទួលបានគំរូ និង ទម្លាប់អនុវត្តអាជីវកម្មតាមបែបថ្មីៗ និង មានទំនួលខុសត្រូវ

4. *ថែរក្សាមនុស្សគ្រប់រូបឲ្យមានសុវត្ថិភាព និង សន្តិសុខ៖* បង្កើតទ្រង់ទ្រាយនៃនិយាម និង ទម្លាប់អនុវត្តដែលធ្វើឲ្យមានមជ្ឈដ្ឋានដែលពឹងផ្អែកលើបច្ចេកវិទ្យា ដែលមានសុវត្ថិភាព និង មានភាពធន់

5. *បង្កើតវិធានថ្មីៗសម្រាប់ល្បែងថ្មីមួយ៖* អភិវឌ្ឍយន្តការធ្វើអភិបាលកិច្ចថ្មី មានភាពបត់បែន ផ្អែកលើលទ្ធផល និង មានការចូលរួម ដើម្បីបំពេញបន្ថែមពីលើគោលនយោបាយ និង បទប្បញ្ញត្តិតាមបែបប្រពៃណី

6. *ឆ្លងកាត់ឧបសគ្គផ្អែកទិន្នន័យ៖* អភិវឌ្ឍនវានុវត្តន៍ដែលអនុញ្ញាតឲ្យយើងទទួលបានអត្ថប្រយោជន៍ពីទិន្នន័យ ស្របពេលជាមួយគ្នានោះ ការពារផលប្រយោជន៍តាមផ្លូវច្បាប់របស់ភាគីពាក់ព័ន្ធទាំងអស់។ (វេទិកាសេដ្ឋកិច្ចពិភពលោក ២០១៨:៨)។

មូលនិធិអភិវឌ្ឍមូលធននៃអង្គការសហប្រជាជាតិ (UNCDF) បានស្នើឲ្យប្រើប្រាស់កាតពិន្ទុសេដ្ឋកិច្ចឌីជីថលដែលមានបរិយាប័ន្ន (IDES) ជាវិធីមួយដើម្បីវាស់វែងបរិយាប័ន្ននៅក្នុងសេដ្ឋកិច្ចឌីជីថល។

IDES ពិចារណាអំពីវិស័យនានាដូចខាងក្រោម៖

- កម្រិតដែលរដ្ឋាភិបាលលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលដែលមានបរិយាប័ន្នយ៉ាងសកម្ម និង កម្រិតដែលគោលនយោបាយ និង បទប្បញ្ញត្តិផ្តល់ការគាំទ្រដល់វិស័យហិរញ្ញវត្ថុឌីជីថល និង សេដ្ឋកិច្ចឌីជីថល
- កម្រិតនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចល័ត (ឧ. ភាពជាម្ចាស់ទូរស័ព្ទ និង ការគ្របដណ្តប់របស់បណ្តាញទូរស័ព្ទ) និង ឋានៈរបស់ស្ថានប្រព័ន្ធនៃការទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថល
- ស្ថានភាពរបស់ស្ថានប្រព័ន្ធនៃនវានុវត្តន៍របស់ប្រទេសមួយ និង
- ការចូលរួមយ៉ាងសកម្មរបស់វិស័យសាធារណៈនិងឯកជននៅក្នុងការអភិវឌ្ឍជំនាញឌីជីថល និង ជំនាញហិរញ្ញវត្ថុ និង ការប្រើប្រាស់បណ្តាញឌីជីថលសម្រាប់ការអភិវឌ្ឍជំនាញដែលពាក់ព័ន្ធ។ (UNCDF ឆ្នាំ២០១៩)

ពាក់ព័ន្ធទៅលើបរិយាប័ន្នឌីជីថលនៅក្នុងវិស័យនយោបាយ ការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិកគឺជា "ដំណើរការនៃការរួមបញ្ចូលប្រជាជនតាមរយៈ ICTs នៅក្នុងគោលនយោបាយ ការសម្រេចចិត្ត និង ការរចនា និង ផ្តល់សេវា ដើម្បីធ្វើឲ្យមានការចូលរួមមានបរិយាប័ន្ន និង មានការពិចារណាយ៉ាងប្រុងប្រយ័ត្ន" (UN ឆ្នាំ២០១៨ ទំព័រ ១១២)។ Macintosh (២០០៤:៣) សម្គាល់ឃើញកម្រិតទាំងបីនៃការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក៖

- *ការអនុញ្ញាតឲ្យប្រើប្រព័ន្ធអេឡិចត្រូនិក (E-enabling)៖* គាំទ្រដល់អ្នកដែល តាមធម្មតាមិនអាចប្រើប្រាស់អ៊ីនធឺណិតបាន និង ទាញយកអត្ថប្រយោជន៍ពីទិន្នន័យជាច្រើន ដែលអាចរកបាន
- *ការបង្កលក្ខណៈឲ្យចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក (E-engaging)៖* ការពិគ្រោះយោបល់ជាមួយអ្នកទស្សនាក្នុងចំនួនច្រើន ដើម្បីធ្វើឲ្យមានការរួមបញ្ចូលកាន់តែជ្រាលជ្រៅ និង គាំទ្រការជជែកវែកញែកដោយមានការពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីបញ្ហាគោលនយោបាយ
- *ការផ្តល់ភាពអង់អាចតាមប្រព័ន្ធអេឡិចត្រូនិក (E-empowering)៖* គាំទ្រដល់ការចូលរួម

យ៉ាងសកម្ម និង ការជួយសម្រួលពីថ្នាក់ក្រោមទៅថ្នាក់លើ ដើម្បីជះឥទ្ធិពលដល់របៀបវារៈផ្នែកនយោបាយ។

ការស្ទង់មតិអំពីរដ្ឋាភិបាលអេឡិចត្រូនិករបស់អង្គការសហប្រជាជាតិ (UN) រួមបញ្ចូលសន្ទស្សន៍នៃការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក ដែលវាស់វែង៖ "(i) ព័ត៌មានអេឡិចត្រូនិក ពោលគឺលទ្ធភាពក្នុងការស្វែងរកព័ត៌មានអនឡាញ (ii) ការពិគ្រោះយោបល់តាមប្រព័ន្ធអេឡិចត្រូនិក ពោលគឺការពិគ្រោះយោបល់ជាសាធារណៈតាមអនឡាញ និង (iii) ការសម្រេចចិត្តតាមប្រព័ន្ធអេឡិចត្រូនិក ពោលគឺរួមបញ្ចូលសាធារណជននៅក្នុងដំណើរការនៃការសម្រេចចិត្តដោយផ្ទាល់" (UN ឆ្នាំ២០១៨ ទំព័រ ១១២)។

## ការវាស់វឌ្ឍនភាព

វឌ្ឍនភាពចំពោះសង្គមឌីជីថលដែលមានបរិយាប័ន្ន អាចត្រូវបានប្រមូលផ្តុំតាមសន្ទស្សន៍មួយចំនួន។

សន្ទស្សន៍អ៊ីនធឺណិតដែលមានបរិយាប័ន្ន "វាស់កម្រិតដែលអ៊ីនធឺណិតមិនត្រឹមតែអាចប្រើប្រាស់បាន និង មានតម្លៃសមរម្យតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ជាប់ពាក់ព័ន្ធនឹងមនុស្សគ្រប់រូប តាមវិធីដែលរួមចំណែកដល់វឌ្ឍនភាពផ្នែកសង្គម និង សេដ្ឋកិច្ចផងដែរ" (អង្គភាពផ្តល់ព័ត៌មានឆ្លាតវៃដល់អ្នកសេដ្ឋកិច្ច ២០២០:១២)។ គំហើញសំខាន់ៗនៃសន្ទស្សន៍ អ៊ីនធឺណិតដែលមានបរិយាប័ន្ន ឆ្នាំ២០២០ រួមមាន៖

- ការប្រើប្រាស់អ៊ីនធឺណិតមានការកើនឡើងនៅទូទាំងសកលលោក ប៉ុន្តែភាពខុសគ្នាយ៉ាងខ្លាំងក្លានៅតែបន្តកើតឡើង ហើយអត្រានៃការរួមបញ្ចូលមានភាពយឺតយ៉ាវនៅក្នុងតំបន់ដែលពិបាកទៅដល់។
- ទិន្នន័យចល័តបានក្លាយជាកត្តាកែប្រែសម្រាប់ក្រុមប្រជាជនដែលមានប្រាក់ចំណូលទាប ប៉ុន្តែការចូលប្រើប្រាស់នៅតែមានតម្លៃថ្លៃខ្លាំង។
- ទោះបីជាមានការរួមតូចក៏ដោយ ក៏គម្លាតយេនឌ័រនៅក្នុងការចូលប្រើប្រាស់ នៅតែមានទំហំធំយ៉ាងខ្លាំង។
- ការលាតសន្ធឹងរបស់ឧបករណ៍ចល័តគឺជានិន្នាការវិជ្ជមាន ប៉ុន្តែតួនាទីរបស់វា ក្នុងនាមជាអ្នកផ្តល់លទ្ធភាពចូលប្រើប្រាស់ សម្រាប់ស្ត្រីក្រីក្រខ្លាំងបំផុតនៅលើពិភពលោក នៅតែមាន

ភាពមិនច្បាស់លាស់។ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបបំផុត វឌ្ឍនភាពនៃការលាតសន្ធឹងនេះ ប្រហែលជាកំពុងតែវិវឌ្ឍន៍បញ្ច្រាសទិសថែមទៀតផង។

- អ៊ីនធឺណិតកំពុងតែជួយសម្រួលដល់ការគ្រប់គ្រងរបស់មនុស្សលើប្រាក់ និង ហិរញ្ញវត្ថុរបស់ពួកគេ និង បរិយាប័ន្នរបស់ពួកគេនៅក្នុងសេដ្ឋកិច្ចដែលមានទ្រង់ទ្រាយធំជាងនេះ។
- ការប្រើប្រាស់អ៊ីនធឺណិតកំពុងតែពង្រីកឱកាសផ្នែកហិរញ្ញវត្ថុសម្រាប់បុគ្គលទាំងឡាយ ជាពិសេស នៅក្នុងពិភពលោកដែលកំពុងតែអភិវឌ្ឍ។
- ការតភ្ជាប់ដោយចល័ត កំពុងតែក្លាយជាកត្តាដែលធ្វើឲ្យមានសមាភាពផ្នែកហិរញ្ញវត្ថុ។ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ការតភ្ជាប់ដោយចល័តមានសារសំខាន់ ចំពោះបរិយាប័ន្នផ្នែកហិរញ្ញវត្ថុ ខ្លាំងជាង នៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ នៅកន្លែងដែលប្រជាជនទំនងជាអនុវត្តកិច្ចការទាំងនោះនៅលើការតភ្ជាប់ថេរដែលមានភាពរឹងមាំជាង។
- មនុស្សកំពុងតែប្រើប្រាស់ប្រព័ន្ធអនឡាញដើម្បីរៀបចំការងារដែលប្រើបច្ចេកវិទ្យាខ្លាំង សម្រាប់ថ្ងៃស្អែក។
- ប្រជាជនវ័យកណ្ដាលលើកកម្ពស់អ៊ីនធឺណិត ច្រើនជាងវិធីផ្សេងទៀត សម្រាប់ការបំពេញការងារបន្ទាន់។
- ឱកាសផ្នែកឌីជីថលសម្រាប់ពង្រឹងសមត្ថភាពផ្ទាល់ខ្លួន នៅក្នុងប្រភេទផ្សេងទៀត កំពុងតែត្រូវបានចាប់ផ្ដើមអនុវត្តយ៉ាងទូលំទូលាយ។ ការប្រើប្រាស់អ៊ីនធឺណិតក៏ជួយដល់ប្រជាជនទាំងឡាយឲ្យមានការចូលរួមកាន់តែច្រើនជាងមុនដែរ។
- ទំនុកចិត្តលើប្រព័ន្ធអ៊ីនធឺណិតមានការធ្លាក់ចុះនៅក្នុងបរិបទមួយចំនួន ដូចជាព័ត៌មានដែលត្រូវបានដាក់តាមអនឡាញដោយរដ្ឋាភិបាល គេហទំព័រដែលមិនមែនជារបស់រដ្ឋាភិបាល និង កម្មវិធី និង ព័ត៌មានដែលត្រូវបានផ្សព្វផ្សាយដោយបុគ្គលទាំងឡាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ (អង្គភាពផ្ដល់ព័ត៌មានឆ្លាតវៃដល់អ្នកសេដ្ឋកិច្ច ២០២០: ១២)

វិធីមួយទៀតដើម្បីតាមដានវឌ្ឍនភាព គឺ តាមរយៈសន្ទស្សន៍នៃការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងការស្ទង់មតិអំពីរដ្ឋាភិបាលអេឡិចត្រូនិករបស់ UN។

ការកែសម្រួលឆ្នាំ២០១៨ លើការស្ទង់មតិអំពីរដ្ឋាភិបាលអេឡិចត្រូនិករបស់អង្គការសហប្រជាជាតិ (២០១៨) បានបង្ហាញដូចខាងក្រោម៖

- រដ្ឋាភិបាលអេឡិចត្រូនិកបាន និង កំពុងតែមានការកើនឡើងយ៉ាងខ្លាំងក្លានៅក្នុងរយៈពេលជាង ១៧ ឆ្នាំកន្លងមកនេះ ចាប់ពីពេលដែលអង្គការសហប្រជាជាតិមានបំណងសិក្សាអំពីស្ថានភាពរបស់រដ្ឋបាលអេឡិចត្រូនិក ជាលើកដំបូង កាលពីឆ្នាំ២០០១។

ការស្ទង់មតិឆ្នាំ២០១៨ គូសបញ្ជាក់អំពីនិន្នាការជាសកលដែលនៅតែមានភាពវិជ្ជមានចំពោះការអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិកនៅកម្រិតខ្ពស់។ សន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិក (EGDI) ជាមធ្យម នៅលើពិភពលោក មានការកើនឡើងពី ០,៤៧ នៅឆ្នាំ២០១៤ ទៅ ០,៥៥ នៅឆ្នាំ២០១៨ (ទំព័រ ៨៤, ៨៧)។

- នៅក្នុងក្រុម "EGDI ខ្ពស់ខ្លាំង" ៦៧% នៃប្រទេសទាំងអស់មកពីតំបន់អឺរ៉ុប តាមដោយ អាស៊ី (២០%) អាមេរិក (៨%) និង អូសេអានី (៥%)។ នៅក្នុងក្រុម "EGDI ខ្ពស់" ថ្នាក់ដឹកនាំមកពីតំបន់អាស៊ី និង អាមេរិក (៣៣% និង ៣១% ដោយឡែកពីគ្នា) តាមដោយ អឺរ៉ុប (២២%) អាហ្វ្រិក (១១%) និង អូសេអានី (៣%)។ នៅក្នុងក្រុម "EGDI ថ្នាក់កណ្តាល" ប្រទេសនៃតំបន់អាហ្វ្រិក មាន ៥០%... និង អាស៊ីមានរហូតដល់ ២០% នៃចំណែកនៅក្នុងក្រុម។ ពុំមានប្រទេសនៃតំបន់អឺរ៉ុប ស្ថិតនៅក្នុងក្រុម EGDI ថ្នាក់កណ្តាល និង ទាបនោះទេ។ ក្នុងចំណោមប្រទេសទាំង ១៥ ដែលស្ថិតនៅក្នុងក្រុម "EGDI ថ្នាក់ទាប" ភាគច្រើនមកពីអាហ្វ្រិក (៨៧%) តាមដោយ ២ ប្រទេសនៅអាស៊ី (១៣%)។ (ទំព័រ ៩៣)

ចំពោះការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេស ការស្ទង់មតិ ឆ្នាំ២០១៨ បានរាយការណ៍ដូចខាងក្រោម៖

- ប្រទេសដាណឺម៉ាក ប្រទេសហ្វាំងឡង់ សាធារណរដ្ឋកូរ៉េ (ចាប់ពីពេលនេះតទៅ ហៅថា ប្រទេសកូរ៉េ) បានជាប់ចំណាត់ថ្នាក់ជាប្រទេសឈានមុខគេជាសកលចំពោះការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក នៅខណៈពេលដែលប្រទេសហូឡង់ ប្រទេសអូស្ត្រាលី ប្រទេសជប៉ុន ប្រទេសនូវែលហ្សេឡង់ ចក្រភពអង់គ្លេស (UK) សហរដ្ឋអាមេរិក និង ប្រទេសអេស្ប៉ាញ កំពុងតែតាមពីក្រោយយ៉ាងកៀក (ទំព័រ ១១៤)។

- ប្រទេសនៃតំបន់អឺរ៉ុបរួមចំនួន ៧០% នៅក្នុងក្រុម ៦២ ប្រទេសដែលមានសន្ទស្សន៍ការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក (EPI) នៅកម្រិតខ្ពស់ខ្លាំង (ទោះបីជា មានចំនួនតែ ២២% នៃរដ្ឋសមាជិក UN ក៏ដោយ)។ អាស៊ីតាមមកបន្ទាប់ ដោយមានចំនួន ៣៦% នៅក្នុងក្រុមដែលមាន "EPI ខ្ពស់ខ្លាំង" ដូចគ្នានោះ (នៅខណៈពេលដែល មានចំនួន ២៤% ក្នុងចំណោមរដ្ឋសមាជិកទាំង ១៩៣) (ទំព័រ ១១៧)។

- ពាក់ព័ន្ធនឹងសមាសធាតុតូចនៃសន្ទស្សន៍នេះ៖
  - ព័ត៌មានអេឡិចត្រូនិក៖ រដ្ឋសមាជិកកំពុងតែចែករំលែកព័ត៌មានកាន់តែច្រើនជាមួយប្រជាពលរដ្ឋរបស់ពួកគេ ភាគច្រើននៅក្នុងវិស័យអប់រំ និង វិស័យសុខាភិបាល និង តាមយ៉ាងកៀក ដោយវិស័យដទៃទៀត (ទំព័រ ១១៨)
  - ការពិគ្រោះយោបល់តាមប្រព័ន្ធអ៊ីនធឺណិត៖ គ្រប់តំបន់ទាំងអស់មានវឌ្ឍនភាពនៅក្នុងប្រើប្រាស់ឧបករណ៍ពិគ្រោះយោបល់នៅក្នុងឆ្នាំ២០១៨ ប្រសិនបើប្រៀបនឹងឆ្នាំ២០១៦។ នៅអឺរ៉ុប គ្រប់ប្រទេសទាំងអស់មានឧបករណ៍ ឬ សកម្មភាពសម្រាប់ការចូលរួមតាមអនឡាញ ៤២ ប្រទេសមានឧបករណ៍បង្កើតបណ្ដាញផ្សព្វផ្សាយសង្គម ៣៩ ប្រទេសមានឧបករណ៍អេឡិចត្រូនិកសម្រាប់ការពិគ្រោះយោបល់ ឬ ការពិភាក្សាជាសាធារណៈ និង ៤០ ប្រទេស នាពេលថ្មីៗនេះ បានប្រើប្រាស់ការពិគ្រោះយោបល់ ឬ ការពិភាក្សាតាមអនឡាញ (ទំព័រ ១១៩)
  - ការសម្រេចចិត្តតាមប្រព័ន្ធអេឡិចត្រូនិកនៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ (ទំព័រ ១២០)។

វឌ្ឍនភាពរបស់អឺរ៉ុបដើម្បីឆ្ពោះទៅកាន់សង្គមឌីជីថលដែលមានបរិយាប័ន្ន អាចត្រូវបានមើលឃើញនៅក្នុងសន្ទស្សន៍សេដ្ឋកិច្ច និង សង្គមឌីជីថលអន្តរជាតិ (I-DESI) (គណៈកម្មការអឺរ៉ុប ឆ្នាំ ២០១៨)។ I-DESI ផ្ដល់ការប៉ាន់ប្រមាណជាទូទៅអំពីគោលជំហររបស់ប្រទេសនៃ EU ទាំង ២៨ ប្រទេស ដោយប្រៀបធៀបនឹងសេដ្ឋកិច្ចរបស់ប្រទេសដែលមិនមែនជា EU ចំនួន ១៧ ប្រទេស។[78] I-DESI វាស់វែងអំពីការតភ្ជាប់ មូលធនមនុស្ស (ជំនាញឌីជីថល) ការប្រើប្រាស់អ៊ីនធឺណិតដោយប្រជាពលរដ្ឋ និង សមាហរណកម្មនៃបច្ចេកវិទ្យា និង សេវាកម្មឌីជីថលសាធារណៈ នៅក្នុងចំណោមលទ្ធផលសំខាន់ៗនៅក្នុងឆ្នាំ២០១៨ របាយការណ៍ I-DESI មានដូចតទៅ។ (i) រដ្ឋសមាជិក EU ជាមធ្យម ដោយប្រៀបធៀបនឹងប្រទេសមិនមែន EU និង ប្រទេស EU ធំៗ ស្ថិតនៅក្នុងចំណោមអ្នកអនុវត្តល្អបំផុតនៅលើសកលលោក៖ រដ្ឋសមាជិក EU ចំនួនប្រាំមួយស្ថិតនៅក្នុងចំណោមប្រទេសដែលទទួលបានលទ្ធផលល្អបំផុតទាំងដប់។ (ii) នៅចន្លោះឆ្នាំ២០១៣ និង ២០១៦ រដ្ឋសមាជិក EU មានវឌ្ឍនភាពយ៉ាងទៀងទាត់លើការអនុម័ត និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ទោះបីជាយ៉ាងណាក៏ដោយ EU ទាំងមូល មិនបានបិទគម្លាត ជាមួយ សហរដ្ឋអាមេរិក ប្រទេសកូរ៉េ និង

[78] ប្រទេសមិនមែន EU ទាំង ១៧ ប្រទេស រួមមាន ប្រទេសអូស្ត្រាលី ប្រទេសប្រេស៊ីល ប្រទេសកាណាដា ប្រទេសឈីលី ប្រទេសចិន ប្រទេសអ៊ីស្លង់ ប្រទេសអ៊ីស្រាអ៊ែល ប្រទេសជប៉ុន ប្រទេសម៉ិកស៊ិក ប្រទេសនូវែលហ្ស៊ីឡង់ ប្រទេសន័រវេ ប្រទេសរុស្ស៊ី ប្រទេសស៊ែប៊ី, South, ប្រទេសស្វីស ប្រទេសទួរគី និង សហរដ្ឋអាមេរិក។

ប្រទេសជប៉ុន បានដោយជោគជ័យនោះទេ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍ និង ផ្ទុយពីរបាយការណ៍ រដ្ឋាភិបាលអេឡិចត្រូនិករបស់ UN នោះគឺ I-DESI ចែងថា រដ្ឋាភិបាលអេឡិចត្រូនិកគឺជារង្វាស់មួយ ដែលរដ្ឋសមាជិក EU មានលទ្ធផលនៃការអនុវត្តជាមធ្យម ទាបជាងប្រទេសសមភាគីដែលមិនមែនជា EU ទាំង ១៧ ប្រទេស។ ប្រាំបួនប្រទេស ក្នុងចំណោមប្រទេសដែលមិនមែនជា EU ទាំង ១៧ ប្រទេស រួមបញ្ចូលទាំង ប្រទេសកូរ៉េ សហរដ្ឋអាមេរិក និង ប្រទេសជប៉ុនផងដែរ នៅក្នុងឆ្នាំ២០១៦ មានពិន្ទុជាមធ្យម ខ្ពស់ជាង EU។

យោងតាមសន្ទស្សន៍បរិវត្តកម្មឌីជីថលនៅអាស៊ី ឆ្នាំ២០១៨ អាស៊ីកំពុងតែតាមពីក្រោយប្រទេសលោកខាងលិច នៅក្នុងការកសាងមជ្ឈដ្ឋានសម្រាប់ការផ្លាស់ប្តូរដែលដឹកនាំដោយបច្ចេកវិទ្យា (អង្គភាពផ្តល់ព័ត៌មានឆ្លាតវៃដល់អ្នកសេដ្ឋកិច្ច ឆ្នាំ២០១៨)។ សន្ទស្សន៍នេះវាស់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល មូលធនមនុស្ស និង ការតភ្ជាប់ផ្នែកឧស្សាហកម្ម។

ប្រទេសកំពូលៗទាំង ១០ នៅក្នុងសន្ទស្សន៍នេះ រួមមាន ប្រទេសសិង្ហបុរី ប្រទេសជប៉ុន ហុងកុង ប្រទេសកូរ៉េ តៃវ៉ាន់ ប្រទេសម៉ាឡេស៊ី ប្រទេសចិន ប្រទេសឥណ្ឌា ប្រទេសថៃ និង ប្រទេសហ្វីលីពីន។

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) កំពុងតែមានវឌ្ឍនភាពឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល (សារព័ត៌មានវៀតណាម/បណ្តាញសារព័ត៌មានអាស៊ី ឆ្នាំ២០១៩)។ សេដ្ឋកិច្ចឌីជីថលរបស់អាស៊ីអាគ្នេយ៍ត្រូវបានប្រមើលមើលថា នឹងឈានដល់ ២០០ ប៊ីលានដុល្លារអាមេរិក ត្រឹមឆ្នាំ ២០១៥។ Bain & Company (២០១៨) បង្ហាញថា សមាមាត្រនៃសេដ្ឋកិច្ចឌីជីថលនៅក្នុងផលិតផលក្នុងស្រុកសរុបរបស់អាស៊ាន គឺ ៧% ដោយប្រៀបធៀបនឹង ១៦% នៅប្រទេសចិន ២៧% នៅ EU-៥ (ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសអ៊ីតាលី ប្រទេសអេស្ប៉ាញ និង ចក្រភពអង់គ្លេស) និង ៣៥% នៅសហរដ្ឋអាមេរិក។ ប្រទេសជាច្រើនជឿជាក់ថា អាស៊ាន មានសក្តានុពលចំពោះការចូលក្នុងសេដ្ឋកិច្ចឌីជីថលកម្រិតកំពូលៗ នៅលើពិភពលោក ត្រឹមឆ្នាំ ២០២៥។

## កិច្ចសហប្រតិបត្តិការនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប លើបញ្ហាចំនួនបី

បញ្ហាប្រឈមសម្រាប់អ្នកបង្កើតគោលនយោបាយ និង ភាគីពាក់ព័ន្ធដទៃទៀត គឺរបៀប ធ្វើការជាមួយគ្នាដោយប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើតសង្គមឌីជីថលដែលមានបរិយាប័ន្នខ្លាំងជាងនេះ។

នៅខណៈពេលដែលមានបញ្ហាបរិយាប័ន្នឌីជីថលយ៉ាងទូលំទូលាយ ដែលកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) អាចសហការគ្នាបាននោះ ជំពូកនេះស្នើឲ្យផ្តោតលើតំបន់ចំនួនបី៖ អនាគតរបស់ការងារ(អ្នកធ្វើការ) ប្រាជ្ញាសិប្បនិម្មិតនៅក្នុងអភិបាលកិច្ច និង ការការពារទិន្នន័យ និង ឯកជន

ភាព។

## ASEM ចំពោះអនាគតនៃការងារ (អ្នកធ្វើការ)

Marr (២០១៩) ណែនាំអំពី វិធីចំនួនប្រាំដូចខាងក្រោម ដែលការងារនឹងមានការប្រែប្រួលនាថ្ងៃអនាគត៖

1. ងាយប្រែប្រួល និង មានរយៈពេលខ្លី៖ នៅក្នុងអង្គការមួយ មុខតំណែងនឹងងាយប្រែប្រួលជាងមុន ហើយ រចនាសម្ព័ន្ធគ្រប់គ្រងដ៏តឹងរ៉ឹងមួយទំនងជានឹងត្រូវបោះបង់ចោល ដោយសារក្រុមការងារដែលធ្វើការតាមគម្រោងកាន់តែច្រើនឡើង

2. កម្លាំងពលកម្មដែលបានធ្វើវិមជ្ឈការ៖ ដោយសារតែបច្ចេកវិទ្យាចល័ត និង ការប្រើអ៊ីនធឺណិតដែលមានរួចជាស្រេចហើយនោះ អ្នកធ្វើការនៅខាងក្រៅការិយាល័យគឺទូទៅរួចទៅហើយ។ និយោជិតនឹងមិនចាំបាច់ត្រូវស្ថិតនៅកន្លែងដដែលនោះទេ។

3. ការជំរុញទឹកចិត្តឲ្យបំពេញការងារ៖ ប្រជាជននឹងត្រូវការអ្វីផ្សេងក្រៅពីប្រាក់បៀវត្សរ៍ដើម្បីជំរុញទឹកចិត្តឲ្យបំពេញការងារ។ មនុស្សជាច្រើនធ្វើការឲ្យអង្គការមួយ ដោយមានបេសកកម្ម និង គោលបំណង ដែលពួកគេជឿជាក់។ ពួកគេក៏ចង់ទទួលបានវត្ថុលើកទឹកចិត្តខុសៗគ្នាផងដែរ ដូចជា ឱកាសអភិវឌ្ឍផ្ទាល់ខ្លួន ឧបករណ៍ដែលប្រើបច្ចេកវិទ្យាចុងក្រោយគេបង្អស់ដើម្បីជួយសម្រួលដល់មហិច្ឆិតាក្នុងការបំពេញការងាររបស់ពួកគេពីគ្រប់ទីកន្លែង និង អ្វីៗផ្សេងៗទៀត។

4. ការរៀនសូត្រពេញមួយជីវិត៖ នយោជិតមិនត្រឹមតែចង់រៀនសូត្រពេញមួយជីវិតការងាររបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ចាំបាច់ត្រូវរៀនជំនាញថ្មីៗទៀតដែរ។ បច្ចេកវិទ្យានឹងបន្តកែប្រែតួនាទីរបស់មនុស្សនៅកន្លែងធ្វើការ ដូច្នេះមនុស្សគ្រប់រូបនឹងត្រូវកែសម្រួលជំនាញរបស់ពួកគេ នៅពេញមួយជីវិតការងាររបស់ពួកគេ។

5. បច្ចេកវិទ្យានឹងបង្កើនការងាររបស់មនុស្ស៖ អាល់កូរីតនៃប្រាជ្ញាសិប្បនិម្មិត និង ម៉ាស៊ីនឆ្លាតវៃនឹងធ្វើការរួមគ្នាជាមួយមនុស្ស។ កម្លាំងពលកម្មមនុស្សនឹងចាំបាច់ត្រូវអភិវឌ្ឍ ផាសុកភាព និង ការទទួលយកមួយកម្រិតទៀត ចំពោះវិធីដែលមនុស្ស និង ម៉ាស៊ីនអាចសហការគ្នាតាមរយៈការខិតខំប្រឹងប្រែងអស់ពីលទ្ធភាពរបស់ភាគីទាំងពីរនៅកន្លែងធ្វើការ។

សាច់រឿងមួយរបស់ Business Insider ដោយប្រើប្រាស់គម្រោងការងារ និង ទិន្នន័យប្រាក់

បៀវត្សរ៍ពីការិយាល័យស្ថិតិការងារនៃសហរដ្ឋអាមេរិក បានសម្គាល់ឃើញការងារកំពូលៗចំនួន ៣០ នៅសហរដ្ឋអាមេរិក នៅទសវត្សរ៍ក្រោយ (Kiersz និង Hoff ឆ្នាំ២០១៩)។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍គឺ បញ្ជីនោះមិនត្រូវបានគ្រប់គ្រងដោយ "អ្នកធ្វើការដែលមានចំណេះដឹង" នោះទេ។ តារាងទី១ រៀបរាប់អំពីការងារមួយចំនួន ក្នុងចំណោមការងារទាំងនេះ។

**តារាងទី១ៈ ការងារនៅទសវត្សរ៍ក្រោយ**

| ការងារចំនួន ៥ នៅផ្នែកខាងលើបំផុតនៃការងារទាំង ៣០ | ការងារចំនួន ៥ នៅផ្នែកខាងក្រោមបំផុតនៃការងារទាំង ៣០ |
|---|---|
| ១. គិលានុប្បដ្ឋាក-យិកាមធ្យម | ២៦. ជាងជួសជុលបំពង់បង្ហូរទឹក អ្នកបំពាក់បំពង់ឧស្ម័ននានា និង |
| ២. អ្នកអភិវឌ្ឍកម្មវិធីសូហ្វវែរ | ២៧. រាល់ការងារដទៃទៀតដែលពាក់ព័ន្ធកុំព្យូទ័រ |
| ៣. អ្នកគ្រប់គ្រងទូទៅ និង អ្នកគ្រប់គ្រងប្រតិបត្តិការ | ២៨. គិលានុប្បដ្ឋាក-យិកាហ្វឹកហាត់មានអាជ្ញាប័ណ្ណ និង គិលានុប្បដ្ឋាក-យិកាវិជ្ជាជីវៈមានអាជ្ញាប័ណ្ណ |
| ៤. អ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ | ២៩. អ្នកឯកទេសគាំទ្រអ្នកប្រើប្រាស់កុំព្យូទ័រ |
| ៥. អ្នកវិភាគអំពីការគ្រប់គ្រង | ៣០. អ្នកវិភាគអំពីសន្តិសុខព័ត៌មាន |

ប្រភពៈ Kiersz និង Madison (២០២០)

អនាគតការងារ(អ្នកធ្វើការ) កំពុងតែត្រូវបានកំណត់ទ្រង់ទ្រាយដោយកម្លាំងដែលពោរពេញដោយថាមពលចំនួនពីរៈ (i) ស្វ័យប្រវត្តិកម្ម និង ប្រាជ្ញាសិប្បនិម្មិត និង (ii) ការលេចឡើងនៃទីផ្សារការងាររយៈពេលខ្លី។

មនុស្សជាច្រើនមានការភ័យខ្លាចថា ស្វ័យប្រវត្តិកម្ម និង ប្រាជ្ញាសិប្បនិម្មិត (AI) នឹងជំនួសកន្លែងអ្នកធ្វើការ។ សេដ្ឋកិច្ចវិទូនៃ Oxford ពីររូប គឺ Carl Frey និង Michael Osborne ទស្សន៍ទាយថា ៤០% នៃគ្រប់ការងារទាំងអស់ (ជាពិសេស ការងារដដែលៗ ដែលមិនសូវមានជំនាញ) នឹងត្រូវបាត់បង់ដោយសារកុំព្យូទ័រ និង មនុស្សយន្ត នៅក្នុងរយៈពេល ២០ ឆ្នាំក្រោយ (Seager ឆ្នាំ២០១៦)។

ការងារដែលនឹងនៅបន្ត គឺជាការងារដែលជាប់ពាក់ព័ន្ធនឹងអន្តរកម្មនៃសង្គមដែលស្មុគស្មាញ ការងារដែលមានគំនិតច្នៃប្រឌិត/ការងារសិល្បៈ ការងារដែលជាប់ពាក់ព័ន្ធនឹងការចាត់ចែងវត្ថុនានាដោយស្វយ័ត (សមត្ថភាពនៅក្នុងការបង្កើនសកម្មភាព និង ផ្លាស់ទីជុំវិញវត្ថុដែលមានទំហំខុសៗ

គ្នា) និង ការងារដែលត្រូវការចំណាប់អារម្មណ៍ និង គុណភាពរបស់មនុស្ស។

មូលនិធិហ្វត (The Ford Foundation (n.d.)) ណែនាំថា ទោះបីជាការងារនានាអាចនឹងបាត់បង់ក៏ដោយ ក៏បច្ចេកវិទ្យាឌីជីថលនឹងបង្កើតឧស្សាហកម្មថ្មីៗ និង ការងារថ្មីៗទៀតដែរ។ មានសក្តានុពលនៅក្នុងជួយបង្កើនផលិតភាពរបស់មនុស្ស ព្រមទាំងគុណភាពការងារ និង បង្កើតឱកាសការងារសម្រាប់ជនពិការផងដែរ។

*ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី* ឆ្នាំ២០១៨ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ណែនាំអំពីសុទិដ្ឋិនិយមដែលត្រូវប្រុងប្រយ័ត្នចំពោះបច្ចេកវិទ្យា និង ការងារ (ADB ២០១៨)។ ទស្សនវិស័យនេះ ទទួលស្គាល់ថាការងារដដែលៗ ការងារធ្វើដោយដៃអាចត្រូវបានបាត់បង់ដោយសារមនុស្សយន្ត។ ទោះបីជាយ៉ាងណាក៏ដោយ គេក៏បានរកឃើញផងដែរថាបច្ចេកវិទ្យាថ្មីៗអាចបង្កើតការងារតាមរយៈការជំរុញឲ្យមានតម្រូវការ និង ផលិតភាព។ បច្ចេកវិទ្យាឌីជីថល ក៏ត្រូវបានមើលឃើញថាកំពុងតែបង្កើតឧស្សាហកម្មថ្មីៗផងដែរ (ឧ. ការព្រីនរូបអវយវៈសិប្បនិម្មិតជាទម្រង់ 3D)។ *ទស្សនវិស័យស្តីពីការងារ និងមុខរបរ* ឆ្នាំ២០១៩ របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច (OECD ២០១៩: ១៣) កត់សម្គាល់ថា "នឹងមានឈ្មួញស្វែងរកការងារកាន់តែច្រើន រួមជាមួយការងារថ្មីៗ ខុសៗគ្នា ដែលជំនួសឲ្យការងារដែលបានបាត់បង់ ហើយនេះនឹងបណ្តាលឲ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធ និង តម្រូវការនៃជំនាញថ្មីៗ"។ បញ្ហាប្រឈមនេះ "នឹងគ្រប់គ្រងការឆ្លងកាត់ឆ្ពោះទៅកាន់ឱកាសថ្មីៗសម្រាប់អ្នកធ្វើការ ឧស្សាហកម្ម និង តំបន់នានាបានដោយជោគជ័យ"។

ស្របពេលជាមួយគ្នានោះ គណៈកម្មការសកលស្តីពីអនាគតការងាររបស់អង្គការអន្តរជាតិ ខាងការងារ ស្នើឲ្យមាន "របៀបវារៈសម្រាប់អនាគតការងារដែលផ្តោតលើមនុស្សជាសំខាន់" (ILO ឆ្នាំ២០១៩)។ អនុសាសន៍របស់ពួកគេរួមមាន ដូចខាងក្រោម៖

- ការវិនិយោគលើសមត្ថភាពរបស់មនុស្ស
    - ការរៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប
    - គាំទ្រប្រជាជនតាមរយៈចម្លងការនានា
    - របៀបវារៈនៃការផ្លាស់ប្តូរដើម្បីសមភាពយេនឌ័រ
    - ពង្រឹងកិច្ចគាំពារសង្គម
- ការវិនិយោគលើស្ថាប័នការងារ

- បង្កើតការធានាចំពោះពលកម្មជាសកល
- ពង្រីកអំណាចក្នុងការគ្រប់គ្រងពេលវេលា
- ធ្វើឲ្យការតំណាងជាសមូហភាពមានភាពរស់រវើកឡើងវិញ
- បច្ចេកវិទ្យាសម្រាប់ការងារសមរម្យ

- វិនិយោគលើការងារដែលសមរម្យ និង មានចីរភាព
  - លើកកម្ពស់ការវិនិយោគលើផ្នែកសំខាន់ៗសម្រាប់ការងារដែលសមរម្យ និង មានចីរភាព
  - បង្កើតទ្រង់ទ្រាយរចនាសម្ព័ន្ធគ្រឿងលើកទឹកចិត្តផ្នែកអាជីវកម្មសារឡើងវិញ ដើម្បីលើកទឹកចិត្តដល់ការវិនិយោគលើសេដ្ឋកិច្ចពិតក្នុងរយៈពេលវែង និង អភិវឌ្ឍសូចនាករនៃវឌ្ឍនភាពបំពេញបន្ថែម ដើម្បីឆ្ពោះទៅកាន់សុខមាលភាព និរន្តរភាពបរិស្ថាន និង សមភាព។

ការវិនិយោគលើសមត្ថភាពរបស់មនុស្ស គួរតែជាអាទិភាពរបស់រដ្ឋាភិបាល សម្រាប់ការបង្កើតសង្គមឌីជីថលដែលមានបរិយាប័ន្ន។ ប៉ុន្តែ នៅក្នុងការធ្វើបែបនេះ វាមានសារសំខាន់នៅក្នុងការចងចាំថា"គោលនយោបាយស្តីពីជំនាញ ជាញឹកញាប់មិនអាចចូលទៅដល់មនុស្សពេញវ័យដែលងាយប្រឈមមុខនឹងហានិភ័យនៃការផ្លាស់ប្តូរ ដែលនៅខាងមុខនោះទេ" (OECD ២០១៩: ១៥)។ អ្នកធ្វើការដែលងាយរងគ្រោះ ជាញឹកញាប់ មិនបានសម្គាល់ឃើញសកម្មភាពរៀនសូត្រដែលពាក់ព័ន្ធនោះទេ និង/ឬ ខ្វះខាតពេលវេលា ឬ ប្រាក់ដើម្បីធ្វើការបណ្តុះបណ្តាល។

បញ្ហាដែលធំជាងនេះទៀតនោះគឺ "មតិយោបល់របស់អ្នកធ្វើការដោយផ្ទាល់ ភាគច្រើន មិនបានចូលរួមនៅក្នុងការជជែកវែកញែក ការសម្រេចចិត្ត និង ការពិភាក្សា ដែលនឹងកំណត់ទ្រង់ទ្រាយនៃអនាគតរបស់ពួកគេនោះទេ (Kinder ឆ្នាំ២០១៩)។" ចំណុចនេះនឹងមានផលប៉ះពាល់ដល់គុណភាព និង ប្រសិទ្ធភាពរបស់គោលនយោបាយ។ ប្រសិនបើអ្នកធ្វើការមិនមែនបានចូលរួមនៅក្នុងការពិភាក្សាទេនោះ អ្នកបង្កើតគោលនយោបាយប្រឈមមុខនឹងហានិភ័យនៃការស្នើឡើងនូវដំណោះស្រាយដែលគ្មានការឆ្លើយតប។ លើសពីនេះទៀត មិនមែនមានតែកម្មវិធីបណ្តុះបណ្តាលល្អៗតែមួយមុខទេ ដែលជាបញ្ហានោះ។ ការរៀបចំ អ្នកធ្វើការដែលងាយរងគ្រោះខ្លាំងបំផុតសម្រាប់អនាគតនៃការងារឲ្យបានគ្រប់គ្រាន់តម្រូវឲ្យមានការដោះស្រាយបញ្ហាវិសមភាព អតុល្យភាពនៃអំណាច និង ភាពបរាជ័យរបស់ទីផ្សារ។

ដើម្បីបង្កើតសង្គមឌីជីថលដែលមានបរិយាប័ន្ន កិច្ចសហប្រតិបត្តិការរបស់ ASEM លើការ

អនុវត្ត "របៀបវារៈសម្រាប់អនាគតការងារដែលផ្តោតលើមនុស្សជាសំខាន់" ត្រូវបានណែនាំ។

បញ្ហាទីពីរ ដែលត្រូវតែយកមកពិចារណានៅក្នុងការដោះស្រាយអនាគតនៃការងារ(អ្នកធ្វើការ) គឺការលេចឡើងនៃ "ទីផ្សារការងាររយៈពេលខ្លី"។ ទីផ្សារការងាររយៈពេលខ្លី គឺជា "ប្រព័ន្ធទីផ្សារសេរីមួយដែលមុខតំណែងបណ្តោះអាសន្នគឺមានភាពទូទៅហើយអង្គការចុះកិច្ចសន្យាជាមួយអ្នកធ្វើការឯករាជ្យសម្រាប់ការចូលរួមក្នុងរយៈពេលខ្លី" (Rouse, n.d.)។ និយមន័យមួយទៀតគឺថា វាសំដៅលើកំណើននៃការប្រើប្រាស់ "វេទិកាឌីជីថល ដែលអនុញ្ញាតឲ្យធ្វើការងារឯករាជ្យភ្ជាប់ទំនាក់ទំនងជាមួយបុគ្គល ឬ អាជីវកម្ម ដើម្បីផ្តល់សេវាកម្ម ឬ បែងចែកទ្រព្យសកម្មក្នុងរយៈពេលខ្លី" (Mastercard and Kaiser Associates ២០១៩: ២)។ នៅទូទាំងសកលលោក ទីផ្សារការងាររយៈពេលខ្លីបានបង្កើតទឹកប្រាក់សរុបចំនួន ២០៤ ប៊ីលានដុល្លារ ដោយសេវាកម្មដឹកជញ្ជូន (ឧ. ការប្រើប្រាស់យានជំនិះរួមគ្នា) មាន ៥៨% នៃតម្លៃនេះ នៅក្នុងឆ្នាំ២០១៨ (Mastercard and Kaiser Associates, ២០១៩: ២) មុនពេលមានជំងឺរាតត្បាតសកល ចម្លងការនៃទីផ្សាររយៈពេលខ្លីជាសកល ត្រូវបានប្រមើលមើលថានឹងមានការកើនឡើងនូវអត្រាកំណើនប្រចាំឆ្នាំនៅក្នុងរយៈពេលជាក់លាក់មួយ (CAGR) ត្រឹម ១៧% ដែលមានចំនួនសរុបប្រហែល ៤៥៥ ពាន់លានដុល្លារ ត្រឹមឆ្នាំ២០២៣។ កំណើនដែលត្រូវបានប្រមើលមើលទុកមុននេះ នឹងជាលទ្ធផលនៃការវិវឌ្ឍន៍របស់ឥរិយាបថសង្គម ជុំវិញការចែករំលែករវាងមិត្តភ័ក្តិ និង បង្កើនអត្រាឌីជីថលនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

អ្នកធ្វើការនៅក្នុងទីផ្សារការងាររយៈពេលខ្លី (រួមទាំង អ្នកធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចដែលប្រើវេទិកាឌីជីថលផងដែរ) រួមមាន អ្នកធ្វើការតាមគម្រោង អ្នកជាប់កិច្ចសន្យាឯករាជ្យ ដែលមិនមែនជាផ្នែកមួយនៃកម្លាំងពលកម្ម (និយោជិត) តាមបែបប្រពៃណីនោះទេ។ ការងាររបស់ពួកគេត្រូវបានបែងចែកជាកិច្ចការ ច្រើនជាងការងារ។ ពួកគេភាគច្រើនធ្វើការតាមអនឡាញ សម្រាប់ក្រុមហ៊ុនដែលមិននៅក្នុងប្រទេសតែមួយជាមួយពួកគេនោះទេ។ ប្រភពកិច្ចការរយៈពេលខ្លី ចំនួនប្រាំធំៗ រួមមាន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ប្រទេសកាណាដា ប្រទេសអូស្ត្រាលី និង ប្រទេសឥណ្ឌា (Chen និង Djankov ឆ្នាំ២០១៨)។ អ្នកផ្គត់ផ្គង់អ្នកធ្វើការរយៈពេលខ្លី ចំនួនប្រាំធំៗ រួមមាន ប្រទេសឥណ្ឌា ប្រទេសបង់ក្លាដេស ប៉ាគីស្ថាន សហរដ្ឋអាមេរិក និង ប្រទេសហ្វីលីពីន។

ទីផ្សារការងាររយៈពេលខ្លីមានរូបរាងខុសៗគ្នារវាងនៅអឺរ៉ុប និង នៅអាស៊ី។ ការសិក្សាអំពីទីផ្សារការងាររយៈពេលខ្លីនៅក្នុងរដ្ឋសមាជិក EU ចំនួន ១៤ រដ្ឋ បានបង្ហាញដូចតទៅ៖

- ការងាររយៈពេលខ្លី គឺជាមុខរបរសំខាន់ ដែលមានប្រជាជនប្រហែល ២% កំពុងតែបំពេញ

ការងារនេះ។

- វាគឺជាប្រភពប្រាក់ចំណូលដ៏សំខាន់ (ពោលគឺ ប្រហែល ២៥% នៃប្រាក់បៀវត្សរ៍ជាមធ្យម របស់អ្នកធ្វើការពេញម៉ោង) ដែលមានចំនួន ៦%។
- ប្រជាជនប្រហែល ៨% ធ្វើការងាររយៈពេលខ្លីយ៉ាងតិចម្តងក្នុងមួយខែ។ (Dazzi ២០១៩: ៧២)។

ការកើតឡើង និង ភាពញឹកញាប់នៃការងាររយៈពេលខ្លី មានលក្ខណៈខុសៗគ្នា ដែលមានចំនួនច្រើនបំផុតនៅក្នុងចក្រភពអង់គ្លេស និង ចំនួនទាបបំផុតនៅប្រទេសហ្វាំងឡង់ ប្រទេសស្លូវ៉ាគី និង ប្រទេសហុងគ្រី។ នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក របាយការណ៍ឆ្នាំ២០១៨ បង្ហាញថា ៨៤% នៃអ្នកគ្រប់គ្រងការជួលបុគ្គលិក បានជួលអ្នកធ្វើការងារឯករាជ្យឲ្យធ្វើការ (SIA ឆ្នាំ២០១៨)។

ការងាររយៈពេលខ្លីមានសារសំខាន់កាន់តែខ្លាំងឡើងនៅអាស៊ាន។ នៅឆ្នាំ២០១៨ ប្រជាជនឥណ្ឌូនេស៊ីជិត ៧៥ លាននាក់ស្ថិតនៅក្នុងក្រុមអ្នកធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (រួមទាំងអ្នកធ្វើការងារអណ្តែត និង ការងារក្រៅម៉ោងផងដែរ) (Sim និង Xinghui ២០២០)។ របាយការណ៍ស៊ីជម្រៅអំពីអ្នកធ្វើការឯករាជ្យនៅលើសកលលោក របស់ PayPal កាលពីឆ្នាំ២០១៨ ចែងថា យ៉ាងតិច ២% នៃប្រជាជនហ្វីលីពីនគឺជាអ្នកធ្វើការ ឯករាជ្យ (Hasnan ឆ្នាំ២០១៩)។ ពួកគេត្រូវបានរាយការណ៍ថា មានចំនួនស្ទើរតែ ២០% នៃកម្លាំងពលកម្មដែលធ្វើការក្រៅការិយាល័យនៅលើសកលលោក (Diesel ឆ្នាំ២០១៩)។ ប្រជាជនហ្វីលីពីនបានចូលរួមនៅក្នុងការងារអនឡាញ ពីព្រោះពួកគេ "រងសម្ពាធពីបញ្ហាការងារ ដូចជា ភាពមិនផ្លាស់ទីនៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រាក់ឈ្នួលទាប" ហើយពួកគេចូលចិត្តធ្វើការងារដែលមានរយៈពេលខ្លីជាង ពីព្រោះវាផ្តល់ជូនពួកគេនូវភាពស្វយ័ត ភាពងាយបត់បែនមួយផ្នែក និង លទ្ធភាពក្នុងការទទួលបានប្រាក់ចំណូលខ្ពស់ជាង (Soriano និង Panaligan ឆ្នាំ២០១៩)។ ការងាររយៈពេលខ្លីក៏មានប្រជាប្រិយភាពនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសវៀតណាម និង ប្រទេសសិង្ហបុរីផងដែរ។ នៅប្រទេសម៉ាឡេស៊ី ២៦% នៃអ្នកធ្វើការគឺជាអ្នកធ្វើការឯករាជ្យ (Jenkins ឆ្នាំ២០១៩)។ នៅក្នុងប្រទេសវៀតណាម ៥៦,៩% នៃប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ ធ្វើការឲ្យខ្លួនឯង។ នៅប្រទេសសិង្ហបុរី នៅឆ្នាំ២០១៨ ៩,៣% នៃនិវាសនជនដែលមានការងារធ្វើទាំងអស់ គឺជាអ្នកធ្វើការ "ដោយខ្លួនឯង" ដោយ ៨ នាក់ ក្នុងចំណោម ១០ នាក់ ធ្វើការងារនេះជាការងារចម្បងរបស់ពួកគេ (Phua ឆ្នាំ ២០២០)។

បញ្ហាប្រឈមសំខាន់ៗដែលអ្នកធ្វើការនៅក្នុងទីផ្សារការងាររយៈពេលខ្លី រួមមាន ប្រាក់ចំណូល

ទាប ទោះបីជាមិនមែនគ្រប់ការងារទាំងអស់ក៏ដោយ, កង្វះខាតសន្តិសុខការងារ ពីព្រោះការងារអាចត្រូវបានបញ្ឈប់ដោយវេទិកានានាតាមបំណង និង ពុំមានការអភិវឌ្ឍជំនាញ ឬ អាជីពនោះទេ ពីព្រោះគន្លងនៃអាជីព ភាគច្រើន គឺគ្មានអត្ថិភាពនោះទេ (Souter ឆ្នាំ២០១៩)។ ប្រហែលជាបញ្ហាប្រឈមដែលសំខាន់បំផុតគឺ ពួកគេមិនត្រូវបានរួមបញ្ចូលនៅក្នុងប្រព័ន្ធគាំពារសង្គមតាមបែបប្រពៃណីនោះទេ ដូចជា អត្ថប្រយោជន៍នៃភាពគ្មានការងារធ្វើ ការទូទាត់ប្រាក់សម្រាប់ព្យាបាលជំងឺ និង សោធននិវត្តន៍ ជាដើម។

អ្នកធ្វើការនៅក្នុងទីផ្សារការងាររយៈពេលខ្លី នៅអឺរ៉ុប ទទួលបានកិច្ចការពារ និង លក្ខខណ្ឌការងារល្អប្រសើរជាង។ សភាអឺរ៉ុបបានអនុម័តលើវិធានដែលផ្តល់សិទ្ធិថ្មីៗដល់អ្នកធ្វើការតាមកិច្ចសន្យាដែលខុសពីធម្មតា និង ការងារដែលគ្មានបទដ្ឋាន (សភាអឺរ៉ុប ឆ្នាំ២០១៩)។ ទាំងនេះ រួមបញ្ចូល វិធានការការពារអ្នកធ្វើការ តាមរយៈការធានាចំពោះលក្ខខណ្ឌការងារដែលមានតម្លាភាពខ្លាំងជាងមុន និង អាចទស្សន៍ទាយទុកមុនបាន ការបណ្តុះបណ្តាលដែលចាំបាច់ដោយឥតគិតថ្លៃ ការដាក់កម្រិតលើម៉ោងធ្វើការ និង រយៈពេលសាកល្បងការងារ និង ទប់ស្កាត់និយោជកមិនឲ្យរារាំងបុគ្គលិកពីការទទួលការងារផ្សេងទៀតនៅក្រៅម៉ោងធ្វើការនោះទេ។

នៅអាស៊ីអាគ្នេយ៍ "វិធានស្តីពីសុវត្ថិភាពអ្នកធ្វើការ និង បទប្បញ្ញត្តិលើការធ្វើប្រតិបត្តិការ ជាញឹកញាប់ មានការកែប្រែជាបន្តបន្ទាប់ ឬ មានភាពមិនគ្រប់គ្រាន់នោះទេ ដូចនៅក្នុងករណីរបស់ប្រទេសនានា ដូចជា ប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី និង ប្រទេសវៀតណាម ជាដើម" (TechCollective ឆ្នាំ២០១៩)។

បញ្ហាទាំងនេះត្រូវតែបានលើកឡើង និង ដោះស្រាយ ប្រសិនបើយើងមានបំណងទទួលបានសង្គមឌីជីថលដែលមានបរិយាប័ន្ន។ នៅក្នុងការរចនាកិច្ចគាំពារសង្គមសម្រាប់អ្នកធ្វើការរយៈពេលខ្លីនៅអាស៊ី គួរតែមានវិធានការចំពោះចំណុចសំខាន់ៗដូចខាងក្រោម៖

- ភ្ជិតគម្លាតនៃការគ្របដណ្តប់លើប្រជាជន និងភាពសមស្របនៃអត្ថប្រយោជន៍។ ការគ្របដណ្តប់គួរតែត្រូវបានលាតសន្ធឹងទៅកាន់អ្នកធ្វើការងារដែលគ្មានបទដ្ឋាន (NSE) ផងដែរ ជាពិសេស អ្នកធ្វើការឲ្យខ្លួនឯង និង/ឬ អ្នកធ្វើការនៅក្នុងទីផ្សារការងាររយៈពេលខ្លី ដែលជាញឹកញាប់ មិនត្រូវបានគ្របដណ្តប់ដោយគ្រោងការណ៍កិច្ចគាំពារសង្គមនោះទេ
- បង្កើតគោលនយោបាយដែលមាននវានុវត្តន៍ និង ក្របខណ្ឌនិយ័តកម្ម និង ធានាចំពោះអនុលោមភាព។ នវានុវត្តន៍នៃគោលនយោបាយដើម្បីពង្រឹងការគ្របដណ្តប់លើគ្រោងការណ៍កិច្ចគាំពារសង្គមសម្រាប់អ្នកធ្វើការ NSE គឺជាចំណុចសំខាន់សម្រាប់ការរៀបចំប្រព័ន្ធកិច្ច

គាំពារសង្គមសម្រាប់ការងារនាថ្ងៃអនាគត ហើយក្របខណ្ឌនិយ័តកម្មក៏នឹងមានសារសំខាន់ណាស់ដែរ ដែលអាចកែសម្រួលដើម្បីគ្របដណ្តប់លើអ្នកធ្វើការ NSE នៅពេលដែលពួកគេពង្រីកការគ្របដណ្តប់នៃធានារ៉ាប់រង និង អត្ថប្រយោជន៍សង្គម

- រៀបចំយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាព
- បំពាក់បច្ចេកវិទ្យាថ្មីៗ ដើម្បីពង្រឹងការផ្តល់កិច្ចគាំពារសង្គម
- បច្ចេកវិទ្យាថ្មី រួមបញ្ចូលទាំងវេទិកាឌីជីថល និង សេវាចល័តផងដែរ អាចជួយសម្រួលដល់ការផ្តល់កិច្ចគាំពារសង្គម ដល់អ្នកធ្វើការ NSE ដែលស្ថិតនៅក្នុងប្រភេទខុសៗគ្នា ដែលបញ្ហាប្រឈមដ៏សំខាន់របស់ពួកគេគឺ ជាញឹកញាប់ ពួកគេមានការងារខុសៗគ្នាជាច្រើន ប៉ុន្តែម្តងម្កាល ពួកគេក៏គ្មានការងារធ្វើដែរ។ (Handayani ឆ្នាំ២០១៩)

សកម្មភាពជាក់លាក់មួយដែល ASEM អាចអនុវត្តសម្រាប់អ្នកធ្វើការនៅក្នុងទីផ្សារការងាររយៈពេលខ្លីបាននោះគឺ អភិវឌ្ឍក្រមនៃសិទ្ធិនានាដោយស្ម័គ្រចិត្ត (មិនចងកាតព្វកិច្ច) ដែលអនុវត្តចំពោះតំបន់ទាំងពីរ។

## ASEM ស្តីពីប្រាជ្ញាសិប្បនិម្មិតនៅក្នុងអភិបាលកិច្ច

អាស៊ី និង អឺរ៉ុប ក៏គួរតែសហការគ្នានៅក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាជ្ញាសិប្បនិម្មិត (AI) នៅក្នុងអភិបាលកិច្ចផងដែរ។ AI កំពុងតែត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលនានាកាន់តែច្រើន ដើម្បីធ្វើឲ្យការផ្តល់សេវាសាធារណៈ និង ប្រតិបត្តិការផ្ទៃក្នុងរបស់ពួកគេ មានប្រសិទ្ធភាព និង ប្រសិទ្ធផលខ្លាំងជាងមុន ដែលអាចនាំទៅរកបទពិសោធន៍របស់ប្រជាជនដែលល្អប្រសើរឡើង។

នៅក្នុងចំណោមសេវាប្រជាជន ដែល AI អាចពង្រឹងបាន រួមមាន៖

- សុវត្ថិភាពសាធារណៈ៖ រួមបញ្ចូលការ ការប្រើប្រាស់ការវិភាគដើម្បីកំណត់អត្តសញ្ញាណជនល្មើស ការគ្រប់គ្រងតាមបណ្តោះព្រំដែន និង ប្រព័ន្ធប្រឆាំងភេរវកម្មផងដែរ
- សុខភាពសាធារណៈ ៖ ជាពិសេស នៅក្នុងការធ្វើរោគវិនិច្ឆ័យ ការទស្សន៍ទាយអំពីការផ្ទុះរាតត្បាតនៃជំងឺឆ្លង និង ការថែទាំសុខភាពជាក់លាក់
- កិច្ចគាំពារសង្គម ៖ ឧបករណ៍ដាក់ពិន្ទុហានិភ័យតាមការទស្សន៍ទាយទុកមុន ដើម្បីជួយដល់បុគ្គលិកសង្គមកិច្ចនៅក្នុងការកំណត់កុមារដែលប្រឈមនឹងហានិភ័យ និង ដើម្បីដំណើរការ

ការទាមទារនានា

- ចីរភាពបរិស្ថាន ៖ ការវិភាគទិន្នន័យតាមប្រព័ន្ធផ្កាយរណប ដើម្បីព្យាករណ៍អំពីថាមពលដើរដោយពន្លឺព្រះអាទិត្យនៅលើសកលលោក ដើម្បីប្រយុទ្ធប្រឆាំងនឹងការឡើងកម្តៅផែនដី និង
- ការដឹកជញ្ជូន ៖ គ្រប់គ្រងចរាចរណ៍តាមរយៈការអនុវត្តអាល់កូរីមភ្លើងចរាចរណ៍ដែលកាន់តែឆ្លាតវៃ និង ការតាមដានតាមពេលវេលាជាក់ស្តែង ដើម្បីគ្រប់គ្រងរចនាបថនៃការធ្វើចរាចរណ៍កម្រិតខ្ពស់ ឬ ទាប បានយ៉ាងមានប្រសិទ្ធភាព។ ( Sharma, Yadav, and Chopra, 2020 )

AI ក៏អាចពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់រដ្ឋាភិបាលបានផងដែរ។ វាអាចធ្វើឲ្យមានភាពសាមញ្ញ និង ពន្លឿនដំណើរការផ្ទៃក្នុង បង្កើនផលិតភាព និង កាត់បន្ថយបន្ទុកចំណាយនានា និង អនុញ្ញាតឲ្យមានការចាត់ចែងធនធានបានកាន់តែល្អប្រសើរ ( Gov CIO ឆ្នាំ២០១៩ )។ AI ក៏អាចរកឃើញការក្លែងបន្លំនៅក្នុងការទាមទារសំណងពីធានារ៉ាប់រងសុខភាព និង ធ្វើឲ្យការប្រមូល និង ការដំណើរការពន្ធអាករមានភាពល្អប្រសើរឡើងផងដែរ។

វាក៏ធ្វើឲ្យការសម្រេចចិត្តមានភាពល្អប្រសើរឡើង និង ធ្វើឲ្យការសម្រេចចិត្តដោយស្វ័យប្រវត្តិ ពោលគឺដំណើរការនៃការសម្រេចចិត្តដោយប្រើអាល់កូរីត ដោយគ្មានការចូលរួមពីមនុស្សណាម្នាក់ក៏អាចដំណើរការទៅបានផងដែរ ( ICO, n.d. )។

ការរៀនសូត្រពីទិន្នន័យប្រវត្តិសាស្ត្រ និង ការស្វែងរករចនាបថនានានៅក្នុងទិន្នន័យបច្ចុប្បន្ន អាចជួយធ្វើឲ្យការសម្រេចចិត្តមានភាពឆាប់រហ័សជាងមុន និង ល្អប្រសើរជាងមុន នៅក្នុងទ្រង់ទ្រាយធំ។ ការសម្រេចចិត្តដោយស្វ័យប្រវត្តិ មានចាប់ពីការបែងចែកប្រភេទប្រវត្តិរូបសង្ខេបសម្រាប់ពាក្យស្នើសុំការងារ ដើម្បីធ្វើការប៉ាន់ស្មានអំពីហានិភ័យរបស់មនុស្សម្នាក់នៅក្នុងការប្រព្រឹត្តិបទល្មើស រហូតដល់ ការចាត់ចែងសេវាសង្គម។

ប្រសិនបើត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវ AI អាចធ្វើឲ្យអភិបាលកិច្ចមានបរិយាប័ន្នកាន់តែខ្លាំងឡើង។ វាអាចត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ដើម្បីចូលទៅជិតក្រុមដែលគេមិនអើពើ និង ពង្រឹងទំនាក់ទំនងជាមួយពួកគេ។

AI ត្រូវបានអនុវត្តដោយរដ្ឋាភិបាលនានានៅទូទាំងពិភពលោករួចរាល់ហើយ។ សូចនាករការត្រៀមខ្លួនជាស្រេចនៃ AI របស់រដ្ឋាភិបាល នៅឆ្នាំ២០១៩ បានរាយការណ៍ថា រដ្ឋាភិបាលថ្នាក់ជាតិដែលអាចទទួលបានផលប្រយោជន៍ពី AI ខ្លាំងជាងគេបំផុត គឺជារដ្ឋាភិបាលដែលមានសេដ្ឋកិច្ច

រឹងមាំ មានអភិបាលកិច្ចល្អ និង មានវិស័យឯកជនដែលប្រកបដោយនវានុវត្តន៍ (Oxford Insights ឆ្នាំ២០១៩)។ រដ្ឋាភិបាលនៅអាស៊ីចំនួនពីរ (សិង្ហបុរី និង ជប៉ុន) និង រដ្ឋាភិបាលនៅអឺរ៉ុបចំនួនប្រាំមួយ (ចក្រភពអង់គ្លេស អាល្លឺម៉ង់ ហ្វាំងឡង់ ស៊ុយអែត បារាំង និង ដាណឺម៉ា) ស្ថិតនៅក្នុងចំណោមរដ្ឋាភិបាលកំពូលៗទាំង១០នៅក្នុងសន្ទស្សន៍នេះ។ការប្រើប្រាស់AIរបស់រដ្ឋាភិបាលអឺរ៉ុបមានចាប់ពី RiskER (ប្រព័ន្ធស្វ័យប្រវត្តិមួយដែលត្រូវបានប្រើប្រាស់ដើម្បី "ទស្សន៍ទាយ" អំពីហានិភ័យនៃការចូលសម្រាកនៅមន្ទីរពេទ្យ នៅក្នុងតំបន់ Emilia-Romagna តាមរយៈការវិភាគលើអថេរប្រជាសាស្ត្រ និង អថេរសុខភាព ជាង ៥០០) របស់ប្រទេសអ៊ីតាលី រហូតដល់ ដំណើរការដោយស្វ័យប្រវត្តិរបស់ប្រទេសដាណឺម៉ាដើម្បីធ្វើការសម្រេចចិត្តលើប្រាក់ចំណូលរបស់សិស្សសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា (Algorithm Watch ឆ្នាំ២០១៩)។

ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីដែលត្រូវបានប្រើប្រាស់ច្រើនជាងគេបំផុតចំនួនពីរ គឺ AI សម្រាប់ការថែរក្សាសណ្តាប់ធ្នាប់ និង ផ្តល់សេវាសង្គម។

នៅខណៈពេលដែលពុំមានភាពជឿនលឿនដូចតំបន់ណាមួយនោះ អាស៊ីត្រូវបានគេមើលឃើញថា "ទំនងជាទទួលបានជោគជ័យប្រកបដោយភាពជឿជាក់ នៅក្នុងការអនុវត្ត AI នៅលើសកលលោក" ដែល "អាចទទួលបានមុខតំណែងឈានមុខគេនៅក្នុងទសវត្សរ៍ក្រោយ" (MIT Technology Review ឆ្នាំ២០១៨)។

ការគាំទ្រជាសាធារណៈចំពោះការប្រើប្រាស់ AI របស់រដ្ឋាភិបាលនៅអាស៊ី ក៏មានកម្រិតខ្ពស់ដែរ។ យោងតាមការស្ទង់មតិកាលពីឆ្នាំ២០១៨ លើអ្នកប្រើប្រាស់អ៊ីនធឺណិតជាង ១៤.០០០ នាក់ នៅក្នុងប្រទេសជាងម្ភៃបួនប្រទេស នៅទូទាំងពិភពលោក (Consultancy.asia ឆ្នាំ២០១៩)៖

> ប្រជាជាតិនៅអាស៊ី មានការគាំទ្រយ៉ាងខ្លាំងចំពោះការប្រើប្រាស់ AI នៅក្នុងអភិបាលកិច្ច ដោយប្រទេសឥណ្ឌា ប្រទេសចិន និង ប្រទេសឥណ្ឌូនេស៊ី គឺជាប្រទេសចំនួនបីដែលមានប្រជាជនគាំទ្រច្រើនជាងគេបំផុត តាមដោយប្រទេសអារ៉ាប៊ីសាអូឌីត និង UAE។ ប្រជាជននៅក្នុងប្រទេសសិង្ហបុរី ប្រទេសកូរ៉េ ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី និង ហុងកុង មានទស្សនៈវិជ្ជមានប្រហាក់ប្រហែលគ្នា នៅខណៈពេលដែលប្រទេសស្វីស ប្រទេសអេស្តូនី និង ប្រទេសអូទ្រីស ស្ថិតនៅក្នុងចំណោមប្រទេសដែលមានការទទួលយកតិចជាងគេបំផុត។

## តារាងទី២៖ ប្រាជ្ញាសិប្បនិម្មិតនៅក្នុងការថែរក្សាសណ្តាប់ និង ផ្តល់សេវាសង្គម នៅក្នុងប្រទេសដែលត្រូវបានជ្រើសរើស នៅអឺរ៉ុប

| | ការថែរក្សាសណ្តាប់ធ្នាប់ | សេវាសង្គម |
|---|---|---|
| ដាណឺម៉ាក | ប្រាជ្ញាសិប្បនិម្មិត (AI) ត្រូវបានប្រើប្រាស់ដើម្បីកាន់កាប់ និង ធ្វើឲ្យប្រភពទិន្នន័យខុសៗគ្នាអាចស្វែងរកបាន រួមបញ្ចូលទាំងប្រព័ន្ធកាន់កាប់ឯកសារ និង ករណីនានា ប្រព័ន្ធគាំទ្រការស៊ើបអង្កេត និង ប្រព័ន្ធនីតិបច្ចេកវិទ្យា និង ប្រព័ន្ធនីតិបច្ចេកវិទ្យាចល័ត | Gladsaxe គឺជាគំរូនៃការតាមដានសម្រាប់កុមារដែលស្ថិតនៅក្នុងកាលៈទេសៈងាយរងគ្រោះ។ វាប្រើប្រាស់ប្រព័ន្ធដែលផ្អែកលើពិន្ទុដើម្បីតាមដានកុមារដែលមានតម្រូវការពិសេសពីដំណាក់កាលដំបូងបំផុត ដោយមានប៉ារ៉ាម៉ែត្រនានា ដូចជា ជំងឺផ្លូវចិត្ត ភាពគ្មានការងារធ្វើ ការខកខានមិនបានទៅតាមការណាត់ជួបរបស់វេជ្ជបណ្ឌិត ឬ ទន្តបណ្ឌិត និង ការលែងលះជាដើម។ |
| ហ្វាំងឡង់ | | AI ត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យ ការថែទាំសុខភាព និង ការថែទាំសង្គម ដែលត្រូវបានធ្វើអនាមិកភាព របស់ប្រជាជននៃទីក្រុង Espoo និង ទិន្នន័យអតិថិជនអំពីការអប់រំកុមារតូច ដើម្បីត្រួតពិនិត្យគន្លងនៃសេវាកម្មតាមរយៈការចាប់ក្រុមកត្តាហានិភ័យរួមបញ្ចូលគ្នា ដែលអាចនាំឲ្យមានតម្រូវការសេវាកម្មផ្នែកសុខមាលភាពកុមារ ឬ សេវាកម្មផ្នែកចិត្តសាស្ត្រកុមារ និង យុវជន។ |
| ហូឡង់ | Criminaliteits Anticipatie Systeem (ប្រព័ន្ធប្រមើលមើលបទឧក្រិដ្ឋ) ទស្សន៍ទាយអំពីទីកន្លែង និង ពេលវេលាដែលបទឧក្រិដ្ឋនឹងកើតឡើង តាមរយៈការវិភាគទិន្នន័យខុសៗគ្នាជាច្រើន។ ភាពទំនងជាកើតឡើងនឹងបទឧក្រិដ្ឋទាំងនេះត្រូវបានចង្អុលបង្ហាញនៅក្នុងផែនទីកម្តៅ។ | |

| | | |
|---|---|---|
| ចក្រភពអង់គ្លេស | ប្រព័ន្ធសម្គាល់ផ្ទៃមុខមួយត្រូវបានប្រើប្រាស់ដោយនគរបាល ដោយទាញយករូបភាពពីកាមេរ៉ាសុវត្ថិភាព ដើម្បីមើលថាតើរូបភាពទាំងនេះមាននៅលើមូលដ្ឋានទិន្នន័យរបស់បុគ្គលដែលនគរបាលកំពុងតែចាប់អារម្មណ៍ដែរឬទេ។ នៅពេលដែលប្រព័ន្ធរកឃើញការផ្គូរផ្គងណាមួយ នគរបាលអាចឃាត់ខ្លួនបុគ្គលនោះដើម្បីធ្វើការសួរចម្លើយ ធ្វើការស្រាវជ្រាវ ឬ ចាប់ខ្លួន។ | សាលាក្រុងនៅក្នុងប្រទេសអង់គ្លេស បានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធសម្រេចចិត្តដោយស្វ័យប្រវត្តិដើម្បីជួយកំណត់ថាតើមានទឹកប្រាក់ចំនួនប៉ុន្មានដែលត្រូវបានចំណាយលើមនុស្សម្នាក់ៗអាស្រ័យលើតម្រូវការរបស់ពួកគេ។ |
| ស៊ុយអែត | | ចាប់តាំងពីឆ្នាំ២០១៧ មក ទីក្រុង Trelleborg បានធ្វើស្វ័យប្រវត្តិកម្មទៅលើផ្នែកមួយចំនួននៃការសម្រេចចិត្តលើអត្ថប្រយោជន៍សង្គម។ កម្មវិធីថ្មីៗត្រូវបានត្រួតពិនិត្យដោយស្វ័យប្រវត្តិ និងផ្ទៀងផ្ទាត់ទៅវិញទៅមកជាមួយមូលដ្ឋានទិន្នន័យដទៃទៀត ដែលពាក់ព័ន្ធ ( ឧ. ទីភ្នាក់ងារពន្ធដារ និង អង្គភាពផ្តល់ការ គាំទ្រលំនៅដ្ឋាន )។ សេចក្តីសម្រេចត្រូវបានចេញដោយស្វ័យប្រវត្តិ ដោយប្រព័ន្ធនេះ។ |

ប្រភព៖ AlgorithWatch ( ២០១៩ )

ប្រទេសកូរ៉េបានប្រើប្រាស់ AI នៅក្នុងកិច្ចខិតខំប្រឹងប្រែងទប់ទល់នឹងជំងឺកូវីដ-១៩ បានដោយជោគជ័យ ( សារព័ត៌មាន ITU ឆ្នាំ២០២០ )។

AI ត្រូវបានប្រើប្រាស់ដើម្បីអភិវឌ្ឍឧបករណ៍ធ្វើតេស្តមេរោគកូរ៉ូណានៅក្នុងរយៈពេលតិចជាងបីសប្តាហ៍ ( ផ្ទុយពីការអភិវឌ្ឍតាមធម្មតា ដែលត្រូវចំណាយពេលពី ពីរ ទៅ បីខែ )។ វាក៏ត្រូវបានប្រើប្រាស់ដើម្បីពង្រឹងការធ្វើរោគវិនិច្ឆ័យផងដែរ។ AI ក៏ត្រូវបានប្រើប្រាស់នៅក្នុងប្រទេសចិន ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ផងដែរ។ ប្រព័ន្ធ AI ចំនួនមួយ ត្រូវបានប្រើប្រាស់នៅក្នុងមន្ទីរពេទ្យរាប់រយកន្លែងនៅក្នុងប្រទេសចិន ដើម្បីជួយធ្វើរោគវិនិច្ឆ័យរាប់ពាន់ករណី (Wang ឆ្នាំ២០២០ )។

ឧទាហរណ៍មួយគឺ ប្រព័ន្ធ AI របស់ Alibaba សម្រាប់ធ្វើរោគវិនិច្ឆ័យជំងឺកូវីដ-១៩ នៅក្នុង CT ស្កែន លើដើមទ្រូងរបស់អ្នកជំងឺ ដែលមានភាពត្រឹមត្រូវចំនួន ៩៦% នៅក្នុងរយៈពេលតិចជាងមួយនាទី (Greene ឆ្នាំ២០២០)។ Wang (ឆ្នាំ២០២០) បានរាយការណ៍ថា បច្ចេកវិទ្យានេះត្រូវបានប្រើប្រាស់នៅក្នុងមន្ទីរពេទ្យជាង ១៦០ កន្លែងនៅក្នុងប្រទេសចិន ដើម្បីជួយដល់ពួកគេនៅក្នុងការធ្វើរោគវិនិច្ឆ័យ ៣៤០.០០០ ករណី។

គំនិតផ្តួចផ្តើម AI ដែលត្រូវគេសម្លឹងមើលច្រើនជាងគេបំផុតនៅអាស៊ី ប្រហែលជាប្រព័ន្ធឥណទានសង្គម (ថ្នាក់ជាតិ) របស់ប្រទេសចិន។ គោលបំណងចម្បងរបស់គំនិតផ្តួចផ្តើមនេះ គឺដើម្បី "ពិនិត្យតាមដាន និង ប៉ាន់ប្រមាណអំពីទំនុកចិត្តរបស់ក្រុមនីមួយៗ ជាពិសេស នៅពេលដែលវាមានទំនាក់ទំនងនឹងច្បាប់ និង វិធានដទៃទៀតដូចខាងក្រោម" (Koty ឆ្នាំ២០១៩)។ តាមការរំពឹងទុក នឹងមានប្រព័ន្ធឥណទានសង្គមមួយសម្រាប់ប្រជាជន មួយសម្រាប់អាជីវកម្ម និង អង្គការផ្សេងទៀត និង មួយសម្រាប់មន្ត្រីរដ្ឋាភិបាល។ ចំពោះការចាត់ចំណាត់ថ្នាក់ប្រជាជន ប្រព័ន្ធនឹងប្រមូលបូកសរុប និង វិភាគទិន្នន័យពីអ្នកធ្វើការទូទាត់ប្រាក់តាមអនឡាញ និង ពិន្ទុដែលផ្តល់ដោយអ្នកជិតខាង ឬ ប្រទេសនានា។ អាជីវកម្មនឹងត្រូវបានវាយតម្លៃតាមលក្ខណវិនិច្ឆ័យផ្នែកនិយ័តកម្ម និង អនុលោមភាព ដែលរួមបញ្ចូលទាំង ការទូទាត់ពន្ធអាករបានទាន់ពេលវេលា ការកាន់កាប់អាជ្ញាប័ណ្ណដែលត្រូវបានតម្រូវ ការបំពេញតាមបទដ្ឋាននៃគុណភាពផលិតផល និង បំពេញតាមលក្ខខណ្ឌតម្រូវនៃការការពារបរិស្ថានផងដែរ។ មន្ត្រីរដ្ឋាភិបាលក៏នឹងត្រូវវាយតម្លៃ ដោយផ្អែកលើលក្ខណវិនិច្ឆ័យនានាផងដែរ ដូចជា កម្រិតដែលពួកគេអនុវត្តតាមបទបញ្ជារបស់រដ្ឋាភិបាលកណ្តាល ជាដើម។

ការប្រើប្រាស់ AI ដោយរដ្ឋាភិបាល មិនមែនគ្មានបញ្ហានោះទេ។ អ្នកប្រាជ្ញផ្តល់ទឡ្ហីករណ៍ថា អាល់កូរីតត្រូវបានកំណត់ទ្រង់ទ្រាយដោយផលប្រយោជន៍ អំណាច និង ភាពធន់ (Katzenbach និង Ulbricht ឆ្នាំ២០១៩)។ AI ពុំមានភាពអព្យាក្រឹត្យនោះទេ ពោលគឺវារួមចំណែកដល់ការរៀបចំឡើងវិញ និង ការកែប្រែអន្តរកម្មសង្គម និង រចនាសម្ព័ន្ធសង្គម។

បញ្ហាសំខាន់ៗចំនួនពីរនៅក្នុងការប្រើប្រាស់AIនៅក្នុងរដ្ឋាភិបាលគឺភាពលម្អៀងរបស់អាល់កូរីត និង អវត្តមាននៃក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌច្បាប់ (Snow ឆ្នាំ២០១៩)។

ភាពលម្អៀងរបស់អាល់កូរីតអាចបំផ្លាញការប្រើប្រាស់ AI នៅក្នុងអភិបាលកិច្ចល្អ។ អាល់កូរីតគឺជា "បណ្តុំសេចក្តីណែនាំអំពីវិធីដែលកុំព្យូទ័រគួរតែបញ្ចប់កិច្ចការជាក់លាក់ណាមួយ" (Caplan et al. ឆ្នាំ២០១៩)។ គុណសម្បត្តិនៃការពឹងផ្អែកលើអាល់កូរីតសម្រាប់ដោះស្រាយបញ្ហា និង ធ្វើការ

សម្រេចចិត្ត គឺថា ពួកគេ "អាចដំណើរការធាតុចូល និង អថេរក្នុងចំនួនច្រើនខ្លាំង ដើម្បីធ្វើការសម្រេចចិត្ត និង អាចធ្វើបែបនេះបាននៅក្នុងល្បឿន និង ភាពជឿជាក់ដែលលើសពីសមត្ថភាពរបស់មនុស្សយ៉ាងខ្លាំង" (Kirkpatrick ឆ្នាំ២០១៦)។

ភាពលម្អៀងរបស់អាល់កូរីតកើតឡើងនៅពេលដែលមានការរួមបញ្ចូលការរើសអើង និង ការប្រកាន់បក្សពួករបស់មនុស្ស នៅក្នុងការរចនា។ ជាលទ្ធផល ការរើសអើងត្រូវបានបង្កប់នៅក្នុងគំរូនោះ។ ដូចបានកត់សម្គាល់ដោយ Knight (ឆ្នាំ២០១៧)៖

"ប្រសិនបើភាពលម្អៀងលួចចូលទៅខាងក្នុងអាល់កូរីត... ដោយគ្មានការទទួលស្គាល់ និង គ្មានការត្រួតពិនិត្យនោះ វាអាចមានលទ្ធផលអវិជ្ជមានយ៉ាងខ្លាំងក្លា ជាពិសេស ចំពោះសហគមន៍ជនក្រីក្រ និង ជនជាតិភាគតិច"។

ភាពលម្អៀងរបស់អាល់កូរីតអាចនាំឲ្យមានក្តីអន្តរាយពីរប្រភេទ ក្តីអន្តរាយនៃការចាត់ចែង និង ក្តីអន្តរាយនៃការតំណាង។ ក្តីអន្តរាយនៃការចាត់ចែង កើតឡើងនៅពេលដែលអាល់កូរីតធ្វើការបែងចែក ឬ កាត់ទុកឱកាស ឬ ធនធានមួយចំនួន ដោយផ្អែកលើការសន្មតដែលមានការរើសអើង។ ឧទាហរណ៍មួយគឺ អាល់កូរីតនៃការប៉ាន់ប្រមាណអំពីហានិភ័យនៃកម្ចីធនាគារ ដែលបដិសេធជាប្រព័ន្ធ លើពាក្យសុំកម្ចីរបស់ស្ត្រី។ ក្តីអន្តរាយនៃភាពជាតំណាង អាច "កើតឡើងនៅពេលដែលប្រព័ន្ធពង្រឹងការស្ថិតនៅក្រោមក្រុមមួយចំនួន នៅតាមបណ្តោយខ្សែបន្ទាត់អត្តសញ្ញាណ" (Machines Gone Wrong, n.d.)។ នៅក្នុងករណីនេះ បច្ចេកវិទ្យាជួយពង្រឹងផ្នត់គំនិត។

ដំណោះស្រាយចំពោះភាពលម្អៀងរបស់អាល់កូរីត គឺគណនេយ្យភាពរបស់អាល់កូរីត "ដំណើរការនៃការកំណត់ទំនួលខុសត្រូវលើក្តីអន្តរាយ នៅពេលដែលការសម្រេចចិត្តរបស់អាល់កូរីតបណ្តាលឲ្យមានលទ្ធផលដែលមានការរើសអើង និង វិសមភាព" (Caplan et al. ២០១៩: ៤)។ គណនេយ្យភាពរបស់អាល់កូរីត មានបីកម្រិត៖

- តម្លាភាព ពាក់ព័ន្ធនឹងទិន្នន័យ និង អាល់កូរីត
- តម្លាភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅកន្លែងដែលអ្នកត្រួតពិនិត្យឯករាជ្យធ្វើការវាយតម្លៃអំពីអាល់កូរីត
- ទំនួលខុសត្រូវផ្នែកសីលធម៌ និង សង្គម ចំពោះផលប៉ះពាល់ដែលមានការរើសអើងរបស់អាល់កូរីត។ (Dickey ឆ្នាំ២០១៧)

កង្វល់ពាក់ព័ន្ធនឹងភាពលម្អៀងរបស់អាល់កូរីត និង គណនេយ្យភាពរបស់អាល់កូរីត បានធ្វើឲ្យមានគំនិតផ្តួចផ្តើមមួយ ហៅថា "សុក្រឹតភាព គណនេយ្យភាព និង តម្លាភាពនៅក្នុងការរៀនសូត្ររបស់ម៉ាស៊ីន"។ កាលពីឆ្នាំ២០១៦ មានអ្នកវិទ្យាសាស្ត្រកុំព្យូទ័រ អ្នកអភិវឌ្ឍ និង អ្នកស្រាវជ្រាវមួយក្រុម បានបញ្ចេញគោលការណ៍ណែនាំចំនួនប្រាំ សម្រាប់អាល់កូរីតដែលមានគណនេយ្យភាព (មូលនិធិ World Wide Web ឆ្នាំ២០១៧)។ គោលការណ៍ទាំងនេះមានបំណងជួយអ្នកអភិវឌ្ឍនៅក្នុងការអភិវឌ្ឍ និង អនុវត្តប្រព័ន្ធអាល់កូរីត តាមវិធីដែលមានគណនេយ្យភាពជាសាធារណៈ។ គោលការណ៍ទាំងប្រាំនោះ រួមមាន៖

- សុក្រឹតភាព៖ ធានាថា ការសម្រេចចិត្តរបស់អាល់កូរីត មិនបានបង្កើតផលប៉ះពាល់ដែលមានការរើសអើង ឬ អយុត្តិធម៌នោះទេ នៅពេលប្រៀបធៀបជាមួយប្រជាសាស្ត្រខុសៗគ្នា
- ភាពអាចពន្យល់បាន៖ ធានាថា ការសម្រេចចិត្តរបស់អាល់កូរីត ព្រមទាំង ទិន្នន័យណាមួយដែលនាំឲ្យមានការសម្រេចចិត្តទាំងនោះ អាចពន្យល់ទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ និងភាគីពាក់ព័ន្ធដទៃទៀត ដោយមិនប្រើពាក្យបច្ចេកទេសបាន
- ភាពអាចធ្វើសវនកម្មបាន៖ អនុញ្ញាតឲ្យតតិយជនដែលមានចំណាប់អារម្មណ៍ ធ្វើការដេញដោល ស្វែងយល់ និង ត្រួតពិនិត្យឡើងវិញលើអាកប្បកិរិយារបស់អាល់កូរីតនោះ តាមរយៈការលាតត្រដាងព័ត៌មាន ដែលអនុញ្ញាតឲ្យមានការពិនិត្យតាមដាន ការផ្ទៀងផ្ទាត់ ឬ ការរិះគន់ រួមបញ្ចូលទាំង តាមរយៈការផ្តល់ឯកសារលម្អិត អ៊ីនធីហ្វេសនៃ ដំណើរការកម្មវិធីដែលមានលក្ខណៈសមស្របតាមផ្នែកបច្ចេកទេស និង លក្ខខណ្ឌប្រើប្រាស់ដែលផ្តល់ការអនុញ្ញាតផងដែរ
- ទំនួលខុសត្រូវ៖ មានវិធីកែតម្រូវដែលអាចមើលឃើញពីខាងក្រៅ ចំពោះផលប៉ះពាល់អវិជ្ជមាននៃប្រព័ន្ធសម្រេចចិត្តរបស់អាល់កូរីត លើបុគ្គល ឬ សង្គម និង កំណត់តួនាទីផ្ទៃក្នុងមួយសម្រាប់អ្នកទទួលខុសត្រូវធ្វើការដោះស្រាយបញ្ហាទាំងនោះបានយ៉ាងទាន់ពេលវេលា
- ភាពត្រឹមត្រូវ៖ សម្គាល់ កត់ត្រា និង បកស្រាយប្រភពនានានៃកំហុស និង ភាពមិនច្បាស់លាស់ នៅក្នុងអាល់កូរីតទាំងមូល និង ប្រភពទិន្នន័យរបស់វា ធ្វើដូច្នេះ ការបញ្ជាក់អំពីអត្ថន័យរំពឹងទុក និង ការបញ្ជាក់អត្ថន័យអំពីករណីដែលអាក្រក់បំផុត អាចត្រូវបានគេស្វែងយល់ និង ជូនដំណឹងអំពីនីតិវិធីសម្រាប់កាត់បន្ថយ។ (មូលនិធិ World Wide Web Foundation ២០១៧: ១១)

សហភាពអឺរ៉ុបកំពុងតែអភិវឌ្ឍវិធាន និង បទប្បញ្ញត្តិថ្មីៗ ស្តីពី AI (Walch ឆ្នាំ២០២០)។ ឧទាហរណ៍៖ របាយការណ៍ស្តីពីប្រាជ្ញាសិប្បនិម្មិត នៃគណៈកម្មការអឺរ៉ុប ស្នើដូចខាងក្រោម៖

- អនុវត្តអភិក្រមដូចគ្នា ចំពោះ AI នៅទូទាំង EU ដើម្បីជៀសវាងការញែកចេញពីគ្នានូវលក្ខខណ្ឌតម្រូវរបស់រដ្ឋសមាជិក ដែលបង្កើតឧបសគ្គចំពោះទីផ្សារតែមួយ
- អនុវត្តអភិក្រមដែលផ្អែកលើហានិភ័យ មានភាពជាក់លាក់តាមវិស័យ ដើម្បីធ្វើនិយ័តកម្ម AI
- សម្គាល់វិស័យ និង កម្មវិធីដែលមានហានិភ័យខ្ពស់ ទុកជាមុន រួមបញ្ចូលទាំងសូហ្វវែរសម្គាល់ផ្ទៃមុខផងដែរ
- ដាក់ចេញនូវលក្ខខណ្ឌតម្រូវផ្អែកនិយ័តកម្មថ្មីៗ និង ការប៉ាន់ប្រមាណជាមុន ដើម្បីធានាថាប្រព័ន្ធ AI ដែលមានហានិភ័យខ្ពស់ អនុលោមតាមលក្ខខណ្ឌតម្រូវផ្អែកសុវត្ថិភាព សុក្រឹតភាព និង ការការពារទិន្នន័យ មុនពេលដែលប្រព័ន្ធនោះត្រូវបានបញ្ចេញទៅលើទីផ្សារ
- ប្រើប្រាស់ការចូលទៅកាន់ទីផ្សារដ៏ធំសម្បើមរបស់អឺរ៉ុបជាឧបករណ៍ដើម្បីលាតសន្ធឹងអភិក្រមរបស់ EU ចំពោះការធ្វើនិយ័តកម្ម AI ទៅទូទាំងពិភពលោក។ (MacCarthy និង Propp ឆ្នាំ២០២០)។

នៅថ្នាក់ជាតិ ប្រទេសបារាំងមានច្បាប់ដែលដោះស្រាយជាមួយតម្លាភាពនៃអាល់កូរីត និង ការសម្រេចចិត្តដោយស្វ័យប្រវត្តិ (AlgorithmWatch ២០១៩: ៦៨–៦៩)។ The Conseil d'Etat តុលាការកំពូលនៃប្រទេសបារាំងចំពោះបញ្ហារដ្ឋបាល កាលពីខែមិថុនា ឆ្នាំ២០១៨ "បានចេញដីកាសម្រេចថា ការសម្រេចចិត្តណាមួយដែលផ្អែកតែលើប្រព័ន្ធឡូការីត តែមួយមុខ អាចមានភាពស្របច្បាប់បានលុះត្រាតែអាល់កូរីតនោះ និង ការដំណើរការផ្ទៃកខាងក្នុងរបស់វា អាចពន្យល់ទៅកាន់អ្នកដែលទទួលរងផលជះពីការសម្រេចចិត្តនោះបានទាំងស្រុង" (Algorithm Watch ២០១៩: ៦៩)។

ASEM អាចធ្វើការដើម្បីឆ្ពោះទៅកាន់ អភិបាលកិច្ច AI ដែលមានសុខដុមនីយកម្ម និង ក្របខណ្ឌច្បាប់សម្រាប់អាស៊ី និង អឺរ៉ុបបាន។ ចំណុចនេះអាចរួមបញ្ចូលដូចខាងក្រោម៖

- បង្កើនអក្ខរភាពនៃឡូការីត ដើម្បីបង្កើតសមត្ថភាពរបស់ប្រជាជន អង្គការ និង មន្ត្រីរដ្ឋាភិបាល នៅក្នុងការស្វែងយល់ថាតើប្រព័ន្ធ AI ដំណើរការដោយរបៀបណា ធ្វើដូច្នេះ ពួកគេអាចទាមទារគណនេយ្យភាព AI បាន

- បង្កើតយន្តការ និង ដំណើរការដើម្បីរួមបញ្ចូលភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការបង្កើត និង ការអនុវត្តវិធាននានាដែលពាក់ព័ន្ធការប្រើប្រាស់ AI នៅក្នុងវិស័យសាធារណៈ
- ធ្វើការវិវឌ្ឍន៍ក្របខណ្ឌមួយ ដែលសិទ្ធិ និង ការការពារតាមផ្លូវច្បាប់របស់ប្រជាជន អាជីវកម្ម និង ភាគីពាក់ព័ន្ធដទៃទៀត ត្រូវបានលើកកម្ពស់។ (សេវាកម្មស្រាវជ្រាវរបស់សភាអឺរ៉ុប ២០១៩: ៦៩–៧៥)

## ASEM ចំពោះការការពារទិន្នន័យ និង ឯកជនភាព

ជំងឺរាតត្បាតសកលធ្វើឲ្យមានការចាប់ផ្តើមជជែកវែកញែកឡើងវិញអំពីការការពារទិន្នន័យ និង ឯកជនភាព។

មនុស្សមួយចំនួនណែនាំថា ភាពជោគជ័យរបស់ប្រទេសនៅអាស៊ីមួយចំនួននៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីគ្រប់គ្រងការរាតត្បាតនៃមេរោគកូរ៉ូណា បានបញ្ចុះបញ្ចូលប្រទេសជាច្រើនទៀតថា "ឯកជនភាពនៃទិន្នន័យតិចជាងមុន មិនលើសពីមុន អាចជាជម្រើសល្អបំផុតចំពោះវិស័យសុខភាពសាធារណៈ" (Meyer ឆ្នាំ២០២០)។

ការយល់ឃើញផ្សេងទៀតត្រូវបានលើកឧទាហរណ៍ដោយ សេចក្តីថ្លែងការណ៍រួមគ្នារបស់ប្រធានគណៈកម្មាធិការអនុសញ្ញា ១០៨ និង ស្នងការការពារទិន្នន័យនៃក្រុមប្រឹក្សាអឺរ៉ុប៖ "រដ្ឋត្រូវតែដោះស្រាយការគំរាមកំហែងដែលបណ្តាលមកពីជំងឺរាតត្បាតសកល កូវីដ-១៩ ពាក់ព័ន្ធនឹងប្រជាធិបតេយ្យ នីតិរដ្ឋ និង សិទ្ធិមនុស្ស រួមបញ្ចូលទាំងសិទ្ធិឯកជនភាព និង ការការពារទិន្នន័យផងដែរ" (Pierucci និង Walters ឆ្នាំ២០២០)។ គណៈកម្មការឯកជនភាពថ្នាក់ជាតិរបស់ប្រទេសហ្វីលីពីនបានចេញសេចក្តីសម្រេចដែលមានលក្ខណៈដូចគ្នា៖ "ទោះបីជានៅពេលមានទុក្ខភ័យ ឬ គ្រាអាសន្ននៃសុខភាពសាធារណៈក៏ដោយ ក៏ឯកជនភាពរបស់អ្នកជំងឺ ការរក្សាការសម្ងាត់នៃកំណត់ត្រាសុខភាព សីលធម៌ផ្នែកវេជ្ជសាស្ត្រ និង សិទ្ធិរបស់កម្មវត្ថុនៃទិន្នន័យ នៅតែមានប្រសិទ្ធភាពអនុវត្ត និង នៅជាប់ខ្លួនពួកគេ ស្មើនឹងការការពារជីវិតដែរ" (គណៈកម្មការឯកជនភាពជាតិ ឆ្នាំ២០២០)។

មានភាពភ័យខ្លាចថា បច្ចេកវិទ្យាដែលបំផ្លាញឯកជនភាព ដែលកំពុងតែត្រូវបានប្រើប្រាស់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគ អាចនៅឋិតថេរជាងមេរោគនោះ។ ដូចបានកត់សម្គាល់ដោយ Harrari (ឆ្នាំ២០២០)៖

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងមិនមានការប្រុងប្រយ័ត្នទេ ជំងឺរាតត្បាតអាចក្លាយជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រនៃការឃ្លាំមើល។ ពីព្រោះវាមិនត្រឹមតែអាចធ្វើឲ្យការប្រើប្រាស់ឧបករណ៍តាមដានខ្នាតធំ ក្លាយជារឿងធម្មតា នៅក្នុងប្រទេសដែលកន្លងមកបានបដិសេធការប្រើប្រាស់ឧបករណ៍ទាំងនោះតែប៉ុណ្ណោះទេ ប៉ុន្តែវាអាចលើសពីរឿងធម្មតាទៅទៀត ពីព្រោះវាជាសញ្ញានៃការផ្លាស់ប្តូរពីការឃ្លាំមើល "នៅខាងលើស្បែក" ទៅកាន់ ការឃ្លាំមើល "នៅខាងក្រោមស្បែក"។

Harrari កំពុងតែសំដៅលើការឃ្លាំមើលតាមរយៈគន្លងទិន្នន័យ ពោលគឺការពិនិត្យតាមដានតាមរយៈព័ត៌មានដែលត្រូវបានបង្កើតឡើងដោយអ្នកប្រើប្រាស់ នៅពេលដែលពួកគេប្រើប្រាស់ ICT។ នៅកន្លែងដែលកាលពីមុន ការឃ្លាំមើលមានន័យថា "ការសង្កេតយ៉ាងដិតដល់អំពីជនសង្ស័យ" បច្ចេកវិទ្យានាពេលបច្ចុប្បន្នបានអនុញ្ញាតឲ្យមានការឃ្លាំមើលលើ "បរិបទនានា ( ទីតាំងភូមិសាស្ត្រ លំហ ពេលវេលាជាក់លាក់ បណ្តាញ ប្រព័ន្ធ និង ប្រភេទមនុស្ស )" ( Marx ២០០២: ១០ )។ ឯកជនភាព "មានទំនាក់ទំនងយ៉ាងខ្លាំងក្លានឹងសម្ភារ និង បច្ចេកវិទ្យាសង្គមនៅក្នុងមជ្ឈដ្ឋានរបស់វា" ( Matzner និង Ochs ឆ្នាំ២០១៩ )។ ច្បាប់ស្តីពីឯកជនភាពលើទិន្នន័យ ( សិទ្ធិរបស់បុគ្គលក្នុងការគ្រប់គ្រងមួយផ្នែកលើវិធីប្រមូល និង ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់គាត់/នាង ) និង ការការពារទិន្នន័យ ( យន្តការក្នុងការទប់ស្កាត់ការប្រើប្រាស់ និង ការទទួលបានទិន្នន័យផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាត ) ដែលបានលេចឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បណ្តាលមកពីកំណើននៃការប្រើប្រាស់កុំព្យូទ័រ ( Solove ឆ្នាំ២០០៦ )។

ដូច្នេះ យើងគ្រាន់តែរំពឹងទុកថា ការប្រើប្រាស់បច្ចេកឌីជីថលយ៉ាងទូលំទូលាយ នៅក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល នឹងអាចធ្វើឲ្យមានកង្វល់លើការការពារទិន្នន័យ និង ឯកជនភាព។

អ៊ីនធឺណិតបានក្លាយជាខ្សែជីវិតដ៏សំខាន់មួយ ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល។ វាបានធ្វើឲ្យមនុស្សកាន់តែច្រើនអាចធ្វើការពីផ្ទះបាន។ ទោះបីជាយ៉ាងណាក៏ដោយ ការចាត់ចែងការងារថ្មីនេះ ក៏បានបង្កើនលទ្ធភាពនៃ "ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតខ្លាំងជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រផងដែរ ( ការសង្កត់ធ្ងន់លើច្បាប់ដើម )" ( McBridev ឆ្នាំ២០២០ )។ គេក៏បានសង្កេតផងដែរថា ជំងឺរាតត្បាតសកលកំពុងតែធ្វើឲ្យអ្នកប្រើប្រាស់លិចចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមកាន់តែជ្រៅ ( Fischer ឆ្នាំ២០២០ )។ នេះមានន័យថា ព័ត៌មានអំពីអ្នកប្រើប្រាស់កាន់តែច្រើន ត្រូវបានបង្កើតឡើង និង ត្រូវបានទាញយកដោយក្រុមហ៊ុនរបស់បណ្តាញផ្សព្វផ្សាយសង្គម។

រដ្ឋាភិបាលកំពុងតែប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលកាត់បន្ថយឯកជនភាព នៅក្នុងការប្រយុទ្ធ

ប្រឆាំងនឹងមេរោគកូរ៉ូណា។ នៅប្រទេសចិន ទីក្រុង និង ខេត្តខុសៗគ្នាជាច្រើនបានប្រើប្រាស់កូដ QR ដែលមានពណ៌ ដែលត្រូវបានដោនឡូតនៅលើទូរស័ព្ទចល័តដើម្បីតាមដានការផ្លាស់ទីរបស់ប្រជាជន និង កំណត់ស្ថានភាពសុខភាពរបស់ពួកគេ (AFP–JIJI ឆ្នាំ២០២០)។ ឧទាហរណ៍៖ ពណ៌ក្រហម ពណ៌លឿង និង ពណ៌បៃតង កំណត់ថាតើមនុស្សម្នាក់អាចចូលក្នុងភោជនីយដ្ឋាន ឬ ឡើងជិះរថភ្លើងបានដែរឬទេ។ ប្រទេសរុស្ស៊ីប្រើប្រាស់កាមេរ៉ាសុវត្ថិភាពដែលមានបច្ចេកវិទ្យាសម្គាល់ផ្ទៃមុខ ដើម្បីអនុវត្តភាពរឹតត្បិតលើការធ្វើចត្តាឡីស័ក្តិ (Reevell ឆ្នាំ២០២០)។ គេបានរាយការណ៍ថា ប្រព័ន្ធអាចបញ្ចប់ការស្វែងរកនៅក្នុងរយៈពេលក្រោម ១០ វិនាទី និង អាចកំណត់អត្តសញ្ញាណអ្នកដែលកំពុងតែពាក់ម៉ាសបាន (តាមរយៈក្រសៃភ្នែករបស់ពួកគេ)។ រដ្ឋាភិបាលនៃប្រទេសកូរ៉េមានប្រព័ន្ធមួយដែលតាមដានការផ្លាស់ទីរបស់បុគ្គលម្នាក់ តាមរយៈចម្លងការនៃប័ណ្ណឥណទាន ទិន្នន័យទីតាំងនៅលើទូរស័ព្ទឆ្លាតវៃ និង វីឌីអូនៃកាមេរ៉ាសុវត្ថិភាព (Louis ឆ្នាំ២០២០)។ អាជ្ញាធរសុខាភិបាលនៃប្រទេសកូរ៉េចេញសេចក្តីជូនដំណឹងឲ្យប្រុងប្រយ័ត្នជាមុន នៅពេលមនុស្សម្នាក់ធ្វើតេស្តវិជ្ជមាន។ សេចក្តីជូនដំណឹងនេះរួមបញ្ចូលប្រវត្តិលម្អិតនៃការផ្លាស់ទីរបស់អ្នកដែលបានឆ្លងមេរោគនោះ ហើយសមាជិកសហគមន៍អាចប្រើប្រាស់សេចក្តីជូនដំណឹងនេះដើម្បីកំណត់ថាតើពួកគេបានប៉ះពាល់ជាមួយបុគ្គលនោះដែរឬទេ។ នៅខណៈពេលដែលឈ្មោះរបស់ជនដែលបានឆ្លងមេរោគ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេនោះ ព័ត៌មានដែលត្រូវបានបញ្ចេញ មានភាពជាក់លាក់គ្រប់គ្រាន់ ដែលនៅក្នុងករណីមួយចំនួន វាមានភាពងាយស្រួលនៅក្នុងកំណត់អត្តសញ្ញាណជនដែលបានឆ្លងមេរោគនោះ ដូច្នេះ កាលពីខែមីនា BBC បានរាយការណ៍ថា នៅក្នុងប្រទេសកូរ៉េ "មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះការមាក់ងាយនៅក្នុងសង្គម (អមជាមួយការធ្វើតេស្តវិជ្ជមាន) គិតចាប់ពីពេលមានជំងឺ" (Kim ២០២០)។

ប្រាកដណាស់ មិនមែនគ្រប់ប្រព័ន្ធតាមដានឌីជីថលទាំងអស់សុទ្ធតែកាត់បន្ថយឯកជនភាពនោះទេ។ កម្មវិធីតាមដានព័ត៌មានទំនាក់ទំនង Trace-Together របស់ប្រទេសសិង្ហបុរី គឺជាឧទាហរណ៍មួយនៃកម្មវិធីតាមដានព័ត៌មានទំនាក់ទំនងដែលការពារឯកជនភាព (HealthHub, n.d.)។ វាដំណើរការតាមរយៈការផ្លាស់ប្តូរសញ្ញាប៊្លូធូសនៅក្នុងចំណោមទូរស័ព្ទចល័តនានាដែលនៅក្បែរគ្នា។ កំណត់ត្រានៃការជួបប្រទះទាំងនេះ ត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទរបស់អ្នកប្រើប្រាស់ និង មិនត្រូវបានបញ្ជូនទៅកាន់អាជ្ញាធររដ្ឋាភិបាលនោះទេ។ ការតាមដានការនៅក្បែរគ្នាដែលការពារឯកជនភាពរបស់ប្រទេសនានានៅអឺរ៉ុប (PEPP-PT) តាមឈ្មោះរបស់វា ត្រូវបានបង្កើតឡើងដោយអ្នកវិទ្យាសាស្ត្រនៅអឺរ៉ុបដើម្បីតាមដានការរីករាលដាលនៃជំងឺកូវីដ-១៩ដោយមិនកាត់បន្ថយឯកជនភាពនោះទេ (ERCIM ២០២០)។ PEPP-PT អនុលោមតាមបទប្បញ្ញត្តិស្តីពីការការពារ

ទិន្នន័យទូទៅ (GDPR) របស់ EU និងភាពអាចធ្វើប្រតិបត្តិការនៅក្នុង EU ទៅវិញទៅមកបាន។ គំនិតផ្តួចផ្តើមរបស់អឺរ៉ុបមួយទៀត គឺការតាមដានការនៅក្បែរគ្នាដែលការពារឯកជនភាពតាមបែបវិមជ្ឈការ មានបំណង "ផ្តល់សន្តិសុខ និង ឯកជនភាពជាអតិបរមា សម្រាប់អ្នកប្រើប្រាស់ចុងក្រោយ" (Ruef, 2020)។

ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល ទូរស័ព្ទចល័តត្រូវបានប្រើប្រាស់ជា "រនាំងអេឡិចត្រូនិច" ដើម្បីការពារអ្នកបំពានចត្តាឡីស័ក្តិ។ ក្រុមហ៊ុនអាចប្រើប្រាស់សូហ្វវែរដើម្បីពិនិត្យតាមដាននិយោជិតដែលធ្វើការពីផ្ទះ ហើយសិស្សត្រូវបានឃ្លាំមើលតាមរយៈកម្មវិធីពិនិត្យតាមដានការប្រឡង។ Mark Surman នាយកប្រតិបត្តិនៃក្រុមហ៊ុន Mozilla បានសង្កេតឃើញថា៖

> ប្រជាជនកំពុងតែមានដំណោះស្រាយដែលមានការឆ្លៀតឱកាស និង គ្មាននិយ័តកម្ម (ដែល)... មិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាលនោះទេ។ ប្រសិនបើមានទីផ្សារសម្រាប់ដំណោះស្រាយទាំងនោះ ចុងបញ្ចប់ អាចនឹងមានការកើនឡើងជាបន្តបន្ទាប់នៃការឃ្លាំមើលនៅកម្រិតទាប ដែលយើងចាំបាច់ត្រូវតែរកវិធីដើម្បីបិទ និង ចងវា។ (Ng, 2020)

សូម្បីតែអ្នកដែលមានការព្រួយបារម្ភអំពីការគំរាមកំហែងផ្នែកឯកជនភាពនៃការឃ្លាំមើលផ្នែកឌីជីថល ក្នុងអំឡុងគ្រាអាសន្ន ក៏មិនបានណែនាំថា រដ្ឋាភិបាលមិនគួរប្រើប្រាស់ការឃ្លាំមើលទាំងនេះដែរ។ ពួកគេទទួលស្គាល់ថា គោលនយោបាយសាធារណៈនៅក្នុងគ្រាអាសន្ននៃសុខភាព គួរតែធ្វើឲ្យមានតុល្យភាពរវាងកង្វល់ផ្នែកសុខភាព ឯកជនភាព និង សេដ្ឋកិច្ច។

ពួកគេណែនាំថា ដើម្បីទទួលបានតុល្យភាពដែលត្រឹមត្រូវ អ្នកធ្វើការសម្រេចចិត្តគួរតែពិចារណាអំពីចំណុចនានាដូចខាងក្រោម៖

- វិធានការឃ្លាំមើលត្រូវតែមានសមាមាត្រត្រឹមត្រូវ មានតម្លាភាពយ៉ាងពេញលេញ និង អាចត្រឡប់ក្រោយវិញបាន
- ប្រសិទ្ធភាពគួរតែមិនមែនជាការពិចារណាតែមួយគត់នៅពេលប្រើប្រាស់ប្រព័ន្ធឃ្លាំមើលនោះទេ
- បច្ចេកវិទ្យាឃ្លាំមើលដែលអនុញ្ញាតឲ្យមានការត្រួតពិនិត្យផ្នែកសង្គមនៅកម្រិតខ្ពស់ ប្រហែលជាត្រូវបានអនុវត្តដោយមិនស្មើភាព ដោយមានការរើសអើង និង ក្នុងគោលបំណងដែលទាក់ទងនឹងការទប់ទល់នឹងមេរោគយ៉ាងពេញលេញនោះទេ។ (Ghosh, Abecassis, Loveridge ឆ្នាំ២០២០)

សកម្មភាពដែលត្រូវបានណែនាំមួយទៀត គឺឲ្យប្រទេសនានាបង្កើតក្របខណ្ឌច្បាប់សម្រាប់សិទ្ធិឌីជីថល នៅក្នុងការទប់ស្កាត់ការបំផ្លាញឯកជនភាពនៅពេលមានជំងឺរាតត្បាតសកល។ អ្នកគាំទ្រជឿជាក់ថា ការបង្កើតច្បាប់សម្រាប់សិទ្ធិឌីជីថល មានសារសំខាន់នៅក្នុងការធានាថា ការរំលោភបំពានលើឯកជនភាពនៅក្នុងគ្រាអាសន្ន ត្រូវបានកាត់បន្ថយជាអប្បបរមា ហើយនឹងអាចត្រឡប់ក្រោយវិញបាន។

នៅពេលខាងមុខ សិទ្ធិឌីជីថលដែលបានសរសេរកូដរួចហើយ គួរតែក្លាយជាទ្រង់ទ្រាយមួយនៅក្រោយពេលមានជំងឺរាតត្បាតសកល នៃសង្គមឌីជីថលដែលមានបរិយាប័ន្ន នៅអាស៊ី និងអឺរ៉ុប។ នៅក្នុងពិភពលោកក្រោយមានជំងឺរាតត្បាតសកល ការគាំទ្រផ្នែកមូលធននិយមលើការឃ្លាំមើល ពោលគឺការធ្វើអាជីវកម្មទិន្នន័យផ្ទាល់ខ្លួនដើម្បីប្រាក់ចំណេញ នឹងមិនបន្ថយល្បឿននោះទេ។ ជាក់ស្តែង កំណើននៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងទីផ្សារអេឡិចត្រូនិក ដែលត្រូវបានរំពឹងទុក នឹងបង្កើតទិន្នន័យកាន់តែច្រើន ដូចជាទិន្នន័យដែលលាតត្រដាងអំពីអ្នកប្រើប្រាស់វេទិកាទាំងនេះកាន់តែច្រើន និង ដែលត្រូវបានទាញយក និង ដំណើរការដោយម្ចាស់វេទិកាដើម្បីប្រាក់ចំណេញ។ នេះមានន័យថា គំនិតផ្តួចផ្តើមអន្តររដ្ឋាភិបាល ស្តីពីការការពារទិន្នន័យ និង ឯកជនភាព ក៏គួរតែបន្តដែរ ប្រសិនបើមិនធ្ងន់ធ្ងរទេនោះ។

មូលដ្ឋានគ្រឹះដ៏ល្អមួយត្រូវបានបង្កើតឡើងនៅក្នុង GDPR របស់ EU រួចរាល់ហើយ "បទដ្ឋានមាស" សម្រាប់ការការពារឯកជនភាពនៃទិន្នន័យ។ ប៉ុន្តែ GDPR បង្កើតបញ្ហាប្រឈមសម្រាប់រដ្ឋាភិបាល និង សាជីវកម្មនៅអាស៊ី។ ប្រទេសនានាដោះស្រាយ "ឯកជនភាព" "សន្តិសុខ" "ការការពារទិន្នន័យ" និង សូម្បីតែ "សិទ្ធិនានា" តាមវិធីខុសៗគ្នា (Consumers International, n.d.)។ លើសពីនេះទៀត GDPR តម្រូវឲ្យមានសកម្មភាពអនុលោមភាពនៃកម្រិតខ្ពស់ជាងយ៉ាងខ្លាំង ប្រសិនបើប្រៀបធៀបនឹងលក្ខខណ្ឌតម្រូវផ្នែកឯកជនភាពដែលមានស្រាប់ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ នៅអាស៊ី។ ចំពោះសាជីវកម្ម ជាពិសេស សាជីវកម្មដែលកំពុងតែធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការដែលគ្មានច្បាប់ឯកជនភាព ការបំពេញតាមលក្ខខណ្ឌតម្រូវរបស់ GDPR គឺមិនងាយស្រួលនោះទេ (Shatter និង Lam ឆ្នាំ២០១៩)។ សាជីវកម្មមួយចំនួននឹងត្រូវគិតឡើងវិញអំពីគំរូអាជីវកម្មរបស់ពួកគេ ដោយផ្អែកលើការយល់ព្រមយ៉ាងទូលំទូលាយលើការប្រមូលទិន្នន័យផ្ទាល់ខ្លួនជាច្រើន។ សូម្បីតែសាជីវកម្មដែលធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការដែលមានច្បាប់ឯកជនភាពទិន្នន័យ ក៏ប្រហែលជានៅតែចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពទម្លាប់អនុវត្តលើទិន្នន័យរបស់ពួកគេដែរ ដើម្បីទទួលបានការវាយតម្លៃថា "សមស្រប" ដោយ EU សម្រាប់គោលបំណងបញ្ជូនទិន្នន័យ។ ការរក្សាទុកទិន្នន័យក្នុងរយៈពេលវែងជាងរយៈពេលដែលចាំបាច់ អាចមានតម្លៃថ្លៃ និង មានភាព

ស្មុគស្មាញនៅក្នុងការអនុវត្តសម្រាប់ក្រុមហ៊ុនជាច្រើននៅអាស៊ី។បញ្ហាប្រឈមដ៏សំខាន់មួយទៀត ជាពិសេសចំពោះសហគ្រាសធុនតូចបំផុត សហគ្រាសធុនតូច និង មធ្យម គឺការរក្សាទុកទិន្នន័យផ្ទាល់ខ្លួនឲ្យមានសុវត្ថិភាព។ ដើម្បីសម្របសម្រួលការធ្វើអាជីវកម្មកាន់តែច្រើន រវាងតំបន់ទាំងពីរ ASEM អាចអភិវឌ្ឍកម្មវិធីមួយដើម្បីជួយដល់អាជីវកម្មនៅអាស៊ី នៅក្នុងការអនុលោមតាម GDPR។

គំនិតផ្តួចផ្តើមរបស់អាស៊ានចំពោះការការពារទិន្នន័យនិងឯកជនភាពគឺជាការអភិវឌ្ឍជាវិជ្ជមាននៅក្នុងការបង្កើតមជ្ឈដ្ឋានដែលការពារ និង លើកកម្ពស់ការការពារទិន្នន័យ និង ឯកជនភាព។ ឯកសារជាមូលដ្ឋាននៃគំនិតផ្តួចផ្តើមនេះគឺ ក្របខណ្ឌអាស៊ាន ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន (ខែវិច្ឆិកា ឆ្នាំ២០១៦) និង ក្របខណ្ឌស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល (ខែធ្នូ ឆ្នាំ២០១៨)។

ក្របខណ្ឌអាស៊ាន ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន មានបំណង "ពង្រឹងការការពារទិន្នន័យផ្ទាល់ខ្លួននៅអាស៊ាន និង សម្របសម្រួលកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមអ្នកចូលរួម ក្នុងបំណងរួមចំណែកដល់ការលើកកម្ពស់ និង កំណើនពាណិជ្ជកម្ម និង លំហូរនៃព័ត៌មាននៅក្នុងតំបន់ និង នៅលើសកលលោក" (ASEAN TELMINelMin ឆ្នាំ២០១៦)។ ក្របខណ្ឌនេះកំណត់គោលការណ៍ការពារទិន្នន័យផ្ទាល់ខ្លួន ដូចតទៅ៖ (i) ការយល់ព្រម ការជូនដំណឹង និង គោលបំណង (ii) ភាពត្រឹមត្រូវនៃទិន្នន័យផ្ទាល់ខ្លួន (iii) ការការពារសន្តិសុខ (iv) ផ្ទេរទៅកាន់ប្រទេស ឬ ទឹកដីមួយផ្សេងទៀត (v) ការរក្សាទុក (vi) គណនេយ្យភាព និង (vii) ការចូលប្រើប្រាស់ និង កែតម្រូវ។

ក្របខណ្ឌអាស៊ានស្តីពីអភិបាលកិច្ចទិន្នន័យឌីជីថល "ចែងអំពីអាទិភាពផ្នែកយុទ្ធសាស្ត្រ គោលការណ៍ និង គំនិតផ្តួចផ្តើម ដើម្បីផ្តល់មគ្គុទ្ទេសក៍ណែនាំដល់រដ្ឋសមាជិកអាស៊ាននៅក្នុងគោលនយោបាយ និង អភិក្រមនិយ័តកម្មរបស់ពួកគេ ចំពោះអភិបាលកិច្ចទិន្នន័យឌីជីថល (ដែលរួមបញ្ចូលទាំងទិន្នន័យផ្ទាល់ខ្លួន និង មិនផ្ទាល់ខ្លួន) នៅក្នុងសេដ្ឋកិច្ចឌីជីថល" (ASEAN TELMIN ឆ្នាំ២០១៨)។ ក្របខណ្ឌនេះសម្គាល់ឃើញអាទិភាពផ្នែកយុទ្ធសាស្ត្រចំនួនបួន រួមមាន៖ (i) វដ្តជីវិត និង ស្ថានប្រព័ន្ធនៃទិន្នន័យ (ii) លំហូរទិន្នន័យឆ្លងដែន (iii) ឌីជីថលនីយកម្ម និង បច្ចេកវិទ្យាដែលកំពុងតែលេចឡើង និង (iv) បញ្ហាច្បាប់ និយ័តកម្ម និង គោលនយោបាយ។ គំនិតផ្តួចផ្តើមចំនួនបួនដើម្បីគាំទ្រអាទិភាពផ្នែកយុទ្ធសាស្ត្រទាំងបួននេះ រួមមាន៖ (i) ក្របខណ្ឌបែងចែកប្រភេទទិន្នន័យរបស់អាស៊ាន (ii) យន្តការលំហូរទិន្នន័យឆ្លងព្រំដែនអាស៊ាន (iii) វេទិកានវានុវត្តន៍ឌីជីថលអាស៊ាន និង (iv) ក្របខណ្ឌការការពារទិន្នន័យ និង ឯកជនភាពរបស់អាស៊ាន។

ទោះបីជាជំងឺរាតត្បាតសកលបានរារាំងកិច្ចប្រជុំទល់មុខគ្នារវាងក្រុមការងារអាស៊ានដែលពាក់ព័ន្ធក្តី ក៏ការធ្វើការលើគំនិតផ្តួចផ្តើមទាំងនេះនៅតែបន្ត តាមរយៈកិច្ចប្រជុំអនឡាញ និង ការផ្លាស់ប្តូរអ៊ីមែលដែរ។

ASEM អាចពង្រឹងគំនិតផ្តួចផ្តើមនេះតាមរយៈការកំណត់សកម្មភាព/គម្រោងដែលអាចនឹងជួយបង្កើតមជ្ឈដ្ឋានមួយដែលមានសុខដុមនីយកម្មចំពោះការការពារទិន្នន័យ និង ឯកជនភាព និងបង្កើនសកម្មភាពសេដ្ឋកិច្ចរវាងតំបន់ទាំងពីរឲ្យកាន់តែខ្លាំងក្លាឡើង។

## អនាគតប្រកបដោយបរិយាប័ន្ន

ការបង្កើតសង្គមឌីជីថលដែលមានបរិយាប័ន្ននៅអាស៊ី និង អឺរ៉ុប នឹងតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង និង គំនិតច្នៃប្រឌិតជាច្រើន ពីសំណាក់រដ្ឋាភិបាល សាជីវកម្ម និង ប្រជាជននៅក្នុងតំបន់ទាំងពីរ។

ជំពូកនេះណែនាំថា ASEM គួរតែពិចារណាអំពីកិច្ចសហប្រតិបត្តិការនៅក្នុងផ្នែកចំនួនបី ដូចខាងក្រោម៖

- អនាគតការងារ (អ្នកធ្វើការ)
  - កិច្ចសហប្រតិបត្តិការបស់ ASEM នៅក្នុងការអនុវត្ត "របៀបវារៈសម្រាប់អនាគតការងារដែលផ្តោតលើមនុស្សជាសំខាន់" ត្រូវបានណែនាំ
  - ASEM អាចពិចារណាអភិវឌ្ឍក្រុមនៃសិទ្ធិនានា (មិនចងកាតព្វកិច្ច) ដោយស្ម័គ្រចិត្តសម្រាប់អ្នកធ្វើការនៅលើទីផ្សារការងាររយៈពេលខ្លី ដែលអនុវត្តចំពោះតំបន់ទាំងពីរ។
- AI នៅក្នុងអភិបាលកិច្ច
  - ASEM អាចធ្វើការដើម្បីឆ្ពោះទៅកាន់អភិបាលកិច្ច AI និង ក្របខណ្ឌច្បាប់សម្រាប់អាស៊ី និង អឺរ៉ុបបាន ដោយផ្តោតលើ៖
    - បង្កើនអក្ខរភាពនៃអាល់កូរីត ដើម្បីបង្កើនសមត្ថភាពរបស់ប្រជាជន អង្គការ និង មន្ត្រីរដ្ឋាភិបាលនៅក្នុងការស្វែងយល់ថាតើប្រព័ន្ធ AI ដំណើរការដោយរបៀបណា ធ្វើដូច្នេះ ពួកគេអាចទាមទារគណនេយ្យភាព AI
    - បង្កើតយន្តការ និង ដំណើរការ ដើម្បីរួមបញ្ចូលភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការបង្កើត និង អនុវត្តវិធាននានាដែលទាក់ទងនឹងការប្រើប្រាស់ AI នៅក្នុងវិស័យសាធារណៈ និង
    - ធ្វើការវិវឌ្ឍន៍ក្របខណ្ឌមួយ ដែលសិទ្ធិ និង ការការពារតាមផ្លូវច្បាប់របស់ប្រជាជនអាជីវកម្ម និង ភាគីពាក់ព័ន្ធដទៃទៀតត្រូវបានលើកកម្ពស់។

- ការការពារទិន្នន័យ និង ឯកជនភាព
  - កិច្ចសហប្រតិបត្តិការរបស់ ASEM នៅក្នុងការបង្កើតមជ្ឈដ្ឋានមួយដែលមានសុខដុមនីយកម្មចំពោះការការពារទិន្នន័យ និង ឯកជនភាព នៅក្នុងតំបន់ទាំងពីរ
  - កិច្ចសហប្រតិបត្តិការរបស់ ASEM នៅក្នុងការជួយឲ្យក្រុមហ៊ុននៅអាស៊ីអនុលោមតាម GDPR។

នៅពេលដែលដៃគូ ASEM ផ្លាស់ប្តូរសង្គមរបស់ពួកគេទៅជាសង្គមឌីជីថល អនុសាសន៍ខាងលើអាចជាផ្នែកមួយនៃផែនការលម្អិតនៃការតភ្ជាប់ ASEM នៅថ្ងៃអនាគត។ កិច្ចប្រជុំកំពូល ASEM លើកទី ១៣ ( ASEM១៣ ) នៅក្នុងឆ្នាំ២០២១ អាចជួយឲ្យអាស៊ី និង អឺរ៉ុប លើកឡើងអំពីការកែប្រែ និង បញ្ហាប្រឈមទាំងនេះរួមគ្នា។

# ឯកសារយោង

Asian Development Bank (2018), *Asian Development Outlook*. https://www.adb.org/sites/default/files/publication/411666/ado2018.pdf (accessed on 1 July 2020).

Agence France Press–JIJI (2020), 'Asia Deploys Innovative, If Invasive, Tech to Curb Virus', *Japan Times*, 20 March 2020. https://www.japantimes.co.jp/news/2020/03/20/business/tech/asia-deploys-innovative-invasive-tech-curb-virus/#.Xr4K3hMzbjA.

AlgorithmWatch (2019), *Automating Society: Taking Stock of Automated Decision-Making in the EU,* a report by AlgorithmWatch in cooperation with Bertelsmann Stiftung, supported by the Open Society Foundation. https://algorithmwatch.org/wp-content/ uploads/2019/02/Automating_Society_Report_2019.pdf

ASEAN Telecommunications and Information Technology Ministers Meeting (ASEAN TELMIN) (2016), *Framework On Personal Data Protection*. https://asean.org/storage/2012/05/10-ASEAN-Framework-on-PDP.pdf (accessed 29 June 2020).

ASEAN TELMIN (2018), *Framework On Digital Data Governance*. https://asean.org/storage/2012/05/6B-ASEAN-Framework-on-Digital-Data-Governance_Endorsed. pdf (accessed 29 June 2020),

Bain and Company (2018) ADVANCING TOWARDS ASEAN DIGITAL INTEGRATION:

Empowering SMEs to Build ASEAN's Digital Future https://www.bain.com/contentassets/37a730c1f0494b7b8dac3002fde0a900/report_advancing_towards_asean_digital_ integration.pdf

Caplan, R., J. Donovan, L. Hanson, and J. Matthews (n.d.), *Algorithmic Accountability: A Primer.* https://datasociety.net/wp-content/uploads/2019/09/DandS_Algorithmic_Accountability.pdf (accessed on 20 June 2020).

Chen, R. and S. Djankov (2018), 'Gig Economy Growth Pains', *World Bank Blogs*, 20 December. https://blogs.worldbank.org/developmenttalk/gig-economy-growth-pains

Consultancy.asia (2019), *Support for AI in Government Highest Among Asian Nations,* 21 May. https://www.consultancy.asia/news/2228/support-for-ai-in-government-highest- among-asian-nations

Consumers International (n.d.), *GDPR: Will It Be the Global Standard for Data Protection?* https://www.consumersinternational.org/news-resources/blog/posts/gdpr-will-it- be-the-global-standard-for-data-protection/ (accessed on 20 June 2020).

Dazzi, D. (2019), 'GIG Economy in Europe', *Italian Labour Law e-Journal*, 2(12), p. 72. https://illej.unibo.it/article/download/9925/10000

Dickey, M.R. (2017), 'Algorithmic Accountability', *TechCrunch*, 1 May. https://techcrunch. com/2017/04/30/algorithmic-accountability/

Diesel, C. (2019), 'The Southeast Asian Gig Economy: Capitalism at Its Most Brutal?', *ASEAN Today*, 23 November. https://www.aseantoday.com/2019/11/the-gig-economy-capitalism-at-its-most-brutal/

Digital Inclusion (n.d.), *Digital Inclusion Definition.* https://digitalinclusion.nz/about/digital-inclusion-definition/ (accessed on 11 June 2020).

Economist Intelligence Unit (2018), *The Asian Digital Transformation Index 2018*. http:// connectedfuture.economist.com/wp- content/uploads/2018/12/ADTI-white paper.pdf

Economist Intelligence Unit (2020), *The Inclusive Internet Index 2020: Executive Summary.* https://theinclusiveinternet.eiu.com/assets/external/downloads/3i-execu tive- summary.pdf

ERCIM (2020), *Pan-European Privacy-Preserving Proximity Tracing, 13 April.* https://ercim- news.ercim.eu/en121/ib/pan-european-privacy-preserving-proximity-tracing

European Commission (2018), *I-DESI 2018: How Digital is Europe Compared to*

*Other Major World Economies?* 26 October. https://ec.europa.eu/digital-single-market/en/news/ how-digital-europe-compared-other-major-world-economies

European Parliament (2019), *MEPs Approve Boost to Workers' Rights in the Gig Economy,* 16 April. https://www.europarl.europa.eu/news/en/press-room/20190410 IPR37562/meps-approve-boost-to-workers-rights-in-the-gig-economy

European Parliamentary Research Service (2019), *A Governance Framework For Algorithmic Accountability and Transparency,* pp. 69–75. https://www.europarl. europa.eu/RegData/etudes/STUD/2019/624262/EPRS_ STU(2019)624262_EN.pdf

Fischer, S. (2020), 'Social Media Use Spikes During Pandemic', *AXIOS,* 24 April. https://www.axios.com/social-media-overuse-spikes-in-coronavirus-pandemic-764b384d- a0ee-4787-bd19-7e7297f6d6ec.html

Ford Foundation (n.d.), *Future of Work(ers)*. https://www.fordfoundation.org/work/ challenging-inequality/future-of-work-ers/ (accessed on 11 June 2020).

Ghosh, D., A. Abecassis, and J. Loveridge (2020), 'Privacy and the Pandemic: Time for a Digital Bill of Rights', *Foreign Policy*, 20 April. https://foreignpolicy.com/ 2020/04/20/ coronavirus-pandemic-privacy-digital-rights-democracy/

Gov CIO (2019), 'How Government Can Benefit from Artificial Intelligence', *Outlook*, 20 February. https://www.govciooutlook.com/news/how-government-can-benefit-from- artificial-intelligence-nid-472.html

Greene, T. (2020), 'Alibaba's New AI System Can Detect Coronavirus in Seconds with 96% Accuracy', TNW. https://thenextweb.com/neural/2020/03/02/alibabas-new-ai-system-can-detect-coronavirus-in-seconds-with-96-accuracy/

Handayani, S.W. (n.d.), '4 Ways to Rethink Social Protection for Future Work in Asia', *Asian Development Blog*, 21 August. https://blogs.adb.org/blog/4-ways-rethink-social- protection-future-work-asia

Harari, Y.N. (2020), 'The World After Coronavirus', *Financial Times*, 20 March 20. https:// www.ft.com/content/19d90308-6858-11ea-a3c9-1fe6fedcca75

Hasnan, L. (2019), 'Philippines' Fast-growing Gig Economy', *ASEAN Post*, 9 October. https://theaseanpost.com/article/philippines-fast-growing-gig-economy

HealthHub (n.d.), *TraceTogether.* https://www.healthhub.sg/apps/38/tracetogether-app (accessed on 11 June 2020).

ICO (n.d.), What Is Automated Decision-making and Profiling? https://ico.org.uk/for-organisations/guide-to-data-protection/guide-to-the-general-data-protection-regulation-gdpr/automated-decision-making-and-profiling/what-is-automated-individual-decision- making-and-profiling/ (accessed on 20 June 2020).

ILO Global Commission on the Future of Work (2019), Work for a Brighter Future. Geneva: ILO. https://www.ilo.org/wcmsp5/groups/public/---dgreports/---cabinet/documents/publication/wcms_662410.pdf

ITU News (2020), Covid-19: *How Korea Is Using Innovative Technology and AI to Flatten the Curve*. https://news.itu.int/covid-19-how-korea-is-using-innovative-technology-and- ai-to-flatten-the-curve (accessed on 11 June 2020).

Jenkins, M. (2019), 'The Surge of the Gig Economy in APAC', *People Matters,* 25 September. https://www.peoplemattersglobal.com/article/life-at-work/the-surge-of-the-gig- economy-in-apac-23203

Katzenbach, C. and L. Ulbricht (2019), 'Algorithmic Governance', *Internet Policy Review,* 8(4). https://policyreview.info/concepts/algorithmic-governance (accessed 11 June 2020).

Khatiwada, S. (2018), 'Will Automation Create Jobs, or Destroy Them?', *Asian Development Blog,* 19 April. https://blogs.adb.org/blog/will-automation-create-jobs-or-destroy- them

Kiersz, A. and M. Hoff (2020), 'The 30 Best High-paying Jobs of the Future', *Business Insider*, 21 May 21. https://www.businessinsider.com/best-jobs-future-growth-2019-3#21- construction-managers-10

Kim, H.E. (2020), 'Coronavirus Privacy: Are South Korea's Alerts Too Revealing?', *BBC News*, 5 March. https://www.bbc.com/news/world-asia-51733145

Kinder, M. (2019), 'Putting the Worker in the Future of Work', *Brookings Institution Blog,* 19 November. https://www.brookings.edu/blog/the-avenue/2019/11/19/putting-the- worker-in-the-future-of-work/

Kirkpatrick, K. (2016), 'Battling Algorithmic Bias How Do We Ensure Algorithms Treat Us Fairly?', *Communications of the ACM*, 59(10), pp.16–17. https://dl.acm.org/doi/fullHtml/10.1145/2983270#:~:text=Algorithms%20are%20able%20to%20process,that%20far%20exceed%20human%20capabilities.&text=The%20risk%20scores%20were%20created,the%20U.S.%20criminal%20justice%20system

Knight, W. (2017), 'Biased Algorithms Are Everywhere, and No One Seems to Care', *MIT Technology Review,* 12 July. https://imdiversity.com/diversity-news/biased-algorithms- are-everywhere-and-no-one-seems-to-care/

Koty, A.C. (2019), 'China's Corporate Social Credit System: What Businesses Need to Know', *China Briefing from Dezan Shira & Associates*, 5 November. https://www.china- briefing.com/news/chinas-corporate-social-credit-system-how-it-works/

Louis, J. (2020), 'Using Tech to Fight COVID-19', *ASEAN Post*, 3 April. https://theaseanpost.com/article/using-tech-fight-covid-19

MacCarthy, M. and K. Propp (2020), 'The EU's White Paper on AI: *A Thoughtful and Balanced Way Forward', Lawfare*, 5 March. https://www.lawfareblog.com/eus-white-paper-ai-thoughtful-and-balanced-way-forward

Machine Gone Wrong (n.d.), Understanding Bias Part I. https://machinesgonewrong.com/bias_i/ (accessed on 11 June 2020).

Macintosh, A. (2004), 'Characterizing E-Participation in Policy-Making', *Proceedings of the 37th Hawaii International Conference on System Sciences* – 2004, p. 3. http://citeseerx.ist.psu.edu/viewdoc/download?doi=10.1.1.98.6150&rep=rep1&type=pdf

Marr, B. (2019), 'The Future of Work: *5 Important Ways Jobs Will Change in the 4th Industrial Revolution', Forbes*, 15 July. https://www.forbes.com/sites/bernardmarr/2019/07/15/the-future-of-work-5-important-ways-jobs-will-change-in- the-4th-industrial-revolution/#7e73d3354c7c

Marx, G.T. (2002), 'What's New About the 'New Surveillance'? Classifying for Change and Continuity', *Surveillance & Society* 1(1), p. 10. http://www.cs.cmu.edu/~srini/15-829/ readings/whatsnew.pdf

Mastercard and Kaiser Associates (2019), *Mastercard Gig Economy Industry Outlook and Needs Assessment.* https://newsroom.mastercard.com/wp-content/uploads/2019/05/Gig-Economy-White-Paper-May-2019.pdf (accessed on 20 June 2020).

Matzner, T. and C. Ochs (2019), 'Privacy', *Internet Policy Review*, 8(4). https://policyreview.info/concepts/privacy (accessed on 11 June 2020).

McBridev, S. (2020), 'Why The Largest Cyberattack In History Will Happen Within Six Months', Forbes, 14 May. https://www.forbes.com/sites/stephenmcbride1/2020/05/14/why-the-largest-cyberattack-in-history-will-happen- within-six-months/#7cb375b5577c

Meyer, D. (2020), 'More Surveillance and Less Privacy Will Be the New Normal after the Coronavirus Pandemic', *Fortune, 20 April.* https://fortune.com/2020/04/20/ privacy- surveillance-coronavirus-pandemic-covid-19-tracking/

MIT Technology Review (2018), Insights Asia's AI Agenda: *The Ecosystem 2018*. https://www.technologyreview.com/2018/12/21/138153/asias-ai-agenda-the-ecosystem/ (accessed on 2 June 2020).

National Privacy Commission (2020), PHE Bulletin No. 7: *Official Statement of the National Privacy Commission on Calls for Patients to Waive Privacy Rights, Publicly Disclose Health Status,* 6 April. https://www.privacy.gov.ph/2020/04/npc-phe-bulletin-no-7-official-statement-of-the-national-privacy-commission-on-calls-for-patients-to-waive-privacy-rights-publicly-disclose-health-status/ (accessed on 2 June 2020).

Ng, A. (2020), 'COVID-19 Could Set a New Norm for Surveillance and Privacy', C/Net, 11 May. https://www.cnet.com/health/covid-19-could-set-a-new-norm-for- surveillance -and-privacy/

Organisation for Economic Co-operation and Development (OECD) (2019), Employment Outlook 2019: The Future of Work – Highlights. Paris: *OECD*. https:// www.oecd.org/ employment/Employment-Outlook-2019-Highlight-EN.pdf

Oxford Insights (2019), *Government Artificial Intelligence Readiness Index 2019*. https:// www.oxfordinsights.com/ai-readiness2019 (accessed on 30 June 2020).

PayPal (2018), *Global Freelancer Survey,* 1 March. https://www.paypal.com/stories/ sea/ paypal-global-freelancer-survey

Phua, R. (2020), 'The Singapore Gig Economy: Right Balance on Regulations Needed to Unlock Its Full Potential, Say Experts', *Channel News Asia*, 27 January. https:// www.channelnewsasia.com/news/singapore/the-singapore-gig-economy-right-balance-on- regulations-needed-to-12235556

Pierucci, A. and J.-P. Walter (2020), *Joint Statement on the Right to Data Protection in the Context of the COVID-19 Pandemic by the Chair of the Committee of Convention 108 and the Data Protection Commissioner of the Council of Europe*, 30 March. https://epic.org/privacy/ covid/Covid19_joint_statement.pdf

Reevell, P. (2020), 'How Russia is Using Facial Recognition to Police Its Coronavirus Lockdown', *ABC News*, 30 April. https://abcnews.go.com/International/russia-facial-recognition-police-coronavirus-lockdown/story?id=70299736

Rouse, M. (n.d.), ‘Gig Economy’, WhatIs.com. https://whatis.techtarget.com/ definition/ gig-economy (accessed on 2 June 2020).

Ruef, M. (2020), *Contact Tracing App DP3T SCIP,* 27 April. https://www.scip.ch/ en/?labs.20200427

Rumelt, R. (2008), *‘Strategy in a ‘Structural Break”, McKinsey Quarterly,* December. https:// www.mckinsey.com/business-functions/strategy-and-corporate-finance/our-insights/ strategy-in-a-structural-break

Seager, C. (2016), ‘After the Robot Revolution, What Will Be Left for Our Children to Do?’, *The Guardian,* 11 May. https://www.theguardian.com/careers/2016/may/11/ robot- jobs-automated-work

Sharma, G.D., A. Yadav, and R. Chopra (2020), ‘Artificial Intelligence and Effective Governance: A Review, Critique and Research Agenda’, *Sustainable Futures*, 2 https://www.sciencedirect.com/science/article/pii/S2666188819300048

Shatter, M. and J. Lam (2019), ‘The Aftermath of Storm GDPR in Asia Pacific’, *RSM*, 23 May. https://www.rsm.global/news/aftermath-storm-gdpr-asia-pacific

SIA (2018), APAC – *Study Shows Gig Economy Is Thriving in Asia Pacific*, 9 April. https:// www2.staffingindustry.com/row/Editorial/Daily-News/APAC-Study-shows-gig-economy- is-thand riving-in-Asia-Pacific-45633 (accessed on 15 June 2020).

Sim, D. and K. Xinghui (2020), ‘The Covid-19 Crisis Is Hurting Asia’s Gig Economy Workers and They Want the Government to Help’, *SCMP*, 16 March. https://www. scmp.com/week-asia/economics/article/3075125/coronavirus-bites-southeast-asias-gig- workers-eye-government

Snow, T. (2019), ‘Decision-making in the Age of the Algorithm: Three Key Principles to Help Public Sector Organisations Make the Most of AI Tools’, NESTA. https:// media.nesta. org.uk/documents/Decision-making_in_the_age_of_the_algorithm.pdf (accessed on 11 June 2020).

Solove, D.J. (2006), ‘A Brief History of Information Privacy Law’, Proskauer on Privacy. https://scholarship.law.gwu.edu/cgi/viewcontent.cgi?article=2076&context=facul ty_publications

Soriano, C.R.R. and J.H.C. Panaligan (2019), ‘Skill-Makers in the Platform Economy: Transacting Digital Labour’, in A. Athique and E. Baulch (eds), Digital Transactions in Asia Economic, Informational, and Social Exchanges. Routledge: 2019. https://www. researchgate.net/publication/331023933_’Skill-Makers’_in_the_Platform_Economy_

Transacting_Digital_Labour_Book_Chapter_in_Digital_Transactions_in_Asia_A_Athique_and_E_ Baulch_eds

Souter, D. (2019), 'Inside the Digital Society: The Gig Economy', APC, 16 December. https://www.apc.org/en/blog/inside-digital-society-gig-economy

TechCollective (2019), The Emergence of Gig Economy in Southeast Asia, 16 July. https://techcollectivesea.com/2019/07/16/the-emergence-of-gig-economy-in-southeast-asia/

United Nations (UN) (2018), United Nations E-Government Survey 2018: Gearing E-Government To Support Transformation Towards Sustainable And Resilient Societies. UNESCAP. https://www.unescap.org/sites/default/files/E-Government %20Survey%202018_FINAL.pdf

United Nations Capital Development Fund (UNCDF) (2019), UNCDF Introduces the Inclusive Digital Economy Scorecard During UN General Assembly. 4 October. https://www.uncdf.org/article/4958/uncdf-introduces-the-inclusive-digital-economy-scorecard- during-un-general-assembly

Viet Nam News/Asia News Network (2019), 'Building an Inclusive Digital Asean by 2040', Inquirer.net, 8 September. https://opinion.inquirer.net/123839/building-an-inclusive-digital-asean-by-2040

Walch, K. (2020), 'AI Laws Are Coming', Forbes, 20 February. https://www.forbes.com/ sites/cognitiveworld/2020/02/20/ai-laws-are-coming/#6dc4e551a2b4

Wang, Y. (2020), 'China Offers Its AI Technology to Diagnose Virus the World Over', China Daily, 2 April. https://global.chinadaily.com.cn/a/202004/02/ WS5e8525f8a 310128217283c1c.html

World Economic Forum (2018), Our Shared Digital Future Building an Inclusive, Trustworthy and Sustainable Digital Society. World Economic Forum. http://www3.weforum.org/docs/WEF_Our_Shared_Digital_Future_Report_2018.pdf

World Wide Web Foundation (2017), Algorithmic Accountability: Applying the Concept to Different Country Contexts. Washington, DC: World Wide Web Foundation. http://webfoundation.org/docs/2017/07/Algorithms_Report

# 8

# កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុប លើបម្លាស់ទីដើម្បីស្វែងរកការងារ ការអប់រំ និង ការបណ្តុះបណ្តាល

## តើអ្វីទៅជាលទ្ធផលកើតចេញពីការផ្លាស់ប្តូរផ្នែកឌីជីថលសម្រាប់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប ?

FLAVIA JURJE TRIFA

### សេចក្តីផ្តើម

ក្នុងរយៈពេល២៤ ឆ្នាំកន្លងមក កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) បានដើរតួនាទីជាវេទិកាមួយដ៏សំខាន់សម្រាប់កិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការលើការតភ្ជាប់ទ្វីបអាស៊ី និង អឺរ៉ុប។ ASEM បានក្លាយជានិមិត្តសញ្ញានៃកិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់រវាងតំបន់ទាំងពីរ។ ដោយមានបច្ចេកវិទ្យាភាពជឿនលឿន និង នវានុវត្តន៍ ព្រមទាំង ឌីជីថលនីយកម្មនៅក្នុងតំបន់ជាច្រើន អភិក្រមកិច្ចសហប្រតិបត្តិការប្រកបដោយនវានុវត្តន៍ត្រូវបានគ្របដណ្តប់នៅក្នុងវិស័យជាច្រើន រួមបញ្ចូលទាំង បញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ការវិនិយោគលើទីតាំងថ្មីៗ កំណើនប្រកបដោយនិរន្តរភាព និង ជាពិសេស បម្លាស់ទីរបស់ប្រជាជន។

ពាក់ព័ន្ធនឹងការដែលប្រទេសកម្ពុជាធ្វើជាប្រធាននៃកិច្ចប្រជុំកំពូល ASEM លើកទី១៣ (ASEM១៣) នៅក្នុងឆ្នាំ២០២១ ជំពូកនេះរួមចំណែកដល់ការសិក្សាស្រាវជ្រាវធំមួយ ស្តីពី "ការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការរវាងអាស៊ី-អឺរ៉ុប៖ ការធានាចំពោះកំណើនប្រកបដោយបរិយាប័ន្ន និង ចីរភាព នៅចំកណ្តាលបញ្ហាប្រឈមជាសកលថ្មីៗ" តាមរយៈការផ្តោតលើទំហំនៃការតភ្ជាប់រវាងមនុស្ស និង មនុស្ស និង ការពិភាក្សាអំពីថាតើឌីជីថលនីយកម្មមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះចំពោះបម្លាស់ទីរបស់មនុស្ស។ ដើម្បីសម្រេចគោលបំណងនេះ ជំពូកនេះនឹងបង្ហាញលិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការផ្លូវការ និងមិនផ្លូវការរវាងអាស៊ីជាពិសេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និង អឺរ៉ុប ហៅថា សហភាពអឺរ៉ុប (EU) ពាក់ព័ន្ធនឹងបម្លាស់ទីដើម្បីស្វែងរកការងារ និង ទេសន្តរប្រវេសន៍ ការអប់រំ និង ការបណ្តុះបណ្តាល។ ក្នុងនាមជាក្របខណ្ឌសមាហរណកម្មប្រចាំ

តំបន់សំខាន់ៗនៃទ្វីបទាំងពីរ ដែលជាផ្នែកមួយនៃ ASEM នោះ ទាំង EU និង អាស៊ាន បានអភិវឌ្ឍគោលនយោបាយបម្លាស់ទីខុសៗគ្នា និង កំពុងតែសហការគ្នាលើវិស័យជាច្រើន ដែលពាក់ព័ន្ធនឹងបម្លាស់ទីរបស់ប្រជាជន។ ដោយផ្អែកលើទម្លាប់អនុវត្តនៅក្នុង EU និង អាស៊ាន ការរួមចំណែកនេះនឹងពិភាក្សាថាតើគេគិតយ៉ាងដូចម្តេចខ្លះចំពោះបទពិសោធន៍ទាំងនេះនៅក្នុងបរិបទ ASEM ដោយលើកឡើងអំពីឱកាស និង បញ្ហាប្រឈម ដែលបង្កើតឡើងដោយបម្លាស់ទីរបស់ប្រជាជន នៅក្នុងការវិវឌ្ឍន៍នៃសេដ្ឋកិច្ចឌីជីថលនៅអាស៊ី និង អឺរ៉ុប។

ទិន្នន័យទាក់ទងនឹង បទពិសោធន៍ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សា គឺដកស្រង់ចេញពីព័ត៌មាន ការសិក្សាមុនៗ និងបទសម្ភាសន៍ជាមួយអ្នកជំនាញរួមមានមន្ត្រីរដ្ឋាភិបាល មន្ត្រីការទូតអង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ និង ភាគីពាក់ព័ន្ធសំខាន់ៗដទៃទៀត ដែលមានភាពសកម្មនៅក្នុងវិស័យបម្លាស់ទីដើម្បីស្វែងរកការងារ ដែលធ្វើឡើងដោយអ្នកនិពន្ធ នៅក្នុងតំបន់ទាំងពីរ (សូមមើល Jurje [២០១៨] និង Jurje និង Lavenex [២០១៩; ២០១៨; ២០១៦; ២០១៤] ផងដែរ)។

ជំពូកនេះ ជាដំបូង នឹងពិភាក្សាអំពីក្របខណ្ឌនៃការបម្លាស់ទីរបស់ប្រជាជន ដែលត្រូវបានអនុវត្តនៅ EU និង អាស៊ាន។ បន្ទាប់មក បន្តដោយការវិភាគទៅលើលិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការលើបម្លាស់ទីដើម្បីស្វែងរកការងារ និង ទេសន្តរប្រវេសន៍ ការអប់រំ និង ការបណ្តុះបណ្តាល ដែលមានរវាងតំបន់ទាំងពីរ។

ការរួមចំណែកនេះនឹងសម្លឹងមើលយុទ្ធសាស្ត្រនៃឌីជីថលនីយកម្មបន្ថែមទៀត នៅទូទាំងទ្វីបអឺរ៉ុប និង អាស៊ី និង ផលប៉ះពាល់នៃយុទ្ធសាស្ត្រទាំងនោះចំពោះបម្លាស់ទីរបស់ប្រជាជន។ ជាចុងក្រោយ សេចក្តីសន្និដ្ឋាននឹងសង្ខេបអំពីគំហើញសំខាន់ៗ និង បង្ហាញអនុសាសន៍នានាសម្រាប់ថ្នាក់ដឹកនាំ ASEM។

## ការតភ្ជាប់រវាងប្រជាជន និង ប្រជាជនទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ និង ក្របខណ្ឌនៃបម្លាស់ទីដើម្បីការសិក្សានៅអាស៊ី និង អឺរ៉ុប

ផ្នែកនេះ ទីមួយ នឹងពិភាក្សាអំពីគោលនយោបាយស្តីពីបម្លាស់ទីដែលមានស្រាប់ នៅក្នុងអាស៊ាន និង EU។ ទីពីរ ផ្នែកនេះនឹងវិភាគអំពីកម្មវិធីកិច្ចសហប្រតិបត្តិការដែលកំពុងតែដំណើរការ និង លិខិតូបករណ៍ដែលត្រូវបានបង្កើតឡើងរវាងតំបន់ទាំងពីរ ពាក់ព័ន្ធនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ និង ការជំរុញការបម្លាស់ទី។

## ការបម្លាស់ទីរបស់ប្រជាជននៅក្នុងអាស៊ាន

បម្លាស់ទីស្វែងរកការងារនៅតំបន់អាស៊ីអាគ្នេយ៍ បើទោះបីជាវាមិនមែនជាផ្នែកមួយនៃសេចក្តីប្រកាសច្បាប់ដើម នៃការបង្កើតអាស៊ានក្នុងឆ្នាំ១៩៦៧ ក៏ដោយ ប៉ុន្តែវាបានចូលមកក្នុងរបៀបវារៈនៃសមាហរណកម្មប្រចាំតំបន់ នៅក្នុងបរិបទនៃការសម្រេចចិត្តរបស់អាស៊ានដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មដែលមានស្រាប់។ បម្លាស់ទីរបស់អ្នកផ្តល់សេវា ឬ អ្នកប្រកបវិជ្ជាជីវៈដែលមានជំនាញខ្ពស់ ដែលមានទំនាក់ទំនងនឹងពាណិជ្ជកម្ម ត្រូវបានលើកឡើងលើកដំបូង នៅក្នុងការអនុម័តលើកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS) ឆ្នាំ១៩៩៥ និង ក្រោយមករួមជាមួយគំនិតផ្តួចផ្តើមចុះកិច្ចព្រមព្រៀងស្តីពីបម្លាស់ទីរូបវ័ន្តបុគ្គល (MNP)។ ការប្តេជ្ញាចិត្តភាគច្រើនត្រូវបានសរសេរនៅក្នុង AFAS ហើយបន្ទាប់មក MNP គ្របដណ្តប់ជាចម្បងលើអ្នកប្រកបវិជ្ជាជីវៈដែលមានកម្រិតខ្ពស់ ដែលមានទំនាក់ទំនងវត្តមាននៃពាណិជ្ជកម្ម ការផ្ទេរនិយោជិតនៅក្នុងសាជីវកម្ម (ដែលមានរយៈពេលស្នាក់នៅចាប់ពី ២ឆ្នាំ រហូតដល់៥/៨ឆ្នាំ) និង អ្នកធ្វើទស្សនកិច្ចផ្នែកអាជីវកម្ម ជាបុគ្គលដែលត្រូវបានជួលឲ្យបម្រើការងារនៅក្នុងប្រទេសដើមកំណើតរបស់ពួកគេ និងចូលក្នុងប្រទេសមួយទៀតក្នុងគោលបំណងពាក់ព័ន្ធនឹងអាជីវកម្ម ក្នុងរយៈពេលខ្លី និង មិនទទួលបានការទូទាត់ប្រាក់នៅក្នុងប្រទេសដែលទទួលពួកគេនោះទេ (ត្រូវបានអនុញ្ញាតនៅចន្លោះ ៣០ ទៅ ១២០ ថ្ងៃ)។ មានតែប្រទេសវៀតណាម ប្រទេសកម្ពុជា និង ប្រទេសហ្វីលីពីនប៉ុណ្ណោះដែលបានចែងអំពីបញ្ញត្តិនានាស្តីពីអ្នកផ្គត់ផ្គង់សេវាកម្មជាប់កិច្ចសន្យា ជាអ្នកផ្តល់សេវាកម្មដែលមិនជាប់ពាក់ព័ន្ធនឹងការបង្កើតពាណិជ្ជកម្មនោះទេ ប៉ុន្តែពួកគេត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងរយៈពេលដែលមានកម្រិត (ឧ. មិនលើសពី ៩០ ថ្ងៃ នៅក្នុងប្រទេសវៀតណាម) ហើយការផ្លាស់ទីរបស់ពួកគេ គឺអាស្រ័យលើលក្ខខណ្ឌតម្រូវផ្នែកអប់រំ និង បទពិសោធន៍។ ទោះបីជាយ៉ាងណាក្តី នៅក្នុងការអនុវត្តជាក់ស្តែង បម្លាស់ទីដើម្បីស្វែងរកការងារដែលទាក់ទងនឹងពាណិជ្ជកម្ម ត្រូវបានគេមើលឃើញថាគ្រាន់តែជាការសម្របសម្រួលដល់បម្លាស់ទីរបស់អ្នកប្រកបវិជ្ជាជីវៈ អ្នកគ្រប់គ្រង និងបុគ្គលិកដែលមានគុណវុឌ្ឍិ ក្រោមប្រភេទបម្លាស់ទីរបស់និយោជិតនៅក្នុងសាជីវកម្មតែប៉ុណ្ណោះ (សូមមើល Nikomborirak និង Jitdumrong [២០១៣] និង ILO និង ADB [២០១៤] ផងដែរ)។ ការធ្វើដំណើរនៅក្នុងតំបន់ ក្នុងរយៈពេលរហូតដល់មួយខែ គឺមិនចាំបាច់មានទិដ្ឋាការនោះទេ សម្រាប់ប្រជាជនអាស៊ាន ប៉ុន្តែទិដ្ឋាការការងារនៅតែត្រូវស្របតាមបទប្បញ្ញត្តិក្នុងប្រទេស។

លើសពីនេះទៀត មានកិច្ចព្រមព្រៀងមួយចំនួនទៀត ដែលហៅថា កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមក (MRAs) ដែលលើកកម្ពស់បម្លាស់ទីរបស់អ្នកប្រកបវិជ្ជាជីវៈមានជំនាញដែលត្រូវបានជ្រើសរើសបន្ថែមទៀត។ កន្លងមក MRAs ត្រូវបានចុះសម្រាប់វិជ្ជាជីវៈនានា ដែល

គ្របដណ្តប់លើផ្នែកវិស្វកម្ម គណនេយ្យ ស្ថាបត្យកម្ម ការអង្កេតគិលានុប្បដ្ឋាយិកា អ្នកអនុវត្តការងារផ្នែកទន្តសាស្ត្រនិងវេជ្ជសាស្ត្រនិងទេសចរណ៍ (បទសម្ភាសន៍១,២)។ទោះបីជាយ៉ាងណាក៏ដោយ MRA មិនបានផ្តល់ "ការផ្លាស់ទីដោយសេរី" ដោយស្វ័យប្រវត្តិនោះទេ ដោយសារតែនីតិវិធីនៃការធ្វើអន្តោប្រវេសន៍នៅក្នុងប្រទេស ឬ ឧបសគ្គផ្នែកភាសា អាចរឹតបន្តឹងការធ្វើបម្លាស់ទីរបស់អ្នកប្រកបវិជ្ជាជីវៈនៅក្នុងតំបន់ (បទសម្ភាសន៍ទី ១ ២ ៣ ៤)។

មានការរំពឹងថានឹងមានលំហូរនៃពលករជំនាញកាន់តែច្រើន បន្ទាប់ពីមានការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នៅឆ្នាំ២០១៥ (សូមមើល លេខាធិការដ្ឋានអាស៊ាន "២០០៨, ២០១៥") តាមរយៈការបង្កើតគំនិតផ្តួចផ្តើមនៃការផ្លាស់ទីបន្ថែមទៀត។ ទាំងនេះរួមមាន ដូចខាងក្រោម៖

- ជួយសម្រួលដល់ការផ្លាស់ទីតាមរយៈការចេញទិដ្ឋាការនិងទិដ្ឋាការការងារសម្រាប់អាជីវកម្ម និង ពលករជំនាញ
- ការទទួលស្គាល់លក្ខណៈសម្បត្តិផ្នែកវិជ្ជាជីវៈ
- ការអនុវត្ត និង អភិវឌ្ឍ MRAs ថ្មីៗ
- ការអភិវឌ្ឍធនធានមនុស្សនៅក្នុងផ្នែកសេវាកម្ម
- សមត្ថភាព និង លក្ខណៈសម្បត្តិសំខាន់ៗនៅក្នុងសេវាកម្មអាទិភាព
- ពង្រឹងសមត្ថភាពនៃកម្មវិធីទីផ្សារការងារ
- ពង្រឹងការផ្លាស់ទីរបស់អ្នកវិទ្យាសាស្ត្រ និង អ្នកស្រាវជ្រាវ
- ការអភិវឌ្ឍធនធានមនុស្ស
- ការលើកកម្ពស់ការងារសមរម្យ
- ការការពារ និង លើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។

ជាពិសេស ចំពោះការផ្លាស់ទីរបស់ប្រជាជន AEC បានព្យាយាមពន្លឿនដំណើរការនៃការអនុវត្ត MRAs ប៉ុន្តែក៏ស្នើសុំឲ្យមានការសម្រេចបាននូវកិច្ចសហប្រតិបត្តិការកាន់តែខ្លាំងឡើងនៅក្នុងចំណោមស្ថាប័ននានានៃបណ្តាញសកលវិទ្យាល័យអាស៊ានផងដែរ ដើម្បីបង្កើតការផ្លាស់ទីរបស់និស្សិត និង បុគ្គលិកអប់រំ។

បន្ថែមពីលើសសរស្តម្ភសេដ្ឋកិច្ចដែលគ្របដណ្តប់លើការបម្លាស់ទី កិច្ចសហប្រតិបត្តិការក្រោមសសរស្តម្ភវប្បធម៌សង្គម បាននាំឲ្យមានការចុះហត្ថលេខាលើសេចក្តីប្រកាស ស្តីពីសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧) និង ក្រោយមក ការព្រមព្រៀងជាឯកច្ឆន្ទរបស់អាស៊ានស្តីពីការការពារ និង ការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ (ឆ្នាំ២០១៨)។ ឯកសារនានាមានបំណងការពារសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ និង គ្រួសាររបស់ពួកគេ ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាតិ និង ស្នើសុំឲ្យកិច្ចគាំពារការងារ ប្រាក់ឈ្នួល និង ជីវភាពរស់នៅយ៉ាងសមស្រប ព្រមទាំងការសម្របសម្រួលលើគោលនយោបាយប្រឆាំងការជួញដូរផងដែរ។ ការផ្លាស់ប្តូរទម្លាប់អនុវត្តល្អៗ និង ការយល់ឃើញអំពីគោលនយោបាយរវាងរដ្ឋាភិបាល សមាគមកម្មករ និង សមាគមនិយោជក ត្រូវបានសម្របសម្រួលយ៉ាងជិតដល់ ជាមួយការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក ដែលស្ថិតនៅក្រោមវេទិកាអាស៊ានស្តីពីពលករទេសន្តរប្រវេសន៍ (បទសម្ភាសន៍ទី ១ ២ ៦ ៧)។ ក៏មានអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីនៅក្នុងអាស៊ាន មួយចំនួនតូចផងដែរ ដែលគ្របដណ្តប់លើទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ សម្រាប់ពលកម្មដែលមានជំនាញទាប ដែលបញ្ជាក់អំពីលក្ខខណ្ឌសម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងប្រទេស ទាក់ទងនឹងរយៈពេលស្នាក់នៅ លក្ខខណ្ឌតម្រូវផ្អែកភាសា និង នីតិវិធីអន្តោប្រវេសន៍ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ពុំមានប្រព័ន្ធកិច្ចសហប្រតិបត្តិការប្រចាំតំបន់សម្រាប់ពលកម្មដែលមានជំនាញទាប ឬ គ្មានជំនាញនោះទេ។

គួរកត់សម្គាល់ផងដែរថា ទិន្នន័យក៏បានសបញ្ជាក់ថាទាំងពលករ ដែលស្របច្បាប់ និងមិនស្របច្បាប់នៅអាស៊ាន គឺជាពលករដែលមានជំនាញទាប និង មានជំនាញខ្លះៗ ជាប្រភេទជនទេសន្តរប្រវេសន៍ ដែលមិនត្រូវបានលើកឡើងនៅកម្រិតតំបន់នោះទេ (សូមមើល ILO និង ADB [២០១៤]; Huelser និង Heal [២០១៤])។ យោងតាម UNDESA និង OECD (២០១៣), ប្រជាជនមួយចំនួន ក្នុងចំណោមប្រជាជនចំនួន ៦,៥ លាននាក់ នៅអាស៊ាន ត្រូវបានរាយការណ៍ថាស្នាក់នៅក្នុងរដ្ឋអាស៊ានដទៃទៀត ទោះបីជា ប្រហែលជាមានការប៉ាន់ស្មានខុសយ៉ាងខ្លាំង ចំពោះការធ្វើទេសន្តរប្រវេសន៍ដែលមិនត្រូវបានកត់ត្រាទុក។ ជាក់ស្តែង គេបានទទួលស្គាល់ថា ជនទេសន្តរប្រវេសន៍ដ៏ច្រើនលើសលប់ដែលកំពុងស្វែងរកការងារធ្វើនៅក្នុងអាស៊ាន មានជំនាញទាប ឬ ជំនាញកម្រិតខ្លះៗ (Huelser និង Heal ២០១៤; Orbeta ២០១៣)។ នៅខណៈពេលដែលលំហូរពលករមានជំនាញនៅអាស៊ានមានការកើនឡើងនោះ វានៅតែមានចំនួនទាប ប្រសិនបើប្រៀបធៀបនឹងលំហូរពលករទេសន្តរប្រវេសន៍ដែលគ្មានជំនាញ ឬ មានជំនាញខ្លះៗនោះ។ Orbeta (២០១៣) បានប៉ាន់ស្មានថា ជនទេសន្តរប្រវេសន៍ជិត ៩ នាក់ ក្នុងចំណោម ១០ នាក់

ដែលមកពីអាស៊ាន ហើយផ្លាស់ទីនៅក្នុងតំបន់ មានជំនាញទាប ហើយទិន្នន័យរបស់ OECD (២០១០/២០១១[79]) បង្ហាញថាភាគច្រើននៃជននិរប្រវេសន៍ មានកម្រិតអប់រំត្រឹមតែបឋមសិក្សាប៉ុណ្ណោះ ដោយមានការធ្វើទេសន្តរប្រវេសន៍ដែលគ្មានជំនាញ ច្រើនជាង ទេសន្តរប្រវេសន៍ដែលមានជំនាញយ៉ាងខ្លាំង ឧទាហរណ៍ ដូចនៅប្រទេសឥណ្ឌូនេស៊ី ប្រទេសមីយ៉ាន់ម៉ា ប្រទេសកម្ពុជា ប្រទេសថៃ និង ឡាវ (មូលដ្ឋានទិន្នន័យ DIOC-E របស់ OECD នៅក្នុង Huelser និង Heal [២០១៤])។ ទិន្នន័យដែលអាចទទួលបានពីរដ្ឋគោលដៅសំខាន់ៗ (Orbeta ២០១៣; ILO និង ADB ២០១៤) ក៏បង្ហាញអំពីគម្លាតរវាងទេសន្តរប្រវេសន៍ដែលមានជំនាញខ្ពស់ និង ទេសន្តរប្រវេសន៍ដែលមានជំនាញទាបដែរ។ ឧទាហរណ៍៖ នៅប្រទេសថៃ មានបុគ្គលិកប្រហែល ៣% ប៉ុណ្ណោះដែលមានជំនាញខ្ពស់ នៅខណៈពេលដែល នៅប្រទេសសិង្ហបុរី បុគ្គលិកដែលមានជំនាញខ្ពស់មានជិតមួយភាគបួន – ទោះបីជាយ៉ាងណាក៏ដោយ ពួកគេភាគច្រើន មកពីខាងក្រៅតំបន់ រួមមានប្រទេសចិន ប្រទេសឥណ្ឌា សហរដ្ឋអាមេរិក (US) និង ចក្រភពអង់គ្លេស។ ដោយសារតែវាផ្ទុយនឹងបម្លាស់ទីដែលមានជំនាញ វាមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលទេសន្តរប្រវេសន៍ដែលមានជំនាញទាប មិនបានស្ថិតនៅលើរបៀបវារៈរបស់ AEC នោះ ដែលជាសញ្ញានៃបញ្ហាប្រឈមផ្នែកនយោបាយយ៉ាងច្បាស់លាស់ ពាក់ព័ន្ធនឹងកង្វល់ផ្នែកអធិបតេយ្យភាពជាតិ និង ភាពស្ទាក់ស្ទើររបស់ប្រទេសទទួល នៅក្នុងការលើកឡើងអំពីប្រធានបទស្តីពីទេសន្តប្រវេសន៍ដែលមានជំនាញទាបនេះ នៅកម្រិតតំបន់។ ប្រទេសគោលដៅសំខាន់ៗនៅក្នុងតំបន់ រួមមាន ប្រទេសម៉ាឡេស៊ី និង ប្រទេសសិង្ហបុរី (ភាគច្រើនគឺអ្នកបម្រើការងារតាមផ្ទះ ដែលមកពីប្រទេសហ្វីលីពីន និង ប្រទេសឥណ្ឌូនេស៊ី និង ជាពិសេសគឺកម្មករសំណង់ និងពលករផ្នែកកសិកម្មដែលមកពីប្រទេសឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី) ព្រមទាំង ប្រទេសថៃ ផងដែរ ដែលមានកម្មករមកពីប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា (ILO និង ADB ២០១៤; Capannelli, ២០១៣)។

## បម្លាស់ទីរបស់ប្រជាជនដោយសេរី នៅ EU

ការផ្លាស់ទីរបស់កម្មករដោយសេរី នាពេលបច្ចុប្បន្ន ប្រជាជន រួមទាំងមូលធន ទំនិញ និង សេវាកម្មនានា បង្កើតបានជាសេរីភាពមូលដ្ឋានចំនួនបួននៃច្បាប់ស្តីពីទីផ្សារតែមួយរបស់អឺរ៉ុប (មាត្រា ១៨ EC)។ ការផ្លាស់ប្តូររបស់កម្មករដោយសេរី យ៉ាងពេញលេញ ត្រូវបានណែនាំនៅក្នុងឆ្នាំ១៩៦៨ ដោយមានបទប្បញ្ញត្តិលេខ ១៦១២/៦៨ ហើយនៅឆ្នាំ១៩៨៧ ច្បាប់ស្តីពីអឺរ៉ុបតែមួយ បានចែងថា និយាមនៃការផ្លាស់ទីដោយសេរីត្រូវបានលាតសន្ធឹងពីក្រុម "កម្មករ" ទៅកាន់ជនអសកម្មផ្នែកសេដ្ឋកិច្ច ហើយបច្ចុប្បន្ន វាបានគ្របដណ្តប់លើប្រជាពលរដ្ឋនៃ EU ទាំងអស់ ព្រមទាំងសាច់ញាតិ

[79] មូលដ្ឋានទិន្នន័យច្បាប់ដើម អាចចូលប្រើប្រាស់បាននៅទីនេះ៖ http://www.oecd.org/els/mig/dioc.htm.

របស់ពួកគេដែលជាជនបរទេសផងដែរ។ បញ្ញត្តិពិសេសៗ អនុវត្តចំពោះវិស័យសេវាកម្ម សម្រាប់ជនដែលនៅតែមានកិច្ចសន្យាការងារជាមួយនិយោជកនៅក្នុងប្រទេសកំណើតរបស់ពួកគេ និង នៅតែបានចុះឈ្មោះនៅក្នុងប្រព័ន្ធសន្តិសុខសង្គមនៃប្រទេសកំណើតរបស់ពួកគេ ប៉ុន្តែផ្លាស់ទៅកាន់ប្រទេស EU មួយផ្សេងទៀត ដើម្បីធ្វើការក្នុងរយៈពេលរហូតដល់ពីរឆ្នាំ។

"បុគ្គលិកដែលបានត្រូវបញ្ជូនមក" ទាំងនេះ ត្រូវបានដកចេញពីការតម្រូវឲ្យមានប័ណ្ណអនុញ្ញាតិធ្វើការ និង មិនចាំបាច់ឆ្លងកាត់ការទទួលស្គាល់អំពីលក្ខណៈសម្បត្តិផ្នែកវិជ្ជាជីវៈរបស់ពួកគេនោះទេ[80] (សេចក្តីណែនាំ ៩៦/៧១/EC)។

បុគ្គលិកទេសន្តរប្រវេសន៍របស់ EU និង គ្រួសាររបស់ពួកគេ មានសិទ្ធិកាត់ពន្ធដូចគ្នា និង ទទួលបានអត្ថប្រយោជន៍សង្គមដូចគ្នានឹងមិត្តរួមការងាររបស់ពួកគេ នៅក្នុងរដ្ឋដែលទទួលពួកគេដែរ (ឧ. ប្រាក់ឧបត្ថម្ភលើការចិញ្ចឹមកូន និង សិទ្ធិទទួលបានការអប់រំសម្រាប់កូន ។ល។) រដ្ឋសមាជិក EU បានសម្របសម្រួលប្រព័ន្ធសន្តិសុខសង្គមរបស់ពួកគេ និង បានបង្កើតក្របខណ្ឌមួយដែលទទួលស្គាល់លក្ខណៈសម្បត្តិទៅវិញទៅមក (Deacon et al. ២០១១)។ សិទ្ធិសង្គមរបស់ប្រជាជាតិនៃប្រទេសទីបី ត្រូវបានលើកឡើងនៅក្នុងសេចក្តីណែនាំអំពីនិវាសនជនរយៈពេលវែងនៅ EU (២០០៣/១០៩/EC) និង សេចក្តីណែនាំអំពីការជួបជុំគ្រួសារឡើងវិញនៅ EU (២០០៣/៨៦/CE)។

របបនៃការផ្លាស់ទីដោយសេរីនៅ EU ត្រូវបានពង្រឹងបន្ថែមតាមរយៈការលុបចោលការត្រួតត្រាព្រំដែនផ្ទៃក្នុងរបស់ EU ដូចបានធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចព្រមព្រៀង Schengen ឆ្នាំ១៩៨៥ និង បានទទួលស្គាល់នៅឆ្នាំ ១៩៩៦។ ការលុបចោលការត្រួតត្រាព្រំដែនផ្ទៃក្នុងនេះ ត្រូវបានចាត់ទុកជាកម្លាំងជំរុញមួយសម្រាប់ការសម្របសម្រួលការធ្វើទេសន្តរប្រវេសន៍ពីខាងក្រៅ មកកាន់ EU។ លក្ខខណ្ឌសម្រាប់ការឆ្លងកាត់ព្រំដែនខាងក្រៅរបស់ EU ទិដ្ឋាការសម្រាប់ការស្នាក់នៅក្នុងរយៈពេលតិចជាងបីខែ និង ផ្នែកជាច្រើននៃគោលនយោបាយស្តីពីសិទ្ធិជ្រកកោន ត្រូវបានធ្វើនិយ័តកម្មដោយវិធាននានារបស់ EU។ ទោះបីជា EU ពុំមានសមត្ថភាពពេញលេញលើការធ្វើអន្តោប្រវេសន៍ផ្នែកសេដ្ឋកិច្ចពីប្រទេសទីបីក៏ដោយ ក៏មានការអនុម័តសេចក្តីណែនាំនានា ដែលពាក់ព័ន្ធនឹងក្រុមជាក់លាក់ ដូចជា បុគ្គលិកដែលមានជំនាញខ្ពស់ (ឧទាហរណ៍៖ សេចក្តីណែនាំអំពីបម្លាស់ទីរបស់និយោជិតនៅក្នុងសាជីវកម្ម ២០១៤/៦៦/EU) សិស្ស អ្នកស្រាវជ្រាវ និងអ្នកធ្វើការតាមរដូវកាល។ លើសពីនេះទៀត របបនៃការផ្លាស់ទីត្រូវបានលាតសន្ធឹងទៅកាន់រដ្ឋដែលមិនមែនជាសមាជិក EU មួយចំនួនតូច ដែលមានទំនាក់ទំនងពិសេសជាមួយ EU ផងដែរ។ សេរីភាពនៃការផ្លាស់ទីយ៉ាង

80 អាចតម្រូវឲ្យមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ។

ពេញលេញ ត្រូវបានណែនាំតាមរយៈសន្ធិសញ្ញាស្តីពីតំបន់សេដ្ឋកិច្ចអឺរ៉ុប នៅក្នុងឆ្នាំ១៩៩២ ដោយមានសមាជិកដែលនៅសល់ពីសមាគមពាណិជ្ជកម្មសេរីអឺរ៉ុបនិងប្រទេសស្វីសតាមរយៈសន្ធិសញ្ញាទ្វេភាគី នៅក្នុងឆ្នាំ១៩៩៩។

លើសពីនេះទៀត កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានជំពូកស្តីពីសេវាកម្ម ត្រូវបានចុះដោយ EU និង ប្រទេសទីបី បានរួមបញ្ចូលបញ្ញត្តិស្តីពីការផ្លាស់ទីពិសេសៗ ដែលមានទំនាក់ទំនងនឹងពាណិជ្ជកម្ម។ ការធ្វើសេរីភាវូបនីយកម្មការផ្លាស់ទីទាំងនេះ ភាគច្រើន គ្របដណ្តប់លើប្រភេទនានានៃបម្លាស់ទីរបស់និយោជិតនៅក្នុងសាជីវកម្ម ឬ ពាក្យដែលប្រើនៅក្នុង EU "បុគ្គលិកសំខាន់" (ជាប្រភេទមួយដែលមានវត្តមានស្ទើរតែ ៧០% នៃកិច្ចព្រមព្រៀងរបស់ EU) និង ប្រជាជនដែលធ្វើការឲ្យខ្លួនឯង នៅក្នុងក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង និង ត្រូវបានគ្រប់គ្រងបានយ៉ាងមានប្រសិទ្ធភាព ដោយប្រជាជាតិទាំងនេះ នៅក្នុងទឹកដីរបស់ EU។ មានករណីលើកលែងមួយចំនួន ដែលផ្តល់សិទ្ធិដល់អ្នកផ្គត់ផ្គង់សេវាកម្មដែលមិនជាប់ពាក់ព័ន្ធនឹងវត្តមានផ្នែកពាណិជ្ជកម្មផងដែរ។ ឧទាហរណ៍មួយនៃករណីលើកលែងនោះគឺ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ច ដែលត្រូវបានចុះជាមួយប្រទេស Cariforum ដែលនៅឆ្ងាយ។

ទោះបីជាយ៉ាងណាក៏ដោយ មានការជំទាស់នឹងសារសំខាន់នៃការប្តេជ្ញាចិត្តដែលទាក់ទងនឹងអ្នកផ្គត់ផ្គង់សេវាកម្ម ដែលមិនទាក់ទងនឹងការបង្កើត។ គេបាននិយាយថា កិច្ចព្រមព្រៀងនេះ "មានការធ្វើតេស្តតម្រូវការសេដ្ឋកិច្ចជាច្រើន ដែលគ្មានភាពច្បាស់លាស់" (Kategekwa ២០០៨: ១១)។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែល Dawson (២០១២: ១៥) ចង្អុលបង្ហាញផ្ទុយពីអ្វីដែលកិច្ចព្រមព្រៀងទូទៅរបស់សហភាពអឺរ៉ុបស្តីពីពាណិជ្ជកម្មសេវាកម្មបានចែង ដែលមានភាពមិនប្រាកដប្រជាគួរសម កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចចែងអំពីលក្ខខណ្ឌយ៉ាងច្បាស់លាស់ និង អាចយល់បាន ចំពោះបម្លាស់ទីជាបណ្តោះអាសន្ន និង លក្ខខណ្ឌតម្រូវដែលត្រង់ទៅត្រង់មកពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការចេញលិខិតបញ្ជាក់ ដោយផ្តោតលើវិស័យជាក់លាក់ដែលរដ្ឋ Cariforum មានសមត្ថភាពផ្តល់សេវាកម្ម។ កូតាជាតួលេខ សម្រាប់បុគ្គលិកសំខាន់ៗ និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សានៅក្នុងវិស័យដែលបានធ្វើសេរីភាវូបនីយកម្មរួចហើយនោះត្រូវបានលុបបំបាត់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ដែលបានចុះហត្ថលេខាជាមួយសាធារណរដ្ឋកូរ៉េ (ចូលជាធរមាន ចាប់ពីឆ្នាំ២០១០) និង ប្រទេសកូឡុំប៊ី និង ប្រទេសប៉េរូ (បានចុះនៅក្នុងឆ្នាំ ២០១១) ក៏ជាករណីដែលមានការផ្តល់ជូននូវបញ្ញត្តិនានានៃ GATS+ ផងដែរ ជាពិសេស ពាក់ព័ន្ធនឹងរយៈពេលស្នាក់នៅជាអតិបរមារបស់បុគ្គលិកជំនាញ ហើយវាក៏រួមបញ្ចូល

អ្នកផ្គត់ផ្គង់សេវាកម្មដែលជាប់កិច្ចសន្យា និង អ្នកប្រកបវិជ្ជាជីវៈឯករាជ្យ អ្នកផ្គត់ផ្គង់សេវាកម្ម ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិស័យពាណិជ្ជកម្មផងដែរ។

ពាក់ព័ន្ធនឹងបម្លាស់ទីរបស់សិស្ស និង អ្នកស្រាវជ្រាវនៅក្នុង EU លិខិតូបករណ៍នៃគោលនយោបាយដ៏ជាក់លាក់ត្រូវបានណែនាំនៅថ្នាក់តំបន់ ហៅថា កម្មវិធី ERASMUS+។

វាគាំទ្រដល់ការអប់រំ ការបណ្តុះបណ្តាល យុវជន និង កីឡានៅទ្វីបអឺរ៉ុប តាមរយៈការផ្តល់ឱកាសដល់ប្រជាជនអឺរ៉ុបជាង ៤ លាននាក់ឲ្យទទួលបានការសិក្សា ការបណ្តុះបណ្តាល និង បទពិសោធន៍នៅក្រៅប្រទេស។ លក្ខណៈពិសេសចម្បងៗរបស់កម្មវិធីនេះគឺ ការទទួលស្គាល់ និង ការធ្វើសុពលកម្មជំនាញ និង លក្ខណៈសម្បត្តិនានា (ឧបករណ៍ខុសៗគ្នា ដែលធានាថា ជំនាញ និង លក្ខណៈសម្បត្តិនានា អាចត្រូវបានគេទទួលស្គាល់កាន់តែងាយស្រួល និង ត្រូវបានយល់ដឹងកាន់តែច្បាស់ នៅក្នុង និង ឆ្លងព្រំដែនជាតិនានា), ការចែកចាយ និង ទាញយកផលប្រយោជន៍ពីលទ្ធផល, ការប្រើប្រាស់លទ្ធផលរបស់គម្រោងដោយបើកចំហ ដើម្បីគាំទ្រការរៀនសូត្រ ការបង្រៀន ការបណ្តុះបណ្តាល និង ការងារយុវជន, ការលើកទឹកចិត្តលើការបោះពុម្ពលទ្ធផលនៃការសិក្សាស្រាវជ្រាវ តាមរយៈគន្លងនៃការចូលប្រើប្រាស់ដោយបើកចំហ។ ស្របពេលជាមួយគ្នានោះ ERASMUS+ រួមបញ្ចូលដែនអន្តរជាតិដ៏រឹងមាំមួយ ហៅថាកិច្ចសហប្រតិបត្តិការជាមួយប្រទេសដៃគូ ជាពិសេសនៅក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សា និង យុវជន។ នៅក្នុងចំណោមសកម្មភាពសំខាន់ៗជាមួយប្រទេសដៃគូ ដែលរួមបញ្ចូលទាំងប្រទេសនានានៅទ្វីបអាស៊ី និងសមភាគីអាស៊ានផងដែរនោះ រួមមានបម្លាស់ទីនៃឥណទានរបស់បុគ្គលជាអន្តរជាតិ គម្រោងកសាងសមត្ថភាពនៅក្នុងការអប់រំកម្រិតខ្ពស់ ការគាំទ្រដល់កិច្ចសន្ទនាអំពីគោលនយោបាយ និង សកម្មភាព Jean Monnet។

ជារួម សមាហរណកម្មសេដ្ឋកិច្ច រួមជាមួយ ការបង្កើតទីផ្សារតែមួយ បានធ្វើឲ្យមានបម្លាស់ទីរបស់ប្រជាជនដោយសេរី និង ពេញលេញ នៅក្នុង EU ហើយបម្លាស់ទីរបស់ពលករនៅខាងក្រៅដែលទាក់ទងនឹងសេវាកម្ម-ពាណិជ្ជកម្ម មានវត្តមាននៅគ្រប់ FTAs ទាំងអស់របស់ EU ដែលមានជំពូកមួយស្តីពីសេវាកម្ម។ ក្រៅពីបម្លាស់ទីរបស់ប្រជាជន ដែលពាក់ព័ន្ធនឹងគ្រឹះស្ថានពាណិជ្ជកម្ម (ពោលគឺ បម្លាស់ទីរបស់និយោជិតនៅក្នុងសាជីវកម្ម និង អ្នកធ្វើទស្សនកិច្ចផ្នែកអាជីវកម្ម) ក៏មានការបើកចំហជាច្រើន ដែលត្រូវបានចែង សម្រាប់ប្រភេទដទៃទៀត ឧទាហរណ៍ដែលគួរឲ្យកត់សម្គាល់មួយគឺ FTA ដែលបានចុះដោយ EU ជាមួយ រដ្ឋនានានៃ Cariforum។ ស្របពេលជាមួយគ្នានោះ បម្លាស់ទីរបស់សិស្ស អ្នកស្រាវជ្រាវ និង បុគ្គលិកអប់រំ ត្រូវបានលើកទឹកចិត្តយ៉ាងខ្ពស់តាមរយៈ ERASMUS+ កម្មវិធីពិសេសរបស់ EU ដើម្បីគាំទ្រដល់ការអប់រំ និង ការអភិវឌ្ឍការបណ្តុះបណ្តាល។

## លិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការសម្រាប់ទេសន្តរប្រវេសន៍ ការអប់រំ និង ការបណ្តុះបណ្តាលរវាងអាស៊ី និង អឺរ៉ុប

នៅក្នុងASEMដែលរួមបញ្ចូលគ្នារវាងEUនិងរដ្ឋសមាជិកEUព្រមទាំងប្រទេសនានានៃអាស៊ាន និងលេដ្ឋាធិការដ្ឋានអាស៊ានផងដែរនោះ (នៅក្នុងចំណោមអ្នកចូលរួមដទៃទៀតដែលពីទ្វីបទាំងពីរនេះ) ការផ្លាស់ប្តូរស្តីពីទេសន្តរប្រវេសន៍អន្តរជាតិ ត្រូវបានផ្តួចផ្តើមគំនិតនៅក្នុងឆ្នាំ២០០៣ ក្រោមសន្និសីទរបស់អគ្គនាយកផ្នែកអន្តោប្រវេសន៍ និង ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ នៃ ASEM ដែលមានវិសាលភាពពង្រឹងទំនាក់ទំនងរវាងអាជ្ញាធរអន្តោប្រវេសន៍របស់សមាជិក និង អនុញ្ញាតឲ្យមានការផ្លាស់ប្តូរព័ត៌មាន និង ទម្លាប់អនុវត្តល្អនៅក្នុងវិស័យទេសន្តរប្រវេសន៍អន្តរជាតិ។

កន្លងមក មានសន្និសីទចំនួន ១៤ ត្រូវបានរៀបចំឡើង ដោយកិច្ចពិភាក្សាគ្របដណ្តប់លើទិដ្ឋភាពភាគច្រើន ដែលទាក់ទងនឹងការត្រួតពិនិត្យការធ្វើទេសន្តរប្រវេសន៍ និង ការគ្រប់គ្រងលំហូរនៃការធ្វើទេសន្តរប្រវេសន៍។ កិច្ចពិភាក្សាបន្ថែមស្តីពីទេសន្តរប្រវេសន៍ ជាពិសេសទេសន្តប្រវេសន៍ស្វែងរកការងារ ការអប់រំ និង បម្លាស់ទីដើម្បីការបណ្តុះបណ្តាល រវាងអាស៊ី និង អឺរ៉ុប ក៏អាចទទួលបានសារសំខាន់បន្ថែមទៀត នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរដ្ឋមន្ត្រីនៃក្រសួងការងារ និង ពលកម្ម។ លើសពីនេះទៀត មូលនិធិអាស៊ី-អឺរ៉ុប ផ្តល់ការគាំទ្រ និង បង្កើនកិច្ចពិភាក្សាស្តីពីទេសន្តរប្រវេសន៍របស់ ASEM តាមរយៈព្រឹត្តិការណ៍នៃកិច្ចសហប្រតិបត្តិការដទៃទៀត និង ការផ្លាស់ប្តូរក្រោមប្រធានបទទេសន្តរប្រវេសន៍របស់ ASEM។ នៅក្នុងការអនុវត្តជាក់ស្តែង ការតភ្ជាប់រវាងប្រជាជននៅអាស៊ី និង អឺរ៉ុប រួមមាន និស្សិតសាកលវិទ្យាល័យ ប្រហែល ៤០០.០០០ នាក់ ដែលផ្លាស់ទីជាអន្តរជាតិ កិច្ចសហការលើការស្រាវជ្រាវជាង ២០០.០០០ និង ជនទេសន្តរប្រវេសន៍ជាង ១៣ លាននាក់ (រួមបញ្ចូលទាំងកម្មករ អ្នកប្រកបវិជ្ជាជីវៈ និង បុគ្គលិកផ្នែកអប់រំ ដែលផ្លាស់ទីរវាងប្រទេសនានានៅអាស៊ី និង អឺរ៉ុបផងដែរ – សូមមើល Becker et al. [២០១៩])។

នៅខណៈពេលដែលកិច្ចសហប្រតិបត្តិការស្តីពីការគ្រប់គ្រងព្រំដែន និង ការប្រឆាំងនឹងសកម្មភាពទេសន្តរប្រវេសន៍ខុសពីធម្មតា ក៏ជាផ្នែកមួយនៃកម្មវិធីអនុតំបន់ EU-អាស៊ាន ផ្សេងៗទៀតដែរនោះ ថ្នាក់ដឹកនាំ EU និង អាស៊ានបានអភិវឌ្ឍលិខិតូបករណ៍ដទៃទៀតនៅក្នុងតំបន់របស់ពួកគេ និង នៅក្នុងចំណោមទ្វីបទាំងនេះ ដើម្បីលើកឡើងអំពីបម្លាស់ទីរបស់មនុស្ស និង បទពិសោធន៍ផ្នែកគោលនយោបាយ ដែលអាចបម្រើដល់ការពង្រីករបៀបវារៈរបស់ ASEM ស្តីពីលំហូរប្រជាជនឆ្លងព្រំដែន។ផ្នែកខាងក្រោមនឹងបង្ហាញអំពីកម្មវិធីកិច្ចសហប្រតិបត្តិការសំខាន់ៗដែលត្រូវបានដាក់ឲ្យអនុវត្តរវាង EU និង អាស៊ាន។

ប្រទេសនានានៃ EU និង អាស៊ាន មានប្រវត្តិនៃកិច្ចសហប្រតិបត្តិការជាយូរលង់ណាស់មកហើយ។

កិច្ចសន្ទនារវាង EU-អាស៊ាន ដែលបានផ្តួចផ្តើមគំនិតនៅក្នុងឆ្នាំ១៩៧៧ និង បានធ្វើ ស្ថាប័នីយកម្ម ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការអាស៊ាន-EEC នៅក្នុងឆ្នាំ១៩៨០ ត្រូវបានកែសម្រួលក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ដើម្បីឆ្លុះបញ្ចាំងអំពីតម្រូវការ និង ការពិតរបស់ភាគីទាំងពីរ។ បច្ចុប្បន្ន វាគ្របដណ្តប់លើទិដ្ឋភាពនានាដែលទាក់ទងនឹងបម្លាស់ទីរបស់ប្រជាជន និង សិទ្ធិរបស់ជនទេសន្តរប្រវេសន៍ កម្មវិធីអប់រំ ដែលមានបំណងពង្រឹងបម្លាស់ទីរបស់សិស្ស និង ការអភិវឌ្ឍក្របខណ្ឌលក្ខណៈសម្បត្តិនៅក្នុងតំបន់ (នៅក្នុងកម្មវិធី ដែលហៅថា កម្មវិធីសហភាពអឺរ៉ុបផ្តល់ការគាំទ្រដល់ការអប់រំកម្រិតខ្ពស់នៅក្នុងតំបន់អាស៊ាន, SHARE) ព្រមទាំង ការគ្រប់គ្រងទេសន្តរប្រវេសន៍ផងដែរ ឧទាហរណ៍៖ កម្មវិធីទេសន្តរប្រវេសន៍ និង ការគ្រប់គ្រងព្រំដែនរវាងអាស៊ាន-EU។

ដោយមើលឃើញកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំអាស៊ាននៅក្នុងកសាងទំនាក់ទំនងកាន់តែជិតស្និទ្ធនៅក្នុងចំណោមរដ្ឋសមាជិកទាំង ១០ និង បង្កើតទីផ្សារ និង មូលដ្ឋានផលិតកម្មតែមួយ EU បានបង្ហាញការគាំទ្រចំពោះគំនិតផ្តួចផ្តើមទាំងនេះ និង បានបង្កើនកម្មវិធីសន្ទនា និង កិច្ចសហប្រតិបត្តិការ ដោយមានគោលបំណងទូទៅក្នុងការពង្រឹងទំនាក់ទំនងផ្នែកសេដ្ឋកិច្ច សង្គម នយោបាយ និង ការតភ្ជាប់រវាងទ្វីបទាំងពីរ។ ទិដ្ឋភាពនានាដែលទាក់ទងនឹងបម្លាស់ទីរបស់ប្រជាជន ការផ្លាស់ប្តូរដើម្បីការអប់រំ និង ការបណ្តុះបណ្តាលផ្នែកអប់រំ និង សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ដែលជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច នយោបាយ និង វប្បធម៌ សង្គម ដែលទូលំទូលាយជាងនេះ ក៏ត្រូវបានរកឃើញនៅក្នុងផែនការសកម្មភាពអាស៊ាន-EU បច្ចុប្បន្ន ឆ្នាំ២០១៦-២០២៤ នៃលិខិតូបករណ៍នៃកិច្ចសន្ទនារវាង អាស៊ាន-EU ដែលមានភាពរឹងមាំជាងមុន, E-READI។[81]

ឧទាហរណ៍៖ កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យគ្រប់គ្រងទេសន្តរប្រវេសន៍ តាមរយៈការគាំទ្រដល់សហគមន៍នយោបាយ និង សន្តិសុខអាស៊ាន ត្រូវបានបង្កើតឡើង ក្រោមកម្មវិធីទេសន្តរប្រវេសន៍ និង ការគ្រប់គ្រងព្រំដែនរវាង EU-អាស៊ាន I និង II ដែលបានជួយពង្រឹងការគ្រប់គ្រងព្រំដែន និង ពន្លឿនការផ្លាស់ទីឆ្លងព្រំដែន។ ដោយមានជំនួយផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស ពី INTERPOL,EUបានផ្តល់ការគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព្រំដែនដែលបានធ្វើសមាហរណកម្ម

---

[81] សម្រាប់ព័ត៌មានលម្អិត សូមមើល៖ https://eeas.europa.eu/headquarters/headquarters-homepage/49815/enhanced-regional- eu-asean-dialogue-instrument-e-readi_km.

នៅក្នុងតំបន់ ដើម្បីជួយសម្រួលដល់ការផ្លាស់ទីនៃទំនិញ និង មនុស្សដោយស្របច្បាប់ និង ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និង ទេសន្តរប្រវេសន៍ដោយមិនស្របច្បាប់ និង ការជួញដូរមនុស្សទូទាំងអាស៊ាន បានកាន់តែល្អប្រសើរ។ ដើម្បីសម្រេចគោលបំណងនេះ EU បានអះអាងអំពីការគាំទ្ររបស់ខ្លួនចំពោះការអនុវត្តសេចក្តីថ្លែងការណ៍រួមគ្នារបស់ថ្នាក់ដឹកនាំអាស៊ាន ឆ្នាំ២០១១ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍ តាមរយៈវិធានការនានា ដូចជា ការចែករំលែកព័ត៌មាន និង ការប្រើប្រាស់បច្ចេកវិទ្យាដែលទាក់ទងនឹងការគ្រប់គ្រងព្រំដែន និង សន្តិសុខឯកសារ។ ក្នុងនាមជាលទ្ធផលដំបូងគេ កម្មវិធី EU បានជួយរដ្ឋសមាជិកអាស៊ាននៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមអង្គភាពគ្រប់គ្រងព្រំដែនរបស់ពួកគេ និង បានពង្រឹងកិច្ចសហប្រតិបត្តិការស្តីពីការផ្លាស់ប្តូរព័ត៌មាន រវាងការិយាល័យ INTERPOL ក្នុងមូលដ្ឋាន និង អគ្គលេខាធិការដ្ឋាន INTERPOL (គណៈប្រតិភូនៃសហភាពអឺរ៉ុប ទីក្រុងចាកាតា ឆ្នាំ២០១៣)។ ជំនួយផ្នែកទេសន្តរប្រវេសន៍ និង ការគ្រប់គ្រងព្រំដែន ត្រូវបានរៀបចំឡើង ដើម្បីលើកឡើងអំពីរបៀបវារៈស្តីពីការតភ្ជាប់រវាងមនុស្ស និង មនុស្ស នៅអាស៊ាន តាមរយៈការពង្រឹងការអនុវត្តច្បាប់ និង កិច្ចសហប្រតិបត្តិការ នៅមណ្ឌលឆ្លងកាត់ធំៗប្រចាំតំបន់។ ការសិក្សាស្តីពីការជួយសម្រួលលក្ខខណ្ឌតម្រូវនៃទិដ្ឋាការសម្រាប់អាស៊ាន និង ប្រទេសទីបី ដែលចូលមកក្នុងតំបន់នេះ ក៏ជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការនេះដែរ។

ទិដ្ឋភាពនានាដែលទាក់ទងនឹងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ត្រូវបានរកឃើញថា ស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការស្តីពីគំនិតផ្តួចផ្តើមសិទ្ធិមនុស្សដែលមានលក្ខណៈទូលំទូលាយជាងនេះ ជាមួយ EU ដែលផ្តល់ការគាំទ្រយ៉ាងពេញលេញដល់គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និង ការការពារសិទ្ធិស្ត្រី និង កុមារ។ បញ្ហានានាដែលទាក់ទងនឹងសិទ្ធិមនុស្សក៏ត្រូវបានបញ្ជាក់ឡើងវិញ ក្រោមកិច្ចសហប្រតិបត្តិការវប្បធម៌សង្គម ជាមួយ EU ដែលចូលរួមនៅក្នុងកិច្ចសន្ទនាអំពីគោលនយោបាយ និង កម្មវិធីនានាដែលលើកកម្ពស់សិទ្ធិមនុស្ស រួមទាំង សុខមាលភាពរបស់ពលករទេសន្តរប្រវេសន៍ផងដែរ (គណៈប្រតិភូនៃសហភាពអឺរ៉ុប ទីក្រុងចាកាតា ឆ្នាំ២០១៣)។ គំនិតផ្តួចផ្តើមនាពេលថ្មីនេះ ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ជាពិសេស ស្ត្រីដែលនៅក្នុងតំបន់អាស៊ាន ដែលត្រូវបានផ្តួចផ្តើមឡើងដោយ EU និង អង្គការសហប្រជាជាតិ គឺកម្មវិធីសុវត្ថិភាព និង យុត្តិធម៌ ដែលលើកឡើងអំពីសិទ្ធិ និង ឱកាសរបស់ពលករទេសន្តរប្រវេសន៍ដែលជាស្ត្រី នៅក្នុងតំបន់អាស៊ាន។ គម្រោងនេះមានបំណងលុបបំបាត់អំពើហិង្សាលើស្ត្រី និង កុមារីគំនិតផ្តួចផ្តើមរយៈពេលច្រើនឆ្នាំ នៅលើសកលលោក ដែលត្រូវបានអនុវត្តតាមរយៈភាពជាដៃគូរវាង ILO និង UNWomen ដែលមានវត្ថុបំណងជាចម្បង នៅក្នុងការធានាថាទេសន្តរប្រវេសន៍ដើម្បី

ស្វែងរកការងារ មានសុវត្ថិភាព និង យុត្តិធម៌ចំពោះស្ត្រីគ្រប់រូបនៅក្នុងតំបន់អាស៊ាន។[82]

ជាផ្នែកមួយនៃការគាំទ្រសម្រាប់សហគមន៍វប្បធម៌សង្គម EU កំពុងតែចារអនុម័តលើ បម្លាស់ទីកាន់តែខ្លាំងរបស់សិស្សនៅក្នុងតំបន់ និង បានផ្តួចផ្តើមគំនិតរៀបចំកម្មវិធីនានាដែលនឹងរួមចំណែកដល់ការធ្វើសុខដុមនីយកម្មការទទួលស្គាល់ប្រព័ន្ធនានា រវាងស្ថាប័នអប់រំកម្រិតខ្ពស់នៅអាស៊ាន (បទសម្ភាសន៍ទី៥ ទី៦)។ វាមានបំណងពង្រឹងលទ្ធភាពក្នុងការប្រៀបធៀបរវាងលក្ខណៈសម្បត្តិរបស់សាកលវិទ្យាល័យនានា និង ជួយសម្រួលដល់ការផ្ទេរឥណទានតាមរយៈការអភិវឌ្ឍក្របខណ្ឌ និង ប្រព័ន្ធត្រួតពិនិត្យលក្ខណៈសម្បត្តិ។

ដូចបានចង្អុលបង្ហាញនៅខាងលើ ឧទាហរណ៍ដែលគួរឲ្យកត់សម្គាល់នៃកិច្ចសហប្រតិបត្តិការរវាង EU-អាស៊ាន នៅក្នុងវិស័យនេះ គឺកម្មវិធី SHARE។ SHARE រួមចំណែកដល់ការតភ្ជាប់រវាងសិស្ស និង សាកលវិទ្យាល័យនៅក្នុងតំបន់ តាមរយៈការគាំទ្រដល់ភាពជឿនលឿននៃចក្ខុវិស័យឆ្នាំ ២០២៥ របស់សហគមន៍អាស៊ាន និង តាមរយៈការធ្វើសុខដុមនីយកម្មកន្លែងផ្តល់ការអប់រំកម្រិតខ្ពស់នៅទូទាំងអាស៊ាន។ យោងតាមបទពិសោធន៍របស់ EU ចំពោះបម្លាស់ទីដើម្បីការសិក្សានៅក្នុងផែនការសកម្មភាពរបស់សហគមន៍អឺរ៉ុបសម្រាប់ការផ្លាស់ទីរបស់និស្សិតសាកលវិទ្យាល័យ (ERASMUS+ គ្រោងការណ៍) កម្មវិធី SHARE មានបំណងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និង ពង្រឹងគុណភាព ការប្រកួតប្រជែងនៅក្នុងតំបន់ និង ការធ្វើអន្តរភាវូបនីយកម្មនៃការអប់រំកម្រិតឧត្តមសិក្សានៅអាស៊ាន។ ការជំរុញការតភ្ជាប់រវាងប្រជាជននៅក្នុងអាស៊ាន និង រវាង EU និង អាស៊ាន គឺជាគោលដៅចម្បងនៃកម្មវិធីនេះ។

កម្មវិធី SHARE កន្លងមក បានផ្តល់អាហារូបករណ៍ជាង ៥០០ កន្លែង ដល់និស្សិត និង បុគ្គលិកសាកលវិទ្យាល័យនៅអាស៊ាន និង បានរៀបចំកិច្ចសន្ទនាអំពីគោលនយោបាយ សិក្ខាសាលា និង វេទិកា ដែលមានអ្នកចូលរួមជាង ២.០០០ នាក់ (សារព័ត៌មាន SHARE នៃ EU ឆ្នាំ២០២០)។ លើសពីនេះ កិច្ចសហប្រតិបត្តិការផ្នែកការសិក្សារវាង EU-អាស៊ី តាមរយៈកម្មវិធី ERASMUS+ កំពុងតែជំរុញឲ្យមានការផ្លាស់ទីរបស់សិស្ស និង បុគ្គលិកអប់រំ ដែលមកពីប្រទេសជាក់លាក់នៃអាស៊ាន (និងកាន់តែទូលំទូលាយជាងនេះទៀត នៅអាស៊ី) ព្រមទាំងផ្តល់ការកសាងសមត្ថភាពផ្នែកការអប់រំកម្រិតខ្ពស់ នៅក្នុងប្រទេសដៃគូទាំងអស់ដែលមកពីតំបន់នេះ។

## ការផ្លាស់ទីរវាងប្រជាជន និង បរិវត្តកម្មឌីជីថលនៅអាស៊ី និង អឺរ៉ុប

ទាំងអឺរ៉ុប និង អាស៊ី បានចូលរួមយ៉ាងខ្លាំងក្លានៅក្នុងសេដ្ឋកិច្ចឌីជីថល និង ការតភ្ជាប់។ ស្រប

[82] សម្រាប់ព័ត៌មានលម្អិត សូមមើល៖ https://www.ilo.org/asia/projects/WCMS_632458/lang--en/index.htm.

ពេលជាមួយគ្នានោះ មានកម្មវិធីកិច្ចសហប្រតិបត្តិការផ្នែកឌីជីថលជាបន្តបន្ទាប់ រវាង EU និង អាស៊ាន ដែលគ្របដណ្តប់បញ្ហាគោលនយោបាយ បទប្បញ្ញត្តិ និង ស្ថានប្រព័ន្ធនៃនវានុវត្តន៍ផ្នែកឌីជីថល កាន់តែទូលំទូលាយថែមទៀត (គាំទ្រដោយ លិខិតុបករណ៍នៃកិច្ចសន្ទនាថ្នាក់តំបន់រវាង EU-អាស៊ាន, E-READ១[83])។

ជាពិសេស នៅ EU ទីផ្សារតែមួយផ្នែកឌីជីថល គ្របដណ្តប់លើការផ្លាស់ទីដោយសេរីរបស់មនុស្ស សេវាកម្ម និង មូលធន និង ស្នើឲ្យបុគ្គល និង អាជីវកម្មទាំងឡាយអាចចូលប្រើប្រាស់ និង ចូលរួមនៅក្នុងសកម្មភាពអនឡាញបានដោយរលូន ស្របតាមលក្ខខណ្ឌនៃការប្រកួតប្រជែងដោយយុត្តិធម៌ និង ការការពារអ្នកប្រើប្រាស់ និង ការការពារទិន្នន័យផ្ទាល់ខ្លួននៅកម្រិតខ្ពស់ ដោយមិនគិតអំពីសញ្ជាតិ ឬ ទីលំនៅនោះទេ។[84] យុទ្ធសាស្ត្រ ឌីជីថលរបស់ EU នាពេលបច្ចុប្បន្ន មានបំណងធ្វើឲ្យការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាអាចដំណើរការបាន សម្រាប់មនុស្ស ជាពិសេស តាមរយៈការវិនិយោគលើការអភិវឌ្ឍសមត្ថភាពផ្នែកឌីជីថល ការធ្វើទំនើបកម្មវិស័យអប់រំនៅទូទាំង EU ការបំពាក់បច្ចេកវិទ្យាឌីជីថលសម្រាប់ការរៀនសូត្រ ការទទួលស្គាល់ និង ការធ្វើសុពលកម្មជំនាញនានា និង ការប្រមើលមើល និង ការវិភាគអំពីតម្រូវការផ្នែកជំនាញ។[85]

សេដ្ឋកិច្ចឌីជីថលនៅអាស៊ានកំពុងតែរីកលូតលាស់យ៉ាងខ្លាំងក្លា ហើយវិធានការគោលនយោបាយ និង ក្របខណ្ឌនានា រួមទាំង ផែនការលម្អិត AEC ឆ្នាំ២០២៥ ផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និង កិច្ចព្រមព្រៀងស្តីពីក្របខណ្ឌ e-ASEAN ផងដែរ ត្រូវបានដាក់ឲ្យអនុវត្តដោយថ្នាក់ដឹកនាំអាស៊ាន ដើម្បីពង្រឹងអត្ថប្រយោជន៍នៃឌីជីថលនីយកម្ម។ លើសពីនេះទៀត អាស៊ានឌីជីថល គឺជាគំនិតផ្តួចផ្តើមមួយរបស់វេទិកាសេដ្ឋកិច្ចពិភពលោក និង ដៃគូថ្នាក់តំបន់នៅអាស៊ានទាំងដៃគូសាធារណៈ និង ឯកជន ដែលមានបំណងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលថ្នាក់តំបន់ នៅក្នុងអាស៊ាន ធ្វើដូច្នេះ អត្ថប្រយោជន៍នៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួនអាចក្លាយជាកម្លាំងចលករមួយសម្រាប់បរិយាប័ន្នផ្នែកសេដ្ឋកិច្ចនៅក្នុងតំបន់។ ដើម្បីសម្រេចគោលបំណងនេះ និង ស្រដៀងគ្នានឹងអភិក្រម EU ដែរ ការធ្វើការដើម្បីបង្កើតការប្តេជ្ញាចិត្តរួមគ្នា ចំពោះការបណ្តុះបណ្តាលជំនាញឌីជីថល សម្រាប់កម្លាំងពលកម្មអាស៊ាន គឺជាវត្ថុបំណងដ៏សំខាន់មួយនៃគំនិតផ្តួចផ្តើមនេះ។[86] លើសពីនេះទៀត វេទិកាអាស៊ានលើកទី១១ ស្តីពីទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ (២០១៨) បានអនុម័តលើប្រធានបទ "ឌីជីថលនីយកម្មដើម្បីលើកកម្ពស់ការងារសមរម្យសម្រាប់ពលករ

---

[83] សូមមើលគណៈកម្មការអឺរ៉ុប (២០១៩a)។

[84] សូមមើលគណៈកម្មការអឺរ៉ុប (២០១៩b)។

[85] សូមមើលគណៈកម្មការអឺរ៉ុប (n.d.)។

[86] សូមមើលវេទិកាសេដ្ឋកិច្ចពិភពលោក (n.d.) ផងដែរ។

ទេសន្តរប្រវេសន៍នៅអាស៊ាន"។ ក្នុងនាមជាសកម្មភាពមួយដែលស្ថិតនៅក្រោមគណៈកម្មាធិការអាស៊ាន លើការអនុវត្តសេចក្តីប្រកាសរបស់អាស៊ានស្តីពីផែនការការងារ ឆ្នាំ២០១៦-២០២០ នៃកិច្ចការពារ និង លើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ វេទិកានេះបានចែករំលែកទម្លាប់អនុវត្តល្អៗ និង បានពិភាក្សាអំពីការយល់ឃើញចំពោះការលើកកម្ពស់បច្ចេកវិទ្យាដើម្បី៖ ទីមួយ ពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ និង ទីពីរ ផ្តល់សេវាកម្មឌីជីថលដល់ពលករទេសន្តរប្រវេសន៍ ជាមួយនឹងទស្សនៈគ្រប់ជ្រុងជ្រោយនៅក្នុងការលើកកម្ពស់សុខមាលភាពរបស់ពលករទេសន្តរប្រវេសន៍ទាំងអស់ ហើយស្របពេលជាមួយគ្នានោះ ក៏ធ្វើការពិចារណាឱ្យបានត្រឹមត្រូវទៅលើការគិតគូរអំពីបញ្ហាយេនឌ័រផងដែរ។[87]

ប្រាកដណាស់ អត្ថន័យរវាងកំណើននៃឌីជីថលនីយកម្មចំពោះការផ្លាស់ទីរបស់មនុស្ស មានច្រើនខុសៗគ្នា វាបង្កើតឱកាស ប៉ុន្តែស្របពេលជាមួយគ្នានោះ វាក៏បង្កើនបញ្ហាប្រឈមផងដែរ។

ផ្នែកខាងក្រោមនឹងធ្វើការប៉ាន់ប្រមាណអំពីអត្ថន័យនៃឌីជីថលនីយកម្មចំពោះការផ្លាស់ទីរបស់មនុស្ស។

## បច្ចេកវិទ្យាឌីជីថល ដែលអាចផ្តល់អត្ថប្រយោជន៍ដល់បម្លាស់ទីរបស់មនុស្សបាន

ឌីជីថលនីយកម្មកំពុងតែបង្កើនភាពងាយស្រួលដល់ការទទួលបានព័ត៌មាន និង ភ្ជាប់ទំនាក់ទំនាក់មនុស្សនៅទូទាំងពិភពលោក។ បច្ចុប្បន្ន គេបានទទួលស្គាល់ថា បច្ចេកវិទ្យាឌីជីថលផ្តល់ឱកាសជាច្រើនដើម្បីធ្វើឲ្យមានភាពសាមញ្ញ ធានាសន្តិសុខ និង ពន្លឿនដំណើរការទេសន្តរប្រវេសន៍។ ការប្រើប្រាស់ឧបករណ៍ និង វេទិកាឌីជីថលបានលាតសន្ធឹងយ៉ាងខ្លាំងនៅក្នុងវិស័យទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ និង ការអភិវឌ្ឍសេវាកម្មសម្រាប់ពលករទេសន្តរប្រវេសន៍។

ខាងក្រោមគឺតំបន់នៃបញ្ហាខុសៗគ្នាដែលឌីជីថលនីយកម្មអាចជួយសម្រួលដល់បម្លាស់ទីរបស់មនុស្ស។ ទិដ្ឋភាពមួយចំនួនក្នុងចំណោមទិដ្ឋភាពទាំងនេះក៏ត្រូវបានលើកឡើងដោយអង្គការអន្តរជាតិផងដែរ ដូចជា ILO ជាដើម[88]៖

- ការប្រើប្រាស់កម្មវិធី និង វេទិកាឌីជីថលដើម្បីធ្វើឲ្យការស្វែងរកការងារធ្វើ ការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ និង ការវេរប្រាក់ (ការផ្ទេរប្រាក់) មានភាពសាមញ្ញជាងមុន ឧ. តាមរយៈការកាត់បន្ថយថ្លៃសេវាធនាគារ និង មានសុវត្ថិភាពជាងមុន (ឧ. ការប្រើប្រាស់កម្មវិធីដែល

[87] សម្រាប់ព័ត៌មានលម្អិត សូមមើល៖ https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/ meetingdocument/wcms_648531.pdf.

[88] សូមមើល ILO (២០១៨)។

ដំណើរការដោយ blockchain ដើម្បីវេរ និង គ្រប់គ្រងប្រាក់)។ លើសពីនេះទៀត ការប្រើប្រាស់កម្មវិធី និង ទំព័រចាត់ចំណាត់ថ្នាក់អនឡាញ អាចជួយជនទេសន្តរប្រវេសន៍ធ្វើការជ្រើសរើសដោយមានព័ត៌មានគ្រប់គ្រាន់ តាមរយៈការអនុញ្ញាតឲ្យពួកគេធ្វើការប្រៀបធៀបទីភ្នាក់ងារស្វែងរកការងារធ្វើ ប្រតិបត្តិករវេរប្រាក់ និង អ្នកផ្តល់សេវាដទៃទៀត។

- ប្រភពនៃការគ្រប់គ្រងទេសន្តរប្រវេសន៍ឌីជីថល អាចជួយកាត់បន្ថយចំណាយ និង ពេលវេលា ដែលពាក់ព័ន្ធនឹងដំណើរការជ្រើសរើសបុគ្គលិកផ្លូវការ (ដែលអាចជំរុញជនទេសន្តរប្រវេសន៍ឲ្យប្រើប្រាស់បណ្តាញមិនផ្លូវការ គ្មានឯកសារ និង គ្មានសុវត្ថិភាព)។
- កម្មវិធីគ្រប់គ្រងតាមប្រព័ន្ធឌីជីថលសម្រាប់ការធ្វើទេសន្តរប្រវេសន៍ក៏អាចរក្សាទុកឯកសារនានាបានដែរ ដូចជា កិច្ចសន្យាការងារ បង្កាន់ដៃបង់ប្រាក់ ឬ សំបុត្រពេទ្យ ជាដើម ដូច្នេះវាបង្កើតកំណត់ត្រានៃការព្រមព្រៀងមួយ ដែលហៅថា "គន្លងឌីជីថល" ដូចបានគូសបញ្ជាក់ដោយ កម្មវិធីត្រីកោណរបស់ ILO នៅក្នុងអាស៊ាន (២០១៨)។ ចំណុចនេះអាចមានសារប្រយោជន៍ ប្រសិនបើវិវាទអំពីលក្ខខណ្ឌនៃកិច្ចសន្យា ការសងប្រាក់ ឬ បញ្ហាដទៃទៀតកើតឡើងរវាងពលករទេសន្តរប្រវេសន៍ និង និយោជក ឬ ទីភ្នាក់ងារជ្រើសរើសបុគ្គលិក។
- ដំណោះស្រាយឌីជីថលដែលផ្តល់សេវាកម្មនានាដល់ជនទេសន្តរប្រវេសន៍ អាចគ្របដណ្តប់លើការគាំទ្រផ្នែកច្បាប់ ជំនួយផ្នែកសុខមាលភាព ឬ ឱកាសនៃការបណ្តុះបណ្តាលតាមអនឡាញ។
- បច្ចេកវិទ្យាឌីជីថលអនុញ្ញាតឲ្យជនទេសន្តរប្រវេសន៍ចែករំលែកព័ត៌មានបានយ៉ាងទាន់ពេលវេលា និង មានតម្លៃសមរម្យ។ បណ្តាញអនឡាញអាចផ្តល់ជំនួយដល់មិត្តពលករទេសន្តរប្រវេសន៍ និង ជួយដល់ពួកគេនៅក្នុងការរៀបចំខ្លួន ឧទាហរណ៍៖ ទិដ្ឋភាពផ្នែករដ្ឋបាលដែលទាក់ទងនឹងការងាររបស់ពួកគេនៅក្រៅប្រទេស។
- សេវារិះគន់តាមអនឡាញអាចជួយពលករទេសន្តរប្រវេសន៍នៅក្នុងការស្វែងរកជំនួយ ទោះបីជាពួកគេធ្វើការនៅកន្លែងដាច់ស្រយាល និង នៅដាច់ពីគេក៏ដោយ។

## ការបំបែក និង បញ្ហាប្រឈមផ្នែកឌីជីថលចំពោះបម្លាស់ទីរបស់ប្រជាជន

ដូចបានចង្អុលបង្ហាញនៅខាងលើ ឌីជីថលនីយកម្មក៏អាចបណ្តាលឲ្យមានការដាក់កំហិតលើប្រជាជន នៅក្នុងក្រុមមួយចំនួន ដែលកំពុងតែផ្លាស់ទីផងដែរ។ ឧទាហរណ៍មួយចំនួន រួមមានដូចខាងក្រោម៖

- គម្លាតពាក់ព័ន្ធនឹងជំនាញឌីជីថល ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍បច្ចេកទេសដែលមានតម្លៃសមរម្យ (ឧ. ទូរស័ព្ទចល័ត និង កុំព្យូទ័រ) និង ផែនការទិន្នន័យ (ពេលគឺអ៊ីនធឺណិត) អាចរំខានដល់សក្តានុពលក្នុងការប្រើប្រាស់សេវាកម្ម និង ឧបករណ៍ដែលបានលើកឡើងនៅខាងលើ ដើម្បីជួយសម្រេចបាននូវទេសន្តរប្រវេសន៍ដែលមានយុត្តិធម៌។
- ឌីជីថលនីយកម្មអាចនាំទៅរកការផ្សព្វផ្សាយព័ត៌មានមិនពិត អ្នកផ្តល់សេវាកម្ម អនឡាញមិនស្មោះត្រង់ និង ការការពារទិន្នន័យផ្ទាល់ខ្លួន និង ឯកជនភាពអនឡាញដែលមានកម្រិត។ ដើម្បីធានាចំពោះការការពារទិន្ន័យស្តីពីពលករទេសន្តរប្រវេសន៍ ដែលត្រូវបានប្រមូល និង រក្សាទុកតាមអនឡាញ តម្រូវឲ្យមានបទប្បញ្ញត្តិនានាដើម្បីធានាចំពោះឯកជនភាព និង សុវត្ថិភាពរបស់អ្នកប្រើប្រាស់វេទិកា និង ឧបករណ៍អនឡាញ។
- ការងារតាមបែបប្រពៃណីជាច្រើន អាចត្រូវបានជំនួសតាមរយៈស្វ័យប្រវត្តិកម្ម និង ឌីជីថលនីយកម្មនៃដំណើរការនានា ដែលជាលទ្ធផល អាចបង្កបញ្ហាដល់ជនទេសន្តរប្រវេសន៍ប្រភេទមួយចំនួន ក្នុងការទទួលបានការងារទាំងនោះ។ ដូច្នេះ ការពិចារណាថាតើជំនាញឌីជីថលអ្វីខ្លះដែលចាំបាច់ នៅក្នុងវិស័យសេដ្ឋកិច្ច និង ការវិនិយោគលើវិស័យអប់រំ ដើម្បីអភិវឌ្ឍសមត្ថភាពដែលសមស្រប គឺជាវិធានការសំខាន់ក្នុងការតភ្ជាប់គម្លាតឌីជីថល។

## សេចក្តីសន្និដ្ឋាន

បម្លាស់ទីរបស់ប្រជាជនមានសារសំខាន់ខ្លាំងណាស់ចំពោះសេដ្ឋកិច្ចនៅអាស៊ី និង អឺរ៉ុប។ នៅខណៈពេលដែល EU នៅក្នុងទិដ្ឋភាពមួយចំនួន គឺជាអ្នកអនុវត្តការផ្លាស់ទីរបស់ប្រជាជនដោយសេរី មុនគេបង្អស់ និង ជាអ្នកលើកកម្ពស់បម្លាស់ទីដើម្បីការសិក្សាដ៏សកម្មមួយនៅថ្នាក់តំបន់នោះ (នៅក្នុងគោលការណ៍ តាមរយៈគម្រោងការណ៍ ERASMUS+) អាស៊ានបានជ្រើសរើសគំរូនៃការផ្លាស់ទីដើម្បីការងារនៅក្នុងតំបន់ដែលមានការជ្រើសរើសកាន់តែខ្លាំងជាងមុន ដោយអនុវត្តតាមការផ្លាស់ទីរបស់អ្នកប្រកបវិជ្ជាជីវៈដែលមានជំនាញ ដើម្បីធ្វើពាណិជ្ជកម្មដែលទាក់ទងនឹងសេវាកម្ម និង លើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរអ្នកស្រាវជ្រាវ និង បុគ្គលិកផ្នែកអប់រំឆ្លងព្រំដែន។ លិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការ EU-អាស៊ានជាច្រើនត្រូវបានបង្កើតឡើង ដោយគ្របដណ្តប់លើទិដ្ឋភាពនានានៃផលប្រយោជន៍រួម ដែលទាក់ទងនឹងទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ សិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ការអប់រំ និង ការបណ្តុះបណ្តាល ព្រមទាំង គោលនយោបាយគ្រប់គ្រងព្រំដែនផងដែរ។ តាមរយៈការពង្រឹងបន្ថែមទៅលើការផ្លាស់ប្តូរបទពិសោធន៍ និង កិច្ចសហប្រតិបត្តិការផ្នែកគោលនយោបាយរវាងអនុតំបន់ទាំងពីរនេះ ASEM អាចពង្រឹងកិច្ចសន្ទនា និង កិច្ចសហ

ប្រតិបត្តិការលើការផ្លាស់ទីដើម្បីស្វែងរកការងារ និង ការអប់រំ រវាងអាស៊ី និង អឺរ៉ុប ជាពិសេសដោយមើលឃើញសារសំខាន់កាន់តែខ្លាំងឡើងនៃសេដ្ឋកិច្ចឌីជីថលរបស់តំបន់ទាំងនេះ។ ដូចបានចង្អុលបង្ហាញដោយថ្នាក់ដឹកនាំ ASEM នៅក្នុង "សិក្ខាសាលាស្តីពីការពង្រឹងមូលធនមនុស្សដើម្បីតភ្ជាប់ផ្នែកឌីជីថលប្រកបដោយចីរភាព" (បាងកក ២០១៩១៣) "សក្តានុពលរបស់សេដ្ឋកិច្ចឌីជីថលនៅក្នុងការជំរុញឲ្យមានកំណើនប្រកបដោយបរិយាប័ន្ន និងចីរភាព មានសារសំខាន់ខ្លាំងណាស់។ ដូច្នេះ វាមានសារសំខាន់ចំពោះដៃគូរបស់ ASEM ក្នុងលើកកម្ពស់ឱ្យបានពេញលេញ នូវអត្ថប្រយោជន៍នៃសេដ្ឋកិច្ចឌីជីថល និង ធ្វើការជាមួយគ្នាដើម្បីដោះស្រាយវិសមភាព និង ផ្តល់ឱកាសស្មើគ្នា ដោយផ្តល់ការអនុញ្ញាតដល់មនុស្សកាន់តែច្រើន តាមរយៈហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាល ព្រមទាំងលើកកម្ពស់អាជីវកម្ម និង ការចូលរួមរបស់សហគមន៍ និងនវានុវត្តន៍ឌីជីថល ផងដែរ"។ ចំណុចនេះមានអត្ថន័យយ៉ាងខ្លាំងចំពោះការផ្លាស់ទីរបស់មនុស្សព្រមទាំងទីផ្សារការងារ និងទីផ្សារអប់រំ។ ខណៈពេលដែលអត្ថប្រយោជន៍នៃការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សម្រាប់ជនទេសន្តរប្រវេសន៍មានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងការទទួលបានព័ត៌មានអំពីការងារនៅក្រៅប្រទេសបានកាន់តែងាយស្រួល បណ្តាញដែលមានសុវត្ថិភាព និង មានតម្លៃទាបជាងមុនសម្រាប់ការផ្ញើប្រាក់ ព្រមទាំង យន្តការការពារការប្រព្រឹត្តិខុសឆ្គងដែលល្អប្រសើរជាងមុននោះ វាក៏មានបញ្ហាប្រឈមផងដែរ។ ការងារត្រូវបានបាត់បង់ដោយសារឌីជីថលនីយកម្ម និងស្វ័យប្រវត្តិកម្ម ហើយការបែងចែកផ្នែកឌីជីថលប្រឈមទៅនឹង ហានិភ័យនៃការដកផ្នែកដែលសំខាន់ណាមួយរបស់ជនទេសន្តរប្រវេសន៍ចេញពីទីផ្សារការងារ។ដើម្បីដោះស្រាយចំណុចខ្សោយទាំងនេះ ដៃគូអាស៊ី និង អឺរ៉ុបអាចប្រើប្រាស់ ASEM ដើម្បី៖

- ចែករំលែកចំណេះដឹង ឧត្តមានុវត្ត និង យុទ្ធសាស្រ្តសម្រាប់រៀបចំកម្លាំងពលកម្មសម្រាប់ទីកន្លែងការងារដែលផ្អែកលើឌីជីថល តាមរយៈការអនុញ្ញាតឲ្យពួកគេទទួលបានជំនាញអក្ខរកម្ម ការបណ្តុះបណ្តាលផ្នែកឌីជីថលដែលចាំបាច់ និង ការទទួលបានជំនាញឡើងវិញប្រសិនបើចាំបាច់ និង

- លើកកម្ពស់ការរៀនសូត្រ និង ការអប់រំពេញមួយជីវិត ជួយសម្រួលដល់ការផ្លាស់ទីដើម្បីការងារកាន់តែខ្លាំងក្លា និង កែសម្រួលច្បាប់ និង បទប្បញ្ញត្តិស្តីពីការងារ ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់អំពីបដិវត្តកម្ម ដែលកើតឡើងដោយសារសេដ្ឋកិច្ចឌីជីថល ប៉ុន្តែក៏ដោះស្រាយបញ្ហាប្រឈមដែលជនទេសន្តរប្រវេសន៍ជួបប្រទះផងដែរ (ឧ. ការការពារទិន្នន័យ ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ)។

ដើម្បីពង្រឹងការតភ្ជាប់រវាងមនុស្ស និង មនុស្សនៅក្នុងយុគសម័យឌីជីថលនីយកម្ម ASEM ក្នុងនាមជាវេទិកានៃកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការផ្នែកគោលនយោបាយ ដែលធ្វើឲ្យអាស៊ី និង អឺរ៉ុបមានទំនាក់ទំនងកាន់តែជិតស្និទ្ធ អាចស្នើឡើងនូវអភិក្រមជារួមមួយចំពោះការផ្លាស់ទី។ ទិដ្ឋភាពនានាដែលគ្របដណ្តប់លើបម្លាស់ទីផ្នែកសេដ្ឋកិច្ច កិច្ចសហប្រតិបត្តិការលើការសិក្សា និង ការបណ្តុះបណ្តាល សិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ព្រមទាំងការត្រួតត្រា និង គ្រប់គ្រងព្រំដែនផងដែរ គួរតែក្លាយជាផ្នែកមួយនៃចក្ខុវិស័យទូទៅ ស្តីពីការផ្លាស់ទីរបស់មនុស្ស ដែល ស្របពេលជាមួយគ្នានោះ លើកឡើងអំពីគោលដៅនៃគោលនយោបាយនៅថ្នាក់តំបន់ និង របៀបវារៈជាសកលបានកាន់តែទូលំទូលាយ។

# ឯកសារយោង

ASEAN (2018), ASEAN Committee on the Implementation of the ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers, 11th ASEAN Forum on Migrant Labour, 29–30 October 2018, Singapore. https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/meetingdocument/wcms_648531.pdf (accessed 15 May 2020).

ASEAN Secretariat (2008), ASEAN Economic Community Blueprint. Jakarta:

ASEAN Secretariat. https://asean.org/wp-content/uploads/archive/5187-10.pdf (accessed 2 May 2020).

ASEAN Secretariat (2015), Economic Community Blueprint 2025. Jakarta:

ASEAN Secretariat. https://www.asean.org/storage/2016/03/AECBP_2025r_FINAL.pdf (accessed 10 April 2020).

ASEM (2019), ASEM Seminar on Enhancing Human Capital for Sustainable Digital Connectivity, 25 October 2019, Bangkok, Thailand. https://cdn.aseminfoboard.org/documents/Summary-of-ASEM-Seminar-on-Enhancing-Human-Capital-for-Sustainable- Digital-Connectivity.pdf (accessed 27 May 2020).

Becker, W., M. Dominguez-Torreiro, A.R. Neves, C.J. Tacao Moura, and M. Saisana (2019), Exploring ASEM Sustainable Connectivity—What Brings Asia and Europe Together? Luxembourg: European Commission and ASEM. https://publications.jrc.ec.europa.eu/ repository/bitstream/JRC112998/asem-report_online.pdf (accessed 16 March 2020).

Capannelli, G. (2013), 'Key Issues on Labour Mobility in ASEAN', paper prepared for the 3rd Roundtable on Labour Migration in Asia. Tokyo: Asian Development Bank Institute.

Dawson, L.R. (2013), 'Labour Mobility and the WTO: The Limits of GATS Mode 4', International Migration, 51(1), pp. 1–23.

Deacon, B., P. De Lombaerde, M.C. Macovei, and S. Schröder (2011), 'Globalization and the Emerging Regional Governance of Labour Rights', International Journal of Manpower, 32(3), pp. 334–365.

European Commission (n.d.), The Digital Skills and Jobs Coalition. https://ec.europa.eu/ digital-single-market/en/digital-skills-jobs-coalition (accessed 20 April 2020).

European Commission (2019a), The EU and ASEAN: Building Stronger Digital Economy & Connectivity Cooperation, 30 October. https://ec.europa.eu/digital-single-market/en/news/eu-and-asean-building-stronger-digital-economy-connectivity-cooperation (accessed 15 May 2020).

European Commission (2019b), A Digital Single Market for the Benefit of All Europeans, 8 May. https://ec.europa.eu/digital-single-market/en/news/digital-single-market-benefit-all- europeans (accessed 15 May 2020).

European Union (EU) Delegation Jakarta (2013), EU–ASEAN Natural Partners. http://eeas. europa.eu/asean/docs/eu_asean_natural_partners_en.pdf (accessed 15 May 2020).

European Union (EU) SHARE Newsletter, First Issue, May 2020, Jakarta. https://admin.share-asean.eu/sites/default/files/We%20SHARE%20Newsletter_book%20format%20%281%29.pdf (accessed 26 May 2020).

Huelser, S. and A. Heal (2014), 'Moving Freely? Labour Mobility in ASEAN', ARTNet Policy Brief. UN ESCAP. https://www.unescap.org/sites/default/files/polbrief40.pdf (accessed 10 May 2020).

International Labour Organization (ILO) (2018), How Digitalization Can Help Achieve Fair Migration, 31 October. https://www.ilo.org/asia/media-centre/statements-and-speeches/WCMS_648541/lang--en/index.htm (accessed 25 May 2020).

International Labour Organization and Asian Development Bank (ILO and ADB) (2014), ASEAN Community 2015: Managing Integration for Better Jobs and Shared Prosperity. Bangkok: ILO and ADB. http://www.adb.org/publications/asean-community-2015-managing- integration-better-jobs-and-shared-prosperity (accessed 18 May 2020).

Jurje, F. (2018), 'EU's External Labour Mobility and Trade – A Multilayered Governance Approach', in S. Carrera, L. den Hertog, D. Kostakopoulou, and M. Panizzon (eds.), The EU External Policies on Migration, Borders and Asylum in an Era of Large Flows: Policy Transfers or Intersecting Policy Universes. Leiden, The Netherlands: Brill Publisher, pp. 207–223.

Jurje, F. and S. Lavenex (2014), 'Trade Agreements as Venues for 'Market Power Europe'? The Case of Immigration Policy', JCMS: Journal of Common Market Studies, 52, pp. 320–336.

Jurje, F. and S. Lavenex (2016), 'Europe–Asia Connectivity: A Case for Labour Mobility', in A. Prakash (ed.), Asia Europe Connectivity Vision 2025: Challenges and Opportunities. Jakarta: ERIA, pp. 159–170.

Jurje, F. and S. Lavenex (2018), 'Mobility Norms in Free Trade Agreements: Migration Governance in Asia Between Regional Integration and Free Trade', European Journal of East Asian Studies, Special Issue, 17(1), pp. 83–117.

Jurje, F. and S. Lavenex (2019), 'The Trade–Migration Nexus from a Multilevel Perspective',

in M. Elsig, G. Spilker, and H. Michael (eds.), The Shifting Landscape of Global Trade Governance. Cambridge University Press, pp. 255–274.

Kategekwa, J. (2008), 'Unlocking the Mode 4 Deadlock: Creative Approaches to Enhancing Mode 4-type Temporary Labor Mobility Commitments in Free Trade and Migration Agreements with Lessons from the GATS', paper prepared for the seminar on 'Swiss Migration EU Mobility Partnerships: Unveiling the promise'. Berne, 12–13 December 2008.

Nikomborirak, D. and S. Jitdumrong (2013), 'ASEAN Trade in Services', in S.B. Das, J. Menon, and R.C. Severino (eds.), ASEAN Economic Community. A Work in Progress. Singapore: Asian Development Bank and Institute of Southeast Asian Studies.

Orbeta, A. Jr. (2013), 'Enhancing Labor Mobility in ASEAN: Focus on Lower-skilled Workers',

Philippine Institute for Development Studies (PIDS) Discussion Paper Series, No. 2013–17, Makati City, Philippines. https://www.econstor.eu/bitstream/10419/126934/1/pidsdps1317.pdf (accessed 12 April 2020).

United Nations Department of Economic and Social Affairs and Organisation for Economic Co-operation and Development (UNDESA and OECD) (2013), World

Migration in Figures. Contribution to UN High Level Dialogue on Migration and Development. https://www.oecd.org/els/mig/World-Migration-in-Figures.pdf (accessed 4 May 2020).

World Economic Forum (n.d.), Digital ASEAN. https://www.weforum.org/projects/digital- asean (accessed 25 May 2020).

## បញ្ជីបទសម្ភាសន៍

1. លេខាធិការដ្ឋានអាស៊ាណ នាយកដ្ឋាន AEC ចាកាតា ប្រទេសឥណ្ឌូនេស៊ី ខែមិថុនា ឆ្នាំ ២០១៤។
2. ក្រសួងធនធានមនុស្ស និង ទេសន្តរប្រវេសន៍ឆ្លងដែន ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី ខែមិថុនា ឆ្នាំ២០១៤
3. ក្រសួងពាណិជ្ជកម្ម ផ្នែកសេវាកម្ម ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី ខែតុលា ឆ្នាំ២០១៤
4. ក្រសួងពាណិជ្ជកម្ម និង ឧស្សាហកម្មនៃប្រទេសសិង្ហបុរី ខែកញ្ញា ឆ្នាំ២០១៥
5. គណៈប្រតិភូនៃសហភាពអឺរ៉ុបប្រចាំប្រទេសឥណ្ឌូនេស៊ី ខែមិថុនា ឆ្នាំ២០១៤
6. គណៈប្រតិភូនៃសហភាពអឺរ៉ុបប្រចាំប្រទេសឥណ្ឌូនេស៊ី ខែតុលា ឆ្នាំ២០១៤
7. លេខាធិការដ្ឋានអាស៊ាន កម្មវិធីកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍរវាងអាស៊ាន-អូស្ត្រាលី ដំណាក់កាលទី II ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី ខែមិថុនា ឆ្នាំ២០១៤។

9

# កិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុបស្ដីពីការផ្ដល់ភាពអង់អាចដល់ស្ត្រី និង យុវជន

## ការតភ្ជាប់ផ្នែកឌីជីថល និង ការអប់រំ

YEO LAY HWEE

### សេចក្តីផ្តើម

ការតភ្ជាប់បានក្លាយជាប្រធានបទដ៏សំខាន់មួយនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ចាប់តាំងពីឆ្នាំ២០១៤។ ក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្ដីការតភ្ជាប់ដែលត្រូវបានកោះប្រជុំនៅក្នុងឆ្នាំ២០១៦ បានដាក់ជូននូវអនុសាសន៍របស់ខ្លួន នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១២ ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងប្រ៊ូសែល កាលពីខែតុលា ឆ្នាំ២០១៨។ កិច្ចប្រជុំកំពូលនេះបានអនុម័តលើ "ផ្នែករូបីយនៃកិច្ចសហប្រតិបត្តិនៅក្នុងវិស័យតភ្ជាប់" ដែលនឹងដើរតួជាឧបករណ៍នាំផ្លូវមួយដើម្បីអនុវត្តរបៀបវារៈនៃការតភ្ជាប់ឲ្យបានជោគជ័យ។ វិស័យអាទិភាពនៃកិច្ចសហប្រតិបត្តិការរួមមានដូចខាងក្រោម៖

- គោលនយោបាយ និង ផែនការស្ដីពីការតភ្ជាប់
- ការតភ្ជាប់ប្រកបដោយចីរភាព
- ការតភ្ជាប់ផ្នែកពាណិជ្ជកម្ម និង ការវិនិយោគ
- ការតភ្ជាប់នាថ្ងៃអនាគត និង សេដ្ឋកិច្ចឌីជីថល
- ការតភ្ជាប់រវាងមនុស្ស និង មនុស្ស
- បញ្ហាប្រឈមផ្នែកសន្តិសុខ ដែលមានទំនាក់ទំនងនឹងការតភ្ជាប់

ដោយសារបញ្ហាប្រឈមដែលបង្កឡើងដោយជំងឺរាតត្បាតសកល កូវីដ ១៩ នៅលើសកលលោក ភាពភ័យខ្លាច និង ភាពមិនច្បាស់លាស់ដែលមានការកើនឡើង មនុស្សជាច្រើនអាចមានការព្រួយបារម្ភអំពីផលវិបាកលើរបៀបវារៈនៃការតភ្ជាប់របស់ ASEM។ ការរាតត្បាតនៃមេរោគកូរ៉ូណា ហាក់បីដូចជាធ្វើឲ្យរបៀបវារៈនៃសាកលភាវូបនីយកម្មត្រូវផ្អាកជាបណ្តោះអាសន្ន និង ធ្វើឲ្យជនដែលមានប្រជាប្រិយភាព និង អ្នកជាតិនិយមខ្លាំង មានភាពក្លាហានក្នុងការស្នើសុំឲ្យមានវិធានការគាំពារកាន់តែច្រើន និង កាត់បន្ថយសារសំខាន់នៃគោលនយោបាយស្តីពីការតភ្ជាប់។ ប៉ុន្តែ មេរៀនដែលនឹងទទួលបានពីការរាតត្បាតនៃមេរោគយ៉ាងខ្លាំងក្លានេះ គឺរបៀបដែលពិភពលោកមានការតភ្ជាប់កាន់តែខ្លាំងក្លា លើសពីអ្វីដែលយើងគិត។ វិធីតែមួយគត់ដែលយើងនឹងដោះស្រាយជាមួយផលប៉ះពាល់ដែលបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ និង ការកម្ចាត់ជំងឺរាតត្បាតសកលនាពេលអនាគតគឺ តាមរយៈការតភ្ជាប់កាន់តែខ្លាំង មិនមែនកាន់តែតិចនោះទេ។ យើងត្រូវការការតភ្ជាប់ផ្នែកឌីជីថលដើម្បីជួយដល់យើងតាមរយៈបទបញ្ជាឲ្យបិទទ្វារប្រទេស និង "ស្នាក់នៅក្នុងផ្ទះ"។ ការរៀនសូត្ររបស់កុមារនៅតាមផ្ទះ និង ការធ្វើការនៅខាងក្រៅការិយាល័យ ឬ ការធ្វើការពីចម្ងាយសម្រាប់មនុស្សពេញវ័យ ត្រូវការប្រើប្រាស់អ៊ីនធឺណិត។ យើងក៏ត្រូវការការតភ្ជាប់កាន់តែខ្លាំងនៅក្នុងចំណោមអ្នកវិទ្យាសាស្ត្រ និង អ្នកស្រាវជ្រាវរបស់យើងផងដែរ នៅក្នុងបំណងស្វែងរកការព្យាបាល ឬ ថ្នាំបង្ការ យើងត្រូវការការតភ្ជាប់ផ្នែកស្ថាប័នកាន់តែខ្លាំងដើម្បីរៀបចំការឆ្លើយតបដែលសម្រេបសម្រួលបានកាន់តែល្អ ទៅនឹងបញ្ហាប្រឈមជាសកលទាំងនោះ និង បញ្ហាប្រឈមដទៃទៀត។

តាមរយៈវេទិកា ASEM ប្រទេសនានានៅអាស៊ី និង អឺរ៉ុបចាំបាច់ត្រូវតែខិតខំប្រឹងប្រែងទ្វេដងលើរបៀបវារៈនៃការតភ្ជាប់ និង ការប្រមូលផ្តុំយុទ្ធសាស្ត្រ និង ផែនការតភ្ជាប់ខុសៗគ្នា ពីផែនការមេរបស់អាស៊ានស្តីពីការតភ្ជាប់ ទៅកាន់គំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវរបស់ប្រទេសចិន ទៅកាន់ភាពជាដៃគូចុងក្រោយបង្អស់រវាង EU-ប្រទេសជប៉ុន ស្តីពីការភ្ជាប់។ ដោយសារតែយើងប្រឈមមុខនឹងបញ្ហាប្រឈមទ្វេដងនៃការងើបចេញពីការរំខានដែលបង្កឡើងដោយជំងឺកូវីដ-១៩ និង បដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួនដែលនឹងមកដល់នាពេលខាងមុខ ការអប់រំ ការបណ្តុះបណ្តាល និង ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការតភ្ជាប់ ឌីជីថល និង ឌីជីថលនីយកម្ម នឹងក្លាយជាអាទិភាពចម្បង។

នៅក្នុងជំពូកនេះ ខ្ញុំនឹងផ្តោតលើការតភ្ជាប់ផ្នែកឌីជីថល និង ការតភ្ជាប់រវាងមនុស្ស និង មនុស្សដែលមានបំណងផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន។

## ហេតុអ្វីផ្តោតលើស្ត្រី និង យុវជន?

ពាក្យស្លោកបុរាណរបស់ប្រទេសអាហ្វ្រិកដែលថា "ប្រសិនបើអ្នកអប់រំស្ត្រីម្នាក់ អ្នកនឹងអប់រំគ្រួសារមួយទាំងមូល (ប្រទេសជាតិ)" ជាការប្រមូលកម្លាំងដើម្បីស្នើសុំឲ្យអ្នកឯកទេសផ្នែកអភិវឌ្ឍន៍ព្យាយាម និង បញ្ជៀបការផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងគម្រោងអភិវឌ្ឍន៍ និង ការផ្តល់ជំនួយខុសៗគ្នា អស់រយៈពេលជាយូរលង់ណាស់មកហើយ។ ការសិក្សាមួយចំនួនបានបង្ហាញថា ជាមធ្យម ស្ត្រីវិនិយោគរហូតដល់ ៩០% នៃប្រាក់ចំណូលរបស់ពួកគេទៅលើគ្រួសារ បើប្រៀបធៀបនឹងបុរសដែលវិនិយោគ ៣០%-៤០% ដែលបង្កើតផលចំណេញផ្នែកសេដ្ឋកិច្ចសង្គមរយៈពេលវែងចំពោះសហគមន៍របស់ពួកគេ។

របាយការណ៍ស្តីពីគម្លាតយេនឌ័រជាសកល ឆ្នាំ២០២០ នៃវេទិកាសេដ្ឋកិច្ចពិភពលោក បានកត់សម្គាល់ថា មានទំនាក់ទំនងទៅវិញទៅមកយ៉ាងខ្លាំងក្លារវាងគម្លាតយេនឌ័ររបស់ប្រទេសមួយ និង លទ្ធផលផ្នែកសេដ្ឋកិច្ចរបស់ប្រទេសនោះ។

នៅខណៈពេលដែលមានការទទួលស្គាល់អំពីសារសំខាន់របស់ស្ត្រី និង សមភាពយេនឌ័រនៅក្នុងការអភិវឌ្ឍសង្គម និង ប្រទេសជាតិនោះ ស្ត្រីនៅតែបន្តទទួលបានសេវាកម្មមិនបានគ្រប់គ្រាន់នៅក្នុងប្រទេសជាច្រើន។ វិសមភាពយេនឌ័រនៅតែបន្តកើតឡើងនៅក្នុងប្រទេសជាច្រើននៅទូទាំងពិភពលោក។ ការទទួលបានការអប់រំដែលមានគុណភាពល្អ និង ការងាររបស់ស្ត្រីនៅតែជាបញ្ហាប្រឈមដ៏ធំមួយ។ នៅក្នុងរបាយការណ៍មួយរបស់វិទ្យាស្ថាន McKinsey Global បានកត់សម្គាល់ថា ប្រសិនបើបុរស និង ស្ត្រីចូលរួមនៅក្នុងសេដ្ឋកិច្ចសកលដោយស្មើភាព ពួកគេនឹងបន្ថែមតម្លៃផលិតផលក្នុងស្រុកសរុប (GDP) ជាសកល ចំនួន ១២ ទ្រីលានដុល្លារអាមេរិក ដោយមានកំណើន ២៦%។ នាពេលបច្ចុប្បន្ន ស្ត្រីរួមចំណែក តែ ៣៧% នៃ GDP សកល តែប៉ុណ្ណោះ។

ដោយហេតុថា សង្គម និង សេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរ ដោយបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) ថ្មីៗ ស្ត្រីប្រឈមមុខនឹងឧបសគ្គដែលមិនអាចជំនះបាន នៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាំងនេះ ដើម្បីពង្រឹងជីវភាពរស់នៅរបស់ពួកគេ និង ទទួលស្គាល់អំពីសក្តានុពលរបស់ពួកគេ។ ឧបសគ្គសំខាន់ៗមួយចំនួនក្នុងចំណោមឧបសគ្គទាំងនេះ មានដូចជា ការចូលរួមរបស់សិស្សស្រីនៅកម្រិតទាប នៅក្នុងការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា (STEM) និង អតុល្យភាពយេនឌ័រនៅក្នុងជំនាញ និង ការងារបច្ចេកទេស។ ជាមូលដ្ឋាន បញ្ហាប្រឈមដ៏សំខាន់បំផុតមួយគឺ កង្វះខាតការប្រើប្រាស់អ៊ីនធឺណិត ឧបករណ៍ឌីជីថល និង បច្ចេកវិទ្យាចល័ត។

វិធីធានាថាស្ត្រីទទួលបានឱកាសស្មើគ្នា ដែលត្រូវបានបង្ហាញដោយបច្ចេកវិទ្យាថ្មីៗនៅក្នុងគន្លងដើម្បីផ្តល់ភាពអង់អាចរបស់ពួកគេ គួរតែក្លាយជាអាទិភាពមួយនៅក្នុងរបៀបវារៈរបស់ ASEM។ ចំណុចនេះក៏នឹងធ្វើឲ្យរបៀបវារៈរបស់ ASEM មានភាពស្របគ្នានឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ នៃអង្គការសហប្រជាជាតិ (UN SDGs) ជាពិសេសគោលដៅលេខ ៥ គឺដើម្បីសម្រេចបាននូវសមភាពយេនឌ័រ និង ផ្តល់ភាពអង់អាចដល់ស្ត្រី និង កុមារីគ្រប់រូប។

ការផ្តោតលើយុវជន គឺជាការសង្កេតយ៉ាងប្រុងប្រយ័ត្នលើអនាគតរបស់ប្រទេសក្នុងរយៈពេលវែង។ ប្រជាជនវ័យក្មេងមានសមាមាត្រចំនួនច្រើន និង កំពុងតែមានការកើនឡើង ក្នុងចំណោមប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ មានយុវជនចំនួន ១,២ ប៊ីលាននាក់ ដែលមានអាយុ ១៥-២៤ឆ្នាំ នៅជុំវិញពិភពលោក និង ជាអកុសល មានយុវជនរហូតដល់ ៧០លាននាក់ក្នុងចំណោមប្រជាជនទាំងនេះ គ្មានការងារធ្វើ និង ១៤៥ លាននាក់ទៀត មិនការងារធ្វើមិនគ្រប់គ្រាន់។[89] យោងតាមអង្គការអន្តរជាតិខាងការងារ (ILO) យុវជនទំនងជាគ្មានការងារធ្វើច្រើនជាងមនុស្សពេញវ័យបីដង។ ភាពគ្មានការងាររបស់យុវជននៅកម្រិតខ្ពស់មិនត្រឹមតែខ្ជះខ្ជាយភាពក្លៀវក្លារបស់ប្រទេសតែប៉ុណ្ណោះទេ ប៉ុន្តែវាមានទំនាក់ទំនងផ្នែកនយោបាយ និង សង្គមជាច្រើនផ្សេងទៀត។ ការមិនពេញចិត្តនឹងភាពគ្មានការងារធ្វើរបស់យុវជនអាចនាំទៅរកភាពចលាចលនៅក្នុងសង្គម និង អស្ថេរភាពនយោបាយ ហើយយុវជនដែលគ្មានការងារធ្វើ ក៏ទំនងជាធ្វើនិរប្រវេសន៍កាន់តែច្រើនផងដែរ។

នៅក្នុងប្រទេសដៃគូ ASEM ជាច្រើន ភាពគ្មានការងារធ្វើរបស់យុវជនគឺជាបញ្ហាប្រឈមយ៉ាងជាក់ស្តែងមួយ។

ភាពគ្មានការងារធ្វើមួយចំនួនគឺជាលទ្ធផលនៃការមានជំនាញមិនត្រូវគ្នា និង មួយចំនួនកើតឡើងដោយសារតម្រូវការក្នុងការធ្វើកំណែទម្រង់មូលដ្ឋានគ្រឹះ និង រចនាសម្ព័ន្ធផ្នែកសេដ្ឋកិច្ច។ ការអប់រំ និង ជំនាញនានាមានសារសំខាន់ចំពោះការអភិវឌ្ឍយុវជន។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការផ្លាស់ទីទៅមុខយ៉ាងឆាប់រហ័សនៃការវិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា និង ភាពក្លៀវក្លារបស់វា ការអប់រំ និង ការបណ្តុះបណ្តាលមិនអាចនៅស្ងៀមបាននោះទេ និង ត្រូវតែវិវឌ្ឍន៍ទៅមុខ ដើម្បីបំពេញតាមតម្រូវការរបស់ទីផ្សារការងារនាពេលអនាគត។

ទំហំនៃបញ្ហារបស់ប្រជាជនវ័យក្មេងដែលគ្មានការងារធ្វើ និង មានការងារធ្វើមិនគ្រប់គ្រាន់ ត្រូវបានទទួលស្គាល់ដោយ UN និង គោលដៅ SDG ឆ្នាំ២០៣០ ដែលរួមបញ្ចូលគោលដៅមួយ

[89] សូមមើល http://www.intracen.org/news/How-digital-skills-can-help-tackle--youth-unemployment/.

(SDG គោលដៅអនុវត្ត ៨.៦) ដែលស្នើសុំឲ្យមានការកាត់បន្ថយសមាមាត្ររបស់យុវជនដែលគ្មានការងារធ្វើ មិនបានទទួលការអប់រំ ឬ ការបណ្តុះបណ្តាល។

ម៉្យាងវិញទៀត SDG គោលដៅអនុវត្ត ៤.៤ ក៏ស្នើឲ្យមានកំណើនយ៉ាងខ្លាំងក្លានៃចំនួនយុវជនដែលមានជំនាញដែលពាក់ព័ន្ធ រួមទាំងជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈផងដែរ ដើម្បីលើកកម្ពស់ការងារ ការងារសមរម្យ និង សហគ្រិនភាព។ ចំណុចទាំងអស់នេះចង្អុលបង្ហាញអំពីសារសំខាន់របស់យុវជននៅក្នុងការជំរុញភាពរីកចម្រើន និង សុខមាលភាពរបស់ប្រទេសជាតិនៅក្នុងរយៈពេលវែង។

យើងបានបង្កើតសារសំខាន់នៃការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីដាក់វិធានការដែលពោរពេញដោយអត្ថន័យ និង គោលនយោបាយស្វែងរកមតិគាំទ្រឲ្យអនុវត្ត សម្រាប់ការផ្តល់ភាពអង់អាចរបស់ពួកគេនោះ យើងចាំបាច់ត្រូវតែដឹងអំពីរបៀបកំណត់ និង វាស់វែងការផ្តល់ភាពអង់អាច។

មាននិយមន័យខុសៗគ្នាជាច្រើនអំពីការផ្តល់ភាពអង់អាច ប៉ុន្តែនិយមន័យដំបូងៗ ភាគច្រើនសង្កត់ធ្ងន់លើទីភ្នាក់ងារ និង ការទទួលបានសមត្ថភាពដើម្បីធ្វើការជ្រើសរើសដែលមានអត្ថន័យ។ ក្របខណ្ឌ "ធនធាន ទីភ្នាក់ងារ និង សមិទ្ធផល" ដំបូងៗរបស់ Naila Kabeer ក៏ផ្តល់គំនិតពិចារណាជាក់ស្តែងសម្រាប់ការវាស់វែងការផ្តល់ភាពអង់អាចដែរ ដែលរួមបញ្ចូលដែនចំនួនបីដែលមានទំនាក់ទំនងទៅវិញទៅមកៈ

- ធនធាន ៖ ទទួលបានការប្រើប្រាស់ធនធានសម្ភារ ធនធានមនុស្ស និង ធនធានសង្គមដែលពង្រឹងសមត្ថភាពរបស់ប្រជាជននៅក្នុងការជ្រើសរើស រួមទាំងចំណេះដឹង ឥរិយាបថ និង ចំណូលចិត្តផងដែរ។
- ទីភ្នាក់ងារ ៖ កំណើននៃការចូលរួម ការបញ្ចេញមតិ ការចរចា និង ការជះឥទ្ធិពលលើការសម្រេចចិត្តអំពីជម្រើសបែបយុទ្ធសាស្ត្រនៅក្នុងជីវិត។
- សមិទ្ធផល ៖ ភាពល្អប្រសើរឡើងដែលពោរពេញដោយអត្ថន័យនៃសុខមាលភាព និង លទ្ធផលនៃជីវិត ដែលបណ្តាលមកពីការប្រើប្រាស់ធនធាន និង កំណើនទីភ្នាក់ងារ (Kabeer ១៩៩៩)។

តាមរយៈការសម្លឹងមើលការផ្តល់ភាពអង់អាចដោយផ្តោតលើទស្សនវិស័យនេះ ជាដំបូង យើងចាំបាច់ត្រូវតែផ្តោតលើការធានាចំពោះការទទួលបានធនធានដោយស្មើភាព និង ការស្នើសុំមតិ

គាំទ្រដើម្បីបង្កើតការចូលរួមរបស់ស្ត្រី និង យុវជនដោយផ្ទាល់។ បន្ទាប់ពីយើងអាចធានាចំពោះការទទួលបានធនធានទាំងនេះយ៉ាងពេញលេញហើយ យើងនឹងអាចធ្វើការប៉ាន់ប្រមាណអំពីលទ្ធផល ដើម្បីសម្គាល់ឧបសគ្គណាមួយផ្សេងទៀត ដែលអាចកើតឡើងបាន ដែលនឹងត្រូវដោះស្រាយ ទោះបីជាឧបសគ្គផ្នែកវប្បធម៌ ផ្នែកសង្គម ឬ ផ្នែកនយោបាយក្តី។

ជំងឺរាតត្បាតសកល កូវីដ-១៩ បានពន្លឿននិន្នាការមួយចំនួន ដែលត្រូវបានចាប់ផ្តើមដោយបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន ដូចជា ឌីជីថលនីយកម្ម ប្រាជ្ញាសិប្បនិម្មិត និង ទិន្នន័យខ្នាតធំ។ ជំងឺកូវីដ-១៩ ក៏បានផ្តល់អំណាចយ៉ាងពេញលេញដល់រដ្ឋផងដែរ ដើម្បីផលប្រយោជន៍ផ្នែកសុខភាពសាធារណៈ រដ្ឋាភិបាលនៅទូទាំងអាស៊ី និង អឺរ៉ុបបានទទួលអំណាចនៅគ្រាអាសន្ន ដើម្បីធ្វើការបិទទ្វារប្រទេសយ៉ាងតឹងរ៉ឹង។ ដើម្បីមានសមត្ថភាពចូលរួមយ៉ាងពេញលេញនៅក្នុងសេដ្ឋកិច្ចថ្មី និង នៅក្នុងសង្គមដែលរដ្ឋាភិបាល និង ក្រុមសហគមន៍ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីផ្តល់សេវាកម្មប្រជាជននឹងចាំបាច់ត្រូវតែមានការប្រើប្រាស់អ៊ីនធឺណិត និង បច្ចេកវិទ្យាឌីជីថលស្មើៗគ្នា។

អ្វីដែលសំខាន់ជាងនេះទៀតនោះ ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីបង្រៀន និង ទទួលបានជំនាញ និង ការបណ្តុះបណ្តាលដែលចាំបាច់ ដើម្បីប្រើប្រាស់បច្ចេកវិទ្យាទាំងនេះបានយ៉ាងពេញលេញ។

របៀបវារៈ និង ចំណុចផ្តោតរបស់ ASEM ស្តីពីការតភ្ជាប់ បានទទួលស្គាល់រួចទៅហើយនូវសារសំខាន់នៃការផ្តល់ជំនួយដល់ស្ត្រី និង យុវជនដើម្បីធានាចំពោះការចូលរួមបានយ៉ាងមានប្រសិទ្ធភាពរបស់ពួកគេ នៅក្នុងសង្គម និង សេដ្ឋកិច្ច។ ការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន គឺជាបុរេលក្ខខណ្ឌតម្រូវ ដើម្បីភាពរីកចម្រើនរបស់សង្គម និង សេដ្ឋកិច្ចរបស់ពួកគេ។ ដើម្បីធ្វើឲ្យពួកគេបញ្ចេញសក្តានុពលរបស់ពួកគេបាន របៀបវារៈរបស់ ASEM ស្តីពីការតភ្ជាប់ ចាំបាច់ត្រូវតែដាក់ការតភ្ជាប់ឌីជីថល និង ការតភ្ជាប់ផ្នែកទន់ដែលកើតឡើងជាមួយគ្នានោះ នៅក្នុងវិស័យអប់រំ និង ធនធានមនុស្ស ជាអាទិភាព។

## សារសំខាន់នៃការតភ្ជាប់ផ្នែកឌីជីថល

បដិវត្តន៍ឌីជីថលបានផ្លាស់ប្តូរវិធីធ្វើការ ទទួលបានព័ត៌មាន និង តភ្ជាប់ជាមួយគ្នាទៅវិញទៅមករបស់យើង។ ICT ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងនាពេលបច្ចុប្បន្ន នៅក្នុងយុគសម័យឌីជីថល ដូចជា អ៊ីនធឺណិត និង ទូរស័ព្ទចល័ត នៅក្នុងចំណោមឧបករណ៍ដទៃទៀត មានសារសំខាន់កាន់តែខ្លាំងចំពោះការបំពេញមុខងារសេដ្ឋកិច្ចនៃសតវត្សរ៍ទី ២១។ ការពង្រីកការតភ្ជាប់ផ្នែកឌីជីថលនឹងពន្លឿនកំណើនសេដ្ឋកិច្ច។ យោងតាមការប៉ាន់ស្មានរបស់ធនាគារពិភពលោក ជាង ៥០% នៃ

ប្រជាជនពិភពលោកនៅតែអហ្វឡាញ។ ការកើនឡើងនៃភាគរយរបស់ប្រជាជនសរុបដែលបានតភ្ជាប់ទៅកាន់អ៊ីនធឺណិត ពី ៤៨% ទៅ ៧៥% បានបន្ថែមទឹកប្រាក់ចំនួន ២ ទ្រីលានដុល្លារក្នុងមួយឆ្នាំទៅលើ GDP ពិភពលោក និង ជួយបង្កើតការងារចំនួន ១៤០ លាន។ ដូច្នេះ ការធ្វើឲ្យអ៊ីនធឺណិតអាចប្រើប្រាស់បានជាសកល និង មានតម្លៃសមរម្យគួរតែជាអាទិភាពសកល។ ការតភ្ជាប់សម្រាប់មនុស្សគ្រប់រូប នៅតែជាគោលដៅអភិវឌ្ឍន៍ដ៏សំខាន់មួយ ប៉ុន្តែក៏ជាបញ្ហាប្រឈមដ៏ខ្លាំងក្លាមួយដែរ។[90]

ICT និង ការតភ្ជាប់ឌីជីថល មិនត្រឹមតែផ្តល់កំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែអាចត្រូវបានបំពាក់យ៉ាងមានប្រសិទ្ធភាពដើម្បីសម្រេច SDGs តាមរយៈការពង្រឹងអភិបាលកិច្ច និង ការសម្រេចបាននូវលទ្ធផលនៅក្នុងវិស័យអប់រំ និង សុខាភិបាលបានកាន់តែល្អថែមទៀតផង។

នៅខណៈពេលដែលអ៊ីនធឺណិត និង អ៊ីនធឺណិតល្បឿនលឿន (broadband) ត្រូវបានដកស្រង់ដោយប្រទេសជាច្រើនថាជាកត្តាសំខាន់ ដែលមានសក្តានុពលចំពោះការអភិវឌ្ឍប្រកបដោយចីរភាពនោះ ភាពខុសគ្នាយ៉ាងខ្លាំងនៅតែកើតឡើងចំពោះអ្នកដែលអាចប្រើប្រាស់ និង ទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាយ៉ាងពិតប្រាកដ។ សមាមាត្រដ៏ធំនៃចំនួនអ្នកដែលមិនបានតភ្ជាប់ គឺជាស្ត្រី។ សម្ព័ន្ធភាពដើម្បីអ៊ីនធឺណិតដែលមានតម្លៃសមរម្យ បានកត់សម្គាល់ថា ភាពខុសគ្នានៃយេនឌ័រមិនត្រឹមតែជា "ទិដ្ឋភាពដែលបង្កក្តីអន្តរាយខ្លាំងជាងគេបំផុតនៃការបែងចែកឌីជីថលនៅលើពិភពលោកប៉ុណ្ណោះទេ" ប៉ុន្តែថែមទាំងមានការកើនឡើងកាន់តែខ្លាំង ដែលគួរឲ្យព្រួយបារម្ភថែមទៀតផង។ ប្រសិនបើប្រៀបធៀបនឹងបុរស ស្ត្រីមិនសូវមានការតភ្ជាប់នោះទេ ហើយសូម្បីតែពេលដែលពួកគេនៅអនឡាញក៏ដោយ ពួកគេមិនសូវទំនងជានឹងប្រើប្រាស់វា ដើម្បីធ្វើឲ្យជីវិតរបស់ពួកគេមានភាពល្អប្រសើរឡើង ដូចបុរសនោះទេ។[91]

នៅពេលដែលសេដ្ឋកិច្ច និង សង្គមកំពុងតែត្រូវបានផ្លាស់ប្តូរដោយបច្ចេកវិទ្យាឌីជីថលនោះ ការសិក្សារបស់ OECD នៅឆ្នាំ២០១៨ បានរកឃើញថា ស្ត្រីដែលនៅអនឡាញ មានចំនួនតិចជាងបុរសរហូតដល់ ២៥០ លាននាក់ ។ នៅទូទាំងសកលលោក ស្ត្រីទំនងជាកាន់កាប់ទូរស័ព្ទចល័តតិចជាងបុរស ២១%។ ស្ត្រីជាច្រើននាក់ រស់នៅតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលទន់ខ្សោយ ហើយពួកគេមិនទំនងជាមានលទ្ធភាពទិញឧបករណ៍ឌីជីថល ទិញសេវាអ៊ីនធឺណិតល្បឿនលឿន ឬ

---

90 សូមមើលរបាយការណ៍នៃការអភិវឌ្ឍពិភពលោករបស់ធនាគារពិភពលោក ឆ្នាំ២០១៦ ស្តីពីភាគលាភឌីជីថល។

91 សូមមើលរបាយការណ៍រួមរបស់មូលនិធិ World Wide Web សម្ព័ន្ធភាពដើម្បីអ៊ីនធឺណិតដែលមានតម្លៃសមរម្យ និង UN Women ផងដែរ "មូលនិធិសេវាកម្ម និង ការប្រើប្រាស់ជាសកល៖ ធនធានដែលមិនទាន់បានប្រើប្រាស់ដើម្បីបិទការបែងចែកឌីជីថលទៅតាមយេនឌ័រ" ខែមីនា ឆ្នាំ២០១៨។ http://webfoundation.org/docs/2018/03/Using-USAFs-to-Close-the-Gender-Digital-Divide-in-Africa.pdf.

ទទួលបានការអប់រំ ដែលចាំបាច់សម្រាប់ការប្រើប្រាស់ និង បើកទូលាយសក្តានុពលនៃបច្ចេកវិទ្យាឌីជីថលនោះទេ។ ការបែងចែកយេនឌ័រនៅក្នុងវិស័យឌីជីថល គឺជាការពិត និង ពុំមានភាពជាតំណាងគ្រប់គ្រាន់របស់ស្ត្រីក្នុងលក្ខណៈជាប្រព័ន្ធ នៅក្នុងការងារ ICT។[92]

ការទទួលបានរបស់ស្ត្រី នូវការអប់រំ ការថែទាំសុខភាព សេវារដ្ឋាភិបាល ឱកាសការងារ និងធនធានដទៃទៀតដែលចាំបាច់ចំពោះការងាររបស់ពួកគេ អាចត្រូវបានពង្រឹងតាមរយៈបច្ចេកវិទ្យាឌីជីថល និង ការតភ្ជាប់។ ជារួម ការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម និង ការផ្តល់ភាពអង់អាច នៅពេលនេះគឺលើសពីអ្វីដែលធ្លាប់ទទួលរងផលប៉ះពាល់ពីការទទួលបាននិងការប្រើប្រាស់អ៊ីនធឺណិត និង បច្ចេកវិទ្យាចល័តរបស់ពួកគេ។ ប៉ុន្តែ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការតភ្ជាប់មិនគ្រប់គ្រាន់ និង កង្វះខាតការទទួលបានបច្ចេកវិទ្យា រារាំងស្ត្រីពីការទទួលបានអត្ថប្រយោជន៍យ៉ាងពេញលេញ។

ការមានបច្ចេកវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធទាំងនេះគឺជារឿងមួយ ប៉ុន្តែមានឧបសគ្គមួយទៀតដែលចូលមករារាំង នៅពេលនិយាយអំពីការផ្តល់ភាពអង់អាចដល់ស្ត្រី នោះគឺវេទិកានៃការអប់រំ និង ការបណ្តុះបណ្តាល ដើម្បីធានាថា ស្ត្រីទទួលបានអត្ថប្រយោជន៍យ៉ាងពេញលេញពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង បច្ចេកវិទ្យាចល័ត។

ការលម្អៀងចំពោះយេនឌ័រ និង ផ្នត់គំនិត និង និយាមវប្បធម៌សង្គម ដែលមានជាប់មកជាមួយ នៅតែបន្តបង្កឧបសគ្គចំពោះការផ្តល់ជំនាញ និង សមត្ថភាពដល់ស្ត្រី ដើម្បីធានាចំពោះបរិយាប័ន្នផ្នែកឌីជីថល។

ជារួម ICT មានសក្តានុពលយ៉ាងខ្លាំងក្លាចំពោះការផ្តល់ភាពអង់អាចដល់ស្ត្រី។ ទោះបីជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធនឹងការប្រើប្រាស់ ICT មានការសង្កេតមើលការបែងចែកយេនឌ័រ។ ប្រសិនបើការបែងចែកយេនឌ័រមិនត្រូវបានដោះស្រាយជាពិសេសទេនោះ មានហានិភ័យដែល ICT អាចធ្វើឲ្យវិសមភាពដែលមានស្រាប់ មានសភាពកាន់តែធ្ងន់ធ្ងរឡើង។

ស្រដៀងគ្នានេះដែរ សក្តានុពលសម្រាប់ ICT នៅក្នុងការគាំទ្រការអភិវឌ្ឍរបស់យុវជនមានភាពខ្លាំងក្លា នៅក្នុងទ្រឹស្តី ប៉ុន្តែមានយុវជនជាច្រើននាក់នៅទូទាំងពិភពលោកនៅតែប្រឈមមុខនឹងឧបសគ្គនានាដដែល នៅពេលនិយាយអំពីការទទួលបាន ICT និង ការប្រើប្រាស់ឧបករណ៍ទាំងនេះបានយ៉ាងមានប្រសិទ្ធភាព។ ឧបសគ្គនានា ដូចជា កង្វះខាតបណ្តាញចល័ត ឬ អ៊ីនធឺណិតល្បឿនលឿន និង ការទទួលបានការតភ្ជាប់នៅកម្រិតមូលដ្ឋាន និង លទ្ធភាពក្នុងការផ្គត់ផ្គង់ទូរស័ព្ទ

[92] របាយការណ៍ OECD "ការតភ្ជាប់ការបែងចែកឌីជីថលទៅតាមយេនឌ័រ៖ រួមបញ្ចូល បង្កើនជំនាញ នវានុវត្តន៍" ឆ្នាំ ២០១៨. http://www.oecd.org/ internet/bridging-the-digital-gender-divide.pdf.

ដៃ និង សេវាទិន្នន័យចល័ត មានន័យថា យុវជនជាច្រើននាក់មិនអាចប្រើប្រាស់សក្តានុពលរបស់ ICT ដើម្បីការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេបានយ៉ាងពេញលេញនោះទេ។ មានការបែងចែកផ្នែកឌីជីថលយ៉ាងខ្លាំងក្លា រវាងយុវជន និង អ្នកដែលមានអាយុលើសពី ៤៥ឆ្នាំ។

បន្ទាប់មក ក៏មានចម្ងល់អំពីការអប់រំ និង ការបណ្តុះបណ្តាលផងដែរ។ សូម្បីតែយុវជនដែលទទួលបានការតភ្ជាប់ផ្នែកឌីជីថលបានយ៉ាងងាយស្រួល និង ត្រូវបានមើលឃើញថា បានកើតនៅក្នុងយុគសម័យឌីជីថលហើយ ក៏គោលនយោបាយនៃការអប់រំដែលហួសសម័យ កង្វះខាតសមត្ថភាពក្នុងការបណ្តុះបណ្តាល និង ភាពបរាជ័យផ្នែកទីផ្សារអាចដាក់កម្រិតលើសមត្ថភាពរបស់ប្រជាជនវ័យក្មេងនៅក្នុងការចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ចឲ្យបានពេញលេញដែរ។ ភាពមិនត្រូវនឹងជំនាញគឺជាបញ្ហាជាក់ស្តែងមួយ និង ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអត្រាដ៏ខ្ពស់នៃភាពគ្មានការងារធ្វើរបស់យុវជន នៅក្នុងប្រទេសជាច្រើន នៅទូទាំងអាស៊ី និង អឺរ៉ុប។ ការវិនិយោគលើ ICT និង ការតភ្ជាប់ផ្នែកឌីជីថល ត្រូវតែដើរទន្ទឹមគ្នានឹងការវិនិយោគលើវិស័យអប់រំ និង ការបណ្តុះបណ្តាល ដើម្បីផ្តល់ភាពអង់អាចដល់ យុវជននៅក្នុងការជ្រើសរើស នៅក្នុងវិស័យសេដ្ឋកិច្ច។ ការផ្តល់ជូនយុវជននូវជំនាញ ឌីជីថល អាចពង្រឹងឱកាសការងាររបស់ពួកគេ។

នៅក្នុងប្រទេស ASEM ជាច្រើន តម្រូវការក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីទទួលបានអត្ថប្រយោជន៍ពីការតភ្ជាប់ឌីជីថល ត្រូវបានរៀបចំឡើងបានយ៉ាងល្អ ដូចជាពីប្រទេសបង់ក្លាដេសនៅភាគខាងត្បូង ទៅប្រទេសម៉ុងហ្គោលនៅភាគខាងជើង។ វេទិកា ASEM អាចត្រូវបានប្រើប្រាស់ដើម្បីសម្របសម្រួល និង នាំមកនូវកិច្ចខិតខំប្រឹងប្រែងនៃភាពជាដៃរវាងរដ្ឋ និង ឯកជន នៅក្នុងការវិនិយោគទាំងនេះ។ ចំណុចដែលសំខាន់ជាងនេះទៀត ដៃគូ ASEM អាចរួមដៃគ្នា និង "ពង្រឹងគំនិតផ្តួចផ្តើមរបស់ពួកគេ ដែលបង្កើតតម្រូវការនៃការបញ្ជូនទិន្នន័យជាអន្តរជាតិកាន់តែខ្លាំងក្លា"។ គំនិតផ្តួចផ្តើមទាំងនេះអាចរួមបញ្ចូលការគាំទ្រដល់ការពង្រីកបណ្តាញអ៊ីនធឺណិតល្បឿនលឿនរបស់វិស័យឯកជន និង កំណើននៃពាណិជ្ជកម្ម និង សេដ្ឋកិច្ចឌីជីថល រវាងអាស៊ី និង អឺរ៉ុបផងដែរ។

ការគាំទ្ររបស់ ASEM ទាំងនោះ នឹងបំពេញបន្ថែមលើវត្ថុបំណងដែលត្រូវបានកំណត់នៅក្នុងផែនការមេ អាស៊ាន ICT ឆ្នាំ២០២០ និង យុទ្ធសាស្ត្រទីផ្សារតែមួយនៅក្នុងវិស័យឌីជីថលរបស់អឺរ៉ុប (Lallana ២០១៦)។

ជំងឺរាតត្បាតសកល កូវីដ-១៩ បានធ្វើឲ្យការតភ្ជាប់ឌីជីថល និង ការប្រើប្រាស់ ICT មានសារសំខាន់កាន់តែខ្លាំងឡើងចំពោះការអភិវឌ្ឍសេដ្ឋកិច្ចរបស់ ASEM។ ជំងឺកូវីដ-១៩ មិនមែន

គ្រាន់តែជាវិបត្តិសុខភាពនោះទេ។

វាបានបំផ្លាញជីវិតរបស់មនុស្សរាប់ពាន់លាននាក់។ ដោយមានការបិទទ្វារប្រទេសនៅទូទាំងពិភពលោក និង វិធានការយ៉ាងតឹងរ៉ឹងនៅក្នុងការបិទសាលារៀន មនុស្សរាប់ពាន់លាននាក់ត្រូវបង្ខំចិត្តស្នាក់នៅក្នុងផ្ទះ និង នៅឆ្ងាយពីសាលារៀន។ ជំងឺកូវីដ-១៩ មានផលប៉ះពាល់មិនស្មើគ្នាចំពោះស្ត្រី និង យុវជន។ កុមារី និង ស្ត្រីវ័យក្មេង ទំនងជាមនុស្សដំបូងគេដែលត្រូវដកចេញពីសាលារៀន និង ប្រហែលជាមិនអាចត្រឡប់ទៅសាលារៀនវិញបាននោះទេ ដោយសារតែបច្ច័យផ្នែកសេដ្ឋកិច្ចដែលពួកគេបានដឹងយ៉ាងច្បាស់។ ILO បានប្រមើលមើលថា នឹងមានកំណើនភាពគ្មានការងារធ្វើចន្លោះពី ៥,៣ លាននាក់ ទៅ ២៤,៧ លាននាក់ ដោយសារ ជំងឺកូវីដ-១៩។

តម្រូវការក្នុងការប្រើវេទិកាអនឡាញដើម្បីធ្វើការ ដើម្បីទទួលបានការអប់រំ និង សេវាកម្មបានធ្វើឲ្យវិសមភាពដែលមានស្រាប់ លេចរូបរាងយ៉ាងច្បាស់ ដែលបែងចែកប្រទេសដែលមាន និង ប្រទេសដែលគ្មានហេដ្ឋារចនាសម្ព័ន្ធឌីជីថលល្អ។ យោងតាមសហភាពទូរគមនាគមន៍អន្តរជាតិរបស់ UN មុនពេលផ្ទុះរាតត្បាតជំងឺកូវីដ-១៩ មានប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែ ៤៧% ប៉ុណ្ណោះដែលប្រើប្រាស់អ៊ីនធឺណិត បើធៀបនឹងប្រជាជនចំនួន ៨៦% នៅក្នុងប្រទេសអភិវឌ្ឍន៍។ ការបែងចែកផ្នែកឌីជីថលបែបនោះនឹងពង្រីកការបែងចែកផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំង ពីព្រោះជំងឺរាតត្បាតសកលបានបង្ខំឲ្យមនុស្សត្រូវ "ស្នាក់នៅក្នុងផ្ទះ"។ នៅកន្លែងដែលមិនអាចប្រើប្រាស់អ៊ីនធឺណិតបាន ឬ ការប្រើប្រាស់អ៊ីនធឺណិតដែលមិនគួរឲ្យទុកចិត្តបាន ការផ្តល់ការអប់រំអនឡាញមានវិសមភាពយ៉ាងខ្លាំង និង ធ្វើការឲ្យមានប្រែប្រួល ពាក់ព័ន្ធនឹងការរីករាលដាលនៃវិសមភាព។

ASEM ក្នុងនាមជាវេទិកាមួយដែលនាំ ៥១ ប្រទេស មកពីភាគខាងជើង និង ភាគខាងត្បូង ដែលមានទាំងសេដ្ឋកិច្ចអភិវឌ្ឍន៍ និង កំពុងអភិវឌ្ឍន៍ មកជួបជុំគ្នា ចាំបាច់ត្រូវដាក់អាទិភាពលើការបិទការបែងចែកផ្នែកឌីជីថល តាមរយៈការវិនិយោគលើការតភ្ជាប់ផ្នែកឌីជីថល។ ការសម្រេចបានការប្រើប្រាស់អ៊ីនធឺណិតដែលមានតម្លៃសមរម្យ គួរតែជាចំណុចអាទិភាពដ៏សំខាន់មួយនៅក្នុងរបៀបវារៈរបស់ ASEM។ សក្តានុពលសម្រាប់ដៃគូចម្រុះរបស់ ASEM ដូចជា ប្រទេសចិន ប្រទេសជប៉ុន និង EU ក្នុងការធ្វើការរួមគ្នាជាមួយប្រទេសម្ចាស់ផ្ទះ នៅទូទាំងអាស៊ី និង អឺរ៉ុប ដើម្បីបង្កើតផ្លូវសូត្រឌីជីថលមួយ គួរតែស្ថិតនៅខាងលើបំផុតនៃរបៀបវារៈរបស់ ASEM។ ការតភ្ជាប់ផ្នែកឌីជីថលគួរតែប្រែជាមានភាពចាំបាច់មិនតិចជាងអគ្គិសនី និង ទឹកនោះទេ។

ជាមួយគ្នានឹងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្នែករឹងនៃការតភ្ជាប់ឌីជីថល ក៏មានភាពចាំបាច់ដូចគ្នា នៅក្នុងការពង្រីកការតភ្ជាប់នៅក្នុងខ្លឹមសារ និង ហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ដទៃទៀត

ដែរ នៅក្នុងទម្រង់នៃការផ្លាស់ប្តូរការអប់រំ ដោយមានវគ្គសិក្សាតាមអនឡាញដែលមានភាពលឿនលឿនបំផុត អន្តរកម្មផ្អែកវប្បធម៌ ការបណ្តុះបណ្តាលឆ្លងដែន និង ការបង្រៀន។ នេះគឺជាអ្វីដែលខ្ញុំនឹងហៅរួមគ្នាថា "ការតភ្ជាប់ផ្អែកអប់រំ និង ធនធានមនុស្ស"។ ការអប់រំ ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ គួរតែជួយរៀបចំខ្លួនរបស់ស្ត្រី និង យុវជនរបស់ ASEM សម្រាប់ការផ្លាស់ប្តូរលក្ខណៈនៃការធ្វើការ និង អភិបាលកិច្ច។

ដូច្នេះ ការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន មិនត្រឹមតែត្រូវការការទទួលបានការតភ្ជាប់ផ្អែករូបវន្ត និង ធនធានសម្ភារតែប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៀត គឺធនធានសង្គម ដូចជា ចំណេះដឹង ឥរិយាបថ និង ជំនាញដែលអាចពង្រឹងទីភ្នាក់ងារ និង សមត្ថភាពរបស់ពួកគេក្នុងការជ្រើសរើស និង ធ្វើការសម្រេចចិត្ត និង ពង្រឹងសុខមាភាព និង លទ្ធផលនៃជីវិតរបស់ពួកគេឲ្យកាន់តែល្អប្រសើរឡើង។

## ការអប់រំ និង ការតភ្ជាប់ផ្អែកធនធានមនុស្ស

ជំងឺរាតត្បាតសកលកូវីដ-១៩ បានបង្ខំឲ្យសាលារៀន និង សាកលវិទ្យាល័យត្រូវបិទទ្វារអស់រយៈពេលជាច្រើនខែ នៅប្រទេសជាច្រើន ។ ការរៀនសូត្រនៅផ្ទះសម្រាប់សិស្ស ការបង្រៀន និង ការបង្កើតថ្នាក់រៀនតាមអនឡាញសម្រាប់និស្សិតសាកលវិទ្យាល័យ គឺជាការពិតសម្រាប់កុមារ និង យុវជនរាប់លាននាក់។

ប៉ុន្តែ ជំងឺរាតត្បាតសកលក៏បានបង្ហាញអំពីភាពខុសគ្នាយ៉ាងខ្លាំង រវាងការទទួលបានការរៀនសូត្រ នៅក្នុងប្រទេស និង តំបន់ដែលមានការតភ្ជាប់ផ្អែកឌីជីថលល្អ និង នៅក្នុងប្រទេស និង តំបន់ដែលគ្មានការតភ្ជាប់អ៊ីនធឺណិត និង ការតភ្ជាប់ចល័ត ដែលមានល្បឿនលឿន និង មានលំនឹង។ ដូច្នេះ រដ្ឋាភិបាលមានអាទិភាពនៅក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដើម្បីការតភ្ជាប់ផ្អែកឌីជីថល។

ការតភ្ជាប់ផ្អែកឌីជីថលល្អក៏នឹងបើកចំហរផ្លូវដែលមានគំនិតច្នៃប្រឌិតនិងមានទិដ្ឋភាពខុសៗគ្នាកាន់តែច្រើន សម្រាប់ស្ត្រី និង យុវជននៅទូទាំងអាស៊ី និង អឺរ៉ុប ដើម្បីទទួលបានការអប់រំទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ។ ការអប់រំក្នុងប្រព័ន្ធនៅសាលារៀន និង គ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា រួមទាំងការអប់រំក្រៅប្រព័ន្ធដែលកំណត់គោលដៅអនុវត្តចំពោះស្ត្រី និង យុវជន ដើម្បីផ្តល់ជូនពួកគេនូវជំនាញនានា ដូចជា អក្ខរកម្មហិរញ្ញវត្ថុ និង ការប្រាស្រ័យទាក់ទង។ល។ ក៏នឹងប្រែទៅជាអាចទទួលបាន និង មានពិពិធភាពកាន់តែខ្លាំង។ ដូច្នេះ ការអប់រំ ព័ត៌មាន និង ឧបករណ៍ទំនាក់ទំនង មានសារសំខាន់ចំពោះការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជន ដែលជាលទ្ធផល

អាចឈានទៅរកសង្គមដែលបំពេញ មុខងារបានល្អជាងមុន។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនប្រទេសនៃ ASEM ប្រព័ន្ធអប់រំត្រូវបានដាក់កំហិតដោយសារកង្វះខាតធនធាន។ ការផ្តល់ការអប់រំល្អត្រូវបានរារាំងដោយសារកង្វះគ្រូបង្រៀន និង សម្ភាររៀនសូត្រ។ សូម្បីតែនៅក្នុងប្រទេសដែលមានការអភិវឌ្ឍខ្លាំងជាងនៃ ASEM ក៏ប្រព័ន្ធអប់រំមួយចំនួននៅតែមានភាពយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាដែលបង្កឡើងដោយបច្ចេកវិទ្យាជឿនលឿនដែរ។ ការមិនត្រូវនឹងជំនាញ ដែលត្រូវបានបញ្ជាក់ គឺជាភ័ស្តុតាងចំពោះការពិតដែលថា ប្រព័ន្ធអប់រំក្នុងប្រព័ន្ធដើរត្រឡប់ក្រោយ និង មិនបានត្រៀមខ្លួនយុវជនសម្រាប់សេដ្ឋកិច្ចនាថ្ងៃអនាគតនោះទេ។ ការអប់រំអំពី ICT នៅក្នុងប្រទេសនានានៃ ASEM ក៏មិនស្មើគ្នាដែរ ដោយមានភាពខុសគ្នាយ៉ាងខ្លាំងក្លាទាំងនៅក្នុងតំបន់ និង អន្តរតំបន់។

ដោយមានការតភ្ជាប់ផ្នែកឌីជីថលដែលល្អប្រសើរជាងមុន រវាងអាស៊ី និង អឺរ៉ុប តើវេទិកា ASEM អាចត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចខ្លះ ដើម្បីពង្រឹង និង បង្កើនការតភ្ជាប់ផ្នែកអប់រំ និង ធនធានមនុស្ស ដើម្បីផ្តល់វគ្គសិក្សា និង ជំនាញដែលគួរឲ្យចាប់អារម្មណ៍ ជាប់ពាក់ព័ន្ធ និង មានគុណភាពល្អដល់ស្ត្រី និង យុវជននៃ ASEM ?

ចំពោះការអប់រំផ្លូវការ រដ្ឋមន្ត្រីអប់រំនៃ ASEM អាចលើកកម្ពស់ការផ្លាស់ប្តូរការអប់រំអនទ្បាញរវាងសាលារៀន និង សាកលវិទ្យាល័យនានាបានយ៉ាងសកម្ម។ សន្និសីទរបស់សាកលវិទ្យាធិការនៃ ASEM គួរតែផ្តោតកិច្ចខិតខំប្រឹងប្រែងលើរបៀបដែលសាកលវិទ្យាល័យទូទាំងអាស៊ី និង អឺរ៉ុបគួរតែរួមកម្លាំងគ្នាដើម្បីផ្តល់វគ្គសិក្សាដែលផ្តល់ភាពអង់អាចដល់ប្រជាជនវ័យក្មេង ក្នុងការគិត និង ធ្វើសកម្មភាពលើបញ្ហាប្រឈមនានានៅថ្នាក់តំបន់ អន្តរតំបន់ និង ជាសកល។ សាកលវិទ្យាល័យក៏គួរតែធ្វើការជាមួយឧស្សាហកម្ម និង សាជីវកម្មដើម្បីផ្តល់ចំណេះដឹង និង ជំនាញដែលចាំបាច់សម្រាប់សេដ្ឋកិច្ចថ្មីផងដែរ។ ការរចនាកម្មវិធីសិក្សាថ្មីមួយ ដែលបណ្តុះគំនិត និង គាំទ្រដល់ការរៀនសូត្រពេញមួយជីវិត នៅក្នុងចំណោមសិស្ស និង វគ្គសិក្សានានា ដើម្បីធ្វើឲ្យពួកគេអាចបន្តទទួលបានអត្ថប្រយោជន៍ពីកម្មវិធីសិក្សានេះនៅក្រោយពេលបញ្ចប់ការសិក្សា និង ពេញមួយជីវិតការងាររបស់ពួកគេ គួរតែជាវត្ថុបំណងដ៏សំខាន់នៃកំណែទម្រង់ណាមួយ ដោយសាកលវិទ្យាល័យដើម្បីត្រៀមខ្លួននិស្សិតដែលបានបញ្ចប់ការសិក្សារបស់ពួកគេ សម្រាប់ពិភពលោកដែលប្រែប្រួលយ៉ាងឆាប់រហ័ស។

ប្រទេសនានានៃ ASEM គួរតែវិនិយោគលើមជ្ឈមណ្ឌលអប់រំ និង ស្រាវជ្រាវ សម្រាប់ការរៀនសូត្រពេញមួយជីវិតរបស់ ASEM (មជ្ឈមណ្ឌល LLL របស់ ASEM)។ ដោយត្រូវបានបង្កើតឡើង

នៅក្នុងឆ្នាំ២០០៥ ក្នុងនាមជាបណ្តាញស្ថាប័នអប់រំកម្រិតខ្ពស់នៅអាស៊ី និង អឺរ៉ុប ដែលធ្វើការរួមគ្នាដើម្បីសម្រេចបានភាពល្អឥតខ្ចោះនៃការស្រាវជ្រាវតាមបែបប្រៀបធៀប អំពីការរៀនសូត្រពេញមួយជីវិត មជ្ឈមណ្ឌល LLL របស់ ASEM ផ្តល់វេទិកា និង រួមចំណែកដល់កិច្ចសន្ទនារវាងអ្នកស្រាវជ្រាវ អ្នកអនុវត្ត និង អ្នកបង្កើតគោលនយោបាយស្តីពីកំណែទម្រង់ និង នវានុវត្តន៍នៃវិស័យអប់រំ។[93]

ពិពិធភាពផ្នែកវប្បធម៌ ភាសា និង ការអភិវឌ្ឍននៅក្នុង ASEM អាចបើកចំហរឱកាសដ៏ធំធេងសម្រាប់ការប្រើប្រាស់ចំណុចខ្លាំងរបស់ស្ថាប័នអប់រំ និង គរុកោសល្យខុសគ្នា និង ក្របខណ្ឌនៃការបង្រៀនផ្សេងៗគ្នា ប្រកបដោយគំនិតច្នៃប្រឌិត ដើម្បីបង្ហាញអំពីក្រុមស្ថាប័នផ្តល់ការអប់រំដ៏គួរឲ្យចាប់អារម្មណ៍មួយ។ ចំណុចទាំងអស់នេះអាចត្រូវបានផ្តល់ជូនតាមរយៈក្របខណ្ឌឌីជីថល ទៅកាន់យុវជននៅក្នុងប្រទេសនានានៃ ASEM ដើម្បីជួយឲ្យពួកគេអភិវឌ្ឍជំនាញដែលចាំបាច់ – ពីការគិតគូរអំពីវប្បធម៌ទៅការយល់ចិត្តអ្នកដទៃ ពីការប្រាស្រ័យទាក់ទងអន្តរវប្បធម៌ទៅទីផ្សារអន្តរជាតិ ពីអក្ខរកម្មផ្នែកហិរញ្ញវត្ថុទៅ fintech និង ជាច្រើនទៀត។

មូលនិធិអាស៊ី-អឺរ៉ុប (ASEF) មានគម្រោងបន្តបន្ទាប់ក្នុងវិស័យអប់រំដ៏គួរឲ្យចាប់អារម្មណ៍ ដែលមានបំណងអនុវត្តចំពោះកុមារ និង យុវជនជាសិស្សសាលា ដែលគួរតែអភិវឌ្ឍបន្ថែមទៀត។ ឧទាហរណ៍៖ មានបណ្តាញថ្នាក់រៀននៅអាស៊ី-អឺរ៉ុប ដែលជាវេទិកាមួយសម្រាប់ការរៀនសូត្ររួមគ្នា និង ផ្លាស់ប្តូរអន្តរវប្បធម៌ នៅក្នុងចំណោមសិស្សវិទ្យាល័យ នៅអាស៊ី និង អឺរ៉ុប។ ដើម្បីកែប្រែស្ថានការណ៍ជាតិនិយមដែលមានគ្រោះថ្នាក់ និង លើកកម្ពស់ វប្បធម៌នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ASEF អាចធ្វើការជាមួយស្ថាប័នអប់រំនៅទូទាំង ASEM ដើម្បីរៀបចំកម្មវិធីសិក្សាសម្រាប់ភាពជាពលរដ្ឋសកល ដែលអាចស្វែងរកបាននៅគ្រប់សាលារៀនទាំងអស់នៅក្នុង ASEM។ ជំងឺរាតត្បាតសកល កូវីដ-១៩ បានលាតត្រដាងការពឹងផ្អែកគ្នាទៅវិញទៅមករបស់យើង និង ដូច្នេះតម្រូវការក្នុងការបង្កើនការយល់ដឹងអំពីបញ្ហាដែលកំពុងតែលេចឡើងជាសកល និង បង្កើតការយល់ដឹងទៅវិញទៅមកអំពីអ្វីដែលពលរដ្ឋសកលត្រូវធ្វើនៅក្នុងកិច្ចសហការ និង ការបង្កើតដំណោះស្រាយរួមគ្នាចំពោះបញ្ហាប្រឈមជាសកល។

ចំណុចអាទិភាពមួយទៀតដែលត្រូវយកមកពិចារណាអំពីលទ្ធផលនៃជំងឺរាតត្បាតសកល កូវីដ-១៩ គឺរបៀបដោះស្រាយចំពោះយុវជន និង មនុស្សវ័យក្មេងដែលបញ្ចប់ការសិក្សានៅពេលដែលមានបញ្ហាប្រឈមដ៏ខ្លាំងក្លាបំផុតនេះដែលហ៊ុំព័ទ្ធដោយភាពគ្មានការងារធ្វើភាពប្រកួតប្រជែងដ៏ខ្លាំងក្លា និង ការរំខានផ្នែកសេដ្ឋកិច្ច។ ក្រុមយុវជនដែលបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ មហាវិទ្យាល័យ និង សាកលវិទ្យាល័យ នៅឆ្នាំ២០២០-២០២១ នឹងប្រឈមមុខនឹងបញ្ហា

93 យោងតាមគេហទំព័រ៖ https://asemlllhub.org/។

ប្រឈមពិសេសៗ ជាពិសេសនៅក្នុងទីផ្សារការងារ។ វិបត្តិកូវីដ-១៩ អាចមានផលប៉ះពាល់រយៈពេលវែងលើក្រុមសិស្ស-និស្សិតទាំងនេះ។ ការសិក្សាបានបង្ហាញថា ការចូលក្នុងទីផ្សារការងារក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែងចំពោះប្រាក់ចំណូលនាពេលអនាគត។

អាជីពរបស់ក្រុមយុវជននេះនឹងទទួលរងផលជះយ៉ាងធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩។ រដ្ឋមន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍយុវជននៅបណ្ដាប្រទេសនៃ ASEM គួរតែធ្វើការតភ្ជាប់ ដើម្បីផ្លាស់ប្ដូរព័ត៌មាន និង បទពិសោធន៍ផ្នែកគោលនយោបាយលើវិធានការភ្លាមៗ និង វិធានការរយៈពេលមធ្យមមួយចំនួន ដើម្បីជួយក្រុមយុវជននេះ។

អ្វីដែលអាចធ្វើបានដើម្បីតភ្ជាប់ពួកគេ ដើម្បីពង្រឹងជំនាញនានា ដូចជា សហគ្រិនភាព ទីផ្សារឌីជីថល។ល។ គួរតែត្រូវបានយកមកពិចារណា។ តើជំនាញណាខ្លះដែលចាំបាច់សម្រាប់ "សេដ្ឋកិច្ចពីចម្ងាយ"? តើបណ្ដាប្រទេសនៃ ASEM អាចចែករំលែកបទពិសោធន៍របស់ពួកគេស្ដីពីការបង្កើតការងារ ការគាំទ្រការងារ និង សិក្ខាកាម កម្មវិធីហាត់ការ និង ពិចារណាអំពីកិច្ចសហប្រតិបត្តិការឆ្លងព្រំដែនដើម្បីចូលរួមនៅក្នុងកម្មវិធីរបស់គ្នាទៅវិញទៅមក។

បញ្ហាចម្បងមួយនៅក្នុងការពិចារណាអំពីការផ្ដល់ភាពអង់អាចដល់យុវជន គឺវិធីដោះស្រាយការប្រកួតប្រជែងក្នុងវិស័យការងារដែលកំពុងតែមានការកើនឡើង ដោយសារការងារកាន់តែច្រើន "ផ្លាស់ទៅផ្ទះ" ពីព្រោះការធ្វើការពីផ្ទះទទួលបានប្រជាប្រិយភាពក្រោយពេលមានជំងឺរាតត្បាតសកល។ ក្រុមហ៊ុនបច្ចេកវិទ្យាធំៗជាច្រើនបានប្រកាសថា ពួកគេកំពុងធ្វើសកម្មភាពដើម្បីធ្វើឲ្យការធ្វើការពីផ្ទះមានភាពអចិន្ត្រៃយ៍នៅកម្រិតណាមួយ។ ហ្វេសប៊ុកបាននិយាយថា ខ្លួនរំពឹងទុកថាជាងពាក់កណ្ដាលនៃនិយោជិតទាំង ៤៥.០០០ នាក់របស់ខ្លួន នឹងធ្វើការពីផ្ទះ នៅក្នុងរយៈពេល ១០ ឆ្នាំបន្ទាប់ទៀត។ ប្រាកដណាស់ សមត្ថភាពក្នុងការធ្វើការពីផ្ទះ ស្របពេលនឹងការផ្ដល់ភាពអង់អាចមួយចំនួន មានន័យថា ភាពប្រកួតប្រជែងក្នុងវិស័យការងារមានការកើនឡើង។

មានការងារកាន់តែច្រើនដែលបើកចំហរសម្រាប់ការប្រកួតប្រជែងជាសកល។ ក្នុងចំណោមការងារទាំងនេះ ភាគច្រើនជាប្រភេទការងារជាប់កិច្ចសន្យា ដោយបន្ថែមភាពមិនច្បាស់លាស់ និងអសន្តិសុខដល់អ្នកធ្វើការ។ ការប្រើប្រាស់ប្រព័ន្ធឌីជីថល និង ការធ្វើការពីចម្ងាយបើកចំហរទាំងឱកាស និង បញ្ហាប្រឈម។ ការផ្ដល់ភាពអង់អាចដល់យុវជនដើម្បីឲ្យពួកគេស្វែងយល់ទាំងអំពីឱកាស និង បញ្ហាប្រឈមទាំងនោះ គួរតែជាអាទិភាពមួយនៅក្នុងរបៀបវារៈរបស់ ASEM។

ចំពោះការផ្ដល់ភាពអង់អាចដល់ស្ត្រីនៅក្នុងយុគសម័យឌីជីថល មានរឿងជាច្រើនដែលចាំបាច់ត្រូវធ្វើ។ ដូចបានកត់សម្គាល់នៅខាងលើ ការបែងចែកយេនឌ័រនៅក្នុងប្រព័ន្ធឌីជីថល មានទំហំធំ

ណាស់។ ជំងឺកូវីដ-១៩ នឹងធ្វើឲ្យការបែងចែកនេះមានសភាពកាន់តែធ្ងន់ធ្ងរឡើង។

ការបែងចែកនេះត្រូវបានបង្ហាញឲ្យឃើញនៅក្នុងទិដ្ឋភាពខុសៗគ្នា។ ឧទាហរណ៍៖ ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទទួលបានការប្រើប្រាស់អ៊ីនធឺណិត និង បច្ចេកវិទ្យាចល័តបានតិចជាង នៅខណៈពេលស្ត្រីនៅក្នុងប្រទេសអភិវឌ្ឍន៍ប្រហែលជាគ្មានបញ្ហាចំពោះការប្រើប្រាស់នេះនោះទេ ផ្ទុយមកវិញ ពួកគេអាចប្រឈមមុខនឹងគម្លាតយេនឌ័រនៅក្នុងវិស័យវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា ដែលមានការកើនឡើងទៅតាមយុគសម័យ ព្រមទាំងការមានតំណាងមិនបានគ្រប់គ្រាន់ជាប្រព័ន្ធរបស់ស្ត្រីនៅក្នុងការងារ ICT និង ក្រុមហ៊ុនបច្ចេកវិទ្យាដែលទើបបង្កើតថ្មី។[94]

ក្រៅពីការដោះស្រាយបញ្ហាការប្រើប្រាស់នេះ (ដែលបណ្តាប្រទេសនៃ ASEM គួរតែផ្តល់អាទិភាព តាមរយៈការវិនិយោគលើការតភ្ជាប់ផ្នែកឌីជីថល) ទៀតនោះ គម្លាតជាច្រើននឹងត្រូវដោះស្រាយ ពាក់ព័ន្ធនឹងការអប់រំ និង ការបណ្តុះបណ្តាល។ ស្ថាប័នអប់រំ និង ស្ថាប័នបណ្តុះបណ្តាល រួមជាមួយស្ថាប័នគោលនយោបាយសង្គម ចាំបាច់ត្រូវធ្វើការជាមួយគ្នា ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដែលអាចរៀបចំ និង ផ្តល់អំណាចដល់ស្ត្រី សម្រាប់ការចាប់យកឱកាសដែលផ្តល់ជូនដោយបច្ចេកវិទ្យាបានកាន់តែច្រើនបន្ថែមទៀត។

ការមានវគ្គបណ្តុះបណ្តាលដែលមានភាពបត់បែននៅក្នុងកាលវិភាគ និង មេរៀន នៅក្នុងការរចនា នឹងជួយលុបចោលឧបសគ្គចំពោះការអប់រំមិនផ្លូវការ និង ការបណ្តុះបណ្តាលរបស់ស្ត្រី។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលកាន់តែសំខាន់ជាងវគ្គបណ្តុះបណ្តាលទៀតនោះគឺ គ្រោងការណ៍នៃការបង្ហាត់បង្រៀន និង ការគាំទ្រ ដែលអាចជួយឲ្យស្ត្រីចូលទៅក្នុងវិស័យនានានៃ STEM និង ឧស្សាហកម្មបច្ចេកវិទ្យា។ ការសិក្សាបានបង្ហាញថា វិធីដ៏ល្អបំផុតមួយ នៅក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅកន្លែងធ្វើការ និង បង្កើតភាពជាអ្នកដឹកនាំប្រកបដោយចីរភាពរបស់ស្ត្រី គឺតាមរយៈការបង្ហាត់បង្រៀនដែលមានរចនាសម្ព័ន្ធ ដែលស្ត្រីអាចរៀនពីគ្នាទៅវិញទៅមកបាន (Neal, Boatman, Miller, n.d.)។ ការតភ្ជាប់ផ្នែកឌីជីថលអាចធ្វើឲ្យមានការបង្រៀនតាមអនឡាញ ដែលស្ត្រីអាចបំផុសគំនិតស្ត្រីនៅតាមបណ្តាប្រទេសនៅ ASEM។

## ចំណាប់អារម្មណ៍បញ្ចប់

បច្ចេកវិទ្យាឌីជីថលកំពុងតែផ្លាស់ប្តូរពិភពអាជីវកម្ម ការងារ និង ការផ្តល់សេវាកម្ម។ ស្ត្រី និង យុវជនគឺជាមនុស្សពីរក្រុមនៅក្នុងសង្គមរបស់យើងដែលត្រូវការការយកចិត្តទុកដាក់ជាពិសេសដើម្បីទទួល

[94] ការសិក្សារបស់ OECD ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ "ការផ្តល់អំណាចដល់ស្ត្រីនៅក្នុងយុគសម័យឌីជីថល៖ តើយើងឈរនៅកន្លែងណា?"

បានភាគលាភផ្នែកឌីជីថល។ ដោយសារវិសមភាពយេនឌ័រនៅតែបន្តកើតឡើង ដូច្នេះស្ថានភាពរបស់ស្ត្រីនឹងមានសភាពកាន់តែអាក្រក់ ដោយសារការរំខានផ្នែកបច្ចេកវិទ្យា ប្រសិនបើគ្មានការចាប់អារម្មណ៍ចំពោះវិធីដែលពួកគេអាចទទួលបាន និង ប្រើប្រាស់បច្ចេកវិទ្យាទេនោះ។ យុវជនជំនាន់នេះនឹងទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន និង ចាំបាច់ត្រូវមានភាពរៀសរវៃ និង មានភាពបត់បែន ដើម្បីដោះស្រាយជាមួយស្ថានភាពសេដ្ឋកិច្ចដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស និង ការកើនឡើងនៃការប្រកួតប្រជែងជាសកល។

ដូច្នេះ ការផ្តល់ភាពអង់អាចដល់ស្ត្រី និង យុវជនតាមរយៈការតភ្ជាប់ផ្នែកឌីជីថល ដែលត្រូវបានបំពេញបន្ថែមដោយការពង្រឹងការផ្តល់ការអប់រំ ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាពធនធានមនុស្ស គួរតែជាអាទិភាពសំខាន់ៗនៅលើរបៀបវារៈរបស់ ASEM។ ហានិភ័យមានកម្រិតខ្ពស់ ពីព្រោះបដិវត្តន៍ឌីជីថលនឹងមិនអើពើចំពោះប្រទេសដែលមិនធ្វើកំណែទម្រង់ដែលចាំបាច់ដើម្បីបញ្ចេញសក្តានុពលដ៏ពេញលេញរបស់ស្ត្រី និង យុវជននៅក្នុងយុគសម័យឌីជីថលនោះទេ។

# ឯកសារយោង

Kabeer, N. (1999), ‘Resources, Agency, Achievements: Reflections on the Measurement of Women’s Empowerment’ in Development and Change, Vol. 30. Blackwell Publishers, pp. 435– 64.

Lallana, E.C. (2016), ‘Deepening Asia-Europe Connectivity through ICT’ in Asia–Europe Connectivity Vision 2025: Challenges and Opportunities’. in Prakash, A. (ed.) An ERIAGovernment of Mongolia Document, pp. 109–26.

Neal, S., J. Boatman, and L. Miller (n.d.), ‘Women as Mentors’. https://www.shrm.org/ResourcesAndTools/hr-topics/employee-relations/Documents/womenasmentors_rr_ddi. pdf_ext=.pdf.

IV

# ការអភិវឌ្ឍប្រកបដោយចីរភាព

**កិច្ចសហប្រតិបត្តិការរបស់ ASEM លើថាមពលស្អាត**

HAN PHOUMIN
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

**ពង្រឹងការទូតសភាដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព**

CHHEANG VANNARITH
*វិទ្យាស្ថានចក្ខុវិស័យអាស៊ី ប្រទេសកម្ពុជា*

**កិច្ចប្រជុំអាស៊ី-អឺរ៉ុប និង និរន្តរភាពសង្គម នៅក្នុងយុគសម័យនៃការតភ្ជាប់ដែលមានការប្រកួតប្រជែង**

JÜRGEN RÜLAND
*សាកលវិទ្យាល័យ FRIEBURG ប្រទេសអាល្លឺម៉ង់*

**កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព៖**

ការគ្រប់គ្រងទឹកនៅតំបន់ទន្លេមេគង្គ និង ទន្លេ DANUBE

THEARITH LENG
*វិទ្យាស្ថានចក្ខុវិស័យអាស៊ី ប្រទេសកម្ពុជា*

# 10

# កិច្ចសហប្រតិបត្តិការ អាស៊ី-អឺរ៉ុប លើវិស័យថាមពលស្អាត

HAN PHOUMIN

## សេចក្តីផ្តើម

កិច្ចសហប្រតិបត្តិការរវាងអាស៊ាន និង អឺរ៉ុបលើវិស័យថាមពល ត្រូវបានលើកឡើងនៅក្នុងផែនការសកម្មភាពអាស៊ាន-EU (ឆ្នាំ២០១៨-២០២២) ដែលកិច្ចសហប្រតិបត្តិការនេះបានរួមបញ្ចូលការចែករំលែកឧត្តម្មានុវត្តស្តីពីការលើកកម្ពស់ការទទួលបានថាមពល សន្តិសុខថាមពល ប្រសិទ្ធភាពនៃថាមពល និង ការអភិរក្ស (EEC) បច្ចេកវិទ្យាថាមពលកកើតឡើងវិញ និង ថាមពលស្អាត និង វិធានការគាំទ្រទីផ្សារថាមពលដែលមានភាពប្រកួតប្រជែង។

តម្រូវការថាមពលនៅលើសកលលោក បានកើនឡើង ១០ ដង ចាប់ពីឆ្នាំ១៩៩៩ មក ហើយវានៅតែបន្តកើនឡើង (IEA ២០២០)។ ទំនាញនៃតម្រូវការថាមពលបានផ្លាស់ប្តូរទិសដៅមកកាន់ទ្វីបអាស៊ី ហើយសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ត្រូវការពាក់កណ្តាលនៃតម្រូវការឧស្ម័នជាសកល។ នៅខណៈពេលដែលបណ្តាប្រទេសនៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) នឹងមើលឃើញថាមានតម្រូវការថាមពលខ្ពស់បំផុត ហើយប្រទេសមួយចំនួនទៀតនឹងមានកំណើនអវិជ្ជមាន ដោយសារប្រសិទ្ធភាពនៃថាមពល និង កត្តាដទៃទៀត ដូចជា កំណើនប្រជាជន និង រចនាសម្ព័ន្ធផ្នែកឧស្សាហកម្មជាដើមនោះ បណ្តាប្រទេសនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នឹងមានលក្ខណៈផ្ទុយពីនេះ ពីព្រោះពួកគេនឹងត្រូវការថាមពលកាន់តែច្រើនដើម្បីគ្រប់គ្រងទិសដៅនៃកំណើនសេដ្ឋកិច្ចរបស់ពួកគេ។ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង កត្តាពីរសំខាន់ៗ គឺ កំណើនសេដ្ឋកិច្ច និង កំណើនប្រជាជននៅក្នុងតំបន់អាស៊ាន គឺជាកត្តាចម្បងដែលនាំឲ្យមានកំណើននៃតម្រូវការថាមពលទ្វេដង នៅក្នុងការទស្សន៍ទាយអំពីគំរូរបស់យើង សម្រាប់ឆ្នាំ២០១៥-២០៤០។ អាស៊ីអាគ្នេយ៍ ព្រមទាំង ប្រទេសដទៃទៀតនៅអាស៊ី បច្ចុប្បន្ន ប្រឈមមុខនឹងបញ្ហាប្រឈមដ៏ខ្លាំងក្លាបំផុត នៅក្នុងការផ្គូរផ្គងតម្រូវការថាមពលនឹងការផ្គត់ផ្គង់ថាមពលដែលមាននិរន្តរភាព ដែលផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចកាបូនទាប។ ចំណុចនេះជាប់ពាក់ព័ន្ធនឹងកំណើននៃតម្រូវការក្នុងការផ្លាស់ប្តូរ ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍ និង ការប្រើប្រាស់ប្រភពថាមពលបៃតង

ច្រើនជាងមុន។ កំណើននៃតម្រូវការថាមពលនឹងអាចបំពេញបាន តាមរយៈការផ្គត់ផ្គង់ថាមពលដែលសមស្រប ដែលថាមពលកកើតឡើងវិញ និង ថាមពលជំនួសដែលមានភាពស្អាតដទៃទៀត ដូចជា ថាមពលកកើតឡើងវិញ អ៊ីដ្រូសែន និង បច្ចេកវិទ្យាស្អាត ចាំបាច់ត្រូវមានការបង្កើនល្បឿន។

ERIA បានធ្វើការសិក្សាស្តីពីសក្តានុពលនៃតម្រូវការអ៊ីដ្រូសែន ដោយផ្អែកលើស៊ីណារីយ៉ូចំនួនបីនៃការបញ្រៀបអ៊ីដ្រូសែននៅក្នុងវិស័យខុសៗគ្នា។ មានការផលិតអ៊ីដ្រូសែនពីរប្រភេទ។ អ៊ីដ្រូសែនអាចបង្កើតបានតាមរយៈកំណែទម្រង់ និង ការបង្កើតឧស្ម័នពី ផូស៊ីលតន្ទនៈ ដូចជា ឧស្ម័នធម្មជាតិ និង ធ្យូងថ្ម ជាដើម ឬ ការអនុវត្តអគ្គិសនីវិភាគទឹក ដោយប្រើប្រាស់អគ្គិសនីដែលផលិតដោយថាមពលកកើតឡើងវិញ ដូចជា កម្តៅទឹក/កម្តៅផែនដី ពន្លឺព្រះអាទិត្យ/PV និង ខ្យល់។ ការសិក្សានេះបានប្រមើលមើលកំណើនជាសក្តានុពលនៃការសម្របខ្លួន និង ការប្រើប្រាស់អ៊ីដ្រូសែននៅគ្រប់វិស័យទាំងអស់ មុនឆ្នាំ២០៤០ ដោយការចំណាយលើអ៊ីដ្រូសែននឹងធ្លាក់ចុះពី ០,៩០ ដុល្លារអាមេរិក/Nm3 (ម៉ែត្រគូបធម្មតា) នាពេលបច្ចុប្បន្ន ទៅ ០,៣០-០,៤០ ដុល្លារអាមេរិក/Nm3 នៅឆ្នាំ២០៤០ ដែលមានភាពប្រកួតប្រជែងនឹងតម្លៃគោលដៅរបស់ប្រេងសាំង។ កំណើនតម្រូវការថាមពលដែលត្រូវបានប៉ាន់ស្មានទុកមុន នៅអាស៊ាន បង្ហាញអំពីការគំរាមកំហែងមួយចំពោះសន្តិសុខថាមពល និង កិច្ចខិតខំប្រឹងប្រែងដើម្បីទប់ទល់នឹងការបញ្ចេញ CO2។ បញ្ហាប្រឈមនៃថាមពលទូទៅទាំងនេះ នឹងត្រូវដោះស្រាយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា រួមបញ្ចូលទាំងវិធីសាស្រ្ត និង វិធានការជាសមូហភាព ដើម្បីអភិវឌ្ឍយ៉ាងឆាប់រហ័ស និង ប្រើប្រាស់ប្រសិទ្ធភាព និង ការសន្សំសំចៃថាមពល និង បច្ចេកវិទ្យារបស់រោងចក្រអគ្គិសនីដែលមានប្រសិទ្ធភាពខ្ពស់ និងដើរដោយធ្យូងថ្ម ដែលបញ្ចេញឧស្ម័ននៅកម្រិតទាប និង សុវត្ថិភាពនៃថាមពលនុយក្លេអ៊ែរ និង បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញទ្វេដង នៅក្នុងថាមពលចម្រុះទូទៅ ដើម្បីការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និង ចីរភាព។

កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅអាស៊ាន បាននាំឲ្យមានកំណើនតម្រូវការថាមពលដែលគួរឲ្យកត់សម្គាល់ នៅក្នុងតំបន់។ ទស្សនវិស័យថាមពល និង សក្តានុពលនៃការសន្សំសំចៃថាមពលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បង្ហាញថា តម្រូវការថាមពលជាចម្បង ត្រូវបានគេរំពឹងទុកថានឹងកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៣,៦% ក្នុងចន្លោះឆ្នាំ២០១៥ និង ឆ្នាំ២០៤០។ នៅក្នុងលក្ខខណ្ឌដាច់ខាត វានឹងកើនឡើងពី ៦៦៦,៦១ លានតោននៃសមាមាត្រប្រេង (Mtoe) នៅឆ្នាំ២០១៥ ទៅ ១៦២៣,៦៣ Mtoe នៅឆ្នាំ២០៤០។ យោងតាមប្រភពថាមពល ប្រេងគឺជាប្រភពថាមពលដ៏ច្រើនលើសលប់ និង ធំជាងគេបំផុត ដែលមានចំណែក ៥០,៥% នៅឆ្នាំ២០៤០

ដែលមានកំណើនបន្តិចពី ៥០,១% នៅឆ្នាំ២០១៥។ ធ្យូងថ្មគឺជាប្រភពថាមពលធំជាងគេទីពីរ ដែលត្រូវបានប៉ាន់ស្មានថាមាន ចំណែក ៤៣,៣% នៅឆ្នាំ២០៤០ ដែលមានកំណើនយ៉ាងខ្លាំងពី ២៦,៩% នៅឆ្នាំ២០១៥។ ឧស្ម័នធម្មជាតិត្រូវបានប៉ាន់ស្មានថាមានចំណែក ២៧,៣% ដែល ធ្លាក់ចុះបន្តិចពី ៣១,៤% នៅឆ្នាំ២០១៥ ដោយសារទិសដៅគោលនយោបាយរបស់បណ្ដាប្រទេស នៃគោលនយោបាយ។ ថាមពលវារីអគ្គិសនីត្រូវបានរំពឹងទុកនឹងធ្លាក់ចុះបន្តិច ពី ២,៤% នៅឆ្នាំ ២០១៥ ទៅ ១,៤% នៅឆ្នាំ២០៤០ ពីព្រោះធនធានត្រូវបានអភិវឌ្ឍយ៉ាងពេញលេញ។ ចំណែក ដែលនៅសល់ប្រហែល ២៥% នៅឆ្នាំ២០១៥ គឺបានមកពីថាមពលកកើតឡើងវិញ ដូចជា កម្ដៅ ផែនដី ខ្យល់ ពន្លឺព្រះអាទិត្យ និង ជីវម៉ាស ហើយចំណែកនេះ នៅឆ្នាំ២០៤០ ទំនងជាកើនឡើង ៣១%។

ចំណែកនៃការប្រើប្រាស់ថាមពលសម្រេច តាមប្រភពតន្ទនៈ ចង្អុលបង្ហាញថា ប្រេងគឺជាប្រភព ថាមពលដែលប្រើប្រាស់យ៉ាងច្រើនលើសលុប ដែលមានចំណែក ៤១,៣% នៅឆ្នាំ២០១៥ និង ៤៥,៤% នៅឆ្នាំ២០៤០ បន្តដោយ អគ្គិសនី ដែលមានចំណែក ១៦,១% នៅឆ្នាំ២០១៥ និង ១៩,៤% នៅឆ្នាំ២០៤០, ធ្យូងថ្មមានចំណែក ៨,៩% នៅឆ្នាំ២០១៥ និង ១២,៣% នៅ ឆ្នាំ២០៤០, ឧស្ម័នធម្មជាតិមានចំណែក ១០,៣% នៅឆ្នាំ២០១៥ និង ១១,៣% នៅឆ្នាំ២០៤០ ដែលប្រភពថាមពលដែលនៅសល់គឺ កម្ដៅ និង ប្រភពថាមពលដទៃទៀត។

ចំណែកនៃការប្រើប្រាស់ប្រេងដ៏ច្រើនលើសលុបនៅក្នុងការប្រើប្រាស់ថាមពលសម្រេច គឺ ដោយសារកំណើនការប្រើប្រាស់ប្រេងនៅក្នុងវិស័យដឹកជញ្ជូន។ ការបង្កើតអគ្គិសនីសរុបត្រូវបាន ប៉ាន់ស្មានថានឹងមានកំណើនជាមធ្យម ៦,៣% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៥ (ស្មើនឹង ៣២,៩ តេរ៉ាវ៉ាត់-ម៉ោង [TWh]) ទៅ (ស្មើនឹង ៥៣ TWh) នៅឆ្នាំ២០៤០។

ចំណែកនៃការបង្កើតអគ្គិសនីដើរដោយធ្យូងថ្ម ត្រូវបានប៉ាន់ស្មានថានឹងមានចំនួនច្រើនជាង គេបំផុត ៥៣% នៅឆ្នាំ២០៤០ ដែលមានកំណើនឡើងយ៉ាងខ្លាំង ពី ៣២,៩% នៅឆ្នាំ២០១៥។ ចំណែករបស់ឧស្ម័នធម្មជាតិ ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះពី ៤៦,៦% នៅឆ្នាំ២០១៥ ទៅ ៣៤,១% នៅឆ្នាំ២០៤០ នៅខណៈពេលដែលចំណែករបស់វារីអគ្គិសនីនឹងធ្លាក់ចុះពី ១៣,៦ % នៅឆ្នាំ២០១៥ ទៅ ៧,៤% នៅឆ្នាំ២០៤០។ ចំណែកនៃកម្ដៅផែនដីនឹងធ្លាក់ចុះពី ២,២ % នៅឆ្នាំ២០១៥ ទៅ ១,៥% នៅឆ្នាំ២០៤០។ ចំណែកដែលនៅសល់ (ខ្យល់ ពន្លឺព្រះអាទិត្យ ជីវម៉ាស) មានចំនួន ១,៦% នៅឆ្នាំ២០១៥ ត្រូវបានប៉ាន់ស្មានថានឹងមានចំនួន ៣,១% នៅ ឆ្នាំ២០៤០។

កំណើនតម្រូវការថាមពលនៅអាស៊ានឆ្លុះបញ្ចាំងអំពីទិន្នាការទូទៅសម្រាប់ការអភិវឌ្ឍអាស៊ី។ ចំណុចនេះគួរឲ្យព្រួយបារម្ភដោយសារបញ្ហាប្រឈមនៅក្នុងការធានាថា ថាមពល ដែលត្រូវការ មានតម្លៃសមរម្យ និង ស្ថេរភាពក្នុងការផ្គត់ផ្គង់។ OECD ប្រហែលជាមានគោលជំហរល្អបំផុតនៅក្នុងការជួយដល់អាស៊ាន នៅក្នុងការផ្លាស់ប្តូរថាមពលរបស់ខ្លួន ដើម្បីឆ្ពោះទៅកាន់ការប្រើប្រាស់ថាមពលស្អាត ដោយថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យាថាមពលស្អាតកាន់តែច្រើននៅក្នុងប្រព័ន្ធថាមពលរបស់ខ្លួន។ ដូច្នេះ គោលនយោបាយថាមពលសមស្រប សម្រាប់សន្តិសុខថាមពល និង ថាមពលដែលមានតម្លៃសមរម្យ នឹងចាំបាច់ត្រូវតែអាចបត់បែនបាន ដោយពិចារណាអំពីតួនាទីរបស់ផូស៊ីលឥន្ធនៈនៅក្នុងការផ្លាស់ប្តូរថាមពល ដូចបានកត់សម្គាល់នៅក្នុងករណីអាស៊ាន។ វាក៏មានសារសំខាន់ផងដែរនៅក្នុងការលើកឡើងថា ការបំពេញតាមតម្រូវការថាមពលដែលមានការកើនឡើងនឹងត្រូវការគោលនយោបាយថាមពល និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលដែលសមស្រប ដើម្បីធានាចំពោះការប្រើប្រាស់ថាមពល និង កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ការគ្រប់គ្រងការផ្លាស់ប្តូរថាមពល និង តថភាពនៃថាមពល

ពិភពលោកកំពុងតែឆ្លងកាត់ការផ្លាស់ប្តូរថាមពល ពីប្រព័ន្ធដែលផ្អែកលើផូស៊ីលឥន្ធនៈទៅប្រព័ន្ធដែលផ្អែកលើការប្រើប្រាស់ថាមពលស្អាតជាងមុន រួមបញ្ចូលទាំង ថាមពលកកើតឡើងវិញ និង ការប្រើប្រាស់ផូស៊ីលឥន្ធនៈដែលស្អាតជាងមុនផងដែរ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសកល និង ជៀសវាងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ការដោះស្រាយការផ្លាស់ប្តូរថាមពល ដើម្បីឆ្ពោះទៅកាន់ប្រព័ន្ធថាមពលស្អាតជាងមុន គឺជាគោលដៅរួម ដូចដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀងជាសកលនៃសន្និសិទស្តីពីការប្រែប្រួលអាកាសធាតុនៃអង្គការសហប្រជាជាតិ, COP21, ដែលថ្នាក់ដឹកនាំសកលបានព្រមព្រៀងគ្នាកំណត់គោលដៅនៃការដាក់កម្រិតលើកំណើនកម្តៅផែនដី ក្នុងកម្រិតទាបជាង ២ អង្សារសេ ប្រសិនបើប្រៀបធៀបនឹងកម្រិតមុនពេលមានបដិវត្តន៍ឧស្សាហកម្ម។

ទោះបីជាបានចុះកិច្ចព្រមព្រៀងស្តីពីគោលដៅរួមក៏ដោយ ក៏វិធីសាស្ត្រ និង វិធានការគោលនយោបានដែលត្រូវអនុវត្តនៅក្នុងប្រទេសនីមួយៗមានលក្ខណៈខុសៗគ្នា ដែលឆ្លុះបញ្ចាំងអំពីភាពខុសគ្នានៅក្នុងបរិបទសេដ្ឋកិច្ចសង្គម នយោបាយ និង ភូមិសាស្ត្ររបស់ពួកគេ។ ជាក់ស្តែងការផ្លាស់ប្តូរថាមពលគឺជាបញ្ហាសេដ្ឋកិច្ចមួយ ដោយសារតែប្រព័ន្ធហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ទំនងជាសម្លឹងមើលតែផលចំណេញភ្លាមៗ ដោយកាត់បន្ថយតម្លៃនៃផលប្រយោជន៍រយៈពេលមធ្យម និង រយៈពេលវែង។ តាមវិធីនេះ បច្ចេកវិទ្យាថ្មី និង ស្អាតហាក់បីដូចជាមានតម្លៃថ្លៃជាង ប្រព័ន្ធ

ថាមពលដែលផ្អែកលើផូស៊ីលឥន្ធនៈធម្មតា។ ដូច្នេះ គោលនយោបាយថាមពលដែលសមស្រប ដើម្បីលៃលកធនធានសេដ្ឋកិច្ចសម្រាប់ការផ្លាស់ប្តូរថាមពល មានសារសំខាន់ខ្លាំងណាស់ ក្នុងការធានាចំពោះការទទួលបានថាមពលប្រកបដោយសមធម៌ និង មានតម្លៃសមរម្យសម្រាប់មនុស្សគ្រប់រូប។

យោងតាមទស្សនវិស័យថាមពលរបស់ ERIA (Kimura and Han, ed. ២០១៩) តម្រូវការផូស៊ីលឥន្ធនៈ (ប្រេង ធ្យូងថ្ម និង ឧស្ម័នធម្មជាតិ) នៅក្នុងតំបន់អាស៊ាន នឹងកើនឡើងជិតបីដងពី ៥០៧ Mtoe នៅក្នុងឆ្នាំ២០១៥ ទៅ ១៣៩៣ Mtoe នៅក្នុងឆ្នាំ២០៤០ ស្របតាមស៊ីណារីយ៉ូអាជីវកម្មជាធម្មតា (BAU) ដែលត្រូវបានតម្រង់ទិសជាចម្បងដោយវត្ថុបំណងនៃការធានាចំពោះសន្តិសុខថាមពល ស្ថេរភាពក្នុងការផ្គត់ផ្គង់ឥន្ធនៈ និង តម្លៃសមរម្យ។ ទោះបីជា នៅក្រោមស៊ីណារីយ៉ូនៃគោលនយោបាយជឿនលឿន (APS) ដែលមានប្រសិទ្ធភាពនៃថាមពលខ្លាំងក្លាជាង និង ការជ្រាបចូលនៃថាមពលដែលមិនមែនជា ផូស៊ីលឥន្ធនៈនៅកម្រិតខ្ពស់ជាងក៏ដោយ ក៏តម្រូវការផូស៊ីលឥន្ធនៈនៅក្នុងឆ្នាំ២០៤០ ត្រូវបានប៉ាន់ស្មានថា នឹងមានចំនួន ១.០២៧ Mtoe ដែលមានចំនួនទ្វេដងនៃតម្លៃនៅក្នុងឆ្នាំ២០១៥។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់នៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃថាមពល និង ប្រភពថាមពលកកើតឡើងវិញក៏ដោយ ក៏វាប្រាកដណាស់ថា ផូស៊ីលឥន្ធនៈនឹងដើរតួយ៉ាងសំខាន់នៅក្នុងភាពចម្រុះនៃថាមពលនៅក្នុងតំបន់អាស៊ាន។

ការគ្រប់គ្រងការផ្លាស់ប្តូរថាមពលនៅអាស៊ាន នឹងតម្រូវឲ្យមានការសង្កត់ធ្ងន់លើវត្តមានរបស់ផូស៊ីលឥន្ធនៈ (ធ្យូងថ្ម ប្រេង និង ឧស្ម័នធម្មជាតិ) នៅក្នុងប្រព័ន្ធថាមពលរយៈពេលខ្លី និង មធ្យម ហើយអ្វីដែលជាបញ្ហានោះគឺ ថាតើយើងត្រូវប្រើប្រាស់ផូស៊ីលឥន្ធនៈតាមរបៀបណាដើម្បីឲ្យមានចីរភាពបរិស្ថាន ដើម្បីធ្វើសកម្មភាពក្នុងនាមជាស្ពានមួយឆ្ពោះទៅកាន់អនាគតនៃថាមពលដែលគ្មានកាបូន ជាជាងគ្រាន់តែលុបបំបាត់វាទាំងស្រុង។ ដើម្បីការអនុវត្តការផ្លាស់ប្តូរថាមពល និង វត្ថុបំណងនៃគោលនយោបាយការប្រែប្រួលអាកាសធាតុបានយ៉ាងជោគជ័យ អ្នកបង្កើតគោលនយោបាយនឹងចាំបាច់ត្រូវរក្សាតុល្យភាពវត្ថុបំណងនៃគោលនយោបាយដទៃទៀតនៃសន្តិសុខថាមពល ការទទួលបានថាមពល និង តម្លៃសមរម្យ ដែលមានសារសំខាន់ស្មើៗគ្នា ឧទាហរណ៍៖ គោលនយោបាយដែលមើលមិនឃើញការហាមឃាត់ការផ្តល់ហិរញ្ញប្បទានជាសាធារណៈដល់បច្ចេកវិទ្យាធ្យូងថ្មស្អាត (CCT) អាចធ្វើឲ្យខូចប្រយោជន៍ ពាក់ព័ន្ធនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយសារកង្វះខាតហិរញ្ញវត្ថុសម្រាប់ CCT ដែលមានប្រសិទ្ធភាពខ្ពស់ ប៉ុន្តែមានតម្លៃថ្លៃជាង អាចនឹងធ្វើឲ្យមានការប្រើប្រាស់បច្ចេកវិទ្យាដែលមានតម្លៃថោកជាង និង មិនសូវមាន

ប្រសិទ្ធភាព ដូចជា បច្ចេកវិទ្យាសំខាន់ៗ ឬ បច្ចេកវិទ្យាមិនសូវសំខាន់ និង ការបញ្ចេញ CO2 នៅកម្រិតខ្ពស់ជាង។

ការផ្លាស់ប្តូរថាមពល និង ការកែប្រែដើម្បីឆ្ពោះទៅកាន់ប្រព័ន្ធថាមពលដែលស្អាតជាងនេះ នឹងមានផលប៉ះពាល់សំខាន់ៗចំពោះអាស៊ាន និង សេដ្ឋកិច្ចពិភពលោក។ ជំហាននៃការអនុម័តគោលនយោបាយដោយប្រទេសនានា បានមើលឃើញការប្រែប្រួលយ៉ាងខ្លាំងក្លានៅក្នុងប្រព័ន្ធថាមពល ដែលថាមពលកកើតឡើងវិញបានជ្រាបចូលទៅក្នុងខ្សែបណ្តាញអគ្គិសនីកាន់តែខ្លាំង។ បញ្ហាប្រឈមដ៏ខ្លាំងក្លាមួយដែលការផ្លាស់ប្តូរថាមពលបានបង្ហាញ គឺចំណាយ និង ចំណេះធ្វើផ្នែកបច្ចេកវិទ្យាដែលពាក់ព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធ និង ចំណាយដែលពាក់ព័ន្ធ ដើម្បីទទួលបានចំណែកថាមពលកកើតឡើងវិញនៅក្នុងប្រព័ន្ធថាមពលកាន់តែខ្ពស់។ បញ្ហាមួយទៀតដែលមានសារសំខាន់ស្មើគ្នា គឺការផ្លាស់ប្តូរស្ថានភាពភូមិសាស្ត្រនយោបាយ ដែលប្រទេសផលិតផូស៊ីលឥន្ធនៈនឹងចាំបាច់ត្រូវកែប្រែជំហានប្រហាក់ប្រហែលគ្នាមួយដើម្បីអនុម័តគំរូសេដ្ឋកិច្ចថ្មីមួយដែលពិពិធភាព ដើម្បីដោះស្រាយនឹងការប្រែប្រួលទាំងនេះ។

វាមានសារសំខាន់នៅក្នុងការកត់សម្គាល់ថា ការកែប្រែ និង ជំហានក្នុងការផ្លាស់ប្តូរថាមពលជាប់ពាក់ព័ន្ធនឹងចំណាយ និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងថាមពលទាំងអស់ ហើយនឹងមានផលប៉ះពាល់ដ៏ធំមួយលើតម្លៃសមរម្យរបស់ថាមពល។ ការផ្សារភ្ជាប់ពីប្រព័ន្ធថាមពលបច្ចុប្បន្នទៅកាន់ប្រព័ន្ធថាមពលដែលមានភាពស្អាតជាង នាពេលអនាគត តម្រូវឲ្យមានការពិចារណាអំពីការប្រើប្រាស់ផូស៊ីលឥន្ធនៈដែលស្អាតជាង និង បច្ចេកវិទ្យាប្រកបដោយនវានុវត្តន៍ ដែលអាចកាត់បន្ថយការបញ្ចេញ CO2 និង ឧស្ម័នផ្ទះកញ្ចក់ (GHG)។ ដូច្នេះ ជំហានដែលត្រូវអនុវត្តជាបន្ទាន់ គឺចាំបាច់ត្រូវកាត់បន្ថយសារធាតុកាបូននៅក្នុងវិស័យថាមពល តាមរយៈគន្លងផ្លូវទៅកាន់សេដ្ឋកិច្ចដែលមានកាបូនទាប ដែលត្រូវការឲ្យមានការប្រើប្រាស់យ៉ាងឆាប់រហ័សនូវការប្រើប្រាស់បច្ចេកវិទ្យាផូស៊ីលឥន្ធនៈស្អាត ការអភិវឌ្ឍថាមពលកកើតឡើងវិញ និង ការបង្កើនប្រសិទ្ធភាពថាមពលទ្វេដង ដោយសារតែវិស័យថាមពលទទួលខុសត្រូវលើពីរភាគបីនៃការបញ្ចេញ GHG ជាសកល។

## ទិសដៅគោលនយោបាយថាមពលរបស់អាស៊ាន និង EU

ផែនការសកម្មភាពអាស៊ានចំពោះកិច្ចសហប្រតិបត្តិការថាមពល (APAEC) ដំណាក់កាលទី២ ដែលស្ថិតនៅក្រោមការត្រៀមផ្តល់ចំណារអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីថាមពល អាស៊ាន (AMEM) នៅក្នុងឆ្នាំ២០២០ នឹងកំណត់គោលដៅអនុវត្តគោលនយោបាយសំខាន់ៗ និង អត្ថន័យនៃ

គោលនយោបាយថាមពល សម្រាប់ការវិនិយោគដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងតំបន់។ គោលដៅអនុវត្តសំខាន់ៗ រួមមាន ការកែសម្រួលប្រសិទ្ធភាពថាមពលថ្មី និង គោលដៅនៃការអភិរក្សពីការកាត់បន្ថយអាំងតង់ស៊ីតេថាមពល ៣០% មុនឆ្នាំ ២០២៥ (ផ្អែកលើកម្រិតនានានៅឆ្នាំ២០០៥) ទៅកាន់កម្រិតដែលកាន់តែច្រើនជាងទៀត ពោលគឺគោលដៅថ្មីដែលទំនងជាកាត់បន្ថយ ៣៥%-៤០% នឹងពាក់ព័ន្ធការពង្រីកវិធីសាស្ត្រប្រសិទ្ធិភាពថាមពលចំពោះការដឹកជញ្ជូន និង ឧស្សាហកម្មនានា។ វាក៏នឹងបង្កើតអនុគោលដៅថ្មីមួយសម្រាប់ចំណែកថាមពលកកើតឡើងវិញនៅក្នុងចំណុះថាមពលដែលបានតម្លើង ដែលបំពេញបន្ថែមលើគោលដៅដែលមានស្រាប់ ដែលមានចំណែក ២៣% នៃថាមពលកកើតឡើងវិញនៅក្នុងការផ្គត់ផ្គង់ថាមពលចម្បងសរុប (TPES) ត្រឹមឆ្នាំ២០២៥។ APAEC ដំណាក់កាលទី២ ក៏នឹងរួមបញ្ចូលវិធានការគោលនយោបាយដើម្បីអនុវត្តខ្សែបណ្តាញឆ្លាតវៃ និង សមាហរណកម្មខ្សែបណ្តាញថាមពលកកើតឡើងវិញ និង វិធានការដោះស្រាយបច្ចេកវិទ្យាដែលកំពុងតែលេចឡើង និង បច្ចេកវិទ្យាជំនួស ដូចជា អ៊ីដ្រូសែន ការរក្សាទុកថាមពល ជីវថាមពល ថាមពលនុយក្លេអ៊ែរ ការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយសារធាតុកាបូន ការវិនិយោគលើថាមពល និង ការផ្តល់ហិរញ្ញប្បទាន និង ការចូលរួមរបស់វិស័យឯកជន ភាពងាយរងគ្រោះ និង ភាពធន់ដែលទាក់ទងនឹងគ្រោះមហន្តរាយ លក្ខខណ្ឌតម្រូវក្នុងការកសាងសមត្ថភាព និង បញ្ហាឆ្លងវិស័យដទៃទៀត។ APAEC ដំណាក់កាលទី២ នឹងបន្តផ្តោតលើការតភ្ជាប់ផ្នែកថាមពល និង សមាហរណកម្មទីផ្សារ ប៉ុន្តែនឹងបន្ថែមប្រធានបទតូចមួយ ស្តីពីការផ្លាស់ប្តូរថាមពល និង ភាពធន់នៃថាមពល ស្តីពីរបៀបដែលតំបន់នេះនឹងត្រូវការយុទ្ធសាស្ត្រមួយដើម្បីដោះស្រាយបញ្ហាផូស៊ីលឥន្ធនៈ និង បច្ចេកវិទ្យាថ្មីៗ។

នៅតំបន់អាស៊ាន មានគម្លាតដ៏ធំនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាក់ព័ន្ធនឹង GDP កំណើនប្រជាជន ការប្រើប្រាស់ថាមពល និង បច្ចេកវិទ្យា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសនីមួយៗប្តេជ្ញាចិត្តធ្វើឲ្យល្អបំផុតដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុទូទៅ។ ប្រទេសនានាមានការប្តេជ្ញាចិត្តរួមគ្នាតាមរយៈគោលនយោបាយខុសៗគ្នា ដូចជា គោលដៅដង់ស៊ីតេថាមពល ឬតាមរយៈគោលដៅជាក់ស្តែងនៃចំណែកថាមពលកកើតឡើងវិញនៅក្នុងភាពចម្រុះនៃថាមពល។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍ប្រឈមមុខនឹងបញ្ហាផ្គត់ថាមពល និង តម្លៃសមរម្យនៃថាមពល នៅខណៈពេលជាមួយគ្នានោះ ការលើកកម្ពស់ថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យាថាមពលស្អាតដទៃទៀត នឹងនៅតែមានតម្លៃថ្លៃ ទោះបីជាចំណាយលើម៉ូឌុលពន្លឺព្រះអាទិត្យ និង ម៉ូឌុលខ្យល់ បានធ្លាក់ចុះយ៉ាងខ្លាំងក៏ដោយ ការចំណាយលើប្រព័ន្ធនៅតែមានតម្លៃថ្លៃនៅពេលអនុវត្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ការធ្វើឲ្យបច្ចេកវិទ្យាស្អាត និង បច្ចេកវិទ្យាបៃតង

ទាំងនេះអាចស្វែងរកបាន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ាននឹងតម្រូវឲ្យមានការចាប់អារម្មណ៍ផ្នែកគោលនយោបាយ រួមបញ្ចូលទាំងបទប្បញ្ញត្តិ និង យន្តការផ្តល់ហិរញ្ញប្បទាន ដែលមានការគាំទ្រពីប្រទេសអភិវឌ្ឍន៍ផងដែរ។

សហភាពអឺរ៉ុប (EU) មានបំណងធ្វើឲ្យគ្មានការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាសត្រឹមឆ្នាំ២០៥០ (EU ២០២០)។ ក្នុងចំណោមគោលដៅដទៃទៀត ក្របខណ្ឌអាកាសធាតុ និងថាមពល ឆ្នាំ២០៣០ ដែលអាចទស្សន៍ទាយទុកមុនបាន រួមមាន គោលដៅ និង វត្ថុបំណងនៃគោលនយោបាយទូទាំង សម្រាប់រយៈពេលចាប់ពីឆ្នាំ២០២១ រហូតដល់ ឆ្នាំ២០៣០។ គោលដៅសំខាន់ៗសម្រាប់ឆ្នាំ២០៣០ រួមបញ្ចូលការកាត់បន្ថយការបញ្ចេញ GHG យ៉ាងតិច ៤០% ពីកម្រិតនៅឆ្នាំ១៩៩០ ចំណែកថាមពលកកើតឡើងវិញយ៉ាងតិច ៣២% និង ការកែលម្អប្រសិទ្ធភាពថាមពលយ៉ាងតិច ៣២,៥%។ ការកាត់បន្ថយការបញ្ចេញ GHG នឹងធ្វើឲ្យ EU អាចឆ្ពោះទៅកាន់សេដ្ឋកិច្ចគ្មានការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាសបាន និង អាចអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងទីក្រុងបារីស។ ចំពោះថាមពលកកើតឡើងវិញ គោលដៅថាមពលកកើតឡើងវិញដែលចងកាតព្វកិច្ចសម្រាប់ EU សម្រាប់ឆ្នាំ២០៣០ ដែលមានការប្រើប្រាស់ថាមពលសម្រេចយ៉ាងតិច ៣២% នឹងរួមបញ្ចូល ខចែងនៃការត្រួតពិនិត្យឡើងវិញត្រឹមឆ្នាំ២០២៣ ចំពោះការកែសម្រួលដើម្បីដំឡើងកម្រិតគោលដៅរបស់ EU។ ចំពោះប្រសិទ្ធភាពនៃថាមពល គោលដៅនៅលើចំណាងជើង ដែលមានប្រសិទ្ធភាពថាមពលយ៉ាងតិច ៣២% នឹងសម្រេចបានរួមគ្នាដោយ EU នៅក្នុងឆ្នាំ២០៣០ ដោយមានខចែងនៃការត្រួតពិនិត្យឡើងវិញដើម្បីដំឡើងកម្រិតត្រឹមឆ្នាំ២០២៣។ ដើម្បីសម្រេចបាននូវការអនុវត្តយ៉ាងមានប្រសិទ្ធភាព ដើម្បីឆ្ពោះទៅកាន់គោលដៅទាំងនេះ ដំណើរការអភិបាលកិច្ចដែលមានតម្លាភាព និង មានថាមវន្ត នឹងជួយសម្រេចគោលដៅអាកាសធាតុ និង គោលដៅថាមពលឆ្នាំ២០៣០ បានយ៉ាងមានប្រសិទ្ធភាព និង ជាបន្តបន្ទាប់។ EU បានអនុម័តលើវិធានពិនិត្យតាមដាន និង រាយការណ៍ដែលមានសមាហរណកម្មដើម្បីធានាចំពោះវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅអាកាសធាតុ និង ថាមពល ឆ្នាំ២០៣០ របស់ខ្លួន និង ការប្តេជ្ញាចិត្តជាអន្តរជាតិក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

## ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៃថាមពលកាបូនទាប

កំណើនយ៉ាងខ្លាំងក្លានៃតម្រូវការថាមពលដែលអាចទស្សន៍ទាយជាមុនបាន នៅអាស៊ាន នឹងត្រូវការហេដ្ឋារចនាសម្ព័ន្ធ និង ការវិនិយោគលើការផ្គត់ផ្គង់ថាមពលដែលមានការសម្របសម្រួល និង មានភាពសមស្រប ដើម្បីធានាចំពោះចីរភាព ការអភិវឌ្ឍ និងបរិស្ថានថាមពលរបស់តំបន់។ ការវិនិយោគលើថាមពលថ្មីៗ និង កកើតឡើងវិញ និង បច្ចេកវិទ្យាស្អាតមួយចំនួននៅតែ

ប្រឈមមុខនឹងអស្ថេរភាព និង ការផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃខ្ពស់។ ដូច្នេះ គោលដៅនៃគោលនយោបាយថាមពល និង ការជ្រាបចូលនៃបច្ចេកវិទ្យាស្អាតនៅក្នុងប្រព័ន្ធថាមពល នឹងចាំបាច់ត្រូវតែបានលើកកម្ពស់។ ការវិនិយោគលើបច្ចេកវិទ្យាកាបូនទាប និង ថាមពលកកើតឡើងវិញ ត្រូវបានមើលឃើញថាមានសារសំខាន់ចំពោះការគ្រប់គ្រងការផ្លាស់ប្តូរថាមពល ឆ្ពោះទៅកាន់ការប្រើប្រាស់ថាមពលស្អាត និង ការដោះស្រាយបញ្ហាបរិស្ថាន។ OECD ប្រហែលជាពុំមានបំណងផ្តល់ហិរញ្ញប្បទានដល់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មនៅទូទាំងសកលលោកនោះទេ ប៉ុន្តែអាស៊ាននឹងកសាងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មបន្ថែមទៀត ដើម្បីបំពេញតាមកំណើននៃតម្រូវការថាមពល និង ឆ្លើយតបទៅនឹងតម្លៃសមរម្យ និង លទ្ធភាពក្នុងការប្រើប្រាស់ថាមពល។

ផ្អែកតាមការពិតនេះ វាប្រហែលជាមានសុវត្ថិភាពនៅក្នុងការធានាថា ការប្រើប្រាស់ធ្យូងថ្មនៅក្នុងការផ្លាស់ប្តូរថាមពលនៅអាស៊ានមានអំណោយផលដល់បរិស្ថានច្រើនជាង តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាដែលអាចស្វែងរកបានយ៉ាងល្អបំផុតដើម្បីកាត់បន្ថយសារធាតុបំពុល និង ការបញ្ចេញ ស្របពេលជាមួយគ្នានោះបង្កើនការជ្រាបចូលនៃថាមពលកកើតឡើងវិញយ៉ាងសន្សឹមៗ។

មានវិស័យនៃកិច្ចសហប្រតិបត្តិការធំៗ ដែល EU អាចជួយដល់អាស៊ានដើម្បីឆ្ពោះទៅកាន់ការសម្រេចបានសេដ្ឋកិច្ចដែលស្អាតជាងនេះ និង មានកាបូនទាបជាងនេះ តាមរយៈការផ្ទេរបច្ចេកវិទ្យា និង ការវិនិយោគ។

តម្រូវការសរុបនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលរបស់ពិភពលោក ត្រូវបានប្រមើលឃើញថានឹងមានចំនួន ៦០ ទ្រីលានដុល្លារអាមេរិក នៅឆ្នាំឆ្នាំ២០១៤-២០៤០ (IEA ឆ្នាំ២០១៦)។ នេះក៏មានន័យផងដែរថា ការវិនិយោគលើថាមពលមានចំនួន ២,៧ ទ្រីលានដុល្លារអាមេរិកក្នុងមួយឆ្នាំ មានភាពចាំបាច់ ត្រឹមឆ្នាំ២០៤០។ នៅអាស៊ីអាគ្នេយ៍តែឯង ត្រូវការទឹកប្រាក់ប្រហែល ១,៧ ទ្រីលានដុល្លារអាមេរិកនៅក្នុងការវិនិយោគសរុបលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ថាមពល នៅឆ្នាំ២០៣៥ ដែលមានចំនួន ៦០% នៃទឹកប្រាក់សរុបនៅក្នុងវិស័យថាមពល (IEA និង ERIA ២០១៣)។ នៅខណៈពេលដែល IEA និង ERIA (២០១៣) ទស្សន៍ទាយទុកមុនថា ការវិនិយោគដែលត្រូវបានតម្រូវ ដែលមានភាពចាំបាច់ចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពល រួមទាំង ស្ថានភាពជាក់ស្តែង និង ទំហំនៃការវិនិយោគដែលចាំបាច់ផងដែរ ឱនភាពនៃការវិនិយោគលើវិស័យថាមពលនាពេលបច្ចុប្បន្ន មិនទាន់បានអនុវត្តនៅឡើយទេ ដែលវាគ្របដណ្តប់លើការទាញយកការបង្កើត និង ការចែកចាយផូស៊ីលឥន្ធនៈ ព្រមទាំងប្រភពថាមពលកកើតឡើងវិញផងដែរ។ ដូច្នេះ ការផ្តល់មូលនិធិទៅលើគម្លាតនៅក្នុងការវិនិយោគលើថាមពលដែលត្រូវការ គឺជាបញ្ហាដ៏សំខាន់មួយសម្រាប់បណ្តាប្រទេសនៅអាស៊ាន។ ហេដ្ឋារចនាសម្ព័ន្ធថាមពល និង

បច្ចេកវិទ្យាស្អាត មានតម្លៃថ្លៃ និង ត្រូវការការវិនិយោគទ្រង់ទ្រាយធំ និង ការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធសុខៗគ្នា។ នៅពេលនិយាយអំពីការផ្ដល់ហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងថាមពល ពាក្យថា "អាចទទួលបានប្រាក់កម្រៃ" "អាចទទួលបានហិរញ្ញប្បទាន" និង "អាចវិនិយោគបាន" នឹងតែងតែត្រូវបានលើកយកមកពិភាក្សានៅក្នុងចំណោមភាគីពាក់ព័ន្ធខុសៗគ្នា ពីព្រោះភាគីពាក់ព័ន្ធនីមួយនឹងសម្លឹងមើលគម្រោងដោយផ្អែកលើទស្សនវិស័យខុសៗគ្នា ពាក់ព័ន្ធនឹងថាតើពួកគេនឹងទទួលបានផលរបរចំនួនប៉ុន្មានពីការវិនិយោគរបស់ពួកគេ។ ឧទាហរណ៍៖ វិនិយោគិននីមួយៗ ដូចជា ធនាគារ រដ្ឋាភិបាល ឬ អ្នកអភិវឌ្ឍជាដើម នឹងមានគំនិតខុសៗគ្នាចំពោះអ្វីដែលគួរតែជាទម្រង់នៃហានិភ័យ/ផលរបររបស់គម្រោង។ នៅក្នុងទ្រង់ទ្រាយធំ គម្រោងដែលអាចទទួលបានប្រាក់កម្រៃ គឺជាគម្រោងដែលធនាគារមានបំណងផ្ដល់ហិរញ្ញប្បទាន។ ប៉ុន្តែការផ្ដល់ហិរញ្ញប្បទានរបស់ធនាគារ គឺជាសមាសធាតុតែមួយគត់នៃរចនាសម្ព័ន្ធវិនិយោគមូលធន ហើយវិនិយោគិនឯកជនភាគច្រើនព្យាយាមទទួលបានផលរបរខ្ពស់ជាងនេះខ្លាំងពី ការវិនិយោគរបស់ពួកគេ។ ដូច្នេះ ពាក្យ "អាចផ្ដល់ហិរញ្ញប្បទាន និង អាចវិនិយោគបាន" ត្រូវបានប្រើប្រាស់ប្រសិនបើគម្រោងបៃតង មើលទៅដូចជាគម្រោងដ៏រឹងមាំមួយ ដែលមានប្រាក់ចំណូលថេរ មានបណ្ដុំការធានាផ្នែកឥណទាន និង មានធានារ៉ាប់រងលើហានិភ័យផ្នែកនយោបាយ ដោយរំពឹងទុកថានឹងមានផលរបរមួយខ្ពង់ ឬ ផលរបរចន្លោះពី ១៣ ទៅ ១៩។ នេះគឺទាបជាងអត្រារារាំងឧបសគ្គយ៉ាងខ្លាំង ចំពោះវិនិយោគិនលើទ្រព្យម្ចាស់ដែលត្រូវបានកែសម្រួលតាមហានិភ័យ សម្រាប់គម្រោងទីផ្សារតូចៗ។ តាមធម្មតា គម្រោងបៃតងមានហានិភ័យជាច្រើន លើកលែងតែគម្រោងនោះត្រូវបានធានាដោយរដ្ឋាភិបាល។

ហិរញ្ញវត្ថុប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលត្រូវការវិនិយោគិនចម្រុះ (អាចជាអ្នកអភិវឌ្ឍន៍ និង/ឬ ក្រុមហ៊ុនភាគហ៊ុនឯកជន ឬ វិនិយោគិនលើសាជីវកម្ម) និង អ្នកផ្ដល់កម្ចីដែលផ្ដល់ជូនដោយធនាគារពាណិជ្ជ ឬ ការផ្ដល់មូលនិធិដោយវិស័យសាធារណៈ។ ឧទាហរណ៍៖ នៅក្នុងរចនាសម្ព័ន្ធមូលធនជាក់លាក់មួយ គម្រោងមួយអាចទទួលបានការវិនិយោគទ្រព្យម្ចាស់ពីក្រុមហ៊ុនភាគហ៊ុនឯកជន ឬ ក្រុមវិនិយោគិន ដែលមានកញ្ចប់ធានារ៉ាប់រងពីគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ (DFIs) ដូចជា ទីភ្នាក់ងារធានា ការវិនិយោគពហុភាគី (MIGA) សាជីវកម្មវិនិយោគឯកជនក្រៅប្រទេស (OPIC) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារពិភពលោក ឬ ធនាគារអភិវឌ្ឍន៍អាស៊ី និង បានសន្យាទទួលបានឥណពន្ធពីធនាគារមួយ ដូចជា Standard Bank ជាដើម។ វិនិយោគិននៅតាមស្ថាប័នអាចចូលរួមដោយផ្ទាល់ ឬ តាមរយៈការចាត់ចែងភាគហ៊ុនឯកជន ឬ ការទិញជម្រើសនៃការផ្ដល់ហិរញ្ញប្បទានដទៃទៀត ដូចជា សញ្ញាប័ណ្ណហេដ្ឋា

រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ជាដើម។ នាពេលបច្ចុប្បន្ន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធភាគច្រើនត្រូវបាន ផ្តល់ហិរញ្ញប្បទានដោយវិស័យឯកជន ភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPPs) ឬ ជំនួយការអភិវឌ្ឍន៍ផ្លូវការនៅខាងក្រៅសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ាន។ ចំពោះ PPPs រដ្ឋសមាជិកអាស៊ានមានគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធ វិធីសាស្ត្រផ្តល់ហិរញ្ញប្បទាន និង សមត្ថភាពផ្នែកហិរញ្ញវត្ថុនៅកម្រិតខុសៗគ្នា។ កម្មវិធី PPP ត្រូវបានបង្កើតឡើង និង ប្រើប្រាស់ជាពិសេសនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃ និង ប្រទេសហ្វីលីពីន និង នាពេលថ្មីៗនេះ នៅប្រទេសសិង្ហបុរី។ នៅខណៈពេលដែលប្រទេសកម្ពុជា និង ប្រទេសវៀតណាមមិនទាន់ធ្វើឲ្យ PPPs មានលក្ខណៈផ្លូវការទេនោះ ការចូលរួមរបស់វិស័យឯកជនបានប្រែជាមានសារសំខាន់កាន់តែខ្លាំងនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ប្រទេសឡាវ និង ប្រទេសមីយ៉ាន់ម៉ា មានសក្តានុពល ប៉ុន្តែពួកគេកំពុងតែប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនដោយសារកង្វះធនធានសារពើពន្ធ ដើម្បីចីរភាពសារពើពន្ធ។ PPPs មិនសូវមានសារសំខាន់នៅក្នុងប្រទេសប្រ៊ុយណេដារូសាឡឹមនោះទេ ដោយពួកគេមានធនធានហិរញ្ញវត្ថុដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ។

## របៀបដោះស្រាយជាមួយការប្រើប្រាស់ធ្យូងថ្មនៅក្នុងការផ្លាស់ប្តូរថាមពល នៅអាស៊ាន

ធ្យូងថ្ម ក្នុងនាមជាប្រភពថាមពលដែលមានចំនួនច្រើនបំផុត និង អាចទុកចិត្តបាន ខ្លាំងជាងគេបំផុត នឹងបន្តធ្វើជាប្រភពថាមពលដ៏ច្រើនលើសលប់ ក្នុងការផលិតអគ្គិសនី ដើម្បីបំពេញតាមតម្រូវការអគ្គិសនីដែលមានកើនឡើងយ៉ាងឆាប់រហ័សនៅតំបន់អាស៊ាន និង ប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍នៅទូទាំងពិភពលោក ទោះបីជាការប្រើប្រាស់ធ្យូងថ្មមានការធ្លាក់ចុះយ៉ាងខ្លាំងនៅបណ្តាប្រទេសនៃ OECD និង ប្រទេសអភិវឌ្ឍន៍ ដោយសារតួនាទីរបស់ឧស្ម័នថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យាជឿនលឿនក៏ដោយ។ នៅឆ្នាំ២០១៥ ភាគរយនៃការប្រើប្រាស់ធ្យូងថ្ម ក្នុងការផលិតអគ្គិសនីនៅអាស៊ាន មានចំនួន ៣២% ហើយភាគរយនេះនឹងកើនឡើងរហូតដល់ ៤២% ត្រឹមឆ្នាំ២០៤០ នៅខណៈពេលដែលភាគរយនៃការប្រើប្រាស់ឧស្ម័ននៅក្នុងការផលិតអគ្គិសនី មានចំនួន ៤២% នៅឆ្នាំ២០១៥ ហើយភាគរយនេះនឹងធ្លាក់ចុះមក ៣៧% នៅឆ្នាំ២០៤០ (Kimura និង Phoumin ២០១៩)។ កំណើននៃការប្រើប្រាស់ធ្យូងថ្មសម្រាប់ផលិតអគ្គិសនីនៅតាមបណ្តាប្រទេសនៅអាស៊ាន នឹងនាំឲ្យមានការស្ថាបនារោងចក្រថាមពលដើរដោយធ្យូងថ្មយ៉ាងទូលំទូលាយ ដោយគ្មានការប្រើប្រាស់បច្ចេកវិទ្យាធ្យូងថ្មស្អាត (CCT) ដែលល្អបំផុត ដែលអាចស្វែងរកបាន នឹងបណ្តាលឲ្យមានកំណើននៃការបញ្ចេញ GHG

និង CO2។ ស្របពេលជាមួយគ្នានោះ ការពណ៌នាអំពីអាកាសធាតុនៅ COP25 និង COP26 នាពេលខាងមុខ ទំនងជានឹងអនុវត្តការហាមឃាត់ការផ្តល់ហិរញ្ញប្បទានធ្យូងថ្មសាធារណៈ ដោយមិនដាក់កម្រិតតែលើបណ្តាប្រទេស OECD នោះទេ ប៉ុន្តែនៅទូទាំងពិភពលោកតែម្តង។ កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសអភិវឌ្ឍន៍នៅក្នុងការហាមឃាត់ការផ្តល់ហិរញ្ញប្បទានធ្យូងថ្ម មានគុណសម្បត្តិរបស់ពួកគេ ប៉ុន្តែប្រទេសទាំងនោះចាំបាច់ត្រូវយល់អំពីផលប៉ះពាល់អចេតនា ដែលអាចកើតចេញពីគោលនយោបាយទាំងនោះ។

យើងគួរតែកត់សម្គាល់ថា ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យានៅក្នុង CCTs បាន និង កំពុងតែសម្រេចបានយ៉ាងឆាប់រហ័សនៅក្នុងប្រទេសអភិវឌ្ឍន៍ នៅខណៈពេលដែលការផ្ទេរ និង ការផ្សព្វផ្សាយបច្ចេកវិទ្យាចំណេះធ្វើ នៃ CCTs ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ មានភាពយឺតយ៉ាវ។ វិធានការដែលត្រូវអនុវត្តដើម្បីកាត់បន្ថយការបញ្ចេញ CO2 និង GHG បានទទួលកម្លាំងជំរុញនៅក្នុងប្រទេសអភិវឌ្ឍន៍ ជាពិសេសនៅក្នុងចំណោមបណ្តាប្រទេសនៃ OECD នៅខណៈពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ខ្វះខាតមធ្យោបាយដើម្បីផ្គត់ផ្គង់បច្ចេកវិទ្យាដែលអាចស្វែងរកបាន ដើម្បីកាត់បន្ថយការបញ្ចេញ CO2 និង GHG។ លើសពីនេះទៀត ប្រទេសចិនកំពុងឈានទៅរកការផ្តល់ហិរញ្ញប្បទានដល់រោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្ម នៅជុំវិញពិភពលោកនៃប្រទេសកំពុងអភិវឌ្ឍន៍ ពីព្រោះវាមិនចងកាតព្វកិច្ចនឹងវិធាន និង បទប្បញ្ញត្តិរបស់ OECD នៅក្នុងការផ្តល់ហិរញ្ញប្បទានធ្យូងថ្ម។

វាគឺជាកង្វល់ពិតប្រាកដដែលថា ប្រសិនបើមិនបានផ្គូរផ្គងគ្នានឹងការរីកសាយភាយយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍថាមពលប្រកបដោយចីរភាពទេនោះ កំណើននៃការប្រើប្រាស់ធ្យូងថ្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីនឹងមានផលប៉ះពាល់អវិជ្ជមានចំពោះសន្តិសុខថាមពលនៅក្នុងតំបន់។ ដោយមានកំណើនដែលត្រូវបានរំពឹងទុកនៃចំណុះនៃការបង្កើតអគ្គិសនីដើរដោយធ្យូងថ្មសារធាតុបំពុលនៅក្នុងមូលដ្ឋានទាំងពីរ ពោលគឺការបញ្ចេញ CO2 និង GHG នឹងក្លាយជាបញ្ហាចម្បងនាពេលអនាគត។

ផ្អែកលើទិន្នន័យនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់[95] ការបញ្ចេញឧស្ម័នពីចំហេះផូស៊ីលឥន្ធនៈ និង ដំណើរការឧស្សាហកម្ម បានរួមចំណែកប្រហែល ៧៨% នៃកំណើនការបញ្ចេញ GHG ចាប់ពីឆ្នាំ១៩៧០ រហូតដល់ ឆ្នាំ២០១១។ ប្រទេសចិន សហរដ្ឋអាមេរិក អឺរ៉ុប និង ប្រទេសឥណ្ឌា គឺជាអ្នកបញ្ចេញខ្លាំងជាងគេបំផុត ដែលរួមចំណែកដល់ការបញ្ចេញ GHG ជាសកល ចំនួន ៣០%

---

95 EPA ទិន្នន័យនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ មាននៅ http://www.epa.gov/climatechange/ghgemissions/global.html (បានចូលប្រើប្រាស់នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥)។

១៥% ៩% និង ៦% ដោយឡែកពីគ្នា។ ដោយមានតម្រូវការនៃការផលិតអគ្គិសនីថ្មីៗ សំខាន់ៗ រោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្ម ដែលគ្មានការកាត់បន្ថយ កំពុងតែត្រូវបានសាងសង់កាន់តែច្រើនឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី។ និន្នាការទាំងនេះ នាំមកនូវតម្រូវការជាបន្ទាន់នៅក្នុងការដោះស្រាយនិរន្តរភាពបរិស្ថាននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសដែលកំពុងផលិតអគ្គិសនីនៅអាស៊ី និង តម្រូវការក្នុងការប្រើប្រាស់បច្ចេកវិទ្យាធ្យូងថ្មស្អាត។

## របៀបបង្កើនការជ្រាបចូលនៃថាមពលកកើតឡើងវិញ

នៅខណៈពេលដែលកំណើនសេដ្ឋកិច្ច បានបង្កើនលទ្ធភាពក្នុងការផ្គត់ផ្គង់ថាមពលកកើតឡើងវិញ (RE) នៅជុំវិញពិភពលោក ប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍នៅតែស្ថិតនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍។

ចំពោះសមាជិកអាស៊ាន ដែលអាចផ្គត់ផ្គង់ការវិនិយោគលើ RE កាន់តែខ្លាំងជាងនេះទៀតនោះ កង្វល់ដ៏សំខាន់មួយ គឺតម្រូវការការស្តុកទុកអគ្គិសនី និង ខ្សែបណ្តាញឆ្លាតវៃ ដើម្បីគាំទ្រដល់កម្រិតនៃការជ្រាបចូលរបស់ RE នៅក្នុងវិស័យអគ្គិសនីកាន់តែខ្ពស់។ បច្ចេកវិទ្យាខ្សែបណ្តាញឆ្លាតវៃ កំពុងតែធ្វើការរួមចំណែកយ៉ាងខ្លាំងក្លាដល់ខ្សែបណ្តាញអគ្គិសនី នៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួននៃ OECD រួចហើយ។ ទោះបីជាយ៉ាងណាក៏ដោយ បច្ចេកវិទ្យាទាំងនេះនៅតែស្ថិតក្រោមការសម្រិតសម្រាំង និង ការកែលម្អជាបន្តបន្ទាប់ ដូច្នេះ ពួកគេងាយរងគ្រោះដោយហានិភ័យផ្នែកបច្ចេកវិទ្យា និង មិនមែនបច្ចេកវិទ្យា ជាសក្តានុពល។ ដូច្នេះ កំណើន RE នឹងត្រូវបានដាក់កំហិតដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំង តាមរយៈការវិវឌ្ឍន៍នៃបច្ចេកវិទ្យាផងដែរ។ ចំណុចទាំងនេះក៏រួមបញ្ចូលសមត្ថភាពនៅក្នុងការប៉ាន់ប្រមាណ និង ការទស្សន៍ទាយទុកមុនអំពីភាពអាចស្វែងរកបាននៃប្រភពថាមពលកកើតឡើងវិញផងដែរ។ ចំណុះទាំងនេះស្នើផ្តល់អត្ថប្រយោជន៍បន្ថែម ជាពិសេសការសន្យាចំពោះភាពអាចទុកចិត្តបានកាន់តែខ្ពស់ និង ប្រសិទ្ធភាពនៃប្រព័ន្ធអគ្គិសនីជាទូទៅ។

នៅក្នុងការការពណ៌នាអំពីអាកាសធាតុ RE ផ្តល់ទស្សនវិស័យដ៏ភ្លឺថ្លាសម្រាប់វិស័យថាមពលនៅលើពិភពលោក។

ប្រទេសនានានៅអាស៊ាននឹងត្រូវអនុវត្តតាមនិន្នាការដូចគ្នានឹងប្រទេសដទៃទៀតនៅលើពិភពលោក និង ពង្រីកឧស្សាហកម្ម RE របស់ពួកគេ។ ដោយសារភាពរីកចម្រើននៃបច្ចេកវិទ្យា កំណើនដ៏ខ្លាំងក្លានៃ RE ដែលអាចនឹងកើតឡើងនាពេលអនាគត នឹងទទួលបានពីថាមពលខ្យល់ ពន្លឺព្រះអាទិត្យ និង ជីវឥន្ធនៈ ដែលនឹងប្រកួតប្រជែងជាមួយផូស៊ីលឥន្ធនៈតាមបែបប្រពៃណី។

នៅក្នុងចំណោមសេដ្ឋកិច្ចនានានៃអាស៊ាន ក៏មានវិសាលភាពដ៏ធំមួយនៃកំណើនវារីអគ្គិសនីផងដែរ ជាពិសេស នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចមិនសូវអភិវឌ្ឍន៍ ដូចជា ប្រទេសកម្ពុជា ប្រទេសមីយ៉ាន់ម៉ា និង ឡាវ ជាដើម។ នៅក្នុងប្រទេសជាច្រើននៅអាស៊ាន ក៏មានសក្តានុពលចំពោះកំណើនថាមពលកម្តៅផែនដីផងដែរ។ ដូច្នេះ ការកាត់បន្ថយការបញ្ចេញ CO2 ដ៏ធំធេងបំផុតត្រូវបានរំពឹងទុកថានឹងកើតឡើងនៅក្នុងវិស័យអគ្គិសនី តាមរយៈការចាប់ផ្តើមប្រើប្រាស់ថាមពលកកើតឡើងវិញឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ ដើម្បីធ្វើឲ្យថាមពលកកើតឡើងជ្រាបចូលក្នុងប្រព័ន្ធអគ្គិសនីក្នុងកម្រិតខ្ពស់នោះ ចាំបាច់ត្រូវមានការវិនិយោគដ៏ធំសម្បើមមួយនៅក្នុងការធ្វើសមាហរណកម្មប្រព័ន្ធអគ្គិសនី ដើម្បីអនុញ្ញាតឲ្យមានការសម្របសម្រួលអន្តរកម្មនៃការបង្កើតអគ្គិសនីដែលត្រូវបានចែកចាយ (រោងចក្រអគ្គិសនីដើរដោយថាមពលខ្យល់ រោងចក្រដើរដោយថាមពលពន្លឺព្រះអាទិត្យ (PV) ខ្នាតធំ ប្រព័ន្ធពន្លឺព្រះអាទិត្យ PV នៅលើដំបូល), ប្រព័ន្ធទីផ្សារ បច្ចេកវិទ្យាដែលឆ្លើយតបនឹងតម្រូវការ និង បច្ចេកវិទ្យាព័ត៌មាន (IT ពោលគឺ ការទទួលបានទិន្នន័យ និង ការប្រាស្រ័យទាក់ទង)។ សមាហរណកម្មប្រព័ន្ធអគ្គិសនីដែលបានសម្របសម្រួលរួច តាមរយៈការប្រើប្រាស់បណ្តាញអ៊ីនធឺណិត (Internet of Things (IoT)) ត្រូវបានស្គាល់ថាជាប្រព័ន្ធខ្សែបណ្តាញឆ្លាតវៃ។ ដោយសារ EU សម្រេចបាននូវការបញ្ជ្រៀបថាមពលកកើតឡើងវិញក្នុងកម្រិតខ្ពស់ដោយប្រើប្រាស់ IoT ឬ ប្រព័ន្ធខ្សែបណ្តាញឆ្លាតវៃ អាស៊ានអាចទទួលបានមេរៀនជាច្រើនពី EU។

ដោយសារប្រព័ន្ធខ្សែបណ្តាញឆ្លាតវៃជាប់ពាក់ព័ន្ធនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធដ៏ស្មុគស្មាញ ដែលមុខងាររបស់វាអាស្រ័យលើធាតុដែលមានទំនាក់ទំនងទៅវិញទៅមកជាច្រើន ការវិនិយោគលើសមាសធាតុនៃប្រព័ន្ធខ្សែបណ្តាញឆ្លាតវៃនឹងមានសក្តានុពលយ៉ាងខ្លាំង លើតម្រូវការនៃប្រព័ន្ធអគ្គិសនីនាពេលអនាគត។

## សក្តានុពលនៃអ៊ីដ្រូសែនចំពោះថាមពលស្អាតនាពេលអនាគត

អ៊ីដ្រូសែនគឺជាធាតុដែលមានច្រើនបំផុតនៅលើសកលលោក និង មានសក្តានុពលនៅក្នុងការជួយជំរុញសេដ្ឋកិច្ច ស្របពេលជាមួយគ្នានោះ បញ្ចេញឧស្ម័នបន្តិចបន្តួច ឬ គ្មានការបញ្ចេញ។ អ៊ីដ្រូសែនអាចត្រូវបានប្រើប្រាស់ជាថាមពលស្អាតសម្រាប់យានជំនិះ សម្រាប់ការដុតកម្តៅ ការផលិតអគ្គិសនី ដំណើរការឧស្សាហកម្ម និង ការរក្សាទុកថាមពល។

តាមមហិច្ឆិតារបស់ EU នៅក្នុងការធ្វើឲ្យអឺរ៉ុបក្លាយជាទ្វីបដំបូងគេបង្អស់នៅលើពិភពលោក ដែលគ្មានការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាស ត្រឹមឆ្នាំ២០៥០ ឥន្ធនៈអ៊ីដ្រូសែននឹងមានតួនាទី

ដ៏សំខាន់ ក្នុងនាមជាកត្តាជំរុញដើម្បីសម្រេចបាននូវតុល្យភាពកាបូន។ អ៊ីដ្រូសែនទំនងជាស្ថិតនៅរបៀបវារៈរបស់ EU ពីព្រោះមានការយល់ព្រមដ៏ច្រើនលើសលប់នៅក្នុងចំណោមតួអង្គទាំងឡាយលើសារសំខាន់របស់អ៊ីដ្រូសែន នៅក្នុងទ្វីបអឺរ៉ុបដែលមានតុល្យភាពកាបូន (McKenna ២០២០)។ EU មានគម្រោងសម្ភោធមូលនិធិនវានុវត្តន៍ ដែលជាឧបករណ៍នៃការសន្យាថានឹងគាំទ្រដល់ការប្រើប្រាស់អ៊ីដ្រូសែននៅក្នុងវិស័យដែលពិបាកនឹងកាត់បន្ថយ ដូចជាការផលិតដែកជាដើម។ កាលពី ១០ឆ្នាំមុន មានការផ្តោតលើការផលិតថាមពល និង របៀបកាត់បន្ថយសារធាតុកាបូន។ ប៉ុន្តែនៅពេលនេះ គោលនយោបាយរបស់ EU កំពុងសម្លឹងមើលវិស័យដែលមានការពិបាកក្នុងការកាត់បន្ថយសារធាតុកាបូនខ្លាំងជាង។ មានការផ្តោតយ៉ាងខ្លាំងលើវិស័យដែក ប៉ុន្តែ EU ក៏កំពុងតែសម្លឹងមើលការចម្រាញ់ វិស័យសារធាតុគីមី និង ការដឹកជញ្ជូនផងដែរ រួមបញ្ចូលទាំងការដឹកជញ្ជូនធុនធ្ងន់ និង ការដឹកជញ្ជូនតាមផ្លូវសមុទ្រផងដែរ។ អឺរ៉ុបផ្តោតលើការពន្លឿនផលិតកម្មអ៊ីដ្រូសែនបៃតងពីប្រភពកកើតឡើងវិញ ប៉ុន្តែនៅត្រូវការរយៈពេលវែងទៀត ហើយភាគច្រើនវាមិនទំនងជានឹងកើតឡើងក្នុងទ្រង់ទ្រាយធំបានទេ រហូតដល់ឆ្នាំ២០៣០។

ស្របពេលជាមួយគ្នានេះ វានឹងត្រូវអាស្រ័យលើវិធីសាស្រ្តផលិតធម្មតា ក្នុងទ្រង់ទ្រាយធំ រួមជាមួយបច្ចេកវិទ្យាចាប់សារធាតុកាបូន ឬ ហៅថា អ៊ីដ្រូសែនខៀវ។

ការស្រាវជ្រាវលើថាមពលអ៊ីដ្រូសែន របស់ ERIA កាលពីពីរឆ្នាំមុន បានសម្គាល់ឃើញសក្តានុពលដ៏សំខាន់នៃការផ្គត់ផ្គង់ និង តម្រូវការថាមពលអ៊ីដ្រូសែន នៅក្នុងតំបន់ EAS។ ការសិក្សារបស់ ERIA បានប្រមើលមើលអំពីកំណើនជាសក្តានុពលនៃការកែសម្រួល និង ការប្រើប្រាស់អ៊ីដ្រូសែននៅគ្រប់វិស័យទាំងអស់ រហូតដល់ ឆ្នាំ២០៤០ ដោយតម្លៃអ៊ីដ្រូសែននឹងមានការធ្លាក់ចុះពី 0,៩0 ដុល្លារអាមេរិក/Nm³ (ម៉ែត្រគូបធម្មតា) នៅក្នុងប្រទេសជប៉ុន នាពេលបច្ចុប្បន្ន ទៅ 0,៣0-0,៤0 ដុល្លារអាមេរិក/Nm³ នៅឆ្នាំ២០៤០ ដែលមានភាពប្រកួតប្រជែងនឹងតម្លៃគោលដៅរបស់ប្រេងសាំង។ ប្រទេសចិនគឺជាអ្នកផលិត និង អ្នកប្រើប្រាស់ថាមពលអ៊ីដ្រូសែនដែលមានសក្តានុពលខ្លាំងជាងគេបំផុតមួយ ក្នុងពេលឆាប់ៗខាងមុខ។ ប្រទេសចិនមានបំណងធ្វើឱ្យមានរថយន្តកោសិកាឥន្ធនៈអ៊ីដ្រូសែនចំនួនមួយលានគ្រឿងនៅលើផ្លូវថ្នល់របស់ខ្លួនត្រឹមឆ្នាំ២០២៩និងត្រឹមឆ្នាំ២០២៣ ប្រទេសចិននឹងវិនិយោគទឹកប្រាក់ចំនួន ១៧ ប៊ីលានដុល្លារបន្ថែមទៀតលើអ៊ីដ្រូសែន។ ប្រទេសជប៉ុនមានភាពសកម្មនៅក្នុងការលើកកម្ពស់ការចាប់ផ្តើមប្រើប្រាស់អ៊ីដ្រូសែនសម្រាប់យានយន្ត រោងចក្រអគ្គិសនី និង ការប្រើប្រាស់ជាសក្តានុពលផ្សេងទៀត នៅទូទាំងសកលលោក។ អ្វីដែលយើងបានដឹងគឺថា ការប្រើប្រាស់អ៊ីដ្រូសែនកំពុងតែលាតសន្ធឹងនៅក្នុងវិស័យដឹកជញ្ជូន ហើយការចាប់ផ្តើមប្រើប្រាស់អ៊ីដ្រូសែនកំពុងតែទទួលបានកម្លាំងជំរុញ។ ឧទាហរណ៍៖ រដ្ឋាភិបាល

នៃរាជធានីតូក្យូនឹងបង្កើនចំនួនរថយន្តក្រុងដែលប្រើអ៊ីដ្រូសែនរហូតដល់ ១០០ គ្រឿង ត្រឹមឆ្នាំ២០២០ ហើយ រដ្ឋាភិបាលមូលដ្ឋាន Sarawak នឹងចាប់ផ្តើមដំណើរការរថយន្តក្រុងដែលប្រើអ៊ីដ្រូសែននាពេលឆាប់ៗនេះ។

នៅខែមិថុនា ឆ្នាំ២០១៩ មុនកិច្ចប្រជុំកំពូល G20 នៅទីក្រុងអូសាកា ទីភ្នាក់ងារថាមពលអន្តរជាតិ បានណែនាំថា ពិភពលោកត្រូវតែ "ទាញយកផលប្រយោជន៍ពីសក្តានុពលរបស់អ៊ីដ្រូសែនដើម្បីដើរតួដ៏សំខាន់មួយនៅក្នុងអនាគតនៃថាមពលស្អាត មានសុវត្ថិភាព និង មានតម្លៃសមរម្យ"។ នៅខណៈពេលដែលបញ្ហាប្រឈមនៅតែមានតម្លៃ ក្នុងការផលិតអ៊ីដ្រូសែនពីប្រភពកកើតឡើងវិញ ត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះត្រឹម ៣០% នៅទសវត្សរ៍ក្រោយ។

នៅខណៈពេលដែលបណ្តាលប្រទេសនៅជុំវិញសកលលោក ជាពិសេស ប្រទេសនានានៃ OECD និង ប្រទេសចិនព្យាយាមលើកកម្ពស់ការចាប់ផ្តើមប្រើប្រាស់ឥន្ធនៈអ៊ីដ្រូសែន មានឧបសគ្គផ្នែកតម្លៃ និង ឧបសគ្គផ្នែកស្ថាប័នខុសៗគ្នាជាច្រើន។

អ្នកជំនាញបានចែករំលែកអំពីឧបសគ្គពីរធំៗ ក្នុងការអភិវឌ្ឍថាមពលអ៊ីដ្រូសែនបៃតង ឬថាមពលអ៊ីដ្រូសែនស្អាត នៅក្នុងប្រទេសចិន។ ទីមួយ កង្វះខាតការសិក្សាសមិទ្ធិលទ្ធភាពគ្រប់ជ្រុងជ្រោយ និង មានសុពលភាព អំពីថាមពលកកើតឡើងវិញ ឬ ថាមពលស្អាត ជាសក្តានុពលព្រមទាំងបណ្តាញហេដ្ឋារចនាសម្ព័ន្ធនៃថាមពលដែលពាក់ព័ន្ធ សម្រាប់ការដឹកជញ្ជូន និង ការចែកចាយផងដែរ។ ទីពីរ មានឧបសគ្គផ្នែកស្ថាប័ន និង និយ័តកម្ម ដើម្បីធ្វើឲ្យគម្រោងអ៊ីដ្រូសែនអាចដំណើរការទៅបាន។ ឧទាហរណ៍៖ បទប្បញ្ញត្តិស្តីពីក្រុមហ៊ុនខ្សែបណ្តាញអគ្គិសនីនាពេលបច្ចុប្បន្ន ពុំមានសមត្ថភាពក្នុងការបញ្ជូនថាមពលកកើតឡើងវិញដែលមានការរឹតត្បិត ព្រមទាំងថាមពលនុយក្លេអ៊ែរ ទៅកាន់ទីតាំងផលិតអ៊ីដ្រូសែនឲ្យខិតចូលទៅជិតទីផ្សារតម្រូវការបាននោះទេ ហើយពួកគេក៏ពុំមានវត្ថុលើកទឹកចិត្តសម្រាប់ការកសាងខ្សែបន្ទាត់ថ្មីៗដែលផ្តោតលើគោលបំណងទាំងនោះដែរ។ លើសពីនេះទៀត បទប្បញ្ញត្តិលើវិស័យថាមពលនាពេលបច្ចុប្បន្នមិនអនុញ្ញាតឲ្យមានការផលិតអ៊ីដ្រូសែននៅនឹងកន្លែង នៅលើស្ថានីយ៍ថាមពលកកើតឡើងវិញ ដោយប្រើប្រាស់អគ្គិសនីដែលមានការរិតត្បិតនោះទេ។

## សេចក្តីបញ្ចប់ និង អត្ថន័យគោលនយោបាយ

ថាមវន្តផ្នែកសេដ្ឋកិច្ច សង្គម និង នយោបាយរបស់អាស៊ានបានធ្វើឲ្យអាស៊ានក្លាយជាតំបន់ដែលមានការរីកចម្រើនលឿនជាងគេបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៃកំណើនតម្រូវការថាមពល សន្តិសុខថាមពល និង លទ្ធភាពក្នុងការទិញថាមពល ដើម្បីគ្រប់គ្រង

ភាពរីកចម្រើននេះ គឺជាការពិតសម្រាប់គ្រប់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់នៅអាស៊ី មិនមែនចំពោះតែអាស៊ាននោះទេ។ នៅខណៈពេលដែលបណ្តាប្រទេសនៃ OECD សម្រេចបាននូវការកាត់បន្ថយការបញ្ចេញ GHG យ៉ាងឆាប់រហ័ស ដែលឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តផ្នែកអាកាសធាតុរបស់ COP21 នោះ ប្រទេសកំពុងអភិវឌ្ឍន៍ នៅអាស៊ីនៅតែមានសកម្មភាពមួយចំនួនដែលត្រូវអនុវត្តដើម្បីសម្រេចបាននូវតុល្យភាពនៃកំណើនសេដ្ឋកិច្ច លទ្ធភាពក្នុងការទិញថាមពល និង លទ្ធភាពក្នុងការស្វែងរកថាមពល។ ភាគច្រើននៃភាពចម្រុះនៃថាមពលនាថ្ងៃអនាគត របស់ប្រទេសកំពុងអភិវឌ្ឍន៍ នៅអាស៊ាន នឹងពឹងផ្អែកលើការប្រើប្រាស់ធ្យូងថ្មសម្រាប់ផលិតអគ្គិសនី។ ក្នុងករណីអាស៊ាន រដ្ឋសមាជិកជាច្រើនត្រូវបានបង្ខាំងឲ្យប្រើប្រាស់ធ្យូងថ្មក្នុងរយៈពេលជាច្រើនឆ្នាំ ដោយកិច្ចសន្យារបស់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មបានបង្ខាំងក្នុងរយៈពេល ២០-៣៥ឆ្នាំ។ ដូច្នេះ ការមិនអើពើចំពោះការប្រើប្រាស់ធ្យូងថ្មនៅអាស៊ាន មានន័យថា មិនអើពើចំពោះការពិត និង ការបញ្ចេញឧស្ម័នដោយសារការប្រើប្រាស់ធ្យូងថ្ម។ ការចាត់ទុកការប្រើប្រាស់ធ្យូងថ្មជាផ្នែកមួយនៃការផ្លាស់ប្តូរថាមពលនៅអាស៊ាន មានសារសំខាន់ខ្លាំងបំផុតចំពោះការដោះស្រាយសក្តានុពលនៃលទ្ធភាពក្នុងការទិញថាមពល និង ការប្រែប្រួលអាកាសធាតុ។ ដូច្នេះ ការប្រើប្រាស់បច្ចេកវិទ្យាធ្យូងថ្មស្អាត នឹងមានភាពបន្ទាន់ និង មានសារសំខាន់នៅក្នុងតំបន់។ ទោះបីជា គោលដៅថាមពលរបស់អាស៊ានត្រូវបានកំណត់ ដើម្បីនាំមកនូវការប្រើប្រាស់ផលិតថាមពលកកើតឡើងវិញកាន់តែច្រើនក៏ដោយ ក៏អាស៊ានប្រឈមមុខនឹងបញ្ហាប្រឈមនានានៅក្នុងការអនុវត្ត ដើម្បីគោលដៅទាំងនោះ ពីព្រោះថាមពលកកើតឡើងវិញនៅតែមានតម្លៃថ្លៃ ពាក់ព័ន្ធចំណាយលើប្រព័ន្ធ ហើយការជ្រាបចូលក្នុងកម្រិតខ្ពស់ត្រូវបានរារាំងដោយខ្សែបណ្តាញចាស់ៗដែលមិនអាចគ្រប់គ្រងការជ្រាបចូលនៃថាមពលកកើតឡើងវិញក្នុងកម្រិតខ្ពស់បាននោះទេ។ ដូច្នេះ ការប្រើប្រាស់ខ្សែបណ្តាញឆ្លាតវៃ IoT គឺជាហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគបៃតងថ្មី និង ដើម្បីអនុញ្ញាតឲ្យមានការជ្រាបចូលនៃថាមពលកកើតឡើងវិញបានកាន់តែខ្លាំង ប៉ុន្តែត្រូវការការវិនិយោគជាច្រើន ដូចជា ការវិនិយោគលើខ្សែបណ្តាញរឹងមាំ កម្មវិធី ការគ្រប់គ្រងទិន្នន័យ និង ធនធានមនុស្ស។ ឥន្ធនៈអ៊ីដ្រូសែនមានសក្តានុពលនៃថាមពលស្អាតនាពេលអនាគត ដោយសារតែភាពងាយបត់បែនរបស់វានៅក្នុងវិស័យជាច្រើន។

ការលើកកម្ពស់ និង ការអនុម័តលើឥន្ធនៈអ៊ីដ្រូសែននឹងមានសារសំខាន់ចំពោះសង្គមស្អាតនាពេលអនាគត។ EU និង ប្រទេសអភិវឌ្ឍន៍កំពុងតែឈានមុខគេនៅក្នុងការស្រាវជ្រាវ និង អភិវឌ្ឍអ៊ីដ្រូសែន ហើយអាស៊ាននឹងចាំបាច់ត្រូវតែតាមឲ្យទាន់ រៀនសូត្រ និង អនុម័តកម្មវិធី និង ប្រើប្រាស់អ៊ីដ្រូសែននៅក្នុងវិស័យសេដ្ឋកិច្ច។ ខាងក្រោមគឺជាអនុសាសន៍នៃគោលនយោបាយសំខាន់ៗ ដែលទាមទារការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំភ្លាមៗ៖

# ការប្រើប្រាស់ធ្យូងថ្មស្អាត

ការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី និង អាស៊ាន ដើម្បីឆ្ពោះទៅរកការទទួលស្គាល់អនាគតនៃថាមពលស្អាត នឹងតម្រូវឲ្យមានការដោះស្រាយជាមួយសមត្ថភាពក្នុងការបង្កើតធ្យូងថ្មថ្មីៗ សំខាន់ៗនាពេលបច្ចុប្បន្ន និង អនាគត ដែលជាការតម្រូវសម្រាប់ការផលិតអគ្គិសនី។ រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មដែលគ្មានការរាថយ កំពុងតែត្រូវបានស្ថាបនាកាន់តែច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ហើយ និន្នាការនេះនឹងនាំមកនូវតម្រូវការជាបន្ទាន់ ក្នុងការដោះស្រាយនិរន្តរភាពបរិស្ថាននៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនៅអាស៊ី ដែលកំពុងតែអភិវឌ្ឍវិស័យអគ្គិសនី និង តម្រូវការនៃការប្រើប្រាស់បច្ចេកវិទ្យាធ្យូងថ្មស្អាត។ ខាងក្រោមគឺជាអនុសាសន៍នៃគោលនយោបាយសំខាន់ៗមួយ ចំនួន។

- ការពណ៌នាអំពីអាកាសធាតុ និង អភិក្រមគោលនយោបាយនៃការហាមឃាត់មិនឲ្យប្រើប្រាស់ធ្យូងថ្ម នឹងត្រូវត្រួតពិនិត្យឡើងវិញដើម្បីជួយសម្រួលដល់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ក្នុងការទិញ CCTs ក្នុងលក្ខខណ្ឌដែលមានជម្រើសថាមពលដែលអាចស្វែងរកបានតិច សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ក្នុងរយៈពេលមធ្យម ដើម្បីបំពេញតាមតម្រូវការថាមពល។ ការចាត់ទុក CCT ជាដំណោះស្រាយបច្ចេកវិទ្យា នឹងក្លាយជាដំណោះស្រាយឈ្នះ-ឈ្នះ។

- ការអភិវឌ្ឍអាស៊ីនឹងពឹងផ្អែកលើ CCTs ដែលមាននៅលើទីផ្សារ ដែលមានតម្លៃសមរម្យ។ កម្ចីសម្រាប់ទិញបច្ចេកវិទ្យា ultra-supercritical (USC) ឬ បច្ចេកវិទ្យា advanced ultra-supercritical (A-USC) ដែលមានកម្រិតខ្ពស់ជាង ប្រសិនបើប្រៀបធៀបនឹងបច្ចេកវិទ្យា Supercritical (SC) និង sub-critical (C)។ ដូច្នេះ វាមានភាពចាំបាច់នៅក្នុងការបន្ទាបតម្លៃដែលត្រូវបង់ជាមុន សម្រាប់ការទិញ A-USC ឬ USC តាមរយៈគោលនយោបាយនានា ដូចជា គ្រោងការណ៍ហិរញ្ញប្បទាន/កម្ចី សម្រាប់បច្ចេកវិទ្យា USC ឬ ស្ថាប័ននយោបាយរឹងមាំ ដើម្បីផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់ CCTs ដល់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី។

- ក្របខណ្ឌនៃគោលនយោបាយគួរតែបញ្ជាក់យ៉ាងច្បាស់អំពីទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុននៃប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗគ្នា តាមរយៈការគូសបញ្ជាក់អំពីវិធានការគោលនយោបាយក្នុងរយៈពេលខ្លី និង រយៈពេលវែង ដើម្បីឆ្ពោះទៅកាន់ឧស្សាហកម្មធ្យូងថ្ម និង ការផលិតថាមពលដើរដោយធ្យូងថ្ម ដោយបង្កើតល្បឿននៃ

ការស្រាវជ្រាវ និង ការអភិវឌ្ឍ (R&D) នៃការដកហូត ការប្រើប្រាស់ និង ការរក្សាទុកសារធាតុកាបូន (CCUS) សម្រាប់ការធ្វើពាណិជ្ជកម្មក្នុងពេលឆាប់ៗ ឬ នៅពេលក្រោយក្នុងថ្ងៃអនាគតដ៏ខ្លីនាពេលខាងមុខ។ គំរូអាជីវកម្មនឹងចាំបាច់ត្រូវអភិវឌ្ឍឡើងជុំវិញ CCUS។

- ត្រូវការការពិគ្រោះយោបល់ជាសាធារណៈ ឬ ការចូលរួមនៅក្នុងមូលដ្ឋានចំពោះផលប៉ះពាល់ជាសក្តានុពលនៃបច្ចេកវិទ្យាធ្យូងថ្មណាមួយដែលត្រូវបានជ្រើសរើស។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ស្ថាប័ននានាប្រហែលជាមិនបានសង្កត់ធ្ងន់លើការចូលរួមនៅក្នុងមូលដ្ឋានបែបនោះទេ។ ដូច្នេះ ចាំបាច់ត្រូវមានការរៀបចំយ៉ាងសកម្មដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីសេចក្តីអន្តរាយជាសក្តានុពល ដែលបណ្តាលមកពីរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មដែលមិនសូវមានប្រសិទ្ធភាព។
- ប្រទេសចិន ប្រទេសដែលឈានមុខគេនៅក្នុងការផ្តល់ហិរញ្ញប្បទានសាធារណៈដល់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មនៅអាស៊ី អាចពិចារណាបង្កប់បទដ្ឋានផ្នែកបរិស្ថាន នៅក្នុងយន្តការនៃការផ្តល់មូលនិធិ ដើម្បីធានាថាការដំណើរការរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម យ៉ោងហោចណាស់ក៏កំពុងតែប្រើប្រាស់បច្ចេកវិទ្យា USC នៃប្រទេសចិន សម្រាប់ការអភិវឌ្ឍអាស៊ី។

## ការជ្រាបចូលនៃ RE តាមរយៈខ្សែបណ្តាញឆ្លាតវៃ និង IoT

ជំនួយ និង កិច្ចសហប្រតិបត្តិការរបស់ EU នឹងក្លាយជាគន្លឹះដើម្បីជំរុញអាស៊ានឲ្យចូលទៅក្នុងកម្រិតដ៏ខ្ពស់មួយនៃ RE តាមរយៈការវិនិយោគ និង កិច្ចសហប្រតិបត្តិការលើខ្សែបណ្តាញឆ្លាតវៃ។ ទាំងនេះរួមមាន៖

- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ "រឹង" ដែលរួមបញ្ចូលសមាសធាតុផ្នែករូបវន្តរបស់ខ្សែបណ្តាញនៅក្នុងប្រទេស និង ចំពោះការតភ្ជាប់ខ្សែបណ្តាញអគ្គិសនីនៅអាស៊ានការផលិតអគ្គិសនីការបញ្ជូននិងបណ្តាញចែកចាយព្រមទាំងកន្លែងរក្សាទុកថាមពលផងដែរដើម្បីរក្សាតុល្យភាពការប្រែប្រួលនៃទម្ងន់ ដែលបណ្តាលមកពីការជ្រាបចូលរបស់ RE នៅកម្រិតកាន់តែខ្ពស់។
- ការវិនិយោគលើវិស័យទូរគមនាគមន៍ ដែលតំណាងឲ្យសេវាទូរគមនាគមន៍ ដែលពិនិត្យតាមដាន ការពារ និង គ្រប់គ្រងខ្សែបណ្តាញ។ ទាំងនេះរួមបញ្ចូលបណ្តាញនៅទីធ្លាធំ បណ្តាញនៅទីវាល បណ្តាញនៅផ្ទះ និង បណ្តាញនៅក្នុងតំបន់មូលដ្ឋាន។

- ការវិនិយោគលើការគ្រប់គ្រងទិន្នន័យ ដែលធានាចំពោះស្វែងរក និង ការប្រើប្រាស់ទិន្នន័យឲ្យបានត្រឹមត្រូវ ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ខ្សែបណ្ដាញឆ្លាតវៃ។
- ការវិនិយោគលើឧបករណ៍ និង បច្ចេកវិទ្យាសូហ្វវែរ ដែលប្រើប្រាស់ និង ដំណើរការព័ត៌មានដែលប្រមូលបានពីខ្សែបណ្ដាញ ដើម្បីពិនិត្យតាមដាន ការពារ និង គ្រប់គ្រងស្រទាប់ហេដ្ឋារចនាសម្ព័ន្ធផ្អែករឹង និង ពង្រឹងខ្សែបណ្ដាញ ដើម្បីអនុញ្ញាតឲ្យមានសមាហរណកម្មនៃថាមពលកកើតឡើងវិញ។

## ថាមពលស្អាតនៃឥន្ធនៈអ៊ីដ្រូសែននាពេលអនាគត

ឧស្សាហកម្មដែលទាក់ទងនឹងអ៊ីដ្រូសែននឹងក្លាយជាការវិនិយោគដ៏ធំសម្បើមមួយក្នុងពេលអនាគតដែលអាចទស្សន៍ទាយបាន។ ទោះបីជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវតែមានការពិចារណាអំពីគោលនយោបាយស្ដីពីការប្រើប្រាស់អ៊ីដ្រូសែននៅក្នុងទ្រង់ទ្រាយធំ និង ការអនុម័តគោលនយោបាយនោះ។ ខាងក្រោមគឺជាទិសដៅនៃគោលនយោបាយសំខាន់ៗសម្រាប់ការវិនិយោគលើអ៊ីដ្រូសែន។

- មានសក្ដានុពលដ៏ខ្លាំងក្លាសម្រាប់ការវិនិយោគលើការផលិតអ៊ីដ្រូសែន ពីថាមពលកកើតឡើងវិញ និង ថាមពលនុយក្លេអ៊ែរ។ លើសពីនេះទៀត អគ្គិសនីផលិតពី RE ដែលមានការរឹតត្បិត គឺស័ក្តិសមសម្រាប់ការផលិតអ៊ីដ្រូសែន ប៉ុន្តែចាំបាច់ត្រូវមានគោលនយោបាយ និង បទប្បញ្ញត្តិច្បាស់លាស់ ដើម្បីលើកកម្ពស់ការផលិតអ៊ីដ្រូសែនទាំងនោះ។
- ចំពោះយានជំនិះប្រើអ៊ីដ្រូសែន ដែលនឹងត្រូវចាប់ផ្ដើមប្រើប្រាស់យ៉ាងទូលំទូលាយនឹងចាំបាច់ត្រូវអភិវឌ្ឍស្ថានីយ៍បញ្ចូលឥន្ធនៈអ៊ីដ្រូសែន និង ទីតាំងដឹកជញ្ជូន និង រក្សាទុកអ៊ីដ្រូសែន។
- ការយល់ដឹងជាសាធារណៈ និង ការមានបំណងទូទាត់ប្រាក់រួមគ្នាជាមួយការផ្ដល់ហិរញ្ញប្បទានសាធារណៈលើការផលិត និង ខ្សែសង្វាក់ផ្គត់ផ្គង់អ៊ីដ្រូសែន នឹងក្លាយជាគន្លឹះសម្រាប់ការលើកកម្ពស់ការវិនិយោគ។
- រដ្ឋាភិបាលចាំបាច់ត្រូវកំណត់គោលដៅសម្រាប់ការជ្រាបចូល/ការប្រើប្រាស់អ៊ីដ្រូសែននៅគ្រប់វិស័យទាំងអស់។ គោលនយោបាយ និង គោលដៅថាមពលដើម្បីលើកកម្ពស់ការប្រើប្រាស់អ៊ីដ្រូសែននឹងលើកទឹកចិត្តឲ្យមានការវិនិយោគលើខ្សែសង្វាក់ផ្គត់ផ្គង់។

កិច្ចប្រជុំកំពូង ASEM នៅក្នុងឆ្នាំ២០២១ នឹងពិភាក្សាអំពីអនាគតនៃកិច្ចសហប្រតិបត្តិការរវាង អាស៊ី-អឺរ៉ុប សម្រាប់កម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយ ដែលដោះស្រាយកង្វល់របស់តំបន់ទាំងពីរនៅថ្ងៃអនាគត។ អនុសាសន៍ខាងលើនឹងជួយដល់ ASEM នៅក្នុងការអភិវឌ្ឍផែនទីបង្ហាញផ្លូវនៅក្នុងវិស័យថាមពលស្អាតសម្រាប់អាស៊ី និង អឺរ៉ុប។

# ឯកសារយោង


European Union (2020), EU Action: 2050 Long-term Strategy. https://ec.europa.eu/clima/policies/strategies/2050 (accessed 27 April 2020).

International Energy Agency (IEA) (2016), World Energy Outlook 2016. Downloadable at https://www.iea.org/reports/world-energy-outlook-2016 (accessed 12 March 2020).

IEA (2020), Global Energy Prospects and Their Implications for Energy Security and Sustainable Development. http://www.oecd.org/parliamentarians/meetings/gpn-meeting-february-2020/Faith-Birol-Global-energy-prospects.pdf (accessed 28 April 2020).

IEA and ERIA (2013), WEO-2013 Special Report: Southeast Asia Energy Outlook. Downloadable at https://webstore.iea.org/weo-2013-special-report-southeast-asia-energy-outlook (accessed 12 March 2020).

Kimura, S. and P. Han (eds.) (2019), Energy Outlook and Energy Saving Potential in

East Asia 2019. Downloadable at https://www.eria.org/publications/energy-outlook-and- energy-saving-potential-in-east-asia-2019/ (accessed 12 March 2020).

Kimura, S. and H. Phoumin (2019), Energy Outlook and Saving Potential in the East Asia. Jakarta: ERIA.

McKenna, J. (2020), Europe's New Love Affairs with Hydrogen. https://spectra.mhi.com/ europes-new-love-affair-with-hydrogen?gclid=EAIaIQobChMI-NS1xoaI6QIVlg4rCh1qMA PqEAAYASAAEgJf6vD_BwE (accessed 27 April 2020).

11

# ការពង្រឹងការទូតសភាដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព

CHHEANG VANNARITH

## សេចក្តីផ្តើម

ដែនអន្តរជាតិកំពុងតែមានភាពស្មុគស្មាញកាន់តែខ្លាំងឡើង ពីព្រោះវាវិវឌ្ឍន៍យ៉ាងឆាប់រហ័សទៅកាន់ពិភពលោកមួយមានលក្ខណៈស្មុគស្មាញចម្រុះ ដែលត្រូវបានកំណត់ដោយអន្តរទំនាក់ទំនងយ៉ាងស្មុគស្មាញ ការពឹងពាក់គ្នាទៅវិញទៅមក និងអន្តរប្រតិបត្តិការ។ រដ្ឋប្រជាជាតិកំពុងមានការពឹងពាក់គ្នាទៅវិញទៅមកកាន់តែច្រើន ហើយបញ្ហាពិភពលោកមានលក្ខណៈកាន់តែស្មុគស្មាញ និងមានទំនាក់ទំនងទៅវិញទៅមក។ សព្វថ្ងៃនេះ វាប្រាកដណាស់ដែលថា គ្មានប្រទេសណាមួយអាចដោះស្រាយបញ្ហាពិភពលោក ដូចជា ការប្រែប្រួលអាកាសធាតុ ភេរវកម្មអំពើហិង្សាជ្រុលនិយម គ្រោះធម្មជាតិ និង ជំងឺរាតត្បាតសកល តែម្នាក់ឯងបាននោះទេ។ ទោះជាយ៉ាងណា ធម្មានុរូប និងមុខងាររបស់អភិបាលកិច្ចពិភពលោក និង ប្រព័ន្ធពហុភាគីមានការធ្លាក់ចុះ នៅចំកណ្តាលរលកនៃនយោបាយគាំពារនិយម នយោបាយប្រជានិយម និងការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ។ កត្តាសំខាន់មួយដែលនាំឱ្យមានការមិនចុះសម្រុងជាមួយប្រព័ន្ធសកលភាវូបនីយកម្ម និង ប្រព័ន្ធពហុភាគី គឺកង្វះខាតការចូលរួមជាសាធារណៈនៅក្នុងការកំណត់ទ្រង់ទ្រាយអភិបាលកិច្ចពិភពលោកមួយប្រភេទដែលផ្តល់អត្ថប្រយោជន៍យ៉ាងពិតប្រាកដដល់ជីវភាពរស់នៅរបស់ប្រជាជន។

ក្នុងន័យនេះ កិច្ចសហការរបស់ភាគីពាក់ព័ន្ធជាច្រើនត្រូវបានទទួលស្គាល់ថាជាអភិក្រមមូលដ្ឋានដើម្បីកំណត់ដំណោះស្រាយពេញលេញ និង មានប្រសិទ្ធភាពចំពោះបញ្ហាប្រឈមរួមគ្នាទាំងនេះ។ អភិបាលកិច្ចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ (UN)។ គោលដៅដែលមានទំនាក់ទំនងខ្លាំងបំផុតទៅនឹងអភិបាលកិច្ច គឺ គោលដៅ ១៦.៦ ស្តីពីការអភិវឌ្ឍ “ស្ថាប័នឲ្យមានប្រសិទ្ធភាព មានគណនេយ្យភាព និង

មានតម្លាភាព នៅគ្រប់កម្រិតទាំងអស់" និងគោលដៅ ១៦.៧ ស្តីពី ការធានាចំពោះ "សេចក្តីសម្រេចដែលមានការឆ្លើយតបប្រកបដោយបរិយាប័ន្នមានការចូលរួម និង មានអ្នកតំណាង"។ គោលដៅដែលពាក់ព័ន្ធនឹងវត្ថុបំណងទាំងនេះ រួមមានគោលដៅ ១៧.១៤ ស្តីពីការពង្រឹង "ការបន្សុីគោលនយោបាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" និង គោលដៅ ១៧.១៦ ស្តីពីការពង្រឹង "ភាពជាដៃគូជាសកល" និង "ភាពជាដៃគូពហុភាគី"។

ការធ្លាក់ចុះនៃសាកលភាវូបនីយកម្ម និងការចុះទន់ខ្សោយនៃអភិបាលកិច្ចពិភពលោកដោយសារការវិលត្រឡប់មកវិញនៃនយោបាយរបស់ប្រទេសមហាអំណាច ការកើនឡើងនៃនយោបាយគាំពារនិយម និងនយោបាយប្រជានិយម និងប្រព័ន្ធពហុភាគីដែលគ្មានប្រសិទ្ធភាព បង្កការគំរាមកំហែងយ៉ាងខ្លាំងដល់សន្តិភាព និងវិបុលភាពពិភពលោក។ ក្នុងបរិបទនេះ ការទូតសភាមានតួនាទីកាន់តែសំខាន់នៅក្នុងការពង្រឹងអភិបាលកិច្ចពិភពលោក និង លើកកម្ពស់កិច្ចពិគ្រោះយោបល់ និងភាពជាដៃគូពហុភាគី។ ជំពូកនេះ ស្វែងយល់ពីតួនាទីរបស់ការទូតសភា និង ស្ថាប័នសភា នៅក្នុងការដោះស្រាយបញ្ហាពិភពលោក ដែលផ្តោតលើការសម្រេចបាននូវ SDGs និង វិធីដែលភាពជាដៃគូសភាវវាងអាស៊ី-អឺរ៉ុប (ASEP) អាចត្រូវបានប្រើប្រាស់ជាយន្តការមួយដើម្បីសម្រេចគោលបំណងទាំងនេះ។

## ការទូតសភា និង បញ្ហាសកល

បញ្ហាសកលមានភាពស្មុគស្មាញ ឆ្លងកាត់ព្រំដែន និង មានទំនាក់ទំនងទៅវិញទៅមកកាន់តែខ្លាំងឡើង។ ភាពស្មុគស្មាញនៃទំនាក់ទំនងបានប្រែជាមានលក្ខណៈធម្មតាតាមរបៀបថ្មី និង មានលក្ខណៈសំខាន់ចំពោះរបៀបរៀបរយរបស់ពិភពលោកដែលកំពុងតែមានការវិវឌ្ឍន៍ ដែលត្រូវបានកំណត់ទ្រង់ទ្រាយដោយតួអង្គជាច្រើន ដែលរួមបញ្ចូលមិនត្រឹមតែប្រទេសមហាអំណាចធំៗប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងប្រទេសមហាអំណាចកម្រិតកណ្តាល រដ្ឋតូចៗ ស្ថាប័នអន្តរជាតិ ស្ថាប័នសភា សាជីវកម្មពហុជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ចលនាសង្គមអន្តរជាតិ និងឧក្រិដ្ឋកម្មឆ្លងដែន និងបណ្តាញភេរវកម្មផងដែរ ក្នុងចំណោមតួអង្គដទៃទៀត (Acharya ២០១៧)។ របៀបរៀបរយនៃពិភពលោកដែលមានទំនាក់ទំនងដ៏ស្មុគស្មាញនេះត្រូវបានកំណត់លក្ខណៈដោយ (i) អវត្តមាននៃប្រទេសមហាអំណាចតែមួយនៅលើពិភពលោក (ii) ការកើនឡើងនៃចំនួន និង ភាពចម្រុះនៃតួអង្គ (iii) ការបន្តមានពិពិធភាពនៃវប្បធម៌ មនោគមវិជ្ជា និងនយោបាយ (iv) កំណើននៃការពឹងពាក់គ្នាទៅវិញទៅមកនៅកម្រិតសកល និង កម្រិតតំបន់ និង (v) អភិបាលកិច្ចជាច្រើនស្រទាប់។ នៅក្នុងពិភពលោកដែលមានទំនាក់ទំនងដ៏ស្មុគស្មាញនេះ ភាពជាអ្នកដឹកនាំដែលមានការសហការគ្នា គឺមានសារៈសំខាន់បំផុតនៅក្នុងការថែរក្សាសន្តិភាព

ការអភិវឌ្ឍ និងយុត្តិធម៌ (Acharya ២០១៧)។ សំណួរគឺ ថាតើសភាមានតួនាទីអ្វីខ្លះចំពោះរបៀបរៀបរយនៃពិភពលោកដ៏ស្មុគស្មាញ ដែលកំពុងតែមានការវិវឌ្ឍន៍នេះ?

## ចាប់តាំងពីចប់សង្គ្រាមត្រជាក់មក តួនាទីរបស់តួអង្គសភានៅក្នុងទំនាក់ទំនងអន្តរជាតិ

មានភាពរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់។ ស្ថាប័នសភាចូលរួមក្នុងកិច្ចការអន្តរជាតិតាមវិធីចំនួនបួន៖ (i) តាមរយៈការពង្រឹងសមត្ថភាពត្រួតពិនិត្យលើគោលនយោបាយការបរទេសរបស់រដ្ឋាភិបាល (ii) តាមរយៈការអនុវត្តការទូតសភា ទាំងនៅកម្រិតទ្វេភាគី និងកម្រិតពហុភាគី (iii) តាមរយៈការចូលរួមក្នុងអង្គការអន្តរជាតិ និង អង្គការក្នុងតំបន់ និង (iv) តាមរយៈការបញ្ជូនកង្វល់ ឬ សាររបស់ប្រជាជនក្នុងមូលដ្ឋាន ទៅអង្គការអន្តរជាតិ និង អង្គការក្នុងតំបន់ (Coefelice ២០១៧)។ សហភាពអន្តរសភា (IPU) បានសង្កត់ធ្ងន់ថា “ការទូតសភា គឺជាផ្នែកដ៏សំខាន់មួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយជួយផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រទេស និងប្រជាជនទាំងឡាយ និង ស្វែងរកការរួមចំណែកផ្នែកទស្សនៈវិស័យរបស់សភា ដល់អភិបាលកិច្ចពិភពលោក ព្រមទាំងការលើកកម្ពស់សន្តិភាពផងដែរ (IPU ២០១៩)។

ការទូតសភា ជាទូទៅ សំដៅទៅលើការប្រើប្រាស់នីតិវិធី និង យន្តការសភាដើម្បីជះឥទ្ធិពលលើទំនាក់ទំនងអន្តរជាតិ និង ការអនុវត្តគោលនយោបាយការបរទេស។ ការទូតសភា និយាយអំពី “ការបង្កើតតួអង្គរដ្ឋ” “ការប្រមូលផ្តុំអំណាច” និង “ឧត្តមគតិរួម” (Gots ២០០៥: ២៧៦)។ ការទូតសភា កំណត់ចំណុចដៅលើ “ការជំរុញប្រតិកម្ម ការសម្របសម្រួល និង ពង្រឹងមុខងារធម្មនុញ្ញរបស់សភាដែលមានស្រាប់ តាមរយៈកិច្ចសន្ទនារវាងប្រទេស និង ប្រទេស អំពីសំណួរស្តីពីគោលនយោបាយបើកចំហរាប់មិនអស់នៅទូទាំងទ្វីប និង គ្រប់កម្រិតនៃអភិបាលកិច្ច (Stavridis និង Jancic ២០១៧)។ សភាមានតួនាទីសំខាន់ផ្នែកគោលនយោបាយនៃការប្រាស្រ័យទាក់ទង និង អាចដើរតួជា “ខ្សែក្រវ៉ាត់បញ្ជូន” នៅក្នុងចំណោមរដ្ឋាភិបាល សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងប្រជាពលរដ្ឋផ្ទាល់ (Stavridis និង Jancic ២០១៦: ១១៥)។ ភស្តុតាងជាច្រើនបង្ហាញថាសភា និង អ្នកតំណាងរាស្ត្រ ជា “តួអង្គស្វ័យការពារ អ្នកផ្លាស់ទីដ៏សំខាន់ អ្នកត្រួសត្រាយផ្លូវ អ្នកកំណត់របៀបវារៈ និងជាតួអង្គសម្តែងតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន” នៅក្នុងកិច្ចការអន្តរជាតិ (Stavridis ២០១៦: ៣៦៨)។

ទាក់ទងនឹងសកម្មភាពនានា ការទូតសភាគ្របដណ្តប់លើកិច្ចការអន្តរជាតិពេញលេញដែលអនុវត្តដោយសមាជិកសភា ដែលមានគោលបំណង “បង្កើនការយោគយល់គ្នាទៅវិញទៅមក

រវាងប្រទេសនានា ដើម្បីជួយគ្នាកែលម្អការគ្រប់គ្រងរបស់រដ្ឋាភិបាល និងការតំណាងឲ្យប្រជាជន និង បង្កើនធម្មានុរូបតាមរបបប្រជាធិបតេយ្យរបស់ស្ថាប័នអន្តររដ្ឋាភិបាល" (Weisglas និង de Boer ២០០៧: ៩៣-៩៤)។ សាកលភាវូបនីយកម្ម សង្គមនីយកម្ម និង កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសធ្វើឱ្យសមាជិកសភាអាចពិភាក្សាអំពីបញ្ហាអន្តរជាតិជាច្រើន និង ផ្លាស់ប្តូរទម្លាប់អនុវត្តល្អបំផុតនៃការគ្រប់គ្រងអំណាចនីតិប្រតិបត្តិរបស់ពួកគេរៀងៗខ្លួន នៅក្នុងកិច្ចការអន្តរជាតិ (Stavridis និង Jancic ២០១៧)។ នៅក្នុងប្រព័ន្ធប្រជាធិបតេយ្យសភា ស្ថាប័នរដ្ឋសភា គឺជា "ស្ថាប័នការបរទេសស្វយ័តដែលផ្តល់ធាតុចូលរបស់ខ្លួនផ្ទាល់នៅក្នុងការបង្កើតគោលនយោបាយការបរទេស និង មានឥទ្ធិពលផ្ទាល់ខ្លួនលើគោលនយោបាយនោះ តាមរយៈការទូតសភា" (Stavridis និង Jancic, ២០១៧: ៥)។

ការទូតសភាអាចត្រូវបានចែកជាបួនស្រទាប់ នៅកម្រិតក្នុងរដ្ឋ អន្តររដ្ឋ ក្នុងតំបន់ និង អន្តរតំបន់។ សភាមានប្រសិទ្ធភាពបំផុតនៅក្នុងការប្រមូលផ្តុំតួអង្គ និង ភាគីពាក់ព័ន្ធផ្សេងៗគ្នា ចាប់ពីអ្នកធ្វើយុទ្ធនាការថ្នាក់មូលដ្ឋាន រហូតដល់មេដឹកនាំនយោបាយ ដើម្បីដោះស្រាយបញ្ហាពិភពលោក (Fiott ២០១១)។ តួនាទីនៅលើឆាកអន្តរជាតិមួយចំនួនរបស់សភា រួមមាន (i) ការរួមចំណែកដល់ការចរចាអន្តររដ្ឋាភិបាល និង ដំណើរការកសាងស្ថាប័ន (ii) ធ្វើការត្រួតពិនិត្យសភាលើដំណើរការចរចាអន្តរជាតិ (iii) ផ្តល់សច្ចាប័ន និង អនុវត្តកិច្ចព្រមព្រៀងអន្តរជាតិ (iv) លើកកម្ពស់កិច្ចសន្ទនាពហុភាគី ពាក់ព័ន្ធនឹងបញ្ហាអន្តរជាតិ និង ការឆ្លើយតប និង (v) ធ្វើការផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាអន្តរជាតិ និង អង្គការនានាទៅកាន់ពលរដ្ឋ។

បញ្ហាសកល ដូចជា ការប្រែប្រួលអាកាសធាតុ ជំងឺរាតត្បាត និង អំពើហិង្សាជ្រុលនិយម ជាដើម ប្រែជាកាន់តែស្មុគស្មាញដោយមានផលប៉ះពាល់ឆ្លងព្រំដែន។ សភាបានចាប់ផ្តើមកែសម្រួលអភិក្រមរបស់ខ្លួន ដើម្បីកំណត់គោលជំហរដោះស្រាយបញ្ហាពិភពលោកឲ្យមានប្រសិទ្ធភាពដោយដឹងថាមធ្យោបាយតែមួយគត់ ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាទាំងនោះគឺតាមរយៈកិច្ចសហប្រតិបត្តិការ និង ភាពជាដៃគូអន្តរជាតិ។ ការទូតសភា គឺជាមធ្យោបាយដ៏សំខាន់មួយនៅក្នុងការពង្រឹងធម្មានុរូប និង ទំនុកចិត្ត និង ភាពជឿជាក់ពីសាធារណជនចំពោះយន្តការសហប្រតិបត្តិការអន្តរជាតិ និង ប្រព័ន្ធពហុភាគី។ ប្រភពរបស់ការទូតសភា រួមមាន សមត្ថភាព ភាពស្របច្បាប់ ចំណេះដឹង និងការទទួលបានរបស់ស្ថាប័ន (Fanck ២០១៨)។

សមាជិកសភាគឺជាភ្នាក់ងារដ៏សំខាន់នៅក្នុងការប្រាស្រ័យទាក់ទង និង ការប្រមូលធាតុចូលសម្រាប់ និង ពីសមាជិករបស់ពួកគេ ទាក់ទងនឹងបញ្ហាអន្តរជាតិដែលមានផលជះលើសន្តិសុខ និង សុខុមាលភាពនៃសេដ្ឋកិច្ចសង្គមរបស់ពួកគេ។ ទោះបីជាមានកំណើននៃការធ្វើឲ្យគំនិតនានា

មានលក្ខណៈប្រជាធិបតេយ្យ ដោយសារវត្តមានរបស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍នៅគ្រប់ទីកន្លែងក៏ដោយក៏សមាជិកសភាត្រូវប្រាស្រ័យទាក់ទងជាមួយសមាជិករបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងការរំពឹងទុករបស់ប្រជាជនដែលកំពុងតែមានការកើនឡើង។ សមាជិកសភា ជាពិសេស អ្នកដែលធ្វើកិច្ចការបរទេស អាចអញ្ជើញថ្នាក់ដឹកនាំក្រសួងនៃរដ្ឋាភិបាល និង ទីភ្នាក់ងាររដ្ឋ ឱ្យសង្ខេបត្រួសៗ និងឆ្លើយសំណួរដេញដោល ស្តីពីបញ្ហាអន្តរជាតិ កិច្ចការបរទេស និង គោលនយោបាយពាណិជ្ជកម្មដែលមានផលជះលើពលរដ្ឋរបស់ពួកគេ។

បន្ថែមពីលើមធ្យោបាយដែលមានប្រសិទ្ធភាព និង ស្របច្បាប់នៃការផ្សព្វផ្សាយរបស់រដ្ឋាភិបាលទៅកាន់ប្រជាជនទៀតនោះ ស្ថាប័នសភាអាចមានឥទ្ធិពលលើគោលនយោបាយការបរទេស និងទំនាក់ទំនងអន្តរជាតិ តាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ និង ការអនុម័តច្បាប់ ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី យន្តការត្រួតពិនិត្យសភា ដូចជា សវនាការ និង ការដាក់ញត្តិ ការអនុម័តលើថវិកាប្រចាំឆ្នាំសម្រាប់សកម្មភាពការបរទេស និងការចរចាការទូតទ្វេភាគី និងពហុភាគី ជាពិសេស ការដោះស្រាយបញ្ហា និងជម្លោះឆ្លងដែន (Sayfullaev ២០១៦)។ លើសពីនេះទៀត ស្ថាប័នសភាមានតួនាទីយ៉ាងសំខាន់នៅក្នុងការទប់ស្កាត់ជម្លោះក្នុងតំបន់ ការរៀបចំគំនិតផ្តួចផ្តើមកសាងសន្តិភាព និង ការកសាងប្រទេសឡើងវិញក្រោយជម្លោះ (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ [UNDP] ២០០៦)។

នៅឆ្នាំ ២០១៦ IPU រួមជាមួយ UNDP បានចេញក្របខ័ណ្ឌគោលនយោបាយរួម និង ឧបករណ៍វាយតម្លៃលើតួនាទីរបស់សភាក្នុងការសម្រេចរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលជាការសន្យាជាសកលក្នុងការបញ្ចប់ភាពក្រីក្រ និងកំណត់ពិភពលោកនៅលើមាគ៌ាដែលមាននិរន្តរភាពដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន។ របៀបវារៈនៃការអភិវឌ្ឍប្រជាជនប្រកបដោយមហិច្ឆតានេះ ដែលត្រូវបានចារអនុម័តដោយថ្នាក់ដឹកនាំនៃរដ្ឋាភិបាលនានានៅក្នុងកិច្ចប្រជុំកំពូលរបស់ UN កាលពីខែកញ្ញា ឆ្នាំ២០១៥ ផ្តោតលើបណ្តុំ SDGs ទាំង ១៧ និង ចំណុចដៅដែលអាចធ្វើសកម្មភាពបានទាំង ១៦៩។ របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពចែងថា

> យើងទទួលស្គាល់ផងដែរនូវតួនាទីដ៏សំខាន់របស់រដ្ឋសភាជាតិតាមរយៈការអនុម័តច្បាប់ និង ការអនុម័តថវិកា និង តួនាទីរបស់ពួកគេ ក្នុងការធានាឲ្យបាននូវគណនេយ្យភាពចំពោះការអនុវត្តការប្តេជ្ញាចិត្តរបស់យើងឲ្យមានប្រសិទ្ធភាព...។ "យើង ប្រជាជន" គឺជាពាក្យចាប់ផ្តើមនៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ ធម្មនុញ្ញនេះចែងថា "យើង ប្រជាជន" កំពុងធ្វើដំណើរនៅថ្ងៃនេះ នៅលើវិថីឆ្ពោះទៅកាន់ឆ្នាំ២០៣០។ ការធ្វើដំណើរ

> របស់យើងនឹងមានការចូលរួមពីសំណាក់រដ្ឋាភិបាល ក៏ដូចជា សភា ប្រព័ន្ធអង្គការសហប្រជាជាតិ និង ស្ថាប័នអន្តរជាតិ អាជ្ញាធរដែនដី ជនជាតិដើមភាគតិច សង្គមស៊ីវិល ធុរកិច្ច និង វិស័យឯកជន សហគមន៍វិទ្យាសាស្ត្រ និង ការសិក្សាដទៃទៀត និងប្រជាជនគ្រប់រូប។ (UN ២០១៥)

ដើម្បីសម្រេច SDGs ចាំបាច់ត្រូវមានអភិក្រមក្នុងសង្គមទាំងមូល មានន័យថា ត្រូវតែមានការរួមបញ្ចូលប្រជាជននៅគ្រប់ដំណាក់កាលទាំងអស់ ចាប់ពីការរចនាគោលនយោបាយដំបូងរហូតដល់ការអនុវត្ត និង ការពិនិត្យតាមដាន។ សភាជាតិ និង សភាថ្នាក់ក្រោមជាតិ ត្រូវតែធ្វើការដើម្បីជួយសម្រួលដល់បញ្ហានេះ។ សមាជិកសភាមានទំនួលខុសត្រូវតាមរដ្ឋធម្មនុញ្ញ និង គណនេយ្យភាពប្រជាធិបតេយ្យ ដើម្បីគាំទ្រ និង តាមដានការអនុវត្ត SDG ដោយដើរតួជាចំណុចប្រសព្វរវាងប្រជាជន និង ស្ថាប័នរដ្ឋ និង លើកកម្ពស់ និងផ្ដល់ភាពអង់អាចដល់គោលនយោបាយ និង ច្បាប់ដែលផ្ដោតលើប្រជាជន ដើម្បីធានាថាគ្មាននរណាម្នាក់ត្រូវបានទុកចោលនោះទេ។ វត្ថុបំណងចម្បងមួយរបស់សភាគឺ បង្កើតកិច្ចសន្ទនាអំពី SDGs ជាមួយភាគីពាក់ព័ន្ធក្នុងមូលដ្ឋានដែលអនុញ្ញាតឱ្យពួកគេបញ្ចេញមតិអំពីរបៀបដែលពួកគេចង់ឃើញ SDGs ត្រូវបានអនុវត្តនៅក្នុងសហគមន៍របស់ពួកគេ។ ការសន្ទនាបែបនេះគួរតែជាផ្នែកធម្មតាមួយនៃអន្តរកម្មរវាងរដ្ឋាភិបាល សភា សមាជិកសភា និងសាធារណជន (UNDP ២០១៧)។

សមាជិកសភាដើរតួយ៉ាងសំខាន់នៅក្នុងការដឹកនាំគោលនយោបាយ តាមរយៈការរៀបចំ និង ការបញ្ចូល SDGs នៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ និង ភាពជាអ្នកដឹកនាំដែលជួយឲ្យ សម្រេចគោលដៅទាំងនោះ រៀបចំការស្រុះស្រួលលើមតិនយោបាយ និងដំណោះស្រាយគោលនយោបាយជាក់លាក់ដើម្បីសម្រេច SDGs ចែករំលែកការវ្លះបញ្ជាំង និងធាតុចូល និង ស្នើសុំអនុសាសន៍ស្ដីពីការអនុវត្ត SDG។ វាគ្មិនសភាមកពីជុំវិញពិភពលោក បានបើកសន្និបាតមួយនៅទីក្រុងហាណូយកាលពីខែមេសា ឆ្នាំ២០១៥ និង សន្និសីទនៅទីក្រុងញូវយ៉កចាប់ពីថ្ងៃទី៣១ ខែសីហា រហូតដល់ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ដោយមានបំណងចូលរួមជាធាតុចូលដល់ SDGs។

សេចក្ដីប្រកាសក្រុងហាណូយសង្កត់ធ្ងន់ដូចតទៅ៖

> យើងប្ដេជ្ញាខិតខំឱ្យអស់ពីសមត្ថភាពដើម្បីពង្រឹងភាពជាម្ចាស់របស់ប្រទេសទៅលើគោលដៅ ជាពិសេសតាមរយៈការធ្វើឱ្យពលរដ្ឋរបស់យើងស្គាល់អំពីគោលដៅទាំងនេះ។ ប្រជាជនត្រូវតែយល់ ថាតើគោលដៅទាំងនោះមានទំនាក់ទំនងនឹងជីវិតរបស់ពួកគេយ៉ាងដូចម្ដេចខ្លះ។ ក្នុងនាមជាតំណាងប្រជាជន យើងទទួលខុសត្រូវក្នុងការធានាថា រាល់មតិ

> យោបល់ទាំងអស់ត្រូវបានយកមកពិចារណានៅក្នុងដំណើរការនយោបាយ ដោយគ្មានការរើសអើង និង ដោយមិនគិតអំពីឋានៈសង្គមនោះទេ...។ យើងប្តេជ្ញាចិត្តធ្វើឲ្យគោលដៅទាំងនោះក្លាយជាច្បាប់ និង បទប្បញ្ញត្តិក្នុងប្រទេសដែលអាចអនុវត្តបាន រួមបញ្ចូលទាំងតាមរយៈដំណើរការថវិកាសំខាន់ៗផងដែរ។ ប្រទេសនីមួយៗត្រូវបំពេញតួនាទីរបស់ខ្លួនដើម្បីធានាថា រាល់គោលដៅទាំងអស់អាចសម្រេចបាន។ យើងជំរុញឲ្យរដ្ឋាភិបាលធ្វើការចរចាដោយត្រូវគិតគូអំពីតម្រូវការ និង ការរំពឹងទុកដ៏ពិតប្រាកដរបស់ពលរដ្ឋ និង ដោះស្រាយទំនាក់ទំនងសំខាន់ៗ រវាងការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ (IPU ២០១៥b)

សេចក្តីប្រកាសរបស់សន្និសីទពិភពលោកលើកទីបួននៃវាគ្មិនសភា គូសបញ្ជាក់អំពីតួនាទីសំខាន់ៗរបស់សភានៅក្នុងការអនុវត្ត SDGs។

> យើងទទួលស្គាល់នូវទំនួលខុសត្រូវសំខាន់ៗដែលមាននៅក្នុងសភា ដើម្បីធានាចំពោះការអនុវត្ត SDGs ថ្មីៗ។ ក្នុងនាមជាវាគ្មិន យើងត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើអ្វីៗគ្រប់យ៉ាងនៅក្នុងអំណាចរបស់យើង ដើម្បីជួយសម្រួលដល់ការពិចារណាលើច្បាប់ដែលពាក់ព័ន្ធ និង ការបែងចែកធនធានថវិកា និងធ្វើឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការសម្រេចគោលដៅ។ យើងនឹងដកស្រង់ចេញពីប្រភេទនៃសកម្មភាពជាច្រើនដើម្បីជួយបង្កើតការយល់ដឹងជាសាធារណៈ និង ភាពជាម្ចាស់របស់ប្រទេស ពង្រឹងទំនាក់ទំនងរវាងរដ្ឋបាលជាតិ និង រដ្ឋបាលមូលដ្ឋាន និង សភា ជួយសម្រួលដល់ការចូលរួមរបស់ពលរដ្ឋ និង វាយតម្លៃ និង រាយការណ៍អំពីវឌ្ឍនភាព។ (IPU ២០១៥a)

តួនាទីសំខាន់ៗរបស់ស្ថាប័នសភា នៅក្នុងការដោះស្រាយបញ្ហាជាតិ និង បញ្ហាសកល មានទំនាក់ទំនងនឹងអំណាច និង អន្តរាគមន៍ស្របច្បាប់របស់ខ្លួន នៅក្នុងការតាក់តែងច្បាប់ ការចាត់ចែងថវិកា ការត្រួតពិនិត្យ និងការតំណាង។ គេបានអះអាងថា

> ...សមាជិកសភាផ្តល់កម្លាំងជំរុញផ្នែកនយោបាយ ដើម្បីឆ្ពោះទៅរកមូលដ្ឋាននីយកម្មការអនុវត្ត និង ការត្រួតពិនិត្យ SDGs។ សភានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនកំពុងតែប្រឈមមុខនឹងបញ្ហាប្រឈម និង ឧបសគ្គនានាចំពោះការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សភា រួមមាន (ក) សមត្ថភាព ធនធាន រចនាសម្ព័ន្ធ និង ដំណើរការមិនគ្រប់គ្រាន់ និង កង្វះខាតឆន្ទៈផ្នែកនយោបាយ (ខ) កង្វះខាតភាពងាយស្រួលក្នុងការទទួលបានជំនួយថវិកា និងព័ត៌មាន (គ) កង្វះខាតការចូលរួមរបស់ពលរដ្ឋជាប្រព័ន្ធ និង (ឃ) ការតំណាងឲ្យស្ត្រី និង ប្រជាជនសំខាន់ៗ មិនបានគ្រប់គ្រាន់។ (គណៈកម្មការសេដ្ឋកិច្ច និង សង្គមកិច្ចនៃអង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក ២០១៩)

## បញ្ហានៃការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ដំណើរការប្រជុំអាស៊ី-អឺរ៉ុប

ដំណើរការនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) បានផ្តួចផ្តើមឲ្យមានការសន្ទនាអំពីការអភិវឌ្ឍប្រកបដោយចីរភាព ដោយមានបំណងជំរុញបន្ថែមនូវកិច្ចពិភាក្សា និងការពិគ្រោះយោបល់អំពីគោលនយោបាយ និង វិធីដើម្បីសម្រេចបាន SDGs។ ការសន្ទនារបស់ ASEM ជាលើកដំបូងស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានធ្វើឡើងនៅទីក្រុងប៊ូដាប៉េស នៅឆ្នាំ ២០១២ បានផ្តោតលើតួនាទីរបស់ទឹកនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ប្រកបដោយចីរភាព។ ASEM លើកទីប្រាំបី ត្រូវបានធ្វើឡើងនៅខេត្តសៀមរាប ប្រទេសកម្ពុជានៅឆ្នាំ ២០១៩ ក្រោមប្រធានបទ "ពង្រឹងភាពជាដៃគូលើបញ្ហាទឹក ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព និង កំណើនប្រកបដោយបរិយាប័ន្ន" ដោយមានបំណងលើកកម្ពស់ការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ និងឧត្តមានុវត្ត នៅក្នុងក្របខ័ណ្ឌ ASEM លើវិស័យគោលនយោបាយសំខាន់ៗ ដូចជា ការទាក់ទងរវាងគ្នានឹងគ្នានៃទឹក-ថាមពល-សន្តិសុខស្បៀង ការប្រែប្រួលអាកាសធាតុ និង ភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដើម្បីសម្រេចបាននូវ SDGs។

ថ្នាក់ដឹកនាំ ASEM ក៏បានយកចិត្តទុកដាក់ជាពិសេសលើការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរតំបន់ និង ភាពជាដៃគូលើការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។ ឧទាហរណ៍៖ សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូល ASEM លើកទី ១១ ក្នុងឆ្នាំ ២០១៦ មានដូចតទៅ៖

ថ្នាក់ដឹកនាំទាំងឡាយបានគូសបញ្ជាក់ពីសារៈសំខាន់នៃការកែសម្រួលដំណើរការរៀបចំផែនការគោលនយោបាយជាតិ ផែនការ ឬ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ដើម្បីបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងការដាក់ឲ្យអនុវត្តការតាមដាន និង ពិនិត្យឡើងវិញជាប្រព័ន្ធ និងពហុស្រទាប់ លើការអនុវត្តរបៀបវារៈឆ្នាំ ២០៣០ នៅកម្រិតជាតិ និងអន្តរជាតិ។ ពួកគេបានសម្តែងការត្រៀមខ្លួនជាស្រេចនៅក្នុងផ្នែកមួយនៃ ASEM ដើម្បីចូលរួមចំណែកដល់ដំណើរការតាមដាន និងពិនិត្យឡើងវិញរបស់ UN និងអង្គការដទៃទៀត នៅកម្រិតពិភពលោក រួមទាំងនៅក្នុងវេទិកាកម្រិតខ្ពស់ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមការឧបត្ថម្ភរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ និងមហាសន្និបាតអង្គការសហប្រជាជាតិផងដែរ។ ដោយទទួលស្គាល់អំពីឱកាសព្រមទាំងបញ្ហាប្រឈមដែលដៃគូទាំងឡាយរបស់ ASEM អាចជួបប្រទះក្នុងការអនុវត្តរបៀបវារៈឆ្នាំ២០៣០ ថ្នាក់ដឹកនាំទាំងឡាយបានព្រមព្រៀងគ្នាលើកកម្ពស់កិច្ចសហប្រតិបត្តិការបន្ថែមទៀត ដែលរួមមានការចែករំលែកឧត្តមានុវត្ត និងបទពិសោធន៍ ក្នុងចំណោមដៃគូនៅក្នុងក្របខ័ណ្ឌនៃកិច្ចសន្ទនាអំពីការអភិវឌ្ឍប្រកបដោយចីរភាព

របស់ ASEM ដែលចាប់ផ្តើមដោយ គំនិតផ្តួចផ្តើមប៊ុយដាប៉េស។ (សេចក្តីថ្លែងការណ៍របស់ប្រធាន ឆ្នាំ២០១៦)

លើសពីនេះទៀត សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូល ASEM លើកទី ១២ ក្នុងឆ្នាំ ២០១៨ មានខ្លឹមសារដូចតទៅ៖

> ថ្នាក់ដឹកនាំបានសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការអនុវត្តឲ្យបានពេញលេញនូវរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង របៀបវារៈនៃវិធានការ Addis Ababa ក្នុងគោលបំណងលុបបំបាត់ភាពក្រីក្រ និង កសាងអនាគតមួយប្រកបដោយបរិយាប័ន្ន និងចីរភាពសម្រាប់អ្នកទាំងអស់គ្នា ដោយមិនទុកនរណាម្នាក់ចោល និង ផ្តោតខ្លាំងលើការឈោងចាប់ជនដែលងាយរងគ្រោះបំផុត។ ថ្នាក់ដឹកនាំបានសង្កត់ធ្ងន់លើតួនាទីរបស់ប្រជាជនវ័យក្មេងក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព និង តួនាទីដែលភាគីពាក់ព័ន្ធអាចបំពេញបាន ដើម្បីបន្តបរិយាប័ន្នសង្គម និង សេដ្ឋកិច្ច សង្គមដែលចីរភាព និង ការអភិវឌ្ឍដែលផ្តោតលើប្រជាជន និង សារសំខាន់នៃភាពជាដៃគូរវាងរដ្ឋ និង ឯកជន។ ថ្នាក់ដឹកនាំក៏បានគូសបញ្ជាក់ពីសារសំខាន់របស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង កិច្ចសហប្រតិបត្តិការប្រកបដោយនវានុវត្តន៍ នៅក្នុងការសម្រេចបាននូវរបៀបវារៈ ឆ្នាំ២០៣០ និង ដោះស្រាយបញ្ហាប្រឈមជាសកល តាមវិធីដែលមានចីរភាពផងដែរ។ (សេចក្តីថ្លែងការណ៍របស់ប្រធាន ឆ្នាំ២០១៨)

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស ASEM នៅក្នុងឆ្នាំ ២០១៩ រដ្ឋមន្ត្រីទាំងឡាយបានអំពាវនាវឲ្យមាន “ការពន្លឿនសកម្មភាព” និង “ការអនុវត្តពេញលេញ” នូវរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

រដ្ឋមន្ត្រីបានសង្កត់ធ្ងន់លើសារសំខាន់នៃការលុបបំបាត់ភាពក្រីក្រគ្រប់ទម្រង់ និង គ្រប់វិស័យ រួមទាំង ភាពក្រីក្រខ្លាំងក្លា ក៏ដូចជា ការការពារសិទ្ធិមនុស្ស ផងដែរ ដែលវាគឺជាតម្រូវការដែលមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ពួកគេបានអំពាវនាវឲ្យមានការផ្លាស់ប្តូរគំរូមួយដើម្បីបង្កើតវដ្តប្រកបដោយគុណធម៌នៃភាពរីកចម្រើនដែលគិតគូដល់បរិស្ថាន ស្របពេលជាមួយគ្នានោះ សង្កត់ធ្ងន់ថា ការអភិវឌ្ឍប្រកបដោយចីរភាព សន្តិសុខ និង សិទ្ធិមនុស្សត្រូវបានពង្រឹងទៅវិញទៅមក។ រដ្ឋមន្ត្រីបានសង្កត់ធ្ងន់លើតួនាទីរបស់ប្រជាជនវ័យក្មេង សង្គមស៊ីវិល និង ភាគីពាក់ព័ន្ធផ្សេងៗ រួមទាំង អាជីវកម្មដែលមានទំនួលខុសត្រូវផងដែរ។ ពួកគេបានគូសបញ្ជាក់

អំពីតួនាទីវិជ្ជមាននៃកិច្ចសហប្រតិបត្តិការរបស់ ASEM និង ការផ្លាស់ប្តូរឧត្តមានុវត្ត និង ការកសាងសមត្ថភាពលើវិស័យអប់រំ ការស្រាវជ្រាវ វិទ្យាសាស្ត្រ នវានុវត្តន៍ និងបច្ចេកវិទ្យា ដើម្បីប្រយុទ្ធប្រឆាំងនឹងវិសមភាព និង ភាពក្រីក្រ។ (សេចក្តីថ្លែងការណ៍របស់ប្រធាន ឆ្នាំ២០១៩)

## តួនាទីរបស់សភាក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ដើម្បីសម្រេច SDGs រដ្ឋាភិបាល និង ស្ថាប័នអន្តរជាតិត្រូវទទួលបានភាពស្របច្បាប់នៅក្នុងការកៀរគរសកម្មភាព និង ធនធាន។ ការវិនិច្ឆ័យពីតម្លៃ និង ការថ្លឹងថ្លែងក្នុងចំណោមវត្ថុបំណងសេដ្ឋកិច្ច សង្គម និង បរិស្ថាន មិនអាចត្រូវបានកំណត់ដោយរដ្ឋាភិបាលតែឯកឯងនោះទេ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធជាច្រើន និង ការយល់ដឹងរួមគ្នាអំពីធម្មជាតិ និង អត្ថប្រយោជន៍របស់ SDGs មានសារសំខាន់ចំពោះការកសាងភាពជាម្ចាស់ និង ការកៀរគរសកម្មភាព។ ការចូលរួមរបស់ពហុភាគីពាក់ព័ន្ធមានសារសំខាន់ខ្លាំងណាស់ បើគិតពីភាពយូរអង្វែងរបស់ SDGs (Monkelban ២០១៩: ៥៦)។

ការកសាងភាពជាដៃគូសកលលើការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានបង្ហាញនៅក្នុង SDG ១៧ ដែលបញ្ជាក់ថា ភាពជាដៃគូអន្តរជាតិ និង កិច្ចសហការរបស់ពហុភាគីពាក់ព័ន្ធ មានសារសំខាន់ចំពោះការសម្រេចបាននូវ SDGs។ SDGs ក៏សង្កត់ធ្ងន់ទៅលើសារសំខាន់នៃបរិយាប័ន្នផងដែរ ពោលគឺការចូលរួមពីគ្រប់ផ្នែកទាំងអស់នៃសង្គម ដើម្បីប្រមូលផ្តុំ និង ចែករំលែកចំណេះដឹង និង ជំនាញ ព្រមទាំងផ្តល់នូវធនធានបច្ចេកទេស និង ហិរញ្ញវត្ថុចាំបាច់ផងដែរ។

ស្ថាប័នសភា ដែលជាស្ពានភ្ជាប់ទំនាក់ទំនងដ៏សំខាន់រវាងរដ្ឋ និង សង្គម គឺជាភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងការកៀរគរធនធាន និង ដឹកនាំរបៀបវារៈជាតិឆ្ពោះទៅកាន់ការសម្រេចគោលដៅក្នុងតំបន់ និង គោលដៅអន្តរជាតិ។ ដូច្នេះ ភាពជាដៃគូរវាងរដ្ឋ និង ឯកជន និង ភាពជាដៃគូសង្គមស៊ីវិល មានសារសំខាន់ក្នុងការសម្រេចឱ្យបាននូវ SDGs។ SDG ១៦ បង្ហាញពីសារសំខាន់នៃការលើកកម្ពស់សង្គមប្រកបដោយសន្តិភាព និង បរិយាប័ន្ន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ សេចក្តីប្រកាសនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពចែងថា "យើងទទួលស្គាល់តួនាទីដ៏សំខាន់របស់សភាជាតិ តាមរយៈការអនុម័តច្បាប់ និង ការអនុម័តថវិកា និង តួនាទីរបស់ពួកគេនៅក្នុងការធានាបាននូវគណនេយ្យភាពក្នុងការអនុវត្តការប្តេជ្ញាចិត្តរបស់យើងបានយ៉ាងមានប្រសិទ្ធភាព"។

សភាមានតួនាទីសំខាន់ៗចំនួនបួន នៅក្នុងការសម្រេចបាននូវ SDGs៖ ការត្រួតពិនិត្យ ការធ្វើនីតិកម្ម ការតំណាង និង ការត្រួតពិនិត្យថវិកា។ ដើម្បីជួយបំពេញបេសកកម្មនេះសភាអាច (i)

បង្កើនការចូលរួមរបស់ជាតិ (ii) ផ្តល់វេទិកាមួយសម្រាប់កិច្ចពិភាក្សា និង កិច្ចសន្ទនាថ្នាក់ជាតិ និងអន្តរជាតិ (iii) ជំរុញការជជែកវែកញែក និង ការបង្កើតការព្រមព្រៀងជាឯកច្ឆន្ទ នៅក្នុងចំណោមភាគីពាក់ព័ន្ធថ្នាក់ជាតិ (iv) បង្កើតក្របខ័ណ្ឌច្បាប់រឹងមាំដែលជំរុញឲ្យភាគីដែលពាក់ព័ន្ធអនុវត្ត SDGs (v) ប្រមូលធាតុចូលពីប្រជាជន និង ក្រុមសង្គមស៊ីវិល (vi) បែងចែកកម្រិតថវិកាសមស្រប និង (vii) ធ្វើការត្រួតពិនិត្យដោយប្រើមូលប្បទានបត្រប្រចាំឆ្នាំ និង ស្នើសុំ និង ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ ដែលទទួលបានពីគណៈកម្មាធិការដែលពាក់ព័ន្ធទាក់ទងនឹងវឌ្ឍនភាពក្នុងការសម្រេចបាន SDGs។

សភាអាចចូលរួមចំណែកក្នុងការរៀបចំ និង អនុវត្តផែនការជាតិស្តីពី SDGs ដោយអនុវត្តដំណើរការពិគ្រោះយោបល់ជាសាធារណៈមានលក្ខណៈទូលំទូលាយ អនុម័តជាផ្លូវការនូវផែនការជាតិបន្ទាប់ពីការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយ និង ការជជែកវែកញែកជាផ្លូវការ និង ស្នើសុំរដ្ឋាភិបាលឲ្យមានរបាយការណ៍វឌ្ឍនភាពជាទៀងទាត់ស្តីពីការអនុវត្តផែនការជាតិ។ តួនាទីចម្បងរបស់សភាក្នុងការតាក់តែងច្បាប់ ការចាត់ចែងថវិកា ការត្រួតពិនិត្យ និង ការតំណាងឲ្យផលប្រយោជន៍របស់មណ្ឌលបោះឆ្នោត មានសារសំខាន់ចំពោះការអនុវត្ត SDGs ពេញលេញ (IPU ២០១៧)។

ការរួមចំណែករបស់សភាចំពោះការពិនិត្យឡើងវិញថ្នាក់ជាតិដោយស្ម័គ្រចិត្ត (VNRs) ជួយវាយតម្លៃ និង តាមដានវឌ្ឍនភាព ទាក់ទងនឹង SDGs។ មុខងារសំខាន់ៗរបស់ VNRs គឺការរៀបចំផែនការ និង ការធ្វើស្ថាប័ននីយកម្ម ការប្រមូលផ្តុំធាតុចូល និង ទិន្នន័យការសរសេរ និង ពិនិត្យឡើងវិញ និង ការធ្វើបទបង្ហាញ និងការតាមដាន។ ការផ្តល់ជូនរបស់ VNRs គឺជាការពង្រឹងភាពជាដៃគូពហុភាគីពាក់ព័ន្ធ និង ការលើកកម្ពស់ការចូលរួមយ៉ាងសកម្ម រួមជាមួយស្មារតីនៃភាពជាម្ចាស់ក្នុងចំណោមភាគីដែលពាក់ព័ន្ធទាំងអស់។ លើសពីនេះទៀត ការផ្តល់អាទិភាពដល់ SDGs នៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជាតិ ការបង្កើនការយល់ដឹងជាសាធារណៈ ការស្វែងរកមតិគាំទ្រផ្អែកគោលនយោបាយ និង ការបង្កើតយន្តការវាយតម្លៃដែលមានប្រសិទ្ធភាព និង មានបរិយាប័ន្ន ពាក់ព័ន្ធនឹងការអនុវត្ត SDGs ត្រូវបានចាត់ទុកថាជារឿងចាំបាច់។

ទាក់ទងនឹង SDG ១៦ (សន្តិភាព យុត្តិធម៌ និង ស្ថាប័នរឹងមាំ) សភាមានតួនាទីសំខាន់ក្នុងការបំពេញចំណុចដៅជាក់លាក់ពីរ៖ ចំណុចដៅ ១៦.៦ ស្តីពី "ការរៀបចំស្ថាប័នឲ្យមានប្រសិទ្ធភាព គណនេយ្យភាព និង តម្លាភាពនៅគ្រប់កម្រិត" និង គោលដៅ ១៦.៧ ស្តីពីការធានាចំពោះ "សេចក្តីសម្រេចដែលមានការឆ្លើយតប មានបរិយាប័ន្ន មានការចូលរួម និង មានអ្នកតំណាង"។ ចំណុចដៅផ្សេងទៀតសំដៅទៅលើគោលការណ៍សំខាន់ៗនៃអភិបាលកិច្ច

បែបប្រជាធិបតេយ្យ ដូចជា នីតិរដ្ឋ យុត្តិធម៌ ការទទួលបានព័ត៌មាន និង សេរីភាពមូលដ្ឋាន។ សភាត្រូវតែចូលរួមនៅក្នុងការអនុវត្ត និង ការត្រួតពិនិត្យក្របខ័ណ្ឌ SDG ទាំងមូល (IPU ២០១៧)។

បញ្ហាប្រឈមសំខាន់សម្រាប់សភា ជាពិសេស ក្នុងបណ្តាប្រទេសនៅអាស៊ី គឺ វិធីបង្កើនការចូលរួម និង ឥទ្ធិពលរបស់ប្រទេសទាំងនោះលើរបៀបវារៈ SDG ព្រោះកម្មវិធី SDG ត្រូវបានរៀបចំឡើងជាចម្បង ដោយអង្គនីតិប្រតិបត្តិ។ វេទិកាសភាអន្តរជាតិ ដូចជា IPU អន្តរសភាអាស៊ាន វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក វេទិកាសភាពិភពលោក ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និង ASEP ចាំបាច់ត្រូវកិច្ចខិតខំប្រឹងប្រែង និង ផ្តល់ធនធានបន្ថែមទៀត ក្នុងការអភិវឌ្ឍការមូលមតិគ្នាជាអន្តរជាតិ ក៏ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រចូលរួមទាក់ទងនឹង SDGs។

## កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

កិច្ចប្រជុំ ASEP បានប្រមូលផ្តុំសមាជិកសភាមកពីទ្វីបអាស៊ី និង អឺរ៉ុប ដើម្បីផ្តល់ធាតុចូលផ្នែកគោលនយោបាយ និង អនុសាសន៍ដល់ដំណើរការ ASEM។ ASEP គឺជាក្រុមសមាជិកសភា នៃ ASEM ហើយកិច្ចប្រជុំលើកដំបូងរបស់ខ្លួនត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៩៦ ស្របពេលជាមួយគ្នានឹង ASEM។ វាគឺជាវេទិកាក្រៅផ្លូវការ ហើយសេចក្តីប្រកាសរបស់ខ្លួនមិនចងកាតព្វកិច្ចតាមផ្លូវច្បាប់នោះទេ។

ASEP មានគោលបំណងសំខាន់ៗពីរ។ ទីមួយ វាដើរតួជាវេទិកាសម្រាប់ទំនាក់ទំនងអន្តរសភា ការផ្លាស់ប្តូរ និង ការទូតក្នុងចំណោមសភានានា និង ជាយានដើម្បីលើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមក នៅក្នុងចំណោមប្រជាជន និង បណ្តាប្រទេសនៅអាស៊ី និងអឺរ៉ុប។ ទីពីរ វាផ្តល់នូវការផ្សារភ្ជាប់គ្នារវាងសភាអាស៊ី និង អឺរ៉ុប និង ASEM អាស្រ័យហេតុនេះ ធ្វើឲ្យមានការចូលរួមចំណែកយ៉ាងសកម្មរបស់សភា ចំពោះដំណើរការរបស់ ASEM ជាពិសេស នៅក្នុងការប្រជុំប្រចាំឆ្នាំ។ សមាជិកសភានៃ ASEP បានគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនៃការទូតអន្តរសភា ដើម្បីធ្វើឲ្យមានការជឿទុកចិត្ត និង ការយោគយល់គ្នាទៅវិញទៅមកបន្ថែមទៀត និង ជំរុញកិច្ចសហប្រតិបត្តិការពហុភាគី រវាងបណ្តាប្រទេសនៅអាស៊ី និង អឺរ៉ុប តាមរយៈកិច្ចសហប្រតិបត្តិការនយោបាយ សេដ្ឋកិច្ច វប្បធម៌សង្គម និង ការអប់រំដែលមានភាពរឹងមាំជាងមុន។

ការសម្រេចបាន SDGs គឺជាផ្នែកដ៏សំខាន់មួយនៃកិច្ចសហប្រតិបត្តិការ ដែលសម្របសម្រួលដោយ ASEM។ ASEP ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកិច្ចសន្ទនា និង ជះឥទ្ធិពលដល់

គោលនយោបាយថ្នាក់ជាតិ និង ថ្នាក់តំបន់ ស្តីពី SDGs។ នៅក្នុងសេចក្តីប្រកាសរបស់ ASEP ស្ទើរតែទាំងអស់ ការអភិវឌ្ឍប្រកបដោយចីរភាព និង កំណើនប្រកបដោយបរិយាប័ន្ន គឺជាពាក្យពីរសំខាន់ៗ។ ជាឧទាហរណ៍៖ នៅ ASEP លើកទី ៨ នៅទីក្រុងរ៉ូម ក្នុងខែតុលា ឆ្នាំ២០១៤ សមាជិកសភាបានសង្កត់ធ្ងន់លើសារសំខាន់របស់អភិក្រមគ្រប់ជ្រុងជ្រោយ ក្នុងការដោះស្រាយការអភិវឌ្ឍប្រកបដោយចីរភាព ពោលគឺ តុល្យភាព និង សមាហរណកម្មនៃសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ពួកគេក៏បានសង្កត់ធ្ងន់លើសារសំខាន់នៃសន្តិសុខស្បៀង និង ការគ្រប់គ្រងធនធានទឹកចម្រុះ និង តួនាទីរបស់បច្ចេកវិទ្យាស្អាតផងដែរ។

សមាជិកសភានៃ ASEP បានទទួចជំរុញឲ្យមានការផ្លាស់ប្តូរឧត្តមានុវត្ត នៃបទពិសោធន៍នៅអឺរ៉ុប និង អាស៊ី នៃការអភិវឌ្ឍប្រព័ន្ធកសិកម្ម និង ស្បៀងអាហារប្រកបដោយចីរភាព... ពួកគេបានសង្កត់ធ្ងន់លើតម្រូវការក្នុងការធ្វើសមាហរណកម្មការគ្រប់គ្រងធនធានទឹក ទៅក្នុងវិស័យសេដ្ឋកិច្ច សង្គម និង បរិស្ថាន នៃការអភិវឌ្ឍប្រកបដោយចីរភាព...។ សមាជិកសភានៃ ASEP បានឯកភាពលើសារសំខាន់នៃការចែករំលែកបទពិសោធន៍ និង ចំណេះដឹងស្តីពីការគ្រប់គ្រងធនធានទឹកដែលបានធ្វើសមាហរណកម្ម [និង] ... បានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់បច្ចេកវិទ្យាស្អាត ថាជាធាតុដ៏សំខាន់មួយសម្រាប់ពង្រឹងការប្រកួតប្រជែង និង លើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព។ (ASEP ២០១៤)

នៅក្នុងកិច្ចប្រជុំ ASEP លើកទីប្រាំបួន នាថ្ងៃទី ២១-២២ ខែមេសា ឆ្នាំ២០១៦ នៅ Ulaanbaatar សមាជិកសភាបានបញ្ជាក់ថា៖

> ស្របតាមគោលដៅដែលបានកំណត់នៅក្នុងរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមាជិកសភានៃ ASEP បានបញ្ជាក់ឡើងវិញអំពីតម្រូវការក្នុងការកសាងសង្គមដែលមានសន្តិភាព យុត្តិធម៌ និង បរិយាប័ន្ន ដោយផ្អែកលើស្ថាប័នដែលមានតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព រួមទាំង ស្ថាប័ននីតិបញ្ញត្តិ នៅគ្រប់កម្រិតទាំងអស់ផងដែរ។ ដូច្នេះ សមាជិកសភានៃ ASEP បានសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់សភាជាតិ នៅក្នុងការអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ ក្នុងគោលបំណងអនុម័តលើច្បាប់ដែលពាក់ព័ន្ធ បែងចែកធនធានថវិកា និង ធានាបាននូវគណនេយ្យភាពរបស់រដ្ឋាភិបាល។ ពួកគេបានទទួលស្គាល់អំពីសារសំខាន់នៃការសន្ទនា និង កិច្ចសហប្រតិបត្តិការ ក្នុងចំណោមសភានៃ ASEP ដែលត្រូវបានគាំទ្រយ៉ាងល្អដោយការផ្លាស់ប្តូរទម្លាប់អនុវត្តល្អបំផុត ស្តីពីនីតិវិធី មុខងារ និង ការរៀបចំផ្នែករដ្ឋបាលរបស់សភា នៅក្នុងទម្រង់នៃការកសាងសមត្ថភាព។ (ASEP ២០១៦)

នៅក្នុងកិច្ចប្រជុំ ASEP លើកទី ១០ នាថ្ងៃទី ២៧-២៨ ខែកញ្ញា ឆ្នាំ ២០១៨ នៅទីក្រុងប្រ៊ុសសែល សមាជិកសភាបានគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងសម្រេចឲ្យបាននូវ SDGs។

កិច្ចប្រជុំ ASEP លើកទី ១០ អំពាវនាវឲ្យមានការប្ដេជ្ញាចិត្តខាងនយោបាយខ្ពស់បំផុតនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសប្រកបដោយប្រសិទ្ធភាពនៅគ្រប់ទិដ្ឋភាពទាំងអស់ រួមមានក្នុងចំណោមទិដ្ឋភាពដទៃទៀត ការកាត់បន្ថយ ការសម្រប ហិរញ្ញវត្ថុ ការអភិវឌ្ឍ និង ការផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និង តម្លាភាពនៃសកម្មភាព និង ការគាំទ្រ ដោយឆ្លុះបញ្ចាំងអំពីសមធម៌ និង គោលការណ៍នៃទំនួលខុសត្រូវ និងសមត្ថភាពរួមផ្សេងៗគ្នា...។ កិច្ចប្រជុំ ASEP លើកទី ១០ បង្ហាញអំពីតម្រូវការក្នុងការកំណត់គោលដៅប្រកបដោយមហិច្ឆតាលើការផលិត និង ការប្រើប្រាស់ប្លាស្ទិក ជាពិសេស សម្ភារប្លាស្ទិកដែលប្រើតែមួយដង និង អញ្ជើញ ASEM ឲ្យធ្វើការពិចារណាអំពីអនុសាសន៍ដ៏រឹងមាំនៅក្នុងទិសដៅឆ្ពោះទៅកាន់ការសម្រេចបានវឌ្ឍនភាពយ៉ាងខ្លាំងក្លា ដើម្បីធានាចំពោះរចនាបថនៃការប្រើប្រាស់ និង ការផលិតប្រកបដោយចីរភាព (គោលដៅទី ១២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព)...។ ASEP លើកទី ១០ បង្ហាញអំពីកង្វល់យ៉ាងខ្លាំងក្លារបស់ខ្លួន ចំពោះការបាត់បង់ជីវចម្រុះដែលមានគុណតម្លៃដ៏លើសលប់ជាបន្តបន្ទាប់ ដែលត្រូវតែការពារដើម្បីអត្ថប្រយោជន៍របស់មនុស្សជំនាន់ក្រោយ និង បញ្ជាក់អំពីតួនាទីដ៏សំខាន់របស់ជីវៈចម្រុះនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ (ASEP ២០១៨)

## សេចក្ដីបញ្ចប់

បញ្ហាសកល ជាពិសេស បញ្ហាចីរភាព មានលក្ខណៈស្មុគស្មាញ និង មានអន្តរទំនាក់ទំនងកាន់តែខ្លាំង។ ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាមធ្យោបាយមួយដើម្បីសម្រេចបាននូវចីរភាព និង បង្កប់នូវការយល់ដឹងយ៉ាងទូលំទូលាយអំពីប្រព័ន្ធបរិស្ថាន សង្គម និងសេដ្ឋកិច្ច។ កង្វះខាតអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និង កម្រិតសកលលោក ក្នុងការដោះស្រាយបញ្ហាចីរភាព គឺជាបញ្ហាមួយដែលគួរឲ្យព្រួយបារម្ភ។ ដូច្នេះ ចាំបាច់ត្រូវមានការផ្លាស់ប្ដូរនវានុវត្តន៍ក្នុងការគិត និង ការធ្វើសកម្មភាព។ ការដោះស្រាយបញ្ហាចីរភាពទាមទារឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ នៅគ្រប់កម្រិតនៃអភិបាលកិច្ច នោះមានន័យថា ជាការឆ្លើយតបដែលមានការសម្របសម្រួលនៅគ្រប់កម្រិតនៃអភិបាលកិច្ច និង គ្រប់វិស័យ និង គ្រប់តួអង្គទាំងអស់នៅក្នុងសង្គម។

នៅក្នុងរបៀបរៀបរយនៃពិភពលោកដ៏ស្មុគស្មាញដែលកំពុងតែមានការវិវឌ្ឍន៍នេះ ការចូលរួមរបស់ពហុភាគីពាក់ព័ន្ធ និង ការកសាងភាពជាដៃគូមានសារសំខាន់ណាស់។ ស្ថាប័នសភា

កំពុងតែដើរតួនាទីកាន់តែសំខាន់នៅក្នុងការដោះស្រាយបញ្ហាសកល ដែលមានភាពស្មុគស្មាញ និង មានទំនាក់ទំនងទៅវិញទៅមក។ ពាក់ព័ន្ធនឹង SDGs សភាមានតួនាទីសំខាន់ៗជាច្រើន ដូចជា ការត្រួតពិនិត្យ ការធ្វើនីតិកម្ម និង ការត្រួតពិនិត្យថវិកា។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីបង្កើនឥទ្ធិពលរបស់ពួកគេនៅក្នុងការកំណត់ទ្រង់ទ្រាយ និង ការអនុវត្ត SDGs សភាត្រូវតែពង្រឹងភាពជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នរបស់ពួកគេ និង អភិវឌ្ឍយុទ្ធសាស្ត្រចូលរួមដែលមានប្រសិទ្ធភាព។

ASEP គឺជាវេទិកាសភាអន្តរជាតិដ៏សំខាន់មួយដែលអាចលើកកម្ពស់កិច្ចសន្ទនា និង ការពិគ្រោះយោបល់របស់សភាលើរបៀបវារៈ SDG បន្ថែមទៀត ជាពិសេសការលើកកម្ពស់ការព្រមព្រៀងជាឯកច្ឆន្ទផ្នែកនយោបាយ ទាំងនៅថ្នាក់ជាតិ និង អន្តរជាតិ ការកៀរគរសកម្មភាព និង ធនធាន និងការកសាងភាពជាដៃគូអន្តរជាតិ និង កិច្ចសហប្រតិបត្តិការពហុភាគី ដែលចាំបាច់ដើម្បីសម្រេចបាននូវ SDGs។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការកសាងសមត្ថភាព ការចែករំលែកចំណេះដឹង និង កិច្ចខិតខំប្រឹងប្រែងរួមគ្នា លើ SDGs ត្រូវតែបានលើកកម្ពស់បន្ថែមទៀត។

អនុសាសន៍ជាក់លាក់សម្រាប់ ASEP មានដូចតទៅ៖ (i) លើកទឹកចិត្តសមាជិក ASEP ទាំងអស់ឲ្យអនុវត្ត VNR សម្រាប់ប្រទេសរបស់ពួកគេ និង បង្កើតវេទិកាចែករំលែកចំណេះដឹងដែលគ្របដណ្តប់លើលទ្ធផលរបស់ VNRs ទាំងនោះ (ii) បង្កើតកម្មវិធីកសាងសមត្ថភាពនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិករបស់ ASEP លើ SDGs សម្រាប់សមាជិកសភា និង បុគ្គលិករបស់ពួកគេ និង (iii) បង្កើតបេសកជនពិសេសរបស់ ASEP ស្តីពី SDGs ដើម្បីចូលរួមប្រកបជាមួយសមាជិកសភានៃ ASEP និង អង្គការអន្តរជាតិ ដូចជា UN ជាដើម បានយ៉ាងមានប្រសិទ្ធភាព។

SEM តម្រូវឲ្យមានសមាសធាតុទាំងអស់របស់ខ្លួន ដើម្បីលើកកម្ពស់សង្គមប្រកបដោយសន្តិភាព និង បរិយាប័ន្ន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព នៅអាស៊ី និង អឺរ៉ុប។ កិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM១៣) ក្នុងឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងបានយ៉ាងល្អ ដើម្បីលើកកម្ពស់ ASEP ឲ្យអនុវត្តអនុសាសន៍ខាងលើ និង ប្រើប្រាស់ ASEP ក្នុងនាមជាដៃគូដ៏មានឥទ្ធិពលនៃដំណើរការ ASEM។

# ឯកសារយោង

Acharya, A. (2017), 'After Liberal Hegemony: The Advent of a Multiplex World Order', Ethics & International Affairs, 31(3), pp. 271–285.

Acharya, A. (2019), 'Reshaping Global Order in the 21st Century: G-Plus Leadership in a Multiplex World', China and World Economy, 7(3), pp. 63–78.

Chair's Statement (2016), 20 Years of ASEM: Partnership for the Future through Connectivity. Ulaanbaatar. https://cdn.aseminfoboard.org/documents/Chairs-Statement-ASEM11- adopted_7JaJqc3.pdf (accessed 10 April 2020).

Chair's Statement (2018), Global Partners for Global Challenges, Asia–Europe Meeting. Brussels. https://cdn.aseminfoboard.org/documents/ASEM12-Chairs-Statement.pdf (accessed 10 April 2020).

Chair's Statement (2019), ASEM Foreign Ministers' Meeting. Madrid, 15–16 December. https://cdn.aseminfoboard.org/documents/2019-12-16-ASEM-FMM-Chairs-Statement.pdf (accessed 10 April 2020).

Cofelice, A. (2017), 'The Parliamentary Assembly of the Mediterranean and its Contribution to Democracy Promotion and Crisis Management', in S. Stavridis and D. Jancic (eds.) Parliamentary Diplomacy in European and Global Governance. Leiden: Brill Nijhoff, pp. 195–196.

Asia–Europe Parliamentary Partnership (ASEP) (2014), Declaration of the Eighth Asia–Europe Parliamentary Partnership Meeting (ASEP8), Rome, 6–7 October. https://cdn. aseminfoboard.org/documents/2014_-_ASEP8-Final_Declaration_1Z3CZcC.pdf (accessed 8 April 2020).

ASEP (2018), Declaration of the 10th Asia–Europe Parliamentary Partnership Meeting. Brussels, 27–28 September. https://cdn.aseminfoboard.org/documents/ASEP10- Adopted-Declaration.pdf (accessed 8 April 2020).

Fanck, D. (2018), 'Parliamentary Diplomacy and Legislative–Executive Relations in EU Foreign Policy: Studying the European Parliament's Mediation of the Macedonian Political Crisis (2015–17)', Journal of Common Market Studies, 56(6), pp. 1305–1322.

Fiott, D. (2011), 'On the Value of Parliamentary Diplomacy', Madariaga Paper, 4(7). http://88.255.97.25/reserve/resfall15_16/Hist311_DBarlas/Week_13.pdf (accessed 10 April 2020).

Gots, N. (2005), 'On the Origins of "Parliamentary Diplomacy"', Cooperation and Conflict: Journal of the Nordic International Studies Association, 40(3), pp. 263–279.

Inter-Parliamentary Union (IPU) (2015a), Fourth World Conference of Speakers of Parliament. New York, 31 August–2 September 2015. http://archive.ipu.org/pdf/publications/ speakers15-e.pdf (accessed 8 April 2020).

IPU (2015b), Hanoi Declaration, The Sustainable Development Goals: Turning Words into Action. Geneva, 1 April. http://archive.ipu.org/conf-e/132/rpt-gendebate.htm (accessed 8 April 2020).

IPU (2017), Parliaments and the Sustainable Development Goals. Geneva. https://www.ipu. org/resources/publications/toolkits/2017-01/parliaments-and-sustainable-development- goals-self-assessment-toolkit (accessed 8 April 2020).

IPU (2019), IPU Presidential Statement on Parliamentary Diplomacy. Geneva, 10 April. https://www.ipu.org/news/statements/2019-04/ipu-presidential-statement-parliamentary-diplomacy (accessed 8 April 2020).

Monkelban, J. (2019), Governance for the Sustainable Development Goals. Singapore: Springer.

Sayfullaev, D. (2016), 'Parliamentary Diplomacy in Making of Foreign Policy', International Journal of Development Research, 6(7), pp. 8590–8592.

Stavridis, S. (2017), 'Conclusions: Parliamentary Diplomacy as a Global Phenomenon', in S. Stavridis and D. Jancic (eds.) Parliamentary Diplomacy in European and Global Governance. Leiden: Brill Nijhoff, p. 368.

Stavridis, S. and D. Jancic (2016), 'Introduction: The Rise of Parliamentary Diplomacy in International Politics', The Hague Journal of Diplomacy, 11, pp. 105–120.

Stavridis, S. and D. Jancic (2017), 'Introduction: The Rise of Parliamentary Diplomacy in International Politics', in S. Stavridis and D. Jancic (eds.) Parliamentary Diplomacy in European and Global Governance. Leiden: Brill Nijhoff, pp. 5–6.

United Nations (2015), Transforming Our World: The 2030 Agenda for Sustainable Development. New York. https://sustainabledevelopment.un.org/post2015/transformingourworld/ publication (accessed 6 April 2020).

United Nations Development Programme (2006), Parliaments, Crisis Prevention and Recovery. New York. http://www.undp.org/content/dam/undp/library/Democratic%20Governance/Parliamentary%20Development/guidelines_on_the_role_of_parliaments_in_conflict_and_ post-conflict_situations.pdf (accessed 6 April 2020).

United Nations Development Programme (2017), Parliament's Role in Implementing the Sustainable Development Goals. New York. https://www.undp.org/content/dam/undp/library/Democratic%20Governance/Parliamentary%20Development/parliaments%20role%20in%20implementing%20the%20SDGs.pdf (accessed 6 April 2020).

United Nations Economic and Social Commission for Asia and the Pacific (2019), Parliamentary Engagement with the Sustainable Development Goals (SDGs): UNDP/ESCAP Parliamentary Workshop. Bangkok, October. https://www.unescap.org/sites/default/files/ Session%201_CC.pdf (accessed 6 April 2020).

Weisglas, F.W. and G. de Boer (2007), Parliamentary Diplomacy, The Hague Journal of Diplomacy 2, pp. 93–99.

# 12

# កិច្ចប្រជុំអាស៊ី-អឺរ៉ុប និង ចីរភាពសង្គមនៅក្នុងយុគសម័យនៃការតភ្ជាប់ប្រកបដោយភាពប្រកួតប្រជែង

JÜRGEN RÜLAND

## សេចក្តីផ្តើម

អស់រយៈពេលជិតមួយទសវត្សរ៍ ការតភ្ជាប់គឺជាពាក្យដ៏ពេញនិយមនៅក្នុងការតស៊ូដើម្បីយកឈ្នះលើភាពក្រីក្រ និង កង្វះការអភិវឌ្ឍនៅអាស៊ី និង ផ្នែកដទៃទៀតនៃប្រទេសលោកខាងត្បូង។ នៅខណៈពេលដែលការតភ្ជាប់គឺជាទស្សនាទានដ៏ទូលំទូលាយមួយដែលគ្របដណ្តប់លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បណ្តាញស្ថាប័ន និង អន្តរកម្មរវាងប្រជាជន និង ប្រជាជន រដ្ឋាភិបាលភាគច្រើនផ្តោតអាទិភាពលើសមាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តោតលើការអភិវឌ្ឍកំពង់ផែ និង អាកាសយានដ្ឋាន ផ្លូវថ្នល់ ផ្លូវរថភ្លើង និង ទីតាំងផលិតថាមពល ជាលក្ខខណ្ឌតម្រូវជាមុនសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ទស្សនវិស័យនេះឆ្លើយតបទៅនឹងការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលលើកឡើងថា ចាប់ពីឆ្នាំ២០១៦-២០៣០ ការអភិវឌ្ឍអាស៊ីត្រូវការការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាទឹកប្រាក់រហូតដល់ ១,៧ ទ្រីលានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ ដើម្បីចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុត ឬ គេចផុតពីអន្ទាក់នៃប្រាក់ចំណូលកម្រិតមធ្យម (២០១៦)។

ជាមួយផែនការមេ ឆ្នាំ២០១០ ស្តីពីការតភ្ជាប់អាស៊ាន[96] ដែលត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០១៦[97] សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានដឹកនាំការធ្វើទំនើបកម្មហេដ្ឋា

[96] មាននៅ https://cil.nus.edu.sg/wp-content/uploads/formidable/18/2010-Master-Plan-on-ASEAN-Connectivity.pdf (បានចូលប្រើប្រាស់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)។

[97] មាននៅ https://asean.org/storage/2016/09/Master-Plan-on-ASEAN-Connectivity-20251.pdf (បានចូលប្រើប្រាស់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)។

រចនាសម្ព័ន្ធអាស៊ី។ ប៉ុន្តែ វាគឺជាសេចក្តីប្រកាសអំពីគំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ (BRI) ខ្នាតយក្សរបស់ប្រទេសចិន នៅក្នុងឆ្នាំ២០១៣ ដែលបានធ្វើឲ្យការតភ្ជាប់ប្រែជាមានភាពលេចធ្លោជាសាធារណៈភ្លាមៗ។ BRI គឺជាយុទ្ធសាស្ត្ររយៈពេលវែង ដែលចំណាយប្រាក់ ១ ទ្រីលានដុល្លារអាមេរិក ដែលតភ្ជាប់រវាងប្រទេសចិន និង អឺរ៉ុបតាមរយៈកម្រងច្រករបៀងហេដ្ឋារចនាសម្ព័ន្ធនៅលើដី បណ្តាញផ្លូវសមុទ្រ និង នាពេលថ្មីៗនេះ គឺផ្លូវអាកាសឆ្លងកាត់តំបន់ប៉ូល។

គំនិតផ្តួចផ្តើមរបស់ប្រទេសចិន ត្រូវបានបន្តដោយ ភាពជាដៃគូរបស់ប្រទេសជប៉ុនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អ នៅក្នុងឆ្នាំ២០១៥។

បណ្តាប្រទេសដទៃទៀតនៅអាស៊ី រួមមាន ប្រទេសឥណ្ឌា សាធារណរដ្ឋកូរ៉េ ប្រទេសថៃ និង ប្រទេសម៉ាឡេស៊ីក៏បានបោះជំហាននៃសកម្មភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចូលមកក្នុងតំបន់ដែរ។ នៅដើមឆ្នាំ២០១៥ កិច្ចប្រតិបត្តិការផ្នែកសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក[98] បានបង្ហាញអំពីផែនការលម្អិតនៃការតភ្ជាប់ និង ក្រោយមក នៅក្នុងឆ្នាំ២០១៨ សហភាពអឺរ៉ុប[99] និង សហរដ្ឋអាមេរិក[100] ក៏បានចូលរួមនៅក្នុងការប្រកួតប្រជែងដើម្បីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែរ។ ខណៈពេលដែលរាល់គ្រោងការណ៍ទាំងនេះធ្វើការសន្មតយ៉ាងត្រឹមត្រូវថា ហេដ្ឋារចនាសម្ព័ន្ធគឺជាបុរេលក្ខខណ្ឌតម្រូវដ៏ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច ការតភ្ជាប់ ទោះបីជាត្រូវបានបដិសេធដោយតួអង្គចម្បងក៏ដោយ បានប្រែជាប្រទាក់ក្រឡាគ្នាជាមួយការពង្រឹងការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយនៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក។[101] ដោយសារតែការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយតម្រូវឲ្យម្ចាស់ជំនួយផ្តល់ហេដ្ឋារចនាសម្ព័ន្ធឲ្យបានឆាប់រហ័ស និង ដោយសន្សំសំចៃបំផុតតាមដែលអាចធ្វើបាន អ្នកវិភាគបានលើកសំណួរពីបញ្ហាចីរភាពរបស់គម្រោងទាំងនោះ។

ទន្ទឹមនឹងការតម្រង់ទិសឆ្ពោះទៅទិសខាងលិចរបស់ BRI នោះ វាមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលការតភ្ជាប់ក៏បានក្លាយជាប្រធានបទដ៏សំខាន់មួយនៅក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ដែលជាវេទិកាសន្ទនាអន្តរតំបន់ ដែលរៀបចំឡើងនៅក្នុងទម្រង់ជាកិច្ចប្រជុំកំពូល រៀងរាល់ពីរឆ្នាំម្តង

---

98 មាននៅ http://publications.apec.org/Publications/2015/01/APEC-Connectivity-Blueprint (បានចូលប្រើប្រាស់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០)។

99 ផ្អែកលើឯកសារស្តីពីយុទ្ធសាស្ត្រ "ការតភ្ជាប់អឺរ៉ុប និង អាស៊ី ពោលគឺវិស័យសម្រាប់យុទ្ធសាស្ត្ររបស់ EU" ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។

100 បានជួយសម្រួលដោយ "ការប្រើប្រាស់ការវិនិយោគកាន់តែល្អប្រសើរនាំទៅរកការអភិវឌ្ឍ" (ឬ ច្បាប់ BUILD) ត្រូវបានអនុម័តដោយសមាជ US ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

101 Business Times នៃប្រទេសសិង្ហបុរី បានកំណត់ភាពប្រកួតប្រជែងផ្នែកហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសចិន និង ប្រទេសជប៉ុន នៅក្នុងតំបន់ទន្លេមេគង្គ ថាជា "សង្គ្រាមនៃការអភិវឌ្ឍ"។ សូមមើល The Business Times ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥។ សូមមើល វេទិកាអាស៊ីបូព៌ា ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៣ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ ផងដែរ; The Diplomat ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

ចាប់តាំងពីឆ្នាំ១៩៩៦ មក (Rüland ១៩៩៦)។ បន្ទាប់ពីមានកិច្ចប្រជុំកំពូល ASEM លើកទីដប់នៅក្នុងឆ្នាំ២០១៤ នៅទីក្រុងមីឡាណូ ប្រទេសអ៊ីតាលី សេចក្តីថ្លែងការណ៍របស់ប្រធានបានផ្តោតលើការបង្កើនចន្លោះទំនេរសម្រាប់ការតភ្ជាប់ (Gaens ២០១៩)។ ក្រោយមកកិច្ចប្រជុំកំពូលឆ្នាំ២០១៦ នៅ Ulaanbaatar ប្រទេសម៉ុងហ្គោល បានដាក់ការតភ្ជាប់ជាប្រធានបទដ៏សំខាន់បំផុត។[102] ចាប់តាំងពីពេលនោះមក ដោយមើលឃើញកំណើននៃការផ្តោតជាអន្តរជាតិ លើចីរភាពផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច បរិស្ថាន និង សង្គមដែលមានភាពមិនគ្រប់គ្រាន់នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលទើបតែបានសម្ភោធថ្មីៗជាច្រើននោះ[103] ការផ្តល់ការតភ្ជាប់ប្រកបដោយចីរភាព បានក្លាយជាកង្វល់ដ៏សំខាន់មួយសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តរបស់ ASEM ដែលជាវត្ថុបំណងមួយដែលត្រូវបានគូសបញ្ជាក់នៅក្នុងរចនាបទដូច mantra នៅស្ទើរតែគ្រប់ឯកសាររបស់ ASEM។ ដូច្នេះ ការតភ្ជាប់ប្រកបដោយចីរភាពត្រូវបានពណ៌នាថាជា ទស្សនាទានដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របៀបវារៈនៃការអភិវឌ្ឍដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ២០១៥ ក្រោយពេលផុតកំណត់កម្មវិធីមុននោះរបស់សហគមន៍អន្តរជាតិ គឺ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ [104]

ការពិនិត្យស៊ីជម្រៅទៅលើការអនុវត្តជាក់ស្តែងនៃគម្រោងអឺរ៉ាស៊ី ណែនាំថា ការប្តេជ្ញាចិត្តផ្តល់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព នៅតែគួរឲ្យជឿច្រើនជាងខ្លឹមសារដែលត្រូវបានបញ្ជាក់។ នៅខណៈពេលដែលមានការកើនឡើងនៃការរិះគន់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគ្រោងការណ៍នៃការតភ្ជាប់ដទៃទៀត ហាក់បីដូចជាបានទាក់ទាញចំណាប់អារម្មណ៍លើចីរភាពផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង បរិស្ថាននោះ មិនសូវមានការរិះគន់ចំពោះអត្ថន័យចំពោះសង្គម និងគម្រោងទាំងនេះទេ”។ ការអភិវឌ្ឍមានចីរភាពផ្នែកសង្គម ប្រសិនបើវាមានបរិយាប័ន្ន យុត្តិធម៌មានភាពចម្រុះ មានតម្លាភាព និង ផ្តល់គុណភាពជីវិតល្អ តាមរយៈប្រាក់ចំណូលគ្រួសារជាចម្បងដែលលើកម្រិតភាពក្រីក្រព្រមទាំងសេវាសាធារណៈដែលមានតម្លៃសមរម្យ និង អាចទទួលបានផងដែរ។ គម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនមិនទាន់បានបំពេញតាមនិយមន័យនេះនៅឡើយទេ ដូច្នេះ ត្រូវបានហ៊ុំព័ទ្ធដោយភាពចម្រូងចម្រាស់ធ្ងន់ធ្ងរ។ ឯកសារនេះវិភាគអំពីផ្នែកសំខាន់ៗនៃបញ្ហាចីរភាព និង ផ្តល់គំនិតយោបល់អំពីរបៀបដែល ASEM អាចពង្រឹងចីរភាពសង្គមនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធអឺរ៉ាស៊ី។

102 កិច្ចប្រជុំកំពូលត្រូវបានធ្វើឡើងក្រោមប្រធានបទ “២០ឆ្នាំរបស់ ASEM៖ ភាពជាដៃគូដើម្បីអនាគត តាមរយៈការតភ្ជាប់”។

103 សូមមើលThe Business Times (សិង្ហបុរី) ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០។

104 The Jakarta Post ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨; Nikkei Asian Review ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩។ ចូលមើល គោលការណ៍ Ise–Shima របស់ G7 សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អផងដែរ https://www.mofa.go.jp/files/000196472.pdf (បានចូលប្រើប្រាស់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០)។

ឯកសារនេះត្រូវបានរៀបចំដូចតទៅ៖ បន្ទាប់ពីសេចក្តីផ្តើមនេះ ផ្នែកបន្ទាប់គូសបញ្ជាក់អំពីលក្ខណៈនៃបញ្ហានិរន្តរភាពសង្គមដែលគេស្គាល់យ៉ាងច្បាស់នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធអឺរ៉ាស៊ី។ ផ្នែកទីបីណែនាំអំពីធាតុចូលចំពោះវិធីដែល ASEM អាចរួមចំណែកដល់ការយកឈ្នះលើចំណុចខ្វះខាតទាំងនេះ។ ផ្នែកចុងក្រោយទាញសេចក្តីសន្និដ្ឋានអំពីឯកសារនេះ និង គូសបញ្ជាក់អំពីតម្រូវការក្នុងការកំណត់ទ្រង់ទ្រាយឡើងវិញក្នុងការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឆ្ពោះទៅកាន់ចីរភាពបរិស្ថាន និង សង្គមដែលកាន់តែល្អប្រសើរឡើង។

## ផលប៉ះពាល់លើសង្គមពីការតភ្ជាប់ប្រកបដោយភាពប្រកួតប្រជែង

គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗតែងតែប្រឈមមុខនឹងហានិភ័យ ពាក់ព័ន្ធនឹងគុណភាពបច្ចេកទេស វដ្តនៃជីវិត ចំណាយ និង និរន្តរភាពបរិស្ថាន និង សង្គម។ ប៉ុន្តែ ទោះបីជាមានបទពិសោធន៍រយៈពេល ៦ ទសវត្សរ៍ នៃការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងពិភពលោកក៏ដោយ ក៏សង្គមនៃគម្រោងនានា ជាញឹកញាប់ ត្រូវបានបញ្ជូនបន្តទៅកាន់ដែនដែលមានអាទិភាពតិចជាងដោយរដ្ឋាភិបាល វិនិយោគិន និង អ្នកជាប់កិច្ចសន្យា។ ដូច្នេះ Michael Cernea អតីតអ្នកជំនាញនៅធនាគារពិភពលោក និង ព្រឹទ្ធបុរសនៃការសិក្សាអំពីការដោះស្រាយផលប៉ះពាល់បានធ្វើការប៉ាន់ស្មានថា នៅទូទាំងពិភពលោក នៅក្នុងឆ្នាំ២០១១-២០២០ គម្រោងហេដ្ឋារចនាសម្ព័ន្ធកំពុងតែ ឬ នឹងធ្វើឲ្យមនុស្សជាង ២០០ លាននាក់ ត្រូវបានជម្លៀសដោយបង្ខំ (Cernea និង Maldonado ២០១៨) [105]។ ពួកគេ ភាគច្រើនបំផុត ប្រមាណ ៨០ លាននាក់ យោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យការជម្លៀសក្នុងប្រទេស (២០១៧) គឺជាជនរងគ្រោះដោយសារគម្រោងវារីអគ្គិសនី។

ដូចដែលការសិក្សា ដោយ Richter et al. (២០១០) ដែលត្រូវបានដកស្រង់ជាច្រើនបង្ហាញថា ប្រជាជនកាន់តែច្រើនដែលនៅតាមតំបន់ខ្សែទឹកខាងក្រោម ពោលគឺជិត ៥០០ លាននាក់ (យោងតាមការគណនាបែបអភិរក្ស) ប្រឈមទៅនឹងផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម ពីទំនប់ទឹកកាន់តែខ្លាំង។

ដូច្នេះ ឱនភាពនៃនិរន្តរភាពសង្គមនៅក្នុងសន្ទះនៃហេដ្ឋារចនាសម្ព័ន្ធអឺរ៉ាស៊ីនាពេលបច្ចុប្បន្នមិនមែនជារឿងចៃដន្យនោះទេ។ សូម្បីតែការវាយតម្លៃមិនពេញលេញក៏បានណែនាំផងដែរថា ប្រជាជនរាប់រយពាន់នាក់ទទួលរងផលជះ ឬ ត្រូវបានគំរាមកំហែងដោយការផ្លាស់ប្តូរទីលំនៅ

---

105 Mongabay ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨. ការប៉ាន់ស្មានដទៃទៀត ដូចជា ការប៉ាន់ស្មានដោយមជ្ឈមណ្ឌលត្រួតពិនិត្យការជម្លៀសក្នុងប្រទេស (២០១៧) ជាដើម បានប៉ាន់ស្មានថាមានចំនួនច្រើនជាងនេះ រហូតដល់ ៣០០ លាននាក់ ឬ ១០ លាន ទៅ ១៥ លាននាក់ក្នុងមួយឆ្នាំ។

ដោយមិនស្ម័គ្រចិត្ត បន្ទាប់ពីគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំនៅក្នុងតំបន់អឺរ៉ាស៊ី។ នៅក្នុងរបាយការណ៍របស់ប្រទេសឡាវតែមួយដែលជាប្រទេសតូចមួយ មានប្រជាជន ៧ លាននាក់ បានប៉ាន់ស្មានថា មានប្រជាជនជាង ១១០.០០០ នាក់ បានផ្លាស់ប្តូរទីលំនៅកាលពីប៉ុន្មានឆ្នាំមុន ដោយសារការសាងសង់ទំនប់ទឹក។[106]

បញ្ហាចម្បងមួយដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ គឺជាតម្រូវការដីធ្លីដ៏ធំធេង។ អាងស្តុកទឹកនៃទំនប់នានា ជាញឹកញាប់ គ្របដណ្តប់លើផ្ទៃដីរាប់រយគីឡូម៉ែត្រការ៉េ រហូតដល់រាប់ពាន់គីឡូម៉ែត្រការ៉េទនោះ ប៉ុន្តែតំបន់សេដ្ឋកិច្ចពិសេស (SEZs) ក៏ត្រូវការលាតសន្ធឹងនៅលើផ្ទៃដីដែលមានទំហំធំដែរ។ លទ្ធកម្មដីធ្លីក៏មានសារសំខាន់ចំពោះរោងចក្រអគ្គិសនីថ្មីៗ ទីតាំងបញ្ជូនអគ្គិសនី បំពង់ឧស្ម័ន ផ្លូវថ្នល់ ផ្លូវរថភ្លើង និង ការធ្វើទំនើបកម្មកំពង់ផែ និង អាកាសយានដ្ឋានផងដែរ។ ដូច្នេះ អ្នកអនុវត្តគម្រោងត្រូវធ្វើលទ្ធកម្ម និង នៅពេលខ្លះរឹបអូសដីធ្លីដែលត្រូវការ និង ធ្វើឲ្យប្រជាជនដែលរស់នៅលើដីធ្លីនោះត្រូវផ្លាស់ប្តូរទីលំនៅ (Mark និង Zhang ឆ្នាំ២០១៧)។[107] ប៉ុន្តែ ការដោះស្រាយផលប៉ះពាល់ និង ការផ្តល់សំណងដល់ការបាត់បង់ទ្រព្យសកម្ម និង ជីវភាពរស់នៅ គឺជាសមាសធាតុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពស្មុគស្មាញ និង មានភាពរសើបខ្លាំងជាងគេបំផុត។

គេចាំបាច់ត្រូវធ្វើការអង្កេតទិន្នន័យដើមគ្រាផ្នែកសេដ្ឋកិច្ចសង្គម និង ការអង្កេតសុរិយោដីឱ្យបានប្រុងប្រយ័ត្នពីដំបូង សម្រាប់ធ្វើការដោះស្រាយផលប៉ះពាល់ និង ការផ្តល់សំណង ប៉ុន្តែ ជាញឹកញាប់វាត្រូវបានឡើងយ៉ាងប្រញាប់ពន្យារពេល ឬ ខកខាតមិនបានធ្វើទាំងស្រុង។ ជាញឹកញាប់អភិបាលកិច្ចគម្រោង និង តម្លាភាព ជាបញ្ហាចោទយ៉ាងសំខាន់ (Rüland ២០១៩)។ ទោះបីជាមានការអបអរសាទរជាញឹកញាប់ថាជារឿងរ៉ាវជោគជ័យ ក៏ដោយ (សូម្បីតែធនាគារពិភពលោក) ដូចជាបានផ្តល់ហិរញ្ញប្បទានសម្រាប់ទំនប់ទឹក Nam Tuen 2 នៅ ប្រទេសឡាវ ឬ តំបន់សេដ្ឋកិច្ចពិសេស Thilawa ដែលនៅក្បែរយ៉ាំងហ្គូនក៏ដោយ ក៏ប្រទេសមីយ៉ាន់ម៉ាបានមានការលំបាកក្នុងការដោះស្រាយបញ្ហាជម្លៀសប្រជាពលរដ្ឋ (EarthRights International ២០១៤)។[108]

ជាធម្មតា ការដោះស្រាយផលប៉ះពាល់ បណ្តាលឲ្យមានបញ្ហាតាមមកជាបន្តបន្ទាប់។ ជាញឹក

106 Mongabay ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧

107 សូមមើល ក្នុងចំណោមសារព័ត៌មានផ្សេងទៀត The Bangkok Post ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤; Mekong Eye ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧; The Nation ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧; Focus Global South ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩; Frontier Myanmar ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០

108 M2 Presswire, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧; Irrawaddy ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧; Global English ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨; Thai News Service ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩; Frontier Myanmar ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០

ញាប់ កន្លែងតាំងទីលំនៅឡើងវិញ នៅឆ្ងាយពីទីលំនៅដើម និង មិនស័ក្តិសមសម្រាប់ការធ្វើកសិកម្ម និង ការនេសាទ ឬ សម្រាប់គម្រោងការងារជំនួស និង គម្រោងជីវភាពរស់នៅនោះទេ (DDA ២០១៤; Thame ២០១៧)។ ការដោះស្រាយផលប៉ះពាល់ ក៏ត្រូវបានបន្តដោយការរំខានផងដែរ ដល់រចនាសម្ព័ន្ធសង្គម ដែលកាលពីមុនធ្លាប់ចាក់ភ្ជាប់គ្នាយ៉ាងតឹង ព្រមទាំងការពារអ្នកភូមិនៅពេលមានវិបត្តិ។ វិបត្តិទាំងនោះកើតឡើងនៅពេលដែលគ្រួសារដែលបានតាំងទីលំនៅឡើងវិញ ត្រូវដោះស្រាយចំពោះបញ្ហាប្រាក់ចំណូលដែលមានការធ្លាក់ចុះ និង ចំណាយលើការរស់នៅដែលមានការកើនឡើងយ៉ាងខ្លាំង៖ ចំពោះស្បៀងអាហារ ធាតុចូលកសិកម្ម ការដឹកជញ្ជូន ផ្ទះសម្បែង ការអប់រំ ការផ្គត់ផ្គង់ទឹក និង សេវាសុខាភិបាល (Yee ២០០៥)។ នៅពេលនោះ ការធ្វើទេសន្តរប្រវេសន៍ទៅកាន់ចំណុចកណ្តាលនៃទីក្រុងគឺជាជម្រើសដែលមិនអាចជៀសវាងបាន។ នៅទីបំផុត អ្នកផ្លាស់ប្តូរទីលំនៅ ត្រូវស្វែងរកទីជម្រកនៅតាមសំណង់អាណាធិបតេយ្យ និង ទីលំនៅមិនរៀបរយ ហើយពួកគេបន្តរស់នៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញដោយបង្ខំ ដោយសារសកម្មភាពកែលម្អសោភ័ណ្ឌភាពទីក្រុង ដែលធ្វើឲ្យពួកគេក្លាយទៅជាជនដែលបង្កឱ្យមានផលប៉ះពាល់ក្នុងសង្គម។[109] ជាទូទៅ វាគឺជាក្រុមដែលមានប្រជាជនក្រីក្រជាងគេបំផុត និង ងាយរងគ្រោះខ្លាំងជាងគេបំផុត ដូចជា កសិករ អ្នកនេសាទ ជនក្រីក្រនៅតំបន់ទីក្រុង មនុស្សចាស់ ស្ត្រី កុមារ និង ជនជាតិដើមភាគតិច ដែលត្រូវរ៉ាប់រងកម្លាំងនៃបន្ទុកសង្គមដែលបង្កឡើងដោយទំនើបកម្មនៃហេដ្ឋារចនាសម្ព័ន្ធ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលធ្វើឲ្យប្រជាជនមួយផ្នែកធំត្រូវស្ថិតនៅក្រោមទំនើបកម្ម ដោយមិនរំពឹងថានឹងមានកែលម្អដែលគួរឲ្យកត់សម្គាល់ចំពោះជីវភាពរស់នៅរបស់ពួកគេនោះ គឺជាការខ្ជះខ្ជាយធនធានមនុស្សដែលមិនអាចទទួលយកបាន។

## តើយើងធ្វើឲ្យការតភ្ជាប់ដែលមានភាពប្រកួតប្រជែង មានចីរភាពសង្គមបានដោយរបៀបណា?

ដូចបានកត់សម្គាល់នៅផ្នែកខាងដើមនៃឯកសារនេះ ហេដ្ឋារចនាសម្ព័ន្ធអាចជាលក្ខខណ្ឌតម្រូវជាមុនដ៏សំខាន់មួយសម្រាប់កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលមានបរិយាប័ន្ន។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាចបំពេញតាមសេចក្តីរំពឹងទុកទាំងនេះបាន លុះត្រាតែគម្រោងទាំងនោះត្រូវបានរៀបចំផែនការ និង អនុវត្តយ៉ាងប្រុងប្រយ័ត្ន ហើយការការពារ និង វិធានការកាត់បន្ថយសម្រាប់ក្រុមដែលមានភាពទន់ខ្សោយផ្នែកសង្គម ត្រូវគេមិនអើពើ មានការខ្វះខាត និង ក្រុមងាយរងគ្រោះដទៃទៀត ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង និង

109 Irrawaddy ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

មិនត្រូវបានបំផ្លាញដោយសារការប្រកួតប្រជែងផ្អែកភូមិសាស្ត្រនយោបាយនោះទេ។ ដោយសារតែ ASEM គឺជាវេទិកាមួយដែលប្រទេសម្ចាស់ជំនួយតាមប្រពៃណី (លោកខាងលិច) នៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច និង ប្រទេសដែលមានសេដ្ឋកិច្ចទើបតែអភិវឌ្ឍន៍ថ្មី (អាស៊ី) ដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធ មកជួបគ្នានោះ វាត្រូវបានរៀបចំឡើងបានយ៉ាងល្អដើម្បីប្រមូលផ្តុំបទពិសោធន៍ល្អៗរបស់ម្ចាស់ជំនួយដែលមានជាយូរមកហើយ និង ថាមពលរបស់តួអង្គថ្មីៗ ដើម្បីហេដ្ឋារចនាសម្ព័ន្ធដែលមាននិរន្តរភាពសង្គម ដែលផ្តល់អត្ថប្រយោជន៍ដល់សមាជិករបស់វេទិកា។ ក្នុងគោលបំណងនេះ ផ្នែកនេះស្នើឡើងនូវបញ្ជីរាយនាមវិធានការនានាដែលមានបំណងពង្រឹងនិរន្តរភាពសង្គមនៃហេដ្ឋារចនាសម្ព័ន្ធនៅបណ្តាប្រទេសនៃ ASEM។

(i) ទោះបីជា ASEM បានកំណត់និយមន័យការតភ្ជាប់ប្រកបដោយចីរភាព[110] រួចហើយក៏ដោយក៏ដែនសង្គមនៅតែមានស្រពិចស្រពិលដដែរ។ ដូច្នេះ ដៃគូ ASEM គួរតែអនុម័តសេចក្តីប្រកាសអំពីក្របខណ្ឌមួយ ដែលកំណត់ភាពច្បាស់លាស់នៃនិយមន័យហេដ្ឋារចនាសម្ព័ន្ធដែលមានចីរភាពសង្គម។ គោលការណ៍ទី ៣ នៃគោលការណ៍ Ise-Shima របស់ G7 សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អនឹងក្លាយជាចំណុចផ្លាស់ប្តូរដ៏ល្អមួយ។ ព័ត៌មានលម្អិតអាចត្រូវបានទាញចេញពីបទប្បញ្ញត្តិ ស្តីពីការការពារ និង ការកាត់បន្ថយផលប៉ះពាល់នៃធនាគារអភិវឌ្ឍន៍ពហុភាគី រួមមាន ធនាគារពិភពលោក និង ADB ឬ អង្គការអន្តរជាតិនានា ដូចជា គណៈកម្មការទំនប់ទឹកពិភពលោកជាដើម (Okano-Heijmans et al. ២០១៨; Okano-Heijmans et al. ២០១៨)។ អង្គការទាំងនេះកំណត់និយមន័យហេដ្ឋារចនាសម្ព័ន្ធថាមានចីរភាពសង្គម ប្រសិនបើគ្មានអ្នកណាម្នាក់ត្រូវបានទុកចោលនោះទេ។

(ii) ក្របខណ្ឌ ASEM សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមាននិរន្តរភាពសង្គម ត្រូវតែរួមបញ្ចូលបញ្ហាការតាំងទីលំនៅឡើងវិញ និង ជីវភាពរបស់ប្រជាជនដែលរងផលជះដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

វាគួរតែបញ្ជាក់ថា បម្លាស់ទីដោយមិនស្ម័គ្រចិត្តត្រូវតែបានដាក់កំហិតលើចំនួន អប្បបរមាដាច់ខាត។ ប្រសិនបើមិនអាចជៀសវាងបានទេនោះ វាគួរតែស្របនឹងបទដ្ឋានអន្តរជាតិ ដែលកំណត់និយមន័យការដោះស្រាយផលប៉ះពាល់ ថាជាគម្រោងអភិវឌ្ឍន៍ដែលមានន័យថា គ្រួសារត្រូវតែផ្លាស់ប្តូរទីលំនៅ ត្រូវតែក្លាយជាអ្នកទទួលផលពីគម្រោង។ នេះមានន័យថា ពួកគេទទួល

---

110 សូមមើល “និយមន័យ ការតភ្ជាប់ ASEM” https://composite-indicators.jrc.ec.europa.eu/asem-sustainable- connectivity/about (បានចូលប្រើប្រាស់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០)។

បានការផ្តល់សំណងដែលមានភាពយុត្តិធម៌ និង ទាន់ពេលវេលា ចំពោះការបាត់បង់ទ្រព្យសម្បត្តិ និង ជីវភាពរស់នៅរបស់ពួកគេ ដោយផ្អែកលើតម្លៃទីផ្សារបច្ចុប្បន្ន។ សំណងត្រូវតែរួមបញ្ចូលគ្រួសារទាំងឡាយនៅក្នុងប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ម្ចាស់ដីធ្លី និង អ្នកជួលពិតប្រាកដ។ នៅក្នុងដំណើរការនេះ បទដ្ឋាននៃការរស់នៅរបស់ពួកគេត្រូវតែមានការកើនឡើងដែលជាលទ្ធផលនៃជីវភាពរស់នៅដែលល្អប្រសើរជាងមុន ទទួលបានសេវាសាធារណៈដែលមានតម្លៃសមរម្យ និង ការគ្រប់គ្រងគម្រោងដែលមានការចូលរួម (Clark ២០០០, ២០០២; Cernea ២០០៨; Wade ២០១១; Mathur ២០១៣; Perera ២០១៤; ធនាគារពិភពលោក និង UNCTAD ២០១៨)។

(iii) ក្របខណ្ឌត្រូវតែលើកឡើងយ៉ាងច្បាស់លាស់អំពីគម្រោងវារីអគ្គិសនី និង គម្រោងផលិតអគ្គិសនីដោយប្រើប្រាស់ធ្យូងថ្ម ដែលមានប្រជាប្រិយភាពនៅក្នុងចំណោមវិនិយោគិននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានផលប៉ះពាល់យ៉ាងខ្លាំងលើផ្នែកសង្គម និង បរិស្ថានរបស់ពួកគេ (Minh et al. ២០១៦; Eyler និង Weatherby ២០១៩)។ គេត្រូវតែជូនដំណឹងដល់អ្នកផ្តល់ហិរញ្ញប្បទានលើគម្រោងអំពីភាពលម្អៀងនៅក្នុងទីក្រុង ដែលជាប់ពាក់ព័ន្ធនឹងគម្រោងជាច្រើន និង ចាំបាច់ត្រូវតែដោះស្រាយ (Siciliano et al. ២០១៥)។

(iv) វាក៏គួរតែលើកឡើងអំពីតម្រូវការនៃតម្លាភាព និង ការពិគ្រោះយោបល់ដែលអាចទុកចិត្តបាន ជាមួយភាគីពាក់ព័ន្ធ និង គូសបញ្ជាក់អំពីគ្រោះថ្នាក់ចំពោះនិរន្តរភាពសង្គមដែលកើតឡើង ប្រសិនបើការបញ្ចប់គម្រោងយ៉ាងឆាប់រហ័សត្រូវបានផ្តល់អាទិភាពច្រើនជាងការធ្វើផែនការយ៉ាងប្រុងប្រយ័ត្ននោះ (ក្រសួងការបរទេស ២០១៧; Mao និង Müller ២០២០)។ សេចក្តីប្រកាសអំពីក្របខណ្ឌគួរតែរួមបញ្ចូលអនុសាសន៍មួយសម្រាប់វិនិយោគិនឲ្យតែងតាំងក្រុមត្រួតពិនិត្យឯករាជ្យ ក្នុងលក្ខណៈជាអង្គការពហុភាគី ដែលរួមបញ្ចូលអ្វីដែលធនាគារពិភពលោក និង ADB បានអនុវត្តរួច។

(v) សេចក្តីប្រកាសអំពីក្របខណ្ឌគួរតែលើកទឹកចិត្តអ្នកផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ (នៅក្នុងករណីដែលពួកគេមិនទាន់បានអនុវត្តនៅឡើយ) ឲ្យបង្កើតប្រព័ន្ធវាយតម្លៃការអនុវត្តដ៏តឹងរ៉ឹង និង ឯករាជ្យ ដូចប្រព័ន្ធរបស់ម្ចាស់ជំនួយទ្វេភាគី និង ទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគីដែលមានជាយូរមកហើយ។ ប្រព័ន្ធវាយតម្លៃគួរតែរួមបញ្ចូលសូចនាករដែលមិនត្រឹមតែត្រួតពិនិត្យកម្រិតដែលគម្រោងនានាសម្រេចបានតាមវត្ថុបំណងផ្នែកសេដ្ឋកិច្ចរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវត្រួតពិនិត្យអនុលោមភាពលើបទដ្ឋានសង្គម និង បរិស្ថានអន្តរជាតិផងដែរ។

(vi) វេទិកា ASEM អាចកាត់បន្ថយការប្រកួតប្រជែងជាសក្តានុពលបានតាមរយៈការចារអនុម័ត

លើភាពចុះសម្រុងនឹងគ្រោងការតភ្ជាប់ដែលកំពុងតែដំណើរការ។ វេទិកានេះអាចលើកកម្ពស់កិច្ចសន្ទនាអំពីនីតិវិធី បទប្បញ្ញត្តិ និង បទដ្ឋានដែលជួយពង្រឹងកំណត់ត្រាអំពីនិរន្តរភាពសង្គមនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធអឺរ៉ាស៊ី។ មូលនិធិអាស៊ី-អឺរ៉ុបអាចក្លាយជាស្ថាប័នមួយសម្រាប់ពង្រឹងចំណេះដឹងអំពីបញ្ហារបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសង្គម។ ជម្រើសផ្សេងទៀត រួមមាន មជ្ឈមណ្ឌលកសាងសមត្ថភាព និង មជ្ឈមណ្ឌលបណ្តុះបណ្តាល ដូចជាមជ្ឈមណ្ឌលមួយដែលត្រូវបានបង្កើតឡើងដោយវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ីនៅប្រទេសវៀតណាម។ [111]

(vii) ASEM គួរតែផ្តួចផ្តើមគំនិតបង្កើតកិច្ចសន្ទនានៅក្នុងចំណោមម្ចាស់ជំនួយដើម្បីកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលកាន់តែខ្លាំងក្លាលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ នៅខណៈពេលកំពុងប្រមូលផ្តុំកម្លាំង វិធីនេះនឹងកាត់បន្ថយការប្រកួតប្រជែង ដាក់កម្រិតលើសកម្មភាពជាន់គ្នាដែលមានការខ្ជះខ្ជាយ និង ថែរក្សាគុណភាពគម្រោង (Broer ២០១៨; Rüland និង Michael ២០១៩)។ ប្រជាជនត្រូវតែជាអ្នកទទួលផលចុងក្រោយនៃកិច្ចសហប្រតិបត្តិការនោះ។

(viii) ការបង្កើតសូចនាករនៃការតភ្ជាប់ ASEM គឺជាគោលការណ៍នៃគំនិតផ្តួចផ្តើមដែលមានការស្វាគមន៍។ ទោះបីជាយ៉ាងណាក៏ដោយ ឧបករណ៍នេះត្រូវតែបានត្រួតពិនិត្យយ៉ាងជិតដល់តាមរយៈការបង្កើតទស្សនាទាននៃសូចនាករដែលកំណត់បរិមាណនៃការខូចខាតរបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធមកលើសង្គម និង បរិស្ថាន។ [112]

---

111 Thai News Service ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ និង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩; TendersInfo ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥

112 សូមមើល ASEM Sustainable Connectivity Portal, https://composite-indicators.jrc.ec.europa.eu/asem-sustainable-connectivity/ (បានចូលប្រើប្រាស់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីបញ្ចប់

សន្ទុះហេដ្ឋារចនាសម្ព័ន្ធអឺរ៉ាស៊ី នាពេលបច្ចុប្បន្ន ត្រូវបានចាត់ទុកថាជាកត្តាជំរុញដល់ការអភិវឌ្ឍដែលមានឥទ្ធិពល។ ការលើកឡើងនេះគឺជាការពិត ជាពិសេសចំពោះកិច្ចខិតខំប្រឹងប្រែងក្រោយពេលមានជំងឺកូវីដ-១៩ ដើម្បីចាប់ផ្តើមការងើបឡើងវិញផ្នែកសេដ្ឋកិច្ច។ ស្រដៀងគ្នានេះដែរ វាផ្តល់ឱកាសសម្រាប់ការកែប្រែទ្រង់ទ្រាយឡើងវិញនៃការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឆ្ពោះទៅរកចីរភាពបរិស្ថាន និង សង្គម កាន់តែខ្លាំងក្លា។[113] ប៉ុន្តែ ពុំមានភាពចាំបាច់នៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើតអ្វីដែលមានស្រាប់ហើយនោះទេ។ វាមានភាពគ្រប់គ្រាន់ក្នុងការធ្វើឱ្យការចងចាំរបស់ស្ថាប័នមានដំណើរការ និងកត់ត្រាមេរៀនដ៏មានតម្លៃ និង ទម្លាប់អនុវត្តល្អបំផុតជាច្រើន ដែលបង្កើតឡើងដោយការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ ក្នុងរយៈពេលជាង ៦ ទសវត្សរ៍ នៅបណ្តាប្រទេស លោកខាងត្បូង។ បទពិសោធន៍ទាំងនេះត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អ និង ត្រូវបានកែប្រែឲ្យក្លាយជាវិធានការការពារ និង វិធានការកាត់បន្ថយផលប៉ះពាល់ ដោយអ្នកផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធពហុភាគី និង ទ្វេភាគី ដែលមានកំណត់ត្រានៃការតាមដានរយៈពេលវែងនៅក្នុងវិស័យនេះ។

កិច្ចប្រជុំកំពូល ASEM នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០២១ គួរតែជាការកត់សម្គាល់ដ៏មានអត្ថន័យអំពីតម្រូវការនៃចីរភាពសង្គមនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ការរួមចំណែករបស់ ASEM ចំពោះការតភ្ជាប់នឹងមានភាពរឹងមាំឡើង ប្រសិនបើ ASEM លើកឡើងអំពីក្របខណ្ឌមួយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានចីរភាពសង្គម រួមជាមួយយន្តការសម្រាប់តាមដាននៅពេលក្រោយ តាមរយៈវេទិកានៃតភ្ជាប់ និង សកម្មភាពរបស់ខ្លួន។

---

[113] សូមមើល ផ្អែកតាមការសិក្សារបស់វិទ្យាស្ថានកិច្ចការអន្តរជាតិនៃប្រទេសសិង្ហបុរី The Business Times (សិង្ហបុរី) ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០។

# ឯកសារយោង

Asian Development Bank (ADB) (2016), Meeting Asia's Infrastructure Needs. Mandaluyong: ADB.

Broer, B. (2018), 'The EU's Connectivity Strategy: An Answer to China's Belt and Road Initiative?', 21 September 2018, Brussels: EU–Asia Centre, http://www.euasiacentre.eu/ pub_details.php?pub_id=245 (accessed 8 April 2020).

Cernea, M. (2008), 'Compensation and Benefit Sharing: Why Resettlement Policies and Practices Must Be Reformed', Water Science and Engineering, 1(1), pp. 89–120.

Cernea, M.M. and J.K. Maldonado (2018), Challenging the Prevailing Paradigm of Displacement and Resettlement. Risks, Impoverishment, Legacies, Solutions. London: Routledge.

Clark, D. (2000), 'Resettlement: The World Bank's Assault on the Poor', Washington, DC: Center for International Environmental Law, https://www.ciel.org/reports/ resettlement- the-world-banks-assault-on-the-poor-may-2000-clark-edited-by-carothers-4/ (accessed 29 May 2020).

Clark, D. (2002), 'An Overview of Revisions to the World Bank Resettlement Policy', 12 September 2002, http://www.mcrg.ac.in/dana.htm (accessed 11 April 2020).

Dawei Development Association (DDA) (2014), Voices from the Ground: Concerns Over the Dawei Special Economic Zone and Related Projects. Dawei: DDA.

EarthRights International (2014), 'Analysis of the Environmental Impact Assessment for Phase I of the Thilawa Special Economic Zone Project in Myanmar', https://earthrights.org/ publication/analysis-of-eia-for-phase-i-of-thilawa-sez/ (accessed 29 May 2020).

Eyler, B. and C. Weatherby (2019), Letters from the Mekong. Towards a Sustainable Water- Energy-Food Future in Cambodia. Washington, DC: Stimson Center.

Gaens, B. (2019), 'The EU–Asia Connectivity Strategy and Its Impact on Asia–Europe Relations', https://www.fiia.fi/en/publication/the-eu-asia-connectivity-strategy-and-its- impact-on-asia-europe-relations (accessed 29 May 2020).

Internal Displacement Monitoring Center (2017), 'Dams and Displacement. An Introduction', https://www.internal-displacement.org/sites/default/files/publications/documents/20170411-idmc-intro-dam-case-study.pdf (accessed 29 May 2020).

Koplitz, S.N., D.J. Jacob, M.P. Sulprizio, L. Myllyvirta, and C. Reid (2017), 'Burden of Disease from Rising Coal-Fired Power Plant Emissions in Southeast Asia', Environmental Science & Technology, 51, pp. 1467–176.

Mao, C. and L.M. Müller (2020), 'Learning from the Competition: China's, Japan's and the EU's Infrastructure Connectivity Rule Setting in Asia', Occasional Paper Series No. 45, Freiburg: Southeast Asia Program, University of Freiburg, http://www.southeastasianstudies.uni- freiburg.de/publications-1/occasional-paper-series-southeast-asian-studies-at-freiburg (accessed 20 June 2020).

Mark, S.S. and Y. Zhang (2017), 'From Impediment to Adaptation: Chinese Investments in Myanmar's New Regulatory Environment', Journal of Current Southeast Asian Affairs, 36(2), pp. 71–100.

Mathur, H.M. (2013), Displacement and Resettlements in India: The Human Cost of Development. Oxford and New York: Routledge.

Minh, H.D., T. Ha, N.N. Hong, and A.N.T. Hoang (2016), Synthesis Report on Socio-environmental Impacts of Coal and Coal-fired Power Plants in Vietnam. Ha Noi: Vietnam Sustainable Energy Alliance.

Ministry of Foreign Affairs of Japan (2017), White Paper on Development Cooperation 2017: Japan's International Cooperation. Tokyo.

Okano-Heijmans, M., W. Zweers, and B. Dekker (2018), 'ASEM Must Prove its Worth by Managing Connectivity Conflict', op-ed, 17 October 2018, The Hague: Clingendael, https://www.clingendael.org/publication/asem-must-prove-its-worth-managing-connectivity-conflict (accessed 29 May 2020).

Okano-Heijmans, M., W. Zweers, and A. Prakash (2018), ASEM Connectivity Inventory, The Hague and Jakarta: Clingendael and Economic Research Institute for ASEAN and East Asia.

Perera, J. (ed.) (2014). Lose to Gain. Is Involuntary Resettlement a Development Opportunity? Mandaluyong: Asian Development Bank.

Richter, B., S. Postel, C. Revenga, T. Scudder, B. Lehner, A. Churchill, and M. Chow (2010), 'Lost in Development's Shadow: The Downstream Human Consequences of Dams', Water Alternatives, 3(2), pp. 14–42.

Rüland, J. (1996), The Asia–Europe Meeting (ASEM): Towards a New Euro–Asian Relationship?

Rostock: Rostocker Informationen zu Politik und Verwaltung, Heft 5.

Rüland, J. (2019), 'Old Wine in New Bottles? How Competitive Connectivity Revitalises an Obsolete Development Agenda in Asia', Journal of Contemporary Asia, Online first: doi.org/1 0.1080/00472336.2019.1705878.

Rüland, J. and A. Michael (2019), 'Overlapping Regionalism and Cooperative Hegemony: How China and India Compete in South and Southeast Asia', Cambridge Review of International Affairs, 32(2), pp. 178–200.

Siciliano, G., F. Urban, S. Kim, and P.D. Lonn (2015), 'Hydropower, Social Priorities and the Rural–Urban Development Divide: The Case of Large Dams in Cambodia', Energy Policy, 86, pp. 273–285.

Thame, C. (2017), SEZs and Value Extraction from the Mekong: A Case Study on the Control and Exploitation of Land and Labour in Cambodia and Myanmar's Special Economic Zones. Bangkok: Thammasat University.

The World Bank and UNCTAD (2018), Relocation and Resettlement, Washington, DC. http://documents.worldbank.org/curated/en/863931521091663000/pdf/124287-BRI- PUBLIC-KN12.pdf (accessed 29 May 2020).

Wade, R.H. (2011), 'Muddy Waters: Inside the World Bank As It Struggled with the Narmada Projects', Economic & Political Weekly, 1 October 2011, https://advance.lexis. com/document/?pdmfid=1516831&crid=aba13945-27fc-41f5-bcb5-d80de6d59f1a&p ddocfullpath=%2Fshared%2Fdocument%2Fnews%2Furn%3AcontentItem%3A53YN-HV11- DXJ6-R3SM-00000-00&pdcontentcomponentid=365197&pdteaserkey=sr201&pditab=allpods&ecomp=pp79k&earg=sr201&prid=f403f707-283a-4d0c-9f7c-668e14edb7e9 (accessed 14 April 2020).

Yee, C.K. (2005), 'Dam-Induced Development and Environmental and Social Sustainability: The Bakun Industrialization Strategy Revisited', Journal of Economic Issues, 39(1), pp. 123–150.

13

# កិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព

## ការគ្រប់គ្រងទឹកនៅក្នុងតំបន់ទន្លេមេគង្គ និង តំបន់ទន្លេ ដានូប

THEARITH LENG

## សេចក្តីផ្តើម

ទន្លេ Danube និង ទន្លេមេគង្គគឺជាទន្លេពីរ ដែលវែងជាងគេបំផុតនៅលើពិភពលោក និង ដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និង ពូជសត្វដទៃទៀតដែលរស់នៅក្នុងអាងទន្លេ។

ទន្លេ Danube គឺជាទន្លេដែលវែងជាងគេទីពីរ នៅទ្វីបអឺរ៉ុប ដែលមានប្រវែងសរុប ២.៨៥៧ គីឡូម៉ែត្រ (គ.ម.)។ អាងទឹករបស់ទន្លេនេះ ដែលលាតសន្ធឹងប្រមាណ ៨១៧.០០០ គីឡូម៉ែត្រការ៉េ (ប្រហែល ១០% នៃទ្វីបអឺរ៉ុប) ត្រូវបានប្រើប្រាស់រួមគ្នាដោយប្រទេសចំនួន ១៩ (Shepherd ២០១៨: ២)។ ទន្លេគឺជាប្រភពដ៏សំខាន់មួយនៃថាមពលវារីអគ្គិសនី កសិកម្ម ការកំសាន្ត ការផ្គត់ផ្គង់ទឹក និងការចូលទៅជិតបរិស្ថានធម្មជាតិរបស់ទ្វីបអឺរ៉ុប។ ទន្លេនេះហូរកាត់រដ្ឋធានីនៃប្រជាជាតិចំនួន ៤ គឺ Vienna, Bratislava, Budapest និង Belgrade ហើយប្រជាជនជិត ២០ លាននាក់ពឹងផ្អែកលើទន្លេនេះសម្រាប់តម្រូវការទឹកប្រចាំថ្ងៃរបស់ពួកគេ។

ទន្លេមេគង្គមានប្រវែងជិត ៥.០០០ គីឡូម៉ែត្រ និង ហូរកាត់ប្រទេសចំនួនប្រាំមួយ រួមមានប្រទេសចិន ប្រទេសមីយ៉ាន់ម៉ា ប្រទេសថៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ប្រទេសឡាវ) ប្រទេសកម្ពុជា និង ប្រទេសវៀតណាម។

បម្រែបម្រួលតាមរដូវកាលនៃកម្ពស់ទឹក និង ជម្រករបស់សត្វនៅតំបន់ដីសើមដ៏ធំ បានធ្វើឱ្យទន្លេនេះក្លាយជាប្រភពដ៏ធំមួយនៃផលិតកម្មកសិកម្ម ថាមពល និង ការទាក់ទាញទេសចរណ៍នៅទ្វីបអាស៊ី។

ជីវចម្រុះដ៏សម្បូរបែបរបស់ទន្លេនេះមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់ប្រជាជន ៦០ លាននាក់ដែលរស់នៅក្នុងតំបន់អាងទន្លេ។ វិស័យជលផល តែមួយគត់ នាំមកនូវប្រាក់ចំណូលប្រចាំឆ្នាំប្រមាណ ១៧ ប៊ីលានដុល្លារ៖ ប្រហែល ៣% នៃ GDP របស់ប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម និង ១៣% នៃតម្លៃសរុបរបស់ជលផលពិភពលោក (ប្រហែល ១៣០ ប៊ីលានដុល្លារ) (VietnamNet ២០១៦)។

ដោយសារសារសំខាន់ដ៏ខ្លាំងក្លានៃទន្លេទាំងពីរ យន្តការពហុភាគីជាច្រើនត្រូវបានបង្កើតឡើង នៅក្នុងតំបន់ទាំងនេះ ដើម្បីធានាចំពោះការប្រើប្រាស់ទឹក និង ធនធានដែលពាក់ព័ន្ធប្រកបដោយចីរភាព។ ទោះបីជាយន្តការក្នុងតំបន់ទាំងនេះ ជារួម បានរួមចំណែកដល់ទំនាក់ទំនងដោយសន្តិភាពក្នុងចំណោមប្រទេសនានានៅក្នុងតំបន់ទាំងនេះក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនដែរ។ ឧទាហរណ៍៖ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ភាពតានតឹងបានកើតឡើងក្នុងចំណោមប្រទេសនានា នៅក្នុងអាងទន្លេមេគង្គ ជាពិសេសរវាងប្រទេសខ្សែទឹកខាងលើ និង ប្រទេសខ្សែទឹកខាងក្រោម។ ដើម្បីដោះស្រាយបញ្ហាទឹកដែលនៅសល់ឲ្យកាន់តែមានប្រសិទ្ធិភាពនោះ ប្រទេសនានានៅទ្វីបអាស៊ី និង អឺរ៉ុប បាន និងកំពុងតែធ្វើការជាមួយគ្នាតាមរយៈយន្តការអន្តរទ្វីបថ្មីមួយ ហៅថាកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។

## យន្តការគ្រប់គ្រងធនធានទឹក និង ទំនាក់ទំនងអន្តររដ្ឋនៅតំបន់ទន្លេ Danube

ការគ្រប់គ្រងធនធានទឹកនៅក្នុងតំបន់ទន្លេ Danube លើកទឹកចិត្តដល់បណ្ដាប្រទេសក្នុងតំបន់ឲ្យសហការគ្នា ដូចជាតាមរយៈការយល់ព្រមចងកាតព្វកិច្ចដោយយន្តការច្បាប់មួយចំនួនដែលមានបំណងធ្វើឲ្យប្រទេសទាំងនេះ ជាចុងក្រោយ មានទំនាក់ទំនងប្រកបដោយសន្តិភាពជាមួយគ្នាទៅវិញទៅមក។

លិខិតតូបករណ៍ដំបូង និង សំខាន់បំផុត ដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងធនធានទឹកនៅក្នុងតំបន់ គឺអនុសញ្ញាការពារទន្លេ Danube (DRPC) ឆ្នាំ១៩៩៤ ដែលបានចុះហត្ថលេខាដោយអង្គភាពចំនួន ១៥ នៅក្នុងអាងទន្លេ Danube (DRB) ដែលគ្របដណ្ដប់លើផ្ទៃដីជាង ២០០០ គីឡូម៉ែត្រក្រឡា។ ហត្ថលេខីទាំងនេះ រួមមាន ប្រទេសអូទ្រីស ប្រទេសបូស្នី និង ហឺហ្សេហ្គូវីណា ប្រទេសប៊ុលហ្គារី ប្រទេសក្រូអាត សាធារណរដ្ឋឆែក ប្រទេសអាល្លឺម៉ង់ ប្រទេសហុងគ្រី ប្រទេសម៉ុលដូវ៉ា ប្រទេសម៉ុងតេណេហ្គ្រោ ប្រទេសរ៉ូម៉ានី ប្រទេសស៊ែប៊ី ប្រទេសស្លូវ៉ាគី ប្រទេសស្លូវេនី ប្រទេសអ៊ុយក្រែន និង គណៈកម្មការអឺរ៉ុប (គណៈកម្មការអន្តរជាតិសម្រាប់ការពារទន្លេ Danube [ICPDR] ២០១៣a: ៤) ។

ភាគីនៃ DRPC បានព្រមព្រៀងសហការគ្នាលើបញ្ហាគ្រប់គ្រងទឹកសំខាន់ៗ ដូចជា ការអភិរក្សទឹកលើដី និង ទឹកក្រោមដី ការគ្រប់គ្រងហានិភ័យពីឧបទ្ទវហេតុ និង ទឹកជំនន់ និងការកាត់បន្ថយការបញ្ចេញការបំពុលពីប្រភព DRB ចូលទៅក្នុងសមុទ្រខ្មៅ (ICPDR ២០១៣a: ៤)។

បន្ទាប់មក ICPDR ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៨ ដើម្បីសម្របសម្រួលបញ្ហាការគ្រប់គ្រងទឹក និង សម្របសម្រួលកិច្ចព្រមព្រៀងរវាងហត្ថលេខីទាំងឡាយ ស្តីពីវិធានការច្បាប់ រដ្ឋបាល និងបច្ចេកទេស ដើម្បីការពារ និង ពង្រឹងគុណភាពរបស់ទន្លេ Danube និង ដៃទន្លេរបស់វា។

ICPDR ត្រូវបានគ្រប់គ្រងដោយក្រុមប្រជុំសាមញ្ញមួយ ដែលទទួលបន្ទុកបង្កើតគោលនយោបាយ និង យុទ្ធសាស្ត្រ និង ក្រុមការងារប្រចាំការមួយ ដែលទទួលខុសត្រូវផ្តល់មគ្គុទ្ទេសក៍ណែនាំ និង រៀបចំសេចក្តីសម្រេច។ លើសពីនេះទៀត ក្រុមអ្នកជំនាញ ក្រុមការងារ និងអ្នកតំណាងរបស់ក្រុមភាគីពាក់ព័ន្ធ ផ្តល់ការគាំទ្រដល់ការងារវិទ្យាសាស្ត្រ និង ការងារបច្ចេកទេសរបស់ ICPDR (ICPDR ២០១៨: ៦)។

លិខិតតូបករណ៍ដ៏មានឥទ្ធិពលមួយទៀតក្នុងការគ្រប់គ្រងបញ្ហាទឹកនៅ DRB គឺសេចក្តីណែនាំស្តីពីក្របខ័ណ្ឌទឹក (WFD) ដែលត្រូវបានអនុម័តដោយសហភាពអឺរ៉ុប (EU) នៅឆ្នាំ ២០០០។ WFD ត្រូវបានចាត់ទុកជាឯកសារមួយក្នុងចំណោមឯកសារការពារទឹក ដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់ ដ៏រឹងមាំបំផុតនៅលើពិភពលោក និងជាអាទិភាពខ្ពស់បំផុតមួយសម្រាប់គ្រប់ប្រទេសទាំងអស់នៃ DRB។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍គឺ ការអនុវត្តរបស់ WFD បានក្លាយជាលក្ខណវិនិច្ឆ័យដ៏សំខាន់មួយនៃការជ្រើសរើសសមាជិកភាព EU (Masliah–Gilkarov ២០១៩)។ នៅក្នុងករណីនេះ ICPDR មានភារកិច្ចអភិវឌ្ឍសមត្ថភាពរបស់បណ្តាប្រទេសនៃ DRB ដើម្បីបំពេញតាមលក្ខណវិនិច្ឆ័យនៃការចូលជាសមាជិក EU។ បណ្តាប្រទេសនៃ DRB បានសហការគ្នាយ៉ាងខ្លាំង ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុង WFD ក៏ដូចជា DRPC ឆ្នាំ១៩៩៤ ផងដែរ។ ទិដ្ឋភាពដែលគួរឱ្យចាប់អារម្មណ៍មួយទៀតរបស់ WFD គឺការអនុម័តគោលការណ៍ "ការបង់ប្រាក់ដោយអ្នកបំពុលបរិស្ថាន" ដែលទាមទារឱ្យប្រទេសនីមួយៗ (ឧទាហរណ៍៖ ប្រតិបត្តិកររោងចក្រវារីអគ្គិសនី) ទូទាត់ការខូចខាតណាមួយដែលពួកគេបានធ្វើចំពោះបរិស្ថាន។ គោលការណ៍នេះ ជាទូទៅអនុវត្តចំពោះសកម្មភាពសាងសង់រោងចក្រវារីអគ្គិសនី ដែលអាចមានផលជះអវិជ្ជមានដល់ប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក (ឧទាហរណ៍៖ ជម្រក និង ប្រភេទសត្វ) ឬ សណ្ឋានទឹក (ឧទាហរណ៍៖ ការហូរសារធាតុផ្សេងៗចូលក្នុងទន្លេ តុល្យភាពទឹក បម្លាស់ទីដីល្បាប់ និង រូបសាស្ត្រទន្លេ) (ICPDR ២០១៣b: ១៥)។

ឧបករណ៍ច្បាប់ដ៏រឹងមាំមួយទៀត ដែលគ្រប់គ្រងបញ្ហាទាក់ទងនឹងទឹក នៅក្នុង DRB គឺ សេចក្តីណែនាំស្តីពីទឹកជំនន់នៅអឺរ៉ុប (EFD) ដែលបានចូលជាធរមាន កាលពីខែវិច្ឆិកា ឆ្នាំ ២០០៧។ EFD ស្នើឲ្យរដ្ឋជាសមាជិកអនុវត្តគោលនយោបាយឱ្យបានគ្រប់គ្រាន់ និង ដែលមានភាពស្រុះស្រួលគ្នា ដើម្បីកាត់បន្ថយគ្រោះទឹកជំនន់។

សេចក្តីណែនាំនេះក៏ធ្វើឲ្យសាធារណជនទទួលបានព័ត៌មានស្តីពីហានិភ័យទឹកជំនន់ និង វិធានការណ៍ដែលពាក់ព័ន្ធផងដែរ។ ស្របតាមសេចក្តីណែនាំនេះ រដ្ឋសមាជិកត្រូវបានរំពឹងថានឹងសម្របសម្រួលទម្លាប់អនុវត្តក្នុងការគ្រប់គ្រងហានិភ័យទឹកជំនន់របស់ពួកគេជាមួយគ្រប់ប្រទេសទាំងអស់ដែលប្រើប្រាស់អាងទន្លេអន្តរជាតិរួមគ្នា រួមទាំងប្រទេសដែលមិនមែនជាសមាជិក EU ផងដែរ (ICPDR ២០១២: ៥)។

នៅឆ្នាំ ២០០០ ផែនការគ្រប់គ្រងស្រុកនៃអាងទន្លេ Danube ដែលបានសម្របសម្រួលសម្រាប់ DRB ទាំងមូល ត្រូវបានបង្កើតឡើង ដោយអនុលោមតាម WFD របស់ EU។ ផែនការនេះត្រូវបានអនុម័តដោយហត្ថលេខីរបស់ ICPDR កាលពីចុងឆ្នាំ ២០០៩។ នៅខែតុលា ឆ្នាំ២០១២ ក្រុមប្រឹក្សាក្រសួងនៃសហគមន៍ថាមពលបានសម្រេចចិត្តអនុវត្ត សេចក្តីណែនាំស្តីពីថាមពលកកើតឡើងវិញរបស់ EU ដែលសន្យាផ្តល់ជូនសហគមន៍ថាមពលរបស់ EU (រួមទាំងប្រទេសនៃ DRB ជាច្រើនផងដែរ) នូវចំណែកចងកាតព្វកិច្ច នៃថាមពលកកើតឡើងវិញ ដែលជាផ្នែកមួយនៃការប្រើប្រាស់ទូទៅរបស់ពួកគេ នៅឆ្នាំ២០២០ (ICPDR ២០១៣b: ១១)។ នេះដើម្បីធានាថាកម្រិតទឹក និង គុណភាពរបស់ទន្លេ Danube នឹងមិនរងការខូចខាត ដោយសារការសាងសង់រោងចក្រវារីអគ្គិសនីជាបន្តបន្ទាប់ នៅតាមបណ្តាប្រទេសនៃ DRB ឬ នៅទ្វីបអឺរ៉ុបទាំងមូលនោះទេ។

ដូចបានគូសបញ្ជាក់នៅខាងលើ ការគ្រប់គ្រងទឹកនៅក្នុង DRB ជាទូទៅ ត្រូវបានធ្វើនិយ័តកម្ម ដោយលិខិតូបករណ៍ដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់ ដូចជា DRPC WFD និង EFD ជាដើម។ ប្រការនេះលើកទឹកចិត្តដល់បណ្តាប្រទេសនៃ DRB ជាពិសេសប្រទេសដែលមានបំណងចង់ក្លាយជាផ្នែកមួយនៃ EU ឲ្យប្រកាន់ខ្ជាប់ ដោយចេតនានូវបណ្តុំវិធានដែលចងកាតព្វកិច្ច ដែលជួយកាត់បន្ថយជាអប្បបរមានូវភាពខុសគ្នា ឬ ទំនាស់រវាងពួកគេចំពោះការប្រើប្រាស់ទឹកបានយ៉ាងមានប្រសិទ្ធភាព។ ក្នុងរយៈពេលមធ្យម ទៅ រយៈពេលវែងបណ្តាប្រទេសនៃ DRB ទំនងជាបន្តសហការជាមួយគ្នា និងមិនងាយមានទំនាស់ជាលក្ខណៈបើកចំហទាក់ទងនឹងទឹកនោះទេ។

# យន្តការគ្រប់គ្រងធនធានទឹក និង ទំនាក់ទំនងអន្តររដ្ឋនៅតំបន់ទន្លេមេគង្គ

មិនដូចគ្នានឹង DRB ដែលការគ្រប់គ្រងទឹក ភាគច្រើនត្រូវបានធ្វើនិយ័តកម្មដោយវិធាន និង បទប្បញ្ញត្តិក្នុងតំបន់នោះទេ ទឹកនៅតំបន់ទន្លេមេគង្គភាគច្រើនត្រូវបានធ្វើនិយ័តកម្ម ដោយគំនិតផ្តួចផ្តើមក្នុងតំបន់ដែលមិនចងកាតព្វកិច្ចមួយចំនួន ដូចជាគណៈកម្មការទន្លេមេគង្គ (MRC) មហាអនុតំបន់ទន្លេមេគង្គ (GMS) គំនិតផ្តួចផ្តើមតំបន់មេគង្គក្រោម (LMI) និងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (LMC)។ គំនិតផ្តួចផ្តើមថ្នាក់តំបន់ដែលមានភាពបត់បែនទាំងនេះ បានផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងដល់ប្រទេសនានានៃតំបន់ទន្លេមេគង្គ ដែលរួមមាន ប្រទេសចិន ឡាវ មីយ៉ាន់ម៉ា ថៃ កម្ពុជា និង វៀតណាម ដែលមានគោលដៅពង្រឹងទំនាក់ទំនងដោយសន្តិភាពនៅក្នុងចំណោមប្រទេសទាំងនេះ។ សារសំខាន់នៃគំនិតផ្តួចផ្តើមថ្នាក់តំបន់ទាំងនេះ អាចត្រូវបានពណ៌នាត្រួសៗដូចខាងក្រោម។

## គណៈកម្មការទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ (MRC) ដែលកាលពីមុនគឺជាគណៈកម្មាធិការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាលមួយដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥។ ប្រទេសសមាជិក MRC រួមមាន ប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម នៅខណៈពេលដែលប្រទេសចិន និង ប្រទេសមីយ៉ាន់ម៉ា គឺជាដៃគូពិភាក្សា (MRC)។ បេសកកម្មចម្បងរបស់ MRC គឺធានាចំពោះការអភិវឌ្ឍទៅវិញទៅមក និង ប្រកបដោយប្រសិទ្ធភាពនៃទន្លេមេគង្គ ស្របពេលជាមួយគ្នានោះកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានចំពោះប្រជាជននិងបរិស្ថាននៅក្នុងអាងទន្លេមេគង្គក្រោម (LMB)។ MRC ក៏មានតួនាទីសំខាន់ផងដែរ ក្នុងនាមជាមជ្ឈមណ្ឌលចំណេះដឹងក្នុងតំបន់ ស្តីពីការគ្រប់គ្រងធនធានទឹក។

## មហាអនុតំបន់មេគង្គ

GMS ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩២ ក្នុងគោលបំណងអនុវត្តគម្រោងដែលមានអាទិភាពខ្ពស់នៅក្នុងប្រទេសតាមដងទន្លេមេគង្គទាំង ៦ (ប្រទេសកម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ កម្មវិធី GMS បានផ្តោតជាចម្បងលើការលើកកម្ពស់ និង សម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធ ដោយធ្វើសមាហរណកម្មប្រទេសនានានៅក្នុងអនុតំបន់តាមប្រព័ន្ធដឹកជញ្ជូន និង បណ្តាញសេដ្ឋកិច្ចជាច្រើនផ្សេងទៀត និង ច្រករបៀង ខ្សែបណ្តាញថាមពល និង ការភ្ជាប់ចរន្តអគ្គិសនី ដើម្បីជួយសម្រួល

ដល់ការផ្លាស់ទីនៃទំនិញ និង ប្រជាជនអន្តររដ្ឋ ក៏ដូចជាការតភ្ជាប់ប្រព័ន្ធទូរគមនាគមន៍ផងដែរ (GMS)។

## គំនិតផ្តួចផ្តើមតំបន់មេគង្គក្រោម

LMI ដែលត្រូវបានស្នើជាផ្លូវការនៅក្នុងឆ្នាំ ២០០៩ គឺជាភាពជាដៃគូពហុជាតិរវាងសហរដ្ឋអាមេរិក (US) និង ៥ ប្រទេស នៅតាមបណ្តោយទន្លេមេគង្គក្រោម រួមមាន ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម។ LMI ភាគច្រើន ដើរតួជាវេទិកាមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍន៍ និង គោលនយោបាយឆ្លងដែននៅក្នុងអនុតំបន់ទន្លេមេគង្គក្រោម។ LMI មានគោលបំណងលើកកម្ពស់ពាណិជ្ជកម្ម សហគ្រិនភាព និង នវានុវត្តន៍ ដើម្បីគាំទ្រដល់ទំនាក់ទំនងរូបវន្ត ស្ថាប័ន និង ប្រជាជន។

## កិច្ចសហប្រតិបត្តិការមេគង្គឡានឆាង

LMC បានចាប់ផ្តើមបន្ទាប់ពីមានកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស LMC លើកដំបូងនៅប្រទេសចិន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ដោយមានការចូលរួមពីប្រទេសសមាជិកចំនួនប្រាំមួយ (ប្រទេសចិន កម្ពុជា ឡាវ ថៃ មីយ៉ាន់ម៉ា និង វៀតណាម)។ គោលបំណងសំខាន់របស់ LMC គឺដើម្បីលើកកម្ពស់សុខមាលភាពរបស់ប្រជាជន ពង្រួមគម្លាតនៃការអភិវឌ្ឍរវាងប្រទេសនានានៅក្នុងតំបន់ និងកសាងសហគមន៍ដែលមានអនាគតរួមគ្នានៅក្នុងចំណោមប្រទេសទាំងនោះ។ ដោយមានការគាំទ្រពីប្រទេសចិន គំនិតផ្តួចផ្តើមនេះព្យាយាមបំពេញបន្ថែមលើយន្តការតភ្ជាប់ដែលមានស្រាប់ ដូចជា គំនិតផ្តួចផ្តើមខ្សែក្រវាត់ និង ផ្លូវ និង ផែនការមេរបស់សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ស្តីពីការតភ្ជាប់គ្នា ឆ្នាំ២០២៥។

គំនិតផ្តួចផ្តើមថ្នាក់តំបន់ទាំងនេះបានធ្វើឲ្យបណ្តាប្រទេសនៅតាមបណ្តោយទន្លេមេគង្គ (ជាពិសេស ប្រទេសនៅតាមដងទន្លេមេគង្គក្រោម) អាចទទួលបានប្រភពផ្សេងៗ ដើម្បីផ្តល់មូលនិធិដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសពីសហរដ្ឋអាមេរិក ប្រទេសចិន និង ប្រទេសជប៉ុន។

វត្តលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចនេះបានរួមចំណែកយ៉ាងសំខាន់ ដល់ការពង្រឹងទំនាក់ទំនងរវាងបណ្តាប្រទេសនៅតាមដងទន្លេមេគង្គក្រោម និង ដៃគូផ្តល់ជំនួយនានា។

លើសពីនេះទៀត ការបង្កើតគំនិតផ្តួចផ្តើមថ្នាក់តំបន់ខុសៗគ្នា នៅក្នុងតំបន់ទន្លេមេគង្គ មិនត្រឹមតែជួយគ្រប់គ្រងការប្រើប្រាស់ទឹកបានយ៉ាងមានប្រសិទ្ធភាពតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកទឹកចិត្តឲ្យមានសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងចំណោមរដ្ឋសមាជិកបន្ថែមទៀត ជាពិសេសរវាងប្រទេសនៅតាមដងទន្លេមេគង្គក្រោម និង ទន្លេមេគង្គលើ។

MRC ហាក់បីដូចជា ប្រភពថាមពលទិន្នន័យទឹកល្អបំផុត នៅខណៈពេលដែល GMS គឺជាស្ថានល្អបំផុត ដែលតភ្ជាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងគ្រប់ប្រទេសទាំងអស់នៅតាមដងទន្លេមេគង្គ លើបញ្ហាជាច្រើន រួមមាន ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ ថាមពល និង សុខភាព។

លើសពីនេះទៀត LMC ជួយពន្លឿនការធ្វើសមាហរណកម្មអាស៊ាន តាមវិធីចំនួនពីរ៖ (i) វាជួយជំរុញផែនការមេរបស់អាស៊ានស្តីពីការតភ្ជាប់ តាមរយៈការផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការសម្របសម្រួលស្ថាប័ន (វណ្ណារិទ្ធ ២០១៨) និង (ii) ព្យាយាមបង្រួមគម្លាតការអភិវឌ្ឍ នៅក្នុងចំណោមបណ្តាប្រទេសនៅតាមដងទន្លេមេគង្គ ដែលជាគោលដៅចម្បងនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។

គំនិតផ្តួចផ្តើមដែលត្រូវបានលើកឡើងខាងលើ បានរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់ទន្លេមេគង្គឲ្យកាន់តែស៊ីជម្រៅថែមទៀត។

## បញ្ហានៅក្នុងយន្តការគ្រប់គ្រងទឹកនៅតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ

### បញ្ហាគ្រប់គ្រងទឹកនៅតំបន់ទន្លេ Danube

ទោះបីជាយន្តការគ្រប់គ្រងទឹកនៅតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ ភាគច្រើនបាននាំឲ្យប្រទេសក្នុងតំបន់ទាំងនេះធ្វើការជាមួយគ្នាដោយសន្តិភាពក៏ដោយ ក៏យន្តការទាំងនេះនៅតែជួបបញ្ហាមួយចំនួនដែរ។ នៅ DRB គុណភាពទឹកនៅមានកម្រិត ហើយមានតែ ២៥% នៃទឹកនៅក្នុងតំបន់ប៉ុណ្ណោះ ដែលអាចចាត់ទុកថាបានឆ្លើយតបនឹងបទដ្ឋានបរិស្ថានចាំបាច់ (ICPDR ២០១៨: ២) ។ ដូច្នេះ បទប្បញ្ញត្តិចងកាតព្វកិច្ចដែលមានស្រាប់ ជាក់ស្តែងមិនបានជួយកែលម្អគុណភាពទឹកនៅក្នុងតំបន់នេះទេ។ កិច្ចសហប្រតិបត្តិការបន្ថែមទៀត នៅក្នុងចំណោមប្រទេសនានានៃ DRB ក៏ដូចជារវាង DRB និងពិភពលោកផងដែរ គួរតែត្រូវបានជំរុញ ដើម្បីដោះស្រាយបញ្ហានេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

បញ្ហាការគ្រប់គ្រងទឹកដ៏ចម្រូងចម្រាសនៅ DRB មួយទៀត គឺការសាងសង់ទំនប់ទឹក និង អាងស្តុកទឹកជាបន្តបន្ទាប់ ដែលនាំឱ្យមានការរំខានដល់លំហូរទឹកទន្លេ។ ទំនប់ទឹក និង អាងស្តុកទឹកត្រូវបានសាងសង់នៅស្ទើរតែគ្រប់តំបន់ភ្នំទាំងអស់នៃ DRB និងនៅតំបន់ទំនាបមួយចំនួន (មានទំនប់ទឹក និង ទំនប់ ច្រើនជាង ៧០០ នៅតាមបណ្តោយដៃទន្លេធំៗនៃទន្លេនេះ) ក្នុង

គោលបំណងជាច្រើនខុសៗគ្នា ប៉ុន្តែជាពិសេសសម្រាប់ការបង្កើតថាមពលវារីអគ្គិសនី (ICPDR ២០១៣a : ២៦)។

គួរកត់សម្គាល់ថា ដោយសារតែថាមពលវារីអគ្គិសនីបានក្លាយជាខ្សែសង្គ្រោះសេដ្ឋកិច្ចដ៏សំខាន់មួយសម្រាប់ប្រទេស DRB មួយចំនួននោះ ពួកគេមានការពិបាកនៅក្នុងការបញ្ឈប់សកម្មភាពវារីអគ្គិសនីនៅក្នុងតំបន់ទាំងស្រុង។

ឧទាហរណ៍៖ ប្រហែល ៦០ ភាគរយនៃការផ្គត់ផ្គង់អគ្គិសនីប្រចាំឆ្នាំរបស់ប្រទេសអូទ្រីសបានមកពីថាមពលវារីអគ្គិសនីដែលត្រូវបានបង្កើតនៅក្នុង DRB (ICPDR)។ ទោះបីជាមានសារសំខាន់បែបនេះក៏ដោយ ក៏ការសាងសង់រោងចក្រវារីអគ្គិសនីនៅ DRB បានក្លាយជាមូលហេតុឈានមុខគេនៃការរំខានដល់ទន្លេ Danube (ICPDR ២០១៣a: ៦៤)។ សកម្មភាពនេះ ជាចុងក្រោយ បង្កការលំបាកយ៉ាងខ្លាំងដល់បម្លាស់ទីរបស់ត្រី និង ដីល្បាប់នៅក្នុងតំបន់។ ដោយសារតែបញ្ហាទាំងនេះ បណ្តាប្រទេសនៃ DRB កំពុងស្វែងរកដៃគូខាងក្រៅដែលមានឧត្តម្មានុវត្ត និង មានបទពិសោធន៍ក្នុងការគ្រប់គ្រងទឹកដើម្បីធានាចំពោះការប្រើប្រាស់ប្រកបដោយចីរភាពឲ្យបានច្រើនជំនាន់។

## បញ្ហាគ្រប់គ្រងទឹកនៅក្នុងតំបន់ទន្លេមេគង្គ

ទោះបីមានយន្តការក្នុងតំបន់មួយចំនួនក៏ដោយ ក៏ហានិភ័យ និង ជម្លោះ ដែលទាក់ទងនឹងការគ្រប់គ្រងទឹកនៅក្នុងចំណោមបណ្តាប្រទេសខាងក្រោមខ្សែទឹក និងប្រទេសខាងលើខ្សែទឹកនៅក្នុងតំបន់មេគង្គ នៅតែមានកម្រិតខ្ពស់។ បញ្ហានានា ដូចជា គ្រោះរាំងស្ងួត និង ការថយចុះនៃជលផលបន្តិចម្តងៗ មានសភាពកាន់តែធ្ងន់ធ្ងរ។

នៅខែកក្កដា ឆ្នាំ២០១៩ គេបានរាយការណ៍ថាប្រទេសនៅក្រោមខ្សែទឹកបានជួបគ្រោះរាំងស្ងួតដ៏ធំមួយ ដែលបានគំរាមកំហែងដល់ជលផល និង ផលិតកម្មកសិកម្មនៅតាមបណ្តោយអាងទន្លេ។ គ្រោះរាំងស្ងួតបានបណ្តាលឱ្យប្រទេសថៃភាគឦសាន្តពុំមានទឹកទន្លេសម្រាប់ប្រើប្រាស់នោះទេ (Eyler និង Salzberg ២០១៩)។

លើសពីនេះទៀត កម្រិតទឹក គឺទាបជាងកម្រិតជាមធ្យមកាន់តែខ្លាំងឡើងៗ។ យោងតាម MRC កម្រិតទឹកនៅឈៀងសែន ប្រទេសថៃ មានកម្ពស់ ២,១០ ម៉ែត្រ (ម.) ក្នុងអំឡុងខែមិថុនា-កក្កដា ឆ្នាំ២០១៩ ពោលគឺ ០,៩២ ម. ទាបជាងកម្រិតមធ្យមរយៈពេលវែង (៣,០២ ម.) (MRC ២០១៩)។ ក្នុងរយៈពេលដូចគ្នានេះ កម្ពស់ទឹកនៅទីក្រុងវៀងច័ន្ទគឺ ៥,៥៤ ម. ពោលគឺ ០,៧០ ម៉ែត្រទាបជាងកម្រិតមធ្យមរយៈពេលវែង (៦,២៤ ម.) ហើយកម្រិតទឹកនៅខេត្តក្រចេះ ប្រទេស

កម្ពុជា គឺ ៩,៣១ ម. ពោលគឺប្រមាណ ៥,៤០ ម. ទាបជាងកម្រិតមធ្យមរយៈពេលវែង (១៤,៧១ ម.)។ ចាប់ពីថ្ងៃទី១០ ខែមិថុនា រហូតដល់ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ មានការធ្លាក់ចុះប្រហែល ០,៣៨ ម. នៅស្ថានីយ៍ក្រចេះ។ លើសពីនេះទៀត បរិមាណដីល្បាប់ដែលសម្បូរសារធាតុចិញ្ចឹម ដែលហូរតាមដងទន្លេ មានការថយចុះយ៉ាងខ្លាំង។ យោងតាមអង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌នៃអង្គការសហប្រជាជាតិ ការថយចុះនេះ ភាគច្រើន បណ្តាលមកពីការសាងសង់ទំនប់នៅផ្នែកខាងលើនៃទន្លេមេគង្គ (Fawthrop ២០១៨)។

យន្តការគោលនយោបាយដែលមានស្រាប់ គឺមិនគ្រប់គ្រាន់សម្រាប់ការកាត់បន្ថយហានិភ័យនៃស្ថានប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ទន្លេមេគង្គនោះទេ។ ជាលទ្ធផល បណ្តាប្រទេសនៅតាមដងទន្លេមេគង្គបានស្វះស្វែងសហការជាមួយប្រទេស និង តំបន់ផ្សេងៗទៀតដើម្បីរៀនសូត្រអំពីគោលនយោបាយ និង ឧត្តមានុវត្ត ដើម្បីគ្រប់គ្រងការប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព នៅក្នុងតំបន់ និង កាត់បន្ថយភាពតានតឹងដែលអាចកើតឡើង នៅក្នុងចំណោមបណ្តាប្រទេសខាងលើខ្សែទឹក និង ខាងក្រោមខ្សែទឹកនៅក្នុងតំបន់ទន្លេមេគង្គ។

## កិច្ចប្រជុំអាស៊ី-អឺរ៉ុបអាចកាត់បន្ថយបញ្ហាគ្រប់គ្រងទឹកនៅតំបន់ទន្លេ Danube និង ទន្លេមេគង្គបាន

ដោយសារតែតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ កំពុងប្រឈមនឹងបញ្ហាគ្រប់គ្រងទឹកនោះ ចាំបាច់ត្រូវបង្កើតយន្តការកិច្ចសហប្រតិបត្តិការរវាងតំបន់ទាំងពីរ។ ដោយមានការចូលរួមពីបណ្តាប្រទេស និង អង្គការអន្តរជាតិច្រើនជាង ៥០ ទូទាំងអឺរ៉ុប និង អាស៊ី ASEM គឺជាមធ្យោបាយមួយដែលអាចអនុវត្តបាន សម្រាប់កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងទឹករវាងទ្វីបទាំងពីរ។

ASEM បានក្លាយជាវេទិកាដ៏សំខាន់មួយសម្រាប់បណ្តាប្រទេសនានានៅអឺរ៉ុប និង អាស៊ី ជាពិសេសប្រទេសនៅតាមអាងទន្លេ Danube និង ទន្លេមេគង្គ ដើម្បីផ្លាស់ប្តូរទម្លាប់អនុវត្តនៃគោលនយោបាយល្អបំផុត និង មេរៀនដែលទទួលបាន និងស្វែងរកដំណោះស្រាយរួមគ្នាចំពោះបញ្ហាទឹកដែលពួកគេបានជួបប្រទះ។

បញ្ហាទឹកត្រូវបានលើកឡើងជាលើកដំបូងនៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ៧ ដែលត្រូវបានប្រារព្ធធ្វើឡើងនៅប្រទេសចិន កាលពីខែតុលា ឆ្នាំ២០០៨ ដែលថ្នាក់ដឹកនាំ ASEM បានពិភាក្សាជាចម្បងអំពីវិធីដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និង កិច្ចការពារបរិស្ថាន រួមទាំង ធនធានទឹកជាទូទៅផងដែរ។ ពួកគេបានឯកភាពលើកទឹកចិត្ត និងគាំទ្រដល់អង្គការក្នុងតំបន់ និង អនុតំបន់នៅក្នុងការបង្កើតគម្រោងស្រាវជ្រាវរួម រួមទាំងគម្រោងដែលទាក់ទងទៅនឹង

ធនធានទឹកសម្រាប់ទ្រទ្រង់ជីវិតផងដែរ (ASEM ២០០៨) ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានការយោងដល់ទន្លេ Danube ឬ ទន្លេមេគង្គ ជាពិសេស នោះទេ។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទីប្រាំបី ថ្នាក់ដឹកនាំទាំងឡាយបានសង្កត់ធ្ងន់លើសារសំខាន់នៃការគ្រប់គ្រងធនធានទឹក និង ភាពចាំបាច់នៃកិច្ចសហការនៅក្នុងការផ្លាស់ប្តូរការស្រាវជ្រាវវិទ្យាសាស្ត្រ បទពិសោធន៍ និង ឧត្តម្ភានុវត្ត។ ពួកគេថែមទាំងបានប្រគល់ភារកិច្ចដល់រដ្ឋមន្ត្រីរបស់ពួកគេឲ្យរៀបចំកិច្ចសន្ទនាកំដាក់លាក់មួយលើបញ្ហានេះនៅដើមឆ្នាំ ២០១១ (ASEM ២០១០) ។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទីប្រាំបួន នៅ ប្រទេសឡាវ កាលពីខែវិច្ឆិកា ឆ្នាំ២០១២ ថ្នាក់ដឹកនាំ ASEM បានលើកឡើងអំពីកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងទឹករវាងតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គជាលើកដំបូង។ ជាពិសេស ពួកគេបានសម្តែងការគាំទ្រចំពោះលទ្ធផលនៃសិក្ខាសាលាស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពរបស់ ASEM ជាលើកដំបូងដែលត្រូវបានប្រារព្ធធ្វើឡើងនៅប្រទេសហុងគ្រី កាលពីថ្ងៃទី ២១-២២ ខែមិថុនា ឆ្នាំ២០១២ ដែលផ្តោតលើតួនាទីដ៏សំខាន់របស់ទឹកនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង បានព្រមព្រៀងគ្នា ចែករំលែកឧត្តម្ភានុវត្ត និង បទពិសោធន៍របស់ពួកគេចំពោះការអភិវឌ្ឍ និង ការប្រើប្រាស់ធនធានទឹកបានយ៉ាងល្អប្រសើររវាងតំបន់ទាំងពីរ (ASEM ២០១២) ។

ក្នុងអំឡុងកិច្ចប្រជុំកំពូល ASEM លើកទី ១០ នៅប្រទេសអ៊ីតាលី កាលពីខែតុលា ឆ្នាំ២០១៤ ថ្នាក់ដឹកនាំបានបញ្ជាក់ជាថ្មីម្តងទៀតអំពី តួនាទីរបស់ ASEM នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការរវាងតំបន់ទាំងពីរ និង បានប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការរបស់ពួកគេលើបញ្ហានានាដែលទាក់ទងនឹងទឹកបន្ថែមទៀត (ASEM ២០១៤) ។

នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅប្រទេសម៉ុងហ្គោលី កាលពីឆ្នាំ ២០១៦ ថ្នាក់ដឹកនាំ ASEM បានទទួលស្គាល់អំពីតួនាទីរបស់ ASEM ក្នុងនាមជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ការចែករំលែកឧត្តម្ភានុវត្ត និង បទពិសោធន៍ ដែលទាក់ទងនឹងការគ្រប់គ្រងទឹករវាងតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ និង បានទទួលស្គាល់អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការលើវិស័យទឹករវាងតំបន់ទាំងពីរដោយ ASEM គឺជាគំរូមួយសម្រាប់ការកែប្រែបញ្ហាប្រឈមទូទៅឲ្យទៅជាឱកាសសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និង កំណើនប្រកបដោយបរិយាប័ន្ន (ASEM ២០១៦)។ ជាចុងក្រោយ នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១២ នៅប្រទេសប៊ែលហ្សិក កាលពីឆ្នាំ ២០១៨ ថ្នាក់ដឹកនាំ ASEM បានបញ្ជាក់ឡើងវិញអំពី

ការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរតំបន់លើការគ្រប់គ្រងធនធានទឹក និង បានទទួលស្គាល់ថា ASEM គឺជាគំរូមួយសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់នេះ (ASEM ២០១៨) ។

## សេចក្តីបញ្ចប់ និងអនុសាសន៍ស្តីពីគោលនយោបាយ

ទន្លេ Danube និងទន្លេមេគង្គ គឺជាខ្សែជីវិតដ៏សំខាន់របស់ទ្វីបអឺរ៉ុប និង អាស៊ី។ ដោយមើលឃើញអំពីសារៈសំខាន់ដ៏ខ្លាំងក្លានេះ យន្តការជាច្រើនកំពុងត្រូវបានដាក់ឲ្យប្រើប្រាស់ ដើម្បីធានាចំពោះការប្រើប្រាស់ទឹកយ៉ាងមានប្រសិទ្ធភាព និង មានចីរភាព ជំរុញកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និង កិច្ចការពារបរិស្ថាននៅក្នុងតំបន់ទាំងនេះ។ ពាក់ព័ន្ធនឹងការគ្រប់គ្រងទឹកនៅតាមដងទន្លេ Danube បណ្តាប្រទេសនៃ DRB បានបង្កើតបទបញ្ញត្តិដ៏ រឹងមាំ ដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់ ដូចជា DRPC WFD EFD និង សេចក្តីណែនាំ ស្តីពីថាមពលកកើតឡើងរបស់ EU ដើម្បីសម្រេចវត្ថុបំណងដែលបានលើកឡើងនៅខាងលើ។ ការបង្កើតឯកសារចងកាតព្វកិច្ចទាំងនោះបានធ្វើឱ្យការគ្រប់គ្រងទឹកនៅក្នុងចំណោមបណ្តាប្រទេស នៃ DRB មានភាពរលូន។

បន្ថែមពីលើឧបករណ៍ច្បាប់ដែលបានលើកឡើងខាងលើទៀតនោះ យន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ត្រូវបានបង្កើតឡើង នៅក្នុងចំណោមបណ្តាប្រទេសនៃ DRB ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលផ្នែកគ្រប់គ្រងធនធានទឹក ឱ្យកាន់តែប្រសើរឡើង។ ឧទាហរណ៍នានា រួមមានកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងទឹករវាងប្រទេសរ៉ូម៉ានី និង ប្រទេសហុងគ្រី និង កិច្ចព្រមព្រៀងរវាងប្រទេសក្រូអាត និង ប្រទេសបូស្នី និង ហឺហ្សេហ្គូវីណា។

ការគ្រប់គ្រងទឹកនៅតំបន់ទន្លេមេគង្គត្រូវបានគ្រប់គ្រងដោយគំនិតផ្តួចផ្តើមថ្នាក់តំបន់ដែលមានភាពបត់បែនកាន់តែខ្លាំង ដូចជា MRC GMS LMI និង LMC ជាដើម។ យន្តការទាំងនេះនៅកម្រិតជាក់លាក់មួយ បានជួយពង្រឹងទំនាក់ទំនងនៅក្នុងចំណោមបណ្តាប្រទេសនៅតាមដងទន្លេមេគង្គក្រោម និង រវាងប្រទេសទាំងនេះ ជាមួយប្រទេសម្ចាស់ជំនួយរបស់ពួកគេ ដូចជាប្រទេសចិន ប្រទេសជប៉ុន និង សហរដ្ឋអាមេរិក ជាដើម។ គំនិតផ្តួចផ្តើមទាំងនេះបានពង្រឹងការចែករំលែកព័ត៌មានស្តីពីបញ្ហានានា ដែលទាក់ទងនឹងទឹកនៅក្នុងតំបន់ទន្លេមេគង្គ និង បានបង្កើនកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចពហុភាគីនៅក្នុងចំណោមប្រទេសទាំងនេះផងដែរ។

ដោយហេតុថា ទាំងតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ បានប្រឈមមុខនឹងបញ្ហាប្រឈមប្រហាក់ប្រហែលគ្នានោះ ថ្នាក់ដឹកនាំនៅក្នុងតំបន់ទាំងពីរបានសម្រេចចិត្តធ្វើការជាមួយគ្នា

ដោយមាន ASEM ជាចំណុចកណ្ដាលនៃកិច្ចសន្ទនា។

កិច្ចប្រជុំកំពូល ASEM លើកទីប្រាំបួន បានបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងធនធានទឹក រវាងតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គ។ ថ្នាក់ដឹកនាំបានបង្ហាញការយល់ឃើញរបស់ពួកគេថា ការចែករំលែកឧត្តមានុវត្ត និង បទពិសោធន៍នានា ដែលទាក់ទងនឹងការគ្រប់គ្រងទឹកគួរតែត្រូវបានលើកទឹកចិត្ត។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូល ASEM លើកទី ១០-១២ ថ្នាក់ដឹកនាំបានឯកភាពគ្នាបង្កើតកិច្ចសហប្រតិបត្តិការទ្វេតំបន់រវាងតំបន់ទាំងពីរ ក្រោមក្របខ័ណ្ឌ ASEM និង ដោះស្រាយគម្រោងកិច្ចសហប្រតិបត្តិការជាក់លាក់ ដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹក។

ទោះបីជាមានការប្តេជ្ញាចិត្តនាពេលបច្ចុប្បន្នរបស់ ASEM នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងទឹករវាងតំបន់ទន្លេ Danube និង តំបន់ទន្លេមេគង្គក៏ដោយ ក៏គួរតែមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឲ្យសេចក្ដីថ្លែងការណ៍ទាំងនេះក្លាយជាសកម្មភាពជាក់ស្ដែង តាមរយៈការប្រមូលផ្ដុំសកម្មភាពនិងធនធាននានា។ កិច្ចប្រជុំកំពូល ASEM លើកទី១៣ (ASEM១៣) នាពេលខាងមុខនេះ នៅរាជធានីភ្នំពេញ នៅដើមខែមិថុនា ឆ្នាំ២០២១ អាចជាចំណុចចាប់ផ្ដើមដ៏ល្អមួយ។ វេទិកាពហុភាគីនេះអាចជួយដល់ទ្វីបអាស៊ី និង អឺរ៉ុប នៅក្នុងការដោះស្រាយបញ្ហាប្រឈមរួមគ្នា និង នាំមកនូវសន្តិភាព និង វិបុលភាពរួមគ្នាសម្រាប់ទ្វីបទាំងពីរ ស្របតាមប្រធានបទនៃកិច្ចប្រជុំកំពូល ASEM លើកទី១៣៖ “ការពង្រឹងពហុភាគីនិយមដើម្បីកំណើនរួម”។

# ឯកសារយោង

Asia–Europe Meeting (ASEM) (2008), Vision and Action: Towards A Win–Win Solution. Chair's Statement of the Seventh Asia–Europe Meeting, 24–25 October. https://www. aseminfoboard.org/events/7th-asem-summit-asem7 (accessed 12 April 2020).

ASEM (2010), Greater Well-Being and More Dignity for All Citizens. Chair's Statement of the Eighth Asia–Europe Meeting, 4–5 October. https://www.aseminfoboard.org/ events/ 8th-asem-summit-asem8 (accessed 12 April 2020).

ASEM (2012), Friends for Peace, Partners for Prosperity. Chair's Statement of the Ninth ASEM Summit, 5–6 November. https://www.aseminfoboard.org/events/9th-asem-summit- asem9 (accessed 13 April 2020).

ASEM (2014), Responsible Partnership for Sustainable Growth and Security. Final Chair's Statement of the 10th ASEM Summit, 16–17 October. https://www. aseminfoboard.org/ events/10th-asem-summit-asem10 (accessed 13 April 2020).

ASEM (2016), 20 Years of ASEM: Partnership For the Future Through Connectivity.

Chair's Statement of the 11th ASEM Summit, 15–16 July. https://www.aseminfoboard. org/ events/11th-asem-summit-asem11 (accessed 15 April 2020).

ASEM (2018), Global Partners for Global Challenges. Chair's Statement of the 12th ASEM Summit, 18–19 October. https://www.aseminfoboard.org/events/12th-asem-summit- asem12 (accessed 12 April 2020).

Bangkok Post (2020), 'The 97km that Frustrate China's Mastery of the Mekong', 10 January. Cambodian official (2019), 'Mekong–Lancang Cooperation', Phnom Penh.

Eyler, B. and A. Salzberg (2019), 'Mekong Near Tipping Point as US–China Rivalry Grows',

Nikei Asian Review, 27 August.

Fawthrop, T. (2018), 'Mekong: More Dams, More Damage', Interpreter, 28 March.

Greater Mekong Subregion, 'Projects of the Greater Mekong Subregion'. https:// greater mekong.org/gms-latest-projects (accessed 4 May 2020).

Helene, M.-G. (2019), 'From Convention to Action', Danube Watch, 2. https://www. icpdr. org/main/publications/danube-watch-2-2019-convention-action (accessed 24 March 2020).

International Commission for the Protection of the Danube River (ICPDR), 'Dams and Structures'. https://www.icpdr.org/main/issues/dams-structures (accessed 24 March 2020).

ICPDR (2012), Preliminary Flood Risk Assessment in the Danube River Basin District. Vienna: ICPDR.

ICPDR (2013a), Assessment Report on Hydropower Generation in the Danube Basin. Vienna: ICPDR Secretariat.

ICPDR (2013b), 'Sustainable Hydropower Development in the Danube Basin', in ICPDR Secretariat (ed.) Guiding Principles on Sustainable Hydropower. Vienna: ICPDR.

ICPDR (2018), Shared Waters–Joint Responsibilities: ICPDR Annual Report 2018. Vienna: ICPDR.

Matthew, P.F. and H. Brian (2020), 'An Upswell of Solidarity: China's Mekong Dams Face Online Backlash', Center for Strategic and International Studies, 24 April. https://www.csis.org/analysis/upswell-solidarity-chinas-mekong-dams-face-online-backlash (accessed 28 April 2020).

Mekong River Commission, 'About MRC'. http://www.mrcmekong.org/about-mrc/ (accessed 18 March 2020).

Mekong River Commission (2019), 'Mekong Water Levels Reach Low Record'. http://www.mrcmekong.org/news-and-events/news/mekong-water-levels-reach-low-record/ (accessed 18 March 2020).

Ministry of Foreign and European Affairs of Croatia, Directorate for International Legal Affairs, 'Overview of Bilateral Treaties of the Republic of Croatia by Country'.

http://www.mvep.hr/en/foreign-politics/bilateral-relations/overview-by-country/bosnia- and-herzegovina,17.html (accessed 19 May 2020).

Shepherd, K. (2018), Interim Report on the Implementation of the Joint Program of Measures in the Danube River Basin 2018. Vienna: ICPDR.

Tuoi Tre News (2020), 'Vietnam Calls for Sustainable Use of Mekong Water after China's Dam Tests', 10 January. https://tuoitrenews.vn/news/politics/20200110/vietnam-calls- for-sustainable-use-of-mekong-water-after-chinas-dam-tests/52534.html (accessed).

Vannarith, C. (2018), Lancang–Mekong Cooperation: A Cambodian Perspective. Singapore: Institute of Southeast Asian Studies.

VietnamNet (2016), 'How Much Economic Value Does the Mekong River Bring to Vietnam?', VietnamNet, 25 January.

# V

# សេចក្តីបញ្ចប់

## ការបោះជំហានទៅមុខ៖ កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់សម្រាប់អាស៊ី និង អឺរ៉ុប

ANITA PRAKASH
*វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា ទីក្រុងចាកាតា*

GARY R. HAWKE
*សាកលវិទ្យាល័យVictoria ប្រទេសនូវែលហ្សេឡង់*

14

# ការបោះជំហានឆ្ពោះទៅមុខ

## កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់ សម្រាប់អាស៊ី និង អឺរ៉ុប

ANITA PRAKASH

GARY R. HAWKE

កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ត្រូវបានរៀបចំឡើងដើម្បីពង្រឹងទំនាក់ទំនងរវាងអាស៊ី និង អឺរ៉ុប ដែលនឹងធានាបាននូវវិបុលភាពជាសមូហភាព និង កំណើនប្រកបដោយបរិយាប័ន្នរវាងតំបន់ទាំងពីរ។ ចាប់តាំងពីពេលចាប់ផ្ដើមនៅក្នុងឆ្នាំ១៩៩៦ មក ASEM បានដើរតួនាទីជាវេទិកាមួយយ៉ាងសំខាន់ក្នុងកិច្ចសន្ទនា និង កិច្ចសហប្រតិបត្តិការនៅក្នុងការតភ្ជាប់អាស៊ី និង អឺរ៉ុប។ ASEM គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីឆ្ពោះទៅរក ការដោះស្រាយតម្រូវការនៃការតភ្ជាប់កាន់តែខ្លាំងនៅក្នុងវិស័យភូមិសាស្ត្រ សេដ្ឋកិច្ច និង ប្រជាជននៅអាស៊ី និង អឺរ៉ុប។ នៅក្នុងកិច្ចប្រជុំកំពូល ASEM លើកទី ១០ នៅក្នុងឆ្នាំ២០១៤ នៅអ៊ីតាលី "ថ្នាក់ដឹកនាំបានគូសបញ្ជាក់អំពីសារសំខាន់នៃការតភ្ជាប់រវាងតំបន់ទាំងពីរ ដើម្បីវិបុលភាពផ្នែកសេដ្ឋកិច្ច និង ការអភិវឌ្ឍប្រកបដោយចីរភាព" (ASEM ២០១៤: កថាខណ្ឌទី ៧)។ កិច្ចប្រជុំកំពូល ASEM លើកទី ១១ នៅក្នុងឆ្នាំ២០១៦ នៅ Ulaanbaatar បានព្រមព្រៀងគ្នាធ្វើឲ្យ ASEM មានការឆ្លើយតបទៅនឹងតម្រូវការដែលកំពុងតែមានការកើនឡើង និង ភាពចាំបាច់ក្នុងការតភ្ជាប់។ ផ្អែកតាមអនុសាសន៍របស់ក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្ដីការតភ្ជាប់ (APGC) ក្រោមអធិបតីភាពរួមគ្នាដោយសេវាកម្មសកម្មភាពខាងក្រៅអឺរ៉ុប និង សហភាពអឺរ៉ុប (EU) តំណាងឲ្យក្រុមប្រទេសនៅអឺរ៉ុប និង ប្រទេសចិន និង ប្រទេសជប៉ុនតំណាងឲ្យក្រុមប្រទេសនៅអាស៊ី កិច្ចប្រជុំកំពូល ASEM លើកទី ១២ នៅទីក្រុងប្រ៊ូសសែល បានអនុម័តទៅលើ "វិស័យការងារសហប្រតិបត្តិការដែលមានលក្ខណៈរូបីនៅក្នុងការតភ្ជាប់ទំនាក់ទំនង" ដែលនឹងដើរតួជាឧបករណ៍នាំផ្លូវសម្រាប់អង្គភាព ASEM ដែលមានសមត្ថកិច្ច ក្នុងការដំណើរការ ASEM ឆ្ពោះទៅមុខ និង អនុវត្តសកម្មភាពដែលមានបំណងទទួលបានលទ្ធផលជាក់ស្ដែងទៅតាមជំនាញរបស់ពួកគេ។

ក្នុងអំឡុងពេលពីរបីខែនៅក្នុងឆ្នាំ២០២១ លក្ខណៈពិសេសជាសមូហភាព និង ដែលមានការសម្របសម្រួលពី ASEM បានរងផលប៉ះពាល់ដោយសារតែកិច្ចប្រជុំកំពូល ASEM លើកទី ១៣ (ASEM១៣) ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលមានភាពអាសន្នចំពោះ សុខភាពពិភពលោក ដូចជាជំងឺរាតត្បាតសកលដែលបង្កដោយមេរោគកូរ៉ូណា (កូវីដ-១៩) ដែលនាំឲ្យមានផលប៉ះពាល់ដែលមិនធ្លាប់មានពីមុនមកលើជីវិតរបស់ប្រជាជន និង សេដ្ឋកិច្ចរបស់ដៃគូ ASEM។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចខ្លាំងរបស់ ASEM គឺជាសក្តានុពលក្នុងការដឹកនាំប្រទេសជាដៃគូមកជួបជុំគ្នា និង ព្រមព្រៀងគ្នាលើមាគ៌ារួមមួយ ដើម្បីស្តារឡើងវិញ និង កសាងឡើងវិញនូវសង្គមនានានៅក្នុងរយៈពេលច្រើនឆ្នាំខាងមុខ។ ASEM១៣ មានបេសកកម្មមួយនៅក្នុងការកំណត់មាគ៌ានាពេលអនាគតសម្រាប់ ASEM ពោលគឺ ពង្រឹងគោលការណ៍ភាពរីកចម្រើនទៅវិញទៅមក ការអភិវឌ្ឍប្រកបដោយចីរភាព និង ពហុភាគីនិយមដែលផ្អែកលើច្បាប់។

## ASEM នៅក្នុងការផ្លាស់ប្តូរ ៖ សារសំខាន់នៃឆ្នាំ២០២១

ជំងឺរាតត្បាតសកល កូវីដ-១៩ គឺជាបញ្ហាប្រឈមដែលមិនធ្លាប់មានពីមុនមក ដែលបានប៉ះពាល់គ្រប់ប្រទេសទាំងអស់។ ក្រៅពីផលប៉ះពាល់ដែលបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរលើជីវិត និង សុខភាព ពិភពលោកក៏ប្រឈមនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប។

ជំងឺរាតត្បាតសកល កូវីដ ១៩ កំពុងតែគំរាមកំហែងដល់អាយុជីវិត ជីវភាពរស់នៅ និង សេដ្ឋកិច្ចទាំងមូល ដែលកំពុងតែលុបចោលទសវត្សរ៍នៃវឌ្ឍនភាពសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និង ផលចំណេញនៅក្នុងការអភិវឌ្ឍមនុស្ស។

ពិភពលោកបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លានៅក្នុងការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ក្រោយនេះ ប៉ុន្តែ មិនបានបន្តដំណើរដើម្បីឈានទៅសម្រេចគោលដៅនៃការបញ្ចប់ភាពក្រីក្រ ត្រឹមឆ្នាំ ២០៣០ ឬ សូម្បីតែមុនពេលដែលមេរោគកូរ៉ូណាបានធ្វើការវាយលុកនោះទេ – ជំងឺរាតត្បាតសកលអាចជំរុញឲ្យមនុស្សប្រហែល ១០០ លាននាក់បន្ថែមទៀតធ្លាក់ចូលទៅក្នុងភាពក្រីក្រធ្ងន់ធ្ងរនៅក្នុងឆ្នាំ២០២០ (ធនាគារពិភពលោក ឆ្នាំ២០២០)។

គ្រប់ប្រទេសទាំងអស់ត្រូវបានវាយប្រហារដោយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចខុសៗគ្នាជាច្រើនទៅលើតម្រូវការការផ្គត់ផ្គង់ និង ការផ្តល់ហិរញ្ញប្បទាន។ គុណតម្លៃស្នូលរបស់ ASEM (ការតភ្ជាប់រវាងអាស៊ី និង អឺរ៉ុប) កំពុងតែស្ថិតនៅក្រោមភាពតានតឹង និង បានរងការរំខាននៅក្នុងចំណោមប្រទេសដៃគូជាច្រើន។ តំបន់ ASEM ក៏កំពុងតែប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើន នៅក្នុងការ

សម្រេចគោលដៅនៃរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។

ការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ ចាប់ពីចុងឆ្នាំ២០១៩ មក បានដាក់សម្ពាធយ៉ាងខ្លាំងលើស្ថានភាពសេដ្ឋកិច្ច និង សង្គមរបស់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់ត្រូវបានរំពឹងទុកថានឹងកើតឡើងនៅក្នុងឆ្នាំ២០២០។ ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០២០ ត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះជាមធ្យម ២,៩% នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី និង ២,៨% នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។[114] អត្រាកំណើនត្រូវបានប្រមើលមើលថានឹងត្រឡប់មកប្រហាក់ប្រហែលគ្នានឹងមុនពេលមានកូវីដ-១៩ វិញនៅក្នុងឆ្នាំ២០២១ ពោលគឺ ៦,៨% នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងងើបឡើងនៅអាស៊ី និង ៥,៦% នៅអាស៊ាន(OECD ២០២០a)។ គេបានប៉ាន់ស្មានថាកំណើននឹងលោតឡើងរហូតដល់ ៦,៨% នៅក្នុងឆ្នាំ២០២១ ដែលជាលក្ខខណ្ឌមូលដ្ឋានដើម្បីត្រឡប់ទៅកាន់ភាពធម្មតាវិញយ៉ាងសន្សឹមៗ។ សេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ទាំងមូល ត្រូវបានរំពឹងទុកថាធ្លាក់ចុះត្រឹម ២,៨% នៅក្នុងឆ្នាំ២០២០ មុនពេលត្រឡប់មកមានកំណើនវិញនៅក្នុងឆ្នាំ២០២១។ រចនាបថនៃកំណើនសេដ្ឋកិច្ចនៅប្រទេសចិន និង ប្រទេសឥណ្ឌា ត្រូវបានរំពឹងទុកថានឹងដើរតាមគន្លងដដែល។ សេដ្ឋកិច្ចរបស់ប្រទេសចិនត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះជាលើកដំបូងនៅឆ្នាំនេះ ចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ មក មុនពេលដែលកំណើន GDP នឹងមានភាពល្អប្រសើរឡើងវិញនៅឆ្នាំបន្ទាប់។ សេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌា ក៏នឹងធ្លាក់ចុះជាលើកដំបូងផងដែរ នៅក្នុងរយៈពេលជាង ៤០ មកនេះ និង ងើបឡើងវិញនៅក្នុងឆ្នាំ២០២១។

ការចង្អុលបង្ហាញអំពីការភ្ជាប់ចំណងពាណិជ្ជកម្មល្អៗឡើងវិញ ក៏មានកម្រិតដែរពីព្រោះការបន្តការរឹតត្បិតនៅតាមព្រំដែន និង ការថយនៃតម្រូវការពីប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន ទំនងជានឹងជះឥទ្ធិពលដល់ទ្វីបអាស៊ី។ សេដ្ឋកិច្ចអាស៊ីដែលកំពុងតែងើបឡើង មានចន្លោះសារពើពន្ធដែលមានកម្រិត ជាពិសេសការធ្លាក់ចុះនៃប្រាក់ចំណូល។ ការធ្វើការនៅលើគម្រោងធំៗបានចុះទន់ខ្សោយ។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមានភាពមិនច្បាស់លាស់ ពីព្រោះប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនដើម្បីតស៊ូជាមួយសន្ទនិយភាពផ្ទាល់ខ្លួនរបស់ពួកគេ។

អាស៊ីអាគ្នេយ៍ទទួលរងផលប៉ះពាល់ជាពិសេស តាមរយៈការបាត់បង់ការធ្វើដំណើរ និង ទេសចរណ៍ ដែលមានចំនួន ១២% នៃសេដ្ឋកិច្ច។ សហគ្រាសធុនតូច និង មធ្យម ដែលមាន

114 អាស៊ានមាន ១០ ប្រទេស៖ ប្រទេសប្រ៊ុយណេ ប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី ប្រទេសមីយ៉ាន់ម៉ា ប្រទេសហ្វីលីពីន ប្រទេសសិង្ហបុរី ប្រទេសថៃ និង ប្រទេសវៀតណាម។

ចំនួនជាង ៩០% នៃចំនួនសហគ្រាសនៅក្នុងតំបន់ ងាយរងគ្រោះជាពិសេសដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច។

អឺរ៉ុបកំពុងតែប្រឈមមុខនឹងសេដ្ឋកិច្ចធ្លាក់ចុះប្រហាក់ប្រហែលគ្នាដែរ។ បញ្ហាប្រឈមចំពោះការស្តារសេដ្ឋកិច្ចឡើងវិញរបស់ខ្លួន មានភាពធ្ងន់ធ្ងរ និង ត្រូវការគោលនយោបាយដែលមាននវានុវត្តន៍ និង កិច្ចសហប្រតិបត្តិការជាសកល។ យោងតាមការព្យាករណ៍រដូវក្តៅ នៅ EU សេដ្ឋកិច្ចរបស់ EU ត្រូវបានកំណត់ថាមានការថយចុះត្រឹម ៨,៣% នៅក្នុងឆ្នាំ២០២០ និង ៥,៨% នៅក្នុងឆ្នាំ២០២១ (គណៈកម្មការអឺរ៉ុប ២០២០: ១)។

EU កំពុងធ្វើការដើម្បីឆ្ពោះទៅកាន់ផែនការស្តារឡើងវិញដែលមានភាពធន់ និង មានចីរភាព។ គេបានព្រមព្រៀងគ្នាប្រមូលផ្តុំទឹកប្រាក់ចំនួន ១,៨ ទ្រីលានអឺរ៉ូ សម្រាប់ឆ្នាំក្រោយៗទៀត ដើម្បីកែប្រែជាចម្បងនូវគំរូសេដ្ឋកិច្ច និង សង្គម រួមជាមួយរបៀបវារៈស្តីពីអាកាសធាតុ និង ឌីជីថល។ EU កំពុងតែដំណើរការដើម្បីក្លាយជាតំបន់ដែលគ្មានការបញ្ចេញកាបូន ត្រឹមឆ្នាំ២០៥០ និង កំពង់តែសម្របសម្រួលផែនការស្តារឡើងវិញ និង ផែនការដែលមានភាពធន់នៅថ្នាក់ជាតិ ដើម្បីចំណុចដៅនៃជំនួញបៃតងនៅអឺរ៉ុប។ ការព្រួយបារម្ភនៅអឺរ៉ុបនៃការស្តារឡើងវិញក្នុងទម្រង់ K ដែលអ្នកមានទទួលបានផលប្រយោជន៍កាន់តែច្រើន។

ដូច្នេះ មានការផ្តោតលើផែនការស្តារឡើងវិញនៅក្នុងតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុត និង វិស័យដែលរងផលប៉ះពាល់ខ្លាំងបំផុត។

## ភាពរីកចម្រើនទៅវិញទៅមកសម្រាប់អាស៊ី និង អឺរ៉ុប៖ ពាណិជ្ជកម្មដែលមានភាពធន់ និង ខ្សែសង្វាក់តម្លៃសកល

វិបុលភាពនៅក្នុងតំបន់ ASEM ត្រូវបានគាំទ្រដោយពាណិជ្ជកម្ម និង ការវិនិយោគ។ អាស៊ី និង អឺរ៉ុបមានទីផ្សារ ដែលមានប្រជាជនជិត ៥ ប៊ីលាននាក់ និង ពាណិជ្ជកម្មអន្តរតំបន់ចំនួន ៣២ ទ្រីលានដុល្លារ នៅក្នុងឆ្នាំ២០១៨។ ទំនិញដែលត្រូវបានផលិតតំណាងឲ្យចំណែកធំបំផុតនៃពាណិជ្ជកម្មរវាងអាស៊ី និង អឺរ៉ុប។

នាពេលបច្ចុប្បន្ន ប្រទេសចិនគឺជាប្រភពធំបំផុតនៃការនាំចូល និង ជាទីផ្សារនាំចេញធំលំដាប់ទីពីររបស់ EU។ បណ្តាប្រទេសនៅ EU និង អាស៊ានបានបង្កើនបង្រួមសកម្មភាពពាណិជ្ជកម្មទ្វេភាគីរបស់ពួកគេយ៉ាងខ្លាំងក្លា នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ដោយ EU មានចំណែកប្រហែល ១៣% នៃពាណិជ្ជកម្មអាស៊ាន។ ពាណិជ្ជកម្មផ្នែកសេវាកម្មក៏មានសារសំខាន់ចំពោះការដំណើរការ

យ៉ាងរលូននៃខ្សែសង្វាក់តម្លៃសកលដែរ និង បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រីកពាណិជ្ជកម្មនៅអាស៊ី និង អឺរ៉ុប នៅក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ។

អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅពេលនេះ បានព្យាករណ៍ថានឹងការមានការថយចុះចំនួន ៩,២% នៃទំហំពាណិជ្ជកម្មទំនិញនៅលើពិភពលោក សម្រាប់ឆ្នាំ២០២០ បន្តដោយកំណើនចំនួន ៧,២% នៅក្នុងឆ្នាំ២០២១ (រូបភាពទី ១)។ ការប៉ាន់ស្មានទាំងនេះមានភាពមិនច្បាស់លាស់យ៉ាងខ្លាំងក្លាខុសពីធម្មតា ដោយសារតែការប៉ាន់ស្មានទាំងនេះអាស្រ័យលើការវិវឌ្ឍន៍នៃជំងឺរាតត្បាតសកល និង រដ្ឋាភិបាលដែលឆ្លើយតបទៅនឹងជំងឺនេះ (WTO ២០២០)។

ទោះបីជាការធ្លាក់ចុះផ្នែកពាណិជ្ជកម្មនៅក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល កូវីដ-១៩ មានទំហំប្រហាក់ប្រហែលគ្នានឹងវិបត្តិហិរញ្ញវត្ថុពិភពលោក ឆ្នាំ២០០៨-២០០៩ ក៏ដោយ ក៏បរិបទសេដ្ឋកិច្ចមានភាពខុសគ្នាខ្លាំងណាស់ដែរ។ GDP រួមតូច នៅក្នុងការថយចុះនៃសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន មានភាពខ្លាំងក្លាជាងមុនយ៉ាងខ្លាំង នៅខណៈពេលដែលការថយចុះផ្នែកពាណិជ្ជកម្មមានភាពធូរស្រាលជាងមុន។ ជាលទ្ធផល ទំហំពាណិជ្ជកម្មទំនិញនៅលើពិភពលោក ត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះប្រហែលពីរដងនៃ GDP ពិភពលោក ស្របតាមអត្រាប្តូរប្រាក់នៅលើទីផ្សារ ជាជាងការធ្លាក់ចុះចំនួនប្រាំមួយដង នៅក្នុងអំឡុងការដួលរលំនៅឆ្នាំ២០០៩ (WTO ២០២០)។

**រូបភាពទី១៖ ទំហំនៃពាណិជ្ជកម្មទំនិញនៅលើពិភពលោក**




សម្គាល់៖ រូបភាពសម្រាប់ឆ្នាំ២០២០ និង ២០២១ គឺជាចំណោល។
ប្រភព៖ WTO (២០២០)

ជំងឺរាតត្បាតសកលបានធ្វើឲ្យមានផលប៉ះពាល់ដល់ខ្សែសង្វាក់ផ្គត់ផ្គង់ ការរំខានដល់ផលិតកម្ម និង ទស្សនវិស័យនៃសេដ្ឋកិច្ចធ្លាក់ចុះជាសកល។ ការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ ចាប់តាំងពីចុងឆ្នាំ២០១៩ មក បានបណ្តាលឲ្យមានការរឹតបន្តឹងការត្រួតពិនិត្យនៅតាមព្រំដែន និង ការរំខានដល់ផលិតកម្ម។ ស្របពេលជាមួយគ្នានោះ គោលនយោបាយសាច់ប្រាក់ និង សារពើពន្ធដ៏តឹងរ៉ឹងបាន បានបញ្ឈប់ការធ្លាក់ចុះនៃប្រាក់ចំណូល ដោយអនុញ្ញាតឲ្យការប្រើប្រាស់ និង ការនាំចូលមានភាពល្អប្រសើរឡើងវិញបន្ទាប់ពីការកាត់បន្ថយការបិទខ្ទប់ក្នុងប្រទេស។ មានហានិភ័យជាច្រើនចំពោះការស្តារឡើងវិញដែលមាននិរន្តរភាពនៅក្នុងរយៈពេលមធ្យម។ ការវិនិយោគ និង ការងារគឺជាគន្លឹះសម្រាប់ការស្តារឡើងវិញ ប៉ុន្តែ ជំងឺកូវីដ-១៩ ដែលនៅតែបន្ត ឬ កើតឡើងវិញម្តងទៀត អាចបណ្តាលឲ្យមានការបាត់បង់ពាណិជ្ជកម្មរវាងអាស៊ី និង អឺរ៉ុបជាបន្តបន្ទាប់។ កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធលើការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និង ការវិនិយោគរវាងបណ្តាប្រទេសនៅអាស៊ី និង អឺរ៉ុប ស្របពេលនឹងការផលិត និង ការផ្គត់ផ្គង់ថ្នាំបង្ការ និង វិធានការសុខភាពសាធារណៈដទៃទៀត នឹងធានាថា ASEM បន្ត និង បង្កើនទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនជាសមូហភាព ដើម្បីអត្ថប្រយោជន៍ទៅវិញទៅមករបស់ទាំងអាស៊ី និង អឺរ៉ុប។

ពាណិជ្ជកម្មរវាងអាស៊ី និង អឺរ៉ុប នឹងធ្លាក់ចុះក្នុងរយៈពេលខ្លី ហើយសហគ្រាសធុនតូចបំផុត សហគ្រាសធុនតូច និង មធ្យម ពាណិជ្ជកម្មផ្នែកសេវាកម្ម និង ទេសចរណ៍នឹងទទួលរងផលប៉ះពាល់ខ្លាំងបំផុត។

ផលប៉ះពាល់លើតម្រូវការដែលអូសបន្លាយរយៈពេលវែងអាចធ្វើឲ្យខ្សែសង្វាក់ផ្គត់ផ្គង់រវាងអាស៊ី និង អឺរ៉ុប ចុះទន់ខ្សោយ ឬ អាចមានភាពជុនដាបថែមទៀតផង។ លើសពីនេះទៀត ការដាក់បញ្ចូលលទ្ធភាពសងបំណុលទៅក្នុងសេដ្ឋកិច្ចជឿនលឿនរបស់អាស៊ី និង អឺរ៉ុប នឹងធ្វើឲ្យលំហូរមូលធនហិរញ្ញវត្ថុទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍មានភាពយឺតយ៉ាវ ឬ មានលំហូរបញ្ច្រាសទិស។

ដូច្នេះ ការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និង ការវិនិយោគក្លាយជាខ្សែបន្ទាត់ចម្បងនៃកិច្ចសហប្រតិបត្តិការនៅ ASEM។ ផ្នែកនានានៃអាស៊ី និង អឺរ៉ុប បានចាប់ផ្តើមធ្វើពិពិធកម្មខ្សែសង្វាក់តម្លៃនៃផលិតកម្មរបស់ពួកគេ។ ចំណុចនេះអាចមានការកើនឡើងកាន់តែបន្ទាន់ថែមទៀត នៅពេលដែលមានតម្រូវការនៅក្នុងវិស័យសេដ្ឋកិច្ចឡើងវិញ។ ដូច្នេះ អាស៊ី និង អឺរ៉ុប ត្រូវតែធ្វើការរួមគ្នាលើវិធានការសម្របសម្រួលពាណិជ្ជកម្ម និង ការវិនិយោគដែលត្រៀមខ្លួនជាស្រេចសម្រាប់ពេលអនាគត និង ធានាចំពោះការផ្តល់ប្រភពទំនិញអន្តរកាល និង ទំនិញចុងក្រោយ តាមរយៈការភ្ជាប់ទំនាក់ទំនងនៃការផ្គត់ផ្គង់ដែលមានភាពធន់ និង មានរយៈពេលខ្លី។

ការពិបាករយៈពេលខ្លីនឹងបង្ហាញវត្តមានដោយខ្លួនឯង ពីព្រោះជំងឺរាតត្បាតសកលអាចបន្តរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលមានស្រាប់។ ការពិបាកទាំងនេះមិនគួររារាំង ASEM ពីកិច្ចសហប្រតិបត្តិការនៅលើវេទិកាពាណិជ្ជកម្ម និង ការវិនិយោគរយៈពេលវែង ដែលមានភាពរឹងមាំ និង មានអត្ថប្រយោជន៍ចំពោះគ្រប់ប្រទេសដៃគូទាំងអស់ ទោះបីជាធំ ឬ តូចក្ដី។

## ការអភិវឌ្ឍប្រកបដោយចីរភាព៖ ការសម្រេចបានចំណុចដៅនៃ SDG នៅដំណាក់កាលក្រោយជំងឺកូវីដ-១៩

ឆ្នាំ២០២០ បានចាប់ផ្ដើមទសវត្សរ៍នៃសកម្មភាព ពោលគឺ ការបញ្ជាក់ឡើងវិញអំពីការប្ដេជ្ញាចិត្តជាសកល តាមរយៈកិច្ចខិតខំប្រឹងប្រែងដែលបានបង្កើនល្បឿន និង ដំណោះស្រាយដែលមាននិរន្តរភាព ចំពោះបញ្ហាប្រឈមធំជាងគេបំផុតរបស់ពិភពលោក ចាប់ពីការកាត់បន្ថយភាពក្រីក្រ និង ការកាត់បន្ថយវិសមភាពយេនឌ័ររហូតដល់ការដោះស្រាយការប្រែប្រួលអាកាសធាតុ។

ប៉ុន្តែ នៅក្នុងរយៈពេលខ្លីតែប៉ុណ្ណោះដែល ជំងឺរាតត្បាតសកល កូវីដ-១៩ បានរំខានដល់កិច្ចខិតខំប្រឹងប្រែងសម្រេចបាននូវរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ សហគមន៍ពិភពលោកកំពុងតែស្ថិតនៅក្នុងស្ថានភាពដែលមិនធ្លាប់កើតឡើងពីមុនមក ដែលវិបត្តិសុខភាព សេដ្ឋកិច្ច និង សង្គមដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាបានធ្វើឲ្យប្រទេសទាំងឡាយប្រឹងប្រែងទប់ស្កាត់ជំងឺរាតត្បាតសកល និង ផ្ដល់ជំនួយហិរញ្ញវត្ថុភ្លាមៗ ដល់ប្រជាជនជាច្រើនដែលរងផលប៉ះពាល់ពីការធ្លាក់ចុះនៃម៉ាក្រូសេដ្ឋកិច្ចដែលពាក់ព័ន្ធ។ ជំងឺរាតត្បាតសកលបានគំរាមកំហែងដល់ការធ្វើឲ្យវឌ្ឍនភាពជាច្រើននៃភាពក្រីក្រ ភាពអត់ឃ្លាន ការថែទាំសុខភាព និង ការអប់រំ ដើរថយក្រោយ។ នៅខណៈពេលដែលមេរោគមានផលប៉ះពាល់ចំពោះមនុស្សគ្រប់រូបនោះ វាកំពុងតែមានផលប៉ះពាល់ខ្លាំងក្លាបំផុតលើជនក្រីក្របំផុត និង ជនដែលងាយរងគ្រោះបំផុតនៅលើពិភពលោក។

UNESCAP (២០១៩) បានរាយការណ៍ថា អាស៊ី និង ប៉ាស៊ីហ្វិក ត្រូវការពន្លឿនវឌ្ឍនភាពដើម្បីឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំងអស់នៃ របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ នៅលើគន្លងរបស់ខ្លួននាពេលបច្ចុប្បន្ន តំបន់នេះនឹងមិនសម្រេចបាន SDGs ណាមួយ ក្នុងចំណោម SDGs ទាំង ១៧ ត្រឹមឆ្នាំ២០៣០ នោះទេ។ ដើម្បីខិតខំប្រឹងប្រែងអនុវត្តតាមមហិច្ឆតារបស់របៀបវារៈឆ្នាំ២០៣០ តម្រូវឲ្យមានវឌ្ឍនភាពដែលមានល្បឿនលឿននៅគ្រប់សកម្មភាពទាំងអស់។ ចំពោះ SDGs ចំនួនបី ស្ថានភាពនេះកំពុងតែមានសភាពកាន់តែអាក្រក់ឡើង និង ចាំបាច់ត្រូវមានចំណាត់ការបន្ទាន់ ដើម្បីធ្វើឲ្យមានសភាពដើមវិញ។

មានវឌ្ឍនភាពចំពោះ SDGs មួយចំនួន (១ ៤ និង ៧) នៅអាស៊ី និង បាស៊ីហ្វិក ប៉ុន្តែអត្រានៃវឌ្ឍនភាព គឺមិនគ្រប់គ្រាន់នោះទេ។ ទោះបីជានៅកន្លែងដែលមានវឌ្ឍនភាពល្អក៏ដោយ ក៏វាមានភាពយឺតយ៉ាវខ្លាំងណាស់ចំពោះការសម្រេចគោលដៅទាំងនេះត្រឹមឆ្នាំ២០៣០។ ឧទាហរណ៍៖ នៅខណៈពេលដែលមានការចុះបញ្ជីវឌ្ឍនភាពខ្លាំងបំផុត ចំពោះការផ្តល់ការអប់រំដែលមានគុណភាពល្អ (SDG ៤) នោះ ចាំបាច់ត្រូវមានវឌ្ឍនភាពកាន់តែលឿនដើម្បីឆ្ពោះទៅសម្រេចបានចំណុចដៅនានាដែលនៅខាងក្រោមគោលដៅនោះ។ ចំពោះ SDGs ជាងពាក់កណ្តាលពុំមានវឌ្ឍនភាពនោះទេ ឬ កំពុងតែវិវឌ្ឍន៍ខុសទិសដៅនៅអាស៊ី។ មានវឌ្ឍនភាពតិចតួចដែលសម្រេចបាន ដើម្បីឆ្ពោះទៅបញ្ចប់ភាពអត់ឃ្លាន (SDG ២) គាំទ្រវិស័យឧស្សាហកម្ម នវានុវត្តន៍ និង ហេដ្ឋារចនាសម្ព័ន្ធ (SDG ៩) កាត់បន្ថយវិសមភាព (SDG ១០) កសាងទីក្រុង និង សហគមន៍ដែលមានចីរភាព (SDG ១១) ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ (SDG ១៣) ការពារជីវិតនៅក្នុងទឹក(SDG១៤)និងជីវិតនៅលើដី(SDG១៥)ឬឆ្ពោះទៅកាន់ការគាំទ្រសន្តិភាព យុត្តិធម៌ និង ស្ថាប័នរឹងមាំ (SDG ១៦)។ និន្នាការអវិជ្ជមានត្រូវបានកត់ត្រាចំពោះវិស័យទឹកស្អាត និង អនាម័យ (SDG ៦) ការធានាបាននូវការងារសមរម្យ និង កំណើនសេដ្ឋកិច្ច (SDG ៨) និង គាំទ្រការប្រើប្រាស់ និង ផលិតកម្មប្រកបដោយការទទួលខុសត្រូវ (SDG ១២) (UNESCAP ២០១៩)។

ជំងឺរាតត្បាតសកល កូវីដ ១៩ បានជះឥទ្ធិពលដល់និន្នាការដើម្បីឆ្ពោះទៅកាន់វឌ្ឍនភាព ហើយគេបានប្រមើលមើលថាវឌ្ឍនភាពរបស់អាស៊ីនឹងមានភាពយឺតយ៉ាវ ឬ ដើរត្រឡប់ក្រោយ។ ការបាត់បង់លទ្ធផលផ្នែកសេដ្ឋកិច្ចនៅក្នុងតំបន់ នឹងមានសភាពកាន់តែអាក្រក់ឡើងដោយសារកង្វះវឌ្ឍនភាពឆ្ពោះទៅសម្រេច SDGs។ កង្វះវឌ្ឍនភាពឆ្ពោះទៅសម្រេច SDG ១៧ អាចបំផ្លាញវឌ្ឍនភាពឆ្ពោះទៅសម្រេច SDGs ផ្សេងៗទៀតទាំងអស់ ពីព្រោះការព្យាយាមពង្រឹងភាពជាដៃគូ និង មធ្យោបាយនៃការអនុវត្តដើម្បីសម្រេចបានចំណុចដៅដែលមានមហិច្ឆតានៃរបៀបវារៈឆ្នាំ២០៣០។ ការគូសបញ្ជាក់អំពីចំណុចដៅដែលផ្តោតលើការវាស់វែងអំពីប្រាក់ចំណូលពន្ធដារ ចីរភាពនៃបំណុល សមត្ថភាពផ្នែកស្ថិតិ ការផ្ទេរបច្ចេកវិទ្យា កិច្ចសហប្រតិបត្តិការអន្តរជាតិ ស្ថានភាពពាណិជ្ជកម្ម និង ទំនាក់ទំនងនៃគោលនយោបាយចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។ វឌ្ឍនភាពនៅក្នុងវិស័យទាំងអស់នេះ គឺចាំបាច់ ដើម្បីធានាថា យើងមានមធ្យោបាយដើម្បីផ្តល់ហិរញ្ញប្បទាន កំណត់ចំណុចដៅ និង អនុវត្តដំណោះស្រាយផ្នែកគោលនយោបាយដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព (UNESCAP ឆ្នាំ២០១៩)។

នៅទូទាំងពិភពលោក បណ្តាប្រទេសនៅអឺរ៉ុបបានចូលទៅជិតការសម្រេចបាននូវ SDGs ខ្លាំងជាងគេបំផុត ប៉ុន្តែពុំមានប្រទេសណាមួយកំពុងដំណើរការដើម្បីឆ្ពោះទៅសម្រេចគោលដៅទាំងនោះត្រឹមឆ្នាំ២០៣០នោះទេ។ ប្រទេសចំនួន ១០ ដែលចូលទៅជិតការសម្រេចបាន SDGs ខ្លាំងជាងគេបំផុត គឺនៅអឺរ៉ុប (SDSN និង IEEP ឆ្នាំ២០១៩)។ ប៉ុន្តែ អឺរ៉ុបប្រឈមមុខនឹងបញ្ហាប្រឈមខ្លាំងជាងគេបំផុតចំពោះគោលដៅនានាដែលទាក់ទងនឹងអាកាសធាតុ ជីវចម្រុះ និង សេដ្ឋកិច្ចក្រាព្រមទាំងចំពោះការពង្រឹងចំណុចប្រសព្វនៃជីវភាពរស់នៅ នៅទូទាំងប្រទេស និង តំបន់នានា។ ជាពិសេស ប្រទេសដែលចាំបាច់ត្រូវពន្លឿនវឌ្ឍនភាពចំពោះការប្រែប្រួលអាកាសធាតុ (SDG ១៣) ការប្រើប្រាស់ និង ផលិតកម្មប្រកបដោយចីរភាព (SDG ១២) កិច្ចការពារ និង ការអភិរក្សជីវចម្រុះ (SDGs ១៤ និង ១៥) និង ប្រព័ន្ធកសិកម្ម និង ស្បៀងអាហារដែលមាននិរន្តរភាព (SDG ២)។

ភាពឈានមុខគេរបស់ EU មានសារសំខាន់ មិនមែនព្រោះតែទ្វីបអឺរ៉ុបចាំបាច់ត្រូវសម្រេចគោលដៅដើម្បីអត្ថប្រយោជន៍របស់ខ្លួនផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ព្រោះតែរបៀបវារៈឆ្នាំ២០៣០ គឺជាការបញ្ជាក់ជាសកលអំពីគុណតម្លៃស្នូលរបស់ EU ផងដែរ។ SDGs តំណាងឲ្យគុណតម្លៃរបស់ទ្វីបអឺរ៉ុប ដូច្នេះ EU គួរតែប្រើប្រាស់គោលដៅទាំងនោះជាផ្នែកមួយនៃសកម្មភាពខាងក្រៅរបស់ពួកគេ (SDSN និង IEEP ២០១៩)។ ជំនួញបៃតងនៅអឺរ៉ុបគឺជាក្របខណ្ឌដាច់ខាតមួយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅអឺរ៉ុប ក្នុងអំឡុងទសវត្សរ៍ខាងមុខ ហើយវាគួរតែត្រូវបានគេលើកកម្ពស់ឲ្យក្លាយជាលិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការជាមួយអាស៊ី ដើម្បីសម្រេច SDGs។

EU បានជះឥទ្ធិពលយ៉ាងខ្លាំងក្លានៅលើពិភពលោកតាមរយៈភាពឈានមុខគេផ្នែកប្រាជ្ញា និង គោលនយោបាយ ភាពឈានមុខគេរបស់ពួកគេនៅក្នុងការអនុវត្ត SDG និង ការពិតដែល EU គឺជាអ្នកគាំទ្រដ៏រឹងមាំបំផុតនៃរបៀបរៀបរយបែបពហុភាគីដែលផ្អែកលើច្បាប់ ដោយមានធម្មនុញ្ញអង្គការសហប្រជាជាតិ ស្ថាប័ន និង សន្ធិសញ្ញានានា ជាចំណុចសំខាន់។ ដូច្នេះ ASEM ត្រូវតែជាវេទិកាពហុភាគីដ៏សំខាន់មួយដើម្បីបន្តអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការ SDG ដែលមានមហិច្ឆតា និង ប្រកបដោយយុទ្ធសាស្ត្រ រវាងអឺរ៉ុប និង អាស៊ី។

សេចក្តីថ្លែងការណ៍របស់ប្រធាន ASEM នៅឆ្នាំ២០១៦ និង ២០១៨ ទទួលស្គាល់អំណាចជាសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ យន្តការនៃកិច្ចសន្ទនារបស់ ASEM រួមទាំងរបៀបវារៈនៃការតភ្ជាប់របស់វា គឺស័ក្តិសមបំផុតសម្រាប់ការគាំទ្រដល់ការបន្តការអភិវឌ្ឍប្រកបដោយចីរភាព និង ចំណាត់ការផ្នែកអាកាសធាតុនៅអាស៊ី និង អឺរ៉ុប។ ការស្វែងរកហេដ្ឋារចនា

សម្ព័ន្ធដែលមានភាពធន់ និង ដំណោះស្រាយដែលមាននវានុវត្តន៍ផ្អែកស្បៀងអាហារ សុខភាព និង សន្តិសុខអ៊ីនធឺណិត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាពនៅអាស៊ី និង អឺរ៉ុប។ ក្រុមការងាររបស់ ASEM ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព គួរតែប្រើប្រាស់ចំណុចនេះជាក្របខណ្ឌមួយដើម្បីត្រួតពិនិត្យវឌ្ឍនភាពក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

## ការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង ស្ថាប័នសម្រាប់ពិភពឌីជីថល

សេដ្ឋកិច្ចឌីជីថលនឹងស្ថិតនៅទីនេះក្នុងរយៈពេលវែង។ ដោយសារតែវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង កំណើនសេដ្ឋកិច្ច បន្តមានការផ្លាស់ប្តូរក្រោមឥទ្ធិពលរបស់ឌីជីថល នីយកម្មតំបន់ ASEM ត្រូវតែទទួលបានអត្ថប្រយោជន៍ពីវឌ្ឍនភាពនេះ។ ASEM ក៏ត្រូវតែឈានមុខគេនៅក្នុងការធានាថា ឌីជីថលនីយកម្មលើកកម្ពស់បរិយាប័ន្នផងដែរ ជាពិសេសចំពោះយុវជន និង ស្ត្រី។ ទ្វីបអាស៊ី និង ទ្វីបអឺរ៉ុបមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលស្ថិតនៅកម្រិតខុសៗគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចសហប្រតិបត្តិការទៅវិញទៅមកដើម្បីការអភិវឌ្ឍផ្នែកសេវាកម្ម មូលធនមនុស្ស បទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យ ពាណិជ្ជកម្មអេឡិចត្រូនិក និង ពន្ធដារតម្រូវឱ្យមានការតភ្ជាប់ផ្នែកស្ថាប័នកាន់តែខ្លាំងក្លារវាងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប។ ASEM មិនអាចបង្កើតវេទិកាមួយដែលលើកឡើងអំពីសសរស្តម្ភដ៏សំខាន់នៃសេដ្ឋកិច្ចឌីជីថលនៅក្នុងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុបបាននោះទេ។ នៅពេលដែលពិភពលោកងើបចេញពីជំងឺកូវីដ-១៩ វិញ វានឹងមានឱកាសអនុវត្តយុទ្ធសាស្ត្រស្តារឡើងវិញឱ្យបានកាន់តែប្រសើរ។ កិច្ចប្រជុំកំពូល ASEM លើកទី១៣ នឹងក្លាយជាឱកាសមួយដើម្បីបំពេញគម្លាតនេះ នៅក្នុងកិច្ចសហប្រតិបត្តិការរបស់ ASEM។

ការកែប្រែរចនាសម្ព័ន្ធ និង ការបង្កើតការងារនៅទ្វីបអាស៊ី និង ទ្វីបអឺរ៉ុបនឹងដោះស្រាយតម្រូវការនៃសេដ្ឋកិច្ចឌីជីថល តាមរយៈការធ្វើសមាហរណកម្ម និង កិច្ចសហប្រតិបត្តិការរវាងស្ថាប័នកាន់តែខ្លាំងក្លា។ ការធ្វើសមាហរណកម្មទៅមុខ និង ថយក្រោយនៃខ្សែសង្វាក់តម្លៃរបស់សេដ្ឋកិច្ចឌីជីថលមានសារសំខាន់ចំពោះ និង រវាងទ្វីបអាស៊ី និង អឺរ៉ុប។ តួនាទីរបស់ ASEM នៅក្នុងការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និង ការផ្លាស់ទីរបស់ប្រជាជនដែលមានជំនាញ ដែលស័ក្តិសមនឹងសេដ្ឋកិច្ចឌីជីថល នឹងទាំងទាន់ពេលវេលា និង មានតម្លៃសម្រាប់ការតភ្ជាប់ផ្នែកស្ថាប័ននៅក្នុងតំបន់ ASEM។ គោលការណ៍ការពារអ្នកប្រើប្រាស់ និង ឯកជនភាព គោលនយោបាយនៃការប្រកួតប្រជែង ប្រព័ន្ធពន្ធដារ និង សន្តិសុខអ៊ីនធឺណិត ក៏ត្រូវការការយកចិត្តទុកដាក់កាន់តែខ្លាំងក្លា និង ការកំណត់មាត្រដ្ឋានជាសកលផងដែរ។

ឯកសារសំខាន់ៗ ដូចជា ផែនការមេ ICT របស់អាស៊ាន ឆ្នាំ២០២០ ជាដើម បានសង្កត់ធ្ងន់លើទិដ្ឋភាពដែលមានបរិយាប័ន្ន និង អាចផ្គត់ផ្គង់បាននៃសេដ្ឋកិច្ចឌីជីថល។ យុទ្ធសាស្ត្រទីផ្សារឌីជីថលតែមួយនៅអឺរ៉ុប គូសបញ្ជាក់អំពីឱកាសផ្នែកឌីជីថលសម្រាប់ប្រជាជន និង អាជីវកម្មតាមរយៈគោលនយោបាយដែលបង្កប់គុណតម្លៃផ្នែកសង្គម និង លើកកម្ពស់បរិយាប័ន្ន។ APGC បានអនុម័តផែនការតភ្ជាប់នៅក្នុងឆ្នាំ២០១៨ ដែលរៀបរាប់អំពីពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែនរួមបញ្ចូលទាំង ការចូលរួមរបស់សហគ្រាសធុនតូចបំផុត សហគ្រាសធុនតូច និង មធ្យម ជាវិស័យអាទិភាពមួយសម្រាប់ដៃគូរបស់ ASEM ផងដែរ។ ភាពស្របគ្នារវាងទ្វីបអាស៊ី ទ្វីបអឺរ៉ុប និង ASEM នៅក្នុងសេដ្ឋកិច្ចឌីជីថលដែលមានបរិយាប័ន្ន និង ផ្អែកលើគុណតម្លៃ អាចក្លាយជាមុខមាត់នៃការតភ្ជាប់រវាងអាស៊ី-អឺរ៉ុបនៅក្នុងទសវត្សរ៍នេះ។

## ពហុភាគីនិយម សកម្មភាពជាសកល និង ពិភពលោកដែលផ្អែកលើច្បាប់៖ តួនាទីរបស់ ASEM

កិច្ចសហប្រតិបត្តិការអន្តរជាតិនឹងក្លាយជាគន្លឹះសម្រាប់ការធ្វើឲ្យមានភាពរីកចម្រើនឡើងវិញស្តារប្រាក់ចំណូល និង ធ្វើឲ្យការផ្លាស់ទីឆ្លងព្រំដែនមានសភាពធម្មតាឡើងវិញ។ ការស្ដាបនាឡើងវិញ និង ការងើបចេញពីជំងឺរាតត្បាតសកលគួរតែរួមបញ្ចូលឱកាសស្មើៗគ្នាសម្រាប់គ្រប់ប្រទេសទាំងអស់។

អនាគតរបស់ ASEM មានទំនាក់ទំនងនឹងការស្តារឡើងវិញនូវពហុភាគីនិយម និង អភិបាលកិច្ចជាសកលដែលផ្អែកលើច្បាប់ ដែលទទួលស្គាល់ភាពខុសគ្នា ប៉ុន្តែមិនទុកអ្នកណាម្នាក់ចោលនោះទេ។ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថា ពហុភាគីនិយមបានផ្តល់ស្ថេរភាព និង វិបុលភាពដល់ប្រទេសជាច្រើនអស់រយៈពេលជិតមួយសតវត្សរ៍មកហើយ។

វិបត្តិហិរញ្ញវត្ថុពិភពលោកនាពេលថ្មីៗនេះ អាចដោះស្រាយបានតាមរយៈសកម្មភាពពហុភាគី និង កិច្ចសហប្រតិបត្តិការ។ ទោះបីជាយ៉ាងណាក៏ដោយ របៀបរៀបរយពហុភាគីដែលផ្អែកលើច្បាប់គឺស្ថិតនៅក្រោមសម្ពាធយ៉ាងធ្ងន់ធ្ងរ ហើយ ASEM មានទំនួលខុសត្រូវយ៉ាងខ្លាំងចំពោះបញ្ជាក់ឡើងវិញ និង រួមចំណែកដល់ការស្តារពហុភាគីនិយម។ ជំងឺរាតត្បាតសកលបានពង្រីកគម្លាតនៃសកម្មភាពពហុភាគីដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព សកម្មភាពផ្នែកបរិស្ថានស្ថេរភាពហិរញ្ញវត្ថុ និង ពាណិជ្ជកម្មអន្តរជាតិ។ ដូចដែល ASEM បានបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះពហុភាគីនិយមនៅគ្រប់សេចក្តីថ្លែងការណ៍ទាំងអស់របស់ខ្លួន វាគឺជាពេលវេលាដ៏សមស្របនៅក្នុងការគាំទ្រយ៉ាងសកម្មចំពោះក្រុម និង អង្គការអន្តរជាតិ ដែលធ្វើការដើម្បី

ឆ្ពោះទៅសម្រេចគោលដៅនេះ។ ASEM គឺជាអង្គការមិនផ្លូវការមួយរបស់បណ្តាប្រទេសនៅអាស៊ី និង អឺរ៉ុប ដែលមានផលប្រយោជន៍រួម។

វាគឺជាជំហានបន្ទាប់ដ៏សមស្របសម្រាប់ ASEM នៅក្នុងចូលទៅជិតអង្គភាពពហុភាគីដែលត្រូវការការពង្រឹង និង ការគាំទ្រ។ ជាលទ្ធផល ASEM នឹងអាចជួយដល់ដំណើរការពហុភាគីនៅក្នុងការលើកឡើងអំពីការងើបឡើងវិញក្រោយពេលមានជំងឺរាតត្បាតសកល និង បង្កើតសាមគ្គីភាពរវាងអភិបាលកិច្ចពិភពលោក និង របៀបរៀបរយដែលផ្អែកលើច្បាប់ ដែលព្យាយាមផ្តល់ការគាំទ្រដល់សុខមាលភាពរបស់ប្រជាជនគ្រប់រូប។

អភិបាលកិច្ចពិភពលោកលើការតភ្ជាប់ក៏ជាបញ្ហាប្រឈមថ្មីមួយផងដែរ ដោយសារតែប្រទេសនានាតស៊ូ និង ប្រកួតប្រជែងដើម្បីបច្ចេកវិទ្យាដែលផ្តល់ការភ្ជាប់ទំនាក់ទំនងទៅវិញទៅមក។ ការគ្រប់គ្រងអ៊ីនធឺណិតគឺមានភាពច្បាស់លាស់បំផុត ប៉ុន្តែបច្ចេកវិទ្យាដែលគូសបញ្ជាក់អំពីពាណិជ្ជកម្មអេឡិចត្រូនិក និង ប្រព័ន្ធហិរញ្ញវត្ថុមានសារសំខាន់ខ្លាំងជាង។ ជំពូកតាមបែបប្រពៃណីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម ស្តីពីទំនិញ សេវាកម្ម និង ការវិនិយោគ នៅខណៈពេលដែលនៅតែមានភាពចម្រូងចម្រាសនោះ នៅពេលនេះ គឺជាផ្នែកបន្ទាប់បន្សំមួយនៅក្នុងវិស័យបច្ចេកវិទ្យា។ នៅឆ្នាំ២០២១ ASEM ត្រូវតែរួមចំណែកដល់សកម្មភាពពិភពលោក ដែលមានបំណងដោះស្រាយបញ្ហាប្រឈមនេះ។

គេត្រូវតែមើលឃើញថា ASEM បានរួមចំណែកដល់ការបង្កើតអភិបាលកិច្ចពិភពលោក ប្រសិនបើ (ដោយមិនគិតអំពីទំហំ និង ប្រាក់ចំណូលទេនោះ) វាងើបចេញពីការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺរាតត្បាតសកលដោយមានភាពរឹងមាំជាងមុន និង បង្កើតអនាគតដែលល្អជាងមុន និង មានបរិយាប័ន្នខ្លាំងជាងមុន សម្រាប់ខ្លួនពួកគេ។ ពហុភាគីនិយម និង អភិបាលកិច្ចពិភពលោកមិនមែនមានអត្ថិភាពដើម្បីតែខ្លួនឯងនោះទេ។ ការធ្វើតេស្តលើកចុងក្រោយសម្រាប់ចំណុចទាំងពីរនេះ គឺដើម្បីធ្វើឲ្យពួកគេបង្កើតវិបុលភាពដែលមានបរិយាប័ន្ន និង មានចីរភាព។ ASEM ត្រូវតែពន្យល់ និង ធ្វើសកម្មភាព លើទិដ្ឋភាពនៃពហុភាគីនិយមដែលខ្លួនចង់បាន។ អង្គភាពពហុភាគី ដូចជា WTO ជាដើម និង វេទិកាអន្តររដ្ឋាភិបាល និង មិនសូវមានលក្ខណៈផ្លូវការ ដូចជា ក្រុមម្ភៃប្រទេស (G20) កំពុងតែឈានមុខគេនៅក្នុងតំបន់របស់ពួកគេ និង តំបន់នានា ចំពោះការចូលរួមនៅក្នុងវិស័យពាណិជ្ជកម្ម ការវិនិយោគ ស្ថេរភាពហិរញ្ញវត្ថុ ការអភិវឌ្ឍប្រកបដោយចីរភាព និង សមាហរណកម្មផ្នែកសេដ្ឋកិច្ច។ ASEM ត្រូវតំណាងឲ្យខ្លួនឯងនៅក្នុងអង្គការទាំងនេះក្នុងនាមជាអ្នកជះឥទ្ធិពល និង អ្នកកំណត់ទ្រង់ទ្រាយនៃពហុភាគីនិយមដែលផ្អែកលើច្បាប់ដែលមានសមត្ថភាពក្នុងការទទួលស្គាល់ភាពខុសគ្នា និង ការមិនទុកនរណាម្នាក់ចោល។

## ការឆ្ពោះទៅកាន់កិច្ចប្រជុំកំពូល ASEM លើកទី១៤៖ ចក្ខុវិស័យរបស់ប្រទេសកម្ពុជា តថភាពសកល និង អាទិភាពសំខាន់ៗនាពេលខាងមុខ

ចក្ខុវិស័យរបស់ប្រទេសកម្ពុជាចំពោះ ASEM និង សកម្មភាពអាទិភាពនៅក្នុងវិស័យផ្តោតយកចិត្តទុកដាក់នៃការតភ្ជាប់របស់ ASEM មានលក្ខណៈគួរឲ្យកត់សម្គាល់សម្រាប់ការក្តោបលើតម្រូវការក្នុងតំបន់ និង ការពិតនៅលើពិភពលោក។

វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានបំពេញតួនាទីជាប្រធាន ASEM ជាបន្តបន្ទាប់ នៅក្នុងការសរសេររបៀបវារៈស្តីពីការតភ្ជាប់ និង គាំទ្រកិច្ចការរបស់ APGC តាមរយៈអនុសាសន៍អំពីការស្រាវជ្រាវ និង គោលនយោបាយ។ សំណើរបស់ប្រទេសកម្ពុជាចំពោះការសិក្សាក្នុងទ្រង់ទ្រាយធំលើ ASEM ដែលមានបរិយាប័ន្ន មានចីរភាព និង ត្រៀមរួចជាស្រេចសម្រាប់ថ្ងៃអនាគត ត្រូវបានធ្វើឡើងទៅកាន់ ERIA ហើយការសិក្សាអំពីផលប៉ះពាល់បានចូលរួមជាមួយចក្ខុវិស័យរបស់ប្រទេសកម្ពុជា ដោយមានគោលនយោបាយដែលអាចអនុវត្តបានចំពោះអនាគតរបស់ ASEM។ មុនពេលមានវិបត្តិកូវីដ-១៩ ប្រទេសកម្ពុជា ដែលជាប្រធាន ASEM១៣ បានទទួលស្គាល់តាំងពីដំបូងមកថា ASEM កំពុងតែឈានចូលទៅក្នុងដំណាក់កាលមួយដែលត្រូវបានកំណត់ដោយការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និង ការរំខាននៅក្នុងសសរស្តម្ភទាំងបីនៃការតភ្ជាប់ និង កិច្ចសហប្រតិបត្តិការ ASEM។ ទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ប្រឈមទៅនឹងភាពបន្ទាន់នៅក្នុងចំណោមប្រជាជន និង ភាគីពាក់ព័ន្ធរបស់ពួកគេដោយសារតែភាពជឿនលឿនផ្នែកបច្ចេកវិទ្យា នវានុវត្តន៍ ស្វ័យប្រវត្តិកម្ម រ៉ូបូតវិទ្យា វេទិកាឌីជីថល និង ការតភ្ជាប់កាន់តែខ្លាំងក្លាឡើង។ បញ្ហាទាំងនេះកំពុងតែញ៉ាំងឲ្យមានកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលមានបរិយាប័ន្ន ភាពរីកចម្រើនដែលមានចីរភាព និង ការផ្លាស់ទីរបស់ប្រជាជន និង ការវិនិយោគទៅកាន់ទីតាំងថ្មីៗ។ តំបន់នៃកិច្ចសហប្រតិបត្តិការថ្មីៗនៅក្នុងវិស័យហិរញ្ញវត្ថុនវានុវត្តន៍ ហេដ្ឋារចនាសម្ព័ន្ធ សុខភាពពិភពលោក និង អភិបាលកិច្ចពហុភាគី លែងជាជម្រើសទៀតហើយ។ ចំណុចនេះគួរតែស្ថិតនៅក្នុងផែនការលម្អិតនៃការតភ្ជាប់របស់ ASEM នាពេលអនាគត ដើម្បីធ្វើឲ្យ ASEM មានភាពច្បាស់លាស់ចំពោះថ្ងៃអនាគត និង ជួយដល់អាស៊ី និង អឺរ៉ុបនៅក្នុងការដោះស្រាយបញ្ហាប្រឈមនៅលើពិភពលោក និង នៅក្នុងតំបន់រួមគ្នា។

កិច្ចប្រជុំកំពូល ASEM លើកទី១៣ នឹងប្រារព្វធ្វើឡើងក្នុងឆ្នាំ២០២១ ពោលគឺរយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទដែលបានគ្រោងទុក នៅក្នុងឆ្នាំ២០២០ ដោយសារតែជំងឺរាតត្បាតសកលកូវីដ-១៩ បានរំខានដល់រចនាសម្ព័ន្ធនៃការតភ្ជាប់រវាងប្រជាជននៅក្នុង និង រវាងបណ្តាប្រទេស

នានា។ សូម្បីតែប្រទេសដែលបានងើបចេញពីវិបត្តិសុខភាព និង បានកសាងសេដ្ឋកិច្ចឡើងវិញក៏ដោយ ក៏ ASEM មានឱកាសធ្វើការប៉ាន់ប្រមាណ និង ផ្តល់ទិសដៅសម្រាប់ទំនាក់ទំនងអាស៊ី-អឺរ៉ុប នាពេលអនាគតដែរ។ ជំពូកមុនៗនៅក្នុងសៀវភៅនេះបានគ្របដណ្តប់លើការប៉ាន់ប្រមាណតាមវិស័យ និង សកម្មភាពជាអាទិភាពជាច្រើនសម្រាប់ ASEM។

ដើម្បីឆ្ពោះទៅកាន់កិច្ចប្រជុំកំពូល ASEM លើកទី ១៤ បញ្ហាសកល និង បញ្ហាប្រចាំតំបន់ជាច្រើនទំនងជានឹងនៅតែបន្តកើតឡើង និង ទាមទារឲ្យមានការឆ្លើយតបពី ASEM។ ភាពតានតឹងផ្នែកពាណិជ្ជកម្មនៅក្នុងចំណោមប្រទេសសេដ្ឋកិច្ចធំៗនឹងបន្តកើតឡើង ទោះបីជាផ្នែកមួយចំនួនត្រូវបានដោះស្រាយរួចហើយក៏ដោយ។ ភាពតានតឹងផ្នែកនយោបាយ និង សង្គម ដែលទាក់ទងនឹងសហគមន៍ និង យេនឌ័រនៅប្រទេសផ្សេងៗគ្នាក្នុងពិភពលោក នឹងធ្វើឲ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាពិសេស យុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងការងារ SDGs វិធានការអាកាសធាតុ និង សេដ្ឋកិច្ចឌីជីថល មានកង្វល់កាន់តែខ្លាំង។

ការត្រួតពិនិត្យ (និង ការអនុវត្ត) ផែនការសុខភាពសាធារណៈ ការអនុវត្ត SDG ការងារយុវជន និង សមភាពយេនឌ័រ នឹងក្លាយជាផ្នែកសំខាន់ៗសម្រាប់យុទ្ធសាស្ត្រជាតិដើម្បីភាពរីកចម្រើន។

ដោយសារតែផែនការតភ្ជាប់នៅទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ប្រកួតប្រជែងគ្នាដើម្បីធនធាន និង ការជះឥទ្ធិពលផ្នែកភូមិសាស្ត្រ បណ្តាប្រទេសនៅទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ត្រូវតែធ្វើឲ្យផែនការទាំងនេះមានលក្ខណៈស្របគ្នានឹងចីរភាពនៃបំណុលកំណើនដែលមានភាពធន់ និង សមីការនៃទំនុកចិត្ត។ បញ្ហាប្រឈមផ្នែកសន្តិសុខដែលមានភាពរំជើបរំជួលនៅខាងក្រោមគន្លងនៃខ្សែសង្វាក់ផ្គត់ផ្គង់សំខាន់ៗនៅក្នុងតំបន់ប៉ាស៊ីហ្វិក ដែលមានទំនាក់ទំនងដោយផ្ទាល់នឹងការតភ្ជាប់ផ្នែកពាណិជ្ជកម្មរវាងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ត្រូវតែបានលើកឡើង និង បានដោះស្រាយ។

ជំងឺរាតត្បាតសកលផ្តល់ពេលវេលា សម្រាប់ការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យក្រោយពេលមានវិបត្តិ។ ចំពោះ ASEM នេះគឺជាឱកាសមួយដើម្បីបណ្តុះបណ្តាលអំពីការផ្តោតយកចិត្តទុកដាក់លើស្ត្រី និង យុវជន។ ធ្វើបែបនេះ បញ្ហាប្រឈមភ្លោះនៃមូលធនមនុស្ស និង ផលិតភាពអាចត្រូវបានលើកឡើងនៅក្នុងទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ហើយតម្លៃផ្នែកសង្គម និង សេដ្ឋកិច្ចនៃផ្នែកដែលមានឥទ្ធិពលទាំងពីររបស់ប្រជាជន អាចត្រូវបានផ្តល់អាទិភាព នៅគ្រប់គោលនយោបាយទាំងអស់។

រាល់ព្រឹត្តិការណ៍ទាំងអស់ជុំវិញ ASEM មានន័យថា ASEM ត្រូវតែឈានមុខគេ ក្នុងការតភ្ជាប់ប្រទេស និង សង្គមនានាឡើងវិញ នៅក្នុងពិភពលោកក្រោយពេលមានជំងឺរាតត្បាតសកល និង បង្រួបបង្រួមទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ដើម្បីឆ្ពោះទៅកាន់អនាគតដែលមានការតភ្ជាប់មានចីរភាព និង មានបរិយាប័ន្ន។ ជំងឺរាតត្បាតសកលធ្វើការឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ការប៉ុនប៉ងពង្រឹងការពឹងផ្អែកលើខ្លួនឯងឡើងវិញ មិនបានកាត់បន្ថយហានិភ័យយ៉ាងខ្លាំងក្លានោះទេ និង មានតែធ្វើឲ្យសុខមាលភាពចុះទន់ខ្សោយទៅវិញ។ សូម្បីតែនៅក្នុងផ្នែកនានា ដូចជា បរិក្ខារពេទ្យ និង ការផ្គត់ផ្គង់ ជាដើម ក៏មិនអាចជៀសផុតពីការពឹងផ្អែកលើគ្នាទៅវិញទៅមកបានដែរ។ លើសពីនេះទៀត មេរៀននៃជំងឺរាតត្បាតសកលបង្ហាញថា កិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាផ្នែកមួយនៃដំណោះស្រាយច្រើនជាងបញ្ហា។

អត្ថប្រយោជន៍នៃការតភ្ជាប់ផ្នែកសេដ្ឋកិច្ចឡើងវិញ ធ្វើឲ្យការរំខានដល់ការតភ្ជាប់ផ្នែកពាណិជ្ជកម្ម និង ផ្នែកដឹកជញ្ជូនដើរត្រឡប់ក្រោយវិញ និង ការដោះស្រាយបញ្ហាប្រឈមឆ្លងដែនផ្តល់អត្ថប្រយោជន៍ភ្លាមៗ និង អត្ថប្រយោជន៍ដែលប្រជាជនគ្រប់រូបគួរតែទទួលបាន (UNECE ២០២០)។ សកម្មភាពដែលមានការព្រមព្រៀងគ្នានឹងផ្តល់លទ្ធផលកាន់តែល្អ នៅក្នុងបរិបទក្របខណ្ឌនៃកិច្ចសហការប្រចាំតំបន់ ដែលផ្តល់វិស័យសំខាន់ៗសម្រាប់ពហុភាគីនិយម។

ASEM នឹងធ្វើដំណើរពីប្រទេសកម្ពុជា ទៅកាន់ទ្វីបអឺរ៉ុបសម្រាប់កិច្ចប្រជុំកំពូលលើកទី១៤ របស់ខ្លួន។ ប្រធានកិច្ចប្រជុំកំពូលនៅអឺរ៉ុប ត្រូវតែដោះស្រាយវិស័យអាទិភាពទាំងនេះ ដើម្បីធានាថាការងាររបស់ ASEM បានកាត់បន្ថយឧបសគ្គចំពោះការតភ្ជាប់ធ្វើសកម្មភាពដើម្បីបង្កើតឱ្យមាននូវវិបុលភាព និង ពង្រឹងការជឿទុកចិត្តនៅក្នុងសកម្មភាព សមូហភាពនៅគ្រប់កម្រិតទាំងអស់។

# ឯកសារយោង

ASEM (2014), ‘Responsible Partnership for Sustainable Growth and Security’, Chair’s Statement of the 10th Asia–Europe Meeting, Milan, 16–17 October.

ASEM (2016), ‘20 Years of ASEM: Partnership for the Future through Connectivity’, Chair’s Statement of the 11th Asia–Europe Meeting, Ulaanbaatar, 15–16 July.

ASEM (2018), ‘Global Partners for Global Challenges’, Chair’s Statement of the 12th Asia–Europe Meeting, Brussels, 18–19 October.

European Commission (2020), ‘European Economic Forecast: Summer 2020 (Interim)’,

Institutional Paper, No. 132. Luxembourg: European Commission.

Kharas, H, D.J. Snower, and S. Strauss (2020), 'Policy Brief. The Future of Multilateralism: Responsible Globalization That Empowers Citizens and Leaves No One Behind', G20/T20 Task Force 5: The Future of Multilateralism and Global Governance. Riyadh.

McCaffrey, D. (2020), 'Is Europe heading for a K-shaped economic recovery?', Euronews, 8 September. https://www.euronews.com/2020/09/08/is-europe-heading-for-a-k-shaped-economic-recovery- (accessed 5 October 2020).

OECD (2020a), 'COVID-19 in Emerging Asia: Regional Socio-Economic Implications and Policy Priorities', Presentation, 27 April. Paris: Organisation for Economic Co-operation and Development.

OECD (2020b), Economic Outlook for Southeast Asia, China and India 2020 – Update: Meeting the Challenges of COVID-19. Paris: Organisation for Economic Co-operation and Development.

SDSN and IEEP (2019), 2019 Europe Sustainable Development Report. Paris and Brussels: Sustainable Development Solutions Network and Institute for European Environmental Policy.

UN DESA (2020), 'Impact of COVID-19 on SDG Progress: A Statistical Perspective',

Policy Brief, No. 81. New York: United Nations Department of Economic and Social Affairs.

UNECE (2020), 'Responding to the Socio-economic Impacts of COVID 19 Pandemic in the UNECE Region'. Geneva: United Nations Economic Commission for Europe.

UNESCAP (2019), Asia and the Pacific SDG Progress Report 2019. Bangkok: United Nations Economic and Social Commission for Asia and the Pacific.

World Bank (2020), The World Bank Annual Report 2020: Supporting Countries in Unprecedented Times. Washington, DC: World Bank.

WTO (2020), 'Trade Shows Signs of Rebound from COVID-19, Recovery Still Uncertain,' Press/862 Press Release, 6 October. Geneva: World Trade Organisation.

# កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី១៣

***កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីអនាគតដែលមានភាពធន់ មានចីរភាព និង ផ្អែកលើច្បាប់ សម្រាប់ ASEM***

កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) គឺជាគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការដ៏ពិសេស ដែលនាំមកនូវវិសាលភាពសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងប្រទេសរវាងបណ្តាប្រទេសជាដៃគូ តាមរយៈសកម្មភាពប្រចាំតំបន់ និង អនុតំបន់។ ASEM មានភាពទូលំទូលាយគ្រប់គ្រាន់នៅក្នុងការគ្របដណ្តប់លើអាទិភាពនៃការអភិវឌ្ឍនៅលើពិភពលោក និង អន្តរទ្វីប។ យ៉ាងណាមិញ វាបានធ្វើមូលដ្ឋាននីយកម្មចំពោះការតភ្ជាប់រវាងបណ្តាប្រទេសដៃគូ ចំពោះភាពជាដៃគូដើម្បីកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ការវិនិយោគ សេដ្ឋកិច្ចឌីជីថល ភាពរីកចម្រើនដែលមានបរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាព។

ដោយសារតែស្រមោលនៃជំងឺរាតត្បាតសកល បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាទាំងនៅទ្វីបអឺរ៉ុប និង ទ្វីបអាស៊ីនោះ ការរៀបចំកិច្ចប្រជុំកំពូល ASEM លើកទី១៣ (ASEM១៣) នៅប្រទេសកម្ពុជា មានសារសំខាន់កាន់តែខ្លាំង ពីព្រោះវាគ្របបណ្តប់លើមាគ៌ានៃភាពរីកចម្រើនដែលមានបរិយាប័ន្ន និង មានវិបុលភាពសម្រាប់តំបន់អាស៊ី-អឺរ៉ុប តាមរយៈកិច្ចសហប្រតិបត្តិការពហុភាគី និង ការអភិវឌ្ឍប្រកបដោយចីរភាព។

ការសិក្សានេះរួមបញ្ចូលគ្នានូវអ្នកប្រាជ្ញ និង អ្នកអនុវត្តការងារមកពីទ្វីបអាស៊ី និង ទ្វីបអឺរ៉ុប ដែលប្រើប្រាស់សុភវិនិច្ឆ័យនៃការសិក្សា និង ការអនុវត្តជាក់ស្តែងរបស់ពួកគេ នៅក្នុងជំពូកផ្សេងៗគ្នារបស់ពួកគេ ដែលគ្របដណ្តប់លើលក្ខណៈពហុវិស័យនៃកិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់រវាងទ្វីបអាស៊ី-អឺរ៉ុប។

ភាពជាដៃគូដើម្បីកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ការវិនិយោគ សេដ្ឋកិច្ចឌីជីថល ហេដ្ឋារចនា សម្ព័ន្ធគុណភាព ការអភិវឌ្ឍជំនាញ ការអប់រំ ស្ត្រី និង យុវជន ការប្រមូលផ្តុំពលកម្ម ការអភិវឌ្ឍប្រកបដោយចីរភាព ពហុភាគីនិយម និង អភិបាលកិច្ចពិភពលោក គឺជាប្រធានបទសំខាន់ៗមួយចំនួនដែលត្រូវបានគ្របដណ្តប់នៅក្នុងការសិក្សានេះ។ ការសិក្សានេះរួមបញ្ចូលបទពិសោធន៍ដ៏សម្បូរបែបនៅក្នុងចំណោមប្រទេសដៃគូ ដែលមានផលិតភាព និង អាចអនុវត្តឡើងវិញបាន។ វាសង្ខេបអំពីតួនាទី និង ចក្ខុវិស័យដ៏ពិសេសរបស់ប្រទេសកម្ពុជា ក្នុងនាមជាប្រទេសម្ចាស់ផ្ទះនៃ ASEM លើកទី១៣ និង ចាំបាច់ត្រូវនាំយកចក្ខុវិស័យទាំងនេះទៅកាន់កិច្ចប្រជុំកំពូល ASEM លើកទី១៤ នៅអឺរ៉ុប។ សៀវភៅនេះបំពេញគោលបំណងនេះ និង បង្កើតមាគ៌ាមួយដើម្បីធ្វើឲ្យ ASEM ក្លាយជាវេទិកាពហុភាគីដែលមានភាពសកម្ម មានប្រសិទ្ធភាព និង មានឥទ្ធិពល សម្រាប់កិច្ចសហប្រតិបត្តិការ និង ការតភ្ជាប់រវាងអាស៊ី និង អឺរ៉ុប។

## អំពី ERIA

វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) លើកទីបី នៅប្រទេសសិង្ហបុរី នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧។ វាគឺជាអង្គការអន្តរជាតិមួយដែលផ្តល់ការស្រាវជ្រាវ និង ការគាំទ្រផ្នែកគោលនយោបាយដល់តំបន់អាស៊ីបូព៌ា និង អាស៊ាន និង ដំណើរការនៃកិច្ចប្រជុំកំពូល EAS។ ការស្រាវជ្រាវរបស់ ERIA ជួយសម្រួលដល់ការតភ្ជាប់នៅក្នុងទ្វីបអាស៊ី និង រវាងទ្វីបអាស៊ី-អឺរ៉ុប ទ្វីបអាស៊ី-អាហ្វ្រិក និង តំបន់ដទៃទៀតក្នុងពិភពលោក។ ប្រទេសសមាជិកចំនួន ១៦ ប្រទេសនៃ EAS រួមមាន ប្រ៊ុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ វៀតណាម អូស្ត្រាលី ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ និង នូវែលហ្សេឡង់ គឺជាសមាជិករបស់ ERIA។

Anita Prakash គឺជាទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ (IEC) នៃការិយាល័យប្រធាន ERIA។ អ្នកអាចទាក់ទងគាត់បានតាមរយៈ anita.prakash@eria.org។


**វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច**
**សម្រាប់អាស៊ាន និងអាស៊ីបូព៌ា**

**ទីស្នាក់ការកណ្តាល៖**
ជាន់ទ្បៅតឿ
លេខាធិកាដ្ឋានអេសាន៖
70A, Jalan Sisingamangaraja
ឆាកាតាខាងត្បូង ១២១១០ ប្រទេសឥណ្ឌូនេស៊ី

គេហទំព័រ www.eria.org

**អាសយដ្ឋានសម្រាប់ផ្ញើសំបុត្រ៖**
Sentral Senayan II, ជាន់ទី ៥ និងទី៦
Jalan Asia Afrika លេខ ៨
Gelora Bung Karno, Senayan
Jakarta Pusat 10270, ប្រទេសឥណ្ឌូនេស៊ី

ISBN 978-602-5460-36-4
9 786025 460364